# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៦៩

បាលីប្រែ ៨២

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

# សម្មោហវិនោទនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# វិភង្គ

# តតិយភាគ

# ៦៩

## បាលីប្រែ ~ ៨២

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៦៩

# វិភង្គ តតិយភាគ

## សិក្ខាបទវិភង្គ

[ ១ ] សិក្ខាបទ ៥ គឺសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ១ ។

[ ២ ] បណ្តាសិក្ខាបទទាំង ៥ នេះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាញ៉ាំងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណកើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញនូវពៀរ ចាកបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលាការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺ ចេតនាជាហេតុវៀរចាកកិរិយាញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាសម្បយុត្តដោយចេតនាជាហេតុវៀរ ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាញ៉ាំងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើ

ដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្តីគិតណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណកើតឡើង ក្នុងសម័យនោះ ការពាល់ត្រូវ ។បេ។ ការផ្គងឡើង ការមិនរាយមាយ របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខា-បទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការវៀរ ការ

ចៀសវាង ការវៀរស្រឡះ ការបណ្ដេញនូវពៀរ ចាកបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិតឲ្យធ្លាក់កន្លង តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរ-កុសល ប្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្ដីគិតណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើងក្នុងសម័យនោះ ការប៉ះពាល់ ។បេ។ ការផ្គងឡើង ការមិនរាយមាយ របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ។

[ ៣ ] បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ

ចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ តើដូចម្តេច ។បេ។ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។បេ។ សិក្ខា-បទ គឺចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យកុហក ។បេ។ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណកើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញនូវពៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ បានដល់ ការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ជាហេតុវៀរ ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្តីគិតណា របស់បុគ្គលដែលវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាក

ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ កើតឡើងក្នុងសម័យនោះ ការប៉ះពាល់ ។បេ។ ការផ្គងឡើង ការមិនរាយមាយ របស់បុគ្គលដែលវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ កើតឡើង ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញនូវពៀរ ចាក

ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ បាន ដល់ ការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលាការ សម្លាប់ហេតុណា របស់បុគ្គលដែលវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជា ហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុ វៀរ ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ តើ ដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្ដីគិតណា របស់បុគ្គលដែលវៀរចាកហេតុជាទីតាំងនៃសេចក្ដី ប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ នេះហៅថា សិក្ខាបទ គឺ ចេតនា ជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយ ចេតនា ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការប៉ះ ពាល់ ។បេ។ ការផ្គងឡើង ការមិនរាយមាយ របស់បុគ្គលដែលវៀរចាក

ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

[ ៤ ] សិក្ខាបទ ៥ គឺសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ១ ។

[ ៥ ] បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ជាចិត្តថោកទាប កណ្ដាល ឧត្តម ជាចិត្តមានឆន្ទៈជាអធិបតី មានវិរិយៈជាអធិបតី មានចិត្តជាអធិបតី មានវីមំសាជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានវិរិយៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានចិត្តជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានវីមំសាជាអធិបតី តែថោកទាប កណ្ដាល ឧត្តម កើតឡើងក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្ដេញនូវពៀរ ចាកបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការ

មិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ជាចិត្តថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានឆន្ទៈជាអធិបតី មានវីរិយៈជាអធិបតី មានចិត្តជាអធិបតី មានវីមំសាជាអធិបតី មានចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានវីរិយៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានចិត្តជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានវីមំសាជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្ដីគិតណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាំងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ជាចិត្តថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានឆន្ទៈជាអធិបតី មានវីរិយៈជាអធិបតី មានចិត្តជាអធិបតី មាន

វីមំសាជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានវិរិយៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានចិត្តជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានវីមំសាជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ។បេ។ ការផ្គងឡើង ការមិនរាយមាយ របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ ជាចិត្តថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានឆន្ទៈជាអធិបតី មានវិរិយៈជាអធិបតី មានចិត្តជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានវិរិយៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានចិត្តជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ

ការបណ្ដេញនូវពៀរ ចាកបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។បេ។ ការប៉ះពាល់ ។បេ។ ការផ្គងឡើង ការមិនរាយមាយ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញុំាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ។

[ ៦ ] បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ តើដូចម្ដេច ។បេ។ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ។បេ។ សិក្ខា-បទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។បេ។ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ជាចិត្តថោកទាប កណ្ដាល ឧត្តម ជាចិត្តមានឆន្ទៈជាអធិបតី មានវីរិយៈជាអធិបតី មានចិត្តជាអធិបតី មានវីមំសាជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានវីរិយៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានចិត្តជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានវីមំសាជាអធិបតី តែ

ជោកទាប កណ្ដាល ឧត្តមកើតឡើងក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្ដេញនូវពៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ បានដល់ ការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គល ដែលវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃ សេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។បេ។ ធម៌ទាំងឡាយដ៏ សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។បេ។ ការប៉ះពាល់ ។បេ។ ការផ្គងឡើង ការមិនរាយមាយ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុ វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ ។ បណ្ដាសិក្ខាទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុ ជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ តើដូច ម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកប ដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាស

ចាកញាណ ប្រកបដោយសង្ខារ ជាចិត្តថោកទាប កណ្តាល ឧត្តម ជាចិត្តមានឆន្ទៈជាអធិបតី មានវិរិយៈជាអធិបតី មានចិត្តជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានវិរិយៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានចិត្តជាអធិបតី តែថោកទាប កណ្តាល ឧត្តម កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញនូវពៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ បានដល់ ការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ជាហេតុវៀរ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។បេ។ ការប៉ះពាល់ ។បេ។ ការផ្គងឡើង ការមិនរាយមាយ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

[ ៧ ] ធម៌ទាំងឡាយ ដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ក៏កើតមាន ។បេ។

ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា សិក្ខា ។ ធម៌ទាំងឡាយ ដូចម្ដេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា ចិត្តជាកាមាវចរ-កុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ក៏កើតមាន ។បេ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា សិក្ខា ។ ធម៌ទាំងឡាយ ដូចម្ដេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ។បេ។ ចម្រើនមគ្គ ដើម្បីកើតក្នុងអរូបភព ។បេ។ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ មិនដល់នូវការសន្សំ ( កិលេសវដ្ដៈ ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិដ៏លំបាក មានការត្រាស់ដឹងដ៏យឺតយូរ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ក៏កើតមាន ។បេ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា សិក្ខា ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## សិក្ខាបទវិភង្គ

## អធិប្បាយ អភិធម្មភាជនីយ

[ ១-៧ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទវិភង្គ ដែលជាលំដាប់បន្ទាប់អំពីអប្បមញ្ញាវិភង្គនោះដូចតទៅ

បទថា **បញ្ច** ជាពាក្យកំណត់ចំនួន ។ បទថា **សិក្ខាបទានិ** បានដល់បទដែលកុលបុត្តគប្បីសិក្សា អធិប្បាយថា ចំណែកមួយនៃសិក្ខាបទ ។ម្យ៉ាងទៀត កុសលធម៌ទាំងអស់ ដែលមកហើយខាងមុខ ឈ្មោះថា **សិក្ខា** ព្រោះជាធម៌ដែលកុលបុត្តគប្បីសិក្សា ។ បណ្ដាអង្គនៃសីល ៥ អង្គណាមួយ ឈ្មោះថា **បទ** ព្រោះអត្ថថា ជាទីអាស្រ័យរបស់សិក្ខាទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **សិក្ខាបទ** ព្រោះជាទីអាស្រ័យនៃសិក្ខា ។

បទថា **បាណាតិបាតា** បានដល់ ចាកការញុំាងជីវិតសត្វឲ្យធ្លាក់ចុះ គឺការសម្លាប់ ការឲ្យស្លាប់ ។ បទថា **វេរមណី** បានដល់ ការវៀរ ។ បទថា **អទិន្នាទានា** បានដល់ ចាកការកាន់យកវត្ថុដែលបុគ្គលដទៃមិនបានឲ្យ អធិប្បាយថា បានដល់ ការនាំទៅនូវទ្រព្យ ដែលបុគ្គលដទៃហួងហែង ។ បទថា **កាមេសុ** បានដល់ ក្នុងវត្ថុកាមទាំងឡាយ ។ បទថា **មិច្ឆាចារា** បានដល់ ចាកការប្រព្រឹត្តលាមក ដោយអំណាចកិលេសកាម ។ បទថា **មុសាវាទា** បានដល់ ចាកវាទៈដែលមិនពិត ។

បទថា **សុរា** ក្នុងបទថា **សុរាមេរយមជ្ជប្បមាទដ្ឋានា** នេះ សុរា មាន

៥ យ៉ាង គឺ **បិដ្ឋសុរា** សុរាធ្វើដោយម្សៅ ១ **បូវសុរា** សុរាធ្វើដោយនំ ១ **ឱទនសុរា** សុរាធ្វើដោយបាយ ១ **កិណ្ណបក្ខិត្តា** សុរាដែលគេដាក់ពូជសុរា ១ **សម្ភារសំយុត្តា** សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ១ ។

បទថា **មេរយ** បានដល់ គ្រឿងត្រាំ ៥ យ៉ាង គឺ **បុប្ផាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្កាឈើ ១ **ផលាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ ១ **គុឡាសវោ** ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ ១ **មធ្វាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្លែចន្ទន៍ ឬគេធ្វើដោយទឹកឃ្មុំ(១) ១ **សម្ភារសំយុត្តោ** ទឹកត្រាំដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ១ ។ សុរា និងមេរ័យទាំង ២ នោះ ឈ្មោះថា **មជ្ជ** គឺទឹកស្រវឹង ព្រោះអត្ថថា ជាទីតាំងនៃការស្រវឹង ។ ជនទាំងឡាយ រមែងផឹកសុរា ឬមេរ័យនោះ ដោយចេតនាណា ចេតនានោះឈ្មោះថា ជាទីតាំងនៃសេចក្តីប្រមាទ ព្រោះជាហេតុឲ្យវង្វេង បានដល់ ចាកទីតាំងនៃសេចក្តីប្រមាទ ព្រោះទឹកស្រវឹង គឺសុរា និងមេរ័យនោះ ។ នេះជាពាក្យអធិប្បាយនៃពាក្យជាប្រធានក្នុងសិក្ខាបទវិភង្គនេះ ។

ក្នុងការចែកបទពាក្យទាំងពួង មានពាក្យថា **យស្មឹ សមយេ កាមាវចរំ** ជាដើម មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចគ្នានឹងពាក្យដែលពោលមកខាងដើមនោះឯង ។ម្យ៉ាងទៀត ព្រោះការវៀរតែម្យ៉ាងប៉ុណ្ណោះ ជា

---

១- ពាក្យថា មធ្វាសវ មកពីពាក្យថា មធុ និងអាសវៈ ពាក្យថា មធុនេះ ប្រែថា ទឹកឃ្មុំក៏បាន ផ្លែស្រគំក៏បាន តែក្នុងទីនេះ យើងប្រែតាមបិដកខ្មែរ ឯលំដាប់លេខរៀងបិដកខ្មែរលំដាប់ទី ៤ នៅត្រង់លំដាប់ទី ៣ ។

សិក្ខាបទក៏មិនមែន សូម្បីចេតនា ក៏ឈ្មោះថា ជាសិក្ខាបទដូចគ្នា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគសម្តែងន័យទី ២ ដើម្បីសម្តែងដល់ចេតនាដែលជាសិក្ខាបទនោះ ។ ធម៌ទាំង ២ គឺវិរតិ និងចេតនាទាំងនោះ ជាសិក្ខាបទប៉ុណ្ណោះក៏មិនមែន សូម្បីធម៌ជាង ៥០ ដែលសម្បយុត្តដោយចេតនា ក៏ជាសិក្ខាបទផងដែរ ព្រោះជាចំណែកនៃធម៌ដែលកុលបុត្តគប្បីសិក្សា ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងន័យទី ៣ តទៅ ។

ក្នុងទីនេះ សិក្ខាបទ មាន ២ យ៉ាង គឺបរិយាយសិក្ខាបទ និងនិប្បរិយាយសិក្ខាបទ ។ ក្នុង ២ យ៉ាងនោះ វិរតិ ជាសិក្ខាបទដោយត្រង់ ពិតហើយ វិរតិនោះ មកក្នុងព្រះបាលីថា **បាណាតិបាតា វេរមណី** ដូច្នេះ មិនមែនចេតនា ។ ព្រោះថា បុគ្គលកាលវៀរ រមែងវៀរចាកបាណាតិបាតនោះៗ ដោយវិរតិនោះឯង មិនមែនដោយចេតនា តែលោកក៏នាំចេតនាមកសម្តែង ។ ដោយទំនងដូចគ្នានោះ ព្រះមានព្រះភាគ ទ្រង់នាំសម្បយុត្តធម៌របស់ចេតនាដ៏សេសមកសម្តែងទៀត ។ ពិតហើយ ក្នុងការឈានកន្លងចេតនាដែលជាបាប ឈ្មោះថា ភាពជាអ្នកទ្រុស្តសីល ។ ហេតុនោះ ក្នុងពេលនៃវិរតិ ទើបព្រះមានព្រះភាគត្រាស់ថា ចេតនានោះ ដោយអំណាចនៃភាពជាអ្នកមានសីលល្អ ។ ធម៌ទាំងឡាយជាង ៥០ មានផស្សៈជាដើម ព្រះមានព្រះភាគ ក៏ទ្រង់កាន់យកហើយ ព្រោះជាធម៌ដែលសម្បយុត្តដោយចេតនានោះ ។

ឥឡូវនេះ ដើម្បីបន្ថែមការដឹងក្នុងសិក្ខាបទទាំងឡាយនេះ បណ្ឌិតគប្បី

ជ្រាបវិនិច្ឆ័យបាណាតិបាតជាដើមនេះ **ដោយធម៌ ដោយកោដ្ឋាស ដោយអារម្មណ៍ ដោយវេទនា ដោយមូល ដោយកម្ម ដោយសាវជ្ជៈ** និងដោយ**បយោគៈ** ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **ដោយធម៌** ធម៌ទាំង ៥ មានបាណាតិបាតជាដើម ជាចេតនាធម៌នោះឯង ។

**ដោយកោដ្ឋាស** ធម៌ទាំង ៥ ជាកម្មបថនោះឯង ។

**ដោយអារម្មណ៍** បាណាតិបាត មានជីវិតិន្ទ្រិយជាអារម្មណ៍ អទិន្នាទាន មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ មិច្ឆាចារ មានស្ត្រី និងបុរសជាអារម្មណ៍ មុសាវាទ មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ការផឹកសុរា មានសង្ខារជាអារម្មណ៍ ។

**ដោយវេទនា** បាណាតិបាត ជាទុក្ខវេទនា អទិន្នាទាន ជាវេទនា ៣ ពិតហើយ អទិន្នាទាននោះ ជាសុខវេទនា ដល់អ្នកត្រេកអរក្នុងការកាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យ ជាទុក្ខវេទនា ព្រោះបុគ្គលដែលកាន់យកទ្រព្យនោះមានការភ័យខ្លាច ជាអទុក្ខមសុខវេទនា ដល់បុគ្គលដែលព្រងើយកាន់យក មិច្ឆាចារ ជាសុខវេទនា ឬជាអទុក្ខមសុខវេទនា មុសាវាទ ជាវេទនា ៣ ដូចអទិន្នាទាន ការផឹកសុរា ជាសុខវេទនា និងឧបេក្ខាវេទនា ។

**ដោយមូល** បាណាតិបាត មានទោសៈ និងមោហៈជាមូល អទិន្នាទាន ជួនកាល មានលោភៈ និងមោហៈជាមូល ជួនកាល មានទោសៈ និងមោហៈជាមូល មិច្ឆាចារ មានលោភៈ និងមោហៈជាមូល មុសាវាទ ជួនកាល មាន

លោភៈ និងមោហៈជាមូល ជួនកាល មានទោសៈ និងមោហៈជាមូល ។ ការផឹកសុរា មានលោភៈ និងមោហៈជាមូល ។

**ដោយកម្ម** ក្នុងធម៌ទាំងនេះ មុសាវាទ ជាវចីកម្ម ធម៌ដ៏សេស ជាកាយកម្មទាំងអស់ ។

**ដោយសាវជ្ជៈ** បាណាតិបាត មានទោសតិចក៏មាន មានទោសច្រើនក៏មាន អទិន្នាទានជាដើម ក៏ដូចគ្នា ។ ហេតុផ្សេងៗ នៃសិក្ខាបទទាំង ៥ នោះ លោកសម្តែងហើយខាងដើមនោះឯង ។

ន័យដទៃទៀត មានដូចតទៅ

ការសម្លាប់ស្រមោចខ្មៅ ស្រមោចក្រហម មានទោសតិច សម្លាប់សត្វដែលធំជាងនោះ មានទោសច្រើន ។ ការសម្លាប់សត្វដែលធំជាងស្រមោចខ្មៅ ស្រមោចក្រហម មានទោសតិច ការសម្លាប់បក្សីដែលធំជាងនោះ មានទោសច្រើន ។ ការសម្លាប់ទន្សងដែលធំជាង មានទោសច្រើនជាង ។ ការសម្លាប់ទន្សាយដែលធំជាង មានទោសច្រើនជាងនោះ ។ ការសម្លាប់ម្រឹគដែលធំជាង មានទោសច្រើនជាងនោះ ។ ការសម្លាប់គោដែលធំជាង មានទោសច្រើនជាងនោះ ។ ការសម្លាប់សេះដែលធំជាង មានទោសច្រើនជាងនោះ ។ ការសម្លាប់ដំរីដែលធំជាង មានទោសច្រើនជាងនោះ ។ ការសម្លាប់មនុស្សទ្រុស្តសីល មានទោសច្រើនជាងនោះ ។ ការសម្លាប់មនុស្សមានវត្តប្រព្រឹត្តដូចគោ មានទោសច្រើនជាងនោះ ។ ការសម្លាប់មនុស្ស អ្នកដល់សរណៈ មានទោសច្រើនជាងនោះ ។ ការសម្លាប់បុគ្គលដែលតាំងនៅក្នុង

សិក្ខាបទ ៥ មានទោសច្រើនជាងនោះ ។ ការសម្លាប់សាមណេរ មានទោសច្រើនជាងនោះ ។ ការសម្លាប់ភិក្ខុជាបុថុជ្ជន មានទោសច្រើនជាងនោះ ។ ការសម្លាប់ព្រះសោតាបន្ន មានទោសច្រើនជាងនោះ ។ ការសម្លាប់ព្រះសកទាគាមី មានទោសច្រើនជាងនោះ ។ ការសម្លាប់ព្រះអនាគាមី មានទោសច្រើនជាងនោះ ។ ការសម្លាប់ព្រះខីណាស្រព មានទោសច្រើនក្រៃលែង ។

ការកាន់យកទ្រព្យរបស់បុគ្គលទ្រុស្តសីល មានទោសតិច ។ ការកាន់យកទ្រព្យរបស់អ្នកមានវត្តប្រព្រឹត្តដូចគោ មានទោសច្រើនជាងនោះ ។ ការកាន់យកទ្រព្យរបស់អ្នកដល់សរណៈ មានទោសច្រើនជាងនោះ ។ ការកាន់យកទ្រព្យរបស់បុគ្គលដែលតាំងនៅក្នុងសីល ៥ មានទោសច្រើនជាងនោះ ។ ការកាន់យកទ្រព្យរបស់សាមណេរ មានទោសច្រើនជាងនោះ ។ ការកាន់យកទ្រព្យរបស់ភិក្ខុបុថុជ្ជន មានទោសច្រើនជាងនោះ ។ ការកាន់យកទ្រព្យរបស់ព្រះសោតាបន្ន មានទោសច្រើនជាងនោះ ។ ការកាន់យកទ្រព្យរបស់ព្រះសកទាគាមី មានទោសច្រើនជាងនោះ ។ ការកាន់យកទ្រព្យរបស់ព្រះអនាគាមី មានទោសច្រើនជាងនោះ ។ ការកាន់យកទ្រព្យរបស់ព្រះខីណាស្រព មានទោសច្រើនក្រៃលែង ។

ការប្រព្រឹត្តខុសកន្លងក្នុងស្រីទ្រុស្តសីល មានទោសតិច ។ ការប្រព្រឹត្តខុសកន្លងក្នុងស្រីដែលមានវត្តប្រព្រឹត្តដូចគោ មានទោសច្រើនជាងនោះ ។ ការប្រព្រឹត្តខុសក្នុងស្រី ដែលដល់សរណៈ មានទោសច្រើនជាងនោះ ។

ការប្រព្រឹត្តខុសកន្លងក្នុងស្រីដែលតាំងនៅក្នុងសីល ៥ មានទោសច្រើនជាងនោះ ។ ការប្រព្រឹត្តខុសក្នុងសាមណេរី មានទោសច្រើនជាងនោះ ។ ការប្រព្រឹត្តខុសកន្លងក្នុងភិក្ខុនីបុថុជ្ជន មានទោសច្រើនជាងនោះ ។ ការប្រព្រឹត្តខុសកន្លង ក្នុងភិក្ខុនីជាព្រះសោតាបន្ន មានទោសច្រើនជាងនោះ ។ ការប្រព្រឹត្តខុសកន្លង ក្នុងភិក្ខុនីជាសកទាគាមី មានទោសច្រើនជាងនោះ ។ ការប្រព្រឹត្តខុសកន្លង ក្នុងភិក្ខុនីជាអនាគាមី មានទោសច្រើនជាងនោះ ។ ការប្រព្រឹត្តខុសកន្លង ក្នុងភិក្ខុនីជាព្រះខីណាស្រព មានទោសច្រើនក្រៃលែង ។

មុសាវាទមានទោសតិច ព្រោះនិយាយកុហកដើម្បីត្រូវការទ្រព្យ មានប្រមាណ ១ កាកណិក ។ មុសាវាទដើម្បីត្រូវការទ្រព្យ ១ មាសក មានទោសច្រើនជាងនោះ ។ មុសាវាទដើម្បីត្រូវការទ្រព្យ ៥ មាសក មានទោសច្រើនជាងនោះ ។ មុសាវាទដើម្បីត្រូវការទ្រព្យកន្លះកហាបណៈ មានទោសច្រើនជាងនោះ ។ មុសាវាទដើម្បីត្រូវការទ្រព្យ ១ កហាបណៈ មានទោសច្រើនជាងនោះ ។ មុសាវាទដើម្បីត្រូវការទ្រព្យដែលមានតម្លៃរាប់មិនបាន មានទោសច្រើនជាងនោះ ។ មុសាវាទធ្វើសង្ឃឲ្យបែកគ្នា មានទោសច្រើនក្រៃលែង ។

ការផឹកសុរាប្រមាណមួយទូកដៃមានទោសតិច ។ ការផឹកសុរាប្រមាណមួយកម្បង់ មានទោសច្រើនជាង ។ ការផឹកសុរារបស់បុគ្គលដែលផឹកច្រើនរហូតឲ្យកាយទ្រេតទ្រោត ហើយប្លន់ស្រុក និគម មានទោសដោយចំណែកមួយប៉ុណ្ណោះ ។

ពិតហើយ ក្នុងបាណាតិបាត ការសម្លាប់ព្រះខីណាស្រព មានទោសច្រើន ក្នុងអទិន្នាទាន ការលួចយកទ្រព្យរបស់ព្រះខីណាស្រព មានទោសច្រើន ក្នុងកាមេសុមិច្ឆាចារ ការប្រព្រឹត្តកន្លងខុសក្នុងភិក្ខុនីជាព្រះខីណាស្រព មានទោសច្រើន ក្នុងមុសាវាទ ការញ៉ាំងសង្ឃឲ្យបែកគ្នា មានទោសច្រើន ក្នុងការផឹកសុរា ការផឹកច្រើនរហូតឲ្យកាយទ្រេតទ្រោត ហើយប្លន់ស្រុក ប្លន់និគម មានទោសច្រើន តែសង្ឃភេទ ដោយការពោលនូវមុសាវាទប៉ុណ្ណោះឈ្មោះថា មានទោសច្រើនជាងទោសទាំងអស់នោះ ព្រោះថា សង្ឃភេទនោះ ជាទោសធំក្រៃលែង អាចឆេះក្នុងនរកអស់មួយកប្ប ។

**ដោយបយោគ** បាណាតិបាត ជាសាហត្ថិកៈ គឺធ្វើដោយដៃរបស់ខ្លួនឯងក៏មាន ជាអាណត្តិកៈ គឺឲ្យអ្នកដទៃធ្វើក៏មាន ។ អទិន្នាទានក៏យ៉ាងនោះ កាមេសុមិច្ឆាចារ មុសាវាទ និងសុរាបានៈ ជាសាហត្ថិកៈប៉ុណ្ណោះ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យបាណាតិបាតជាដើម ដោយធម៌ជាដើម ក្នុងអធិការនេះយ៉ាងនេះហើយ គប្បីជ្រាបវិនិច្ឆ័យនូវគាថាបាណាតិបាតាវេរមណីជាដើម **ដោយធម៌ ដោយកោដ្ឋាស ដោយអារម្មណ៍ ដោយវេទនា ដោយមូល ដោយកម្ម ដោយខណ្ឌ ដោយសមាទាន** និង**ដោយបយោគ** ដូចតទៅ

ក្នុងពាក្យទាំងនោះ ពាក្យថា **ដោយធម៌** ការវៀរទាំង ៥ ជាចេតនា-កម្មនោះឯងដោយលំដាប់ ដោយអំណាចនៃសីលដោយអម ។

**ដោយកោដ្ឋាស** ការវៀរទាំង ៥ ជាកម្មបថនោះឯង ។

**ដោយអារម្មណ៍** ការវៀរចាកបាណាតិបាត ព្រោះធ្វើជីវិតិន្ទ្រិយរបស់អ្នកដទៃ ឲ្យជាអារម្មណ៍ រមែងវៀរដោយចេតនាដែលជាបាបរបស់ខ្លួន ។ ក្នុងការវៀរដ៏សេសក្រៅអំពីនេះ ក៏ន័យនេះឯង ព្រោះថា ការវៀរទាំងអស់នេះ ធ្វើវត្ថុដែលបុគ្គលគប្បីឈានកន្លងឲ្យជាអារម្មណ៍ហើយ រមែងវៀរចាកចេតនាដែលជាបាបនោះឯង ។

**ដោយវេទនា** ការវៀរទាំងអស់ជាសុខវេទនា ឬជាឧបេក្ខាវេទនា ។

**ដោយមូល** កាលវៀរដោយចិត្តដែលសម្បយុត្តដោយញាណ រមែងជាអលោភមូល អទោសមូល និងអមោហមូល កាលវៀរដោយចិត្តប្រាសចាកញាណ រមែងជាអលោភមូល និងអទោសមូលប៉ុណ្ណោះ ។

**ដោយកម្ម** ក្នុងទីនេះ មុសាវាទាវេរមណី ជាវចីកម្ម ការវៀរដ៏សេសជាកាយកម្ម ។

**ដោយខណ្ឌ** គឺដោយការដាច់ គ្រហស្ថទាំងឡាយ រមែងឈានកន្លងសិក្ខាបទណាមួយ សិក្ខាបទនោះៗ ប៉ុណ្ណោះ រមែងដាច់ រមែងបែកធ្លាយសិក្ខាបទដ៏សេសមិនដាច់ មិនបែកធ្លាយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះគ្រហស្ថទាំងឡាយ មិនមែនជាអ្នកមានសីលប្រចាំ គ្រហស្ថទាំងនោះ អាចរក្សាសិក្ខាបទណាមួយ ក៏រក្សាសិក្ខាបទនោះៗ ឯង តែសិក្ខាបទទាំង

ឡាយរបស់សាមណេរ សូម្បីលោកប្រព្រឹត្តកន្លងត្រឹមតែសិក្ខាបទមួយ ឈ្មោះថា ដាច់ទាំងអស់ ។ សិក្ខាបទទាំងនោះ ដាច់តែម្យ៉ាងក៏មិនមែន សូម្បីសីលដ៏សេសទាំងឡាយ រមែងដាច់ដូចគ្នានោះឯង ។ ការឈានកន្លងសីលទាំងនោះ មានវត្ថុជាទណ្ឌកម្ម កាលសាមណេរនោះ ធ្វើទណ្ឌកម្មដោយពោលថា ខ្ញុំនឹងមិនធ្វើយ៉ាងនេះទៀត សីលរមែងបរិបូណ៌ ។

**ដោយសមាទាន** កាលគ្រហស្ថអធិដ្ឋាននោះឯងថា **បញ្ច សីលានិ អធិដ្ឋហាមិ** ខ្ញុំនឹងអធិដ្ឋានសីល ៥ ដូច្នេះក្តី កាលសមាទានសីលនោះដោយញែកសិក្ខាបទនីមួយៗក្តី រមែងឈ្មោះថា សមាទានហើយ គឺថា គ្រហស្ថនោះ អង្គុយនៅក្នុងសម្នាក់បុគ្គលណា ហើយសមាទានថា **បញ្ច សីលានិ សមាទិយាមិ** ខ្ញុំសូមសមាទានសីល ៥ ក្តី សូមសមាទានសិក្ខាបទនីមួយៗក្តី ឈ្មោះថា រមែងសមាទាននោះឯង ។

**ដោយបយោគ** សិក្ខាបទទាំងពួង បណ្ឌិតគប្បីជ្រាបថា ជាសាហត្ថិកប្បយោគទាំងអស់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ដែលជាសិក្ខា ៥ នេះ ដោយភាពជាកោដ្ឋាសនៃសិក្ខាពួកណា ដើម្បីសម្តែងសិក្ខាទាំងនោះ ទើបទ្រង់ផ្តើមវារៈនៃសិក្ខានេះថា **កតមេ ធម្មា សិក្ខា** ដូច្នេះ ។

*គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ដែលជាសិក្ខានោះដូចតទៅ កុសលធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ឈ្មោះថា* **សិក្ខា** *ព្រោះភាពជាធម៌ដែលបុគ្គលគប្បីសិក្សា ព្រោះហេតុនោះ ដើម្បីសម្តែងកុសលធម៌ទាំងឡាយនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា* **យស្មឹ សមយេ កាមាវចរំ** *ជាដើម ។ ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបអត្ថដោយញ៉ាំងព្រះបាលីឲ្យពិស្តារ ដោយន័យដូចពោលហើយ ក្នុងចិត្តុប្បាទកណ្ឌខាងដើមនោះឯង ឯក្នុងសិក្ខាបទវិភង្គនេះ សម្តែងត្រឹមតែមាតិកាប៉ុណ្ណោះ ៗ*

**អដ្ឋកថាអភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## សិក្ខាបទវិភង្គ

## បញ្ហាបុច្ឆកៈ

[ ៨ ] សិក្ខាបទ ៥ គឺសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ១ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ១ ។ បណ្ដាសិក្ខាបទទាំង ៥ សិក្ខាបទ ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ៩ ] សិក្ខាបទទាំង ៥ ជាកុសលតែម្យ៉ាង ប្រកបដោយវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា មានវិបាកធម៌ជាប្រក្រតី មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក តែជាប្រយោជន៍ដល់ឧបាទាន មិនប្រកបដោយសេចក្ដីសៅហ្មង តែគួរដល់នូវសេចក្ដីសៅហ្មង ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខា តែមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដល់នូវការសន្សំ មិនមែនជារបស់សេក្ខបុគ្គលទាំង

មិនមែនជារបស់អសេក្ខបុគ្គល មានសភាពតូចច្មារ មានអារម្មណ៍តូចច្មារ ជាកណ្តាល មានសភាពមិនទៀង ពោលថា មានមគ្គជាអារម្មណ៍ផង ថាមាន មគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន កើតឡើងហើយក៏មាន មិន ទាន់កើតឡើង តែមិនគួរពោលថា បម្រុងនឹងកើតឡើងក៏មាន ជាអធិបតីក៏ មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាង ក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅ មានអារម្មណ៍ជាខាង ក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ១០ ] ពួកសិក្ខាបទមិនមែនហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកប ដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ ប្រកបដោយហេតុ តែមិនមែនហេតុ មិនមែន ហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកសិក្ខាបទ ប្រព្រឹត្តទៅជាមួយនឹង បច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការ ប៉ះពាល់ មិនមានរូប ជាលោកិយ គួរដឹងច្បាស់ដោយវិញ្ញាណណាមួយ មិនគួរដឹងច្បាស់ដោយវិញ្ញាណណាមួយ ។ ពួកសិក្ខាបទ មិនមែនអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជា អាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹង អាសវៈ តែមិនមែនជាអាសវៈ មិនគួរពោលថាជាអាសវៈ ទាំងប្រកបដោយ អាសវៈផង ថាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ គឺ

ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។ ពួកសិក្ខាបទ មិនមែនសញ្ញោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ច្រឡំ ទាំងតាំងឡើងដោយចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកទេ ។ ពួកសិក្ខាបទ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈមានហេតុ មិនគួរលះដោយភាវនា ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ប្រព្រឹត្តទៅជាមួយនឹងវិចារ ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន កើតព្រមដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន ប្រកបដោយសុខក៏មាន មិនកើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខា ជាកាមាវចរ មិនមែនរូបាវចរ មិនមែនជាអរូបាវចរ ជាបរិយាបន្ន ជាអនិយ្យានិកៈ ជាអនិយតៈ ជាសឧត្តរៈ ជាអរណៈ ។

បញ្ហាបុច្ឆកៈ ចប់

សិក្ខាបទវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ៨-១០ ] ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបថា សិក្ខាបទទាំងឡាយជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ ក្នុងអារម្មណត្តិកៈទាំងឡាយ សិក្ខាបទទាំងឡាយណា ដែលពោលក្នុងទីនេះថា ជាសត្តារម្មណៈ គឺមានសត្វជាអារម្មណ៍ ក៏ព្រោះសិក្ខាបទទាំងនោះ ធ្វើសង្ខារដែលដល់នូវការរាប់ថា ជាសត្វប៉ុណ្ណោះ ឲ្យជាអារម្មណ៍ និងព្រោះសិក្ខាបទទាំងអស់នោះសម្ដែងហើយដោយអំណាចនៃសម្បត្តវិរតិ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ជាបរិត្តារម្មណៈផង ជាបច្ចុប្បន្នារម្មណៈផង ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា សិក្ខាបទទាំងពួង ជាពហិទ្ធារម្មណ៍ ព្រោះបុគ្គលវៀរវត្ថុណា វត្ថុនោះ ជារបស់ខាងក្រៅទាំងអស់ ដូច្នេះ ។

សិក្ខាបទវិភង្គនេះ ក្នុងអភិធម្មភាជនីយក្ដី ក្នុងបញ្ហាបុច្ឆកៈក្ដី ព្រះសម្ពុទ្ធត្រាស់សិក្ខាបទទាំងឡាយថា ជាលោកិយប៉ុណ្ណោះ ព្រោះថា ន័យទាំង ២ នេះ ជាបរិច្ឆេទជាមួយគ្នា ដោយភាពជាលោកិយនោះឯង ។ សិក្ខាបទវិភង្គនេះ ព្រះមានព្រះភាគទ្រង់នាំចេញ គឺចែកសម្ដែងជាបរិវដ្ដៈ ២ ដូចពណ៌នាមក ដូច្នេះឯង ៕

**បញ្ហាបុច្ឆកៈ ចប់**

**អដ្ឋកថាសិក្ខាបទវិភង្គ ចប់**

# អភិធម្មបិដក

## បដិសម្ភិទាវិភង្គ

[ ១១ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងអត្ថ និងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ១២ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការកើតឡើងនៃទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការរលត់ទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថ និងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ១៣ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្តីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងផលនៃហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងធម៌ និងអត្ថនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ១៤ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ធម៌ទាំងឡាយណាកើត ចម្រើន លូតលាស់ ដុះដាល ចម្រុងចម្រើន កើតប្រាកដហើយ សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយនោះ កើត ចម្រើន លូតលាស់ ដុះដាល ចម្រុងចម្រើន កើតប្រាកដហើយ អំពីធម៌ទាំងឡាយណា សេចក្តីដឹងក្នុងធម៌ទាំងឡាយនោះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងអត្ថ និងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ១៥ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងជរានិងមរណៈ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹង ក្នុងការកើតឡើងនៃជរា និងមរណៈ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការរលត់នៃជរា និងមរណៈ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃជរា និងមរណៈ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងអត្ថ និងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ១៦ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងជាតិ ។បេ។ សេចក្តីដឹងក្នុងភព ។បេ។ សេចក្តីដឹងក្នុងឧបាទាន ។បេ។ សេចក្តីដឹងក្នុងតណ្ហា ។បេ។

សេចក្តីដឹងក្នុងវេទនា ។បេ។ សេចក្តីដឹងក្នុងផស្សៈ ។បេ។ សេចក្តីដឹងក្នុងសឡាយតនៈ ។បេ។ សេចក្តីដឹងក្នុងនាមរូប ។បេ។ សេចក្តីដឹងក្នុងវិញ្ញាណ ។បេ។ សេចក្តីដឹងក្នុងសង្ខារទាំងឡាយ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការកើតឡើងនៃសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការរលត់នៃសង្ខារ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងអត្ថ និងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ១៧ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ បណ្តាបដិសម្ភិទាទាំង ៤ នោះ ធម្មប្បដិសម្ភិទា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះដឹងនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ នេះឈ្មោះថា ធម្មប្បដិសម្ភិទា ភិក្ខុនោះ ដឹងនូវសេចក្តីនៃភាសិតនោះៗ ថា នេះសេចក្តីនៃភាសិតនេះ នេះសេចក្តីនៃភាសិតនេះ នេះឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថ និងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

## សុត្តន្តភាជនីយ ចប់

# អដ្ឋកថា
# បដិសម្ភិទាវិភង្គ
# សុត្តន្តភាជនីយ
# សង្គហវារ

[ ១១-១៧ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបដិសម្ភិទាវិភង្គ ក្នុងលំដាប់នៃសិក្ខាបទវិភង្គដូចតទៅ

បទថា **ចតស្សោ** ជាពាក្យកំណត់ចំនួន ។ បទថា **បដិសម្ភិទា** បានដល់ បញ្ញាដែលបែកធ្លាយ ។ ព្រោះដំបូង ព្រះមានព្រះភាគត្រាស់ថា ការបែកធ្លាយក្នុងអត្ថ ឈ្មោះថា **អត្ថេ ញាណំ អត្ថប្បដិសម្ភិទា** ជាដើម ហេតុនោះ បណ្ឌិតគប្បីជ្រាបថា មិនមែនជាការបែកធ្លាយក្នុងវត្ថុណាឡើយ ក្រៅអំពីការបែកធ្លាយរបស់ញាណប៉ុណ្ណោះ ព្រោះហេតុនោះ ដោយពាក្យថា បដិសម្ភិទា ៤ ទើបខ្ញុំសង្គ្រោះអត្ថនេះថា ការបែកធ្លាយនៃញាណមាន ៤ ប្រការ ។

បដិសម្ភិទាក្នុងអត្ថ ឈ្មោះថា **អត្ថប្បដិសម្ភិទា** អធិប្បាយថា ញាណដែលដល់នូវការបែកធ្លាយក្នុងអត្ថដែលអាចធ្វើវិគ្គហៈ អត្ថប្រភេទផ្សេងៗ ឲ្យជាក់ច្បាស់ដោយការពិចារណា ។ ក្នុងបទដ៏សេសក៏ន័យនេះ ។ ពិតហើយ ញាណដែលដល់នូវការបែកធ្លាយក្នុងធម៌ ដែលអាចធ្វើវិគ្គហៈ ក្នុងធម្មជាតផ្សេងៗ ឲ្យជាក់ច្បាស់ ដោយការពិចារណា ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ ញាណដែលដល់នូវការបែកធ្លាយ ក្នុងការពោលនូវនិរុត្តិធម៌ ដែលអាចធ្វើ

វិគ្គហៈក្នុងនិរុត្តិ គឺភាសាផ្សេងៗ ឲ្យជាក់ច្បាស់ដោយការពិចារណា ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។ ញាណដែលដល់នូវការបែកធ្លាយក្នុងបដិភាណ គឺឈ្លាសក្នុងការសួរឆ្លើយបានរហ័ស ដែលអាចធ្វើវិគ្គហៈក្នុងបដិភាណប្រភេទផ្សេងៗ ឲ្យជាក់ច្បាស់ ដោយការពិចារណា ឈ្មោះថា **បដិភាណប្បដិ-សម្ភិទា** ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងចែកបដិសម្ភិទាទាំងឡាយ តាមដែលទ្រង់តាំងទុក ទើបត្រាស់ពាក្យថា ការបែកធ្លាយក្នុងអត្ថ ឈ្មោះថា **អត្ថេ ញាណំ អត្ថប្បដិសម្ភិទា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អត្ថោ** បើពោលដោយសង្ខេប បានដល់ផលរបស់ហេតុ ។ ពិតហើយ ផលរបស់ហេតុនោះ គប្បីចូលទៅរក គប្បីដល់ គប្បីសម្រេចបានដោយអំណាចនៃហេតុ ព្រោះហេតុនោះ ទើបហៅថា **អត្ថ** ។ កាលពោលដោយប្រភេទហើយ បណ្ឌិតគប្បីជ្រាបថា **អត្ថ** បានដល់ ធម៌ទាំង ៥ នេះ គឺសភាវៈណាមួយដែលអាស្រ័យគ្នាកើតឡើងព្រោះបច្ច័យ ១ ព្រះនិព្វាន ១ អត្ថនៃភាសិត ១ វិបាក ១ កិរិយា ១ ។

កាលពិចារណាអត្ថនោះ ញាណដែលដល់នូវការបែកធ្លាយក្នុងអត្ថនោះ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។

បទថា **ធម្មោ** កាលពោលដោយសង្ខេប បានដល់ បច្ច័យ ។ ពិតហើយ ព្រោះបច្ច័យនោះ រមែងជាក់ច្បាស់ រមែងឲ្យធម៌នោះប្រព្រឹត្តទៅផងឲ្យដល់ផង ព្រោះហេតុនោះ ទើបហៅថា **ធម្ម** តែកាលពោលដោយប្រភេទ

បណ្ឌិតគប្បីជ្រាបថា **ធម្ម** បានដល់ ធម៌ទាំង ៥ នេះ គឺហេតុណាមួយដែលញ៉ាំងផលឲ្យកើតឡើង ១ អរិយមគ្គ ១ ភាសិត ១ កុសល ១ អកុសល ១ ។

កាលពិចារណាធម៌នោះ ញាណដែលដល់នូវការបែកធ្លាយក្នុងធម៌នោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។

បទថា **តត្រ ធម្មនិរុត្តាភិលាបេ ញាណំ** បានដល់ សភាវនិរុត្តិ ( ភាសា ) ឯណា រមែងប្រព្រឹត្តទៅក្នុងអត្ថផង ក្នុងធម៌ផង កាលពិចារណាធ្វើនូវសព្ទ គឺសំឡេងដែលជាសភាវនិរុត្តិនោះ ព្រោះការពោលសភាវនិរុត្តិនោះ ឲ្យជាអារម្មណ៍ ញាណដែលដល់នូវការដឹង បែកធ្លាយក្នុងវាចាដែលជាសភាវនិរុត្តិនោះ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។ និរុត្តិប្បដិសម្ភិទានេះ កើតឡើងដោយអាការយ៉ាងនេះ ឈ្មោះថា មានសំឡេងជាអារម្មណ៍ មិនឈ្មោះថា មានបញ្ញត្តិជាអារម្មណ៍ឡើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជនទាំងឡាយស្ដាប់សំឡេងហើយ រមែងដឹងថា នេះជាសភាវនិរុត្តិ នេះមិនមែន ។ ពិតហើយ បុគ្គលសម្រេចបដិសម្ភិទាហើយ កាលមានបុគ្គលពោលថា **ផស្សោ** ដូច្នេះ រមែងជ្រាបថា នេះជាសភាវនិរុត្តិ ឬកាលអ្នកដទៃពោលថា **ផស្សា** ក្តី **ផស្សំ** ក្តី ដូច្នេះ ក៏រមែងដឹងថា នេះមិនមែនជាសភាវនិរុត្តិ ។ ក្នុងវេទនាជាដើមក៏ន័យនេះឯង ។

សួរថា បុគ្គលអ្នកសម្រេចបដិសម្ភិទានោះ រមែងដឹងសំឡេង ដែលជានាម អាខ្យាត ឧបសគ្គ និងព្យញ្ជនៈដទៃ ឬមិនដឹង ឆ្លើយថា ក្នុងខណៈ

លោកស្តាប់សំឡេង រមែងដឹងថា នេះជាសភាវនិរុត្តិ នេះមិនមែន បន្ទាប់អំពីនោះ នឹងដឹងសំឡេងដែលជានាមជាដើមនោះបាន តែសេចក្តីនេះ មានបុគ្គលជំទាស់ថា នេះមិនមែនកិច្ចនៃបដិសម្ភិទា ដូច្នេះហើយ បានលើកយករឿងនេះមកពោលថា

បានឮថា ព្រះថេរៈឈ្មោះថា តិស្សទត្តៈ កាន់យកស្លាកមាស ត្រង់ពោធិមណ្ឌល ហើយបវារណាដល់ភិក្ខុទាំងឡាយ ដោយពាក្យថា បណ្តាភាសា ១៨ ខ្ញុំនឹងពោលដោយភាសាណា ។ ឯពាក្យបវារណានោះ ព្រះថេរៈ លោកតាំងនៅក្នុងការសិក្សា ទើបបានបវារណា មិនមែនតាំងនៅក្នុងបដិសម្ភិទា ហើយពោលបវារណាឡើយ ព្រោះថា ព្រះថេរៈនោះ លោកឲ្យបុគ្គលប្រាប់រឿយៗ លោកក៏រៀនយកភាសានោះៗ ព្រោះភាពដែលលោកមានបញ្ញាច្រើន បន្ទាប់អំពីនោះមក លោកក៏បវារណាយ៉ាងនេះ ព្រោះតាំងនៅហើយ ក្នុងការសិក្សា ។

កាលលោកពោលថា ធម្មតាសត្វទាំងឡាយរមែងរៀនភាសាបាន ហើយពោលពាក្យនេះក្នុងទីនេះ ។ ពិតហើយ មាតា និងបិតាឲ្យទារកដេកត្រង់គ្រែឬតាំង ក្នុងពេលដែលកូននៅជាទារក ហើយនិយាយរឿងនោះៗ ធ្វើកិច្ចនោះៗ ។ ទារកទាំងឡាយ រមែងកំណត់ភាសានោះៗ របស់មាតាបិតាថា ពាក្យនេះ បុគ្គលនេះពោលហើយ ពាក្យនេះ បុគ្គលនេះពោលហើយ កាលកន្លងទៅ ពួកក្មេងរមែងចេះភាសាទាំងអស់ ។ មាតាជាជនជាតិទមិឡ បិតាជាអ្នកអន្ធកៈ កុមារដែលកើតអំពីជនទាំង ២ នោះ បើគេស្តាប់ពាក្យរបស់

មាតាមុន គេនឹងពោលភាសាទមិឡមុន បើស្តាប់ពាក្យរបស់បិតាមុន គេនឹងនិយាយភាសាអន្ធកៈមុន តែបើមិនបានស្តាប់ពាក្យរបស់ជនទាំង ២ ក៏នឹងនិយាយភាសាមគធៈ ។ ទារកណា កើតក្នុងព្រៃធំ មិនមានស្រុក អ្នកដទៃជាអ្នកនិយាយក្នុងព្រៃធំនោះមិនមាន ទារកនោះ កាលនិយាយតាមធម្មតារបស់ខ្លួន ក៏នឹងនិយាយភាសាមគធៈនោះឯង ។ ភាសាមគធៈប៉ុណ្ណោះប្រើច្រើន ក្នុងទីទាំងពួង គឺក្នុងនរក ១ ក្នុងកំណើតនៃសត្វតិរច្ឆាន ១ ក្នុងបិត្តិវិស័យ ១ ក្នុងមនុស្សលោក ១ ក្នុងទេវលោក ១ ។

ក្នុងភាសារបស់សត្វទាំងឡាយ ភាសា ១៨ យ៉ាង ក្រៅអំពីភាសានៃអ្នកមគធៈ មានភាសារបស់មនុស្សព្រៃ របស់អ្នកអន្ធកៈ របស់អ្នកយោនកៈ របស់ទមិឡ តាមដែលពោលហើយជាដើម រមែងប្រែប្រួលទៅ ភាសារបស់អ្នកមគធៈ ពោល គឺជាវោហាររបស់ព្រហ្ម ជាវោហាររបស់ព្រះអរិយៈ តាមសេចក្តីពិត ភាសាមួយនេះប៉ុណ្ណោះ មិនប្រែប្រួល សូម្បីព្រះសម្មាសម្ពុទ្ធគ្រាទ្រង់លើកព្រះត្រៃបិដក គឺព្រះពុទ្ធវចនៈ ជាបែបផែន ក៏ទ្រង់លើកឡើងដោយមគធភាសានោះឯង សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះយល់អត្ថបានងាយ ។

ពិតហើយ ការស្តាប់ព្រះពុទ្ធវចនៈ ដែលលើកឡើងកាន់បែបផែនដោយមគធភាសា ជាការមិនយឺតយូរដល់អ្នកសម្រេចបដិសម្ភិទាទាំងឡាយ កាលបើពុទ្ធវចនៈនោះ គ្រាន់តែប៉ះត្រចៀកប៉ុណ្ណោះ អត្ថរមែងប្រាកដ រាប់រយរាប់ពាន់ន័យ ។ ពុទ្ធវចនៈដែលលើកឡើងកាន់បែបផែន ដោយភាសាដទៃ

ចាំបាច់ពិចារណាសេចក្តីហើយ ពិចារណាសេចក្តីទៀត ទើបយល់បាន ។ ឈ្មោះថា ការសម្រេចបដិសម្ភិទារបស់បុថុជ្ជន ព្រោះរៀនច្រើន រមែងមិនមាន ។ ឈ្មោះថា អរិយសាវកដែលមិនសម្រេចបដិសម្ភិទាមិនបាន មិនមាន ។

បទថា **ញាណេសុ ញាណំ** បានដល់ កាលលោកពិចារណាញាណធ្វើញាណដែលដឹងបដិសម្ភិទាទាំងពួង ឲ្យជាអារម្មណ៍ ញាណដែលដល់នូវការបែកធ្លាយ ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។

បណ្ឌិតគប្បីជ្រាបថា បដិសម្ភិទាទាំង ៤ នេះ រមែងដល់នូវការបែកធ្លាយក្នុងឋានៈ គឺភូមិ ២ យ៉ាង និងរមែងបរិសុទ្ធដោយហេតុ ៥ យ៉ាង ។

សួរថា បដិសម្ភិទា ៤ រមែងដល់នូវការបែកធ្លាយក្នុងឋានៈ ២ ដូចម្តេច ឆ្លើយថា ក្នុងឋានៈ ២ គឺសេក្ខភូមិ និងអសេក្ខភូមិ ។

ក្នុងឋានៈ ២ នោះ បដិសម្ភិទារបស់មហាថេរៈទាំង ៨០ រូប ដល់នូវប្រភេទជាអសេក្ខភូមិ គឺបដិសម្ភិទារបស់ព្រះសារីបុត្តត្ថេរ របស់ព្រះមហាមោគ្គល្លានត្ថេរ របស់ព្រះមហាកស្សបត្ថេរ របស់ព្រះមហាកច្ចាយនត្ថេរ របស់ព្រះមហាកោដ្ឋិតត្ថេរជាដើម ។ បដិសម្ភិទារបស់បុគ្គលដែលដល់នូវសេក្ខភូមិ គឺរបស់ព្រះអានន្ទត្ថេរ របស់ចិត្តគហបតី របស់ធម្មិកឧបាសក របស់ឧបាលិគហបតី របស់នាងខុជ្ជុត្តរាឧបាសិកាជាដើម ។ បដិសម្ភិទាទាំងឡាយរមែងដល់នូវការបែកធ្លាយក្នុងភូមិទាំង ២ នោះ ដោយប្រការដូច្នេះ ។

សួរថា បដិសម្ភិទាទាំងឡាយ រមែងជាធម្មជាតបរិសុទ្ធដោយហេតុ ៥

ដូចម្តេច ? ឆ្លើយថា ដោយអធិគម ដោយបរិយត្តិ ដោយសវនៈ ដោយបរិបុច្ឆា ដោយបុព្វយោគ ។

ក្នុងហេតុទាំង ៥ នោះ អរហត្តឈ្មោះថា **អធិគម** ពិតហើយ បដិសម្ភិទារបស់អ្នកសម្រេចអរហត្តនោះ រមែងជាធម៌បរិសុទ្ធ ។ ព្រះពុទ្ធវចនៈឈ្មោះថា **បរិយត្តិ** ។ ពិតហើយ បដិសម្ភិទារបស់បុគ្គលដែលរៀនពុទ្ធវចនៈនោះ រមែងជាធម៌បរិសុទ្ធ ។ ការស្តាប់ធម៌ ឈ្មោះថា **សវនៈ** ។ ពិតហើយ បដិសម្ភិទាទាំងឡាយ របស់អ្នកស្តាប់ធម៌ដោយគោរព រមែងជាធម្មជាតបរិសុទ្ធ ។ អដ្ឋកថាឈ្មោះថា **បរិបុច្ឆា** ។ ពិតហើយ បដិសម្ភិទាទាំងឡាយរបស់អ្នកពោលនូវអត្ថនៃព្រះបាលីដែលខ្លួនរៀនមកហើយ រមែងជាធម៌បរិសុទ្ធ ។ ភាពជាព្រះយោគាវចរក្នុងកាលមុន គឺភាពជាអ្នកមានកម្មដ្ឋានដែលខ្លួនបរិហារហើយ ដោយន័យនៃការនាំកម្មដ្ឋានទៅ និងនាំកម្មដ្ឋានត្រឡប់មកក្នុងអតីតភព ឈ្មោះថា **បុព្វយោគ** ។ ពិតហើយ បដិសម្ភិទារបស់ព្រះយោគាវចរក្នុងកាលមុន រមែងជាធម៌បរិសុទ្ធ ។

បណ្តាហេតុទាំង ៥ នោះ បដិសម្ភិទារបស់ព្រះតិស្សត្ថេរ ដែលជាបុត្តរបស់បុនព្វសុកុដុម្ពិកៈ បានជាធម៌បរិសុទ្ធហើយដោយការសម្រេចអរហត្ត ។

បានឮថា ព្រះតិស្សត្ថេរនោះ រៀនព្រះពុទ្ធវចនៈក្នុងតម្ពបណ្ណិទ្វីប ហើយទៅកាន់ត្រើយនាយ រៀនយកពុទ្ធវចនៈក្នុងសម្នាក់របស់ព្រះធម្មរក្ខិតត្ថេរ ដែនយោនកៈ ចប់ការរៀន ក៏ធ្វើដំណើរមកដល់កំពង់សម្រាប់ឡើងទូក កើតការសង្ស័យក្នុងពុទ្ធវចនៈមួយបទ ទើបធ្វើដំណើរត្រឡប់មកវិញ អស់ចម្ងាយផ្លូវ

១០០ យោជន៍ កាលទៅក្នុងសម្នាក់របស់អាចារ្យ ក្នុងរវាងផ្លូវ បានឆ្លើយបញ្ហាដល់កុដុម្ពិកៈម្នាក់ កុដុម្ពិកៈនោះ កើតនូវសេចក្ដីជ្រះថ្លា បានប្រគេនសំពត់កម្ពលដែលមានតម្លៃមួយសែន ព្រះតិស្សត្ថេរនោះនាំសំពត់មកប្រគេនអាចារ្យ អាចារ្យឲ្យចិញ្ច្រាំសំពត់នោះដោយកាំបិត ហើយធ្វើជាបរិកណ្ឌត្រង់ទីអង្គុយ ។

សួរថា អាចារ្យធ្វើបែបនោះដើម្បីប្រយោជន៍អ្វី ឆ្លើយថា ដើម្បីអនុគ្រោះដល់ជនឯក្រោយ ។ បានឮថា អាចារ្យនោះមានបរិវិតក្កថា ក្នុងអនាគតកាល សព្រហ្មចារីទាំងឡាយ នឹងសម្គាល់ដល់គន្ធដែលពួកគេប្រព្រឹត្តហើយ នឹងសង្កេតដល់បដិបទាដែលគប្បីបំពេញ ។ ព្រះតិស្សត្ថេរ ក៏កាត់សេចក្ដីសង្ស័យបានក្នុងសម្នាក់របស់អាចារ្យហើយ ទើបឈានចុះកាន់កំពង់ ឈ្មោះជម្ពុកោលៈ ដល់វិហារឈ្មោះវាលិកៈ ក្នុងពេលបោសសម្អាតលានព្រះចេតិយ លោកក៏បោសសម្អាតលានព្រះចេតិយ ។ ព្រះថេរៈទាំងឡាយឃើញទីដែលព្រះតិស្សត្ថេរនោះបោសហើយ ក៏គិតថា ទីនេះ ជាទីបោសសម្អាតដែលភិក្ខុមានរាគៈទៅប្រោស តែដើម្បីសាកល្បងព្រះថេរៈ ទើបសួរបញ្ហា ។ ព្រះតិស្សត្ថេរនោះ ក៏ពោលដោះស្រាយបញ្ហាដែលភិក្ខុទាំងនោះសួរហើយ គ្រប់បទ ព្រោះខ្លួនជាអ្នកសម្រេចបដិសម្ភិទា ។

បដិសម្ភិទារបស់ព្រះតិស្សទត្តត្ថេរ និងរបស់ព្រះនាគសេនត្ថេរបានបរិសុទ្ធហើយដោយបរិយត្តិ បដិសម្ភិទារបស់សាមណេរឈ្មោះសុធម្ម បរិសុទ្ធហើយដោយការស្ដាប់ធម៌ដោយគោរព ។

បានឮថា សាមណេរនោះ ជាក្មួយរបស់ព្រះធម្មទិន្នត្ថេរ អ្នកនៅក្នុងតលង្គរវាសី ក្នុងខណៈកោរសក់ស្រេចក៏សម្រេចអរហត្ត កាលលោកកំពុងអង្គុយស្តាប់ធម៌ក្នុងរោងវិនិច្ឆ័យធម៌របស់ព្រះថេរៈ ដែលជាលោកអាំនោះឯងបានជាអ្នកជំនាញក្នុងព្រះត្រៃបិដក ។

បដិសម្ភិទារបស់ព្រះតិស្សទត្តត្ថេរ ដែលពោលអត្ថនៃព្រះបាលីដែលខ្លួនរៀនមក បានជាធម៌បរិសុទ្ធហើយ ។ ម្យ៉ាងទៀត ព្រះយោគាវចរក្នុងកាលមុន ដែលបំពេញគតបច្ចាគតវត្ត គឺវត្តដែលនាំកម្មដ្ឋានទៅ និងនាំកម្មដ្ឋានត្រឡប់មក ហើយខ្វល់ខ្វាយមករហូតដល់អនុលោមកម្មដ្ឋាន មានបដិសម្ភិទាដែលដល់នូវសេចក្តីបរិសុទ្ធហើយ មានច្រើនមិនមានទីបំផុត ។

បណ្តាហេតុទាំង ៥ នោះ ហេតុ ៣ គឺបរិយត្តិ សវនៈ និងបរិបុច្ឆា ជាហេតុដែលមានកម្លាំងដល់ការបែកធ្លាយបុព្វយោគ ជាពលវប្បច្ច័យ ដល់អធិគម ។

សួរថា បុព្វយោគជាបច្ច័យមានកម្លាំងដល់បញ្ញាជាគ្រឿងបែកធ្លាយឬទេ ឆ្លើយថា ជាបច្ច័យ តែមិនដូចហេតុ ៣ នោះ ព្រោះបរិយត្តិ សវនៈ បរិបុច្ឆា នឹងមានក្នុងកាលមុនក្តី មិនមានក្តី តែបើពោលដោយបុព្វយោគហើយ វៀរចាកការពិចារណាសង្ខារទាំងឡាយ ក្នុងកាលមុនផង ក្នុងកាលបច្ចុប្បន្នផង បដិសម្ភិទាទាំងឡាយ ឈ្មោះថា មិនមាន ។ ហេតុទាំង ២ នេះ រួមបូលគ្នាឧបការៈហើយ រមែងធ្វើបដិសម្ភិទាឲ្យបរិសុទ្ធ ។

**សង្គហវារ ចប់**

# អធិប្បាយ

## សច្ចវារជាដើម

ឥឡូវនេះ ដើម្បីចែកបដិសម្ភិទាទាំងឡាយ ដោយអត្ថនៃការសម្តែងប្រភេទនៃអត្ថ ៥ យ៉ាង និងធម៌ ៥ យ៉ាង ដែលទ្រង់សង្គ្រោះក្នុងសង្ខេបវារ ទើបព្រះមានព្រះភាគ ផ្តើមប្រភេទវារៈ ដោយន័យជាដើមថា **ចតស្សោ** ដូច្នេះទៀត ។ វារៈនោះមាន ៥ យ៉ាង ដោយអំណាចនៃសច្ចវារ ហេតុវារ ធម្មវារ បច្ចយាការវារ បរិយត្តិវារ ។

ក្នុងវារៈទាំងនោះ ព្រះមានព្រះភាគ ត្រាស់សច្ចវារ ក៏ដើម្បីសម្តែងថា ទុក្ខដែលអាស្រ័យបច្ច័យកើតឡើង និងព្រះនិព្វាន ដែលគប្បីសម្រេចបាន ដោយបច្ច័យជាអត្ថ និងដើម្បីសម្តែងថា សមុទយៈដែលធ្វើផលឲ្យកើត និងអរិយមគ្គដែលជាហេតុឲ្យដល់ព្រះនិព្វាន ជាធម៌ ។

ព្រះមានព្រះភាគត្រាស់ហេតុវារ ក៏ដើម្បីសម្តែងថា ហេតុដែលធ្វើផលឲ្យកើតឡើងឯណានីមួយជាធម៌ និងដើម្បីសម្តែងផលនៃហេតុជាអត្ថ ។ ក្នុងសេចក្តីនេះ ព្រះមានព្រះភាគទ្រង់លើកធម្មប្បដិសម្ភិទាសម្តែងមុន ដោយមិនប្រព្រឹត្តទៅតាមលំដាប់ ដោយលំដាប់នៃហេតុ និងផល ។

ធម៌ពួកណា កើតអំពីហេតុ មានរូបធម៌ និងអរូបធម៌នោះៗ ដើម្បីទ្រង់សម្តែងថា ធម៌ទាំងនោះ ជាអត្ថ និងដើម្បីសម្តែងថា ហេតុ មានរូបធម៌ និងអរូបធម៌នោះៗ ជាធម្មៈ ទើបព្រះមានព្រះភាគត្រាស់ធម្មវារ ។

ដើម្បីសម្តែងថា ធម៌ទាំងឡាយ មានជរា និងមរណៈជាដើម ជាអត្ថ និង

ធម៌ទាំងឡាយ មានជាតិជាដើម ពោល គឺហេតុកើតឡើងដល់ជរា និងមរណៈជាដើម ជាធម្មៈ ទើបព្រះមានព្រះភាគត្រាស់បច្ចយាការវារ ។

លំដាប់នោះ ដើម្បីសម្តែងនូវភាសិតនោះៗ ពោល គឺបរិយត្តិជាធម៌ និងនូវភាពនៃភាសិតដែលគប្បីសម្រេចបានដោយបច្ច័យ ពោល គឺភាសិតជាអត្ថ ទើបព្រះមានព្រះភាគត្រាស់បរិយត្តិវារ ។ ក្នុងសេចក្តីនេះ បណ្ឌិតកាលជ្រាបភាសិតហើយ រមែងជ្រាបអត្ថនៃភាសិតនោះបាន ព្រោះហេតុនោះ ទើបទ្រង់លើកធម្មប្បដិសម្ភិទាឡើងសម្តែងមុន ដោយមិនប្រព្រឹត្តទៅតាមលំដាប់ គឺដោយលំដាប់នៃភាសិត និងអត្ថនៃភាសិត ។

ម្យ៉ាងទៀត ដើម្បីសម្តែងប្រភេទនៃបរិយត្តិធម៌ ទើបព្រះមានព្រះភាគត្រាស់បដិនិទ្ទេសវារដែលមានពាក្យសួរជាប្រធានថា បណ្តាបដិសម្ភិទាទាំង ៤ នោះ ធម្មប្បដិសម្ភិទា តើដូចម្តេច ក្នុងបដិនិទ្ទេសវារនោះ ទ្រង់កាន់យកបែបផែនទាំងអស់ដោយមិនសេសសល់ ដោយអង្គ ៩ មានសុត្តៈជាដើមថា ជាធម្មប្បដិសម្ភិទា ទ្រង់កាន់យកបែបផែនទាំងអស់ ដោយមិនសេសសល់ ដោយអំណាចនៃភាសិតក្នុងទីនេះថា នេះជាអត្ថនៃភាសិតនេះ នេះជាអត្ថនៃភាសិតនេះ ដូច្នេះថា ជាអត្ថប្បដិសម្ភិទា ដូច្នេះ ។៚

**អដ្ឋកថាសុត្តន្តភាជនីយ ចប់**

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ១៨ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិ-សម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយ កើតឡើង ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងនូវញាណទាំងឡាយថា បុគ្គលដឹងក្នុងញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៤ គឺអត្ថប្បដិ-សម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា សម្ប-យុត្តដោយញាណ ។បេ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ

ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអា-រម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិ-ភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិ-សម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិ-សម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុង

ញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្ប-ដិសម្ភិទា ។ បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិ-សម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងអរូបភព ព្រោះកិរិយាកន្លងនូវអាកិញ្ចញ្ញាយតនៈដោយប្រការទាំងពួង ហើយលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យ

នោះ ផស្សៈក៏កើតមាន ។បេ។ សេចក្ដីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាកុសល សេចក្ដីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះដោយនិរុត្តិណា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះជាធម្មជាត ញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ១៩ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអកុសល តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាអកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយទិដ្ឋិ មានរូបជាអារម្មណ៍ក្ដី ។បេ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយ កើតឡើង ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្ដីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាអកុសល សេចក្ដីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងក្នុងញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៤ គឺអត្ថប្ប-

ដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាអកុសល ប្រទ្បំដោយសោមនស្ស សម្បយុត្តដោយទិដ្ឋិ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រាសចាកទិដ្ឋិ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រាសចាកទិដ្ឋិ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា សម្បយុត្តដោយទិដ្ឋិ ។បេ។ ប្រទ្បំដោយឧបេក្ខា សម្បយុត្តដោយទិដ្ឋិ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកទិដ្ឋិ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកទិដ្ឋិ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយទោមនស្ស សម្បយុត្តដោយបដិឃៈ ។បេ។ ប្រទ្បំដោយទោមនស្ស សម្បយុត្តដោយបដិឃៈ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា សម្បយុត្តដោយវិចិកិច្ឆា ។បេ។ ប្រទ្បំដោយឧបេក្ខា សម្បយុត្តដោយឧទ្ធច្ចៈ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយ កើតឡើង ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាអកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយ នេះឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ២០ ] បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បសម្ភិទា បដិភា-ណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា ចក្ខុវិញ្ញាណ ជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាចក្ខុវិញ្ញាណ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើងហើយ ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន ឧបេក្ខាកើតមាន ចិត្តេកគ្គតាកើតមាន មនិន្ទ្រិយកើតមាន ឧបេក្ខិន្ទ្រិយកើតមាន ជីវិតិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបអាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភា-ណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា សោតវិញ្ញាណជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាសោតវិញ្ញាណ ប្រកបដោយឧបេក្ខា មានសំឡេងជាអារម្មណ៍ កើតឡើងហើយ ។បេ។ ឃានវិញ្ញាណ ប្រកបដោយឧបេក្ខា មានក្លិនជាអារម្មណ៍ កើតឡើងហើយ ។បេ។ ជិវ្ហាវិញ្ញាណ ប្រកបដោយឧបេក្ខា

មានរសជាអារម្មណ៍កើតឡើងហើយ ។បេ។ កាយវិញ្ញាណ ប្រកបដោយសុខ មានផ្សព្វជាអារម្មណ៍ កើតឡើងហើយ ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន សុខកើតមាន ចិត្តេកគ្គតាកើតមាន មនិន្ទ្រិយកើតមាន សុខិន្ទ្រិយកើតមាន ជីវិតិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបអាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹតតើដូចម្តេច ។ ក្នុងសម័យណា មនោធាតុជាវិបាក ព្រោះកម្មជាកាមាវចរកុសលដែលបុគ្គលធ្វើហើយ សន្សំហើយ ជាមនោធាតុ ប្រកបដោយឧបេក្ខា មានរូបជារម្មណ៍ក្តី ។បេ។ មានផ្សព្វជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយ កើតឡើង ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន វិតក្កកើតមាន វិចារកើតមាន ឧបេក្ខាកើតមាន ចិត្តេកគ្គតាកើតមាន មនិន្ទ្រិយកើតមាន ឧបេក្ខិន្ទ្រិយកើតមាន ជីវិតិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា

មិនមានរូបអាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យា-ក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាមនោវិញ្ញាណ-ធាតុ ប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាមួយ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន វិតក្កកើតមាន វិចារកើតមាន បីតិកើតមាន សុខកើតមាន ចិត្តេកគ្គតាកើតមាន មនិន្ទ្រិយកើតមាន សោមនស្សិន្ទ្រិយកើតមាន ជីវិតិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបអាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណ

ទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំង អត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុ ជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាមនោវិញ្ញាណធាតុប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន វិតក្កកើតមាន វិចារកើតមាន ឧបេក្ខាកើតមាន ចិត្តេកគ្គតាកើតមាន មនិន្ទ្រិយកើតមាន ឧបេក្ខិន្ទ្រិយកើតមាន ជីវិតិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបអាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុ ជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើ

ហើយ សន្សំហើយ ជាធាតុប្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ។បេ។ ប្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រឡំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ប្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈកើតមាន ។បេ។ សេចក្តីមិនរាយមាយកើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណជាអារម្មណ៍ ក្នុងសម័យនោះ ផស្សៈកើតមាន ។បេ។ សេចក្តី

មិនរាយមាយកើតមាន នេះពួកធម៌ជាកុសល ជាវិបាក ព្រោះកម្មជារូបាវ-ចរកុសលនោះ ដែលបុគ្គលធ្វើហើយ សន្សំហើយ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ ផស្សៈកើតមាន ។បេ។ សេចក្តីមិនរាយមាយកើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណាញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណាបុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងអរូបភព ព្រោះកិរិយាកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងសម័យនោះផស្សៈកើតមាន ។បេ។ សេចក្តីមិនរាយមាយកើតមាន នេះពួកធម៌ជាកុសលជាវិបាក ព្រោះកម្មជាអរូបាវចរកុសលនោះឯង ដែលបុគ្គលធ្វើហើយ សន្សំហើយ ព្រោះកិរិយាកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងសម័យនោះ ផស្សៈកើតមាន ។បេ។ សេចក្តីមិន

រាយមាយកើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះ ឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់កាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈកើតមាន ។បេ។ សេចក្តីមិនរាយមាយកើតមាន ពួកធម៌ជាកុសលជាវិបាក ព្រោះឈានជាលោកុត្តរកុសលនេះឯង ដែលបុគ្គលធ្វើហើយ ចម្រើនហើយ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាសុញ្ញតៈ ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈកើតមាន ។បេ។ សេចក្តីមិនរាយមាយកើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា

ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា ចក្ខុវិញ្ញាណជាវិបាក ព្រោះកម្មជាអកុសលដែលបុគ្គលធ្វើហើយ សន្សំហើយ ជាវិញ្ញាណប្រទ្បំដោយឧបេក្ខា មានរូបជាអារម្មណ៍កើតហើយ ។បេ។ សោតវិញ្ញាណ ប្រទ្បំដោយឧបេក្ខា មានសំឡេងជាអារម្មណ៍ កើតហើយ ។បេ។ ឃានវិញ្ញាណ ប្រទ្បំដោយឧបេក្ខា មានក្លិនជាអារម្មណ៍ កើតហើយ ។បេ។ ជិវ្ហាវិញ្ញាណ ប្រទ្បំដោយឧបេក្ខា មានរសជាអារម្មណ៍ កើតហើយ ។បេ។ កាយវិញ្ញាណប្រទ្បំដោយទុក្ខ មានផ្សព្វជាអារម្មណ៍ កើតហើយ ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន ទុក្ខកើតមាន ចិត្តេកគ្គតាកើតមាន មនិន្ទ្រិយកើតមាន ទុក្ខិន្ទ្រិយកើតមាន ជីវិតិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបអាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះ ឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។

ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោធាតុ ជាវិបាក ព្រោះកម្មជាអកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាធាតុ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផ្សព្វអារម្មណ៍ក្តី កើតឡើងហើយ ។បេ។ មនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយ កើតឡើង ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន វិតក្កកើតមាន វិចារកើតមាន ឧបេក្ខាកើតមាន ចិត្តេកគ្គតាកើតមាន មនិន្ទ្រិយកើតមាន ឧបេក្ខិន្ទ្រិយកើតមាន ជីវិ-តិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូប ដែលអាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះ ឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ២១ ] បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភា-ណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោធាតុជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្ម-វិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផ្សព្វជាអា-

រម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយ កើតឡើង ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន វិតក្កកើតមាន វិចារកើតមាន ឧបេក្ខាកើតមាន ចិត្តេកគ្គតាកើតមាន មនិន្ទ្រិយកើតមាន ឧបេក្ខិន្ទ្រិយកើតមាន ជីវិតិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបដែលអាស្រ័យនឹងគ្នា ហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះ ឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុ ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី កើតឡើង ។បេ។ មនោវិញ្ញាណធាតុ ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយ កើតឡើង ក្នុងសម័យនោះ ផស្សៈកើតមាន វេទនាកើតមាន សញ្ញាកើតមាន ចេតនាកើតមាន ចិត្តកើតមាន វិតក្កកើត

មាន វិចារកើតមាន ឧបេក្ខាកើតមាន ចិត្តេកគ្គតាកើតមាន វីរិយិន្ទ្រិយកើតមាន សមាធិន្ទ្រិយកើតមាន មនិន្ទ្រិយកើតមាន ឧបេក្ខិន្ទ្រិយកើតមាន ជីវិ-តិន្ទ្រិយកើតមាន ឬក៏ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបដែលអាស្រ័យនឹងគ្នាហើយ កើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនោះ ជាធម្មជាតញុំាងអត្ថនេះ ឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺអត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រទ្បំដោយសោមនស្ស សម្បយុត្តដោយញាណ ។បេ។ ប្រទ្បំដោយសោមនស្ស សម្ប-យុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ប្រទ្បំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើងហើយ ។បេ។ បុគ្គលចម្រើននូវ

*រូបាវចរជ្ឈាន ។បេ។ បុគ្គលចម្រើននូវអរូបាវចរជ្ឈាន ជាកិរិយា មិនមែន កុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ជាគ្រឿងនៅជាសុខក្នុង បច្ចុប្បន្ន ព្រោះការកន្លងអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយលះ បង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញានា-សញ្ញាយតនសញ្ញា ។បេ។ ក្នុងសម័យនោះ ផស្សៈកើតមាន ។បេ។ សេចក្តី មិនរាយមាយកើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំង ឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយ និរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណ ទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុាំង អត្ថនេះ ឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។*

*[ ២២ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិ-សម្ភិទា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ កើតក្នុងចិត្តុប្បាទ ៤ ជា ញាណសម្បយុត្ត ខាងកាមាវចរកុសល កើតក្នុងចិត្តុប្បាទ ៤ ជាញាណ សម្បយុត្ត ខាងកិរិយា អត្ថប្បដិសម្ភិទា កើតក្នុងចិត្តុប្បាទទាំងនុ៎ះផង កើត ក្នុងមគ្គ ៤ ផល ៤ ផង ។*

***អភិធម្មភាជនីយ ចប់***

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ១៨-២២ ] បណ្ដាបដិសម្ភិទាទាំង ៤ នោះ បដិសម្ភិទា ៣ ជាលោកិយ អត្ថប្បដិសម្ភិទា ជាលោកិយ និងលោកុត្តរលាយឡំគ្នា ។ ពិតហើយ អត្ថប្បដិសម្ភិទានោះ ជាលោកុត្តរដោយអំណាចនៃញាណ ក្នុងមគ្គនិងផល ដែលមានព្រះនិព្វានជាអារម្មណ៍ ។

ក្នុងអភិធម្មភាជនីយ លោកចែកបដិសម្ភិទាទាំងនោះ ដោយវារៈទាំង ៤ ដោយអំណាចនៃកុសល អកុសល វិបាក និងកិរិយា ។ ក្នុងវារៈទាំងនោះ កុសលចិត្តមានប្រមាណប៉ុនណា ដែលព្រះមានព្រះភាគ ទ្រង់បានចែកក្នុងចិត្តុប្បាទកណ្ឌខាងដើម បណ្ឌិតគប្បីជ្រាបថា បដិសម្ភិទានីមួយៗ ៤ ក្នុងចិត្តនិទ្ទេសនីមួយៗ ទ្រង់ចែកហើយ ដោយអំណាចនៃកុសលចិត្តទាំងអស់មានប្រមាណប៉ុណ្ណោះ ។ ក្នុងអកុសលចិត្តទាំងឡាយក៏ន័យនេះឯង ។

ក្នុងវារៈពោលដោយវិបាក និងកិរិយា ព្រះមានព្រះភាគ ទ្រង់វៀរធម្មប្បដិសម្ភិទា ព្រោះវិបាក និងកិរិយាទាំងឡាយ ទ្រង់សង្គ្រោះដោយអត្ថហើយ ទ្រង់ចែកបដិសម្ភិទានីមួយៗ ៣ ប៉ុណ្ណោះ ក្នុងវិបាកចិត្ត និងក្នុងកិរិយាចិត្តនីមួយៗ តែទ្រង់សម្ដែងសង្ខេបព្រះបាលីត្រឹមតែមួយមាតិកាប៉ុណ្ណោះ ។ បណ្ឌិតគប្បីជ្រាបព្រះបាលីនោះ ដោយអំណាចសេចក្ដីពិស្ដារដែលមកហើយខាងដើមនោះឯង ។

សួរថា ក្នុងវារៈពោលដោយកុសល និងអកុសលទាំងឡាយ ទ្រង់ត្រាស់ថា សេចក្ដីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា

*ដូច្នេះ យ៉ាងណា ក្នុងវារៈពោលដោយវិបាកនេះ ទ្រង់មិនត្រាស់យ៉ាងនេះថា ញាណក្នុងធម៌ទាំងឡាយ ដែលមានធម៌ទាំងនោះ ជាធម្មវិបាក ឈ្មោះថា ធម្មប្បដិសម្ភិទា ដូច្នេះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះទ្រង់ត្រាស់ហើយខាងដើម ។*

*បើមានអ្នកសួរថា បើយ៉ាងនោះ អត្ថប្បដិសម្ភិទានេះ ក៏មិនគប្បីពោលក្នុងទីនេះ ព្រោះទ្រង់ត្រាស់ខាងដើមហើយថា ញាណក្នុងវិបាកនៃធម៌ទាំងនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា ដូច្នេះ ។ គួរឆ្លើយថា មិនពោលក៏មិនបាន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអត្ថប្បដិសម្ភិទា ក្នុងវារៈពោលដោយកុសល និងអកុសលខាងដើម ទ្រង់មិនបានត្រាស់ដោយអំណាចការកើតឡើងនៃវិបាកចិត្ត និងកិរិយាចិត្ត ចំណែកវារៈពោលដោយកិរិយា ការពោលថា ( ញាណក្នុងធម៌ទាំងឡាយ ) ដែលមានធម៌ទាំងនេះ ជាកិរិយា ( ឈ្មោះថា ធម្មប្បដិសម្ភិទា ) ដូច្នេះ រមែងមិនគួរដូចគ្នា ព្រោះហេតុនោះ ក្នុងវារៈទាំង ២ នេះ ទើបព្រះមានព្រះភាគទ្រង់ចែកបដិសម្ភិទានីមួយៗ ៣ ប៉ុណ្ណោះ ។*

*បណ្តាបទទាំងនោះ បទថា* **យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ** *សេចក្តីថា បញ្ញត្តិយ៉ាងនេះថា នេះជាផស្សៈ នេះជាវេទនា នៃធម៌ទាំងនោះ ដែលព្រះមានព្រះភាគត្រាស់ដោយន័យជាដើមថា ផស្សៈ ... មាន ( ក្នុងសម័យនោះ ) រមែងមានដោយនិរុត្តិណា ។*

*បទថា* **ធម្មនិរុត្តាភិលាបេ ញាណំ** *បានដល់ ញាណក្នុងការពោល*

ធម្មនិរុត្តិ គឺសការបញ្ញត្តិនោះ ដែលប្រព្រឹត្តទៅក្នុងអត្ថ និងក្នុងធម៌នោះ ។ ញាណដែលកើតឡើង ធ្វើអភិលាបសទ្ទ ( សំឡេងក្នុងការពោល ) ឲ្យជាអារម្មណ៍នោះឯង ទ្រង់ត្រាស់ហើយ ក្នុងទីនេះ ។ បទថា **យេន ញាណេន** បានដល់ ដោយបដិភាណប្បដិសម្ភិទាញាណណា ។ បទថា **តានិ ញាណានិ ជានាតិ** បានដល់ រមែងដឹងបដិសម្ភិទា ៣ ក្រៅអំពីនេះ ។

ឥឡូវនេះ ញាណណា ដឹងនូវការបែកធ្លាយនូវញាណទាំងនោះ ដោយប្រការណា ដើម្បីសម្ដែងការប្រព្រឹត្តទៅនៃញាណនោះ ក្នុងញាណទាំងនោះ ដោយប្រការនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា **ឥមានិ ញាណានិ ឥទមត្ថជោតកានិ** ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះ ឲ្យភ្លឺដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **ឥទមត្ថជោតកានិ** បានដល់ ធ្វើឲ្យបញ្ចាំង គឺប្រកាសនូវអត្ថនេះ អធិប្បាយថា ញាណទាំង ៣ នេះ រមែងធ្វើឲ្យបញ្ចាំង រមែងប្រកាស រមែងកំណត់នូវអត្ថឈ្មោះនេះ ។ បទថា **ឥតិ ញាណេសុ ញាណំ** បានដល់ ការដឹងក្នុងញាណទាំង ៣ ដែលប្រព្រឹត្តទៅដោយអាការនេះ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ ក្នុងបដិសម្ភិទាទាំង ៤ នោះ បដិភាណប្បដិសម្ភិទានេះ រមែងដឹងនូវកិច្ចរបស់បដិសម្ភិទាទាំងឡាយនេះថា នេះជាកិច្ចរបស់បដិសម្ភិទានេះ នេះជាកិច្ចរបស់បដិសម្ភិទានេះក៏ពិត តែខ្លួនឯង រមែងមិនអាចធ្វើកិច្ចរបស់បដិសម្ភិទាទាំងនោះ បានឡើយ ប្រៀបដូចព្រះធម្មកថិកដែលជាពហុស្សូត រមែងមិនអាចធ្វើកិច្ចរបស់ធម្មកថិក

ដែលជាអប្បស្សុត គឺមានការបេះដឹងតិចបាន ។

បានឮថា ភិក្ខុ ២ រូប មួយរូបជាពហុស្សុត មួយរូបជាអប្បស្សុត ភិក្ខុទាំង ២ រូបនោះ រៀននូវធម្មកថាមគ្គមួយជាមួយគ្នា ។ ក្នុងភិក្ខុ ២ រូបនោះ ភិក្ខុដែលមានសុតៈតិច ជាអ្នកមានសំឡេងពីរោះ ឯភិក្ខុដែលជាពហុស្សុត មានសំឡេងខ្សោយ ក្នុងភិក្ខុ ២ រូបនោះ ភិក្ខុអប្បស្សុត សម្ដែងធម៌ ធ្វើបរិស័ទទាំងអស់ឲ្យញាប់ញ័រដោយសម្បត្តិ គឺសំឡេងរបស់ខ្លួន ក្នុងទីដែលខ្លួនទៅហើយ ។ មហាជនស្ដាប់ធម៌របស់លោក សុទ្ធតែមានចិត្តត្រេកអរពោលថា ភិក្ខុអង្គនោះពោលថា ភិក្ខុដែលពោលធម៌បានយ៉ាងនេះ ប្រហែលជាអ្នកទ្រទ្រង់ព្រះត្រៃបិដកមួយរូប តែភិក្ខុដែលជាពហុស្សុត ពោលថា អ្នកទាំងឡាយនឹងជ្រាបបានក្នុងពេលស្ដាប់ធម៌ថា ភិក្ខុរូបនេះ ទ្រទ្រង់ព្រះត្រៃបិដកឬទេ ។ ភិក្ខុជាពហុស្សុតនោះ ទោះបីពោលយ៉ាងនេះ តែលោកមិនអាចពោលដូចភិក្ខុដែលជាអប្បស្សុត ដែលអាចពោលធម៌ធ្វើបរិស័ទទាំងអស់ ឲ្យញាប់ញ័របាន ។ បណ្ឌិតគប្បីជ្រាបថា ក្នុងបដិសម្ភិទា ៤ នោះ បដិភាណប្បដិសម្ភិទា រមែងដឹងកិច្ចរបស់បដិសម្ភិទា ៣ ក្រៅអំពីនេះ ដូចភិក្ខុពហុស្សុតដឹងនូវកិច្ចការងាររបស់ភិក្ខុដែលជាអប្បស្សុត តែខ្លួនឯង មិនអាចធ្វើកិច្ចនោះបាន ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

ព្រះមានព្រះភាគ កាលទ្រង់ចែកបដិសម្ភិទាទាំងឡាយដោយអំណាចនៃចិត្តុប្បាទយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្ដែងព្រំដែន ដែលជាទីកើតឡើងនៃបដិសម្ភិទាទាំងនោះ ទើបត្រាស់ពាក្យថា **ចតស្សោ បដិសម្ភិទា** ជាដើម

*ទៀត ។*

*ក្នុងសេចក្តីនោះ បទថា* **តិស្សោ បដិសម្ភិទា កាមាវចរកុសលតោ ចតូសុ ញាណសម្បយុត្តេសុ ចិត្តុប្បាទេសុ** *នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃព្រះសេក្ខៈទាំងឡាយ ។*

*ពិតហើយ ព្រោះធ្វើធម៌ ៥ ដែលខ្ញុំបានពោលហើយខាងដើម ឲ្យជាអារម្មណ៍ក្នុងវេលាពិចារណាធម៌ របស់ព្រះសេក្ខបុគ្គលទាំងនោះ ធម្មប្បដិសម្ភិទា រមែងកើតឡើងក្នុងកុសលចិត្ត ដែលសម្បយុត្តដោយញាណ ៤ ដួង ។ ដោយទំនងដូចគ្នានេះ ព្រោះធ្វើសំឡេងឲ្យជាអារម្មណ៍ ក្នុងវេលាពិចារណានិរុត្តិ និរុត្តិប្បដិសម្ភិទា រមែងកើតឡើង ព្រោះធ្វើញាណដែលដឹងបដិសម្ភិទាទាំងពួងឲ្យជាអារម្មណ៍ ក្នុងវេលាពិចារណាញាណ បដិភាណប្បដិសម្ភិទា រមែងកើតឡើង ។*

*ឯបទថា* **កិរិយតោ ចតូសុ** *នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចអសេក្ខបុគ្គលទាំងឡាយ ។ ពិតហើយ ព្រោះធ្វើធម៌ ៥ តាមដែលពោលហើយខាងដើម ឲ្យជាអារម្មណ៍ ក្នុងវេលាពិចារណាធម៌របស់អសេក្ខបុគ្គលទាំងនោះ ធម្មប្បដិសម្ភិទា រមែងកើតឡើងក្នុងកិរិយាចិត្ត ដែលសម្បយុត្តដោយញាណ ៤ ដួង ។ ដោយទំនងដូចគ្នា ព្រោះធ្វើសំឡេងឲ្យជាអារម្មណ៍ ក្នុងវេលាពិចារណានិរុត្តិប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា រមែងកើតឡើង ព្រោះធ្វើញាណដែលដឹងបដិសម្ភិទាទាំងពួង ឲ្យជាអារម្មណ៍ ក្នុងវេលាពិចារណាញាណ បដិភាណប្បដិសម្ភិទា រមែងកើតឡើង ។*

តែបទថា **អត្ថប្បដិសម្ភិទា ឯតេសុ ចេវ ឧប្បជ្ជតិ** នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចសេក្ខបុគ្គល និងអសេក្ខបុគ្គល ។ ពិតហើយ ព្រោះធ្វើអត្ថមានប្រភេទតាមដែលពោលហើយខាងដើម ឲ្យជាអារម្មណ៍ ក្នុងវេលាពិចារណាអត្ថរបស់សេក្ខបុគ្គលទាំងឡាយ អត្ថប្បដិសម្ភិទានេះ រមែងកើតឡើងក្នុងកុសលចិត្តដែលសម្បយុត្តដោយញាណ ៤ ដួង និងរមែងកើតឡើងក្នុងមគ្គចិត្ត និងក្នុងផលចិត្ត ក្នុងវេលានៃមគ្គ និងផលក៏ធ្វើអត្ថមានប្រភេទដូចពោលហើយខាងដើមនោះឯង ឲ្យជាអារម្មណ៍ ក្នុងវេលាពិចារណាអត្ថរបស់ព្រះអសេក្ខបុគ្គល អត្ថប្បដិសម្ភិទានេះ រមែងកើតឡើងក្នុងកិរិយាចិត្តដែលសម្បយុត្តដោយញាណ ៤ ដួង និងក្នុងសាមញ្ញផល ដែលតាំងនៅខាងលើក្នុងវេលានៃផល ហេតុនោះ បដិសម្ភិទាទាំងនេះ កាលកើតដល់ព្រះសេក្ខបុគ្គល និងព្រះអសេក្ខបុគ្គល រមែងកើតក្នុងភូមិទាំងនេះ យ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងន័យនេះ ដើម្បីសម្តែងដល់ភូមិ ដូច្នេះ ។ល។

## អដ្ឋកថាអភិធម្មភាជនីយ ចប់

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ២៣ ] បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិ-សម្ភិទា បដិភាណប្បដិសម្ភិទា ។ បណ្តាបដិសម្ភិទាទាំង ៤ បដិសម្ភិទាជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ២៤ ] បដិសម្ភិទា ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ប្រកបដោយវេទនាជាសុខក៏មាន ប្រកបដោយវេទនាមិនមែនទុក្ខ មិនមែនសុខក៏មាន ។ បដិសម្ភិទា ៣ មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន អត្ថប្បដិសម្ភិទា ជាវិបាកក៏មាន មានវិបាក-ធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ បដិសម្ភិទា ៣ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន អត្ថប្បដិសម្ភិទា មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រ-យោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ បដិសម្ភិទា ៣ ជាធម៌មិនសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង អត្ថប្បដិសម្ភិទា ជាធម៌មិនសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មងក៏មាន ជាធម៌មិនសៅហ្មងទាំងមិនគួរដល់នូវសេចក្តីសៅហ្មងក៏មាន ។ បដិសម្ភិទា ៣ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារ អត្ថប្បដិសម្ភិទា ប្រព្រឹត្ត

ទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។ បដិសម្ភិទា កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក៏មាន ។ បដិសម្ភិទា ៣ ដល់នូវការសន្សំកពូនឡើង ( ដោយកម្មកិលេស ) ក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន អត្ថប្បសម្ភិទា ដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ។ បដិសម្ភិទា ៣ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល អត្ថប្បដិសម្ភិទា ជារបស់សេក្ខបុគ្គលក៏មាន មិនមែនជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ។ បដិសម្ភិទា ៣ មានសភាពតូចឆ្មារ អត្ថប្បដិសម្ភិទា មានសភាពតូចឆ្មារក៏មាន ប្រមាណមិនបានក៏មាន ។ និរុត្តិប្បដិសម្ភិទា មានអារម្មណ៍តូចឆ្មារ បដិសម្ភិទា ៣ មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ។ បដិសម្ភិទា ៣ ជាកណ្តាល អត្ថប្បដិសម្ភិទា ជាកណ្តាលក៏មាន ឧត្តមក៏មាន ។ បដិសម្ភិទា ៣ មានសភាពមិនទៀង អត្ថប្បដិសម្ភិទា មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន ។ និរុត្តិប្បសម្ភិទា មិនគួរ

ពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងឡើយ អត្ថប្បដិសម្ភិទា មិនមានមគ្គអារម្មណ៍ទេ តែមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន បដិសម្ភិទា ២ មានមគ្គជាអារម្មណ៍ តែមិនមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាអធិបតីផងក៏មាន ។ បដិសម្ភិទា ៣ កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន មិនគួរពោលថា បម្រុងនឹងកើតឡើងទេ អត្ថប្បដិសម្ភិទា កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន បម្រុងនឹងកើតឡើងក៏មាន ។ បដិសម្ភិទា ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។ និរុត្តិប្បដិសម្ភិទា មានអារម្មណ៍ជាបច្ចុប្បន្ន បដិសម្ភិទា ២ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអា-រម្មណ៍ជាបច្ចុប្បន្នក៏មាន អត្ថប្បដិសម្ភិទា មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ។ បដិសម្ភិទា ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន ។ និរុត្តិប្បដិសម្ភិទា មានអារម្មណ៍ខាងក្រៅ បដិសម្ភិទា ៣ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។ បដិសម្ភិទាមិនប្រកបដោយ ការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

[ ២៥ ] បដិសម្ភិទាទាំងឡាយ ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាហេតុផង ប្រកបដោយហេតុផង មិនគួរពោលថា មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាមិនមែនជាហេតុ ទាំងមិនមានហេតុផងឡើយ ។ បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប បដិសម្ភិទា ៣ ជាលោកិយ អត្ថប្បដិសម្ភិទា ជាលោកិយក៏មាន ជាលោកុត្តរក៏មាន បុគ្គលគប្បីដឹងច្បាស់ដោយវិញ្ញាណណាមួយ មិនគប្បីដឹងច្បាស់ដោយវិញ្ញាណណាមួយ ។

[ ២៦ ] បដិសម្ភិទាទាំងឡាយ មិនមែនអាសវៈ ។ បដិសម្ភិទា ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ អត្ថប្បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ បដិសម្ភិទាទាំងឡាយ ប្រាសចាកអាសវៈ ។ បដិសម្ភិទា ៣ មិនគួរពោលថាជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈឡើយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈទេ អត្ថប្បដិសម្ភិទា មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈក៏មាន មិនគួរពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈក៏មាន ។ បដិសម្ភិទាទាំងឡាយ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ ។ បដិសម្ភិទា

៣ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ អត្ថប្បដិសម្ភិទា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈទាំងមិនមានអាសវៈក៏មាន ។

[ ២៧ ] បដិសម្ភិទាទាំងឡាយ មិនមែនសញ្ញោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ប្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ប្រឡំ ទាំងតាំងឡើងដោយចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ។ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។

[ ២៨ ] បដិសម្ភិទាទាំងឡាយ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មានហេតុ មិនគួរលះដោយភាវនា ។ បដិសម្ភិទា ៣ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក អត្ថប្បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ។ បដិសម្ភិទា ៣ ប្រព្រឹត្តទៅជាមួយនឹងវិចារ អត្ថប្បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន ។ បដិសម្ភិទាទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន ប្រឡំដោយបីតិក៏មាន មិនប្រឡំដោយបីតិក៏

មាន ប្រទូ្បំដោយសុខក៏មាន មិនប្រទូ្បំដោយសុខក៏មាន ប្រទូ្បំដោយឧបេក្ខាក៏មាន មិនប្រទូ្បំដោយឧបេក្ខាក៏មាន ។ បដិសម្ភិទា ៣ ជាកាមាវចរ អត្ថប្បដិសម្ភិទា ជាកាមាវចរក៏មាន មិនមែនជាកាមាវចរក៏មាន ។ បដិសម្ភិទាទាំងឡាយ មិនមែនជារូបាវចរ មិនមែនអរូបាវចរ ។ បដិសម្ភិទា ៣ ជាបរិយាបន្ន អត្ថប្បដិសម្ភិទា ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ បដិសម្ភិទា ៣ ជាអនិយ្យានិកៈ អត្ថប្បដិសម្ភិទា ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ។ បដិសម្ភិទា ៣ មានសភាពមិនទៀង អត្ថប្បដិសម្ភិទា មានសភាពទៀងក៏មាន មានសភាពមិនទៀងក៏មាន ។ បដិសម្ភិទា ៣ ប្រកបដោយឧត្តរៈ ( ការរើខ្ជួន ) អត្ថប្បដិសម្ភិទា ប្រកបដោយឧត្តរៈក៏មាន មិនមានឧត្តរៈក៏មាន ។ បដិសម្ភិទាទាំងឡាយ មិនមានសត្រូវទេ ។

**បញ្ហាបុច្ឆកៈ ចប់**

**បដិសម្ភិទាវិភង្គ ចប់**

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ២៣-២៨ ] ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបភាពដែលបដិសម្ភិទា ៤ ជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ តែក្នុងអារម្ម-ណត្តិកៈទាំងឡាយ និរុត្តិប្បដិសម្ភិទា ធ្វើសំឡេងប៉ុណ្ណោះ ឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ទើបជាបរិត្តារម្មណៈ ។

អត្ថប្បដិសម្ភិទា កាលពិចារណាអត្ថ ពោល គឺកាមាវចរវិបាក និង កាមាវចរកិរិយា និងអត្ថដែលអាស្រ័យបច្ច័យកើតឡើងជាបរិត្តារម្មណៈ កាល ពិចារណាអត្ថនៃរូបាវចរ និងអរូបាវចរ មានប្រភេទតាមដែលពោលហើយនោះ ជាមហគ្គតារម្មណៈ កាលពិចារណាអត្ថនៃលោកុត្តរវិបាក និងព្រះនិព្វានដែល ជាបរមត្ថ ជាអប្បមាណារម្មណៈ ។

ធម្មប្បដិសម្ភិទា កាលពិចារណាកាមាវចរកុសលធម៌ កាមាវចរអកុ-សលធម៌ និងធម៌ដែលជាបច្ច័យ ជាបរិត្តារម្មណៈ កាលពិចារណាកុសលធម៌ ដែលជារូបាវចរ អរូបាវចរ និងធម៌ដែលជាបច្ច័យ ជាមហគ្គតារម្មណៈ កាល ពិចារណាកុសលធម៌ដែលជាលោកុត្តរ និងធម៌ដែលជាបច្ច័យ ជាអប្ប-មាណារម្មណៈ ។

បដិភាណប្បដិសម្ភិទា កាលពិចារណាញាណ ក្នុងកាមាវចរកុសល កាមាវចរវិបាក និងកាមាវចរកិរិយា ជាបរិត្តារម្មណៈ កាលពិចារណាញាណក្នុង កុសល វិបាក និងកិរិយាដែលជារូបាវចរ និងអរូបាវចរ ដឹងអារម្មណ៍ទាំង

ឡាយ របស់ញាណទាំងនោះ ជាមហគ្គតារម្មណៈ កាលពិចារណាញាណក្នុងកុសល និងវិបាកដែលជាលោកុត្តរ ជាអប្បមាណារម្មណៈ ។

អត្ថប្បដិសម្ភិទា ជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុក៏មានជាមគ្គាធិបតីដោយការចម្រើនមគ្គ មានវិរិយៈជាប្រធាន មិនគប្បីពោលថាជាមគ្គាធិបតីដោយការចម្រើនមគ្គ ដែលមានឆន្ទៈ និងចិត្តជាប្រធានក្នុងកាលនៃផល ក៏មិនគប្បីពោលនោះឯង ។

ធម្មប្បដិសម្ភិទា ជាមគ្គារម្មណៈក្នុងកាលពិចារណាមគ្គ កាលពិចារណាធ្វើមគ្គឲ្យជាធំ ជាមគ្គាធិបតីដោយអំណាចអារម្មណាធិបតី ។

បដិភាណប្បដិសម្ភិទា ជាមគ្គារម្មណៈក្នុងកាលពិចារណាញាណក្នុងមគ្គ កាលពិចារណាធ្វើមគ្គឲ្យជាធំ ជាមគ្គាធិបតី ជានវត្តព្វារម្មណៈក្នុងកាលពិចារណាញាណដ៏សេស ។

និរុត្តិប្បដិសម្ភិទា ធ្វើសំឡេងដែលជាបច្ចុប្បន្ននោះឯង ឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ទើបជាបច្ចុប្បន្នារម្មណៈ ។

អត្ថប្បដិសម្ភិទា កាលពិចារណាអត្ថនៃវិបាក អត្ថនៃកិរិយា និងអត្ថដែលអាស្រ័យបច្ច័យកើតឡើងដែលជាអតីត ជាអតីតារម្មណៈ កាលពិចារណាអត្ថទាំងនោះដែលជាអនាគត ជាអនាគតារម្មណៈ កាលពិចារណាអត្ថទាំងនោះដែលជាបច្ចុប្បន្ន ជាបច្ចុប្បន្នារម្មណៈ ។ កាលពិចារណាបរមត្ថដែលជាលោកុត្តរ ជានវត្តព្វារម្មណៈ ។

ធម្មប្បដិសម្ភិទា កាលបុគ្គលពិចារណាកុសល អកុសល និងធម៌ដែល

ជាបច្ច័យដែលជាអតីត ជាអតីតារម្មណៈ កាលពិចារណាធម៌ទាំងនោះដែល ជាអនាគត ជាអនាគតារម្មណៈ កាលពិចារណាក្នុងបច្ចុប្បន្ន ជាបច្ចុប្បន្នា-រម្មណៈ ។

បដិភាណប្បដិសម្ភិទា កាលពិចារណាកុសលញ្ញាណ វិបាកញ្ញាណ និង កិរិយាញ្ញាណដែលជាអតីត ជាអតីតារម្មណៈ កាលពិចារណាញ្ញាណទាំង នោះដែលជាអនាគត ជាអនាគតារម្មណៈ ។ កាលពិចារណាញ្ញាណទាំងនោះ ដែលជាបច្ចុប្បន្ន ជាបច្ចុប្បន្នារម្មណៈ ។

និរុត្តិប្បដិសម្ភិទា ជាពហិទ្ធារម្មណៈ ព្រោះមានសំឡេងជាអារម្មណ៍ ។ ក្នុងបដិសម្ភិទា ៣ ក្រៅអំពីនេះ អត្ថប្បដិសម្ភិទា កាលពិចារណាអត្ថនៃវិបាក អត្ថនៃកិរិយា និងអត្ថដែលអាស្រ័យបច្ច័យ កើតឡើងខាងក្នុង ជាអជ្ឈត្តា-រម្មណៈ កាលពិចារណាអត្ថទាំងនោះខាងក្រៅ ជាពហិទ្ធារម្មណៈ កាល ពិចារណាអត្ថទាំងខាងក្រៅ ទាំងខាងក្នុង ជាអជ្ឈត្តពហិទ្ធារម្មណៈ កាល ពិចារណាបរមត្ថ ( ព្រះនិព្វាន ) ជាពហិទ្ធារម្មណៈប៉ុណ្ណោះ ។ ធម្មប្បដិ-សម្ភិទាជាអជ្ឈត្តារម្មណៈ ក្នុងកាលពិចារណាកុសល អកុសល និងធម៌ដែល ជាបច្ច័យក្នុងខាងក្នុង ជាពហិទ្ធារម្មណៈ ក្នុងកាលពិចារណាកុសល អកុសល និងធម៌ដែលជាបច្ច័យខាងក្រៅ ជាអជ្ឈត្តពហិទ្ធារម្មណៈ ក្នុងវេលាពិចារណា កុសល អកុសលដែលជាបច្ច័យទាំងខាងក្នុង ទាំងខាងក្រៅ ។ បដិភាណប្ប-ដិសម្ភិទា ក្នុងកាលពិចារណាញ្ញាណ ក្នុងកុសល វិបាក និងកិរិយាខាងក្នុង ជាអជ្ឈត្តារម្មណៈ ក្នុងកាលពិចារណាញ្ញាណក្នុងកុសល វិបាក និងកិរិយាខាង

ក្រៅ ជាពហិទ្ធារម្មណៈ ក្នុងកាលពិចារណាញាណក្នុងកុសល វិបាក និង កិរិយា ទាំងខាងក្នុង ទាំងខាងក្រៅ ជាអជ្ឈត្តពហិទ្ធារម្មណៈ ។

ក្នុងបញ្ហាបុច្ឆកៈនេះ បដិសម្ភិទា ៣ ជាលោកិយ អត្ថប្បដិសម្ភិទាជាលោកិយផង លោកុត្តរផង ។ ពិតហើយ ក្នុងបដិសម្ភិទាវិភង្គនេះ ព្រះសម្មាសម្ពុទ្ធ ត្រាស់ន័យទាំង ៣ គឺសុត្តន្តន័យ អភិធម្មន័យ និងបញ្ហាបុច្ឆកៈជាបរិច្ឆេទតែមួយ ព្រោះបដិសម្ភិទាទាំង ៤ នោះ ជាលោកិយ និងលោកុត្តរ លាយឡំគ្នា ។ ក្នុងន័យទាំង ៣ បណ្ដាបដិសម្ភិទាទាំងនេះ បដិសម្ភិទា ៣ ជាលោកិយ អត្ថប្បដិសម្ភិទាជាលោកិយផង ជាលោកុត្តរផង ហេតុនោះ បដិសម្ភិទាវិភង្គនេះ ព្រះមានព្រះភាគទ្រង់ក៏នាំចេញ គឺចែកសម្ដែងហើយជាបរិវដ្ដ ៣ ដូចពណ៌នាមក ដូច្នេះ ។៚

## បញ្ហាបុច្ឆកៈ ចប់

## អដ្ឋកថាបដិសម្ភិទាវិភង្គ ចប់

# អភិធម្មបិដក

## ញាណវិភង្គ

[ ២៩ ] ញាណវត្ថុ មានប្រការ ១ គឺវិញ្ញាណ ៥ មិនមែនហេតុ មិនមានហេតុ ប្រាសចាកហេតុ ប្រកបដោយបច្ច័យ ត្រូវបច្ច័យប្រជុំតាក់តែង មិនមានរូប ជាលោកិយ ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ដែលគន្ថៈគប្បីដោតក្រង ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ដែលយោគៈគប្បីប្រព្រឹត្តកន្លង ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន គួរដល់នូវសេចក្តីសៅហ្មង ជាអព្យាក្រឹត ប្រកបដោយអារម្មណ៍ មិនមែនចេតសិក ជាវិបាក មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន មិន សៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង មិនប្រកបដោយវិតក្ក តែប្រកបដោយវិចារ មិនមែនមិនមានវិតក្ក មានត្រឹមតែវិចារ មិនមានវិតក្ក ទាំងមិនមានវិចារ មិនកើតព្រមដោយបីតិ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មិនដល់នូវការសន្សំ ( កិលេសវដ្ដៈ ) ទាំងមិនដល់នូវការមិនសន្សំ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល មានសភាពតូចឆ្មារ ជាកាមាវចរ មិនមែនជារូបាវចរ មិនមែនជាអរូបាវចរ ជាបរិយាបន្ន មិនមែនជាអបរិយាបន្ន មិនទៀង មិនមែនជានិយ្យានិកៈ ដែលកើតឡើងហើយ ដែលគួរដឹងដោយមនោវិញ្ញាណ មិនទៀង ដែលត្រូវជរាគ្របសង្កត់ ។ វិញ្ញាណ ៥ មានវត្ថុកើតហើយ មានអារម្មណ៍កើតហើយ

មានវត្ថុកើតហើយក្នុងកាលមុន មានអារម្មណ៍កើតហើយក្នុងកាលមុន មានវត្ថុខាងក្នុង មានអារម្មណ៍ខាងក្រៅ មានវត្ថុមិនប្រឡំគ្នា មានអារម្មណ៍មិនប្រឡំគ្នា មានវត្ថុផ្សេងៗ មានអារម្មណ៍ផ្សេងៗ មិនរងអារម្មណ៍ជាទីគោចរនៃគ្នានិងគ្នាទេ មិនកើតឡើង ព្រោះការមិនប្រមូលមក ( នូវអារម្មណ៍ ) មិនកើតឡើង ព្រោះការមិនធ្វើទុកក្នុងចិត្ត ( នូវអារម្មណ៍ ) មិនកើតឡើង ព្រោះការមិនប្រឡូកប្រឡំ ( ដោយវិញ្ញាណដទៃ ) មិនកើតឡើង មិនមុន មិនក្រោយ មិនកើតឡើងក្នុងលំដាប់នៃគ្នានិងគ្នា វិញ្ញាណ ៥ មិនមានគ្រឿងអាង បុគ្គលបើវៀរចាកការប៉ះពាល់នូវអារម្មណ៍ ក៏មិនដឹងច្បាស់នូវធម៌ណាមួយដោយវិញ្ញាណទាំង ៥ ទាំងមិនដឹងច្បាស់នូវធម៌ណាមួយក្នុងលំដាប់នៃវិញ្ញាណទាំង ៥ មិនសម្រេចឥរិយាបថណាមួយ ដោយវិញ្ញាណទាំង ៥ ទាំងមិនសម្រេចឥរិយាបថណាមួយ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ មិនតាំងផ្តើមកាយកម្ម មិនតាំងផ្តើមវចីកម្មដោយវិញ្ញាណទាំង ៥ ទាំងមិនតាំងផ្តើមកាយកម្ម មិនតាំងផ្តើមវចីកម្មក្នុងលំដាប់នៃវិញ្ញាណទាំង ៥ មិនកាន់យកនូវធម៌ជាកុសល និងអកុសល ដោយវិញ្ញាណទាំង ៥ ទាំងមិនកាន់យកនូវធម៌ជាកុសល និងអកុសល ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ មិនចូលឈាន មិនចេញចាកឈាន ដោយវិញ្ញាណទាំង ៥ ទាំងមិនចូលឈាន មិនចេញចាកឈាន ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ មិនច្យុត មិនកើត ដោយវិញ្ញាណទាំង ៥ ទាំងមិនច្យុត មិនកើតក្នុងលំដាប់នៃវិញ្ញាណទាំង ៥ មិនលក់ មិនភ្ញាក់ មិនឃើញសុបិន ដោយវិញ្ញាណទាំង ៥ ទាំងមិនលក់ មិនភ្ញាក់ មិន

ឃើញសុបិនក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ បញ្ញាជាគ្រឿងសម្តែងនូវវត្ថុតាមលំដាប់នៃមាតិកា ។ ញាណវត្ថុ មានប្រការមួយយ៉ាងនេះឯង ។

[ ៣០ ] ញាណវត្ថុ មាន ២ គឺបញ្ញាជាលោកិយ និងបញ្ញាជាលោកុត្តរ បញ្ញាដែលបុគ្គលគប្បីដឹងដោយញាណណាមួយ និងបញ្ញាដែលបុគ្គលមិនគប្បីដឹងដោយវិញ្ញាណណាមួយ បញ្ញាប្រព្រឹត្តទៅជាមួយនឹងអាសវៈ និងបញ្ញាមិនមានអាសវៈ បញ្ញាប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ និងបញ្ញាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ បញ្ញាជាប្រយោជន៍ដល់សញ្ញោជនៈ និងបញ្ញាមិនជាប្រយោជន៍ដល់សញ្ញោជនៈ បញ្ញាប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ និងបញ្ញាប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ ដល់សញ្ញោជនៈ បញ្ញាដែលគន្ថៈគប្បីដោតក្រង និងបញ្ញាដែលគន្ថៈមិនគប្បីដោតក្រង បញ្ញាប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងនិងបញ្ញាប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រង បញ្ញាដែលឱឃៈគប្បីប្រព្រឹត្តកន្លង និងបញ្ញាដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង បញ្ញាប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លង និងបញ្ញាប្រាសចាកឱឃៈ ទាំងឱឃៈមិនគប្បីប្រព្រឹត្តកន្លង បញ្ញាដែលយោគៈគប្បីប្រព្រឹត្តកន្លង និងបញ្ញាដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង បញ្ញាប្រាសចាកយោគៈ តែយោគៈគប្បីប្រព្រឹត្តកន្លង និងបញ្ញាប្រាសចាកយោគៈ ទាំងយោគៈមិនគប្បីប្រព្រឹត្តកន្លង បញ្ញាជាប្រយោជន៍ដល់នីវរណៈ និងបញ្ញាមិនជាប្រយោជន៍ ដល់នីវរណៈ បញ្ញាប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ និងបញ្ញាប្រាសចាកនីវរណៈ ទាំងមិនជា

ប្រយោជន៍ដល់នីវរណៈ បញ្ញាដែលបរាមាសស្ទាបអង្អែល និងបញ្ញាដែលបរាមាសមិនស្ទាបអង្អែល បញ្ញាប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែល និងបញ្ញាប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែល បញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ និងបញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ បញ្ញាជាប្រយោជន៍ដល់ឧបាទាន និងបញ្ញាមិនជាប្រយោជន៍ដល់ឧបាទាន បញ្ញាប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន និងបញ្ញាប្រាសចាកឧបាទានទាំងមិនជាប្រយោជន៍ដល់ឧបាទាន បញ្ញាគួរដល់សេចក្តីសៅហ្មង និងបញ្ញាមិនគួរដល់សេចក្តីសៅហ្មង បញ្ញាប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តីសៅហ្មង និងបញ្ញាប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង បញ្ញាប្រកបដោយវិតក្ក និងបញ្ញាមិនមានវិតក្ក បញ្ញាប្រកបដោយវិចារ និងបញ្ញាមិនមានវិចារ បញ្ញាប្រកបដោយបីតិ និងបញ្ញាមិនមានបីតិ បញ្ញាកើតព្រមដោយបីតិ និងបញ្ញាមិនកើតព្រមដោយបីតិ បញ្ញាកើតព្រមដោយសុខ និងបញ្ញាមិនកើតព្រមដោយសុខ បញ្ញាកើតព្រមដោយឧបេក្ខា និងបញ្ញាមិនកើតព្រមដោយឧបេក្ខា បញ្ញាជាកាមាវចរ និងបញ្ញាមិនមែនជាកាមាវចរ បញ្ញាជារូបាវចរ និងបញ្ញាមិនមែនជារូបាវចរ បញ្ញាជាអរូបាវចរ និងបញ្ញាមិនមែនជាអរូបាវចរ បញ្ញាជាបរិយាបន្ន និងបញ្ញាជាអបរិយាបន្ន បញ្ញាជានិយ្យានិកៈ និងបញ្ញាជាអនិយ្យានិកៈ បញ្ញាទៀង និងបញ្ញាមិនទៀង បញ្ញាប្រកបដោយឧត្តរៈ និងបញ្ញាមិនមែនជាឧត្តរៈ បញ្ញាញុំាងប្រយោជន៍ឲ្យកើត និងបញ្ញា

មានប្រយោជន៍កើតហើយ ញាណវត្ថុមានប្រការ ២ យ៉ាងនេះឯង ។

[ ៣១ ] ញាណវត្ថុ មាន ៣ គឺចិន្តាមយប្បញ្ញា ( បញ្ញាសម្រេចដោយការគិត ) សុតមយប្បញ្ញា ( បញ្ញាសម្រេចដោយការស្តាប់ ) និងភាវនាមយប្បញ្ញា ( បញ្ញាសម្រេចដោយការចម្រើន ) ទានមយប្បញ្ញា ( បញ្ញាសម្រេចដោយទាន ) សីលមយប្បញ្ញា ( បញ្ញាសម្រេចដោយសីល ) និងភាវនាមយប្បញ្ញា ( បញ្ញាសម្រេចដោយភាវនា ) បញ្ញាក្នុងអធិសីល បញ្ញាក្នុងអធិចិត្ត និងបញ្ញាក្នុងអធិប្បញ្ញា សេចក្តីឈ្លាសក្នុងការចម្រើន សេចក្តីឈ្លាសក្នុងការមិនចម្រើន និងសេចក្តីឈ្លាសក្នុងឧបាយ ។ បញ្ញាជាវិបាក បញ្ញាមានវិបាកធម៌ជាប្រក្រតី និងបញ្ញាមិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី បញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន បញ្ញាដែលប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន និងបញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន បញ្ញាប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ បញ្ញាមិនមានវិតក្ក មានត្រឹមតែវិចារ និងបញ្ញាមិនមានវិតក្ក ទាំងមិនមានវិចារ បញ្ញាកើតព្រមដោយបីតិ បញ្ញាកើតព្រមដោយសុខ និងបញ្ញាកើតព្រមដោយឧបេក្ខា បញ្ញាដល់នូវការសន្សំ ( កម្មកិលេស ) បញ្ញាដល់នូវការមិនសន្សំ ( កម្មកិលេស ) និងបញ្ញាមិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ បញ្ញាជារបស់សេក្ខបុគ្គល បញ្ញាជារបស់

អសេក្ខបុគ្គល និងបញ្ញា មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល បញ្ញាតូចឆ្មារ បញ្ញាមានសភាពធំ និងបញ្ញាមានប្រមាណមិនបាន បញ្ញាមានអារម្មណ៍តូចឆ្មារ បញ្ញាមានអារម្មណ៍ដល់នូវសភាពធំ និងបញ្ញាមានអារម្មណ៍មានប្រមាណមិនបាន បញ្ញាមានមគ្គជាអារម្មណ៍ បញ្ញាមានមគ្គជាហេតុ និងបញ្ញាមានមគ្គជាអធិបតី បញ្ញាដែលកើតឡើងហើយ បញ្ញាដែលមិនទាន់កើតឡើង និងបញ្ញាដែលប្រុងនឹងកើតឡើង បញ្ញាជាអតីត បញ្ញាជាអនាគត និងបញ្ញាជាបច្ចុប្បន្ន បញ្ញាមានអារម្មណ៍ជាអតីត បញ្ញាមានអារម្មណ៍ជាអនាគត និងបញ្ញាមានអារម្មណ៍ជាបច្ចុប្បន្ន បញ្ញាជាខាងក្នុង បញ្ញាជាខាងក្រៅ និងបញ្ញាជាខាងក្នុង និងខាងក្រៅ បញ្ញាមានអារម្មណ៍ខាងក្នុងបញ្ញាមានអារម្មណ៍ខាងក្រៅ និងបញ្ញាមានអារម្មណ៍ខាងក្នុង និងខាងក្រៅ ។ បញ្ញាប្រកបដោយវិតក្ក និងប្រកបដោយវិចារជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន ដល់នូវការសន្សំ ( កម្មកិលេស ) ក៏មាន ដល់នូវការមិនសន្សំក៏មាន មិនមែនដល់នូវការសន្សំ ទាំងមិនដល់នូវ

ការមិនសន្សំក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន មានសភាពតូចថោកក៏មាន ដល់នូវសភាពធំក៏មាន មានប្រមាណមិនបានក៏មាន មានអារម្មណ៍តូចថោកក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន ដែលកើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន មានអារម្មណ៍ជាខាងក្នុងក៏មាន មានអារម្មណ៍ជាខាងក្រៅក៏មាន មានអារម្មណ៍ជាខាងក្នុង និងខាងក្រៅក៏មាន ។ បញ្ញាមិនមានវិតក្ក មានត្រឹមតែវិចារ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ ជាប្រក្រតីក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ដល់នូវការសន្សំ ( កម្មក្កិលេស ) ក៏មាន ដល់នូវការមិនសន្សំក៏មាន មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំក៏មាន ជារបស់

សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខ-បុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន បម្រុងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុងនិងខាងក្រៅក៏មាន ។ បញ្ញាមិនមានវិតក្ក មិនមានវិចារ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន ដល់នូវការសន្សំ ( កម្មកិលេស ) ក៏មាន ដល់នូវការមិនសន្សំក៏មាន ដល់នូវការមិនសន្សំ ទាំងមិនដល់នូវការមិនសន្សំក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល និងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន មានអារម្មណ៍តូចថ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន បម្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏

មាន មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន មានអារម្មណ៍ជាខាងក្នុងក៏មាន មានអារម្មណ៍ជាខាងក្រៅក៏មាន មានអារម្មណ៍ជាខាងក្នុង និងខាងក្រៅក៏មាន ។ បញ្ញាកើតព្រមដោយបីតិ បញ្ញាកើតព្រមដោយសុខជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រកបដោយវិតក្ក ប្រកបដោយវិចារក៏មាន មិនមានវិតក្កមានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ដល់នូវការសន្សំក៏មាន ដល់នូវការមិនសន្សំក៏មាន មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន មានសភាពតូចថ្មារក៏មាន ដល់នូវសភាពធំក៏មាន មានប្រមាណមិនបានក៏មាន មានអារម្មណ៍តូចថ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន កើតឡើងហើយក៏មាន មិនទាន់កើត

ឡើងក៏មាន បម្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន មានអារម្មណ៍ជាខាងក្នុងក៏មាន មានអារម្មណ៍ជាខាងក្រៅក៏មាន មានអារម្មណ៍ជាខាងក្នុង និងខាងក្រៅក៏មាន ។ បញ្ញាកើតព្រមដោយឧបេក្ខាជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ដល់នូវការសៅហ្មងក៏មាន ដល់នូវការមិនសៅហ្មងក៏មាន មិនដល់នូវការសៅហ្មង ទាំងមិនដល់នូវការមិនសៅហ្មងក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន មានសភាពតូចឆ្មារក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន បម្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន

ជាបច្ចុប្បន្នក៏មាន មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន មានអារម្មណ៍ជាខាងក្នុងក៏មាន មានអារម្មណ៍ជាខាងក្រៅក៏មាន មានអារម្មណ៍ជាខាងក្នុង និងខាងក្រៅក៏មាន ។ ញាណវត្ថុ មានប្រការ ៣ យ៉ាងនេះឯង ។

[ ៣២ ] ញាណវត្ថុ មាន ៤ គឺកម្មស្សកតញ្ញាណ ( សេចក្តីដឹងថាសត្វមានកម្មជារបស់ខ្លួន ) សច្ចានុលោមិកញ្ញាណ ( សេចក្តីដឹងប្រព្រឹត្តទៅតាមសច្ចៈ ៤ ) ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយផល សេចក្តីដឹងក្នុងទុក្ខ សេចក្តីដឹងក្នុងហេតុដែលនាំឲ្យកើតទុក្ខ សេចក្តីដឹងក្នុងការរលត់នៃទុក្ខ សេចក្តីដឹងក្នុងបដិបទាជាដំណើរដល់នូវការរលត់នៃទុក្ខ បញ្ញាជាកាមាវចរ បញ្ញាជារូបាវចរ បញ្ញាជាអរូបាវចរ បញ្ញាជាអបរិយាបន្ន សេចក្តីដឹងក្នុងធម៌ សេចក្តីដឹងក្នុងការប្រព្រឹត្តទៅតាមសេចក្តីដឹងក្នុងការកំណត់ សេចក្តីដឹងក្នុងការសន្មត បញ្ញាក្នុងការសន្សំ ( កម្មកិលេស ) មិនមែនក្នុងការមិនសន្សំក៏មាន បញ្ញាក្នុងការមិនសន្សំ មិនមែនក្នុងការសន្សំក៏មាន បញ្ញាក្នុងការសន្សំផង ក្នុងការមិនសន្សំផងក៏មាន បញ្ញាមិនមែនក្នុងការសន្សំ ទាំងមិនមែនក្នុងការមិនសន្សំក៏មាន បញ្ញាក្នុងសេចក្តីនឿយណាយ មិនមែនក្នុងការត្រាស់ដឹងក៏មាន បញ្ញាក្នុងការត្រាស់ដឹង មិនមែនក្នុងសេចក្តីនឿយណាយក៏មាន បញ្ញាក្នុងសេចក្តីនឿយណាយផង ក្នុងការត្រាស់ដឹងផងក៏មាន បញ្ញាមិនមែនក្នុងសេចក្តីនឿយ

ណាយ មិនមែនក្នុងការត្រាស់ដឹងក៏មាន បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ បញ្ញាមានចំណែកនៃការតាំងនៅ បញ្ញាមានចំណែកនៃសេចក្តីវិសេស បញ្ញាមានចំណែកនៃសេចក្តីនឿយណាយ បដិសម្ភិទា ៤ បដិបទា ៤ អារម្មណ៍ ៤ សេចក្តីដឹងក្នុងជរា និងមរណៈ សេចក្តីដឹងក្នុងការកើតឡើងនៃជរា និងមរណៈ សេចក្តីដឹងក្នុងការរលត់នៃជរា និងមរណៈ សេចក្តីដឹងក្នុងបដិបទាជាដំណើរដល់នូវការរលត់នៃជរា និងមរណៈ សេចក្តីដឹងក្នុងជាតិ ។បេ។ សេចក្តីដឹងក្នុងភព ។បេ។ សេចក្តីដឹងក្នុងឧបាទាន ។បេ។ សេចក្តីដឹងក្នុងតណ្ហា ។បេ។ សេចក្តីដឹងក្នុងវេទនា ។បេ។ សេចក្តីដឹងក្នុងផស្សៈ ។បេ។ សេចក្តីដឹងក្នុងសឡាយតនៈ ។បេ។ សេចក្តីដឹងក្នុងនាមរូប ។បេ។ សេចក្តីដឹងក្នុងវិញ្ញាណ ។បេ។ សេចក្តីដឹងក្នុងសង្ខារទាំងឡាយ សេចក្តីដឹងក្នុងការកើតឡើងនៃសង្ខារ សេចក្តីដឹងក្នុងការរលត់នៃសង្ខារ សេចក្តីដឹងក្នុងបដិបទាជាដំណើរដល់នូវការរលត់នៃសង្ខារ ញាណវត្ថុមានប្រការ ៤ យ៉ាងនេះឯង ។

[ ៣៣ ] ញាណវត្ថុ មាន ៥ គឺសម្មាសមាធិ ប្រកបដោយអង្គ ៥ សម្មាសមាធិ ប្រកបដោយញាណ ៥ ញាណវត្ថុ មានប្រការ ៥ យ៉ាងនេះឯង ។ ញាណវត្ថុ មាន ៦ គឺបញ្ញាក្នុងអភិញ្ញា ៦ ញាណវត្ថុ មានប្រការ ៦ យ៉ាងនេះឯង ។ ញាណវត្ថុ មាន ៧ គឺញាណវត្ថុ ៧៧ ញាណវត្ថុ មានប្រការ ៧ យ៉ាងនេះឯង ។ ញាណវត្ថុ មាន ៨ គឺបញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ញាណវត្ថុ មានប្រការ ៨ យ៉ាងនេះឯង ។ ញាណវត្ថុ មាន

៩ គឺបញ្ញាក្នុងអនុបុព្វវិហារសមាបត្តិ ៩ ញាណវត្ថុ មានប្រការ ៩ យ៉ាង នេះឯង ។

[ ៣៤ ] ញាណវត្ថុ មាន ១០ បានដល់ តថាគតពល ១០ របស់ព្រះតថាគតជាពល ដែលព្រះតថាគតបានប្រកបហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ ពល ១០ ដូចម្ដេចខ្លះ ។ ព្រះតថាគតក្នុងលោកនេះ ជ្រាបច្បាស់តាមពិតនូវហេតុ ថាជាហេតុផង ជ្រាបច្បាស់តាមពិតនូវអំពើមិនមែនហេតុ ថាជាអំពើមិនមែនហេតុផង នេះឯងជាតថាគតពល ( ទី ១ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគតអាស្រ័យហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគតជ្រាបច្បាស់តាមពិតនូវវិបាកនៃកម្មសមាទាន ( ការកាន់យកកម្មជាកុសល ) ជាអតីត អនាគត និងបច្ចុប្បន្នតាមបច្ច័យ តាមហេតុ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវវិបាកនៃកម្មសមាទានជាអតីត អនាគត និងបច្ចុប្បន្នតាមបច្ច័យ តាមហេតុ នេះឯងជាតថាគតពល ( ទី ២ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគតអាស្រ័យហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគតជ្រាបច្បាស់តាមពិតនូវបដិបទាជាដំណើរទៅ ( កាន់សុគតិ និងទុគ្គតិ ) ក្នុងទីទាំងពួង ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវបដិបទាជាដំណើរ

ទៅកាន់សុគតិ និងទុគ្គតិ ក្នុងទីទាំងពួង នេះឯងជាតថាគតពល ( ទី ៣ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគតអាស្រ័យហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគតជ្រាបច្បាស់តាមពិតនូវលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗ គ្នា ត្រង់ដែលតថាគតជ្រាបច្បាស់តាមពិតនូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗ គ្នា នេះឯងជាតថាគតពល ( ទី ៤ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគត អាស្រ័យហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទ ក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគត ជ្រាបច្បាស់តាមពិតនូវអធ្យាស្រ័យផ្សេងៗ គ្នា របស់សត្វទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវអធ្យាស្រ័យផ្សេងៗ គ្នា របស់សត្វទាំងឡាយ នេះឯងជាតថាគតពល ( ទី ៥ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគតអាស្រ័យហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគត ជ្រាបច្បាស់តាមពិតនូវឥន្ទ្រិយចាស់ក្លា និងទន់របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវឥន្ទ្រិយចាស់ក្លា និងទន់របស់ពួកសត្វដទៃ របស់បុគ្គលដទៃ នេះឯងជាតថាគតពល ( ទី ៦ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគតអាស្រ័យហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យ

ប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគតជ្រាបច្បាស់តាមពិតនូវសេចក្តីសៅហ្មងនូវសេចក្តីផូរផង់ នូវការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ នេះឯងជាតថាគតពល ( ទី ៧ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគតជ្រាបច្បាស់តាមពិតនូវការរឭកជាតិ ដែលនៅអាស្រ័យក្នុងភពមុន ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវការរឭកជាតិ ដែលបាននៅអាស្រ័យក្នុងភពមុន នេះឯងជាតថាគតពល ( ទី ៨ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគតជ្រាបច្បាស់តាមពិតនូវការច្យុតិ និងការកើត របស់សត្វទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវការច្យុតិ និងការកើត របស់សត្វទាំងឡាយ នេះឯងជាតថាគតពល ( ទី ៩ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្កដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅ ។ មួយវិញទៀត ព្រះតថាគតជ្រាបច្បាស់តាមពិតនូវការអស់នៃអាសវៈទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវការអស់នៃអាសវៈទាំងឡាយ នេះឯង

ជាតថាគតពល ( ទី ១០ ) របស់ព្រះតថាគត ជាពលដែលព្រះតថាគត អាស្រ័យហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិ-ស័ទ ទើបញុំាងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ តថាគតពលទាំង ១០ នេះ របស់ព្រះតថាគត ជាពលដែលព្រះតថាគតប្រកបហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទ ក្នុងពួកបរិស័ទ ទើបញុំាងចក្កដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅ ញាណវត្ថុមានប្រការ ១០ យ៉ាងនេះឯង ។

## មាតិកា ចប់

# អដ្ឋកថា

## ញាណវិភង្គ

### ឯកកមាតិកាជាដើម

[ ២៩-៣៤ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់តាំងមាតិកាក្នុងញាណវិភង្គ ក្នុងលំដាប់នៃបដិសម្ភិទាវិភង្គនោះ ដោយបរិច្ឆេទទាំង ១០ ដែលមានមាតិកាពួក ១ ជាដើម មានមាតិកាពួក ១០ ជាបរិយោសាន ដោយន័យមានពាក្យជាដើមថា **ឯកវិធេន ញាណវត្ថុ** ដូច្នេះហើយ ទ្រង់ធ្វើអធិប្បាយដោយលំដាប់នៃបទទាំងឡាយដែលទ្រង់តាំងទុក ។

បណ្ដាបទទាំងនោះ បទថា **ឯកវិធេន** បានដល់ ដោយប្រការមួយ ឬដោយចំណែកមួយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ញាណវត្ថុ** នេះ ឈ្មោះថា **ញាណវត្ថុ** ព្រោះអត្ថថា ញាណនោះផង វត្ថុនោះផង មានដល់សម្បត្តិទាំងឡាយ មានប្រការផ្សេងៗ ។ ឈ្មោះថា **ញាណវត្ថុ** ព្រោះអត្ថថា ជាទីតាំង តែក្នុងទីនេះ គប្បីជ្រាបថាជា **ញាណវត្ថុ** ដោយអត្ថមុននោះឯង ។ ដោយហេតុនោះឯង ក្នុងទីបំផុតនៃការកំណត់ញាណវត្ថុពួក ១ ទើបព្រះមានព្រះភាគត្រាស់ថា **យាថាវកវត្ថុវិភាវនា បញ្ញា ឯវំ ឯកវិធេន ញាណវត្ថុ** ដូច្នេះ បញ្ញាជាគ្រឿងសម្ដែងនូវវត្ថុ តាមលំដាប់នៃមាតិកា ។ ញាណវត្ថុមានប្រការ ១ យ៉ាងនេះឯង ។

បទថា **បញ្ច វិញ្ញាណា** បានដល់ វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម ។ បណ្ឌិតគប្បីជ្រាបបទទាំងឡាយ មានបទថា **ន ហេតុ** ជាដើម

ដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាធម្មសង្គណីខាងដើមនោះឯង តែបើពោលដោយសង្ខេបហើយ ពាក្យណាដែលគប្បីពោលក្នុងទីនេះ ពាក្យនោះជាក់ច្បាស់ក្នុងនិទ្ទេសវារ ។

ម្យ៉ាងទៀត ក្នុងមាតិកាញាណវត្ថុពួក ១ នេះ យ៉ាងណា សូម្បីក្នុងបទទុកមាតិកាជាដើមក៏យ៉ាងនោះ គឺបើពាក្យណាដែលខ្ញុំគប្បីពោល ពាក្យនោះ ក៏នឹងជាក់ច្បាស់ក្នុងនិទ្ទេសវារនោះឯង ។ បណ្ឌិតគប្បីជ្រាបត្រឹមតែការកំណត់មាតិកាយ៉ាងនេះ ក្នុងមាតិកានៃញាណវិភង្គនេះ ។ ពិតហើយ ក្នុងញាណវិភង្គនេះ ព្រះមានព្រះភាគទ្រង់តាំងឯកមាតិកាដោយសង្ខេប ជា ២ ចំណែក គឺដោយបទថា **ន ហេតុ អហេតុកា** ជាដើមមុន ដោយអំណាចធម្មសង្គហមាតិកា ដោយបទថា **អនិច្ចា ជរាភិភូតា** ជាដើម ដោយអំណាចធម៌មិនមែនមាតិកា និងដោយចែកដោយបទទាំងឡាយ ៧៨ បទ ។ ម្យ៉ាងទៀត ទ្រង់តាំងមាតិកាដោយពួក ២ ចំនួន ៣៥ ទុកៈ ដែលសមគួរដល់ធម៌ពួក ២ ។

ទ្រង់តាំងតិកមាតិកាក្នុងតិកៈ ៨៨ តិកៈ ដែលសមគួរដល់ធម៌ពួក ៣ គឺដោយពាហិរត្តិកៈ ៤ តិកៈ មានបទថា **ចិន្តាមយា បញ្ញា** ជាដើម ដោយតិកមាតិកា ១៤ តិកៈ ដែលត្រាស់ដោយអំណាចនៃបញ្ញាដែលមិនពិតប្រាកដ មានបទថា **វិបាកា បញ្ញា** ជាដើម ដោយតិកមាតិកា ១៣ តិកៈ ដែលត្រាស់ដោយអំណាចនៃបញ្ញាដែលពិតប្រាកដ ដែលជាបទទី ១ ក្នុងវិតក្កត្តិកៈដោយតិកមាតិកា ៧ តិកៈ ដែលត្រាស់ដោយអំណាចនៃបញ្ញា

ដែលពិតប្រាកដ ដែលជាបទទី ២ ដោយតិកមាតិកា ១២ តិកៈ ដែលត្រាស់ដោយអំណាចនៃបញ្ញាដែលពិតប្រាកដ ដែលជាបទទី ៣ ដោយតិកមាតិកា ១៣ តិកៈ ដែលត្រាស់ដោយអំណាចនៃបញ្ញាដែលពិតប្រាកដ ដែលជាបទទី ១ ក្នុងបីតិត្តិកៈ ដោយបទទី ២ ( សុគហគតៈ ) ក៏ដូចគ្នា ( គឺមាន ១៣ តិកៈ ) ដោយតិកមាតិកា ១២ តិកៈ ដែលត្រាស់ដោយអំណាចនៃបញ្ញាដែលពិតប្រាកដ ដែលជាបទទី ៣ ក្នុងបីតិត្តិកៈនោះឯង ។

ម្យ៉ាងទៀត ទ្រង់តាំងចតុក្កមាតិកាដោយចតុក្កៈ ២១ ចតុក្កៈ មានពាក្យថា កម្មស្សកតញ្ញាណជាដើម ។

ទ្រង់តាំងបញ្ចកមាតិកា ២ បញ្ចកៈ ។ ទ្រង់តាំងឆក្កមាតិកា ១ ឆក្កៈ ។ ទ្រង់តាំងសត្តកមាតិកា ១១ សត្តកៈ ដែលត្រាស់ដោយសង្ខេបយ៉ាងនេះថា **សត្តសត្តតិ ញាណវត្ថុ** ញាណវត្ថុ ៧៧ ដូច្នេះ ។ ទ្រង់តាំងអដ្ឋកមាតិកា ១ អដ្ឋកៈ ។ ទ្រង់តាំងនវកមាតិកា ១ នវក ។

## ទសកមាតិកា

ទ្រង់តាំងទសកមាតិកា ១ ទសកៈប៉ុណ្ណោះ មានបទថា **ទស តថាគតស្ស តថាគតពលានិ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ទស** ជាបទកំណត់ចំនួន ។ បទថា **តថាគតស្ស** បានដល់ ឥសីទាំងឡាយក្នុងកាលមុន មានព្រះពុទ្ធព្រះនាមវិបស្សីជាដើម យាងមកហើយ

យ៉ាងណា ព្រះតថាគតអង្គនេះ ក៏យាងមកហើយយ៉ាងនោះ ។ ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយអង្គនោះយាងទៅហើយ យ៉ាងណា ព្រះតថាគតអង្គនេះ ក៏យាងទៅហើយ យ៉ាងនោះ ។ បទថា **តថាគតពលានិ** បានដល់ កម្លាំងមិនទូទៅដល់ជនពួកដទៃ គឺមានចំពោះព្រះតថាគតប៉ុណ្ណោះ ។ ម្យ៉ាងទៀត អធិប្បាយថា កម្លាំងទាំងឡាយរបស់ព្រះពុទ្ធក្នុងកាលមុនមកហើយ ដោយឧបនិស្សយសម្បត្តិ គឺបុណ្យ យ៉ាងណា សូម្បីកម្លាំងនៃព្រះតថាគតអង្គនេះ ក៏យាងមកហើយយ៉ាងនោះ ។

កម្លាំងរបស់ព្រះតថាគតក្នុងទីនេះ មាន ២ យ៉ាង គឺកម្លាំងកាយ ១ កម្លាំងញាណ ១ ។

ក្នុងកម្លាំង ២ យ៉ាងនោះ បណ្ឌិតគប្បីជ្រាបកម្លាំងកាយរបស់ព្រះតថាគត ដោយទំនងនៃត្រកូលដំរីនោះឯង ។

## កម្លាំងកាយរបស់ព្រះតថាគត

សមដូចបោរាណាចារ្យពោលថា ត្រកូលនៃដំរីទាំងឡាយ ១០ គឺ

ត្រកូលនៃដំរីឈ្មោះកាឡាវកៈ ១ ត្រកូលនៃដំរីឈ្មោះគង្គេយ្យៈ ១ ត្រកូលនៃដំរីឈ្មោះបណ្ឌរៈ ១ ត្រកូលនៃដំរីឈ្មោះតម្ពៈ ១ ត្រកូលនៃដំរីឈ្មោះបិង្គលៈ ១ ត្រកូលនៃដំរីឈ្មោះគន្ធៈ ១ ត្រកូលនៃដំរីឈ្មោះមង្គលៈ ១ ត្រកូលនៃដំរីឈ្មោះហេមៈ ១ ត្រកូលនៃដំរីឈ្មោះឧបោសថ ១ ត្រកូលនៃដំរីឈ្មោះឆទ្ទន្ត ១ ។

បណ្ដាត្រកូលដំរីទាំងនោះ ត្រកូលដំរីឈ្មោះកាឡាវកៈ បណ្ឌិតគប្បីជ្រាប ថា ជាត្រកូលដំរីធម្មតា ។

កម្លាំងបុរស ១០ នាក់ ស្មើនឹងកម្លាំងដំរីកាឡាវកៈ ១ កម្លាំងដំរីកាឡាវកៈ ១០ ស្មើនឹងកម្លាំងដំរីគង្គេយ្យៈ ១ កម្លាំងដំរីគង្គេយ្យៈ ១០ ស្មើនឹងកម្លាំងដំរីបណ្ឌរៈ ១ កម្លាំងដំរីបណ្ឌរៈ ១០ ស្មើនឹងកម្លាំងដំរីតម្ពៈ ១ កម្លាំងដំរីតម្ពៈ ១០ ស្មើនឹងកម្លាំងដំរីបិង្គលៈ ១ កម្លាំងដំរីបិង្គលៈ ១០ ស្មើនឹងកម្លាំងដំរីគន្ធៈ ១ កម្លាំងដំរីគន្ធៈ ១០ ស្មើនឹងកម្លាំងដំរីមង្គលៈ ១ កម្លាំងដំរីមង្គលៈ ១០ ស្មើនឹងកម្លាំងដំរីហេមៈ ១ កម្លាំងដំរីហេមៈ ១០ ស្មើនឹងកម្លាំងដំរីឧបោសថ ១ កម្លាំងដំរីឧបោសថ ១០ ស្មើនឹងកម្លាំងដំរីឆទ្ទន្ត ១ កម្លាំងដំរីឆទ្ទន្ត ១០ ស្មើនឹងកម្លាំងព្រះតថាគតមួយអង្គ ។

កម្លាំងនោះឯង លោកហៅថា កម្លាំងរបស់ព្រះនារាយណ៍ដូច្នេះក៏មាន ។ កម្លាំងរបស់ព្រះតថាគតនោះ ស្មើគ្នានឹងកម្លាំងរបស់ដំរីធម្មតា ១០០០ កោដិ និងស្មើគ្នាជាមួយកម្លាំងរបស់បុរស ១០០០០ កោដិ ។ នេះជាកម្លាំងរបស់ព្រះតថាគត មានប្រមាណប៉ុណ្ណេះ ។

កម្លាំងញាណនេះ គឺទសពលញ្ញាណ ដែលមកហើយក្នុងព្រះបាលីនេះមុននោះឯង ញាណរបស់ព្រះសាស្ដា រាប់ពាន់មិនមែនតិចដទៃទៀត យ៉ាងនេះ គឺទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ អកម្បនញ្ញាណ គឺញាណដែលមិនញាប់ញ័រក្នុងបរិស័ទ ៨ ញាណដែលកំណត់ដឹងកំណើត ៤ ញាណដែលកំណត់ដឹងគតិ ៥ ដែលមកហើយក្នុងមហាសីហនាទសូត្រ ញាណ

៧៣ ដែលមកហើយក្នុងសំយុត្តនិកាយ ញាណទាំងឡាយមាន ៧៧ យ៉ាង ដោយប្រការដូច្នេះ នេះឈ្មោះថា ញាណពល ។ ញាណពលប៉ុណ្ណោះ លោកបំណងយកក្នុងទីនេះ ។ ពិតហើយ **ញាណ** ព្រះមានព្រះភាគត្រាស់ហៅថា កម្លាំង ព្រោះអត្ថថា ជាការៈដែលមិនញាប់ញ័រ និងព្រោះអត្ថថា ជាការឧបត្ថម្ភ ។

បទថា **យេហិ ពលេហិ សមន្នាគតោ** បានដល់ ព្រះតថាគតនោះ ទ្រង់ចូលដល់ហើយ ចូលដល់ដោយល្អ ដោយកម្លាំងនៃព្រះញាណ ១០ ណា ។

បទថា **អាសភំ ឋានំ** បានដល់ ឋានៈដ៏ប្រសើរ ឋានៈដ៏ឧត្តម ។ ម្យ៉ាងទៀត អធិប្បាយថា ព្រះពុទ្ធក្នុងកាលមុន ទ្រង់ធំក្រៃលែងមាន ទ្រង់ចូលដល់ឋានៈ ដូចព្រះពុទ្ធទាំងនោះ ។ ម្យ៉ាងទៀត ប្រៀបដូចគោឧសភ ដែលជាគោចម្រើនបំផុតក្នុងចំនួនគោ ១០០ គោវសភ ជាគោដែលចម្រើនបំផុតក្នុងចំនួនគោ ១០០០ ឬគោឧសភ ដែលប្រសើរក្នុងចំនួនគោ ១០០ ក្រោល ឬគោវសភប្រសើរក្នុងចំនួនគោ ១០០០ ក្រោល គោនិសភជាគោមេហ្វូងនៃគោទាំងអស់ ជាគោអត់ធន់ចំពោះអន្តរាយទាំងពួង មានពណ៌សគួរស្រឡាញ់ នាំការៈទៅបានច្រើន មិនញាប់ញ័រ សូម្បីសំឡេងរន្ទះ ១០០ ដង ។ គោនិសភៈនោះ បំណងយកគោឧសភក្នុងទីនេះ ។ ពិតហើយ ពាក្យថា គោឧសភនេះ ជាពាក្យប្រៀបធៀបនូវឋានៈដ៏ប្រសើរនោះ ។ ពាក្យថា អាសភ ជាឈ្មោះរបស់គោឧសភនោះ ។ បទថា **ឋានំ** បានដល់

ការជាន់ផែនដីមិនញាប់ញ័រដោយជើងទាំង ៤ ។ ឋានៈនេះឈ្មោះថា អាសភ ព្រោះអត្ថថា ជាការឈររបស់គោអាសភដូចគោឧសភ គឺគោនិសភប្រកប ដោយកម្លាំងរបស់គោឧសភ ប្រើជើងទាំង ៤ ជាន់ផែនដី រមែងឈរស៊ប់ មិនញាប់ញ័រយ៉ាងណា សូម្បីព្រះតថាគតក៏យ៉ាងនោះ ប្រកបដោយកម្លាំង របស់ព្រះតថាគត ១០ ប្រើព្រះបាទា គឺវេសារជ្ជញ្ញាណ ៤ ជាន់ផែនដី គឺ បរិស័ទ ៨ ទ្រង់ជាអ្នកមិនញាប់ញ័រដោយបច្ចាមិត្ត ដែលប្រាថ្នាអាក្រក់ក្នុង លោកនេះ ទាំងទេវលោក ឈ្មោះថា ទ្រង់តាំងនៅដោយឋានៈដែលមិនញាប់ ញ័រ ។ កាលទ្រង់តាំងនៅយ៉ាងនេះ ទើបទ្រង់ប្ដេជ្ញា គឺទ្រង់ចូលដល់ឋានៈដ៏ ប្រសើរនោះ រមែងមិនត្រឡប់វាចា ព្រោះទ្រង់លើកឋានៈដ៏ប្រសើរនោះ ក្នុងព្រះអង្គ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អាសភំ ឋានំ បដិជានាតិ** ដូច្នេះ ។

បទថា **បរិសាសុ** បានដល់ ក្នុងបរិស័ទ ៨[1] ។ បទថា **សីហនាទំ នទតិ** បានដល់ ទ្រង់បន្លឺព្រះសូរសៀងដ៏អង់អាច គឺទ្រង់បន្លឺព្រះសូរសៀង មិនមានកោតខ្លាច ម្យ៉ាងទៀត ទ្រង់បន្លឺសូរសៀងដូចសីហៈ ។ សេចក្ដីនេះ បណ្ឌិតគប្បីសម្ដែងដោយព្រះសូត្រ ឈ្មោះសីហនាទសូត្រ ។ ម្យ៉ាងទៀត សីហៈ ព្រះមានព្រះភាគ ត្រាស់ហៅថា សីហៈ ព្រោះអត់ធន់ និងព្រោះ ការសម្លាប់យ៉ាងណា ព្រះតថាគតក៏យ៉ាងនោះ សត្វលោក ហៅថា សីហៈ

---

១- ខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហបតិបរិស័ទ សមណបរិស័ទ ចាតុម្មហារាជិកាបរិស័ទ តាវត្តិង្សបរិស័ទ មារបរិស័ទ ព្រហ្មបរិស័ទ ។

ព្រោះអត់ធន់ចំពោះលោកធម៌ទាំងឡាយបាន និងព្រោះទ្រង់សម្លាប់នូវលទ្ធិដទៃ ។ ការបន្លឺសំឡេង គឺការបន្លឺរបស់សីហៈ ដែលពោលហើយយ៉ាងនេះ ឈ្មោះថា **សីហនាទ** ។ ក្នុងទីនេះ សីហៈដែលប្រកបហើយដោយកម្លាំងរបស់សីហៈ ជាអ្នកក្លៀវក្លាក្នុងទីទាំងពួង ជាអ្នកមានការព្រឺរោមព្រឺស្បែកទៅប្រាសហើយ រមែងបន្លឺសីហនាទយ៉ាងណា សូម្បីសីហៈ គឺព្រះតថាគតក៏យ៉ាងនោះ ប្រកបហើយដោយកម្លាំងរបស់ព្រះតថាគត ជាអ្នកក្លៀវក្លាក្នុងបរិស័ទ ៨ មិនជាអ្នកព្រឺរោមព្រឺស្បែក ។ ទ្រង់រមែងបន្លឺនូវសីហនាទដែលដល់ព្រមហើយដោយលម្អនៃទេសនា មានវិធីផ្សេងៗ ដោយន័យជាដើមថា **ឥតិ រូបំ** រូបយ៉ាងនេះជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បរិសាសុ សីហនាទំ នទតិ** ដូច្នេះ ។

បទថា **ព្រហ្មំ** ក្នុងបទថា **ព្រហ្មចក្កំ បវត្តេតិ** នេះ បានដល់ ប្រសើរ ឧត្តម គឺបរិសុទ្ធហើយ ។ ឯសព្ទថា **ចក្ក** សព្ទនេះ រមែងប្រាកដក្នុងអត្ថថា សម្បត្តិ លក្ខណៈ ចំណែកនៃរថ ឥរិយាបថ ទាន រតនៈ ធម៌ ខុរចក្កជាដើម ក្នុងទីនេះ **ចក្ក** សព្ទ ប្រព្រឹត្តទៅក្នុងចក្ក គឺធម្មចក្ក និងគប្បីធ្វើធម្មចក្កនោះឲ្យជាក់ច្បាស់ដោយចែកជា ២ ។

**ចក្ក** សព្ទនេះ ប្រាកដក្នុងអត្ថថា **សម្បត្តិ** ដូចក្នុងប្រយោគជាដើមថា **ចត្តារិមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវមនុស្សានំ** ម្នាលភិក្ខុទាំងឡាយ ចក្កនេះមាន ៤ ចក្ក ៤ តែងប្រព្រឹត្តទៅ ( ដើម្បីជាប្រយោជន៍ ) ដល់ពួកទេវតា និងមនុស្សដែលប្រកបដោយចក្ក ... ដូច្នេះ ។

ចក្ក សព្ទ ប្រាកដក្នុងអត្ថថា **លក្ខណៈ** ដូចក្នុងប្រយោគជាដើមថា **ហេដ្ឋា បាទតលេសុ ចក្កានិ ជាតានិ** ព្រះរាជកុមារដែលមានរូបចក្រកើតត្រង់ផ្ទៃនៃព្រះបាទាខាងក្រោម ដូច្នេះ ។

ចក្ក សព្ទ ប្រាកដក្នុងអត្ថថា **ចំណែកនៃរថ** ដូចក្នុងប្រយោគជាដើមថា **ចក្កំវ វហតោ បទំ** ដូចកង់រទេះវិលតាមជានជើងគោដែលកំពុងអូសទៅ ដូច្នេះ ។

ចក្ក សព្ទ ប្រាកដក្នុងអត្ថថា **ឥរិយាបថ** ដូចក្នុងប្រយោគជាដើមថា **ចតុចក្កំ នវទ្វារំ** សរីរៈមានចក្ក ៤ មានទ្វារ ៩ ដូច្នេះ ។

ចក្ក សព្ទ ប្រាកដក្នុងអត្ថថា **ទាន** ដូចក្នុងប្រយោគជាដើមថា **ទទំ ភុញ្ជ ច មា ច បមាទោ ចក្កំ បវត្តយ សព្វបាណិនំ** សូមព្រះអង្គទ្រង់ឲ្យទានហើយ សឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ ( ក្នុងបុណ្យទាំងឡាយ ) សូមព្រះអង្គញុំាងចក្កធម៌ឲ្យប្រព្រឹត្តទៅ ដូច្នេះ ។

ចក្ក សព្ទ ប្រាកដក្នុងអត្ថថា **រតនៈ** ដូចក្នុងប្រយោគជាដើមថា **ទិព្វំ ចក្ករតនំ បាតុរហោសិ** ចក្ករ័តន៍ជាទិព្វមានកាំ ១០០០ ព្រមទាំងខ្នង និងដុំបរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដហើយ ដូច្នេះ ។

ចក្ក សព្ទ ប្រាកដក្នុងអត្ថថា **ធម៌** ដូចក្នុងប្រយោគជាដើមថា **មយា បវត្តិតំ ចក្កំ** ញុំាងធម្មចក្ក ជាចក្កដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ដូច្នេះ ។

ចក្ក សព្ទ ប្រាកដក្នុងអត្ថថា **ខុរចក្ក** ដូចក្នុងប្រយោគជាដើមថា **ឥច្ឆា-**

**ហតស្ស ចោរស្ស ចក្កំ ភមតិ មត្ថកេ** ចក្រវិលកិនអំបែងក្បាលបុគ្គលដែលឥស្សាគ្របសង្កត់ហើយ ដូច្នេះ ។

**ចក្ក** សព្ទ ប្រាកដក្នុងអត្ថថា **គ្រឿងប្រហារ** ដូចក្នុងប្រយោគជាដើមថា **ខុរបរិយន្តេន ចេបិ ចក្កេន** ដោយគ្រឿងចក្រមានខ្នងកង់ដ៏មុត ដូចជាកាំបិតកោរ ដូច្នេះ ។

**ចក្ក** សព្ទ ប្រាកដក្នុងអត្ថថា **មណ្ឌលនៃរន្ទះ** ដូចក្នុងប្រយោគជាដើមថា **អសនិវិចក្កំ** ( ម្នាលភិក្ខុទាំងឡាយ ) កាំរន្ទះធ្លាក់ចំលើបុគ្គលណាដូច្នេះ ។ តែក្នុងទីនេះ **ចក្ក** សព្ទ ប្រព្រឹត្តទៅក្នុងចក្រ គឺធម៌ ។

ធម្មចក្រនោះ មាន ២ យ៉ាង គឺបដិវេធញ្ញាណ ១ ទេសនាញ្ញាណ ១ ។ ក្នុងញាណ ២ យ៉ាងនោះ ធម្មចក្រដែលបញ្ញាអប់រំហើយ នាំអរិយផលមកឲ្យដល់ខ្លួន ជាបដិវេធញ្ញាណ ដែលករុណាអប់រំហើយ នាំអរិយផលមកឲ្យដល់សាវកទាំងឡាយ ជាទេសនាញ្ញាណ ។

បណ្តាញាណទាំងនោះ បដិវេធញ្ញាណមាន ២ គឺឧប្បជ្ជមាន គឺបដិវេធញ្ញាណដែលកំពុងកើតឡើង ១ ឧប្បន្ន គឺបដិវេធញ្ញាណដែលកើតឡើងហើយ ១ ។

ពិតហើយ បដិវេធញ្ញាណនោះ រាប់ចាប់តាំងអំពីការចេញអភិនេស្រ្កមណ៍ រហូតដល់អរហត្តមគ្គ ឈ្មោះថា កំពុងកើតឡើង ក្នុងខណៈនៃផល ឈ្មោះថា កើតឡើងហើយ ។ ម្យ៉ាងទៀត បដិវេធញ្ញាណ តាំងអំពីទ្រង់នៅក្នុងស្ថានតុសិត រហូតដល់អរហត្តមគ្គ ត្រង់មហាពោធិបល្ល័ង្ក ឈ្មោះថា កំពុង

កើតឡើង ក្នុងខណៈនៃផល ឈ្មោះថា កើតឡើងហើយ ។ ម្យ៉ាងទៀត បដិវេធញ្ញាណ រាប់ចាប់តាំងអំពីទ្រង់បានព្យាករណ៍របស់ព្រះសម្មាសម្ពុទ្ធព្រះនាមទីបង្ករ រហូតដល់អរហត្តមគ្គ ឈ្មោះថា កំពុងកើតឡើង ក្នុងខណៈនៃផល ឈ្មោះថា កើតឡើងហើយ ។

ទេសនាញាណក៏មាន ២ គឺ **បវត្តមាន** គឺទេសនាញាណដែលកំពុងប្រព្រឹត្តទៅ ១ **បវត្ត** គឺទេសនាញាណដែលប្រព្រឹត្តទៅហើយ ១ ។

ពិតហើយ ទេសនាញាណនោះ ដែលប្រព្រឹត្តទៅរហូតដល់សោតាបត្តិ-មគ្គ របស់ព្រះអញ្ញាកោណ្ឌញ្ញៈ ឈ្មោះថា កំពុងប្រព្រឹត្តទៅ ក្នុងខណៈនៃផល ឈ្មោះថា ប្រព្រឹត្តទៅហើយ ។

ក្នុងញាណទាំងនោះ បដិវេធញ្ញាណ ជាលោកុត្តរ ទេសនាញាណ ជាលោកិយ ក្នុងញាណទាំង ២ នោះ ជារបស់មិនទូទៅដល់ជនពួកដទៃ ជាឱរសញ្ញាណ គឺញាណដែលកើតអំពីទ្រូងរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ។

ព្រះតថាគតទ្រង់ប្រកបហើយដោយកម្លាំងទាំងឡាយ ១០ ណា ទើបទ្រង់ប្តេជ្ញាឋានៈដ៏ប្រសើរ និងកម្លាំងទាំងឡាយណាដែលទ្រង់តាំងទុក តាំងអំពីដើមថា **ទស តថាគតស្ស តថាគតពលានិ** តថាគតពល ១០ របស់ព្រះតថាគត ដូច្នេះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងកម្លាំងទាំងនោះដោយពិស្តារ ទើបត្រាស់ថា ពល ១០ ដូចម្តេចខ្លះ ព្រះតថាគតក្នុងលោកនេះជ្រាបច្បាស់តាមពិតនូវហេតុ ថាជាហេតុផង ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឋានញ្ច ឋានតោ** បានដល់ ទ្រង់ដឹងធម៌

ដែលជាហេតុ ដោយភាពជាហេតុ ។ ពិតហើយ ហេតុ ទ្រង់ហៅថា ឋានៈ ព្រោះជាទីតាំងឡើងនៃផល គឺជាទីកើតឡើង និងប្រព្រឹត្តទៅនៃផល ដោយការប្រព្រឹត្តទៅទាក់ទងអំពីហេតុនោះ ។ ព្រះមានព្រះភាគ កាលទ្រង់ជ្រាបនូវឋានៈនោះថា ធម៌ពួកណាៗ ជាហេតុ ជាបច្ច័យដើម្បីកើតឡើងនៃពួកធម៌ណាៗ ពួកធម៌នោះៗ ឈ្មោះថា ជាហេតុ ដូច្នេះ និងកាលទ្រង់ជ្រាបថា ពួកធម៌ណាៗ មិនមែនហេតុ មិនមែនបច្ច័យដើម្បីកើតឡើងនៃពួកធម៌ណាៗ ទេ ពួកធម៌នោះៗ ឈ្មោះថា មិនមែនហេតុ ដូច្នេះ ទើបឈ្មោះថា ទ្រង់ជ្រាបធម៌ដែលជាឋានៈដោយភាពជាឋានៈ និងធម៌ដែលមិនមែនឋានៈ ដោយភាពមិនមែនឋានៈតាមសេចក្តីពិត ។ បទថា **យម្បិ** បានដល់ ដោយញាណណា ។ បទថា **ឥទម្បិ តថាគតស្ស** អធិប្បាយថា ឋានាឋានញ្ញាណរបស់ព្រះតថាគតនេះ ឈ្មោះថា ជាកម្លាំងរបស់ព្រះតថាគត បណ្ឌិតគប្បីជ្រាបការប្រកបក្នុងបទទាំងពួងយ៉ាងនេះ ។

បទថា **កម្មសមាទានំ** បានដល់ កម្មដែលជាកុសល និងអកុសលដែលតាំងចិត្តធ្វើហើយ ។ម្យ៉ាងទៀត កម្មនោះឯង ឈ្មោះថា កម្មសមាទាន ។ បទថា **ឋានសោ ហេតុសោ** បានដល់ ដោយបច្ច័យ និងដោយហេតុ ។ ក្នុងបទទាំងនោះ គតិ ឧបធិ កាល និងបយោគ ជាឋានៈរបស់វិបាក កម្ម ឈ្មោះថា ជាហេតុ ។

បទថា **សព្វត្ថគាមិនី** បានដល់ ទៅកាន់គតិទាំងពួង និងទៅកាន់ទីមិនមែនគតិ ។ បទថា **បដិបទំ** បានដល់ មគ្គ ។ បទថា **យថាភូតំ បជា-**

**ឆាតិ** បានដល់ ទ្រង់រមែងជ្រាបសភាវៈការបដិបត្តិ ពោល គឺចេតនាដែលជាកុសល និងអកុសល ដោយមិនវិបរិតក្នុងវត្ថុមួយ ដោយន័យនេះថា កាលមនុស្សទាំងឡាយមានចំនួនច្រើន សម្លាប់សត្វ ១ នោះឯង ចេតនារបស់បុគ្គលនេះនឹងនាំទៅកាន់នរក ឯចេតនារបស់បុគ្គលនេះនឹងនាំទៅកាន់កំណើតក្នុងសត្វតិរច្ឆាន ។

បទថា **អនេកធាតុំ** បានដល់ ជាធាតុច្រើនដោយធាតុទាំងឡាយ មានចក្ខុធាតុជាដើម ឬកាមធាតុជាដើម ។ បទថា **នានាធាតុំ** បានដល់ ជាធាតុមានប្រការផ្សេងៗ ព្រោះធាតុទាំងនោះ មានលក្ខណៈផ្សេងគ្នា ។ បទថា **លោកំ** បានដល់ លោក គឺខន្ធ អាយតនៈ និងធាតុ ។ បទថា **យថាភូតំ បជានាតិ** បានដល់ ទ្រង់ចាក់ធ្លុះសភាវៈនូវធាតុនោះៗ ដោយមិនវិបរិត ។ បទថា **នានាធិមុត្តិកតំ** បានដល់ ទ្រង់ជ្រាបនូវភាពដែលសត្វទាំងឡាយមានអធ្យាស្រ័យផ្សេងៗ គ្នា មានអធ្យាស្រ័យថោកទាបជាដើម ។

បទថា **បរសត្តានំ** បានដល់ របស់សត្វដែលជាធំ ។ បទថា **បរ-បុគ្គលានំ** បានដល់ សត្វដែលថោកថយពួកដទៃ ក្រៅអំពីសត្វដែលជាធំនោះ ។ម្យ៉ាងទៀត បទទាំង ២ នេះ ដែលពោលហើយ មានអត្ថដូចគ្នានោះឯង ព្រះមានព្រះភាគ ត្រាស់ ២ យ៉ាង ដោយអំណាចនៃវេនេយ្យ-សត្វ ។ បទថា **ឥន្ទ្រិយបរោបរិយត្តំ** អធិប្បាយថា នូវភាពដែលឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមចាស់ក្លា និងមិនចាស់ក្លា គឺចម្រើននិងវិនាស ។

បទថា **ឈានវិមោក្ខសមាធិសមាបត្តីនំ** បានដល់ នៃឈាន ៤ មាន

បឋមជ្ឈានជាដើមនៃវិមោក្ខ ៨ ជាដើមថា បុគ្គលមានរូបជ្ឈាន តែងឃើញរូបនៃសមាធិ ៣ មានសវិតក្ក សវិចារសមាធិជាដើម និងនៃអនុបុព្វសមាបត្តិ ៩ មានបឋមជ្ឈានសមាបត្តិជាដើម ។ បទថា **សំកិលេសំ** បានដល់ ធម៌ដែលជាចំណែកនៃសេចក្តីវិនាស ។ បទថា **វោទានំ** បានដល់ ធម៌ជាចំណែកវិសេស គឺចំណែកល្អ ។ បទថា **វុដ្ឋានំ** បានដល់ រមែងចេញចាកឈានជាដើម ដោយហេតុណា រមែងជ្រាបនូវហេតុនោះ ។

បទថា **បុព្វេនិវាសានុស្សតឹ** បានដល់ ទ្រង់រឭកដល់ខន្ធ ដែលធ្លាប់អាស្រ័យហើយក្នុងកាលមុន ។ បទថា **ចុតូបបាតំ** បានដល់ នូវចុតិ និងបដិសន្ធិ ។ បទថា **អាសវានំ ខយំ** បានដល់ ព្រះនិព្វានដែលរលត់នូវអាសវៈទាំងឡាយ ពោល គឺការអស់ទៅនៃកាមាសវៈជាដើម ។ បទថា **ឥមានិ** បានដល់ កម្លាំង ១០ ពួកណា ដែលបានត្រាស់ហើយខាងដើមថា តថាគតពល ១០ របស់ព្រះតថាគត ទ្រង់ធ្វើសរុបថា កម្លាំងទាំង ១០ ប្រការនេះ ។

បណ្ឌិតកាលជ្រាបអធិប្បាយដោយលំដាប់ ក្នុងមាតិកានេះយ៉ាងនេះហើយ ឥឡូវនេះ គប្បីជ្រាបទៀតថា ព្រះមានព្រះភាគ ត្រាស់កម្លាំង ១០ នេះដោយលំដាប់ ព្រោះព្រះតថាគត ទ្រង់ឃើញនូវវេនេយ្យសត្វទាំងឡាយមិនមានកិលេសាវរណៈ ( កិលេសជាគ្រឿងរារាំង ) ដែលជាហេតុនៃការសម្រេចនូវការអស់ទៅនៃអាសវៈ និងមិនជាហេតុនៃការសម្រេចដោយឋានាឋានញ្ញាណមុននោះឯង ព្រោះទ្រង់ឃើញហេតុ គឺលោកិយសម្មាទិដ្ឋិ និង

ទ្រង់ឃើញការមិនមានហេតុ គឺនិយតមិច្ឆាទិដ្ឋិ បន្ទាប់អំពីនោះ ទ្រង់ឃើញសត្វទាំងនោះ មិនមានវិបាកជាគ្រឿងរារាំងដោយកម្មវិបាកញ្ញាណ ព្រោះទ្រង់ឃើញបដិសន្ធិរបស់តិហេតុកសត្វ ។ ទ្រង់ឃើញសត្វទាំងឡាយមិនមានកម្មជាគ្រឿងរារាំងដោយសព្វត្ថគាមិនីបដិបទាញាណ គឺញាណជាគ្រឿងឈមចុះក្នុងផ្លូវទៅកាន់ភូមិទាំងពួង ព្រោះទ្រង់ឃើញការមិនមាននៃអនន្តរិយកម្ម កាលបើយ៉ាងនេះ ទ្រង់ឃើញគុណវិសេសនៃការប្រព្រឹត្ត ដើម្បីសម្តែងធម៌អនុគ្រោះដល់សត្វដែលមិនមានកម្មជាគ្រឿងរារាំង ដោយអនេកធាតុនានា-ធាតុញ្ញាណ គឺញាណជាគ្រឿងឈមចុះក្នុងលោក ដែលជាអនេកធាតុ និងនានាធាតុ ព្រោះទ្រង់ឃើញការផ្សេងគ្នានៃធាតុ ។ លំដាប់នោះ ទ្រង់ឃើញនូវអធិមុត្តិ គឺអធ្យាស្រ័យរបស់សត្វទាំងឡាយ បានដោយនានាធិមុត្តិក-តញ្ញាណ គឺញាណឈមចុះដឹងអធ្យាស្រ័យផ្សេងៗ គ្នា ដើម្បីសម្តែងធម៌ដោយអំណាចនៃអធ្យាស្រ័យដោយមិនពិចារណាដល់ការធ្វើ និងការសម្តែងចេញ ។ បន្ទាប់អំពីនោះ ទ្រង់ឃើញការទន់ខ្សោយ និងការចាស់ក្លានៃឥន្ទ្រិយ ដោយឥន្ទ្រិយបរោបរិយត្តញ្ញាណ ដើម្បីសម្តែងធម៌តាមសមត្ថភាព តាមកម្លាំងដល់សត្វដែលមានអធ្យាស្រ័យ ដែលទ្រង់ឃើញហើយយ៉ាងនេះ ព្រោះឃើញសទ្ធាជាដើម ជាធម៌ចាស់ក្លា និងទន់ខ្សោយ ។ កាលបើយ៉ាងនេះ សូម្បីជាអ្នកមានឥន្ទ្រិយចាស់ក្លា និងមិនចាស់ក្លា ទ្រង់កំណត់ដឹងហើយ បើសត្វទាំងនោះនៅឆ្ងាយ ទ្រង់ក៏ចូលទៅជិតដោយឆាប់រួសរាន់ដោយភាពវិសេសនៃឫទ្ធិ ព្រោះទ្រង់ជាអ្នកមានវសីក្នុងឈានជាដើម ដោយការដឹងក្នុងឈានជាដើម ។

កាលចូលទៅហើយ ទ្រង់ឃើញនូវជាតិក្នុងកាលមុន របស់សត្វទាំងនោះ ដោយបុព្វេនិវាសានុស្សតិញ្ញាណ និងទ្រង់ឃើញនូវភាពវិសេសនៃចិត្តដូចគ្នានោះ ដោយចេតោបរិយញ្ញាណ ដែលទ្រង់គប្បីដល់ដោយអានុភាពនៃទិព្វចក្ខុ ទើបទ្រង់សម្តែងធម៌ ដើម្បីការអស់ទៅនៃអាសវៈ ព្រោះសត្វទាំងនោះ មានមោហៈទៅប្រាសហើយ ដោយបដិបទាដែលឲ្យដល់នូវការអស់ទៅនៃអាសវៈ ដោយអានុភាពនៃអាសវក្ខយញ្ញាណ ។ នេះជាការអធិប្បាយសេចក្តី ក្នុងមាតិកា ៕៚

# អភិធម្មបិដក

## ឯកកនិទ្ទេស

[ ៣៥ ] វិញ្ញាណ ៥ មិនមែនហេតុ មិនមានហេតុ ប្រាសចាកហេតុ ប្រកបដោយបច្ច័យ ត្រូវបច្ច័យប្រជុំតាក់តែង ជាអរូប ជាលោកិយ ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ដែលគន្ថៈគប្បីដោតក្រង ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ដែលយោគៈគប្បីប្រព្រឹត្តកន្លង ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន គួរដល់នូវសេចក្តីសៅហ្មង ជាអព្យាក្រឹត ប្រកបដោយអារម្មណ៍ មិនមែនចេតសិក ជាវិបាក មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន មិនសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង មិនប្រកបដោយវិតក្ក តែប្រកបដោយវិចារ មិនមែនជាមិនមានវិតក្ក មានត្រឹមតែវិចារ មិនមានវិតក្ក ទាំងមិនមានវិចារ មិនកើតព្រមដោយបីតិ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មិនដល់នូវការសន្សំ ( កម្មក្កិលេស ) ទាំងមិនដល់នូវការមិនសន្សំ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល មានសភាពតូចឆ្មារ ជាកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាបរិយាបន្ន មិនមែនអបរិយាបន្ន ជាសភាពមិនទៀង ជាអនិយ្យានិកៈ ដែលកើតឡើងហើយ ដែលគួរដឹងដោយមនោវិញ្ញាណ មិនទៀង ដែលត្រូវជរាគ្របសង្កត់ ។

[ ៣៦ ] ត្រង់ពាក្យថា វិញ្ញាណ ៥ មានវត្ថុកើតហើយ មានអារម្មណ៍កើតហើយ គឺកាលបើវត្ថុ និងអារម្មណ៍កើតហើយ វិញ្ញាណទាំងឡាយក៏កើតឡើងដែរ ។ ពាក្យថា ( វិញ្ញាណ ៥ ) មានវត្ថុកើតហើយក្នុងកាលមុន មានអារម្មណ៍កើតហើយក្នុងកាលមុន គឺកាលបើវត្ថុកើតហើយក្នុងកាលមុន និងអារម្មណ៍កើតហើយក្នុងកាលមុន វិញ្ញាណទាំងឡាយ ក៏កើតឡើងដែរ ។ ពាក្យថា ( វិញ្ញាណ ៥ ) មានវត្ថុខាងក្នុង មានអារម្មណ៍ខាងក្រៅ គឺវិញ្ញាណទាំង ៥ មានវត្ថុខាងក្នុង មានអារម្មណ៍ខាងក្រៅ ។ ពាក្យថា ( វិញ្ញាណ ៥ ) មានវត្ថុមិនប្រឡំគ្នា មានអារម្មណ៍មិនប្រឡំគ្នា គឺកាលបើវត្ថុមិនប្រឡំគ្នា កាលបើអារម្មណ៍មិនប្រឡំគ្នា វិញ្ញាណទាំងឡាយ ក៏កើតឡើងដែរ ។ ពាក្យថា ( វិញ្ញាណ ៥ ) មានវត្ថុផ្សេងៗ មានអារម្មណ៍ផ្សេងៗ គឺវត្ថុ និងអារម្មណ៍របស់ចក្ខុវិញ្ញាណដោយឡែក វត្ថុ និងអារម្មណ៍របស់សោតវិញ្ញាណដោយឡែក វត្ថុ និងអារម្មណ៍របស់ឃានវិញ្ញាណដោយឡែក វត្ថុ និងអារម្មណ៍របស់ជិវ្ហាវិញ្ញាណដោយឡែក វត្ថុ និងអារម្មណ៍របស់កាយវិញ្ញាណដោយឡែក ។ ពាក្យថា ( វិញ្ញាណ ៥ ) មិនរងអារម្មណ៍ជាទីគោចរនៃគ្នានិងគ្នាទេ គឺសោតវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់ចក្ខុវិញ្ញាណ ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់សោតវិញ្ញាណ ឃានវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់ចក្ខុវិញ្ញាណ ចក្ខុវិញ្ញាណមិនរងអារម្មណ៍ជាទីគោចររបស់ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់ចក្ខុវិញ្ញាណ ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ជិវ្ហាវិញ្ញាណ

ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់កាយវិញ្ញាណ របស់សោត-វិញ្ញាណ ។បេ។ របស់ឃានវិញ្ញាណ ។បេ។ របស់ជិវ្ហាវិញ្ញាណ ។បេ។ ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់កាយវិញ្ញាណ កាយវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់ចក្ខុវិញ្ញាណ សោតវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់កាយវិញ្ញាណ កាយវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់សោតវិញ្ញាណ ឃានវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់កាយ-វិញ្ញាណ កាយវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់ឃានវិញ្ញាណ ជិវ្ហា-វិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់កាយវិញ្ញាណ កាយវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចររបស់ជិវ្ហាវិញ្ញាណ ។ ពាក្យថា ( វិញ្ញាណ ៥ ) មិនកើតឡើង ព្រោះការមិនប្រមូលមក ( នូវអារម្មណ៍ ) គឺកាលបុគ្គលប្រមូលមក ( នូវអារម្មណ៍ មានរូបារម្មណ៍ជាដើម ) វិញ្ញាណទាំងឡាយក៏កើតឡើង ។ ពាក្យថា ( វិញ្ញាណ ៥ ) មិនកើតឡើង ព្រោះការមិនធ្វើទុកក្នុងចិត្ត ( នូវអារម្មណ៍ ) គឺកាលបុគ្គលធ្វើទុកក្នុងចិត្ត ( នូវអារម្មណ៍ ) វិញ្ញាណទាំងឡាយ ក៏កើតឡើង ។ ពាក្យថា ( វិញ្ញាណ ៥ ) មិនកើតឡើង ព្រោះការមិនប្រឡូកគ្នា គឺមិនកើតឡើងតាមលំដាប់គ្នាទេ ។ ពាក្យថា ( វិញ្ញាណ ៥ ) មិនកើតឡើង មិនមុន មិនក្រោយ គឺមិនកើតក្នុងខណៈជាមួយគ្នាទេ ។ ពាក្យថា ( វិញ្ញាណ ៥ ) មិនកើតឡើង ក្នុងលំដាប់នៃគ្នានិងគ្នា គឺសោតវិញ្ញាណ មិនកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណដែលកើតហើយទាំងចក្ខុវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃសោតវិញ្ញាណដែលកើតហើយដែរ

*ឃានវិញ្ញាណ មិនកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណដែលកើតហើយ ទាំងចក្ខុ-វិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃឃានវិញ្ញាណ ដែលកើតហើយដែរ ជិវ្ហា-វិញ្ញាណ មិនកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណដែលកើតហើយ ទាំងចក្ខុវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃជិវ្ហាវិញ្ញាណដែលកើតហើយដែរ កាយវិញ្ញាណ មិនកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណដែលកើតហើយ ទាំងចក្ខុវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃកាយវិញ្ញាណ ដែលកើតហើយដែរ ចក្ខុវិញ្ញាណ មិនកើតក្នុងលំដាប់នៃសោតវិញ្ញាណ ។បេ។ នៃឃានវិញ្ញាណ ។បេ។ នៃជិវ្ហា-វិញ្ញាណ ។បេ។ នៃកាយវិញ្ញាណដែលកើតហើយ ទាំងកាយវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណដែលកើតហើយដែរ សោតវិញ្ញាណ មិនកើតក្នុងលំដាប់នៃកាយវិញ្ញាណដែលកើតហើយ ទាំងកាយវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃសោតវិញ្ញាណដែលកើតហើយដែរ ឃានវិញ្ញាណ មិនកើតក្នុងលំដាប់នៃកាយវិញ្ញាណដែលកើតហើយ ទាំងកាយវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃឃានវិញ្ញាណដែលកើតហើយដែរ ជិវ្ហាវិញ្ញាណ មិនកើតក្នុងលំដាប់នៃកាយវិញ្ញាណដែលកើតហើយ ទាំងកាយវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃជិវ្ហាវិញ្ញាណដែលកើតហើយដែរ ។ ពាក្យថា វិញ្ញាណ ៥ មិនមានគ្រឿងអាង គឺវិញ្ញាណទាំង ៥ មិនមានការនឹក មិនមានគ្រឿងអាង មិនមានការប្រមូលមក មិនមានការធ្វើទុកក្នុងចិត្តទេ ។ ពាក្យថា បុគ្គលមិនដឹងច្បាស់នូវធម៌ណាមួយដោយវិញ្ញាណទាំង ៥ គឺបុគ្គលមិនដឹងច្បាស់នូវធម៌ណាមួយដោយវិញ្ញាណទាំង ៥ ។ ពាក្យថា បើវៀរចាកការប៉ះពាល់នូវអារម្មណ៍ គឺ*

បើវៀរចាកអារម្មណ៍ មានរូបារម្មណ៍ជាដើម ដែលមកកាន់គន្លងនៃទ្វារ មានចក្ខុទ្វារជាដើម ។ ពាក្យថា បុគ្គលមិនដឹងច្បាស់នូវធម៌ណាមួយក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺបុគ្គលមិនដឹងច្បាស់នូវធម៌ណាមួយ ដោយមនោធាតុក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ ពាក្យថា មិនសម្រេចនូវឥរិយាបថណាមួយដោយវិញ្ញាណទាំង ៥ ឥរិយាបថ សេចក្តីថា មិនសម្រេចឥរិយាបថណាមួយ គឺការដើរក្តី ការឈរក្តី ការអង្គុយក្តី ការដេកក្តី ដោយវិញ្ញាណទាំង ៥ ។ ពាក្យថា មិនសម្រេចឥរិយាបថណាមួយ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ សេចក្តីថា មិនសម្រេចឥរិយាបថណាមួយ គឺការដើរក្តី ការឈរក្តី ការអង្គុយក្តី ការដេកក្តី ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ ពាក្យថា មិនតាំងផ្តើមកាយកម្ម មិនតាំងផ្តើមវចីកម្ម ដោយវិញ្ញាណទាំង ៥ គឺមិនតាំងផ្តើមនូវកាយកម្ម និងវចីកម្ម ដោយវិញ្ញាណទាំង ៥ ។ ពាក្យថា មិនតាំងផ្តើមកាយកម្ម មិនតាំងផ្តើមវចីកម្ម ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺមិនតាំងផ្តើមនូវកាយកម្ម និងវចីកម្ម ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ ពាក្យថា មិនកាន់យកនូវធម៌ជាកុសល និងអកុសល ដោយវិញ្ញាណទាំង ៥ គឺមិនសមាទាននូវធម៌ជាកុសល និងអកុសល ដោយវិញ្ញាណទាំង ៥ ។ ពាក្យថា មិនកាន់យកនូវធម៌ជាកុសល និងអកុសលក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺមិនសមាទាននូវធម៌ជាកុសល និងអកុសលដោយមនោ-ធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ ពាក្យថា មិនចូលឈាន មិនចេញចាកឈានដោយវិញ្ញាណទាំង ៥ មិនចូល មិនចេញ ដោយវិញ្ញាណទាំង

៥ ។ ពាក្យថា មិនចូលឈាន មិនចេញចាកឈាន ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺមិនចូល មិនចេញ ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ ពាក្យថា មិនច្យុត មិនកើត ដោយវិញ្ញាណទាំង ៥ គឺមិនឃ្លាត មិនកកើតដោយវិញ្ញាណទាំង ៥ ។ ពាក្យថា មិនច្យុត មិនកើត ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺមិនឃ្លាត មិនកកើត ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ ពាក្យថា មិនលក់ មិនភ្ញាក់ មិនឃើញសុបិនដោយវិញ្ញាណទាំង ៥ គឺមិនដេកលក់ មិនដឹងស្មារតី មិនយល់សប្តិដោយវិញ្ញាណទាំង ៥ ។ ពាក្យថា មិនលក់ មិនភ្ញាក់ មិនឃើញសុបិន ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺមិនដេកលក់ មិនដឹងស្មារតី មិនយល់សប្តិដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។

បញ្ញាជាគ្រឿងសម្តែងតាមលំដាប់នៃមាតិកាយ៉ាងនេះឯង ។

## ញាណវត្ថុ មានប្រការ ១ យ៉ាងនេះ

# អដ្ឋកថា

## ឯកកនិទ្ទេស

[ ៣៥-៣៦ ] *ឥឡូវនេះ ជាការសម្ដែងការបដិសេធសាធារណហេតុ ក្នុងបទថា* **ន ហេតុមេវ** *ក្នុងនិទ្ទេសវារដែលព្រះមានព្រះភាគទ្រង់ផ្ដើម ដោយន័យជាដើមថា* **បញ្ចវិញ្ញាណា ន ហេតុមេវ** *នៃមាតិកាតាមដែល ទ្រង់តាំងទុក ។ ក្នុងបទទាំងនោះ បទណាដែលគប្បីពោលដោយន័យជាដើម ថា ហេតុមាន ៤ យ៉ាង គឺហេតុហេតុ ១ បច្ចយហេតុ ១ ឧត្តមហេតុ ១ សាធារណហេតុ ១ ។*

*ពាក្យទាំងអស់ ខ្ញុំបានពោលហើយ ក្នុងការអធិប្បាយអត្ថនៃបទទាំង ឡាយ ក្នុងរូបកណ្ឌ ( ធម្មសង្គណី ) ថា* **សព្វំ រូបំ ន ហេតុមេវ** *ជាដើម នោះឯង ។*

*ក្នុងបទថា* **អហេតុកាមេវ** *ជាដើម បណ្ឌិតគប្បីជ្រាបថា លោកចុះ* **ម** *អក្ខរៈ ដោយអំណាចនៃព្យញ្ជនសន្ធិ គឺជា* **អហេតុកា ឯវ** *។ ក្នុងបទដ៏ សេសក៏ន័យនេះឯង ។ម្យ៉ាងទៀត ក្នុងពួកនៃធម៌ មានបទថា* **ហេតូ ធម្មា ន ហេតូ ធម្មា** *ពួកធម៌ជាហេតុ ពួកធម៌មិនមែនជាហេតុជាដើម វិញ្ញាណ ៥ រមែងមិនមានក្នុងបទថា ពួកធម៌ជាហេតុ ឬពួកធម៌ប្រកបដោយហេតុ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបអត្ថដោយចំណែកមួយក្នុងបទទាំងពួង ក្នុងទីនេះ ដោយន័យនេះថា វិញ្ញាណ ៥ ជានហេតុនោះឯង ជាអហេតុកៈនោះឯង ដូច្នេះ ។*

បទថា **អព្យាកតមេវ** នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃវិបាកាព្យាកត ។ បទថា **សារម្មណមេវ** នេះ ត្រាស់ដោយអំណាចឱលុព្ភារម្មណៈ ( អារម្មណ៍ជាគ្រឿងតោង ) ។ ពិតហើយ អារម្មណ៍មាន ២ យ៉ាង គឺបច្ចយារម្មណៈ ១ ឱលុព្ភារម្មណៈ ១ ។ តែក្នុងទីនេះ ជាកិច្ចនៃឱលុព្ភារម្មណៈនោះឯង ។ សូម្បីបច្ចយារម្មណៈ ក៏រមែងបានដូចគ្នា ។

បទថា **អចេតសិកាមេវ** ព្រះមានព្រះភាគត្រាស់សំដៅយកចិត្តប៉ុណ្ណោះក្នុងអចេតសិកធម៌ ៣ យ៉ាង គឺចិត្ត រូប និងនិព្វាន ។ បទថា **នោ អបរិយាបន្នមេវ** បានដល់ ធម៌ដែលទាក់ទងហើយដោយភាពជាធម៌ ដែលទាក់ទងក្នុងគតិ ចុតិ និងភព គឺសង្សារវដ្ត ឈ្មោះថា **នោ អបរិយាបន្ន** ។ សភាវធម៌ណា មិននាំចេញចាកលោក គឺចាកវដ្ដៈ ព្រោះហេតុនោះ ទើបសភាវធម៌នោះ ឈ្មោះថា ជាអនិយ្យានិកៈ ។ បទថា **ឧប្បន្នំ មនោវិញ្ញាណវិញ្ញេយ្យមេវ** ព្រះមានព្រះភាគត្រាស់ក្នុងរូបកណ្ឌថា ជាឧប្បន្នរូប ជារូបត្រូវដឹងដោយវិញ្ញាណ ៦ ដូច្នេះ ព្រោះផ្ដើមនៅវិញ្ញាណ ដែលមានអារម្មណ៍ជាអតីតជាដើម ឲ្យធ្លាក់ទៅតាមក្រសែនៃវិញ្ញាណ ៥ នោះឯង ព្រោះប្រារព្ធរូបជាដើម ដែលកើតចំពោះហើយ ដល់ចក្ខុវិញ្ញាណជាដើម ប្រព្រឹត្តទៅ ។ វិញ្ញាណ ៥ សូម្បីកំពុងកើតឡើងហើយ រមែងមិនជាអារម្មណ៍ដល់ចក្ខុវិញ្ញាណជាដើម រមែងប្រព្រឹត្តទៅដល់មនោវិញ្ញាណប៉ុណ្ណោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា គប្បីដឹងដោយមនោវិញ្ញាណនោះឯង ដូច្នេះ ។ បទថា **អនិច្ចមេវ** បានដល់ វិញ្ញាណ ៥ ឈ្មោះថា ជាធម្មជាតមិនទៀង

នោះឯង ព្រោះអត្ថថា មានហើយ បែរជាមិនមាន គឺកើតឡើងហើយ ក៏រលត់ទៅ ។ បទថា **ជរាភិភូតមេវ** បានដល់ វិញ្ញាណ ៥ ឈ្មោះថាត្រូវជរាគ្របសង្កត់នោះឯង ព្រោះដែលជរាគ្របសង្កត់ហើយ ។

បទថា **ឧប្បន្នវត្ថុកា ឧប្បន្នារម្មណា** ជាពាក្យបដិសេធវិញ្ញាណ ៥ ដែលជាអនាគត ។ ពិតហើយ វិញ្ញាណទាំង ៥ នោះ រមែងមិនកើតឡើងក្នុងវត្ថុ និងអារម្មណ៍ដែលជាអនាគត ។ បទថា **បុរេជាតវត្ថុកា បុរេជាតារម្មណា** ជាការបដិសេធវិញ្ញាណ ៥ ដែលកើតឡើងព្រមគ្នា ។ ពិតហើយ វិញ្ញាណ ៥ នោះ មិនកើតឡើងព្រោះអាស្រ័យវត្ថុ ឬអារម្មណ៍ដែលកើតឡើងព្រមគ្នា ។ ឯវិញ្ញាណ ៥ នោះ ជាធម្មជាតកើតខាងក្រោយដោយខ្លួនឯង រមែងកើតឡើងក្នុងវត្ថុ និងអារម្មណ៍ដែលកើតមុន ។

បទថា **អជ្ឈត្តិកវត្ថុកា** ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃវត្ថុខាងក្នុង ដែលជារបស់ខ្លួន ។ ពិតហើយ វិញ្ញាណ ៥ នោះ រមែងធ្វើបសាទរូប ៥ ដែលជាខាងក្នុងឲ្យជាវត្ថុដែលអាស្រ័យកើត កើតឡើង ។ បទថា **ពាហិរារម្មណា** បានដល់ មានរូបខាងក្រៅជាអារម្មណ៍ ។ ក្នុងសេចក្តីនោះ បណ្ឌិតគប្បីជ្រាបចតុក្ក ៤ ។ ពិតហើយ វិញ្ញាណ ៥ ជាធម៌ជាខាងក្នុង ព្រោះមានបសាទជាវត្ថុអាស្រ័យកើត ។ មនោវិញ្ញាណជាខាងក្នុង មានវត្ថុដែលអាស្រ័យគ្នាកើត ជាខាងក្រៅ ក្នុងវេលាធ្វើហទយរូបឲ្យជាវត្ថុដែលអាស្រ័យកើត កើតឡើង ខន្ធ ៣ ដែលសម្បយុត្តដោយវិញ្ញាណ ៥ ជាខាងក្រៅ មានវត្ថុដែលអាស្រ័យកើតជាខាងក្នុង ខន្ធ ៣

ដែលសម្បយុត្តដោយមនោវិញ្ញាណជាខាងក្រៅ មានវត្ថុដែលអាស្រ័យកើតជាខាងក្រៅ ក្នុងវេលាធ្វើហទយរូបឲ្យជាវត្ថុដែលអាស្រ័យកើត កើតឡើង ។ បទថា **អសម្ភិន្នវត្ថុកា** បានដល់ មានវត្ថុដែលមិនទាន់រលត់ហើយ ។ ពិតហើយ វិញ្ញាណទាំង ៥ នោះ រមែងមិនកើតឡើង ព្រោះអាស្រ័យវត្ថុដែលរលត់ទៅហើយ គឺកន្លងទៅហើយ ។ ក្នុងភាពដែលវិញ្ញាណ ៥ មានអារម្មណ៍មិនទាន់រលត់ ក៏ន័យនេះ ។

ក្នុងបទថា **អញ្ញំ ចក្ខុវិញ្ញាណស្ស វត្ថុ ច អារម្មណាញ្ច** ជាដើម វត្ថុនិងអារម្មណ៍របស់ចក្ខុវិញ្ញាណ មួយបែប របស់សោតវិញ្ញាណជាដើម មួយបែប ។ ចក្ខុវិញ្ញាណ សូម្បីធ្វើវត្ថុឯណានីមួយក្នុងសោតប្បសាទជាដើម ឲ្យជាវត្ថុអាស្រ័យកើត ឬធ្វើរូបឯណានីមួយក្នុងសំឡេងជាដើម ឲ្យជាអារម្មណ៍ ហើយដល់នូវភាពសមគួរ ដោយភាពសមគួរ ( អាចកើតឡើង ) ក៏កើតឡើងមិនបាន តែចក្ខុវិញ្ញាណរមែងកើតឡើង ព្រោះធ្វើចក្ខុបសាទប៉ុណ្ណោះឲ្យជាវត្ថុ និងធ្វើរូបឲ្យជាអារម្មណ៍ ទើបកើតឡើងបាន ។ វត្ថុក្តី ទ្វារក្តី អារម្មណ៍ក្តី របស់ចក្ខុវិញ្ញាណនោះ ជារបស់ទាក់ទងគ្នាយ៉ាងនេះ រមែងមិនឆ្លងទៅកាន់វត្ថុដទៃ ឬទៅកាន់ទ្វារដទៃ ឬអារម្មណ៍ដទៃ ។

ចក្ខុវិញ្ញាណ មានវត្ថុដ៏ពិតប្រាកដ មានទ្វារដ៏ពិតប្រាកដ មានអារម្មណ៍ដ៏ពិតប្រាកដប៉ុណ្ណោះ ទើបកើតឡើងបាន សូម្បីក្នុងសោតវិញ្ញាណជាដើមក៏ន័យនេះឯង ។

ក្នុងបទថា **ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ** នេះ

*អធិប្បាយថា វិញ្ញាណទាំងនោះរមែងមិនសោយអារម្មណ៍នៃគ្នានិងគ្នា គឺវិញ្ញាណមួយ មិនសោយអារម្មណ៍របស់វិញ្ញាណមួយទៀត គឺចក្ខុវិញ្ញាណមិនសោយអារម្មណ៍របស់សោតវិញ្ញាណ សោតវិញ្ញាណ ក៏មិនសោយអារម្មណ៍របស់ចក្ខុវិញ្ញាណជាដើម ។ ពិតហើយ បើបុគ្គលប្រមូលមកនូវអារម្មណ៍ មានពណ៌ខៀវជាដើមហើយ គប្បីប្រគល់ឲ្យដល់សោតិន្ទ្រិយថា អញ្ជើញចុះ សូមលោកកំណត់ពណ៌នោះ ចូរប្រាប់ថា អារម្មណ៍នោះឈ្មោះអ្វី ដូច្នេះ ចក្ខុ-វិញ្ញាណមិនខ្វាចក្រែង គប្បីពោលតាមធម្មតារបស់ខ្លួន យ៉ាងនេះថា នែអ្នកល្ងង់ខ្លៅ អ្នកស្វែងរក ១០០ ឆ្នាំក្តី ១០០០ ឆ្នាំក្តី វៀរអញ គឺចក្ខុវិញ្ញាណហើយ ឯងនឹងដឹងពណ៌នោះបានដូចម្តេច សូមឯងនាំពណ៌នោះមកប្រគល់ឲ្យចក្ខុបសាទ អញនឹងដឹងនូវអារម្មណ៍នោះ ថាជាពណ៌ខៀវ ឬពណ៌លឿង ព្រោះនោះ មិនមែនជាវិស័យនៃវិញ្ញាណដទៃ នុ៎ះជាវិស័យរបស់អញប៉ុណ្ណោះ ។ សូម្បីវិញ្ញាណដ៏សេស ក៏មានន័យដូចគ្នា ។ ដោយប្រការយ៉ាងនេះ ទើបវិញ្ញាណ ៥ ឈ្មោះថា មិនសោយអារម្មណ៍នៃគ្នានិងគ្នា ។*

*បទថា* **សមន្នាហរន្តស្ស** *បានដល់ កាលនឹកគិតដោយអាវជ្ជនៈនោះឯង ។ បទថា* **មនសិករោន្តស្ស** *បានដល់ កាលធ្វើទុកក្នុងចិត្តដោយអា-វជ្ជនៈនោះឯង ។ ពិតហើយ ចិត្តទាំងនេះ គឺបញ្ចវិញ្ញាណ រមែងកើតឡើងក្នុងកាលគិតដល់ និងក្នុងកាលធ្វើទុកក្នុងចិត្តដោយអាវជ្ជនៈនោះឯង ។*

*បទថា* **ន អព្ពោកិណ្ណា** *បានដល់ មិនច្រឡូកច្រឡំដោយវិញ្ញាណដទៃ រមែងកើតឡើងជាប់តគ្នាក៏មិនមែន ។ ទ្រង់ហាមការជាប់តគ្នានៃវិញ្ញាណទាំង*

នោះ ដោយបទនេះ ។ ការកើតរួមគ្នានៃចិត្តទាំងពួង ព្រះមានព្រះភាគ ទ្រង់បដិសេធហើយ ដោយបទថា **ន អបុព្វំ អចរិមំ** នេះ ។ ទ្រង់បដិសេធការកើតឡើងបន្តបន្ទាប់លំដាប់នៃគ្នានិងគ្នា ដោយបទថា **ន អញ្ញមញ្ញស្ស សមនន្តរា** នេះ ។

សូម្បីបទ ៤ មានបទថា **អាវដ្ដនា** ជាដើម ជាឈ្មោះរបស់អាវជ្ជនៈនោះឯង ពិតហើយ ព្រះមានព្រះភាគត្រាស់ហៅអាវជ្ជនៈនោះថា **អាវដ្ដនា** ព្រោះការវិលវល់ផ្លាស់ប្ដូរទៅនៃភវង្គ ទ្រង់ត្រាស់ហៅថា **អាភោគោ** ព្រោះការគិតដល់ចិត្តនោះឯង ទ្រង់ត្រាស់ហៅថា **សមន្នាហារោ** ព្រោះប្រមូលមកនូវរូបជាដើម ត្រាស់ហៅថា **មនសិការោ** ព្រោះធ្វើទុកក្នុងចិត្តនូវរូបារម្មណ៍ទាំងនោះឯង ។ កាលដែលវិញ្ញាណ ៥ អាចតាំងនៅក្នុងឋានៈនៃអាវជ្ជនៈហើយធ្វើកិច្ច មានអាវដ្ដនាជាដើម ព្រះមានព្រះភាគ ទ្រង់ហាមហើយដោយសង្ខេបក្នុងទីនេះ ដោយអាការដូច្នេះ ។

បទថា **ន កិញ្ចិ ធម្មំ បដិវិជានាតិ** បានដល់ បុគ្គលរមែងមិនដឹងច្បាស់នូវកុសល ឬអកុសលត្រឹមតែម្យ៉ាង ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយយ៉ាងនេះថា ធម៌ទាំងឡាយ មានចិត្តជាប្រធានជាដើម ។

បទថា **អញ្ញត្រ អភិនិបាតមត្តា** បានដល់ វៀរត្រឹមតែការប៉ះពាល់របស់រូបារម្មណ៍ជាដើម ។ អធិប្បាយថា បុរសជាអ្នកឈ្លាសល្អហើយ រមែងមិនដឹងធម៌ដទៃ ត្រឹមតែមួយ បណ្ដាកុសលដោយវិញ្ញាណ ៥ វៀររូបជាដើមដែលមកកាន់គន្លង ម្យ៉ាងទៀត ចក្ខុវិញ្ញាណក្នុងទីនេះ រមែងត្រឹមតែជាការ

ឃើញប៉ុណ្ណោះ សូម្បីសោតវិញ្ញាណជាដើម ក៏រមែងត្រឹមតែការស្តាប់ ... ការហិត ... ការលិទ្ធភក្ស ... ការប៉ះពាល់ប៉ុណ្ណោះ ។ ការដឹងអារម្មណ៍ មានកុសលជាដើម របស់វិញ្ញាណទាំងនោះយ៉ាងដទៃ ដែលផុតចាកត្រឹមតែការឃើញជាដើម មិនមាន ។

បទថា **មនោធាតុយាបិ** បានដល់ ដោយមនោធាតុ គឺសម្បដិច្ឆន្នចិត្ត ។ម្យ៉ាងទៀត **បិ** អក្ខរៈ ក្នុងបទថា **មនោធាតុយាបិ** នេះ ប្រើក្នុងអត្ថសង្គ្រោះចូលគ្នា ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីនេះយ៉ាងនេះថា បុគ្គលរមែងមិនដឹងនូវធម៌ណាមួយ ដែលជាកុសល និងអកុសល ដោយវិញ្ញាណដែលប្រព្រឹត្តទៅតាមទ្វារ ៥ ទាំងអស់ គឺដោយមនោធាតុ ដោយមនោ-វិញ្ញាណធាតុទាំងឡាយ ដែលបន្តអំពីមនោធាតុនោះ ។

ក្នុងបទថា **ន កញ្ចិ ឥរិយាបថំ កប្បេតិ** ជាដើម ក៏ន័យនេះឯង ។ពិតហើយ បុគ្គលរមែងមិនសម្រេចឥរិយាបថណាមួយ ក្នុងការដើរជាដើមបានដោយវិញ្ញាណដែលប្រព្រឹត្តទៅតាមទ្វារ ៥ ។

បុគ្គលរមែងមិនតាំងកាយកម្ម មិនតាំងវចីកម្មដោយវិញ្ញាណ ៥ រមែងមិនសមាទានធម៌ ដែលជាកុសល និងអកុសល រមែងមិនចូលសមាធិ គឺសមាបត្តិដែលជាលោកិយ ឬលោកុត្តរ រមែងមិនចេញចាកសមាធិដែលជាលោកិយ ឬលោកុត្តរ រមែងមិនចុតិចាកភព រមែងមិនកើតឡើងក្នុងភពដោយវិញ្ញាណ ៥ ។ ពិតហើយ កិច្ច មានការដឹងច្បាស់នូវធម៌ដែលជាកុសល និងអកុសលជាដើម មានចុតិជាទីបំផុត ទាំងអស់នោះ រមែងមានដោយចិត្តតាម

មនោទ្វារប៉ុណ្ណោះ រមែងមិនមានដោយចិត្តដែលប្រព្រឹត្តទៅតាមទ្វារ ៥ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់បដិសេធវីថិចិត្តដែលប្រព្រឹត្តទៅជាមួយជវ័ន ក្នុងការធ្វើនូវកិច្ចទាំងពួងនេះ ក្នុងវិញ្ញាណ ៥ នេះ ។ ម្យ៉ាងទៀត កិច្ចទាំងឡាយដែលពោលហើយទាំងនោះ រមែងមិនមានដល់ចិត្តដែលប្រកបដោយវិញ្ញាណ ៥ យ៉ាងណា សូម្បីការឈានចុះកាន់និយាមធម៌ជាដើម ក៏យ៉ាងនោះ ។ ពិតហើយ បុគ្គលរមែងមិនឈានចុះកាន់មិច្ឆត្តនិយាម[១] ឬសម្មត្តនិយាម[២] បានដោយវិញ្ញាណ ៥ ។ ជវ័ននោះ ( ជវ័នក្នុងបញ្ចទ្វារ ) រមែងមិនស្ទុះទៅ ព្រោះប្រារព្ធនាម និងគោត្ត រមែងមិនស្ទុះទៅ ព្រោះប្រារព្ធបញ្ញត្តិ មានកសិណជាដើម រមែងមិនប្រព្រឹត្តទៅដោយអំណាចនៃវិបស្សនាដែលប្រកបដោយលក្ខណៈ ឬប្រកបដោយអារម្មណ៍ រមែងមិនប្រព្រឹត្តទៅដោយអំណាចនៃវិបស្សនាដែលមានកម្លាំង ដែលជាវុដ្ឋានគាមិនី រមែងមិនស្ទុះទៅ ព្រោះប្រារព្ធរូប និងអរូបធម៌ រមែងមិនស្ទុះទៅ ព្រោះប្រារព្ធព្រះនិព្វាន ។ ម្យ៉ាងទៀត បដិសម្ភិទាញាណ រមែងមិនកើតរួមជាមួយជវ័ន ( ក្នុងបញ្ចទ្វារ ) នោះ អភិញ្ញាញាណ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ សព្វញ្ញុតញ្ញាណ ក៏រមែងមិនកើតជាមួយជវ័ននោះ ។ តែធម៌មានប្រភេទផ្សេងៗ ទាំងអស់ រមែងមានក្នុងជវ័នតាមមនោទ្វារប៉ុណ្ណោះ ។

បទថា **ន សុបតិ ន បដិពុជ្ឈតិ ន សុបិនំ បស្សតិ** អធិប្បាយថា

---

១- ទំនៀមខាងខុស បានដល់ អនន្តរិយកម្ម ៥ និងនិយតមិច្ឆាទិដ្ឋិ ។

២- ទំនៀមខាងត្រូវ បានដល់ លោកុត្តរមគ្គ ៤ ។

ព្រះមានព្រះភាគ ទ្រង់បដិសេធវីថិចិត្ត មួយអន្លើដោយជវនក្នុងឋានៈទាំង ៣ នេះថា បុគ្គលរមែងមិនឈមចុះកាន់និទ្រា រមែងមិនលក់ រមែងមិនភ្ញាក់ រមែងមិនសុបិនណាមួយ ដោយចិត្តដែលប្រព្រឹត្តទៅតាមបញ្ចទ្វារទាំងអស់ ។

ពិតហើយ កាលបុគ្គលកំពុងដេកលក់ ទោះបីមានបុគ្គលអុជប្រទីបធំឲ្យឆេះសន្ធោសន្ធៅ ហើយបង្អោនប្រទីបទាំងនោះ ចូលទៅជិតភ្នែក ដំបូងអាវជ្ជនចិត្តដែលប្រព្រឹត្តទៅតាមចក្ខុទ្វារ មិនធ្វើភវង្គចិត្តឲ្យប្តូរទៅ អាវជ្ជនចិត្តដែលប្រព្រឹត្តទៅតាមមនោទ្វារប៉ុណ្ណោះ ធ្វើភវង្គចិត្តឲ្យប្តូរទៅ ។ ពេលនោះជវនចិត្តសេពអារម្មណ៍ហើយ ក៏ធ្លាក់ចុះកាន់ភវង្គ ។ ក្នុងវារៈទី ២ អាវជ្ជនចិត្តដែលប្រព្រឹត្តទៅតាមចក្ខុទ្វារ ធ្វើភវង្គចិត្ត ឲ្យប្រព្រឹត្តទៅ បន្ទាប់អំពីនោះ វីថិចិត្ត មានចក្ខុវិញ្ញាណជាដើម មានជវនចិត្តជាទីបំផុត ក្នុងលំដាប់បន្ទាប់អំពីជវនចិត្តនោះ ភវង្គចិត្ត រមែងប្រព្រឹត្តទៅ ។ ក្នុងវារៈទី ៣ កាលអាវជ្ជនចិត្តដែលប្រព្រឹត្តទៅតាមមនោទ្វារ ធ្វើភវង្គចិត្ត ឲ្យប្រព្រឹត្តទៅហើយទើបជវនចិត្តដែលប្រព្រឹត្តទៅតាមមនោទ្វារ ស្ទុះទៅ ។ កាលដឹងដោយចិត្តនោះ ទើបបុគ្គលដឹងថា ពន្លឺនេះ គឺពន្លឺអ្វី ។

ដោយទំនងដូចគ្នានេះដែរ កាលបុគ្គលកំពុងដេកលក់ស៊ប់ ទោះបីបុគ្គលណាម្នាក់ ប្រគំតន្ត្រីក្បែរត្រចៀក ឬបង្អោនផ្កាដែលមានក្លិនក្រអូបក្តី ស្អុយក្តី ចូលទៅក្បែរច្រមុះ ឬដាក់សប្បិក្តី ទឹកអំពៅក្តី ចូលទៅក្នុងមាត់ យកបាតដៃវាយត្រង់ខ្នងក្តី ដំបូង អាវជ្ជនចិត្ត ដែលប្រព្រឹត្តទៅតាមសោតទ្វារជាដើម មិនធ្វើភវង្គចិត្តឲ្យប្តូរទៅ ។ អាវជ្ជនចិត្ត ដែលប្រព្រឹត្តទៅតាមមនោទ្វារប៉ុណ្ណោះ

ធ្វើភវង្គចិត្តឲ្យប្តូរទៅ លំដាប់នោះ ជវនចិត្តសេពអារម្មណ៍ហើយក៏ធ្លាក់ចុះកាន់ភវង្គ ។ ក្នុងវារៈទី ២ អាវជ្ជនចិត្ត ដែលប្រព្រឹត្តទៅក្នុងសោតទ្វារជាដើម រមែងធ្វើភវង្គចិត្ត ឲ្យប្រព្រឹត្តទៅ បន្ទាប់អំពីនោះវិថិចិត្ត មានសោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណជាដើម មានជវនចិត្តជាទីបំផុត រមែងប្រព្រឹត្តទៅ ។ បន្ទាប់អំពីជវនចិត្តនោះ ភវង្គចិត្ត រមែងប្រព្រឹត្តទៅ ។ ក្នុងវារៈទី ៣ អាវជ្ជនចិត្តដែលប្រព្រឹត្តទៅតាមមនោទ្វារ ធ្វើភវង្គចិត្តឲ្យប្តូរទៅ ជវនចិត្តដែលប្រព្រឹត្តទៅតាមមនោទ្វារ ក៏ស្ទុះទៅ ។ កាលដឹងដោយចិត្តនោះ ទើបបុគ្គលប្រាប់បានថា សំឡេងក្នុងទីនេះ ជាសំឡេងអ្វី គឺជាសំឡេងស័ង្ខ សំឡេងស្គរ ឬក្លិនក្នុងទីនេះណាមួយ គឺក្លិនឫសឈើ ក្លិនខ្លឹមឈើ ឬថា រសដែលដាក់ចូលទៅក្នុងមាត់របស់ខ្ញុំនេះ ជារសអ្វី ជារសសប្បិ ឬជារស ទឹកអំពៅ ឬថា អ្នកណាវាយខ្នងខ្ញុំ វាយខ្ញុំខ្លាំងពិតៗ ។ បុគ្គលរមែងភ្ញាក់ឡើងដោយជវនចិត្តដែលប្រព្រឹត្តទៅតាមបញ្ចទ្វារ ។ បុគ្គលរមែងយល់សប្តិ ដោយជវនចិត្តតាមមនោទ្វារនោះឯង មិនមែនយល់សប្តិដោយជវនចិត្តដែល ប្រព្រឹត្តទៅតាមបញ្ចទ្វារ ។

## ហេតុនៃការយល់សប្តិ ៤ យ៉ាង

បុគ្គលកាលយល់សប្តិនោះ រមែងយល់សប្តិដោយហេតុ ៤ ប្រការ គឺ ព្រោះធាតុកម្រើក ១ ព្រោះអារម្មណ៍ ធ្លាប់សោយមក ១ ព្រោះទេវតា

បណ្ដាលចិត្ត ១ ព្រោះបុព្វនិមិត្ត ១ ។

ក្នុង ៤ យ៉ាងនោះ បុគ្គលមានធាតុកម្រើក ព្រោះប្រកបដោយបច្ច័យមានប្រមាត់ជាដើម ធ្វើឲ្យខុសប្រក្រតី ទើបឈ្មោះថា យល់សប្តិព្រោះធាតុកម្រើក ។ម្យ៉ាងទៀត កាលយល់សប្តិឃើញរឿងផ្សេងៗ ដូចកំពុងធ្លាក់អំពីភ្នំ ដូចកំពុងហោះទៅតាមអាកាស និងដូចត្រូវសត្វសាហាវ មានដំរី និងចោរជាដើមដេញតាមហើយ ។

បុគ្គលកាលយល់សប្តិ ព្រោះធ្លាប់ជួបមក រមែងយល់សប្តិឃើញអារម្មណ៍ដែលខ្លួនធ្លាប់ជួបប្រទះមកហើយ ក្នុងកាលមុន ។

សម្រាប់បុគ្គលដែលយល់សប្តិ ព្រោះទេវតាបណ្ដាលចិត្ត ទេវតារមែងបង្អោនអារម្មណ៍មានបែបផ្សេងៗ ចូលទៅដើម្បីប្រយោជន៍ ឬដើម្បីវត្ថុមិនជាប្រយោជន៍ ព្រោះជាអ្នកប្រាថ្នាប្រយោជន៍ ឬព្រោះជាអ្នកប្រាថ្នាវត្ថុមិនជាប្រយោជន៍ បុគ្គលនោះ រមែងយល់សប្តិឃើញអារម្មណ៍ទាំងនោះ ដោយអានុភាពនៃទេវតាទាំងនោះ ។

បុគ្គលកាលយល់សប្តិ ព្រោះបុព្វនិមិត្ត រមែងយល់សប្តិឃើញជាបុព្វ-និមិត្ត ( ប្រផ្នូល ) នៃប្រយោជន៍ ឬវត្ថុមិនជាប្រយោជន៍ ដែលបម្រុងនឹងកើតដោយអំណាចនៃបុណ្យ និងបាប ដូចព្រះមាតារបស់ព្រះពោធិសត្វ ទ្រង់សុបិននិមិត្តក្នុងការបានបុត្ត និងដូចព្រះពោធិសត្វ ទ្រង់មហាសុបិននិមិត្ត ៥ យ៉ាង និងដូចព្រះបាទបសេនទិកោសលទ្រង់សុបិននិមិត្ត ១៦ យ៉ាង ។

ក្នុងហេតុទាំង ៤ នោះ បុគ្គលយល់សប្តិឃើញវត្ថុណា ព្រោះធាតុកម្រើក

និងព្រោះធ្លាប់ជួបមក វត្ថុនោះ មិនមែនជាការពិតឡើយ ។ បុគ្គលយល់សប្តិឃើញវត្ថុណា ព្រោះទេវតាបណ្តាលចិត្ត វត្ថុនោះពិតខ្លះ មិនពិតខ្លះ ព្រោះថាទេវតាក្រោធហើយ ប្រាថ្នានឹងឲ្យដល់នូវសេចក្តីវិនាស ដោយឧបាយរបស់ខ្លួន ទើបបណ្តាលវត្ថុនោះឲ្យវិបរិតទៅក៏បាន ។ ក្នុងសេចក្តីនោះ មានរឿងនេះជានិទស្សនៈថា

បានឮថា ក្នុងនាគមហាវិហារ ក្នុងព្រះនគររោហណៈ ព្រះមហាថេរៈមិនសូមអនុញ្ញាតអំពីភិក្ខុសង្ឃ ប្រើឲ្យកាប់ដើមខ្ទឹងមួយដើម ទេវតាដែលនៅអាស្រ័យត្រង់ដើមឈើ ខឹងក្រោធនឹងព្រះថេរៈហើយ ជាដំបូងធ្វើជាលួងលោមព្រះថេរៈ បន្ទាប់មក ក៏ពន្យល់សប្តិថា ព្រះរាជាដែលជាឧបដ្ឋាករបស់លោកម្ចាស់នឹងសោយទិវង្គត ក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះ ។ ព្រះថេរៈ ក៏នាំរឿងនោះទៅប្រាប់ដល់ស្នំរបស់ព្រះរាជា ។ ពួកស្រីស្នំនាំគ្នាស្រែកដោយសំឡេងខ្លាំងព្រមគ្នា ព្រះរាជាសួរថា នុ៎ះជាសំឡេងអ្វី ពួកស្រីស្នំទាំងនោះទូលថា ព្រះថេរៈពោលយ៉ាងនេះ ។ ព្រះរាជាឲ្យរាជបុរសរាប់ចំនួនថ្ងៃ កាល ៧ ថ្ងៃកន្លងទៅ ( ព្រះរាជាមិនសោយទីវង្គត ) ទ្រង់ព្រះពិរោធ បញ្ជាឲ្យកាត់ដៃនិងជើងរបស់ព្រះថេរៈ ។

បុគ្គលយល់សប្តិឃើញវត្ថុណាព្រោះបុព្វនិមិត្ត វត្ថុនោះ រមែងពិតដោយចំណែកមួយ ។ ការផ្សេងគ្នានៃយល់សប្តិរមែងមាន ព្រោះការផ្សេងគ្នាទៅតាមការទាក់ទងដោយមូលហេតុទាំង ៤ នេះឯង ។

ព្រះសេក្ខៈ និងបុថុជ្ជនប៉ុណ្ណោះ រមែងយល់សប្តិទាំង ៤ យ៉ាងនេះ ព្រោះ

មិនទាន់បានលះវិបល្លាស ៤ ព្រះអសេក្ខបុគ្គលរមែងមិនយល់សប្តិ ព្រោះលះវិបល្លាសបានហើយ ។

សួរថា បុគ្គលកាលយល់សប្តិ លក់ហើយយល់សប្តិ ឬភ្ញាក់ហើយយល់សប្តិ ឬមិនមែនលក់ និងមិនមែនភ្ញាក់ហើយយល់សប្តិ ឆ្លើយថា ក្នុងទីនេះ ការយល់សប្តិដូចម្ដេច គប្បីជ្រាបដូច្នេះ បើបុគ្គលដេកលក់ ហើយយល់សប្តិសោត សេចក្ដីនេះ មិនត្រូវតាមព្រះអភិធម្ម ព្រោះថា បុគ្គលដេកលក់ដោយភវង្គចិត្ត ភវង្គចិត្តនោះ រមែងមិនមានរូបនិមិត្តជាដើមជាអារម្មណ៍ មិនសម្បយុត្តដោយកិលេស មានរាគៈជាដើមឡើយ ឯបុគ្គលយល់សប្តិ ចិត្តទាំងឡាយបែបនេះ គឺចិត្តដែលសម្បយុត្តដោយរាគៈជាដើម រមែងកើតឡើង ។

បើបុគ្គលភ្ញាក់រមែងយល់សប្តិ សេចក្ដីនេះមិនត្រូវតាមព្រះវិន័យ ព្រោះបុគ្គលភ្ញាក់ហើយយល់សប្តិឃើញវត្ថុណា យល់សប្តិឃើញវត្ថុនោះ ដោយចិត្តដែលប្រព្រឹត្តទៅដោយអព្វោហារិក តែឈ្មោះថា អនាបត្តិ ព្រោះការឈានកន្លងបញ្ញត្តិដែលភិក្ខុធ្វើហើយ ដោយចិត្តដែលប្រព្រឹត្តទៅដោយអព្វោ-ហារិកមិនមាន តែរមែងជាអនាបត្តិដោយចំណែកមួយ ព្រោះការឈានកន្លងបញ្ញត្តិដែលភិក្ខុអ្នកយល់សប្តិធ្វើហើយ ។

បើបុគ្គលមិនលក់មិនភ្ញាក់រមែងយល់សប្តិ បុគ្គលនោះ រមែងមិនឈ្មោះថាយល់សប្តិ ។ សួរថា កាលបើយ៉ាងនោះ មិនមានការយល់សប្តិឬ ឆ្លើយថា មិនមានក៏មិនមែន សួរថា សេចក្ដីនេះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះ

បុគ្គលត្រូវដេកលក់ដូចស្វាគ្របសង្កត់ហើយ ទើបយល់សប្តិ សមដូចលោកពោលថា មហាបពិត្រ បុគ្គលដេកលក់ដូចស្វាគ្របសង្កត់ហើយ រមែងយល់សប្តិ ។ ពាក្យថា ដេកលក់ដូចស្វាគ្របសង្កត់ បានដល់ ដែលប្រកបដោយការដេកលក់ដូចស្វា ។ ពិតហើយ ការដេកលក់ណា ឈ្មោះថាផ្លាស់ប្តូរទៅដោយរហ័ស ព្រោះប្រឡូកប្រឡំហើយដោយកុសលចិត្តជាដើមរឿយៗ ដូចការដេកលក់របស់ស្វា រមែងផ្លាស់ប្តូរទៅរហ័សក្នុងការប្រព្រឹត្តទៅនៃការដេកលក់ណា មានការដាច់ខ្សែភវង្គរឿយៗ បុគ្គលដែលប្រកបដោយការដេកលក់នោះរមែងយល់សប្តិ ព្រោះហេតុនោះ ការយល់សប្តិនេះទើបជាកុសលខ្លះ ជាអកុសលខ្លះ ជាអព្យាកតខ្លះ ។ ក្នុងការយល់សប្តិទាំងនោះ កាលបុគ្គលយល់សប្តិថា បានថ្វាយបង្គំព្រះចេតិយ ស្តាប់ធម៌ សម្តែងធម៌ជាដើម ការយល់សប្តិគប្បីជ្រាបថា ជាកុសល កាលយល់សប្តិថា ធ្វើបាណាតិបាតជាដើម ការយល់សប្តិគប្បីជ្រាបថា ជាអកុសល ការយល់សប្តិដែលផុតចាកចិត្តទាំង ២ នេះ ក្នុងខណៈនៃអាវជ្ជនៈ និងតទារម្មណៈគប្បីជ្រាបថា ជាអព្យាកត ។ ក្នុងកាលដែលពោលដោយរឿងយល់សប្តិប៉ុណ្ណោះថា វត្ថុនេះស្រដៀងគ្នានឹងរឿងដែលខ្ញុំឃើញហើយ វត្ថុនេះស្រដៀងគ្នានឹងរឿងដែលខ្ញុំឮហើយ ការយល់សប្តិក៏ជាអព្យាកតដូចគ្នា ។

សួរថា កុសលធម៌ និងអកុសលធម៌ ដែលបុគ្គលធ្វើក្នុងខណៈយល់សប្តិជាធម៌មានវិបាក ឬមិនមានវិបាក ឆ្លើយថា មានវិបាក តែកម្មដែលធ្វើក្នុងគ្រាយល់សប្តិនោះ មិនអាចឲ្យបដិសន្ធិបានទេ ព្រោះវិបាកនោះមានកម្លាំង

ខ្សោយ កាលកម្មដទៃបដិសន្ធិហើយ កម្មដែលធ្វើក្នុងគ្រាយល់សប្តិរមែងឲ្យផលបានក្នុងបវត្តិកាល ។

បទថា **ឯវំ យាថាវករវត្ថុ វិភាវនាបញ្ញា** បានដល់ ការអធិប្បាយវិញ្ញាណ ៥ ថា នហេតុ ជាការអធិប្បាយតាមសេចក្តីពិត ។ បញ្ញា ឈ្មោះថា ជាគ្រឿងសម្តែងរឿងរបស់វិញ្ញាណ ៥ តាមសេចក្តីពិត ព្រោះអត្ថថា ញ៉ាំងរឿងតាមសេចក្តីពិតនោះឲ្យជាក់ច្បាស់ ។ ដូចគ្នានេះដែរ ការអធិប្បាយវិញ្ញាណ ៥ ថាជាអហេតុកៈ ការអធិប្បាយវិញ្ញាណ ៥ ថាត្រូវជាគ្របសង្កត់ ការអធិប្បាយវិញ្ញាណ ៥ ថាមិនយល់សប្តិ ជាការអធិប្បាយតាមសេចក្តីពិត ។ បញ្ញា ឈ្មោះថា ជាគ្រឿងសម្តែងរឿងរបស់វិញ្ញាណ ៥ តាមសេចក្តីពិត ព្រោះអត្ថថា ញ៉ាំងរឿងតាមសេចក្តីពិតនោះ ឲ្យជាក់ច្បាស់ ។ បញ្ញាណា ដែលព្រះមានព្រះភាគទ្រង់តាំងទុកក្នុងមាតិកាខាងក្រោយថា បញ្ញាជាគ្រឿងសម្តែងតាមលំដាប់នៃមាតិកាយ៉ាងនេះឯង បញ្ញានោះ គប្បីជ្រាបថា ការដឹងរឿងរបស់វិញ្ញាណ ៥ ដូចពោលមកនេះ ឈ្មោះថា បញ្ញាជាគ្រឿងសម្តែងតាមលំដាប់នៃមាតិកាយ៉ាងនេះឯង ដូចពណ៌នាមក ដូច្នេះ ។ ការរាប់ញាណដោយចំណែកនីមួយៗ ឬការកំណត់ញាណដោយអាការៈមួយៗ យ៉ាងនេះថា ញាណវត្ថុ មានប្រការ ១ យ៉ាងនេះ រមែងមានដោយអំណាចនៃបញ្ញានោះឯង ។៚

**អដ្ឋកថាឯកកនិទ្ទេស ចប់**

# អភិធម្មបិដក

## ទុកនិទ្ទេស

[ ៣៧ ] បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាជាលោកិយ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាជាលោកុត្តរ ។ បញ្ញាទាំងអស់ បុគ្គលត្រូវដឹងដោយវិញ្ញាណនីមួយ មិនត្រូវដឹងដោយវិញ្ញាណនីមួយ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រកបដោយអាសវៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមិនមានអាសវៈ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាជាប្រយោជន៍ដល់សញ្ញោជនៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមិនជាប្រយោជន៍ដល់សញ្ញោជនៈ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាដែលគន្ថៈគប្បីដោតក្រង បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាដែលគន្ថៈមិនគប្បីដោតក្រង ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង បញ្ញាក្នុងមគ្គ ៤ ក្នុង

ផល ៤ ឈ្មោះថា បញ្ញាប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រង ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាដែលឱឃៈគប្បីប្រព្រឹត្តកន្លង បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លង បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកឱឃៈ ទាំងឱឃៈមិនគប្បីប្រព្រឹត្តកន្លង ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាដែលយោគៈគប្បីប្រព្រឹត្តកន្លង បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកយោគៈ តែយោគៈគប្បីប្រព្រឹត្តកន្លង បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកយោគៈ ទាំងយោគៈមិនគប្បីប្រព្រឹត្តកន្លង ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាជាប្រយោជន៍ដល់នីវរណៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមិនជាប្រយោជន៍ដល់នីវរណៈ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាដែលបរាមាសស្ទាបអង្អែល បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះ

ថា បញ្ញាដែលបរាមាសមិនស្ទាបអង្អែល ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែល បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែល ។ បញ្ញាក្នុងវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាដែលកិលេស មានតណ្ហាជាដើមកាន់យកហើយ បញ្ញាក្នុងកុសលប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងកិរិយា និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាដែលកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាជាប្រយោជន៍ដល់ឧបាទាន បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមិនជាប្រយោជន៍ដល់ឧបាទាន ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាគួរដល់នូវសេចក្តីសៅហ្មង បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមិនគួរដល់នូវសេចក្តីសៅហ្មង ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកសេចក្តីសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ។ បញ្ញាសម្បយុត្តដោយវិតក្ក

ឈ្មោះថា បញ្ញាប្រកបដោយវិតក្ក បញ្ញាប្រាសចាកវិតក្ក ឈ្មោះថា បញ្ញាមិនមានវិតក្ក ។ បញ្ញាសម្បយុត្តដោយវិចារ ឈ្មោះថា បញ្ញាប្រកបដោយវិចារ បញ្ញាប្រាសចាកវិចារ ឈ្មោះថា បញ្ញាមិនមានវិចារ ។ បញ្ញាសម្បយុត្តដោយបីតិ ឈ្មោះថា បញ្ញាប្រកបដោយបីតិ បញ្ញាប្រាសចាកបីតិ ឈ្មោះថា បញ្ញាមិនមានបីតិ ។ បញ្ញាសម្បយុត្តដោយបីតិ ឈ្មោះថា បញ្ញាកើតព្រមដោយបីតិ បញ្ញាប្រាសចាកបីតិ ឈ្មោះថា បញ្ញាមិនកើតព្រមដោយបីតិ ។ បញ្ញាសម្បយុត្តដោយសុខ ឈ្មោះថា បញ្ញាកើតព្រមដោយសុខ បញ្ញាប្រាសចាកសុខ ឈ្មោះថា បញ្ញាមិនកើតព្រមដោយសុខ ។ បញ្ញាសម្បយុត្តដោយឧបេក្ខា ឈ្មោះថា បញ្ញាកើតព្រមដោយឧបេក្ខា បញ្ញាប្រាសចាកឧបេក្ខា ឈ្មោះថា បញ្ញាមិនកើតព្រមដោយឧបេក្ខា ។ បញ្ញាក្នុងកាមាវចរកុសល និងអព្យាក្រឹត ឈ្មោះថា បញ្ញាជាកាមាវចរ ឯបញ្ញាជារូបាវចរ បញ្ញាជាអរូបាវចរ បញ្ញាជាអបរិយាបន្ន មិនឈ្មោះថា បញ្ញាជាកាមាវចរទេ ។ បញ្ញាក្នុងរូបាវចរកុសល និងអព្យាក្រឹត ឈ្មោះថា បញ្ញាជារូបាវចរ ឯបញ្ញាជាកាមាវចរ បញ្ញាជាអរូបាវចរ បញ្ញាជាអបរិយាបន្ន មិនឈ្មោះថា បញ្ញាជារូបាវចរទេ ។ បញ្ញាក្នុងអរូបាវចរកុសល និងអព្យាក្រឹត ឈ្មោះថា បញ្ញាជាអរូបាវចរ ឯបញ្ញាជាកាមាវចរ បញ្ញាជារូបាវចរ បញ្ញាជាអបរិយាបន្ន មិនឈ្មោះថា បញ្ញាជាអរូបាវចរទេ ។ បញ្ញាក្នុងកុសល និងអព្យាក្រឹតប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាជាបរិយាបន្ន បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាជាអបរិយាបន្ន ។ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤

ឈ្មោះថា បញ្ញាជានិយ្យានិកៈ បញ្ញាក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងវិបាកប្រព្រឹត្តទៅក្នុងភូមិ ៤ ក្នុងកិរិយា និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាជាអនិយ្យានិកៈ ។ បញ្ញាក្នុងមគ្គ ៤ ឈ្មោះថា បញ្ញាទៀង បញ្ញាក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងវិបាកប្រព្រឹត្តទៅក្នុងភូមិ ៤ ក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាមិនទៀង ។ បញ្ញាក្នុងកុសល និងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រកបដោយឧត្តរៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាជាអនុត្តរៈ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាញុំាងប្រយោជន៍ឲ្យកើត តើដូចម្ដេច ។ បញ្ញាជាកិរិយាអព្យាក្រឹតក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៤ របស់ព្រះអរហន្ត កាលញុំាងអភិញ្ញាឲ្យកើតឡើង កាលញុំាងសមាបត្តិឲ្យកើតឡើង ឈ្មោះថា បញ្ញាញុំាងប្រយោជន៍ឲ្យកើត បញ្ញាជាកិរិយាអព្យាក្រឹត ក្នុងអភិញ្ញាដែលកើតហើយ ក្នុងសមាបត្តិដែលកើតហើយ របស់ព្រះអរហន្ត ក្នុងវិបាកប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា បញ្ញាមានប្រយោជន៍កើតហើយ ។

## ញាណវត្ថុ មានប្រការ ២ យ៉ាងនេះឯង

# អដ្ឋកថា

## ទុកនិទ្ទេស

[ ៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងញាណវត្ថុពួក ២ ដូចតទៅនេះ បទថា **ចតូសុ ភូមីសុ កុសលេ** បានដល់ បញ្ញាខាងកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ របស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងទីនេះថា បញ្ញាណាញុំាងនូវសំយោជនៈ ពោល គឺវិបាកដែលទាក់ទងហើយក្នុងភូមិរបស់ខ្លួនឲ្យកើតឡើង ឲ្យបាននូវផល គឺឲ្យប្រព្រឹត្តទៅក្នុងអត្ថ ៥ យ៉ាង[១] ដែលខ្ញុំបានពោលហើយក្នុងបដិសម្ភិទាវិភង្គ ព្រោះហេតុនោះ ទើបបញ្ញានោះឈ្មោះថា បញ្ញាញុំាងប្រយោជន៍ឲ្យកើត ។

បទថា **អរហតោ អភិញ្ញំ ឧប្បាទេន្តស្ស សមាបត្តឹ ឧប្បាទេន្តស្ស កិរិយាព្យាកតេ** បានដល់ បញ្ញាខាងកាមាវចរកិរិយា ក្នុងវេលាធ្វើបរិកម្មដើម្បីអភិញ្ញា និងដើម្បីសមាបត្តិ ។ ពិតហើយ បញ្ញានោះរមែងធ្វើប្រយោជន៍ ពោល គឺកិរិយា មានអភិញ្ញា និងសមាបត្តិឲ្យកើត ឲ្យបាននូវផល ឲ្យប្រព្រឹត្តទៅទូទៅ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា បញ្ញាញុំាងប្រយោជន៍ឲ្យកើត ។ ន័យរបស់អដ្ឋកថា ដែលជាបាលីមុត្តកៈ ន័យម្យ៉ាងទៀតដូចតទៅ

បញ្ញាណាជាកាមាវចរកិរិយាដែលកើតឡើងមុន រមែងជាបច្ច័យដល់កាមាវចរកិរិយាដែលកើតឯក្រោយ ដោយអំណាចអនន្តរប្បច្ច័យជាដើម បញ្ញា

---

១- សភាវៈណាមួយដែលអាស្រ័យគ្នាកើតឡើង ព្រោះបច្ច័យ ១ ព្រះនិព្វាន ១ អត្ថនៃភាសិត ១ វិបាក ១ កិរិយា ១ ( សូមមើលត្រង់អដ្ឋកថាបដិសម្ភិទាវិភង្គ លេខឃ្នាប ១១-១៧ ) ។

នោះ ឈ្មោះថា **អត្ថជាបិកបញ្ញា** ព្រោះអត្ថថា ញ៉ាំងប្រយោជន៍ ពោល គឺកិរិយានោះ ឲ្យកើតឡើង សូម្បីបញ្ញាក្នុងរូបាវចរ និងអរូបាវចរ ក៏ន័យនេះឯង ។

ក្នុងនិទ្ទេសនៃបទទី ២ បទថា **ចតូសុ ភូមីសុ វិបាកេ** បានដល់ បញ្ញាក្នុងកាមាវចរវិបាក ឈ្មោះថា **ជាបិតត្ថា** គឺបញ្ញាមានប្រយោជន៍កើតហើយ ព្រោះញ៉ាំងប្រយោជន៍ក្នុងកាមាវចរវិបាកឲ្យកើតហើយ តាំងនៅដោយអំណាចនៃបច្ច័យ មានសហជាតបច្ច័យជាដើម ។ បញ្ញាក្នុងវិបាក មានរូបាវចរវិបាកជាដើមក៏ន័យនេះដូចគ្នា ។ មួយទៀត បញ្ញាទាំងអស់នេះ ឈ្មោះថា **ជាបិតត្ថា** ព្រោះអត្ថថា ឲ្យកើត ឲ្យបានផល ឲ្យប្រព្រឹត្តទៅទូទៅ ដោយហេតុទាំងឡាយរៀងៗ ខ្លួនខ្លះ សូម្បីខ្លួនឯង ក៏ជាប្រយោជន៍ខ្លះ ។

ក្នុងបញ្ញាដែលជាកិរិយា ដែលព្រះមានព្រះភាគ ត្រាស់ថា ( បញ្ញាជាកិរិយាអព្យាក្រឹត ) ក្នុងអភិញ្ញាដែលកើតហើយ ក្នុងសមាបត្តិដែលកើតហើយ របស់ព្រះអរហន្ត ដូច្នេះ ក៏ន័យនេះឯង ។

ន័យរបស់អដ្ឋកថាដែលជាបាលីមុត្តកៈមួយទៀតដូចតទៅ

បញ្ញាក្នុងកាមាវចរកិរិយា ឈ្មោះថា បញ្ញាញ៉ាំងប្រយោជន៍ឲ្យកើត ព្រោះអត្ថថា ញ៉ាំងប្រយោជន៍ ពោល គឺកាមាវចរកិរិយា ឲ្យកើត ហើយតាំងនៅដោយអំណាចនៃសហជាតបច្ច័យជាដើម ។ សូម្បីក្នុងបញ្ញាដែលជាកិរិយាក្នុងរូបាវចរ និងអរូបាវចរ ក៏ន័យនេះឯង ។

ម្យ៉ាងទៀត បញ្ញាទាំងអស់នេះ ឈ្មោះថា បញ្ញាញុំាងប្រយោជន៍ឲ្យកើត ព្រោះអត្ថថា ឲ្យកើត ឲ្យបានផល ឲ្យប្រព្រឹត្តទៅទូទៅដោយហេតុទាំងឡាយ រៀងៗ ខ្លួនខ្លះ សូម្បីខ្លួនឯងក៏ជាប្រយោជន៍ខ្លះ ។ ពាក្យដ៏សេសទាំងអស់ក្នុងទីនេះប្រាកដច្បាស់ហើយនោះឯង ព្រោះមានន័យដូចពោលហើយក្នុងអដ្ឋកថាធម្មសង្គហៈ ដូច្នេះ ៕

## អដ្ឋកថាឯកកនិទ្ទេស ចប់

# អភិធម្មបិដក

## តិកនិទ្ទេស

[ ៣៨ ] បណ្តាបញ្ញាទាំងនោះ ចិន្តាមយប្បញ្ញា តើដូចម្តេច ។ បុគ្គល មិនបានស្តាប់ ( នូវពាក្យពន្យល់ ) អំពីសម្នាក់បុគ្គលដទៃទេ តែបាននូវសេចក្តីគាប់ចិត្ត នូវសេចក្តីយល់ឃើញ នូវសេចក្តីពេញចិត្ត នូវការឈ្វេងយល់ នូវសេចក្តីពិនិត្យឃើញ នូវការចូលចិត្ត ក្នុងការសម្លឹងមើលនូវធម៌ដ៏សមគួរណាយ៉ាងនេះ ក្នុងការងារប្រកបដោយឧបាយបញ្ញាក្តី ក្នុងសិល្បសាស្ត្រប្រកបដោយឧបាយបញ្ញាក្តី ក្នុងវិជ្ជាស្ថានប្រកបដោយឧបាយបញ្ញាក្តី ថា សត្វមានកម្មជារបស់ខ្លួនក្តី ថាសត្វប្រព្រឹត្តទៅតាមមគ្គសច្ចក្តី ថារូបមិនទៀងក្តី ថាវេទនាមិនទៀងក្តី ថាសញ្ញាមិនទៀងក្តី ថាសង្ខារទាំងឡាយមិនទៀងក្តី ថាវិញ្ញាណមិនទៀងក្តី នេះហៅថា ចិន្តាមយប្បញ្ញា ។ បណ្តាបញ្ញាទាំងនោះ សុតមយប្បញ្ញា តើដូចម្តេច ។ បុគ្គលបានស្តាប់ ( នូវពាក្យពន្យល់ ) អំពីសម្នាក់នៃបុគ្គលដទៃហើយ បាននូវសេចក្តីគាប់ចិត្ត នូវសេចក្តីយល់ឃើញ នូវសេចក្តីពេញចិត្ត នូវការឈ្វេងយល់ នូវសេចក្តីពិនិត្យឃើញ នូវការចូលចិត្ត ក្នុងការសម្លឹងមើលនូវធម៌ដ៏សមគួរយ៉ាងនេះ ក្នុងការងារប្រកបដោយឧបាយប្រាជ្ញាក្តី ក្នុងសិល្បសាស្ត្រ ប្រកបដោយឧបាយប្រាជ្ញាក្តី ក្នុងវិជ្ជាស្ថានប្រកបដោយឧបាយប្រាជ្ញាក្តី ថាសត្វមានកម្មជារបស់ខ្លួនក្តី ថាសត្វប្រព្រឹត្តទៅតាមមគ្គសច្ចក្តី ថារូបមិនទៀងក្តី ថាវេទនាមិនទៀងក្តី ថាសញ្ញាមិនទៀងក្តី ថាសង្ខារទាំងឡាយមិនទៀងក្តី ថាវិញ្ញាណមិនទៀង

ក្តី នេះហៅថា សុតមយប្បញ្ញា ។ បញ្ញាទាំងអស់ របស់បុគ្គលចូលកាន់សមាបត្តិ ឈ្មោះថា ភាវនាមយប្បញ្ញា ។

[ ៣៩ ] បណ្តាបញ្ញាទាំងនោះ ទានមយប្បញ្ញា តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធទាន ព្រោះបានទាន នេះហៅថា ទានមយប្បញ្ញា ។ បណ្តាបញ្ញាទាំងនោះ សីលមយប្បញ្ញា តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើងព្រោះប្រារព្ធសីល ព្រោះបានសីល នេះហៅថា សីលមយប្បញ្ញា ។ បញ្ញាទាំងអស់ របស់បុគ្គលដែលចូលកាន់សមាបត្តិ ឈ្មោះថា ភាវនាមយប្បញ្ញា ។

[ ៤០ ] បណ្តាបញ្ញាទាំងនោះ បញ្ញាក្នុងអធិសីល តើដូចម្តេច ។ កាលដែលបុគ្គលសង្រួមក្នុងបាតិមោក្ខសំវរៈ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង នេះហៅថា បញ្ញាក្នុងអធិសីល ។ បណ្តាបញ្ញាទាំងនោះ បញ្ញាក្នុងអធិចិត្ត តើដូចម្តេច ។ កាលបុគ្គលចូលកាន់រូបាវចរសមាបត្តិ និងអរូបាវចរសមាបត្តិ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង នេះហៅថា បញ្ញាក្នុងអធិចិត្ត ។ បណ្តាបញ្ញាទាំងនោះ បញ្ញាក្នុងអធិប្បញ្ញា តើដូចម្តេច ។ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ នេះហៅថា បញ្ញាក្នុងអធិប្បញ្ញា ។

[ ៤១ ] បណ្ដាបញ្ញាទាំងនោះ សេចក្ដីឈ្លាសក្នុងការចម្រើន តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះថា កាលបុគ្គលធ្វើទុកក្នុងចិត្តនូវធម៌ពួកនេះ ធម៌ទាំងឡាយ ជាអកុសលដែលមិនទាន់កើត ក៏មិនកើតឡើង ទាំងពួកធម៌ជាអកុសលដែលកើតហើយ ក៏សាបសូន្យទៅវិញ ពុំនោះសោត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវធម៌ពួកនេះៗ ធម៌ទាំងឡាយ ជាកុសលដែលមិនទាន់កើត ក៏កើតឡើង ទាំងពួកធម៌ជាកុសលដែលកើតហើយ ក៏ប្រព្រឹត្តទៅដើម្បីភាពដ៏ក្រៃលែង ដើម្បីភាពដ៏ធំទូលាយ ដើម្បីសេចក្ដីចម្រើន ដើម្បីពេញលេញ នេះហៅថា សេចក្ដីឈ្លាសក្នុងការចម្រើន ។ បណ្ដាបញ្ញាទាំងនោះ សេចក្ដីឈ្លាស ក្នុងការមិនចម្រើន តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណាក្នុងធម៌ទាំងឡាយនោះថា កាលបុគ្គលធ្វើទុកក្នុងចិត្តនូវធម៌ពួកនេះ ធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើត ក៏មិនកើតឡើង ទាំងពួកធម៌ជាកុសលដែលកើតហើយ ក៏រលត់ទៅវិញ ពុំនោះសោត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវធម៌ពួកនេះៗ ធម៌ទាំងឡាយ ជាអកុសល ដែលមិនទាន់កើត ក៏កើតឡើង ទាំងពួកធម៌ជាអកុសល ដែលកើតហើយ ក៏ប្រព្រឹត្តទៅ ដើម្បីភាពដ៏ក្រៃលែង ដើម្បីភាពដ៏ធំទូលាយ នេះហៅថា សេចក្ដីឈ្លាស ក្នុងការមិនចម្រើន ។ បញ្ញាទាំងអស់ ជាឧបាយក្នុងធម៌ទាំងនោះ ឈ្មោះថា សេចក្ដីឈ្លាសក្នុងឧបាយ ។

[ ៤២ ] បញ្ញាក្នុងវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា បញ្ញាជាវិបាក បញ្ញាក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា បញ្ញាមានវិបាក-ធម៌ជាប្រក្រតី បញ្ញាក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាមិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ។

[ ៤៣ ] បញ្ញាក្នុងវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន បញ្ញាក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។

[ ៤៤ ] បញ្ញាសម្បយុត្តដោយវិតក្ក និងវិចារ ឈ្មោះថា បញ្ញាប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ បញ្ញាប្រាសចាកវិតក្ក តែសម្បយុត្តដោយវិចារ ឈ្មោះថា បញ្ញាមិនមានវិតក្ក មានត្រឹមតែវិចារ បញ្ញាប្រាសចាកវិតក្ក និងវិចារ ឈ្មោះថា បញ្ញាមិនមានវិតក្ក ទាំងមិនមានវិចារ ។

[ ៤៥ ] បញ្ញាសម្បយុត្តដោយបីតិ ឈ្មោះថា បញ្ញាកើតព្រមដោយបីតិ បញ្ញាសម្បយុត្តដោយសុខ ឈ្មោះថា បញ្ញាកើតព្រមដោយសុខ បញ្ញាសម្បយុត្តដោយឧបេក្ខា ឈ្មោះថា បញ្ញាកើតព្រមដោយឧបេក្ខា ។

[ ៤៦ ] បញ្ញាក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា

ដល់នូវការសន្សំ ( កម្មកិលេស ) បញ្ញាក្នុងមគ្គ ៤ ឈ្មោះថា បញ្ញាដល់នូវការមិនសន្សំ បញ្ញាក្នុងវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៤ និងក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាមិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ ។

[ ៤៧ ] បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៣ ឈ្មោះថា បញ្ញាជារបស់សេក្ខបុគ្គល បញ្ញាក្នុងអរហត្តផលជាន់លើ ឈ្មោះថា បញ្ញាជារបស់អសេក្ខបុគ្គល បញ្ញាក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាមិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ។

[ ៤៨ ] បញ្ញាក្នុងកាមាវចរកុសល និងអព្យាក្រឹត ឈ្មោះថា បញ្ញាតូចថ្ងារ បញ្ញាក្នុងរូបាវចរកុសល អរូបាវចរកុសល និងអព្យាក្រឹត ឈ្មោះថា បញ្ញាមានសភាពធំ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមានប្រមាណមិនបាន ។

[ ៤៩ ] បណ្តាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍តូចថ្ងារ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធធម៌ទាំងឡាយតូចថ្ងារ នេះហៅថា បញ្ញាមានអារម្មណ៍តូចថ្ងារ ។ បណ្តាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ដល់នូវសភាពធំ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើងព្រោះប្រារព្ធធម៌ទាំងឡាយ

ដល់នូវសភាពធំ នេះហៅថា បញ្ញាមានអារម្មណ៍ដល់នូវសភាពធំ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ប្រមាណមិនបាន តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធធម៌មានប្រមាណមិនបាន នេះហៅថា បញ្ញាមានអារម្មណ៍ប្រមាណមិនបាន ។

[ ៥០ ] បណ្ដាបញ្ញាទាំងនោះ បញ្ញាមានមគ្គជាអារម្មណ៍ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្ដីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធអរិយមគ្គ នេះហៅថា បញ្ញាមានមគ្គជាអារម្មណ៍ ។ បញ្ញាក្នុងមគ្គ ៤ ឈ្មោះថា បញ្ញាមានមគ្គជាហេតុ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាមានមគ្គជាអធិបតី តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះធ្វើអរិយមគ្គឲ្យជាអធិបតី នេះហៅថា បញ្ញាមានមគ្គជាអធិបតី ។

[ ៥១ ] បញ្ញាក្នុងវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៤ កើតឡើងហើយក៏មាន បម្រុងនឹងកើតឡើង តែមិនគួរពោលថា មិនទាន់កើតឡើងក៏មាន បញ្ញាក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៤ និងក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ កើតឡើងហើយក៏មាន មិនទាន់កើតឡើង តែមិនគួរពោលថា បម្រុងនឹងកើតឡើងក៏មាន ។

[ ៥២ ] បញ្ញាទាំងអស់ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។

[ ៥៣ ] បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ជាអតីត តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធធម៌ទាំងឡាយជាអតីត នេះហៅថា បញ្ញាមានអារម្មណ៍ជាអតីត ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ជាអនាគត តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធនូវធម៌ទាំងឡាយជាអនាគត នេះហៅថា បញ្ញាមានអារម្មណ៍ជាអនាគត ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ជាបច្ចុប្បន្ន តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើងព្រោះប្រារព្ធនូវធម៌ទាំងឡាយជាបច្ចុប្បន្ន នេះហៅថា បញ្ញាមានអារម្មណ៍ជាបច្ចុប្បន្ន ។

[ ៥៤ ] បញ្ញាទាំងអស់ ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន ។

[ ៥៥ ] បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ខាងក្នុង តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធនូវធម៌ទាំងឡាយជាខាងក្នុង នេះហៅថា បញ្ញាមានអារម្មណ៍ខាងក្នុង ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ខាងក្រៅ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធនូវធម៌ទាំង

ឡាយជាខាងក្រៅ នេះហៅថា បញ្ញាមានអារម្មណ៍ខាងក្រៅ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ខាងក្នុង និងខាងក្រៅ តើដូចម្ដេច ។ បញ្ញាការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណាកើតឡើង ព្រោះប្រារព្ធនូវធម៌ទាំងឡាយ ជាខាងក្នុង និងខាងក្រៅ នេះហៅថា បញ្ញាមានអារម្មណ៍ខាងក្នុង និងខាងក្រៅ ។

ញាណវត្ថុ មានប្រការ ៣ យ៉ាងនេះឯង

# អដ្ឋកថា

## តិកនិទ្ទេស

[ ៣៨-៥៥ ] ក្នុងនិទ្ទេសនៃញាណវត្ថុពួក ៣ បញ្ហា ព្រះមានព្រះភាគត្រាស់ហៅថា **យោគ** ក្នុងបទថា **យោគវិហិតេសុ** នេះ មានអធិប្បាយថា ដែលចាត់ចែងដោយបញ្ញា គឺបង្អោននាំទៅដោយបញ្ញា ។ កម្មាយតនៈ គឺប្រភពកើតនៃការងារ ក្នុងបទថា **កម្មាយតនេសុ** នេះ គឺការងារនោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា កម្មាយតនៈ ព្រោះអត្ថថា ការងារនោះផង ជាប្រភពកើតផងនៃអាជីវៈជាដើម ក្នុងបទថា **សិប្បាយតនេសុ** ក៏ន័យនេះដូចគ្នា ។

ក្នុងការងារទាំងនោះ ការងារមាន ២ យ៉ាង គឺហីនកម្ម និងឧក្កដ្ឋកម្ម ។ ក្នុងកម្ម ២ យ៉ាងនោះ កម្ម គឺការងាររបស់ជាងឈើ ការងាររបស់អ្នកចាក់សំរាមជាដើម ឈ្មោះថា **ហីនកម្ម** គឺកម្មថោកថយ កម្ម គឺកសិកម្ម ពាណិជ្ជកម្ម និងគោរក្ខកម្មជាដើម ឈ្មោះថា **ឧក្កដ្ឋកម្ម** គឺកម្មខ្ពង់ខ្ពស់ ។ ក្នុងសិប្បៈក៏មាន ២ យ៉ាង គឺសិប្បៈថោកថយ និងសិប្បៈខ្ពង់ខ្ពស់ ។ ក្នុងសិប្បៈ ២ យ៉ាងនោះ សិប្បៈ គឺសិប្បៈរបស់ជាងផែង សិប្បៈរបស់ជាងតម្បាញ សិប្បៈរបស់ស្មូនឆ្នាំង សិប្បៈរបស់ជាងស្បែក សិប្បៈរបស់ជាងកាត់សក់ជាដើម ឈ្មោះថា ហីនសិប្បៈ គឺសិប្បៈថោកថយ សិប្បៈ គឺសិប្បៈដែលរាប់ម្រាមដៃ ( គិតលេខដោយម្រាមដៃ ) សិប្បៈគណនា ( គិតលេខដោយគណិតវិទ្យា ) សិប្បៈសរសេរ ( នាយស្មៀន ) ជាដើម ឈ្មោះថា ឧក្កដ្ឋសិប្បៈ គឺសិប្បៈខ្ពង់ខ្ពស់ ។ វិជ្ជដ្ឋាន គឺថ្នាក់នៃវិជ្ជានោះឯង ។ ព្រះ

មានព្រះភាគ ទ្រង់កាន់យកថ្នាក់នៃវិជ្ជា ដែលប្រកបដោយធម៌ប៉ុណ្ណោះ ។ ចំណែកថ្នាក់នៃវិជ្ជាគ្រហ្ម មានវិជ្ជាទាយជោគជតា វិជ្ជាហៅពស់ឲ្យមកស្រូបពិស វិជ្ជាស្តោះពិស វិជ្ជាសលាកៈ ពេទ្យវះជាដើម មិនកាន់យកថាជាថ្នាក់នៃវិជ្ជាខ្ពង់ខ្ពស់ ព្រោះសង្គ្រោះចូលក្នុងសិប្បាយតនៈនោះឯងថា បពិត្រលោកអាចារ្យ ខ្ញុំប្រាថ្នានឹងសិក្សាសិល្បសាស្ត្រ ដូច្នេះ ។

ក្នុងការងារថោកទាបជាដើមនោះ បុរសអ្នកឈ្លាសម្នាក់ធ្វើផ្ទះ ធ្វើប្រាសាទ ធ្វើយាន ធ្វើទូកជាដើម ដោយធម្មតារបស់ខ្លួនឯង ដើម្បីការនៅជាសុខរបស់មនុស្សទាំងឡាយ ព្រោះថា បុរសអ្នកឈ្លាសនោះ តាំងនៅដោយការធ្វើប្រយោជន៍ដោយគិតថា មនុស្សទាំងនេះកើតទុក្ខ ព្រោះមិនមានលំនៅ ទើបធ្វើផ្ទះ មានផ្ទះទ្រវែង និងផ្ទះ ៤ ជ្រុងជាដើម ដើម្បីការពារនូវរងា និងកម្តៅថ្ងៃ សាងប្រាសាទ មានប្រាសាទមួយជាន់ និងពីរជាន់ជាដើម កាលយានពាហនៈមិនមាន ក៏គិតថា ឈ្មោះថា ការសញ្ចរទៅមកជាទុក្ខ ដើម្បីបន្ទោបង់នូវការចុករួយស្រពន់ជើងជាដើម សាង-រ៉ រទេះគោ និងរថជាដើម កាលមិនមានទូក ក៏គិតថា ឈ្មោះថា គ្រឿងសញ្ចរទៅក្នុងសមុទ្ទជាដើមមិនមាន ទើបធ្វើទូកមានប្រការផ្សេងៗ ។ បុរសអ្នកឈ្លាសវៃនោះ មិនឃើញវត្ថុទាំងអស់នោះដែលបុគ្គលដទៃធ្វើ មិនបានរៀន គឺមិនបានយកលំនាំដែលបុគ្គលដទៃធ្វើ មិនបានស្តាប់អំពីអ្នកដទៃប្រាប់ តែបុគ្គលនោះធ្វើដោយការគិតតាមធម្មតារបស់ខ្លួន ។ ពិតហើយ ការងារដែលបុគ្គលអ្នកមានបញ្ញាធ្វើតាមធម្មតារបស់ខ្លួន រមែងដូចគ្នានឹងការងារទាំងឡាយ ដែលជនដទៃរៀន

មកធ្វើហើយនោះឯង នេះជាន័យក្នុងហីនកម្ម គឺការងារថោកថយ ។

ក្នុងឧក្កដ្ឋកម្ម គឺការងារខ្ពង់ខ្ពស់ បណ្ឌិតម្នាក់គិតថា កាលកសិកម្មមិនមាន ជីវិតរបស់មនុស្សទាំងឡាយ រមែងមិនប្រព្រឹត្តទៅ ដូច្នេះ ដើម្បីការនៅជាសុខរបស់មនុស្សទាំងឡាយ ទើបសាងឧបករណ៍ធ្វើស្រែ មាននឹម និងនង្គ័លជាដើម ។ ដោយទំនងនោះ រមែងសាងឧបករណ៍ពាណិជ្ជកម្ម និងគោរក្ខកម្ម មានប្រការផ្សេងៗ ។ បុរសនោះ មិនឃើញឧបករណ៍ទាំងអស់នោះ ដែលបុគ្គលដទៃធ្វើ ។បេ។ រមែងដូចគ្នានឹងការងារដែលបុគ្គលដទៃរៀនមក ធ្វើហើយនោះឯង នេះជាន័យក្នុងឧក្កដ្ឋកម្ម ។

ក្នុងប្រភពកើតនៃសិប្បៈទាំង ២ បណ្ឌិតម្នាក់ប្រាថ្នាការនៅជាសុខរបស់មនុស្សទាំងឡាយ ទើបរៀបចំហីនសិប្បៈ មានសិប្បៈរបស់ជាងផែងជាដើម និងសាងសិប្បៈខ្ពង់ខ្ពស់ គឺវិធីរាប់ដៃ រាប់ដោយគណនា រាប់ដោយការដកចេញ ការកត់ត្រាផ្សេងៗ មានមាតិកាជាដើម ។ បណ្ឌិតនោះ មិនបានឃើញសិប្បៈទាំងអស់នោះដែលបុគ្គលដទៃធ្វើ ។បេ។ រមែងដូចគ្នានឹងសិប្បៈដែលបុគ្គលដទៃរៀនមកធ្វើហើយនោះឯង នេះជាន័យក្នុងប្រភពកើតនៃសិប្បៈ ។

ម្យ៉ាងទៀត បណ្ឌិតពួកខ្លះញ៉ាំងថ្នាក់នៃវិជ្ជាទាំងឡាយ មានមន្តហៅពស់ឲ្យមកស្រូបពិសជាដើមដែលប្រកបដោយធម៌ ឲ្យកើតឡើង ដើម្បីព្យាបាលមនុស្សទាំងឡាយ ដែលត្រូវអមនុស្សបៀតបៀន និងត្រូវពស់ចឹកជាដើម ។ បណ្ឌិតនោះមិនឃើញថ្នាក់នៃវិជ្ជាទាំងនោះ ដែលបុគ្គលដទៃធ្វើ មិនបានរៀនថ្នាក់នៃវិជ្ជាដែលបុគ្គលដទៃរៀនហើយ ទាំងមិនបានស្តាប់អំពីបុគ្គលដទៃ តែ

បណ្ឌិតនោះធ្វើដោយការគិតតាមទំនើងរបស់ខ្លួន ។ ពិតហើយ ថ្នាក់នៃវិជ្ជានោះ ដែលបុគ្គលអ្នកមានបញ្ញាធ្វើតាមធម្មតារបស់ខ្លួន ក៏ដូចគ្នានឹងថ្នាក់នៃវិជ្ជាដែលជនដទៃរៀនមកធ្វើហើយនោះឯង ។

បទថា **កម្មស្សកតំ វា** បានដល់ ញាណ គឺការដឹងយ៉ាងនេះថា កម្មនេះជារបស់សត្វទាំងឡាយ កម្មនេះជារបស់យើងទាំងឡាយ ។

បទថា **សច្ចានុលោមិកំ វា** បានដល់ វិបស្សនាញាណ ។ ពិតហើយ វិបស្សនាញាណនោះ ហៅថា សច្ចានុលោមិកញ្ញាណ ព្រោះអនុលោមតាមសច្ចៈ ៤ ។

ឥឡូវនេះ ដើម្បីសម្ដែងអាការ គឺការប្រព្រឹត្តទៅនៃសច្ចានុលោមិកញ្ញាណនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា **រូបំ អនិច្ចន្តិ វា** រូបមិនទៀងក្ដីជាដើម ។ ក្នុងអធិការនេះ អនិច្ចលក្ខណៈប៉ុណ្ណោះ មកហើយ ទុក្ខលក្ខណៈនិងអនត្តលក្ខណៈ មិនបានមកហើយ តែគប្បីជ្រាបថា មកហើយនោះឯង ដោយអំណាចនៃអត្ថ ព្រោះថា ធម៌ណាមិនទៀង ធម៌នោះជាទុក្ខ ធម៌ណាជាទុក្ខ ធម៌នោះជាអនត្តា ដូច្នេះ ។

បទថា **យំ ឯវរូបឹ** បានដល់ អនុលោមិកញ្ញាណណា មានសភាវៈដូចបានអធិប្បាយហើយយ៉ាងនោះ ។

បទទាំងអស់ មានបទថា **ខន្តឹ** ជាដើម ជាវេវចនៈនៃបញ្ញាទាំងអស់ ។ ពិតហើយ បញ្ញានោះ ឈ្មោះថា អនុលោមិក ព្រោះអត្ថថា អនុលោមដោយការសម្ដែងភាពមិនជាសត្រូវដល់ហេតុ ៥ យ៉ាង មានប្រកបកើតនៃ

ការងារជាដើម ដែលព្រះមានព្រះភាគ ត្រាស់ខាងដើម ។ ដូចគ្នានោះដែរ បញ្ញាឈ្មោះថា អនុលោមិក ព្រោះអត្ថថា អនុលោមតាមការប្រព្រឹត្តដែលជាប្រយោជន៍ដល់សត្វទាំងឡាយ ព្រោះអត្ថថា អនុលោមតាមមគ្គសច្ច ព្រោះអត្ថថា អនុលោមតាម ដោយការអនុលោម តាមព្រះនិព្វានដែលជាបរមត្ថសច្ច ។ ញាណណា អត់ធន់ អាចឃើញនូវហេតុទាំងអស់នោះ ព្រោះហេតុនោះ ទើបញាណនោះ ឈ្មោះថា ខន្តិញ្ញាណ ។ ឈ្មោះថា ទិដ្ឋិញ្ញាណ ព្រោះអត្ថថា ឃើញ ។ ឈ្មោះថា រុចិញ្ញាណ ព្រោះអត្ថថា គាប់ចិត្ត ។ ឈ្មោះថា មុតិញ្ញាណ ព្រោះអត្ថថា រីករាយ ។ ព្រះបាលីថា **មុទតីតិ មុទីតិ** ឈ្មោះថា មុទិតិញ្ញាណ ព្រោះអត្ថថា ត្រេកអរ ដូច្នេះក៏មាន ។ ឈ្មោះថា បេក្ខញ្ញាណ ព្រោះអត្ថថា សម្លឹង ។ ធម៌ទាំងឡាយមានប្រភពកើតនៃការងារជាដើម ទាំងអស់នោះ រមែងអត់ធន់ចំពោះការសម្លឹងនៃបញ្ញានោះ ។ ម្យ៉ាងទៀត បើពោលដោយពិសេស ធម៌ទាំងឡាយ ពោល គឺខន្ធ ៥ កាលចូលទៅសម្លឹងពិចារណារឿយៗ ដោយអំណាចរបស់មិនទៀង ជាទុក្ខ ជាអនត្តា រមែងអត់ធន់ចំពោះការសម្លឹងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មនិជ្ឈានខន្តិ** ។

បទថា **បរតោ អស្សុត្វា បដិលភតិ** បានដល់ មិនបានស្តាប់ពាក្យណែនាំរបស់អ្នកដទៃ គិតឯងនោះឯង រមែងបាន ។

បទថា **អយំ វុច្ចតិ** បានដល់ បញ្ញានេះ ព្រះមានព្រះភាគត្រាស់ហៅថា ចិន្តាមយប្បញ្ញា ។

ចិន្តាមយប្បញ្ញានោះ រមែងមិនកើតដល់បុគ្គលពួកណាមួយ រមែងកើតឡើងដល់មហាសត្វទាំងឡាយដែលដឹងក្រៃលែងប៉ុណ្ណោះ ។

ក្នុងចិន្តាមយប្បញ្ញានេះ សច្ចានុលោមិកញ្ញាណ រមែងកើតដល់ព្រះពោធិសត្វទាំង ២ ( មហាពោធិសត្វ និងបច្ចេកពោធិសត្វ ) ប៉ុណ្ណោះ ។

បញ្ញាដ៏សេស បណ្ឌិតគប្បីជ្រាបថា រមែងកើតឡើងដល់បុគ្គលដែលមានបញ្ញាច្រើន មានបារមីពេញហើយទាំងអស់ ។

ក្នុងបទថា **បរតោ សុត្វា បដិលភតិ** នេះ បណ្ឌិតគប្បីជ្រាបថា បញ្ញាទាំងអស់ ដែលបុគ្គលបានហើយ ព្រោះឃើញប្រកពកើតនៃការងារជាដើម ដែលបុគ្គលដទៃកំពុងធ្វើ ធ្វើស្រេចហើយក្តី ព្រោះស្តាប់ពាក្យរបស់បុគ្គលណាមួយ ដែលប្រាប់ក្តី ព្រោះរៀនយកក្នុងសម្នាក់នៃអាចារ្យក្តី ឈ្មោះថា បុគ្គលបានស្តាប់អំពីអ្នកដទៃហើយនោះឯង ទើបបាន ។

បទថា **សមាបន្នស្ស** បញ្ញាដែលប្រព្រឹត្តក្នុងខាងក្នុងសមាបត្តិ របស់បុគ្គលដែលដល់ព្រមដោយសមាបត្តិ ឈ្មោះថា ភាវនាមយប្បញ្ញា ។

បទថា **ទានំ អារព្ភ** បានដល់ អាស្រ័យទាន អធិប្បាយថា មានចេតនាក្នុងការឲ្យជាបច្ច័យ ។ បទថា **ទានាធិគច្ឆ** បានដល់ ដល់បុគ្គលដែលដល់នូវការឲ្យ គឺសម្រេចការឲ្យ ។ បទថា **យា ឧប្បជ្ជតិ** បានដល់ បញ្ញាដែលសម្បយុត្តដោយចេតនាក្នុងទានយ៉ាងនេះឯណា រមែងកើតឡើង បញ្ញានេះ ឈ្មោះថា **ទានមយប្បញ្ញា** ។

ទានមយប្បបញ្ញានោះ រមែងកើតឡើងដោយអាការ ៣ យ៉ាង គឺ

ជាបុព្វចេតនាដល់បុគ្គលដែលគិតថា អញនឹងឲ្យទាន ជាមុញ្ចនចេតនាដល់បុគ្គលដែលកំពុងឲ្យទាន ជាអបរចេតនា ដល់បុគ្គលដែលឲ្យទានហើយពិចារណាទាននោះ ។

ក្នុងបទថា **សីលំ អារព្ភ សីលាធិគច្ឆ** នេះ ព្រះមានព្រះភាគ ទ្រង់បំណងយកបញ្ញា ដែលសម្បយុត្តដោយចេតនាក្នុងសីលនោះ ថាជាសីលមយប្បញ្ញា ។ សីលមយប្បញ្ញានេះ កើតឡើងដោយអាការ ៣ នោះឯង គឺបុព្វចេតនាដល់បុគ្គលដែលគិតថា អញនឹងញ៉ាំងសីលឲ្យបរិបូណ៌ មុញ្ចនចេតនាដល់បុគ្គលដែលកំពុងញ៉ាំងសីលឲ្យបរិបូណ៌ អបរចេតនាដល់បុគ្គលដែលញ៉ាំងសីលឲ្យបរិបូណ៌ ហើយពិចារណានោះ ។ ភាវនាមយប្បញ្ញា ខ្ញុំបានពោលហើយខាងដើមនោះឯង ។

ក្នុងអធិសីលប្បញ្ញាជាដើម បណ្ឌិតគប្បីជ្រាបសីលជាដើមដោយប្រព្រឹត្តទៅនីមួយៗ ២ យ៉ាង គឺសីល និងអធិសីល ចិត្ត និងអធិចិត្ត បញ្ញា និងអធិប្បញ្ញា ។ ក្នុងបទទាំងនោះ សីល ៥ ក្តី សីល ១០ ក្តី ឈ្មោះថា សីលដោយអំណាចនៃការសង្គ្រោះចូលក្នុងធម្មនិយាម ( សំយុត្តនិកាយ និទានវគ្គ ) នេះថា ព្រះតថាគតកើតឡើងក្តី ព្រះតថាគតមិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ ឥទប្បច្ច័យនោះ តែងឋិតនៅជាធម្មតា ដូច្នេះ ។ ពិតហើយ កាលព្រះតថាគតទ្រង់កើតឡើងក្តី មិនទាន់កើតឡើងក្តី សីលនោះក៏នៅមាន ។

សួរថា កាលព្រះតថាគតទ្រង់មិនទាន់កើតឡើង បុគ្គលណាបញ្ញត្តសីល

*ឆ្លើយថា តាបស បរិព្វាជក សព្វញ្ញុពោធិសត្វ និងស្តេចចក្កពត្តិរមែងបញ្ញត្ត នូវសីល ។*

*កាលព្រះសម្មាសម្ពុទ្ធទ្រង់កើតឡើងហើយ ភិក្ខុសង្ឃ ភិក្ខុនីសង្ឃ ឧបា-សក ឧបាសិកា រមែងប្រកាសឲ្យដឹងនូវសីលនោះ ។ ចំណែកបាតិមោក្ខ-សំវរសីល ដែលជាសីលក្រៃលែងជាងសីលទាំងអស់ កាលព្រះតថាគត ទ្រង់កើតឡើងប៉ុណ្ណោះទើបមាន កាលទ្រង់មិនកើតឡើង មិនមាន ដ្បិតថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយប៉ុណ្ណោះ រមែងបញ្ញត្តនូវបាតិមោក្ខសំវរសីលនោះ ព្រោះការបញ្ញត្តថា សេចក្តីនេះរមែងមាន ព្រោះការឈានកន្លងក្នុងរឿងនេះ នេះមិនមែនជាវិស័យរបស់ជនដទៃ ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយ ប៉ុណ្ណោះ និងជាកម្លាំងរបស់ព្រះពុទ្ធទាំងឡាយ ។ បាតិមោក្ខសំវរសីល ជា អធិសីល ព្រោះហេតុណា ព្រោះហេតុនោះ ដើម្បីសម្តែងអធិសីលប្បញ្ញា ទើបព្រះមានព្រះភាគត្រាស់ថា* **ចាតិមោក្ខសំវរំ សំវរន្តស្ស** *ដោយប្រការ ដូច្នេះ ។*

*ម្យ៉ាងទៀត សមាបត្តិ ៨ ដែលជាគ្រឿងប្រព្រឹត្តទៅក្នុងវដ្តៈ ឈ្មោះថា ចិត្ត ដោយអំណាចការសង្គ្រោះដោយនិយាមដែលព្រះមានព្រះភាគ ត្រាស់ ខាងដើមនោះឯង ។ ពិតហើយ កាលព្រះមានព្រះភាគ ទ្រង់កើតឡើង ហើយក្តី មិនទាន់កើតឡើងក្តី ចិត្តដែលប្រព្រឹត្តទៅក្នុងសមាបត្តិទាំង ៨ នោះ ក៏នៅតែមាន ( ជាធម្មតា ) ។ សួរថា កាលព្រះតថាគតមិនទាន់កើតឡើង អ្នកណាញុំាងចិត្តដែលប្រព្រឹត្តទៅក្នុងសមាបត្តិទាំងនោះ ឲ្យកើតឡើង ឆ្លើយ*

ថា តាបស បរិព្វាជក ព្រះសព្វញ្ញូពោធិសត្វ និងស្តេចចក្កពត្តិ ។

កាលព្រះមានព្រះភាគ ទ្រង់កើតឡើងហើយ ជនទាំងឡាយដែលប្រាថ្នាគុណវិសេស មានភិក្ខុជាដើម រមែងញ៉ាំងចិត្តបែបនោះឲ្យកើតឡើងបាន តែសមាបត្តិ ៨ ដែលជាបាទឲ្យវិបស្សនាដែលក្រៃលែងជាងចិត្តទាំងពួង កាលព្រះតថាគតទ្រង់កើតហើយប៉ុណ្ណោះទើបមាន បើទ្រង់មិនទាន់កើតឡើង ចិត្តបែបនោះ មិនមាន ដ្បិតថា ព្រះសព្វញ្ញូទាំងឡាយប៉ុណ្ណោះ ទ្រង់រមែងបញ្ញត្តនូវសមាបត្តិទាំង ៨ នោះ ។ សមាបត្តិ ៨ ជាអធិចិត្ត ព្រោះហេតុណា ព្រោះហេតុនោះ ដើម្បីសម្តែងបញ្ញាដែលសម្រេចជាអធិចិត្ត ទើបព្រះមានព្រះភាគត្រាស់ថា **វុឋាវចរាវុឋាវចរសមាបត្តី សមាបជ្ជន្តស្ស** ជាដើម ដោយប្រការដូច្នេះ ។

កម្មស្សកតាញាណ ឈ្មោះថា បញ្ញា ដោយអំណាចនៃការសង្គ្រោះដោយនិយម ដែលព្រះមានព្រះភាគត្រាស់ហើយខាងដើមនោះឯង ។ ពិតហើយ កាលព្រះតថាគតទ្រង់កើតឡើងហើយក្តី មិនទាន់កើតឡើងក្តី កម្មស្សកតាញាណនោះក៏មាន កាលព្រះតថាគតមិនទាន់កើតឡើង កម្មស្សកតាញាណនោះ ក៏នៅតែកើតឡើង ដោយអំណាចនៃការឲ្យទាន របស់វេលាមព្រាហ្មណ៍ និងរបស់ព្រះវេស្សន្តរជាដើម ។ កាលព្រះតថាគត ទ្រង់កើតឡើងហើយ ប្រមាណនៃបុគ្គលដែលញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅដោយញាណនោះ រាប់មិនបាន ។

បញ្ញាក្នុងមគ្គ និងផល ជាសភាវៈក្រៃលែងជាងបញ្ញាទាំងអស់ កាល

ព្រះតថាគត ទ្រង់កើតឡើងហើយប៉ុណ្ណោះ ទើបជាសភាវៈផ្សាយចេញទៅ កាលទ្រង់មិនទាន់កើតឡើង មិនប្រព្រឹត្តទៅឡើយ បញ្ញាក្នុងមគ្គ និងផល ឈ្មោះថា អធិប្បញ្ញា ព្រោះហេតុណា ព្រោះហេតុនោះ ដើម្បីសម្តែងនូវបញ្ញា ដោយអធិប្បញ្ញា ទើបទ្រង់ត្រាស់ពាក្យថា **ចត្វសុ មគ្គេសុ** ជាដើម ដោយប្រការដូច្នេះ ។

ក្នុងសីលជាដើមបើមានពាក្យសួរថា ក្នុងចំណែកទាំង ៦ នេះ គឺសីល អធិសីល ចិត្ត អធិចិត្ត បញ្ញា អធិប្បញ្ញា វិបស្សនាបញ្ញា អាស្រ័យធម៌ណាប្រព្រឹត្តទៅ ឆ្លើយថា អាស្រ័យអធិប្បញ្ញា ។ ព្រោះហេតុនោះ គប្បីជ្រាបថា ប្រៀបដូចបុគ្គលហៅឆត្រ និងទង់ដែលមានទំហំធំថា អតិឆត្តៈ និងអតិធជៈ ព្រោះប្រៀបធៀបឆត្រ ឬទង់ដែលមានទំហំតូចយ៉ាងណា បាតិមោក្ខ-សំវរសីលនេះ ក៏យ៉ាងនោះដូចគ្នា ឈ្មោះថា អធិសីល ព្រោះប្រៀបធៀបជាមួយសីល ៥ និងសីល ១០ ។ សមាបត្តិ ៨ ដែលជាបាទឲ្យវិបស្សនាកើតឡើង ឈ្មោះថា អធិចិត្ត ព្រោះប្រៀបធៀបជាមួយសមាបត្តិ ៨ ដែលជាបាទប្រព្រឹត្តទៅក្នុងវដ្តៈ ។ វិបស្សនាបញ្ញា និងបញ្ញាក្នុងមគ្គ ក្នុងផល ឈ្មោះថា អធិប្បញ្ញា ព្រោះប្រៀបធៀបជាមួយកម្មស្សកតាបញ្ញា ។

ក្នុងនិទ្ទេសនៃអាយកោសលជាដើម បទថា **អាយោ** បានដល់ សេចក្តីចម្រើន **អាយ** គឺសេចក្តីចម្រើននោះ មាន ២ យ៉ាង គឺ **អនត្ថហានិ** គឺសេចក្តីវិនាសនៃវត្ថុដែលមិនជាប្រយោជន៍ ១ និងអត្ថុប្បត្តិ គឺធ្វើប្រយោជន៍ឲ្យកើតឡើង ១ ។ បទថា **អបាយោ** បានដល់ សេចក្តីមិនចម្រើន ។

សេចក្តីមិនចម្រើននោះ ក៏មាន ២ គឺ **អត្ថហានិ** គឺសេចក្តីវិនាសនៃវត្ថុដែលជាប្រយោជន៍ ១ និង **អនត្ថុប្បត្តិ** គឺការធ្វើវត្ថុដែលមិនជាប្រយោជន៍ឲ្យកើតឡើង ១ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឥមេ ធម្មេ មនសិករោតោ** ជាដើម ដើម្បីសម្តែងបញ្ញានោះ ។

បទថា **ឥទំ វុច្ចតិ** អធិប្បាយថា បញ្ញាក្នុងការធ្វើអកុសលធម៌ទាំងនេះមិនឲ្យកើតឡើង និងក្នុងការលះអកុសលធម៌ទាំងនេះ បញ្ញាក្នុងការធ្វើកុសលធម៌ទាំងឡាយឲ្យកើតឡើង និងតាំងនៅនេះឯណា បញ្ញានេះ ទ្រង់ត្រាស់ថា អបាយកោសល ។ បញ្ញាក្នុងការធ្វើកុសលធម៌ទាំងឡាយ មិនឲ្យកើតឡើង និងក្នុងការលះកុសលធម៌ទាំងឡាយ បញ្ញាក្នុងការធ្វើអកុសលទាំងឡាយឲ្យកើតឡើង តាំងនៅនេះឯណា បញ្ញានេះ ទ្រង់ត្រាស់ថា ជាអបាយកោសល ។ សួរថា អាយកោសលជាបញ្ញា ចូរស្នេះទុកចុះ ឯអបាយកោសល តើជាបញ្ញាដូចម្តេចកើត ឆ្លើយថា អ្នកមានបញ្ញាប៉ុណ្ណោះ រមែងដឹងច្បាស់ថា កាលអញដាក់ចិត្តយ៉ាងនេះ កុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើង រមែងមិនកើតឡើង កុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ រមែងវិនាសទៅ និងរមែងដឹងច្បាស់ថា អកុសលធម៌ទាំងឡាយដែលមិនទាន់កើតឡើង រមែងកើតឡើង អកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ រមែងចម្រើនឡើង ដូច្នេះ ។ បុគ្គលនោះ កាលដឹងយ៉ាងនេះហើយ រមែងមិនឲ្យអកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើង កើតឡើងបាន រមែងលះអកុសលធម៌ទាំងឡាយដែលកើតឡើងហើយ រមែងធ្វើកុសលធម៌

ទាំងឡាយ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង រមែងធ្វើកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ឲ្យដល់នូវការចម្រើនបរិបូណ៌ ។ អបាយ-កោសល បណ្ឌិតគប្បីជ្រាបថា ជាបញ្ញានេះឯង ដោយប្រការដូច្នេះ ។

ក្នុងបទថា **សព្វាបិ តត្រុបាយា បញ្ញា ឧបាយកោសល្លំ** នេះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃការដឹងដល់ហេតុក្នុងការកើតឡើងនៃឋានៈ ដើម្បីដោះស្រាយក្នុងកិច្ចការដែលប្រញាប់ ឬភ័យដែលកើតឡើងនោះឯង ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាតិកនិទ្ទេស ចប់**

# អភិធម្មបិដក

## ចតុក្កនិទ្ទេស

[ ៥៦ ] បណ្ដាញាណទាំងនោះ កម្មស្សកតញ្ញាណ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា មានសភាពយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើល្អ ធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន ការប្រព្រឹត្តខុស ឬត្រូវក្នុងមាតាមានផល ( បាបបុណ្យ ) ការប្រព្រឹត្តខុស ឬត្រូវក្នុងបិតាមានផល ( បាបបុណ្យ ) ពួកសត្វជាឱបបាតិកកំណើតមាន ពួកសមណ-ព្រាហ្មណ៍ក្នុងលោក ដែលប្រព្រឹត្តត្រឹមត្រូវ ប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួន ហើយប្រកាសក៏មាន នេះហៅថា កម្មស្សកតញ្ញាណ សូម្បីបញ្ញាជាកុសល ដែលប្រកបដោយអាសវៈទាំងអស់ វៀរលែងតែសច្ចានុលោមិកញ្ញាណចេញ ក៏ឈ្មោះថា កម្មស្សកតញ្ញាណដែរ ។ បណ្ដាញាណទាំងនោះ សច្ចានុលោមិកញ្ញាណតើដូចម្ដេច ។ សេចក្ដីចូលចិត្ត សេចក្ដីយល់ឃើញ សេចក្ដីពេញចិត្ត ការឈ្វេងយល់ ការពិនិត្យឃើញ សេចក្ដីចូលចិត្ត ក្នុងការសម្លឹងមើលនូវធម៌ដ៏សមគួរណា មានសភាពយ៉ាងនេះ ថារូបមិនទៀងក្ដី ថាវេទនាមិនទៀងក្ដី ថាសញ្ញាមិនទៀងក្ដី ថាសង្ខារទាំងឡាយមិនទៀងក្ដី ថាវិញ្ញាណមិនទៀងក្ដី នេះហៅថា សច្ចានុលោមិកញ្ញាណ ។ បញ្ញាក្នុងមគ្គ ៤ ឈ្មោះថា ញាណ

របស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ។ បញ្ញាក្នុងផល ៤ ឈ្មោះថា ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយផល ។

[ ៥៧ ] ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ឈ្មោះថា សេចក្តីដឹងក្នុងកងទុក្ខ ឈ្មោះថា សេចក្តីដឹងក្នុងហេតុនាំឲ្យកើតកងទុក្ខ ឈ្មោះថា សេចក្តីដឹងក្នុងធម៌ជាទីរលត់នៃកងទុក្ខ ឈ្មោះថា សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ បណ្តាញាណទាំងនោះ សេចក្តីដឹងក្នុងកងទុក្ខ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធនូវទុក្ខ នេះហៅថា សេចក្តីដឹងក្នុងកងទុក្ខ ។ ព្រោះប្រារព្ធនូវហេតុនាំឲ្យកើតកងទុក្ខ ។បេ។ ព្រោះប្រារព្ធនូវធម៌ ជាទីរលត់នៃកងទុក្ខ ។បេ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធនូវបដិបទាជាដំណើរទៅកាន់ទីរលត់កងទុក្ខ នេះហៅថា សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[ ៥៨ ] បញ្ញាក្នុងកាមាវចរកុសល និងអព្យាក្រឹត ឈ្មោះថា បញ្ញាជាកាមាវចរ បញ្ញាក្នុងរូបាវចរកុសល និងអព្យាក្រឹត ឈ្មោះថា បញ្ញាជារូបាវចរ បញ្ញាក្នុងអរូបាវចរកុសល និងអព្យាក្រឹត ឈ្មោះថា បញ្ញាជាអរូបាវចរ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាជាអបរិយាបន្ន ។

[ ៥៩ ] បណ្តាញាណទាំងនោះ សេចក្តីដឹងក្នុងធម៌ តើដូចម្តេច ។ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា សេចក្តីដឹងក្នុងធម៌ ។ អ្នកផងតែង

ណែនាំនូវសេចក្តីពន្យល់ ក្នុងកាលជាអតីត និងកាលជាអនាគត តាមធម៌នេះ ដែលខ្លួនបានដឹង បានឃើញ បានសម្រេច បានដឹងច្បាស់ បានជ្រៀតជ្រែក ហើយមែនពិត បុគ្គលណាមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងកាលជាអតីត បានដឹងច្បាស់នូវទុក្ខ បានដឹងច្បាស់នូវទុក្ខសមុទ័យ បានដឹងច្បាស់នូវទុក្ខនិរោធ បានដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទា បុគ្គលទាំងនោះ បានដឹងច្បាស់នូវទុក្ខនេះឯង បានដឹងច្បាស់នូវទុក្ខសមុទ័យនេះឯង បានដឹងច្បាស់នូវទុក្ខនិរោធនេះឯង បានដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទានេះឯង បុគ្គលណាមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងកាលជាអនាគតនឹងដឹងច្បាស់នូវទុក្ខ នឹងដឹងច្បាស់នូវទុក្ខសមុទ័យ នឹងដឹងច្បាស់នូវទុក្ខនិរោធ នឹងដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទា បុគ្គលទាំងនោះ នឹងដឹងច្បាស់នូវទុក្ខនេះឯង នឹងដឹងច្បាស់នូវទុក្ខសមុទ័យនេះឯង នឹងដឹងច្បាស់នូវទុក្ខនិរោធនេះឯង នឹងដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទានេះឯង ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះហៅថា សេចក្តីដឹងក្នុងការប្រព្រឹត្តទៅតាម ។ បណ្តាញាណទាំងនោះ សេចក្តីដឹងក្នុងការកំណត់ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ទាបស្ទង់មើលនូវចិត្តរបស់សត្វដទៃ របស់បុគ្គលដទៃដោយចិត្តរបស់ខ្លួនឯង តែងដឹងច្បាស់ គឺចិត្តប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តប្រាស

ចាកទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្តប្រកបដោយមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្តរួញរាក្តី ក៏ដឹងច្បាស់ថា ចិត្តរួញរា ចិត្តរាយមាយក្តី ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដល់នូវភាពដ៏ប្រសើរក្តី ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាពដ៏ប្រសើរ ចិត្តដល់នូវភាពមិនប្រសើរក្តី ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាពមិនប្រសើរ ចិត្តប្រកបដោយឧត្តរៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយឧត្តរៈ ចិត្តមិនមានឧត្តរៈក្តី ក៏ដឹងច្បាស់ថា ចិត្តមិនមានឧត្តរៈ ចិត្តតម្កល់មាំក្តី ក៏ដឹងច្បាស់ថា ចិត្តតម្កល់មាំ ចិត្តមិនតម្កល់មាំក្តី ក៏ដឹងច្បាស់ថា ចិត្តមិនតម្កល់មាំ ចិត្តផុតស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តផុតស្រឡះ ចិត្តមិនផុតស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនផុតស្រឡះ ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះហៅថា សេចក្តីដឹងក្នុងការកំណត់ ។ បញ្ញាដ៏សេស វៀរលែងតែសេចក្តីដឹងក្នុងធម៌ សេចក្តីដឹងក្នុងការប្រព្រឹត្តទៅតាម និងសេចក្តីដឹងក្នុងការកំណត់ចេញ ឈ្មោះថា សេចក្តីដឹងក្នុងការសន្មត ។

[ ៦០ ] បណ្តាញាណទាំងនោះ បញ្ញាក្នុងការសន្សំ ( កម្មកិលេស ) មិនមែនក្នុងការមិនសន្សំ តើដូចម្តេច ។ បញ្ញាក្នុងកាមាវចរកុសល ឈ្មោះថា បញ្ញាក្នុងការសន្សំ ( កម្មកិលេស ) មិនមែនក្នុងការមិនសន្សំ ។ បញ្ញាក្នុងមគ្គ ៤ ឈ្មោះថា បញ្ញាក្នុងការមិនសន្សំ មិនមែនក្នុងការសន្សំ ។ បញ្ញាក្នុងរូបាវចរកុសល និងអរូបាវចរកុសល ឈ្មោះថា បញ្ញាក្នុងការសន្សំផង

ក្នុងការមិនសន្សំផង បញ្ញាដ៏សេស ឈ្មោះថា បញ្ញាមិនមែនក្នុងការសន្សំ ទាំងមិនមែនក្នុងការមិនសន្សំ ។

[ ៦១ ] បណ្តាញាណទាំងនោះ បញ្ញាក្នុងសេចក្តីនឿយណាយ មិនមែនក្នុងការត្រាស់ដឹង តើដូចម្តេច ។ បុគ្គលជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយដោយបញ្ញាណា តែមិនត្រាស់ដឹងនូវអភិញ្ញាទាំងឡាយ ទាំងមិនត្រាស់ដឹងនូវសច្ចៈទាំងឡាយទេ នេះហៅថា បញ្ញាក្នុងសេចក្តីនឿយណាយ មិនមែនក្នុងការត្រាស់ដឹង ។ បុគ្គលនោះ កាលបើប្រាសចាកតម្រេក ក្នុងកាមទាំងឡាយហើយ រមែងត្រាស់ដឹងនូវអភិញ្ញាទាំងឡាយ តែមិនត្រាស់ដឹងនូវសច្ចៈទាំងឡាយដោយប្រាជ្ញា នេះហៅថា បញ្ញាក្នុងការត្រាស់ដឹង មិនមែនក្នុងសេចក្តីនឿយណាយ ។ បញ្ញាក្នុងមគ្គ ៤ ឈ្មោះថា បញ្ញាក្នុងសេចក្តីនឿយណាយផង ក្នុងការត្រាស់ដឹងផង ។ បញ្ញាដ៏សេស ឈ្មោះថា បញ្ញាមិនមែនក្នុងសេចក្តីនឿយណាយ មិនមែនក្នុងការត្រាស់ដឹង ។

[ ៦២ ] បណ្តាញាណទាំងនោះ បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ តើដូចម្តេច ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយកាម រមែងជាស់តឿននូវបុគ្គលដែលបានបឋមជ្ឈាន ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ សតិមានសភាពដ៏សមគួរដល់បញ្ញានោះតាំងនៅស្មើ ឈ្មោះថា បញ្ញាមានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្ត ដោយសញ្ញាមិនប្រកបដោយវិតក្ក រមែងជាស់តឿន ( នូវបុគ្គលដែលបានបឋមជ្ឈាននោះ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញា

ប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈរមែងដាស់តឿន ( នូវបុគ្គលដែលបាន បឋមជ្ឈាននោះ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីទៀយណាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយវិតក្ក រមែងដាស់តឿននូវបុគ្គល ដែលបានទុតិយជ្ឈាន ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ សតិ មានសភាពដ៏សមគួរដល់បញ្ញានោះតាំងនៅស្មើ ឈ្មោះថា បញ្ញាមានចំណែក នៃការតាំងនៅ ការធ្វើទុកក្នុងចិត្ត ដោយសញ្ញាប្រកបដោយឧបេក្ខា រមែង ដាស់តឿន ( នូវបុគ្គលដែលបានទុតិយជ្ឈាននោះ ) ឈ្មោះថា បញ្ញាមាន ចំណែកនៃសេចក្តីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈរមែងដាស់តឿន ( នូវបុគ្គលដែលបានទុតិយជ្ឈាននោះ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីទៀយណាយ ។ ការធ្វើទុកក្នុងចិត្ត ដោយសញ្ញាប្រកបដោយបីតិ រមែងដាស់តឿននូវបុគ្គលដែលបានតតិយជ្ឈាន ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ សតិមានសភាពដ៏សមគួរ ដល់បញ្ញានោះតាំងនៅស្មើ ឈ្មោះថា បញ្ញាមានចំណែកនៃការតាំងនៅ ការ ធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយអទុក្ខមសុខវេទនា រមែងដាស់តឿន ( នូវបុគ្គលដែលបានតតិយជ្ឈាននោះ ) ឈ្មោះថា បញ្ញាមានចំណែកនៃ សេចក្តីវិសេស ការធ្វើទុកក្នុងចិត្ត ដោយសញ្ញាប្រកបដោយនិព្វិទា ប្រកប ដោយវិរាគៈ រមែងដាស់តឿន ( នូវបុគ្គលដែលបានតតិយជ្ឈាននោះ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីទៀយណាយ ។ ការធ្វើទុកក្នុងចិត្ត ដោយសញ្ញាប្រកបដោយសុខ រមែងដាស់តឿននូវបុគ្គលដែលបានចតុត្ថជ្ឈាន

ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ សតិមានសភាពដ៏សមគួរដល់បញ្ញានោះតាំងនៅស្មើ ឈ្មោះថា បញ្ញាមានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្ត ដោយសញ្ញាប្រកបដោយអាកាសានញ្ចាយតនៈ រមែងជាស់តឿន ( នូវបុគ្គលដែលបានចតុត្ថជ្ឈាននោះ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងជាស់តឿន ( នូវបុគ្គលដែលបានចតុត្ថជ្ឈាននោះ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីនឿយណាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយរូប រមែងជាស់តឿននូវបុគ្គលដែលបានអាកាសា-នញ្ចាយតនៈ ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ សតិមានសភាពដ៏សមគួរដល់បញ្ញានោះតាំងនៅស្មើ ឈ្មោះថា បញ្ញាមានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយវិញ្ញាណញ្ចាយតនៈ រមែងជាស់តឿន ( នូវបុគ្គលដែលបានអាកាសានញ្ចាយតនៈនោះ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងជាស់តឿន ( នូវបុគ្គលដែលបានអាកាសានញ្ចាយតនៈ ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីនឿយណាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយអាកាសានញ្ចាយតនៈ រមែងជាស់តឿននូវបុគ្គលដែលបានវិញ្ញាណញ្ចាយតនៈ ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ សតិមានសភាពដ៏សមគួរដល់បញ្ញានោះតាំងនៅស្មើ ឈ្មោះថា បញ្ញាមានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្តដោយ

សញ្ញាប្រកបដោយអាកិញ្ចញ្ញាយតនៈ រមែងដាស់តឿន ( នូវបុគ្គលដែលបានវិញ្ញាណញ្ចាយតនៈ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្ដីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿននូវបុគ្គលដែលបានវិញ្ញាណញ្ចាយតនៈ ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្ដីនឿយណាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយវិញ្ញាណញ្ចាយតនៈ រមែងដាស់តឿននូវបុគ្គលដែលបានអាកិញ្ចញ្ញាយតនៈ ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្ដីសាបសូន្យ សតិមានសភាពដ៏សមគួរដល់បញ្ញានោះតាំងនៅស្មើ ឈ្មោះថា បញ្ញាមានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្តដោយសញ្ញាប្រកបដោយនេវសញ្ញានាសញ្ញាយតនៈ រមែងដាស់តឿន ( នូវបុគ្គលដែលបានអាកិញ្ចញ្ញាយតនៈ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្ដីវិសេស ការធ្វើទុកក្នុងចិត្ត ដោយសញ្ញាប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿន ( នូវបុគ្គលដែលបានអាកិញ្ចញ្ញាយតនៈ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្ដីនឿយណាយ ។

[ ៦៣ ] បណ្ដាញាណទាំងនោះ បដិសម្ភិទា ៤ តើដូចម្ដេច ។ អត្ថប្បដិសម្ភិទា ១ ធម្មប្បដិសម្ភិទា ១ និរុត្តិប្បដិសម្ភិទា ១ បដិភាណប្បដិសម្ភិទា ១ ។ ការដឹងក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា ការដឹងក្នុងធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទា ការដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថ និងធម៌ទាំងនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា ការដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ នេះបដិសម្ភិទា ៤ ។

[ ៦៤ ] បណ្ដាញាណទាំងនោះ បដិបទា ៤ តើដូចម្ដេច ។ បញ្ញាដែលប្រតិបត្តិលំបាកមានការត្រាស់ដឹងយូរ ១ បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ១ បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងយូរ ១ បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ១ ។ បណ្ដាបញ្ញាទាំង ៤ នោះ បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងយូរ តើដូចម្ដេច ។ កាលបុគ្គលញ៉ាំងលោកុត្តរសមាធិ ឲ្យកើតដោយលំបាក ដោយកម្រ កាលត្រាស់ដឹងនូវហេតុ គឺលោកុត្តរសមាធិនោះដោយយឺតយូរ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណាកើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងយូរ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ តើដូចម្ដេច ។ កាលបុគ្គលញ៉ាំងលោកុត្តរសមាធិឲ្យកើតដោយលំបាក ដោយកម្រ កាលត្រាស់ដឹងនូវហេតុ គឺលោកុត្តរសមាធិនោះដោយឆាប់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងយូរ តើដូចម្ដេច ។ កាលបុគ្គលញ៉ាំងលោកុត្តរសមាធិឲ្យកើត ដោយមិនលំបាក ដោយមិនក្រ កាលដឹងច្បាស់នូវហេតុ គឺលោកុត្តរសមាធិនោះ ដោយយឺតយូរ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិងាយ មានការ

ត្រាស់ដឹងយូរ ។ បណ្តាបញ្ញាទាំងនោះ បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ តើដូចម្តេច ។ កាលបុគ្គលញុំាងលោកុត្តរសមាធិ ឲ្យកើតដោយមិនលំបាក ដោយមិនក្រ កាលដឹងច្បាស់នូវហេតុ គឺលោកុត្តរសមាធិនោះដោយឆាប់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា កើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ។ នេះបដិបទា ៤ ។

[ ៦៥ ] បណ្តាញាណទាំងនោះ អារម្មណ៍ ៤ តើដូចម្តេច ។ បញ្ញាមានសភាពតូចឆ្មារ ទាំងមានអារម្មណ៍តូចឆ្មារ ១ បញ្ញាមានសភាពតូចឆ្មារ តែមានអារម្មណ៍ប្រមាណមិនបាន ១ បញ្ញាប្រមាណមិនបាន តែមានអារម្មណ៍តូចឆ្មារ ១ បញ្ញាប្រមាណមិនបាន ទាំងមានអារម្មណ៍ប្រមាណមិនបាន ១ ។ បណ្តាបញ្ញាទាំងនោះ បញ្ញាមានសភាពតូចឆ្មារ ទាំងមានអារម្មណ៍តូចឆ្មារ តើដូចម្តេច ។ កាលបុគ្គលមិនបាននូវសមាធិតាមសេចក្តីប្រាថ្នា ទាំងផ្សាយទៅនូវអារម្មណ៍តិចតួច បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា កើតឡើង នេះហៅថា បញ្ញាមានសភាពតូចឆ្មារ ទាំងមានអារម្មណ៍តូចឆ្មារ ។ បណ្តាបញ្ញាទាំងនោះ បញ្ញាមានសភាពតូចឆ្មារ តែមានអារម្មណ៍ប្រមាណមិនបាន តើដូចម្តេច ។ កាលបុគ្គលមិនបាននូវសមាធិ តាមសេចក្តីប្រាថ្នា តែផ្សាយទៅនូវអារម្មណ៍ដ៏ធំទូលាយ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា កើតឡើង នេះហៅថា បញ្ញាមានសភាពតូចឆ្មារ តែមាន

អារម្មណ៍ប្រមាណមិនបាន ។ បណ្តាបញ្ញាទាំងនោះ បញ្ញាប្រមាណមិនបាន តែមានអារម្មណ៍តូចឆ្មារ តើដូចម្តេច ។ កាលបុគ្គលបាននូវសមាធិដូចសេចក្តីប្រាថ្នា តែផ្សាយទៅនូវអារម្មណ៍តិចតួច បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង នេះហៅថា បញ្ញាប្រមាណមិនបាន តែមានអារម្មណ៍តូចឆ្មារ ។ បណ្តាបញ្ញាទាំងនោះ បញ្ញាប្រមាណមិនបាន ទាំងមានអារម្មណ៍ប្រមាណមិនបាន តើដូចម្តេច ។ កាលបុគ្គលបាននូវសមាធិ ដូចសេចក្តីប្រាថ្នា ទាំងផ្សាយទៅនូវអារម្មណ៍ដ៏ធំទូលាយ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណានូវធម៌ ការឃើញត្រូវណា កើតឡើង នេះហៅថា បញ្ញាប្រមាណមិនបាន ទាំងមានអារម្មណ៍ប្រមាណមិនបាន ។ នេះអារម្មណ៍ ៤ ។

[ ៦៦ ] សេចក្តីដឹងរបស់បុគ្គលព្រមព្រៀងដោយមគ្គ ឈ្មោះថា សេចក្តីដឹងក្នុងជរាមរណៈ ឈ្មោះថា សេចក្តីដឹងក្នុងហេតុ ដែលឲ្យកើតជរាមរណៈ ឈ្មោះថា សេចក្តីដឹងក្នុងការរលត់ជរាមរណៈ ឈ្មោះថា សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ជរាមរណៈ ។ បណ្តាញាណទាំងនោះ សេចក្តីដឹងក្នុងជរាមរណៈ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធជរាមរណៈ នេះហៅថា សេចក្តីដឹងក្នុងជរាមរណៈ ។ ព្រោះប្រារព្ធហេតុដែលឲ្យកើតជរាមរណៈ ។បេ។ ព្រោះប្រារព្ធការរលត់ជរាមរណៈ ។បេ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញ

ត្រូវណា កើតឡើង ព្រោះប្រារព្ធបដិបទាជាដំណើរទៅកាន់ទីរលត់ជរាមរណៈ នេះហៅថា សេចក្ដីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ជរាមរណៈ ។ សេចក្ដីដឹងរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ឈ្មោះថា សេចក្ដីដឹងក្នុងជាតិ ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងភព ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងឧបាទាន ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងតណ្ហា ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងវេទនា ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងផស្សៈ ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងសឡាយតនៈ ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងនាមរូប ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងវិញ្ញាណ ។បេ។ ឈ្មោះថា សេចក្ដីដឹងក្នុងសង្ខារទាំងឡាយ ឈ្មោះថា សេចក្ដីដឹងក្នុងហេតុ ដែលឲ្យកើតសង្ខារ ឈ្មោះថា សេចក្ដីដឹងក្នុងការរលត់នៃសង្ខារ ឈ្មោះថា សេចក្ដីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់សង្ខារ ។ បណ្ដាញាណទាំងនោះ សេចក្ដីដឹងក្នុងសង្ខារទាំងឡាយ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធនូវសង្ខារទាំងឡាយ នេះហៅថា សេចក្ដីដឹងក្នុងសង្ខារទាំងឡាយ ។ ព្រោះប្រារព្ធហេតុដែលឲ្យកើតសង្ខារ ។បេ។ ព្រោះប្រារព្ធការរលត់នៃសង្ខារ ។បេ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធនូវបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ នេះហៅថា សេចក្ដីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។

**ញាណវត្ថុ មានប្រការ ៤ យ៉ាងនេះឯង ។**

# អដ្ឋកថា

## ចតុក្កនិទ្ទេស

[ ៥៦-៦៦ ] ក្នុងនិទ្ទេសនៃញាណវត្ថុពួក ៤ ក្នុងបទថា **អត្ថិ ទិន្នំ** ជាដើម បណ្ឌិតគប្បីជ្រាបអត្ថដោយឧបាយនេះថា ផលមាន ព្រោះទានដែលខ្ញុំឲ្យហើយជាបច្ច័យ ដូច្នេះ ។

បទថា **ឥទំ វុច្ចតិ** អធិប្បាយថា ញាណណាមែងដឹងថា កម្មនេះជារបស់ខ្លួន កម្មនេះមិនមែនជារបស់ខ្លួន ញាណនេះ ទើបព្រះមានព្រះភាគត្រាស់ ហៅថា **កម្មស្សកតាញាណំ** ។

បណ្តាកម្មទាំង ២ ( របស់ខ្លួន និងរបស់អ្នកដទៃ ) កម្ម គឺកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ មនោទុច្ចរិត ៣ នេះ មិនឈ្មោះថា ជាកម្មនៃខ្លួនទេ ។

សុចរិតកម្មទាំង ១០ ក្នុងទ្វារទាំង ៣ ឈ្មោះថា ជាកម្មរបស់ខ្លួន ។

អកុសលទាំងអស់ ទោះជារបស់ខ្លួន ឬរបស់អ្នកដទៃក៏ដោយ មិនឈ្មោះថា ជាកម្មរបស់ខ្លួនឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះទម្លាយនូវប្រយោជន៍ និងព្រោះធ្វើវត្ថុដែលមិនជាប្រយោជន៍ឲ្យកើត ។ កុសលទាំងអស់ជារបស់ខ្លួនក្តី របស់អ្នកដទៃក្តី ឈ្មោះថា ជាកម្មរបស់ខ្លួន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការទម្លាយវត្ថុដែលមិនមែនជាប្រយោជន៍ និងព្រោះធ្វើប្រយោជន៍ឲ្យកើត ។ ការរាប់ចំនួនបុគ្គល ដែលតាំងនៅក្នុងកម្មស្សកតញ្ញាណនេះ ដែលអាចដឹងយ៉ាងនេះ ហើយឲ្យទានច្រើន បំពេញសីលឲ្យបរិបូណ៌ សមាទានឧបោសថ ហើយសោយសេចក្តីសុខដោយសេចក្តីសុខ

សោយសម្បត្តិដោយសម្បត្តិ ហើយសម្រេចព្រះនិព្វាន កំណត់មិនបាន ។

ដូចបុរសមានទ្រព្យ ឲ្យជញ្ជូនសប្បិ ទឹកឃ្មុំ ស្ករអំពៅជាដើម មួយអន្លើដោយអំបិល ល្ង អង្ករជាដើម ដាក់រទេះ ៥០០ ធ្វើដំណើរឆ្លងផ្លូវកន្តារ កាលសេចក្តីត្រូវការដោយកិច្ចណាមួយកើតឡើង បុរសនោះមិនគិត មិនតក់ស្លុត ព្រោះគ្រឿងឧបភោគបរិភោគទាំងពួង ជារបស់ដែលបុរសនោះគ្រប់គ្រងហើយ រមែងដល់គោលដៅដ៏ក្សេមបានដោយងាយនោះឯង យ៉ាងណា បុគ្គលតាំងនៅក្នុងកម្មស្សកតញ្ញាណនេះ ឲ្យទានជាច្រើន ។បេ។ រមែងដល់ព្រះនិព្វានទីងរាប់ប្រមាណក៏យ៉ាងនោះ ។

បទថា **ឋបេត្វា សច្ចានុលោមិកំ ញាណំ** អធិប្បាយថា វៀរវិបស្សនាញាណដែលបានឈ្មោះថា សច្ចានុលោមិកញ្ញាណ ព្រោះអនុលោមតាមមគ្គសច្ច និងបរមត្ថសច្ចហើយ កុសលប្បញ្ញាដ៏សេសដែលជាអារម្មណ៍របស់អាសវៈទាំងអស់ ឈ្មោះថា កម្មស្សកតញ្ញាណ ។

ក្នុងបទថា **មគ្គសមង្គិស្ស ញាណំ ទុក្ខេបេតំ ញាណំ** នេះ ព្រះមានព្រះភាគទ្រង់កាន់យកមគ្គញ្ញាណ ១ ប៉ុណ្ណោះក្នុងឋានៈ ៤ ដោយអំណាចនៃការចាក់ធ្លុះសច្ចៈ ១ ក្នុងសច្ចៈ ៤ ។

បទថា **ធម្មេ ញាណំ** នេះ បញ្ញាក្នុងមគ្គ ឈ្មោះថា ធម្មញ្ញាណដោយអំណាចនៃការចាក់ធ្លុះសច្ចៈ ១ ក្នុងសច្ចៈទាំង ៤ ចូរស្ទេះទុកសិន បញ្ញាក្នុងផល ឈ្មោះថា **ធម្មញ្ញាណ** បានដូចម្តេច បញ្ញាក្នុងផល ឈ្មោះថា **ធម្មញ្ញាណ** បាន ដោយអំណាចនៃនិរោធសច្ច ។ ពិតហើយ បញ្ញាទាំង ២

នោះ គឺក្នុងមគ្គ និងផល គប្បីជ្រាបថា ឈ្មោះថា **ធម្មញ្ញាណ** ព្រោះញាណនោះ ប្រព្រឹត្តទៅដោយកិច្ច និងដោយអារម្មណ៍ក្នុងធម៌ គឺអរិយសច្ច ៤ ដែលមិនមានវត្ថុដទៃជាបច្ច័យ ដែលមានអត្ថជាក់ច្បាស់ ។

ក្នុងបទថា **សោ ឥមិនា ធម្មេន** នេះ មគ្គញ្ញាណ ព្រះមានព្រះភាគត្រាស់ហៅថា ធម៌ ដោយវោហារថា គោចរ ព្រោះមគ្គញ្ញាណ មានធម៌ជាគោចរ ។ ម្យ៉ាងទៀត ពាក្យថា **ឥមិនា ធម្មេន** នេះ ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ អធិប្បាយថា ដែលដឹងនូវធម៌នេះ មានពាក្យអធិប្បាយថា មគ្គញ្ញាណដែលដឹងសច្ចធម៌ ៤ ហើយតាំងនៅ ។ បទថា **ទិដ្ឋេន** អធិប្បាយថា ដែលឃើញធម៌ដោយទស្សនៈ ហើយតាំងនៅ ។ បទថា **បត្តេន** បានដល់ ទ្រង់សម្រេចធម៌ ព្រោះសម្រេចអរិយសច្ច ៤ ហើយតាំងនៅ ។ បទថា **វិទិតេន** បានដល់ អរិយសច្ច ៤ ដែលទ្រង់ដឹងច្បាស់ហើយ គឺទ្រង់ធ្វើឲ្យប្រាកដហើយដោយមគ្គញ្ញាណ ព្រោះហេតុនោះ ទើបអរិយសច្ចទាំង ៤ នោះ ឈ្មោះថា ជាធម៌ដែលព្រះមានព្រះភាគដឹងច្បាស់ហើយដោយធម៌ ។ ដោយធម៌ដែលមានមគ្គញ្ញាណដឹងច្បាស់នោះ ។

បទថា **បរិយោគាឡ្ហេន** បានដល់ ទ្រង់ឈមចុះកាន់សច្ចៈទាំង ៤ ហើយតាំងនៅ ។

បទថា **នយំ នេតិ** បានដល់ ទ្រង់បង្អោនទៅ ទ្រង់នាំទៅ ទ្រង់បញ្ជូនន័យទៅក្នុងអតីត និងអនាគត ។ ទ្រង់បញ្ជូនន័យទៅនេះមិនជាកិច្ចរបស់មគ្គញ្ញាណ ជាកិច្ចរបស់បច្ចវេក្ខណញ្ញាណ ព្រះសាស្ដាទ្រង់ធ្វើមគ្គញ្ញាណឲ្យជា

ន័យឲ្យដូចគ្នានឹងការបង្អោនទៅក្នុងអតីត និងអនាគត ។ ព្រោះហេតុអ្វី ព្រោះមគ្គញាណមានមគ្គជាហេតុ ។ ពិតហើយ បច្ចវេក្ខណញាណ រមែងមានដល់ព្រះមានព្រះភាគដែលមានមគ្គចម្រើនហើយ ។ ព្រោះហេតុនោះ ទើបព្រះសាស្តាទ្រង់ធ្វើមគ្គញាណនោះឯង ឲ្យជាន័យ គឺឲ្យដូចគ្នានឹងការបង្អោនទៅ ។ ន័យម្យ៉ាងទៀត គប្បីជ្រាបអធិប្បាយក្នុងសេចក្តីនេះ យ៉ាងនេះថា មគ្គញាណដែលមានសច្ចៈ ៤ ជាគោចរនេះ ដែលព្រះមានព្រះភាគសម្រេចហើយ ទ្រង់បញ្ជូនន័យ ពោល គឺបច្ចវេក្ខណញាណ ក្នុងអតីត និងអនាគត ដោយញាណដែលជាហេតុនោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់បង្អោនទៅដោយញាណនោះ ដោយប្រការណា ដើម្បីសម្តែងនូវអាការនោះ ដោយប្រការនោះ ទើបត្រាស់ថា **យេ ហិ កេ ចិ អតីតមទ្ធានំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អព្ភញ្ញំសុ** បានដល់ ដឹងហើយ គឺចាក់ធ្លុះហើយ ។ បទថា **ឥមញ្ញេវ** បានដល់ សមណព្រាហ្មណ៍ពួកណាមួយបានដឹងទុក្ខណាក្នុងអតីត និងដឹងទុក្ខក្នុងអនាគត រមែងមិនដឹងទុក្ខនោះឯង ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់អធិប្បាយដូច្នេះនេះ ព្រោះអត្ថដូចគ្នា ។ ពិតហើយ ក្នុងអតីត សមណ-ព្រាហ្មណ៍ពួកណាមួយ ដឹងហើយនូវខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះឯង វៀរតណ្ហាថា ជាទុក្ខសច្ច ដឹងហើយនូវតណ្ហានោះឯងថា ជាសមុទយសច្ច ដឹងហើយនូវនិព្វាននោះឯងថា ជានិរោធសច្ច ដឹងហើយនូវអរិយមគ្គនោះឯងថាជាមគ្គសច្ច ក្នុងអនាគតក៏នឹងដឹងយ៉ាងនេះឯង ក្នុងបច្ចុប្បន្នក៏ដឹងយ៉ាង

នេះឯង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ដោយអត្ថតែមួយ ។

បទថា **ឥធំ វុច្ចតិ អន្វយេ ញាណំ** បានដល់ ញាណនេះ ហៅថា អនុគមនញ្ញាណ គឺញាណជាគ្រឿងតាមដឹង នយនញ្ញាណ គឺញាណជាគ្រឿងបង្អោនទៅ និងការណញ្ញាណ គឺញាណជាហេតុ ។

បទថា **បរិយេ ញាណំ** បានដល់ ញាណជាគ្រឿងកំណត់ចិត្ត ។ បទថា **បរសត្តានំ** បានដល់ សត្វដ៏សេស វៀរខ្លួនឯង ។ បទក្រៅអំពីនេះ គឺបទថា **បរបុគ្គលានំ** នេះ ជាវេវចនៈនៃបទថា **បរសត្តានំ** នោះឯង ។ បទថា **ចេតសា ចេតោ បរិច្ច បជានាតិ** អធិប្បាយថា កំណត់ដឹងចិត្តរបស់សត្វទាំងនោះដោយចិត្តរបស់ខ្លួនដោយអំណាចនៃចិត្ត មានរាគៈជាដើម ហើយដឹងបានដោយប្រការផ្សេងៗ ។ ពាក្យណាដែលគប្បីពោល មានបទថា **សរាគំ វា** ជាដើម ពាក្យនោះ ខ្ញុំបានពោលហើយ ក្នុងសតិប្បដ្ឋានវិភង្គនោះឯង ។

ចំណែកការផ្សេងគ្នា មានដូចតទៅនេះ ក្នុងបរិច្ឆេទញ្ញាណនេះ សូម្បីលោកុត្តរចិត្ត ក៏រមែងបានក្នុងបទនេះថា ចិត្តប្រកបដោយឧត្តរៈក្តី ចិត្តផុតស្រឡះក្តី ។ ពិតហើយ ចិត្តរបស់អ្នកដទៃ សូម្បីមិនចូលទៅកាន់វិបស្សនា ក៏ជាវិស័យរបស់ញាណនោះឯង ។

បទថា **អវសេសា បញ្ញា** បានដល់ វៀរបញ្ញា ៣ យ៉ាង មានធម្មញ្ញាណជាដើម ( វៀរបញ្ញាក្នុងធម៌ បញ្ញាក្នុងការប្រព្រឹត្តទៅតាម និងបញ្ញាក្នុងការកំណត់ ) បញ្ញាដ៏សេសទាំងអស់ ឈ្មោះថា បញ្ញាក្នុងការសន្មត ។

ព្រោះសន្មតថាជាញាណ ។ ក្នុងសម្មតិញ្ញាណនេះ មានវចនត្ថៈដូចតទៅ ឈ្មោះថា **សម្មតិញ្ញាណំ** ព្រោះអត្ថថា ញាណក្នុងសន្មត ។

បទថា **កាមាវចរកុសលេ បញ្ញា** អធិប្បាយថា បញ្ញាក្នុងកាមាវចរ-កុសលនេះ រមែងសន្សំចុតិ និងបដិសន្ធិក្នុងវដ្តៈ ដោយចំណែកមួយប៉ុណ្ណោះ ព្រោះហេតុនោះ ទើបបញ្ញានោះ ឈ្មោះថា **អាចយាយ នោ អបចយាយ** តែបញ្ញាក្នុងលោកុត្តរមគ្គ ព្រោះមិនសន្សំចុតិ និងបដិសន្ធិ ហេតុនោះ ទើបត្រាស់ហៅថា **អបចយាយ នោ អាចយាយ ។** បញ្ញាក្នុងរូបាវចរកុសល និងអរូបាវចរកុសល រមែងសន្សំចុតិបដិសន្ធិ រមែងមិនសន្សំកិលេសទាំងឡាយ និងធម៌ទាំងឡាយដែលមានកិលេសជាមូលផងដែរ ដោយអំណាចនៃការសង្កត់សង្កិន ព្រោះហេតុនោះ ទើបត្រាស់ថា **អាចយាយ ចេវ អប-ចយាយ ច** បញ្ញាដ៏សេស រមែងសន្សំចុតិ និងបដិសន្ធិក៏មិនមែន មិនសន្សំក៏មិនមែន ព្រោះហេតុនោះ ទើបត្រាស់ថា **នេវ អាចយាយ នោ អបច-យាយ** ដូច្នេះ ។

បទថា **ន ច អភិញ្ញាយោ បដិវិជ្ឈតិ** នេះ ត្រាស់សំដៅយកបញ្ញាក្នុងបឋមជ្ឈាន ។ ពិតហើយ បញ្ញានោះ រមែងប្រព្រឹត្តទៅព្រមដើម្បីនឿយណាយចំពោះកិលេស ព្រោះបឋមជ្ឈាននោះ ជាធម៌ដែលព្រះយោគាវចរគប្បីសម្រេចដោយការស្ងាត់ចាកកាម ព្រះយោគាវចរ ជាអ្នកមានរាគៈទៅប្រាសហើយក្នុងកាមទាំងឡាយ ព្រោះបញ្ញាក្នុងបឋមជ្ឈាននោះ តែរមែងមិនចាក់ធ្លុះនូវអភិញ្ញាទាំង ៥ ព្រោះមិនបានសម្រេចការៈនៃឈាន ដែលជាបាទ

របស់អភិញ្ញា រមែងមិនចាក់ធ្លុះនូវសច្ចៈទាំងឡាយ ព្រោះនៅមាននិមិត្តជាអារម្មណ៍ ដោយអាការយ៉ាងនេះ បញ្ញានេះរមែងមានដើម្បីការនឿយណាយ រមែងមានដើម្បីការចាក់ធ្លុះ ។ បទថា **សេ្វ** បានដល់ បុគ្គលដែលសម្រេចបឋមជ្ឈានហើយតាំងនៅ ។ បទថា **កាមេសុ វីតរាគោ សមានោ** បានដល់ បុគ្គលអ្នកមានរាគៈទៅប្រាសហើយដោយអំណាចកាមទាំងឡាយដែលខ្ទង់សង្កត់សង្កិនហើយយ៉ាងនោះឯង ។ បទថា **អភិញ្ញាយោ បដិវិជ្ឈតិ** បានដល់ ចាក់ធ្លុះអភិញ្ញា ៥ ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់សំដៅយកបញ្ញាក្នុងចតុត្ថជ្ឈាន ពិតហើយ បញ្ញាក្នុងចតុត្ថជ្ឈានរមែងចាក់ធ្លុះនូវអភិញ្ញា ៥ ព្រោះជាបាទនៃអភិញ្ញាខ្លះ រមែងចាក់ធ្លុះនោះឯង ព្រោះសម្រេចភាពជាអភិញ្ញាខ្លះ ព្រោះហេតុនោះ ទើបបញ្ញានោះ រមែងមានដើម្បីការចាក់ធ្លុះ តែមិនមានដើម្បីការនឿយណាយ ព្រោះបញ្ញាក្នុងបឋមជ្ឈាននោះឯង ជាហេតុឲ្យនឿយណាយក្នុងកិលេសទាំងឡាយ ។

សួរថា បញ្ញាក្នុងទុតិយជ្ឈាន និងតតិយជ្ឈាននេះ បញ្ញានេះរមែងសេពនូវចំណែកណា ឆ្លើយថា បញ្ញាក្នុងទុតិយជ្ឈាន តតិយជ្ឈាន រមែងសេពបឋមជ្ឈានដោយអំណាចនៃសោមនស្សក៏បាន នឹងរមែងសេពនូវចតុត្ថជ្ឈានដោយអំណាចការមិនមានវិតក្កក៏បាន ។ បញ្ញាក្នុងទុតិយជ្ឈាន និងតតិយជ្ឈាននោះ គប្បីធ្វើអធិប្បាយឲ្យជាបញ្ញាដែលអាស្រ័យបឋមជ្ឈានខ្លះ ដែលអាស្រ័យចតុត្ថជ្ឈានខ្លះ ដោយអាការយ៉ាងនេះ ។

បទថា **ឆព្វិធាយ ចេវ បដិវេធាយ ច** បានដល់ មគ្គប្បញ្ញារមែងមាន

ដើម្បីការនឿយណាយ ព្រោះការនឿយណាយក្នុងវដ្តៈទាំងអស់ និងរមែងមានដើម្បីការចាក់ធ្លុះ ព្រោះការចាក់ធ្លុះនូវអភិញ្ញា ៦ ។

ក្នុងបទថា **បឋមស្ស ឈានស្ស លាភី** ជាដើម អធិប្បាយថា ព្រះយោគាវចរណាដែលបានបឋមជ្ឈាន ដែលមិនទាន់ស្ទាត់ជំនាញ សញ្ញាមនសិការដែលជាធម៌សហគតៈដោយកាម ដោយអំណាចនៃអារម្មណ៍ រមែងរាយមាយ ចាក់ដោត ដាស់តឿន ព្រះយោគាវចរនោះ ដែលចេញអំពីបឋមជ្ឈាននោះហើយ ទើបបញ្ញាក្នុងបឋមជ្ឈាននោះវិនាស វិនាសដោយជុំវិញ វិនាសដោយអំណាចនៃសញ្ញាមនសិការ ដែលស្ទុះតាមកាមរបស់ព្រះយោគាវចរនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ហានភាគិនី** ដូច្នេះ ។

បទថា **តទនុធម្មតា** បានដល់ ជាសភាវៈសមគួរដល់បញ្ញានោះ ។ បទថា **សតិ សន្តិដ្ឋតិ** នេះ ព្រះមានព្រះភាគ ត្រាស់សំដៅយកមិច្ឆាសតិ មិនបានត្រាស់សំដៅយកសម្មាសតិឡើយ ។ ពិតហើយ និកន្តិ គឺការពេញចិត្តដែលមានសភាវៈសមគួរដល់បឋមជ្ឈានដែលត្រេកអរ ដែលត្រេកត្រអាល ព្រោះឃើញបឋមជ្ឈានដោយភាពជាធម៌ល្អិត ប្រណីត រមែងកើតឡើងដល់បុគ្គលណា បញ្ញាក្នុងបឋមជ្ឈាននោះ របស់បុគ្គលនោះ រមែងមិនវិនាស និងរមែងមិនចម្រើន ដោយអំណាចនៃនិកន្តិ គឺការពេញចិត្ត រមែងជាបញ្ញាដែលមានចំណែកនៃការតាំងនៅ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឋិតិភាគិនី** ដូច្នេះ ។

បទថា **អវិតក្កសហគតា** បានដល់ ដែលសហគតៈដោយឈានដែលមិនមានវិតក្ក ដោយអំណាចអារម្មណ៍របស់ព្រះយោគាវចរដែលមនសិការទុតិយជ្ឈានដែលមិនមានវិតក្ក ដោយភាពជាធម៌ល្អិត និងប្រណីត ។ បទថា **សមុទាចរន្តិ** បានដល់ រមែងបៀតបៀន រមែងដាស់តឿននូវព្រះយោគាវចរដែលចេញចាកបឋមជ្ឈាន ដែលស្ទាត់ជំនាញ ហើយដើម្បីសម្រេចទុតិយជ្ឈាន ។ បញ្ញាក្នុងបឋមជ្ឈាននោះ ព្រះមានព្រះភាគត្រាស់ហៅថា **វិសេសភាគិនី** ព្រោះភាពជាឋានៈនៃការកើតឡើងនៃទុតិយជ្ឈាន ដែលជារបស់វិសេសដោយអំណាចសញ្ញាមនសិការដែលស្ទុះតាមទុតិយជ្ឈាន ដែលមានខាងលើនៃបឋមជ្ឈាននោះ ។

បទថា **និព្វិទាសហគតា** បានដល់ សញ្ញាមនសិការ ដែលសហគតៈដោយវិបស្សនាញាណ ពោល គឺនិព្វិទាញាណរាយមាយទៅកាន់ព្រះយោគាវចរបុគ្គល ដែលបានបឋមជ្ឈាន ចេញចាកឈានហើយនោះឯង ។ ពិតហើយ កាលការលះអង្គនៃឈានកំពុងប្រព្រឹត្តទៅ វិបស្សនាញាណ រមែងនឿយណាយ រមែងអផ្សុក ព្រោះហេតុនោះ ទើបត្រាស់ថា និព្វិទា ដូច្នេះ ។ បទថា **សមុទាចរន្តិ** បានដល់ ចាក់ដោត ដាស់តឿន ដើម្បីការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ បទថា **វិរាគូបសញ្ហិតា** បានដល់ ប្រកបដោយព្រះនិព្វាន ពោល គឺវិរាគៈ ពិតហើយ វិបស្សនាញាណត្រាស់ហៅថា ប្រកបដោយវិរាគៈ ព្រោះប្រព្រឹត្តទៅថា មគ្គនេះ អាចធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺវិរាគៈ ។ សញ្ញាមនសិការដែលសម្បយុត្តដោយវិបស្សនាញាណនោះ ក៏

ឈ្មោះថា ប្រកបដោយវិរាគៈនោះឯង ។ បញ្ញាក្នុងបឋមជ្ឈាននោះ ព្រះមានព្រះភាគត្រាស់ហៅថា **និព្វេធភាគិនី** ព្រោះជាបទដ្ឋាននៃការចាក់ធ្លុះអរិយមគ្គ ដោយអំណាចនៃសញ្ញាមនសិការទាំងនោះរបស់វិបស្សនាញាណនោះ បញ្ញាក្នុងបឋមជ្ឈាននោះឯង ត្រាស់ក្នុងឋានៈ ៤ ដោយប្រការដូច្នេះ ។ បញ្ញាក្នុងទុតិយជ្ឈានជាដើម បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះឯង ។

បទថា **កិច្ឆេន កសិរេន សមាធឹ ឧប្បាទេន្តស្ស** បានដល់ ដល់ព្រះយោគាវចរ ដែលលំបាកដោយសម្បយោគ គឺការប្រកប ដែលប្រព្រឹត្តទៅជាមួយសង្ខារដោយក្រលំបាក ជាទុក្ខ សង្កត់កិលេសទាំងឡាយហើយ មកហើយក្នុងវេលាជាទីមក ក្នុងចំណែកខាងដើមនៃបុគ្គល ដែលនឹងញ៉ាំងលោកុត្តរសមាធិឲ្យកើតឡើង ។ បទថា **ទន្ធំ តណ្ហានំ អភិជានន្តស្ស** អធិប្បាយថា ដល់ព្រះយោគាវចរ កាលសង្កត់កិលេសទាំងឡាយហើយ នៅអស់កាលយូរ ក្នុងវេលាអប់រំវិបស្សនា ទើបដឹង ទើបចាក់ធ្លុះ ទើបដល់ឋានៈ ពោល គឺលោកុត្តរសមាធិនោះយឺតៗ សន្សឹមៗ ប្រព្រឹត្តទៅ ។

បទថា **អយំ វុច្ចតិ** បានដល់ បញ្ញានេះកើតឡើងដោយអាការយ៉ាងនេះ បញ្ញានេះសូម្បីកើតឡើងហើយក្នុងខណៈនៃចិត្ត ១ ដួង ក្នុងកាលនៃមគ្គ ព្រោះបដិបទាដែលសង្កត់កិលេសបានដោយលំបាក និងព្រោះបញ្ញាដែលកើតអំពីការអប់រំវិបស្សនាប្រព្រឹត្តទៅយឺតយូរ ទើបព្រះមានព្រះភាគ ត្រាស់

ហៅថា **ទុក្ខាបដិបទា ទន្ធាភិញ្ញា** គឺបដិបត្តិលំបាក ត្រាស់ដឹងក៏យឺតយូរ ដោយអំណាចនៃការត្រាស់ដឹង ដូច្នេះ ។ ក្នុងបទទាំង ៣ ខាងមុខ បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះឯង ។

បទថា **សមាធិស្ស ន និកាមលាភិស្ស** បានដល់ ព្រះយោគាវចរណា មិនបានសមាធិ តាមសេចក្ដីត្រូវការ ព្រះយោគាវចរនោះ ឈ្មោះថា បានសមាធិនោះមិនទាន់ស្ទាត់ជំនាញ អធិប្បាយថា ដល់ព្រះយោគាវចរ ដែលបានឈានមិនទាន់ស្ទាត់ជំនាញ ដែលមានសមាធិមិនជាបច្ច័យ ដើម្បីឈានទៅមុខ ដើម្បីជាប្រយោជន៍ក្នុងការចូលសមាធិខាងលើៗ ។ បទថា **អារម្មណំ ថោកំ ផរន្តស្ស** អធិប្បាយថា ដែលផ្សាយអារម្មណ៍តូចតាច ដែលមិនទាន់ចម្រើននោះឯង ព្រោះធ្វើបរិកម្មក្នុងបរិត្តារម្មណ៍ មានប្រមាណប៉ុនចង្អេរ ឬប៉ុនផ្តិលជាប្រមាណ ហើយសម្រេចអប្បនាក្នុងអារម្មណ៍នោះឯង ។ ក្នុងបទដ៏សេសទាំងឡាយក៏ន័យនេះដូចគ្នា ។ ព្រះយោគាវចរដែលបានឈានដែលស្ទាត់ហើយ ព្រះមានព្រះភាគត្រាស់ថា **និកាមលាភី** ក្នុងអធិការនេះ ព្រោះជាបដិបក្ខចំពោះព្រះយោគាវចរ ដែលបានសមាធិមិនទាន់ស្ទាត់ជំនាញ និងត្រាស់ហៅអារម្មណ៍ដែលចម្រើនហើយថា **វិបុលំ** ព្រោះផ្ទុយនឹងអារម្មណ៍ដែលមិនទាន់ចម្រើនហើយ ។ បទដ៏សេសក៏ន័យដូចគ្នានេះឯង ។

បទថា **ឋានសោមេតំ ញាណំ** នេះ ព្រះមានព្រះភាគ ត្រាស់ទុក

ដោយអំណាចនៃការចាក់ធ្លុះតែម្យ៉ាងនៃសច្ចៈទាំង ៤ ព្រោះធ្វើនូវព្រះនិព្វាន នោះឯងឲ្យជាអារម្មណ៍ ។ បទថា **ជរាមរណេ អារព្ភ** ជាដើម ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃការកំណត់សច្ចៈក្នុងបុព្វភាគ ក្នុងពេលដែលប្រារព្ធវត្ថុ គឺសច្ចៈនីមួយៗ ប្រព្រឹត្តទៅ ។ ពាក្យដ៏សេសក្នុងបទទាំងពួងមានអត្ថងាយយល់ហើយ ។l៚

## អដ្ឋកថាចតុក្កនិទ្ទេស ចប់

# អភិធម្មបិដក

## បញ្ចកនិទ្ទេស

[ ៦៧ ] បណ្ដាញាណទាំងនោះ សម្មាសមាធិប្រកបដោយអង្គ ៥ តើដូចម្ដេច ។ បីតិផរណតា ( ការផ្សាយបីតិ ) ១ សុខផរណតា ( ការផ្សាយសុខ ) ១ ចេតោផរណតា ( ការផ្សាយចិត្ត ) ១ អាលោក-ផរណតា ( ការផ្សាយពន្លឺ ) ១ បច្ចវេក្ខណានិមិត្ត ( ការកំណត់ការពិចា-រណា ) ១ ។ បញ្ញាក្នុងឈាន ២ ឈ្មោះថា បីតិផរណតា បញ្ញាក្នុងឈាន ៣ ឈ្មោះថា សុខផរណតា បញ្ញាផ្សាយទៅក្នុងចិត្តនៃបុគ្គលដទៃ ឈ្មោះថា ចេតោផរណតា ទិព្វចក្ខុ ឈ្មោះថា អាលោកផរណតា បច្ចវេក្ខណាញាណរបស់បុគ្គលដែលចេញចាកសមាធិនោះៗ ឈ្មោះថា បច្ចវេក្ខណានិមិត្ត ។ នេះហៅថា សម្មាសមាធិប្រកបដោយអង្គ ៥ ។

[ ៦៨ ] បណ្ដាញាណទាំងនោះ សម្មាសមាធិ ប្រកបដោយញាណ ៥ តើដូចម្ដេច ។ ញាណកើតឡើងជាក់ច្បាស់ថា សមាធិនេះមានសេចក្ដីសុខក្នុងបច្ចុប្បន្នផង មានសេចក្ដីសុខ ជាវិបាកក្នុងខាងមុខផង ១ ញាណកើតឡើងជាក់ច្បាស់ថា សមាធិនេះប្រសើរមិនមានអាមិស ១ ញាណកើតឡើងជាក់ច្បាស់ថា សមាធិនេះមិនមែនបុរសលាមកសេពឡើយ ១ ញាណកើតឡើងជាក់ច្បាស់ថា សមាធិនេះជាធម៌ស្ងប់ដ៏ឧត្ដម បាននូវសេចក្ដីស្ងប់រម្ងាប់ បាននូវភាពនៃចិត្តដ៏ខ្ពស់ឯក តែមិនដល់នូវការសង្កត់សង្កិន ( ធម៌ជាសត្រូវ ) និងការរារាំង ( កិលេស ) ដោយចិត្តដែលប្រកបដោយសង្ខារ គឺព្យាយាម ១ ញាណកើតឡើងជាក់ច្បាស់ថា អាត្មាអញនោះមានស្មារតី ចូលកាន់

មាធិនេះ មានស្មារតីចេញចាកសមាធិនេះ ១ ។ នេះឈ្មោះថា សម្មាសមាធិ ប្រកបដោយញាណ ៥ ។

ញាណវត្ថុ មានប្រការ ៥ យ៉ាងនេះឯង

# អដ្ឋកថា

## បញ្ចកនិទ្ទេស

[ ៦៧-៦៨ ] គប្បីជ្រាបវិគ្គហៈក្នុងនិទ្ទេសនៃញាណវត្ថុពួក ៥ ដូចតទៅ បណ្ដាបទទាំងឡាយ មានបទថា **បីតិផរណតា** ជាដើម បញ្ញាក្នុងឈានទាំង ២ ឈ្មោះថា **បីតិផរណតា** ព្រោះអត្ថថា ផ្សាយបីតិទៅ កើតឡើង ។ បញ្ញាក្នុងឈាន ៣ ឈ្មោះថា **សុខផរណតា** ព្រោះអត្ថថា ផ្សាយសេចក្ដីសុខទៅ កើតឡើង ។ បញ្ញាកំណត់ចិត្តបុគ្គលដទៃនោះ ឈ្មោះថា **ចេតោផរណតា** ព្រោះអត្ថថា ផ្សាយទៅកាន់បុគ្គលដទៃកើតឡើង ។ បញ្ញាដែលជាទិព្វចក្ខុ ឈ្មោះថា **អាលោកផរណតា** ព្រោះអត្ថថា ផ្សាយពន្លឺ កើតឡើង ។ **បច្ចវេក្ខណាញាណ** ឈ្មោះថា បច្ចវេក្ខណនិមិត្ត ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា **ទ្វីសុ ឈានេសុ បញ្ញា បីតិ-ផរណតា** ជាដើម ។ ក្នុងបទទាំងនោះ ការផ្សាយបីតិទៅ ការផ្សាយសុខទៅ ដូចជាជើងទាំង ២ ការផ្សាយចិត្តទៅ ការផ្សាយអាលោកទៅ ដូចដៃទាំង ២ ឈានដែលជាបាទនៃអភិញ្ញាជាកាយចំណែកកណ្ដាល បច្ចវេក្ខណ-

និមិត្ត ដូចជាក្បាល ហេតុនោះ ទើបព្រះមានព្រះភាគ សំដែងសម្មាសមាធិ មានអង្គ ៥ ឲ្យដូចជាបុរសដែលដល់ព្រមហើយដោយចំណែកប្រកបនៃរាង កាយ ។ បទថា **អយំ បញ្ចង្គិកោ សម្មាសមាធិ** បានដល់ ព្រះមាន ព្រះភាគ ត្រាស់ឈានសមាធិដែលជាបាទថា សមាធិនេះដែលប្រកបហើយ ដោយអង្គ ៥ ដូចគ្នានឹងដៃ ជើង និងក្បាល ឈ្មោះថា សម្មាសមាធិ ដូច្នេះ ។

សមាធិក្នុងអរហត្តផល ព្រះមានព្រះភាគទ្រង់បំណងយកក្នុងបទថា **អយំ សមាធិ បច្ចុប្បន្នសុខោ ចេវ** ជាដើម សមាធិនោះ ឈ្មោះថា មានសុខ ក្នុងបច្ចុប្បន្ន ព្រោះជាសុខ ក្នុងខណៈនៃសមាធិនោះពិតៗ ។ សមាធិដែល កើតមុនៗ ឈ្មោះថា មានសេចក្តីសុខជាវិបាកក្នុងខាងមុខ ព្រោះជាបច្ច័យ ដល់សមាធិសុខដែលកើតក្រោយៗ ។

ផលចិត្តដែលស្ងប់ ដែលល្អិតរមែងញុំាងមធុររូប គឺរូបដែលល្អឲ្យតាំង ឡើង ។ ពិតហើយ កាលព្រះយោគាវចរ ចេញចាកផលសមាបត្តិហើយ កាយវិញ្ញាណ ដែលសហគតៈដោយសេចក្តីសុខ អាស្រ័យផោដ្ឋព្វៈ មាន សម្ផស្សជាសុខ ដែលជ្រួតជ្រាបទៅក្នុងកាយទាំងពួង រមែងកើតឡើង ។ សមាធិ ឈ្មោះថា មានសេចក្តីសុខ ដោយបរិយាយនេះ ។ សមាធិនេះ ឈ្មោះថា **អរិយោ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ។ ឈ្មោះថា **និរា-មិសោ** ព្រោះមិនមានអាមិស គឺកាម អាមិស គឺវដ្តៈ អាមិស គឺលោក ។ ឈ្មោះថា **អកាបុរិសសេវិតោ** ព្រោះមហាបុរសទាំងឡាយ មានព្រះពុទ្ធជា ដើមសេពហើយ ។ ឈ្មោះថា **សន្តោ** ព្រោះស្ងប់ចាកអង្គ ព្រោះស្ងប់ចាក

អារម្មណ៍ និងព្រោះស្ងប់ហើយចាកសេចក្ដីក្រវល់ក្រវាយ គឺកិលេសទាំងពួង ។ ឈ្មោះថា **បណីតោ** ព្រោះអត្ថថា មិនក្ដៅក្រហាយ ។ ឈ្មោះថា **បដិប្បស្សទ្ធិលទ្ធោ** ព្រោះបាននូវសេចក្ដីស្ងប់រម្ងាប់កិលេស ឬព្រោះបានភាវៈ គឺសេចក្ដីស្ងប់រម្ងាប់ចាកកិលេស ។ ពិតហើយ បទថា **បដិប្បស្សទ្ធំ** និង **បដិប្បស្សទ្ធិ** ដោយអត្ថដូចគ្នានោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា **បដិប្ប-ស្សទ្ធិលទ្ធោ** ព្រោះសមាធិនេះ ដែលព្រះអរហន្តអ្នកមានកិលេសស្ងប់រម្ងាប់បានហើយ ។ ឈ្មោះថា **ឯកោទិភាវាធិគតោ** ព្រោះខ្លួនសម្រេចហើយដោយភាពជាធម៌ពិតប្រាកដ ឬព្រោះសម្រេចហើយនូវភាពជាសមាធិ ។ ឈ្មោះថា **ន សសង្ខារនិគ្គយ្ហវារិតគតោ** ព្រោះសមាធិនោះសង្កត់សង្កិនបច្ចនិកធម៌ គឺធម៌ដែលជាសត្រូវ ហើយហាមកិលេសទាំងឡាយ ទើបសម្រេចដោយចិត្តដោយប្រកបព្រម ប្រព្រឹត្តទៅជាមួយនឹងសង្ខារ ក៏មិនមែនដូចសមាធិដែលប្រព្រឹត្តទៅដោយអាសវៈ ដែលមិនទាន់ស្ងាត់ជំនាញ ។ ព្រះយោគាវចរកាលចូលសមាធិនោះ ឬចេញចាកសមាធិនោះ រមែងជាអ្នកមានសតិចូលសមាធិ និងមានសតិចេញចាកសមាធិ ព្រោះដល់នូវភាពបរិបូណ៌នៃសតិ ។ ម្យ៉ាងទៀត មានសតិចូលសមាធិ មានសតិចេញចាកសមាធិដោយអំណាចនៃកាលតាមដែលបានកំណត់ ព្រោះហេតុនោះ ក្នុងសេចក្ដីនេះ ញាណណាកើតឡើងចំពោះខ្លួនប៉ុណ្ណោះ មិនមានវត្ថុដទៃជាបច្ច័យ រមែងកើតដល់បុគ្គលជាអ្នកពិចារណា យ៉ាងនេះថា សមាធិនេះ មានសេចក្ដីសុខក្នុងបច្ចុប្បន្នផង មានសេចក្ដីសុខ ជាវិបាកក្នុងខាងមុខផង ដូច្នេះ ញាណនេះ

ជាអង្គ ១ ក្នុងបណ្តាអង្គ ៥ ។ ក្នុងអង្គដ៏សេស ក៏មានន័យនេះដូចគ្នា ។ សមាធិនេះ ដែលព្រះមានព្រះភាគ ហៅឈ្មោះថា សម្មាសមាធិមានញាណ ៥ ដោយបច្ចវេក្ខណញ្ញាណទាំង ៥ នេះ ដោយប្រការដូច្នេះ ។ល។

## អដ្ឋកថាបញ្ហាកនិទ្ទេស ចប់

# អភិធម្មបិដក

## ជក្កណិទ្ទេស

[ ៦៩ ] បណ្តាញាណទាំងនោះ បញ្ញាក្នុងអភិញ្ញា ៦ តើដូចម្តេច ។ សេចក្តីដឹង ក្នុងចំណែកនៃឫទ្ធិ ១ សេចក្តីដឹង ក្នុងសោតធាតុដ៏បរិសុទ្ធ ១ សេចក្តីដឹងក្នុងការកំណត់ចិត្តរបស់សត្វដទៃ ១ សេចក្តីដឹងប្រកបដោយការរឭកឃើញនូវខន្ធរបស់សត្វដទៃ ដែលនៅអាស្រ័យក្នុងកាលមុន ១ សេចក្តីដឹងក្នុងការច្យុត និងការកើតរបស់សត្វទាំងឡាយ ១ សេចក្តីដឹងក្នុងការអស់អាសវៈទាំងឡាយ ១ នេះឈ្មោះថា បញ្ញាក្នុងអភិញ្ញា ៦ ។

ញាណវត្ថុ មានប្រការ ៦ យ៉ាងនេះឯង

# អដ្ឋកថា

## ឆក្កនិទ្ទេស

[ ៦៩ ] ក្នុងនិទ្ទេសនៃញាណវត្ថុពួក ៦ ក្នុងការសម្តែងឫទ្ធិដែលសម្តែងឫទ្ធិដែលប្រព្រឹត្តទៅដោយន័យ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា គឺជាមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ដូច្នេះជាដើម ឈ្មោះថា **ឥទ្ធិវិធេ ញាណំ** បញ្ញាក្នុងអប្បនាដែលមិនមានវិតក្ក មិនមានវិចារដែលសហគតៈដោយឧបេក្ខា ដែលរូបាវចរ ឲ្យសម្រេចភាពជាបុគ្គលច្រើនជាដើម ដែលមានក្នុងខណៈនៃចិត្ត ១ ដួងនោះឯង ព្រះមានព្រះភាគត្រាស់ដោយពាក្យថា **ឥទ្ធិវិធេ ញាណំ** នេះ ។

ក្នុងទិព្វសោតធាតុ ដែលមានសំឡេង បែកជាសំឡេងឆ្ងាយ និងសំឡេងជិតជាដើម ជាអារម្មណ៍ ឈ្មោះថា **សោតធាតុវិសុទ្ធិយា ញាណំ** ។ បញ្ញាក្នុងអប្បនា ដែលមិនមានវិតក្ក និងវិចារ ដែលសហគតៈដោយឧបេក្ខា ដែលជារូបាវចរដែលមានសំឡេងកន្ទងវិស័យ នៃសោតធាតុធម្មតាជាអារម្មណ៍ ដែលមានក្នុងខណៈនៃចិត្ត ១ ដួងនោះ ព្រះមានព្រះភាគ ត្រាស់ដោយពាក្យថា **សោតធាតុវិសុទ្ធិយា ញាណំ** នេះ ។ បទថា ញាណក្នុងការកំណត់ចិត្តរបស់សត្វដទៃ ឈ្មោះថា **បរចិត្តេ ញាណំ** ។ បញ្ញាក្នុងអប្បនាមានប្រការតាមដែលពោលហើយ មានចិត្តប្រកបដោយរាគៈជាដើម របស់សត្វដទៃជាអារម្មណ៍ដែលមានក្នុងខណៈចិត្ត ១ ដួងនោះឯង ព្រះមានព្រះភាគត្រាស់ដោយពាក្យថា **បរចិត្តេ ញាណំ** នេះ ។

*ញាណដែលសម្បយុត្តដោយការតាមរឭកដល់ខន្ធ ដែលធ្លាប់អាស្រ័យក្នុងកាលមុន ឈ្មោះថា* **បុព្វេនិវាសានុស្សតិញ្ញាណំ** ។ *បញ្ញាក្នុងអប្បនាមានប្រការតាមដែលពោលហើយ ដែលសម្បយុត្តដោយសតិជាគ្រឿងតាមរឭកដល់ខន្ធដែលធ្លាប់អាស្រ័យហើយក្នុងកាលមុន ដែលមានក្នុងខណៈនៃចិត្ត ១ ដូងនោះឯង ព្រះមានព្រះភាគ ត្រាស់ដោយពាក្យថា* **បុព្វេ-និវាសានុស្សតិញ្ញាណំ** *នេះ ។*

*ញាណក្នុងការដឹងចុតិ និងក្នុងបដិសន្ធិ របស់សត្វទាំងឡាយ ឈ្មោះថា* **សត្តានំ ចុតូបបាតេ ញាណំ** *បញ្ញាក្នុងអប្បនាមានប្រការតាមដែលពោលហើយ ដែលមានវណ្ណធាតុរបស់សត្វទាំងឡាយ ដែលចុតិ និងបដិសន្ធិជាអារម្មណ៍ ដែលមានក្នុងខណៈនៃចិត្ត ១ ដូងនោះឯង ព្រះមានព្រះភាគត្រាស់ដោយពាក្យថា* **សត្តានំ ចុតូបបាតេ ញាណំ** *នេះ ។*

*ញាណជាគ្រឿងកំណត់ដឹងសច្ចៈ ឈ្មោះថា* **អាសវានំ ខយេ ញាណំ** *ញាណនេះ ជាលោកុត្តរប៉ុណ្ណោះ ញាណ ៥ ដ៏សេស ជាលោកិយ ។៙*

**អដ្ឋកថាជក្កនិទ្ទេស ចប់**

# អភិធម្មបិដក

## សត្តកនិទ្ទេស

[ ៧០ ] បណ្តាញាណទាំងនោះ ញាណវត្ថុ ៧៧ តើដូចម្តេច ។ សេចក្តីដឹងថា ជរាមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរាមរណៈក៏មិនមាន ១ សេចក្តីដឹងថា ជរាមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យក្នុងកាលអតីត ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរាមរណៈក៏មិនមាន ១ សេចក្តីដឹងថា ជរាមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យក្នុងកាលអនាគត ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរាមរណៈក៏មិនមាន ១ សេចក្តីដឹងថា ធម្មដ្ឋិតិញ្ញាណណារបស់បុគ្គលនោះ ធម្មដ្ឋិតិញ្ញាណនោះមានសភាពអស់ទៅ មានសភាពសូន្យទៅ មានសភាពប្រាសចាកតម្រេក មានសភាពរលត់ ១ ។ សេចក្តីដឹងថា ជាតិ ( កើតមាន ) ព្រោះភពជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា ភព ( កើតមាន ) ព្រោះឧបាទានជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា ឧបាទាន ( កើតមាន ) ព្រោះតណ្ហាជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា តណ្ហា ( កើតមាន ) ព្រោះវេទនាជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា វេទនា ( កើតមាន ) ព្រោះផស្សៈ ជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា ផស្សៈ ( កើតមាន ) ព្រោះសឡាយតនៈជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា សឡាយតនៈ ( កើតមាន ) ព្រោះនាមរូបជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា នាមរូប ( កើតមាន ) ព្រោះវិញ្ញាណជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា សង្ខារ ( កើតមាន )

ព្រោះអវិជ្ជាជាបច្ច័យ ១ សេចក្ដីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ១ សេចក្ដីដឹងថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជា ជាបច្ច័យក្នុងកាលអតីត ១ សេចក្ដីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ១ សេចក្ដីដឹងថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យក្នុងកាលអនាគត ១ សេចក្ដីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ១ សេចក្ដីដឹងថា ធម្មដ្ឋិតិញ្ញាណណារបស់បុគ្គលនោះ ធម្មដ្ឋិតិញ្ញាណនោះមានសភាពអស់ទៅ មានសភាពសូន្យទៅ មានសភាពប្រាសចាកតម្រេក មានសភាពរលត់ ១ ។ នេះឈ្មោះថា ញាណវត្ថុ ៧៧ ។

ញាណវត្ថុ មានប្រការ ៧ យ៉ាងនេះឯង

# អដ្ឋកថា

## សត្តកនិទ្ទេស

[ ៧០ ] ក្នុងនិទ្ទេសនៃញាណវត្ថុ ពួក ៧ ព្រះមានព្រះភាគ ត្រាស់នូវបច្ចវេក្ខណញ្ញាណ ដោយការផ្សេងគ្នានៃកាល ៣ ក្នុងអង្គនៃបដិច្ចសមុប្បាទ ១១ តែអង្គ ១ ដោយអំណាចនៃការប្រព្រឹត្តទៅ និងការមិនប្រព្រឹត្តទៅ ដោយន័យថា **ជាតិប្បច្ចយា ជរាមរណំ** ជាដើម ហើយក៏ត្រាស់ញាណនោះទៀតដោយសង្ខេប ដោយប្រការទាំងឡាយ មានការអស់ទៅជាធម្មតាជាដើមយ៉ាងនេះថា **យម្បិស្ស តំ ធម្មដ្ឋិតិញ្ញាណំ** ដូច្នេះ ។

បណ្ដាញាណទាំងនោះ ញាណ ២ គឺ **ជាតិប្បច្ចយា ជរាមរណំ** និង **អសតិ ជាតិយា នត្ថិ ជរាមរណំ** ត្រាស់ដោយអំណាចនៃបច្ចុប្បន្នកាលដែលវែងឆ្ងាយ ។ ញាណ ២ ក្នុងអតីត ញាណ ២ ក្នុងអនាគតយ៉ាងនេះគឺ **អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ** ព្រោះហេតុនោះ ញាណទាំង ៦ នេះ មួយអន្លើដោយធម្មដ្ឋិតិញ្ញាណ ទើបជាញាណ ៧ ។ បណ្ដាបទទាំងនោះ បទថា **ធម្មដ្ឋិតិញ្ញាណំ** បានដល់ ញាណក្នុងបច្ចយាការ ។ ពិតហើយ បច្ចយាការ ព្រះមានព្រះភាគហៅថា **ធម្មដ្ឋិតិ** ព្រោះធម៌ទាំងឡាយជាហេតុទាំងនោះ ជាហេតុនៃការប្រព្រឹត្តទៅ និងតាំងនៅ ។ ញាណក្នុងធម្មដ្ឋិតិនោះ ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ។ ពាក្យថា ធម្មដ្ឋិតិញ្ញាណនោះ ជាឈ្មោះរបស់ញាណ ៦ យ៉ាងនោះឯង ។ ព្រោះក្នុងអង្គនីមួយៗ មានញាណ ៧ ញាណ ៧ ក្នុងអង្គនីមួយៗ ( អង្គបច្ចយាការ ១១ ) ទើបជាញាណ

៧៧ ។

បណ្ដាបទទាំងនោះ បទថា **ខយធម្មំ** បានដល់ សភាវៈដែលដល់នូវការអស់ទៅ ។ បទថា **វយធម្មំ** បានដល់ សភាវៈដែលដល់នូវការវិនាសទៅ ។ បទថា **វិរាគធម្មំ** បានដល់ សភាវៈដែលដល់នូវការសូន្យទៅ ។ បទថា **វិរាគធម្មំ** បានដល់ មានភាវៈដែលមិនគួរត្រេកអរ ។ បទថា **និរោធធម្មំ** បានដល់ មានសភាវៈដែលអស់ទៅ ។

សួរថា មានប្រយោជន៍អ្វី ដែលព្រះមានព្រះភាគត្រាស់ដោយញាណនេះ ឆ្លើយថា ព្រះមានព្រះភាគ ត្រាស់ការពិចារណាវិបស្សនាដែលកើត ដើម្បីវិបស្សនាដទៃទៀត ។

សួរថា ព្រះមានព្រះភាគត្រាស់អធិប្បាយដូចម្ដេច ដោយពាក្យនោះ ឆ្លើយថា ត្រាស់វិបស្សនា និងបដិវិបស្សនា ៧ ជង ។

ពិតហើយ ការឃើញសង្ខារទាំងពួងថាមិនទៀង ជាទុក្ខ ជាអនត្តាដោយញាណទី ១ ។ ឃើញញាណទី ១ នោះដោយញាណទី ២ រមែងគួរឃើញញាណទី ២ ដោយញាណទី ៣ ឃើញញាណទី ៣ ដោយញាណទី ៤ ឃើញញាណទី ៤ ដោយញាណទី ៥ ឃើញញាណទី ៥ ដោយញាណទី ៦ ឃើញញាណទី ៦ ដោយញាណទី ៧ ឃើញញាណទី ៧ រមែងគួរ ។ ទើបព្រះមានព្រះភាគត្រាស់វិបស្សនា និងបដិវិបស្សនាទុក ៧ ជង ដោយប្រការដូច្នេះឯង ។៚

**អដ្ឋកថាសត្តកនិទ្ទេស ចប់**

# អភិធម្មបិដក

## អដ្ឋកនិទ្ទេស

[ ៧១ ] បណ្ដាញាណទាំងនោះ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ តើដូចម្ដេច ។ បញ្ញាក្នុងសោតាបត្តិមគ្គ ១ បញ្ញាក្នុងសោតាបត្តិផល ១ បញ្ញាក្នុងសកទាគាមិមគ្គ ១ បញ្ញាក្នុងសកទាគាមិផល ១ បញ្ញាក្នុងអនាគាមិមគ្គ ១ បញ្ញាក្នុងអនាគាមិផល ១ បញ្ញាក្នុងអរហត្តមគ្គ ១ បញ្ញាក្នុងអរហត្តផល ១ នេះបញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ។

ញាណវត្ថុ មានប្រការ ៨ យ៉ាងនេះឯង

# អដ្ឋកថា

## អដ្ឋកនិទ្ទេស

[ ៧១ ] ក្នុងនិទ្ទេសនៃញាណវត្ថុពួក ៨ បទថា **សោតាបត្តិមគ្គេ បញ្ញា** បានដល់ បញ្ញាក្នុងសោតាបត្តិមគ្គ ។ ព្រះមានព្រះភាគ ត្រាស់បញ្ញាដែលសម្បយុត្តដោយសោតាបត្តិមគ្គនេះឯង ។ ក្នុងពាក្យដ៏សេស ក៏មានន័យនេះឯង ៗ។

**អដ្ឋកថាអដ្ឋកនិទ្ទេស ៨ ចប់**

# អភិធម្មបិដក

## ឆវកនិទ្ទេស

[ ៧២ ] បណ្តាញាណទាំងនោះ បញ្ញាក្នុងអនុបុព្វវិហារសមាបត្តិ ៩ តើដូចម្តេច ។ បញ្ញាក្នុងបឋមជ្ឈានសមាបត្តិ ១ បញ្ញាក្នុងទុតិយជ្ឈានសមាបត្តិ ១ បញ្ញាក្នុងតតិយជ្ឈានសមាបត្តិ ១ បញ្ញាក្នុងចតុត្ថជ្ឈានសមាបត្តិ ១ បញ្ញាក្នុងអាកាសានញ្ចាយតនសមាបត្តិ ១ បញ្ញាក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ១ បញ្ញាក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ១ បញ្ញាក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ ១ បច្ចវេក្ខណញាណរបស់បុគ្គល ដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិ ១ នេះបញ្ញាក្នុងអនុបុព្វវិហារសមាបត្តិ ៩ ។

ញាណវត្ថុ មានប្រការ ៩ យ៉ាងនេះឯង

# អដ្ឋកថា

## នវកនិទ្ទេស

[ ៧២ ] និទ្ទេសនៃញាណវត្ថុក ៩ បទថា **អនុបុព្វវិហារ សមាបត្តីសុ** បានដល់ ក្នុងសមាបត្តិទាំងឡាយ ពោល គឺធម៌ជាគ្រឿងនៅដោយលំដាប់ ៗ គប្បីជ្រាបថា ភាពដែលមានសមាបត្តិទាំងនោះ ជាអនុបុព្វវិហារ ព្រោះអត្ថថា ដែលព្រះយោគាវចរគប្បីចូលដោយលំដាប់ គឺតាមលំដាប់ និងគប្បីជ្រាបភាពដែលមានសមាបត្តិទាំងនោះ ជាសមាបត្តិ ព្រោះអត្ថថា ជាធម៌ដែលព្រះយោគាវចរគប្បីចូល ៗ

ក្នុងបញ្ហាទាំងនោះ គប្បីជ្រាបសម្បយុត្តប្បញ្ញា ៨ យ៉ាង មានពាក្យថា **បឋមជ្ឈានសមាបត្តិយា បញ្ញា** ជាដើម ។ បញ្ញាក្នុងបច្ចវេក្ខណៈ ជាបញ្ញាប្រការទី ៩ ។ ពិតហើយ បញ្ញាក្នុងបច្ចវេក្ខណៈនោះ រមែងប្រព្រឹត្តទៅដល់ព្រះយោគាវចរ ដែលពិចារណានិរោធសមាបត្តិ ដោយភាពជាធម៌ល្អិត ប្រណីត ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បច្ចវេក្ខណញាណរបស់បុគ្គល ដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិ ដូច្នេះ ។ល។

**អដ្ឋកថានវកនិទ្ទេស ចប់**

# អភិធម្មបិដក

## ធសកណិទ្ទេស

[ ៧៣ ] បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិតនូវហេតុ ថាជាហេតុផង នូវអំពើមិនមែនហេតុ ថាជាអំពើមិនមែនហេតុផង តើដូចម្ដេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ( សម្មាទិដ្ឋិ ) ហើយប្រកាន់នូវសង្ខារណាមួយ ថាទៀង ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនោះមានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន តែងប្រកាន់នូវសង្ខារណាមួយ ថាទៀង ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ហើយប្រកាន់នូវសង្ខារណាមួយ ថាជាសុខ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន តែងប្រកាន់នូវសង្ខារណាមួយ ថាជាសុខ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ហើយប្រកាន់នូវធម៌ណាមួយ ថាជាខ្លួន ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន តែងប្រកាន់នូវធម៌ណាមួយ ថាជាខ្លួន ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ហើយផ្ដាច់បង់នូវមាតាចាកជីវិត ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មាន

ប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន រមែងផ្តាច់បង់នូវមាតាចាកជីវិត ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ហើយផ្តាច់បង់នូវបិតាចាកជីវិត ។បេ។ ផ្តាច់បង់នូវព្រះអរហន្តចាកជីវិត ។បេ។ ញ៉ាំងព្រះលោហិតរបស់ព្រះតថាគតឲ្យកើតឡើងដោយចិត្តប្រទូស្ត ។បេ។ បំបែកសង្ឃ ។បេ។ ឧទ្ទិសនូវគ្រូដទៃ ។បេ។ ធ្វើភពទី ៨ ឲ្យកើតឡើង ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន តែងញ៉ាំងភពទី ៨ ឲ្យកើត ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គ កើតឡើងក្នុងលោកធាតុ ១ មិនមុន មិនក្រោយ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះ មានប្រាកដ ត្រង់ដែលព្រះអរហន្តសម្មាសម្ពុទ្ធ ១ ព្រះអង្គកើតឡើងក្នុងលោកធាតុ ១ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលស្តេចចក្កពត្តិ ២ ព្រះអង្គ កើតឡើងក្នុងលោកធាតុ ១ មិនមុន មិនក្រោយ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះ មានប្រាកដ ត្រង់ដែលស្តេចចក្កពត្តិ ១ ព្រះអង្គ កើតឡើងក្នុងលោកធាតុ ១ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលស្ត្រីបានជាព្រះអរហន្តសម្មាសម្ពុទ្ធ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មានប្រាកដ ត្រង់ដែលបុរស

បានជាព្រះអរហន្តសម្មាសម្ពុទ្ធ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលស្ត្រីបានជាស្តេចចក្កពត្តិ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មានប្រាកដ ត្រង់ដែលបុរសបានជាស្តេចចក្កពត្តិ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលស្ត្រី បានអត្តភាពជាព្រះឥន្ទ្រ បានអត្តភាពជាមារ បានអត្តភាពជាព្រហ្ម ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មានប្រាកដ ត្រង់ដែលបុរសបានអត្តភាពជាព្រះឥន្ទ្រ បានអត្តភាពជាមារ បានអត្តភាពជាព្រហ្ម ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលវិបាករបស់កាយទុច្ចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មានប្រាកដ ត្រង់ដែលវិបាករបស់កាយទុច្ចរិត មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលវិបាករបស់វចីទុច្ចរិត និងមនោទុច្ចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបថា ហេតុនេះ មានប្រាកដ ត្រង់ដែលវិបាករបស់វចីទុច្ចរិត និងមនោទុច្ចរិត មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែន

ជាបច្ច័យទេ ត្រង់ដែលវិបាករបស់កាយសុចរិត មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលវិបាករបស់កាយសុចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលវិបាករបស់វចីសុចរិត និងមនោសុចរិត មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះ មានប្រាកដ ត្រង់ដែលវិបាករបស់វចីសុចរិត និងមនោសុចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលប្រកបដោយកាយទុច្ចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតក្នុងលោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រោះមានកាយទុច្ចរិតនោះជាហេតុ ព្រោះមានកាយទុច្ចរិតនោះជាបច្ច័យ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះ មានប្រាកដ ត្រង់ដែលបុគ្គលប្រកបដោយកាយទុច្ចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមានកាយទុច្ចរិតនោះជាហេតុ ព្រោះមានកាយទុច្ចរិតនោះជាបច្ច័យ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត លុះបែកធ្លាយ

រាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងលោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រោះមានវចីទុច្ចរិត និងមនោទុច្ចរិតនោះជាហេតុ ព្រោះមានវចីទុច្ចរិត និងមនោទុច្ចរិតនោះ ជាបច្ច័យ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះ មានប្រាកដ ត្រង់ដែលបុគ្គលប្រកបដោយវចី-ទុច្ចរិត ប្រកបដោយមនោទុច្ចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមានវចីទុច្ចរិត និងមនោទុច្ចរិតនោះ ជាហេតុ ព្រោះមានវចីទុច្ចរិត និងមនោទុច្ចរិតនោះ ជាបច្ច័យ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលប្រកបដោយកាយសុចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមានកាយសុចរិតនោះជាហេតុ ព្រោះមានកាយសុចរិតនោះជាបច្ច័យ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះ មានប្រាកដ ត្រង់ដែលបុគ្គលប្រកបដោយកាយសុចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងលោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រោះមានកាយសុចរិតនោះជាហេតុ ព្រោះមានកាយសុចរិតនោះជាបច្ច័យ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមានវចីសុចរិត និងមនោសុចរិត

នោះជាហេតុ ព្រោះមានវចីសុចរិត និងមនោសុចរិតនោះជាបច្ច័យ ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះ មានប្រាកដ ត្រង់ដែលបុគ្គលប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងលោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រោះមានវចីសុចរិត និងមនោសុចរិតនោះជាហេតុ ព្រោះមានវចីសុចរិត និងមនោសុចរិតនោះជាបច្ច័យ ការណ៍នុ៎ះ ទើបមាន ។ ពួកធម៌ណាៗ ជាហេតុ ជាបច្ច័យ ដើម្បីកើតឡើងនៃពួកធម៌ណាៗ ពួកធម៌នោះៗ ឈ្មោះថា ជាហេតុ ពួកធម៌ណាៗ មិនមែនហេតុ មិនមែនបច្ច័យ ដើម្បីកើតឡើងនៃពួកធម៌ណាៗទេ ពួកធម៌នោះៗ ឈ្មោះថា មិនមែនហេតុ ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគតមានការជ្រាបច្បាស់តាមពិតនូវហេតុ ថាជាហេតុផង នូវអំពើមិនមែនហេតុ ថាជាអំពើមិនមែនហេតុផង ។

[ ៧៤ ] បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិតនូវវិបាក របស់កម្មសមាទាន ( ការកាន់យកនូវកម្មជាកុសល និងអកុសល ) ជាអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ តើដូចម្ដេច ។ ព្រះតថាគត ក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា កម្មសមាទានដ៏លាមកពួកខ្លះ មានគតិសម្បត្តិ រារាំងមិនឲ្យផលក៏មាន កម្មសមាទានដ៏លាមកពួកខ្លះ មានឧបធិសម្បត្តិ រារាំងមិនឲ្យផលក៏មាន កម្មសមាទានដ៏លាមកពួកខ្លះ មានកាលសម្បត្តិ រារាំងមិនឲ្យផលក៏មាន កម្មសមាទានដ៏លាមក

ពួកខ្លះ មានបយោគសម្បត្តិ រារាំងមិនឲ្យផលក៏មាន កម្មសមាទានដ៏លាមក ពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវគតិវិបត្តិក៏មាន កម្មសមាទានដ៏លាមក ពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវឧបធិវិបត្តិក៏មាន កម្មសមាទានដ៏លាមក ពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវកាលវិបត្តិក៏មាន កម្មសមាទានដ៏លាមក ពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវបយោគវិបត្តិក៏មាន កម្មសមាទានដ៏ល្អ ពួកខ្លះ មានគតិវិបត្តិ រារាំងមិនឲ្យផលក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ មាន ឧបធិវិបត្តិ រារាំងមិនឲ្យផលក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ មានកាលវិបត្តិ រារាំងមិនឲ្យផលក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ មានបយោគវិបត្តិ រារាំង មិនឲ្យផលក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវ គតិសម្បត្តិក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវ ឧបធិសម្បត្តិក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវ កាលសម្បត្តិក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវ បយោគសម្បត្តិក៏មាន ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការ ពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិតនូវវិបាក របស់កម្មសមាទាន ជា អតីត អនាគត និងបច្ចុប្បន្នតាមបច្ច័យ តាមហេតុ ។

[ ៧៥ ] បណ្តាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់តាម ពិតនូវបដិបទា ជាដំណើរទៅក្នុងទីទាំងពួង តើដូចម្តេច ។ ព្រះតថាគតក្នុង លោកនេះ ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្តីប្រតិបត្តិជាដំណើរទៅ

កាន់នរក ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់តិរច្ឆាន ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ប្រេតវិស័យ ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់មនុស្សលោក ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទេវលោក ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ព្រះនិព្វាន ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណានូវធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិតនូវបដិបទា ជាដំណើរទៅក្នុងទីទាំងពួង ។

[ ៧៦ ] បណ្តាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់តាមពិតនូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗ គ្នា តើដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់នូវសេចក្តីផ្សេងគ្នានៃខន្ធ ទ្រង់ជ្រាបច្បាស់នូវសេចក្តីផ្សេងគ្នានៃអាយតនៈ ទ្រង់ជ្រាបច្បាស់នូវសេចក្តីផ្សេងគ្នានៃធាតុ ឈ្មោះថា ជ្រាបច្បាស់នូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗ ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគតមានការជ្រាបច្បាស់តាមពិត នូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗ គ្នា ។

[ ៧៧ ] បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវអធ្យាស្រ័យផ្សេងៗ គ្នានៃពួកសត្វ តើដូចម្តេច ។ ព្រះតថាគត ក្នុង

លោកនេះ ទ្រង់ជ្រាបច្បាស់ថា ពួកសត្វមានអធ្យាស្រ័យថោកទាបក៏មាន ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់ក៏មាន ក្នុងបច្ចុប្បន្នកាល ពួកសត្វមានអធ្យាស្រ័យថោកទាបតែងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វដែលមានអធ្យាស្រ័យថោកទាបដូចគ្នា ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់ តែងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា សូម្បីក្នុងអតីតកាល ពួកសត្វមានអធ្យាស្រ័យថោកទាប បានសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាបដូចគ្នា ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ បានសេពគប់ គប់រក ចូលទៅអង្គុយជិតហើយនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា សូម្បីក្នុងអនាគតកាល ពួកសត្វដែលមានអធ្យាស្រ័យថោកទាប នឹងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាបដូចគ្នា ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ នឹងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគតមានការជ្រាបច្បាស់តាមពិតនូវអធ្យាស្រ័យផ្សេងៗ គ្នានៃពួកសត្វ ។

[ ៧៨ ] បណ្តាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់តាមពិតនូវឥន្ទ្រិយចាស់ក្លា និងទន់ របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ តើដូចម្តេច ។ ព្រះតថាគត ក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់នូវអាសយៈ ( ធម៌

ជាទីនៅអាស្រ័យរបស់ពួកសត្វ ) ទ្រង់ជ្រាបច្បាស់នូវអនុសយៈ ( កិលេសដែលដេកត្រាំនៅក្នុងសន្តានរបស់ពួកសត្វ ) ទ្រង់ជ្រាបច្បាស់នូវចរិតរបស់ពួកសត្វ ទ្រង់ជ្រាបច្បាស់នូវអធ្យាស្រ័យរបស់ពួកសត្វ ទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ដែលឲ្យត្រាស់ដឹងងាយ ដែលឲ្យត្រាស់ដឹងក្រ មានភព្វ និងឥតភព្វ ។ ចុះអាសយៈ ( ធម៌ជាទីនៅអាស្រ័យ ) របស់ពួកសត្វ តើដូចម្តេច ។ សត្វទាំងឡាយអាស្រ័យនូវភវទិដ្ឋិ ( សេចក្តីយល់ថា មាន ) ក្តី អាស្រ័យនូវវិភវទិដ្ឋិ ( សេចក្តីយល់ថា មិនមាន ) ក្តី ដូច្នេះថា លោកទៀងខ្លះ ថាលោកមិនទៀងខ្លះ ថាលោកមានទីបំផុតខ្លះ ថាលោកមិនមានទីបំផុតខ្លះ ថាជីវិតនោះ ក៏គឺសរីរៈនោះខ្លះ ថាជីវិតដទៃ សរីរៈក៏ដទៃខ្លះ ថាសត្វស្លាប់ហើយកើតទៀតខ្លះ ថាសត្វស្លាប់ហើយមិនកើតទៀតខ្លះ ថាសត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានខ្លះ ថាសត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ ឬក៏សេចក្តីពេញចិត្ត ដែលអនុលោមទៅក្នុងធម៌ទាំងឡាយ ដែលកើតឡើងព្រោះអាស្រ័យនូវធម៌នេះជាបច្ច័យក្តី សេចក្តីដឹងតាមពិតក្តី ជាការណ៍ដែលសត្វទាំងឡាយបានចំពោះហើយ ព្រោះមិនពឹងផ្អែកនូវអន្តធម៌ទាំងពីរ គឺភវទិដ្ឋិ និងវិភវទិដ្ឋិនុ៎ះទេ នេះឈ្មោះថា អាសយៈរបស់ពួកសត្វ ។ ចុះអនុសយៈរបស់ពួកសត្វ តើដូចម្តេច ។ អនុសយៈ ៧ គឺកាមរាគានុសយៈ ១ បដិឃានុសយៈ ១ មានានុសយៈ ១ ទិដ្ឋានុសយៈ ១ វិចិកិច្ឆានុសយៈ ១

ភវរាគានុសយៈ ១ អវិជ្ជានុសយៈ ១ ។ ឥដ្ឋារម្មណ៍ណាក្នុងលោក មាន សភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ រាគានុសយៈរបស់ពួកសត្វ រមែងដេកត្រាំក្នុងឥដ្ឋារម្មណ៍នោះ អនិដ្ឋារម្មណ៍ណាក្នុងលោក មានសភាព មិនគួរស្រឡាញ់ មានសភាពមិនគួរត្រេកអរ បដិឃានុសយៈរបស់ពួកសត្វ រមែងដេកត្រាំក្នុងអនិដ្ឋារម្មណ៍នោះ ព្រោះហេតុនោះ អវិជ្ជា រមែងធ្លាក់ចុះ តាមក្នុងធម៌ទាំង ២ នេះ មានះក្តី ទិដ្ឋិក្តី វិចិកិច្ឆាក្តី បុគ្គលគប្បីឃើញថា តាំងនៅក្នុងទីជាមួយគ្នានឹងអវិជ្ជានោះ នេះឈ្មោះថា អនុសយៈ របស់ពួក សត្វ ។ ចុះចរិតរបស់ពួកសត្វ តើដូចម្តេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិ-សង្ខារ និងអនេញ្ជាភិសង្ខារ មានជាន់តូចតាចក្តី មានជាន់ធំដុំក្តី នេះឈ្មោះ ថា ចរិតរបស់ពួកសត្វ ។ ចុះអធ្យាស្រ័យរបស់ពួកសត្វ តើដូចម្តេច ។ ពួកសត្វមានអធ្យាស្រ័យថោកទាបក៏មាន ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់ ក៏មាន ក្នុងបច្ចុប្បន្នកាល ពួកសត្វមានអធ្យាស្រ័យថោកទាប រមែងសេព គប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប ដូចគ្នា ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់ រមែងសេពគប់ គប់រក ចូលទៅ អង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា សូម្បីក្នុងអតីត-កាល ពួកសត្វមានអធ្យាស្រ័យថោកទាប បានសេពគប់ គប់រក ចូលទៅ អង្គុយជិតហើយនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាបដូចគ្នា ពួកសត្វ មានអធ្យាស្រ័យខ្ពង់ខ្ពស់ បានសេពគប់ គប់រក ចូលទៅអង្គុយជិតហើយ នឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា សូម្បីក្នុងអនាគតកាល ពួក

សត្វមានអធ្យាស្រ័យថោកទាបនឹងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វដែលមានអធ្យាស្រ័យថោកទាបដូចគ្នា ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់នឹងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា នេះឈ្មោះថា អធ្យាស្រ័យរបស់ពួកសត្វ ។ ចុះពួកសត្វមានធូលីច្រើនក្នុងភ្នែកនោះ តើដូចម្តេច ។ កិលេសវត្ថុ ១០ គឺលោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ កិលេសវត្ថុទាំង ១០ នេះ ពួកសត្វណាបានសេពគប់ បានអប់រំ បានធ្វើឲ្យច្រើន បានធ្វើឲ្យជុះដាលហើយ ពួកសត្វនោះ ឈ្មោះថា មានធូលីច្រើនក្នុងភ្នែក ។ ពួកសត្វមានធូលីតិចក្នុងភ្នែកនោះ តើដូចម្តេច ។ កិលេសវត្ថុ ១០ នេះ ពួកសត្វណាមិនបានសេពគប់ មិនបានអប់រំ មិនបានធ្វើឲ្យច្រើន មិនបានធ្វើឲ្យជុះដាលហើយ ពួកសត្វនោះឯង ឈ្មោះថា មានធូលីតិចក្នុងភ្នែក ។ ពួកសត្វមានឥន្ទ្រិយទន់នោះ តើដូចម្តេច ។ ឥន្ទ្រិយ ៥ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ឥន្ទ្រិយទាំង ៥ នេះ ពួកសត្វណាមិនបានសេពគប់ មិនបានអប់រំ មិនបានធ្វើឲ្យច្រើន មិនបានធ្វើឲ្យជុះដាលហើយ ពួកសត្វនោះឯង ឈ្មោះថា មានឥន្ទ្រិយទន់ ។ ពួកសត្វមានឥន្ទ្រិយចាស់ក្លានោះ តើដូចម្តេច ។ ឥន្ទ្រិយទាំង ៥ នេះ ពួកសត្វណាបានសេពគប់ បានអប់រំ បានធ្វើឲ្យច្រើន បានធ្វើឲ្យជុះដាលហើយ ពួកសត្វនោះឯង ឈ្មោះថា មានឥន្ទ្រិយចាស់ក្លា ។ ពួកសត្វមានអាការអាក្រក់នោះ តើដូចម្តេច ។ ពួកសត្វណា មានអាសយៈអាក្រក់ មានអនុសយៈអាក្រក់

មានចរិតអាក្រក់ មានអធ្យាស្រ័យអាក្រក់ មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយទន់ ពួកសត្វនោះឯង ឈ្មោះថា មានអាការអាក្រក់ ។ ពួកសត្វមានអាការល្អនោះ តើដូចម្តេច ។ ពួកសត្វណា មានអាសយៈល្អ មានចរិតល្អ មានអធ្យាស្រ័យល្អ មានធូលីតិចក្នុងភ្នែក មានឥន្ទ្រិយចាស់ក្លា ពួកសត្វនោះឯង ឈ្មោះថា មានអាការល្អ ។ ពួកសត្វដែលឲ្យត្រាស់ដឹងក្រនោះ តើដូចម្តេច ។ ពួកសត្វណាមានអាការអាក្រក់ ពួកសត្វនោះ ឈ្មោះថា ឲ្យត្រាស់ដឹងក្រ ពួកសត្វណាមានអាការល្អ ពួកសត្វនោះ ឈ្មោះថា ឲ្យត្រាស់ដឹងងាយ ។ ពួកសត្វឥតភ័ព្វនោះ តើដូចម្តេច ។ ពួកសត្វណា ប្រកបដោយការរារាំង គឺអនន្តរិយកម្ម ប្រកបដោយការរារាំង គឺនិយតមិច្ឆាទិដ្ឋិ ប្រកបដោយការរារាំង គឺអហេតុកបដិសន្ធិ ជាអ្នកមិនមានសទ្ធា មិនមានសេចក្តីប្រាថ្នា ឥតប្រាជ្ញា មិនគួរចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ពួកសត្វនោះឯង ឈ្មោះថា ឥតភ័ព្វ ។ ពួកសត្វមានភ័ព្វនោះ តើដូចម្តេច ។ ពួកសត្វណា ជាអ្នកមិនប្រកបដោយការរារាំង គឺអនន្តរិយកម្ម មិនប្រកបដោយការរារាំង គឺនិយតមិច្ឆាទិដ្ឋិ មិនប្រកបដោយការរារាំង គឺអហេតុកបដិសន្ធិ ជាអ្នកមានសទ្ធា មានសេចក្តីប្រាថ្នា មានប្រាជ្ញា គួរចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ពួកសត្វនោះឯង ឈ្មោះថា មានភ័ព្វ ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណានូវធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវឥន្ទ្រិយចាស់ក្លា និងទន់របស់ពួក

សត្វដទៃ របស់ពួកបុគ្គលដទៃ ។

[ ៧៩ ] បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវសេចក្ដីសៅហ្មង នូវសេចក្ដីផូរផង់ នូវការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ តើដូចម្ដេច ។ ពាក្យថា បុគ្គលមានឈាន បានដល់ បុគ្គលមានឈាន ៤ ពួក គឺបុគ្គលមានឈានពួក ១ សម្គាល់នូវសម្បត្តិ ថាជាវិបត្តិក៏មាន បុគ្គលមានឈានពួក ១ សម្គាល់នូវវិបត្តិ ថាជាសម្បត្តិ ក៏មាន បុគ្គលមានឈានពួក ១ សម្គាល់នូវសម្បត្តិ ថាជាសម្បត្តិក៏មាន បុគ្គលមានឈានពួក ១ សម្គាល់នូវវិបត្តិ ថាជាវិបត្តិក៏មាន នេះឈ្មោះថា បុគ្គលមានឈាន ៤ ពួក ។ បុគ្គលមានឈាន ៤ ពួក ដទៃទៀត គឺ បុគ្គលមានឈានពួក ១ ចូលឈានយឺតយូរ តែចេញរហ័សក៏មាន បុគ្គលមានឈានពួក ១ ចូលឈានរហ័ស តែចេញយឺតយូរក៏មាន បុគ្គលមានឈានពួក ១ ចូលឈានយឺតយូរ ចេញក៏យឺតយូរក៏មាន បុគ្គលមានឈានពួក ១ ចូលឈានរហ័ស ចេញក៏រហ័សក៏មាន នេះឈ្មោះថា បុគ្គលមានឈាន ៤ ពួក ។ បុគ្គលមានឈាន ៤ ពួកដទៃទៀត គឺបុគ្គលមានឈានពួក ១ ជាអ្នកឈ្លាសក្នុងការធ្វើចិត្តឲ្យនឹងធឹងក្នុងសមាធិ តែមិនឈ្លាសក្នុងការចូលក្នុងសមាធិក៏មាន បុគ្គលមានឈានពួក ១ ជាអ្នកឈ្លាសក្នុងការចូលក្នុងសមាធិ តែមិនឈ្លាសក្នុងការធ្វើចិត្តឲ្យនឹងធឹងក្នុងសមាធិក៏មាន បុគ្គលមានឈានពួក ១ ជាអ្នកឈ្លាសក្នុងការធ្វើចិត្តឲ្យនឹងធឹងក្នុងសមាធិផង ជាអ្នកឈ្លាសក្នុងការចូលក្នុងសមាធិផងក៏មាន បុគ្គលមានឈានពួក ១ ជាអ្នក

មិនឈ្លាសក្នុងការធ្វើចិត្តឲ្យនឹងធឹងក្នុងសមាធិ ទាំងមិនឈ្លាសក្នុងការចូលក្នុងសមាធិក៏មាន នេះឈ្មោះថា បុគ្គលមានឈាន ៤ ពួក ។ ពាក្យថា ឈាន បានដល់ ឈាន ៤ គឺបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ ពាក្យថា វិមោក្ខ បានដល់ វិមោក្ខ ៨ គឺបុគ្គលមានរូបឃើញនូវរូប នេះវិមោក្ខទី ១ បុគ្គលមានសេចក្តីសម្គាល់ថា មិនមានរូបខាងក្នុង ឃើញរូបខាងក្រៅ នេះវិមោក្ខទី ២ បុគ្គលមានអធ្យាស្រ័យ ( សម្គាល់ ) ថារូបល្អ នេះវិមោក្ខទី ៣ បុគ្គលកន្លងបង់នូវរូបសញ្ញា ដល់នូវការរលត់បដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ក៏ចូលអាកាសានញ្ចា-យតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត នេះវិមោក្ខទី ៤ បុគ្គលកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត នេះវិមោក្ខទី ៥ បុគ្គលកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន នេះវិមោក្ខទី ៦ បុគ្គលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន នេះវិមោក្ខទី ៧ បុគ្គលកន្លងនូវនេវ-សញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលសញ្ញាវេទយិតនិរោធ នេះវិមោក្ខទី ៨ ។ ពាក្យថា សមាធិ បានដល់ សមាធិ ៣ គឺសមាធិប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ សមាធិមិនមានវិតក្ក មានត្រឹមតែវិចារ សមាធិមិនមានទាំងវិតក្ក មិនមានទាំងវិចារ ។ ពាក្យថា សមាបត្តិ

បានដល់ អនុបុព្វវិហារសមាបត្តិ ៩ គឺបឋមជ្ឈានសមាបត្តិ ទុតិយជ្ឈាន-សមាបត្តិ តតិយជ្ឈានសមាបត្តិ ចតុត្ថជ្ឈានសមាបត្តិ អាកាសានញ្ចាយ-តនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវ-សញ្ញានាសញ្ញាយតនសមាបត្តិ សញ្ញាវេទយិតនិរោធសមាបត្តិ ។ ពាក្យថា សេចក្ដីសៅហ្មង បានដល់ ធម៌ជាចំណែកនៃសេចក្ដីសាបសូន្យ ។ ពាក្យថា សេចក្ដីផូរផង់ បានដល់ ធម៌ជាចំណែកនៃគុណវិសេស ។ ពាក្យថា ការចេញ គឺសេចក្ដីផូរផង់ ឈ្មោះថា ការចេញ ទាំងការចេញចាកសមាធិនោះៗ ក៏ឈ្មោះថា ការចេញដែរ ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវសេចក្ដីសៅហ្មង នូវសេចក្ដីផូរផង់ នូវការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ ។

[ ៨០ ] បណ្ដាញាណទាំងនោះ ព្រះតថាគតមានការជ្រាបច្បាស់តាមពិត នូវការរឭកជាតិដែលនៅអាស្រ័យក្នុងកពមុន តើដូចម្ដេច ។ ព្រះតថា-គតក្នុងលោកនេះ រឭកជាតិដែលបាននៅអាស្រ័យក្នុងកពមុន ជាអនេកជាតិ គឺរឭកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១០០០ ជាតិ ១ សែន ជាតិក៏បាន រឭកបានច្រើនសំវដ្ដកប្ប ច្រើនវិវដ្ដកប្ប ច្រើនសំវដ្ដវិវដ្ដកប្ប ក៏បាន ដូច្នេះថា តថាគត បានកើតក្នុងកពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខ

ទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគត លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ តថាគតក៏មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគតនោះ លុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ព្រះតថាគតរឭកតាមនូវជាតិ ដែលនៅអាស្រ័យក្នុងភពមុន បានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវការរឭកជាតិ ដែលនៅអាស្រ័យក្នុងភពមុន ។

[ ៨១ ] បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវការច្យុត និងការកើតរបស់ពួកសត្វ តើដូចម្តេច ។ ព្រះតថាគត ក្នុងលោកនេះ មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា រមែងឃើញពួកសត្វដែលច្យុត ដែលកើតជាសត្វថោកទាប ខ្ពង់ខ្ពស់ មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានគតិល្អ មានគតិអាក្រក់ ក៏ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ( របស់ខ្លួន ) ថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវពួកព្រះអរិយបុគ្គល មានសេចក្តីយល់ខុស ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស សត្វទាំងនោះ លុះបែកធ្លាយរាងកាយខាងមុខអំពី

សេចក្ដីស្លាប់ ក៏បានចូលទៅកាន់កំណើតអបាយ ទុគ្គតិ វិនិបាត នរក មួយទៀត អើហ្ន៎ សត្វទាំងឡាយអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវពួកព្រះអរិយៈ មានសេចក្ដីយល់ត្រូវ ប្រកាន់នូវអំពើតាមសេចក្ដីយល់ត្រូវ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ ក៏បានចូលទៅកាន់លោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រះតថាគតមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា រមែងឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានគតិល្អ មានគតិអាក្រក់ ក៏ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ( របស់ខ្លួន ) ដោយប្រការដូច្នេះ ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគតមានការជ្រាបច្បាស់តាមពិត នូវការច្យុត និងការកើតរបស់ពួកសត្វ ។

[ ៨២ ] បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវការអស់ទៅនៃអាសវៈទាំងឡាយ តើដូចម្ដេច ។ ព្រះតថាគត ក្នុងលោកនេះ ព្រោះការអស់ទៅនៃអាសវៈ ក៏ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួន ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគតមានការជ្រាបច្បាស់តាមពិត នូវការអស់ទៅនៃអាសវៈទាំងឡាយ ។

ញាណវិភង្គ ចប់

# អដ្ឋកថា

## ទសកនិទ្ទេស

## អធិប្បាយ កម្លាំងទី ១

[ ៧៣ ] ក្នុងនិទ្ទេសនៃញាណវត្ថុទាំង ១០ បទថា **អដ្ឋានំ** ជាការបដិសេធហេតុ ។ បទថា **អនវកាសោ** បានដល់ ជាការបដិសេធបច្ច័យ ។ ដោយពាក្យទាំង ២ ព្រះមានព្រះភាគ ទ្រង់បដិសេធហេតុនោះឯង ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ហៅហេតុថា **ឋាន** និង **អវកាស** គឺឱកាសនៃផលរបស់ខ្លួន ព្រោះផលប្រព្រឹត្តទៅទាក់ទងដោយហេតុនោះ ។ បទថា **យំ** បានដល់ ដោយហេតុណា ។ បទថា **ទិដ្ឋិសម្បន្នោ** បានដល់ ព្រះអរិយសាវកដែលជាព្រះសោតាបន្ន ដល់ព្រមហើយដោយមគ្គទិដ្ឋិ ។ បទថា **កញ្ចិ សង្ខារំ** បានដល់ សូម្បីសង្ខារណាមួយ ក្នុងសង្ខារដែលបច្ច័យតាក់តែងដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **និច្ចតោ ឧបគច្ឆេយ្យ** បានដល់ គប្បីកាន់យកថាជារបស់ទៀង ។ បទថា **នេតំ ឋានំ វិជ្ជតិ** បានដល់ ហេតុនោះមិនមាន គឺរកមិនបាន ។ បទថា **យំ បុថុជ្ជនោ** បានដល់ បុថុជ្ជន ... គប្បីកាន់យកដោយហេតុណា ។ បទថា **ឋានមេតំ វិជ្ជតិ** បានដល់ ហេតុនេះមាន អធិប្បាយថា បុថុជ្ជននោះ គប្បីកាន់យកនូវវត្ថុសង្ខារណាមួយ ក្នុងសង្ខារទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយភាពជារបស់ទៀងដោយសស្សតទិដ្ឋិ ។ សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៤ រមែងមិនជាអារម្មណ៍របស់ទិដ្ឋិ ឬរបស់អកុសលទាំងឡាយដទៃ ដូចដុំដែកក្រហម ដែលក្តៅអស់

មួយថ្ងៃ រមែងមិនជាអារម្មណ៍របស់រុយទាំងឡាយ ព្រោះជារបស់ក្តៅខ្លាំង គប្បីជ្រាបអធិប្បាយក្នុងបទថា **កិញ្ចិ សង្ខារំ សុខតោ** ដោយន័យនេះ ។ បទថា **សុខតោ ឧបគច្ឆេយ្យ** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកការប្រកាន់ដោយភាពជាសុខ ដោយអំណាចនៃអត្តទិដ្ឋិយ៉ាងនេះថា ខាងមុខអំពីកាយបែកធ្លាយ ខ្លួនមានសេចក្តីសុខដោយចំណែកមួយ មិនមានរោគ ដូច្នេះជាដើម ។ ព្រះអរិយសាវក មានចិត្តវិប្បយុត្តចាកទិដ្ឋិ ហើយប្រកាន់សង្ខារណាមួយ ដោយភាពជាសុខ ដូចបុគ្គលត្រូវសេចក្តីក្តៅក្រហាយគ្របសង្កត់ហើយ ឲ្យដំរីចុះប្រេងទាំងឡាយ ធ្វើឲ្យតក់ស្លុត ដើម្បីរម្ងាប់សេចក្តីក្តៅក្រហាយ ដូចបោក្ខរព្រាហ្មណ៍អ្នកស្រឡាញ់ក្នុងការស្អាត ចូលទៅរកលាមក ( នោះមិនមែនឋានៈ ) ។ ក្នុងអត្តវាទ ព្រះមានព្រះភាគមិនត្រាស់ថា សង្ខារ តែត្រាស់ពាក្យថា **កញ្ចិ ធម្មំ** ដើម្បីសង្គ្រោះនូវបញ្ញត្តិ មានកសិណប្បញ្ញត្តិជាដើម ។

បណ្ឌិតគប្បីជ្រាបការកំណត់ក្នុងញាណនេះ ដោយអំណាចនៃភូមិ ៤ របស់អរិយសាវក និងដោយអំណាចនៃភូមិ ៣ របស់បុថុជ្ជន ។ម្យ៉ាងទៀត ការកំណត់ក្នុងវារៈទាំងពួង ដោយអំណាចនៃភូមិ ៣ នោះឯង រមែងគួរដល់អរិយសាវក ។ បុថុជ្ជនប្រកាន់នូវវត្ថុណាមួយ ព្រះអរិយសាវករមែងកម្ចាត់នូវការប្រកាន់វត្ថុនោះ ពិតហើយ បុថុជ្ជនរមែងប្រកាន់នូវសង្ខារណាមួយថា ជារបស់ទៀង សុខ អត្តា ព្រះអរិយសាវក កាលកំណត់សង្ខារនោះថា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ឈ្មោះថា កម្ចាត់នូវការប្រកាន់បាន ។

ក្នុងបទថា **មាតរំ** ជាដើម ស្រីអ្នកឲ្យកើតនោះឯង ឈ្មោះថា មាតា បុរសអ្នកឲ្យកំណើត ឈ្មោះថា បិតា ។ ព្រះខីណាស្រព ដែលជាមនុស្ស ប៉ុណ្ណោះ ព្រះមានព្រះភាគបំណងយកថាជាព្រះអរហន្ត ។ បើមានពាក្យសួរ ថា ព្រះអរិយសាវកគប្បីផ្តាច់ជីវិតសត្វឬ ឆ្លើយថា សេចក្តីនេះជាអឋានៈ ។ បើបុគ្គលណាមួយ គប្បីពោលនឹងអរិយសាវកដែលអន្ទោលទៅក្នុងអន្តរភព សូម្បីមិនដឹងថា ខ្លួនជាអរិយសាវក យ៉ាងនេះថា ចូរលោកផ្តាច់ជីវិតស្រមោច ក្រហមនេះ លោកនឹងបានជាស្តេចចក្កពត្តិក្នុងផ្ទៃនៃចក្កវាឡទាំងមូល ដូច្នេះ ព្រះអរិយសាវកនោះ មិនគប្បីផ្តាច់ផ្តិលសត្វនោះ ចាកជីវិតដោយពិត ។ម្យ៉ាងទៀត ជនទាំងឡាយ គប្បីពោលនឹងអរិយសាវកទាំងនោះ យ៉ាងនេះថា បើអ្នកមិនសម្លាប់សត្វនេះសោត ពួកយើងនឹងកាត់ក្បាលរបស់អ្នក ដូច្នេះ ជនទាំងនោះ គប្បីកាត់ក្បាលរបស់ព្រះអរិយសាវកនោះដោយពិត ព្រោះថា លោកមិនអាចសម្លាប់សត្វនោះឡើយ ។ ពាក្យនេះ លោកពោលដើម្បី សម្តែងភាវៈដែលជាបុថុជ្ជន មានទោសច្រើន និងដើម្បីសម្តែងកម្លាំងរបស់ អរិយសាវក ។ ពិតហើយ ក្នុងសេចក្តីនេះ គប្បីជ្រាបអធិប្បាយដូចតទៅ ភាពជាបុថុជ្ជន មានទោសច្រើន បុថុជ្ជន ធ្វើអនន្តរិយកម្ម មានការសម្លាប់ មាតាបាន អរិយសាវក ឈ្មោះថា មានកម្លាំងច្រើន ព្រោះលោកមិនធ្វើ កម្មទាំងនេះ ។

បទថា **ទុដ្ឋេន ចិត្តេន** បានដល់ មានចិត្តគិតសម្លាប់ ដែលសម្បយុត្ត ដោយទោសៈ ។ បទថា **លោហិតំ ឧប្បាទេយ្យ** បានដល់ ញុំាងលោហិត

ក្នុងសរីរៈរបស់ព្រះសម្ពុទ្ធដែលទ្រង់គង់ព្រះជន្មនៅ មានប្រមាណមួយចម្អែតរុយ ឲ្យពុរពង ។

បទថា **សង្ឃំ ភិន្ទេយ្យ** បានដល់ ញុំាងសង្ឃដែលមានសង្វាសស្មើគ្នា ដែលនៅក្នុងសីមាស្មើគ្នា ឲ្យបែកគ្នា ដោយហេតុ ៥ ប្រការ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងវិនយបិដក បរិវារ ) ថា ម្នាលឧបាលិ សង្ឃបែកគ្នាដោយអាការ ៥ គឺដោយកម្ម ( មានអបលោកនកម្មជាដើម ) ១ ដោយឧទ្ទេស ( មាននិទានឧទ្ទេសជាដើម ) ១ ដោយសម្តែងភេទរកវត្ថុ ១៨ យ៉ាង ១ ដោយអនុស្សាវនៈ គឺសូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន ១ ដោយប្រគល់ស្លាក ១ ដូច្នេះ ។

បណ្តាពាក្យទាំងនោះ ពាក្យថា ដោយកម្ម បានដល់ កម្មណាមួយក្នុងកម្ម ៤ យ៉ាង មានអបលោកនកម្មជាដើម ។ ពាក្យថា ដោយឧទ្ទេស បានដល់ ដោយការសូធ្យបាតិមោក្ខុទ្ទេសណាមួយ ក្នុងការសូធ្យបាតិមោក្ខុទ្ទេស ៥ យ៉ាង ។ ពាក្យថា ដោយសម្តែងភេទករវត្ថុ ១៨ យ៉ាង បានដល់ ពោលសម្តែងភេទករវត្ថុ មាន **អធម្មំ ធម្មោ** ធម៌ ថាមិនមែនធម៌ជាដើម ដោយរឿងដែលកើតឡើងទាំងនោះ ។ ពាក្យថា អនុស្សាវនៈ គឺសូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន បានដល់ ការបន្ទឺវាចាក្បែរត្រចៀក ដោយន័យថា លោកទាំងឡាយ រមែងដឹងថា ខ្ញុំចេញបួសហើយអំពីត្រកូលខ្ពស់ និងជាពហុសូតមិនមែនឬ លោកទាំងឡាយក៏មិនគួរកើតគំនិតថា ឈ្មោះថា បុគ្គលដូចខ្ញុំ គប្បីឲ្យរៀនពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាខុសអំពីធម៌

អំពីវិន័យ អវីចិនរកត្រជាក់ដូចគុម្ពឧប្បលខៀវដល់ខ្ញុំឬ ខ្ញុំមិនខ្លាចអបាយឬ ។ ពាក្យថា ដោយប្រគល់ស្លាក បានដល់ ការដែលប្រៀនប្រដៅយ៉ាងនោះ ហើយធ្វើចិត្តរបស់លោកឲ្យមាំទាំ ហើយឲ្យចាប់ស្លាក ដោយពាក្យថា លោកទាំងឡាយ ចូរចាប់ស្លាកនេះ ( ដើម្បីឲ្យបានជាគ្នីគ្នារបស់ខ្លួន ) ។

ម្យ៉ាងទៀត ក្នុងអាការដែលធ្វើឲ្យសង្ឃបែកគ្នានោះ កម្មនោះឯង ឬឧទ្ទេសជាប្រមាណ ។ ភេទករវត្ថុ ១៨ យ៉ាង អនុស្សាវនៈ ការប្រគល់ស្លាកជាបុព្វភាគ ។ ពិតហើយ កាលចង្អុលបង្ហាញដោយអំណាចនៃភេទករវត្ថុ ១៨ ប្រៀនប្រដៅឲ្យកើតសេចក្ដីពេញចិត្តក្នុងវត្ថុនោះ ហើយឲ្យចាប់ស្លាក សង្ឃមិនទាន់បែកគ្នា តែកាលណាភិក្ខុ ៤ រូប ឬច្រើនជាង ចាប់ស្លាកយ៉ាងនេះហើយ បែកគ្នា ធ្វើកម្ម ឬសូត្រនិទ្ទេសដោយឡែកពីគ្នា កាលនោះសង្ឃ ឈ្មោះថា បែកគ្នាហើយ ។

បុគ្គលដែលជាសោតាបន្ន ដល់ព្រមដោយទិដ្ឋិ គប្បីញ៉ាំងសង្ឃឲ្យបែកគ្នាដោយអាការយ៉ាងនេះ នោះមិនមែនជាឋានៈ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងអនន្តរិយកម្ម ៥ មានការសម្លាប់មាតាជាដើម ដែលបុថុជ្ជនធ្វើ តែព្រះអរិយសាវកមិនធ្វើ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ដើម្បីការជាក់ច្បាស់នៃកម្មទាំងនោះ គប្បីជ្រាបវិនិច្ឆ័យ ដោយកម្ម ១ ដោយទ្វារ ១ ដោយការតាំងនៅអស់កប្ប ១ ដោយវិបាក គឺផលនៃកម្ម ១ ដោយសាធារណៈជាដើម ១ ។

បណ្ដាពាក្យទាំងនោះ ជាបឋមពោលដោយកម្ម ពិតហើយ ក្នុងអនន្តរិ-

យកម្មទាំងនេះ កាលជាមនុស្សនោះឯង ផ្តាច់បង់ជីវិតមាតា ឬបិតាដែលជាមនុស្ស ដែលមានភេទមិនប្តូរ កម្មរមែងជាអនន្តរិយកម្ម ។ មនុស្សដែលធ្វើកម្មនោះ គិតថា អញនឹងហាមវិបាកនៃអនន្តរិយកម្មនោះ ទើបញុំាងចក្ក-វាឡទាំងមូល ឲ្យពេញដោយព្រះសថូប ដែលសម្រេចដោយមាស មានប្រមាណប៉ុនមហាចេតិយក្តី ថ្វាយមហាទានដល់ភិក្ខុសង្ឃ អង្គុយពេញល្វែងចក្កវាឡទាំងមូលក្តី ចាប់ជាយសង្ឃាដីរបស់ព្រះមានព្រះភាគ ដែលត្រាស់ដឹង ហើយត្រាច់ទៅក្តី កាលកាយបែកធ្លាយ រមែងចូលដល់នរកនោះឯង តែបុគ្គលណាខ្លួនឯងជាមនុស្ស ផ្តាច់បង់ជីវិតមាតាបិតា ដែលជាសត្វតិរច្ឆាន ឬខ្លួនឯងជាសត្វតិរច្ឆាន ផ្តាច់បង់ជីវិតមាតាបិតា ដែលជាមនុស្សឲ្យដាច់ទៅ កម្មរបស់បុគ្គលនោះ មិនជាអនន្តរិយកម្ម តែជាកម្មធ្ងន់ រមែងតាំងនៅក្បែរគ្នានឹងអនន្តរិយកម្មនោះឯង ។ បញ្ហានេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃសត្វដែលកើតជាមនុស្ស ។

ក្នុងសេចក្តីនេះ បណ្ឌិតគប្បីពោលដល់ចតុក្កៈនៃការសម្លាប់ពពែ ចតុក្កៈនៃសង្គ្រាម និងចតុក្កៈនៃការសម្លាប់ចោរ ដូច្នេះ គឺ

មនុស្សធ្វើមាតា ឬបិតាជាមនុស្ស ដែលនៅក្នុងទីជិតពពែឲ្យស្លាប់ ដោយបំណងថា អញនឹងសម្លាប់ពពែ ដូច្នេះ រមែងទទួលអនន្តរិយកម្ម ។ បើមានចេតនាសម្លាប់ពពែ ឬមានចេតនាសម្លាប់មាតាបិតា តែពពែស្លាប់ រមែងមិនបានទទួលអនន្តរិយកម្ម ។ បើមានចេតនាសម្លាប់មាតាបិតា ធ្វើមាតាបិតាឲ្យស្លាប់ រមែងបានទទួលអនន្តរិយកម្មពិតប្រាកដ ក្នុងចតុក្កៈ ២ ដ៏សេសក្រៅ

អំពីនេះ ក៏ន័យនោះឯង ។

ក្នុងការសម្លាប់ព្រះអរហន្ត បណ្ឌិតគប្បីជ្រាបចតុក្កៈទាំងនេះ ដូចចតុក្កៈក្នុងការសម្លាប់មាតាបិតា ដូច្នោះ ។ បុគ្គលធ្វើព្រះអរហន្ត ដែលជាមនុស្សឲ្យស្លាប់ រមែងបានទទួលអនន្តរិយកម្ម ញុំាងព្រះអរហន្តដែលជាយក្ខ ឲ្យស្លាប់ មិនជាអនន្តរិយកម្ម បើធ្វើព្រះអរហន្តដែលជាយក្ខឲ្យស្លាប់ រមែងមិនជាអនន្តរិយកម្ម តែជាកម្មធ្ងន់ប្រហែលគ្នានឹងអនន្តរិយកម្មនោះឯង ។ មយ៉ាងទៀត កាលបុគ្គលប្រហារដោយសស្ត្រា ឬដាក់ថ្នាំពិសដល់ព្រះអរហន្តដែលជាមនុស្ស ក្នុងកាលដែលលោកនៅជាបុថុជ្ជននោះឯង បើលោកសម្រេចអរហត្តហើយ ក៏បរិនិព្វានដោយហេតុនោះ រមែងជាអរហន្តឃាត តែទានដែលបុគ្គលថ្វាយ ក្នុងកាលដែលលោកនៅជាបុថុជ្ជន គ្រាលោកសម្រេចជាព្រះអរហន្តហើយ ទើបឆាន់អាហារ ទានដែលឲ្យនោះ ឈ្មោះថា ឲ្យដល់បុថុជ្ជនប៉ុណ្ណោះ ។ កាលបុគ្គលសម្លាប់ព្រះអរិយបុគ្គលដ៏សេស រមែងមិនបាត់ជាអនន្តរិយកម្ម តែជាកម្មធ្ងន់ក្បែរនឹងអនន្តរិយកម្មដូចគ្នា ។

ក្នុងលោហិតុប្បាទ ឈ្មោះថា ការហូរចេញនៃព្រះលោហិត ព្រោះការកាត់នូវធម៌ គឺរូបធម៌ ដោយការព្យាយាមរបស់បុគ្គលដទៃ រមែងមិនមានព្រោះព្រះតថាគត មានព្រះកាយមិនបែក មានត្រឹមតែលោហិតដែលកកក្នុងទីមួយកន្លែងខាងក្នុងព្រះសរីរៈប៉ុណ្ណោះ សូម្បីបំណែកថ្មដែលទេវទត្តប្រមៀលទៅចំត្រង់ចុងព្រះបាទ ( មេជើង ) របស់ព្រះតថាគត ព្រះបាទដែលត្រូវបាំងដោយកាប់នឹងពូថៅ ក៏មានត្រឹមតែព្រះលោហិតដែលជាំខាងក្នុងប៉ុណ្ណោះ ។

កម្មរបស់ទេវទត្ត ដែលធ្វើបែបនោះ រមែងជាអនន្តរិយកម្ម ។ ឯពេទ្យជីវក យកកំបិត ធ្វើការវះកាត់ព្រះធាវី គឺកាត់ស្បែករបស់ព្រះតថាគតតាមគាប់ចិត្ត ហើយនាំយកព្រះលោហិតដែលជាទោសចេញអំពីទីនោះ បានធ្វើឲ្យជាផាសុក កម្មរបស់ពេទ្យជីវកធ្វើយ៉ាងនោះ ជាបុញ្ញកម្មនោះឯង ។

បើមានពាក្យសួរថា កាលព្រះតថាគតបរិនិព្វានហើយ ជនទាំងឡាយណាទម្លាយនូវព្រះចេតិយ កាប់នូវព្រះស្រីមហាពោធិ៍ ដើរជាន់ព្រះធាតុ តើកម្មអ្វី រមែងមានដល់ជនទាំងនោះ ឆ្លើយថា កម្មដែលធ្ងន់ដូចគ្នានឹងអនន្ត-រិយកម្ម រមែងមានដល់ជនទាំងនោះ ។ បុគ្គលគួរកាប់មែកពោធិ៍ ដែលបៀតបៀនព្រះស្តូបបញ្ចុះព្រះធាតុ ព្រះពុទ្ធបដិមា ឬបើពួកបក្សីទាំងឡាយទំត្រង់ដើមពោធិព្រឹក្សនោះ បន្ទោបង់វច្ចៈ ធ្លាក់ត្រង់ព្រះចេតិយ សមគួរកាត់មែកពោធិ៍នោះឯង ព្រោះថា សរីរចេតិយ គឺចេតិយដែលបញ្ចុះព្រះធាតុ រមែងធំជាងបរិភោគចេតិយ គឺចេតិយ ដែលបញ្ចុះរបស់ប្រើប្រាស់នៃព្រះពុទ្ធ ។ សូម្បីឫសរបស់ព្រះពោធិព្រឹក្ស ដែលចាក់ទម្លាយចេតិយទោះកាប់ ក៏គួរ ។ ចំណែកនៃដើមពោធិ៍ណា បៀតបៀនខឿនពោធិព្រឹក្សមិនគួរកាត់មែកពោធិ-ព្រឹក្សនោះដើម្បីរក្សាខឿនឡើយ ។ ពិតហើយ ខឿនពោធិព្រឹក្ស ធ្វើដើម្បីជាប្រយោជន៍ដល់ដើមពោធិ៍ មិនគួរកាប់មែកពោធិ៍ដើម្បីជាប្រយោជន៍ដល់ខឿនឡើយ ។ សូម្បីក្នុងប្រាង្គ ( សម្រាប់បញ្ចុះព្រះធាតុ ) ក៏ន័យនេះឯង ។ តែព្រះធាតុដែលបុគ្គលរក្សាក្នុងប្រាង្គណា ដើម្បីរក្សាប្រាង្គនោះទោះកាប់មែកពោធិ៍ក៏គួរ ។ ដើម្បីរក្សាដើមពោធិ៍ សមគួរកាប់មែកពោធិ៍ដែលនាំឱជៈចេញ

ទៅ ឬដែលស្អុយរលួយនោះឯង បុណ្យក៏រមែងកើតដល់បុគ្គលនោះដូចការបដិបត្តិចំពោះព្រះសរីរៈ ។

ក្នុងសង្ឃភេទ កាលសង្ឃនៅក្នុងសីមាមិនប្រជុំគ្នា កាលភិក្ខុធ្វើភេទករវត្ថុ ១៨ អនុស្សាវនា និងការឲ្យចាប់ស្លាក នាំបរិស័ទបំបែកទៅមួយផ្នែកធ្វើហើយ ឬសូត្រឧទ្ទេស រមែងជាសង្ឃភេទផង ជាអនន្តរិយកម្មផង ។ កាលធ្វើកម្ម ឬសូត្រឧទ្ទេស ដោយសម្គាល់ថា សង្ឃនឹងសាមគ្គីគ្នា ទើបគួរធ្វើ ។ ពិតហើយ កាលធ្វើកម្មដោយសម្គាល់ថា សង្ឃនឹងសាមគ្គី រមែងមិនជាសង្ឃ-ភេទ មិនជាអនន្តរិយកម្ម ។ ដោយទំនងដូចគ្នានេះ រមែងមិនជាសង្ឃភេទ មិនជាអនន្តរិយកម្ម ដល់បរិស័ទដែលតិចជាង ៩ រូប តែជនពួកណានៃជនទាំងឡាយ ដោយកំណត់រួមទាំងអស់តិចបំផុត ៩ អង្គ ធ្វើសង្ឃឲ្យបែកគ្នា អនន្តរិយកម្ម រមែងកើតដល់បុគ្គលនោះ ។ កម្មដែលមានទោសច្រើនរមែងកើតដល់អធម្មវាទីទាំងឡាយ ដែលអនុលោមតាម ឯធម្មវាទីមិនមានទោសឡើយ ។

ក្នុងសង្ឃភេទនៃជនត្រឹម ៩ អង្គនោះ មានសូត្រ ( ក្នុងវិនយបិដក ចុល្លវគ្គ ) ដូចតទៅនេះថា ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង ៤ រូប ភិក្ខុប៉ែកម្ខាង ៤ រូប ឯភិក្ខុជាគម្រប់ ៩ សូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្តីប្រេះឆានៃសង្ឃផង ហៅថា សង្ឃភេទផង ។ ម្នាល

ឧបាលិ សេចក្ដីប្រេះធានៃសង្ឃ និងសង្ឃភេទ រមែងមានដល់ភិក្ខុ ៩ រូបក៏មាន ដល់ភិក្ខុច្រើនជាង ៩ រូបទៅក៏មាន ដូច្នេះ ។

បណ្ដាអនន្តរិយកម្មទាំង ៥ សង្ឃភេទប៉ុណ្ណោះជាវចីកម្ម អនន្តរិយកម្មដ៏សេសជាកាយកម្ម គប្បីជ្រាបវិនិច្ឆ័យ ដោយកម្មយ៉ាងនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយទ្វារ អនន្តរិយកម្មទាំងអស់នោះឯង រមែងតាំងឡើងអំពីកាយទ្វារខ្លះ អំពីវចីទ្វារខ្លះ បណ្ដាអនន្តរិយកម្ម ៥ នេះ អនន្តរិយកម្ម ៤ ខាងដើម តាំងឡើងហើយ តាមវចីទ្វារ ដោយអំណាចសេចក្ដីព្យាយាមដោយការប្រើ ឬសេចក្ដីព្យាយាម ដែលសម្រេចដោយវិជ្ជា រមែងសម្រេចតាមកាយទ្វារនោះឯង ។ សង្ឃភេទតាំងឡើងតាមកាយទ្វាររបស់អ្នកធ្វើ តែបែកដោយហត្ថវិការៈ ( ការកម្រើកដៃ ) រមែងសម្រេចតាមវចីទ្វារនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអនន្តរិយកម្មនេះ ដោយទ្វារយ៉ាងនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយការតាំងនៅអស់កប្ប ក្នុងអនន្តរិយកម្មទាំង ៥ នេះ សង្ឃភេទប៉ុណ្ណោះជាកម្មតាំងនៅអស់កប្ប ពិតហើយ កាលកប្ប ( ខាងដើមនៃកប្ប ) ឬកណ្ដាលនៃកប្បកំពុងប្រព្រឹត្តទៅ អ្នកធ្វើសង្ឃភេទ រមែងផុតចាកការឲ្យផលនៃកម្ម ក្នុងកាលកប្បវិនាសទៅនោះឯង ។ បើបុគ្គលធ្វើសង្ឃភេទក្នុងថ្ងៃនេះដោយគិតថា កប្បនឹងវិនាសទៅក្នុងថ្ងៃស្អែកនេះ បុគ្គលនោះនឹងផុតចាកអបាយ ក្នុងថ្ងៃស្អែកនេះ ពិតប្រាកដ រមែងភ្លើងឆេះក្នុងនរក

មួយថ្ងៃប៉ុណ្ណោះ តែការធ្វើកម្មដូចពោលមកនេះ មិនមាន ។ អនន្តរិយកម្ម ៤ ដ៏សេស ទោះជាអនន្តរិយកម្មដូចគ្នា តែមិនតាំងនៅអស់កប្ប ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអនន្តរិយកម្មនេះ ដោយការតាំងនៅអស់កប្ប ដូចពណ៌នាមក ដូច្នេះ ។

ពាក្យថា ដោយវិបាក បុគ្គលណាធ្វើកម្មទាំង ៥ យ៉ាងនេះ សង្ឃភេទប៉ុណ្ណោះ រមែងឲ្យផលដល់បុគ្គលនោះដោយអំណាចនាំបដិសន្ធិ កម្មដ៏សេសរមែងដល់នូវការរាប់ក្នុងពាក្យយ៉ាងនេះជាដើមថា កម្មមានហើយ ផលនៃកម្មមិនមាន ។ កាលមិនធ្វើសង្ឃភេទ លោហិតុប្បាទ រមែងឲ្យផលដោយអំណាចបដិសន្ធិ កាលមិនធ្វើកម្មទាំង ២ យ៉ាងនោះ អរហន្តឃាត រមែងឲ្យផលដោយអំណាចបដិសន្ធិ កាលមិនធ្វើកម្មទាំង ៣ នោះ បើបិតាជាអ្នកមានសីល មាតាជាអ្នកទ្រុស្តសីល ឬមានសីលទាបជាងបិតា បិតុឃាតរមែងឲ្យផលដោយអំណាចបដិសន្ធិ ។ បើមាតាជាអ្នកមានសីល បិតាជាអ្នកទ្រុស្តសីល ឬមានសីលទាបជាងមាតា មាតុឃាតរមែងឲ្យផល ដោយអំណាចបដិសន្ធិ ។ កាលមាតា និងបិតាមានសីល ឬទ្រុស្តសីលស្មើគ្នា មាតុឃាតប៉ុណ្ណោះរមែងឲ្យផលដោយអំណាចបដិសន្ធិ ព្រោះថា មាតាជាអ្នកធ្វើវត្ថុដែលធ្វើបានដោយក្រ និងមានឧបការៈច្រើនដល់កូនទាំងឡាយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអនន្តរិយកម្មនេះ ដោយការឲ្យផលយ៉ាងនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយសាធារណៈ អនន្តរិយកម្ម ៤ ខាងដើម ទូទៅដល់គ្រហស្ថ និងបព្វជិតទាំងអស់ ឯសង្ឃភេទរមែងជាអនន្តរិយកម្មដល់ភិក្ខុ មាន

ប្រការតាមដែលពោលហើយនោះឯង មិនជាអនន្តរិយកម្ម ដល់បុគ្គលដទៃ ព្រោះព្រះបាលី ( ក្នុងវិនយបិដក ចុល្លវគ្គ ) ថា ម្នាលឧបាលិ ភិក្ខុនីមិនឈ្មោះថា បំបែកសង្ឃទេ តែបានឈ្មោះថា ព្យាយាមដើម្បីបំបែក ( សង្ឃ ) សិក្ខមានាក៏មិនឈ្មោះថា បំបែកសង្ឃ សាមណេរ ក៏មិនឈ្មោះថា បំបែកសង្ឃ សាមណេរី ក៏មិនឈ្មោះថា បំបែកសង្ឃ ឧបាសក ក៏មិនឈ្មោះថា បំបែកសង្ឃ ឧបាសិកាក៏មិនឈ្មោះថា បំបែកសង្ឃ តែបានឈ្មោះថា ព្យាយាមដើម្បីបំបែកសង្ឃ ។ ម្នាលឧបាលិ លុះតែភិក្ខុដែលមានខ្លួនជាប្រក្រតី មានសំវាសស្មើគ្នា ស្ថិតនៅក្នុងសីមាជាមួយគ្នា ទើបឈ្មោះថា បំបែកសង្ឃ ដូច្នេះ ព្រោះហេតុនោះ ទើបសង្ឃភេទនេះ មិនទួទៅដល់បុគ្គលដទៃឡើយ ។

ពាក្យថា ជាដើម អនន្តរិយកម្មទាំងអស់នេះ សហគតៈដោយទុក្ខវេទនា សម្បយុត្តដោយទោសៈ និងមោហៈ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងអនន្តរិយកម្មនេះ ដោយសាធារណៈជាដើមយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **អញ្ញំ សត្ថារំ** អធិប្បាយថា ព្រះសោតាបន្នគប្បីកាន់យកមេលទ្ធិដទៃយ៉ាងនេះថា បុគ្គលនេះជាសាស្ដារបស់អញ សូម្បីក្នុងវាងកពថា បុគ្គលនេះជាសាស្ដារបស់អញ អាចធ្វើកិច្ចរបស់សាស្ដាបាន សេចក្ដីនេះមិនមែនជាឋានៈ ។

បទថា **អដ្ឋមំ ភវំ និព្វត្តេយ្យ** អធិប្បាយថា ព្រះសោតាបន្នមានបញ្ញាតិចជាងព្រះអរិយបុគ្គលទាំងអស់ ឈានកន្លងភពទី ៧ ហើយកើតក្នុងភព ៨ សេចក្ដីនេះមិនជាឋានៈ ព្រោះថា ព្រះមានព្រះភាគសំដៅយកភពទី ៧

ដោយកំណត់យ៉ាងខ្ពស់បំផុត ទើបត្រាស់ហៅព្រះសោតាបន្នទោះថាជាបុគ្គល ទៀង មានការត្រាស់ដឹងខាងមុខ ។ សួរថា អ្វីរមែងកំណត់កពនោះ បុព្វ-ហេតុរមែងកំណត់ឬ ឬថា មគ្គដែលលោកបានចំពោះហើយកំណត់ ឬថា មគ្គ ៣ ខាងលើរមែងកំណត់ ឆ្លើយថា ពាក្យនោះ ត្រឹមតែជាឈ្មោះដែល ព្រះសម្មាសម្ពុទ្ធទ្រង់កាន់យកហើយ ។

បុគ្គលឈ្មោះថា ទៀង រមែងមិនមាន បុគ្គលណាកាលពោលថា បុព្វ-ហេតុរមែងកំណត់ ឈ្មោះថា ពោលដល់ឧបនិស្ស័យនៃមគ្គ ៣ ខាងលើ រមែងដល់នូវភាពដែលបុព្វហេតុ មិនជាឧបនិស្ស័យនៃបឋមមគ្គ ព្រោះហេតុ នោះ ទើបបឋមមគ្គដល់នូវការកើតឡើងអំពីធម៌ដែលមិនជាធម៌ និងមិនជា បច្ច័យនៃបុព្វហេតុនោះ ។ បើពោលថា មគ្គដែលបានហើយ រមែងកំណត់ ដូច្នេះ មគ្គខាងលើ ៣ ក៏មិនមានកិច្ច បឋមមគ្គប៉ុណ្ណោះមានកិច្ច កាលបើ ដូច្នេះ ការធ្វើកិលេសទាំងឡាយឲ្យអស់ទៅហើយបរិនិព្វាន ក៏គប្បីមានត្រឹម តែដោយបឋមមគ្គ ។ បើពោលថា មគ្គ ៣ ខាងលើរមែងកំណត់ បឋមមគ្គ ក៏មិនមានកិច្ច មគ្គ ៣ ខាងលើប៉ុណ្ណោះមានកិច្ច ព្រះយោគាវចរ មិនបាន ញ៉ាំងបឋមមគ្គឲ្យកើតហើយ ក៏គប្បីញ៉ាំងមគ្គ ៣ ខាងលើ ឲ្យកើតឡើង ។ បឋមមគ្គនោះឯង ក៏គប្បីមិនកើតឡើងហើយ ក៏ធ្វើកិលេសទាំងឡាយឲ្យអស់ ទៅបាន ព្រោះហេតុនោះ ធម៌ណាមួយដទៃ រមែងមិនបានកំណត់កពនោះ វិបស្សនារបស់មគ្គ ៣ ខាងលើនោះឯង រមែងកំណត់ ។ ពិតហើយ បើ វិបស្សនារបស់មគ្គ ៣ ខាងលើនោះជាធម៌មានបញ្ញាមុតស្រួចនាំទៅ សោ-

តាបន្នបុគ្គលនោះ ញុំាងភព ១ ប៉ុណ្ណោះឲ្យកើតឡើងហើយ ក៏សម្រេចអរហត្ត ហើយបរិនិព្វាន ។ បើមានបញ្ញាទន់ជាងនោះ ក៏នឹងសម្រេចអរហត្តហើយ បរិនិព្វានក្នុងភពទី ២ ទី ៣ ទី ៤ ទី ៥ ទី ៦ ។ អ្នកមានបញ្ញាទន់ជាង សោតាបន្នទាំងអស់ នឹងញុំាងភពទី ៧ ឲ្យកើតឡើងហើយ ក៏សម្រេចអរហត្ត ទើបបដិសន្ធិក្នុងភពទី ៨ របស់លោកមិនមាន ។ ដោយប្រការដូច្នេះ ទើប ពាក្យនោះ ទើបត្រឹមតែជាឈ្មោះដែលព្រះសម្មាសម្ពុទ្ធទ្រង់កាន់យកហើយ ។

ពិតហើយ ព្រះសាស្តាទ្រង់ពិចារណាថ្លឹងថ្លែងហើយដោយការពិចារណា របស់ព្រះពុទ្ធ ទើបទ្រង់កំណត់ដោយព្រះសព្វញ្ញុតញ្ញាណថា បុគ្គលនេះមាន បញ្ញាច្រើនជាងជនទាំងពួង មានវិបស្សនាមុតស្រួច ញុំាងភពទី ១ ប៉ុណ្ណោះ ឲ្យកើត ហើយក៏កាន់យកអរហត្ត ដូច្នេះ ទើបទ្រង់ដាក់ឈ្មោះថា បុគ្គលនេះ ជាឯកពីជី ។ ត្រាស់ថា បុគ្គលនេះញុំាងភពទី ២ ទី ៣ ទី ៤ ទី ៥ ទី ៦ ឲ្យកើតហើយ នឹងកាន់យកអរហត្ត ទើបទ្រង់ដាក់ឈ្មោះថា បុគ្គលនេះជា កោលំកោលៈ ។ ត្រាស់ថា បុគ្គលនេះ ញុំាងភពទី ៧ ឲ្យកើតឡើងហើយ នឹងកាន់យកអរហត្ត ទើបទ្រង់ដាក់ឈ្មោះថា បុគ្គលនេះជា សត្តក្ខត្តុបរមៈ ។

បុគ្គលណាមួយឈ្មោះថា ទៀង រមែងមិនមានដល់ភពទាំង ៧ ។ ម្យ៉ាង ទៀត ព្រះអរិយសាវកដែលមានបញ្ញាតិចជាង ដោយអាការយ៉ាងណាមួយ ក៏មិនដល់ភពទី ៨ រមែងបរិនិព្វាន ក្នុងចន្លោះភពនោះឯង ។ ពិតហើយ ព្រះសោតាបន្ន ដែលជាបុគ្គលត្រេកអរក្រៃលែងក្នុងវដ្តៈ ដូចជាសក្កទេវរាជ ជាដើម ក៏រមែងទៅកាន់ភពទី ៧ ប៉ុណ្ណោះ វិបស្សនាញាណ របស់លោក

សូម្បីមានប្រក្រតីនៅដោយសេចក្តីប្រមាទដោយអាការទាំងពួង ក៏រមែងដល់នូវការចាស់ក្លាដោយជុំវិញ ក្នុងភពទី ៧ ព្រោះកាលលោកនៀយណាយក្នុងអារម្មណ៍ សូម្បីមានប្រមាណតិចតួច ហើយរមែងសម្រេចព្រះនិព្វានបាន ។ កាលបើលោកឈានចុះកាន់និទ្រា ឬកំពុងដើរទៅខាងមុខ មានបុគ្គលណាមួយឈរខាងក្រោយខ្នង គប្បីកាត់ក្បាល ដោយដាវដ៏មុតថ្លា ឬគប្បីចាប់លោកពន្លិចក្នុងទឹកឲ្យស្លាប់ ឬរន្ទះគប្បីធ្លាក់លើក្បាលរបស់លោក ក្នុងកាលបែបនេះ ឈ្មោះថា ធ្វើកាលកិរិយាដែលមានបដិសន្ធិទៀត រមែងមិនមាន រមែងសម្រេចអរហត្តនោះឯងហើយបរិនិព្វាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធ្វើភពទី ៨ ឲ្យកើតឡើង ការណ៍នុ៎ះមិនមាន ។

បទថា **ឯកិស្សា លោកធាតុយា** បានដល់ ក្នុងលោកធាតុមានចំនួនមួយម៉ឺន ។ ពិតហើយ ពុទ្ធក្ខេត្ត មាន ៣ គឺជាតិក្ខេត្ត ១ អាណាខេត្ត ១ វិសយក្ខេត្ត ១ ។

បណ្តាខេត្តទាំងនោះ លោកធាតុមានចំនួនមួយម៉ឺន ឈ្មោះថា ជាតិក្ខេត្ត ពិតហើយ លោកធាតុមួយម៉ឺននោះ រមែងញាប់ញ័រក្នុងកាលព្រះតថាគតចុះកាន់ព្រះឧទររបស់ព្រះមាតា ក្នុងកាលដែលទ្រង់យាងចេញមហាភិនេស្រ្កមណ៍ ក្នុងកាលដែលទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងកាលដាក់ព្រះជន្មាយុសង្ខារ និងក្នុងកាលបរិនិព្វាន ។

ចក្កវាឡចំនួនមួយសែនកោដិ ឈ្មោះថា អាណាខេត្ត ពិតហើយ

អាណា គឺអំណាចនៃអាដានាដិយបរិត្ត មោរបរិត្ត ធជគ្គបរិត្ត និងរតនបរិត្ត ជាដើម រមែងប្រព្រឹត្តទៅ គឺផ្សាយទៅក្នុងសែនកោដិចក្កវាឡនេះ ។

តែការកំណត់វិសយក្ខេត្ត រមែងមិនមាន ។ ពិតហើយ ព្រោះព្រះបាលី ( ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា របស់ដែលត្រូវដឹងមានកំណត់ត្រឹមណា ញាណក៏មានកំណត់ត្រឹមនោះ ញាណមានកំណត់ត្រឹមណា របស់ដែលត្រូវដឹងក៏មានកំណត់ត្រឹមនោះ ដូច្នេះ ឈ្មោះថា វត្ថុហួសវិស័យរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនមាន ។

ក្នុងពុទ្ធក្ខេត្តទាំង ៣ នោះ ព្រះសូត្រថា វៀរចក្កវាឡនេះ ព្រះពុទ្ធទាំងឡាយ រមែងកើតឡើងក្នុងចក្កវាឡដទៃ ដូច្នេះ រមែងមិនមាន តែព្រះសូត្រថា ព្រះពុទ្ធទាំងឡាយ រមែងមិនកើតឡើង ដូច្នេះមាន ។

បិដកមាន ៣ គឺវិនយបិដក សុត្តន្តបិដក អភិធម្មបិដក សង្គីតិមាន ៣ គឺសង្គីតិរបស់ព្រះមហាកស្សបត្ថេរ របស់ព្រះយសត្ថេរ របស់ព្រះមោគ្គលីបុត្តតិស្សត្ថេរ ។ ក្នុងពុទ្ធវចនៈ គឺបិដក ៣ ដែលព្រះសង្គីតិកាចារ្យ លើកឡើងកាន់សង្គីតិទាំង ៣ នេះ ព្រះសូត្រថា ផុតចាកចក្កវាឡនេះហើយ ព្រះពុទ្ធទាំងឡាយ រមែងកើតឡើងក្នុងចក្កវាឡដទៃ ដូច្នេះមិនមាន តែព្រះសូត្រថា ព្រះពុទ្ធទាំងឡាយ រមែងមិនកើតឡើង ដូច្នេះមាន ។

បទថា **អបុព្វំ អចរិមំ** បានដល់ ទ្រង់មិនកើតឡើងព្រមគ្នា គឺមិនមុនមិនក្រោយ ។ មានពាក្យអធិប្បាយថា ព្រះពុទ្ធទាំងឡាយ រមែងកើតឡើងមុន ឬក្រោយគ្នា មិនព្រមគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អបុញ្ញំ អចរិមំ** ដូចតទៅ

ចាប់តាំងអំពីការប្រាថ្នាចំពោះអភិនីហារព្រះហឫទ័យ ត្រង់ពោធិបល្ល័ង្កថា អញមិនទាន់សម្រេចពោធិញ្ញាណហើយ នឹងមិនក្រោកឡើង ដូច្នេះ រហូតទៅដល់បដិសន្ធិក្នុងព្រះឧទរមាតា មិនគប្បីយល់ថា ជាកាលមុន ។ ពិតហើយ ក្នុងបដិសន្ធិរបស់ព្រះពោធិសត្វ លោកធ្វើការកំណត់ជាតិក្ខេត្ត ដោយការញាប់ញ័រនៃចក្កវាឡមួយម៉ឺននោះឯង ។ ក្នុងរវាងនេះ រមែងហាមការកើតឡើងនៃព្រះសម្ពុទ្ធអង្គដទៃ ចាប់តាំងពីបរិនិព្វាន ដរាបដល់ព្រះធាតុមានប្រមាណប៉ុនគ្រាប់ស្ពៃនៅមាននៅឡើយ មិនគប្បីយល់ថា ជាកាលក្រោយ ។ ពិតហើយ កាលព្រះបរមធាតុតាំងនៅ នៅឡើយ ព្រះពុទ្ធទាំងឡាយឈ្មោះថា តាំងនៅនោះឯង ព្រោះហេតុនោះ ក្នុងរវាងនេះរមែងហាមការកើតឡើងនៃព្រះពុទ្ធអង្គដទៃ ។ កាលព្រះធាតុបរិនិព្វានហើយ ការកើតឡើងនៃព្រះពុទ្ធអង្គដទៃ មិនត្រូវហាម ។

ពិតហើយ ឈ្មោះថា អន្តរធាន មាន ៣ យ៉ាង គឺ **បរិយត្តិអន្តរធាន** គឺការសាបសូន្យនៃការរៀនព្រះត្រៃបិដក ១ **បដិវេធអន្តរធាន** គឺសាបសូន្យមគ្គ និងផល ១ **បដិបត្តិអន្តរធាន** គឺសាបសូន្យកិច្ចបដិបត្តិ ១ ។

បណ្ដាអន្តរធាន ៣ យ៉ាងនោះ ព្រះត្រៃបិដកឈ្មោះថា **បរិយត្តិ** ការចាក់ធ្លុះសច្ចៈឈ្មោះថា **បដិវេធ** បដិបទាឈ្មោះថា **បដិបត្តិ** ។ ក្នុងពាក្យទាំងនោះ បដិវេធ និងបដិបត្តិ មានក៏បាន មិនមានក៏បាន ។ ពិតហើយ ក្នុងកាលមួយ ភិក្ខុដែលធ្វើនូវការចាក់ធ្លុះមានច្រើន មិនគប្បីចង្អុលបង្ហាញបាន

ថា ភិក្ខុនេះជាបុថុជ្ជន បានឮថា ក្នុងកោះនេះឯង សម័យមួយ ឈ្មោះថា ភិក្ខុដែលជាបុថុជ្ជនមិនមានហើយ ។ សូម្បីភិក្ខុដែលបំពេញបដិបទាក្នុងកាលខ្លះក៏មានច្រើន ក្នុងកាលខ្លះក៏មានតិច ។ ដោយប្រការដូច្នេះ បដិវេធ និងបដិបត្តិ ក៏ឈ្មោះថា មានក៏បាន មិនមានក៏បាន ។ បរិយត្តិជាគោលកំណត់ការតាំងនៅនៃព្រះសាសនា ។ ពិតហើយ បណ្ឌិតស្តាប់ព្រះត្រៃបិដកហើយ ក៏ញុំាងបដិបត្តិ និងបដិវេធទាំង ២ ឲ្យពេញបាន ដូចព្រះពោធិសត្វនៃយើងទាំងឡាយ ញុំាងអភិញ្ញា ៥ និងសមាបត្តិ ៧ ឲ្យកើតឡើង ក្នុងសម្នាក់អាឡារតាបស ហើយក៏សួរបរិកម្ម ក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ តាបសនោះប្រាប់ថា មិនដឹង ទើបយាងទៅកាន់សម្នាក់របស់ឧទកតាបស-រាមបុត្ត ទ្រង់ប្រៀបធៀបនូវគុណវិសេសដែលទ្រង់សម្រេចហើយ ទ្រង់សួរបរិកម្មនៃនេវសញ្ញានាសញ្ញាយតនៈ ឧទកតាបសរាមបុត្តនោះ ប្រាប់ហើយ ព្រះមហាសត្វទ្រង់ញុំាងសមាបត្តិនោះឲ្យដល់ព្រមហើយ ក្នុងលំដាប់នៃពាក្យរបស់តាបសនោះឯងយ៉ាងនោះ ភិក្ខុអ្នកមានបញ្ញា ក៏យ៉ាងនោះឯង ស្តាប់បរិយត្តិហើយ រមែងញុំាងបដិបត្តិ និងបដិវេធទាំង ២ ឲ្យពេញបាន ។ ព្រោះហេតុនោះ កាលបរិយត្តិតាំងនៅ សាសនាក៏ឈ្មោះថាតាំងនៅ ។ ក្នុងកាលណាបរិយត្តិនោះអន្តរធានទៅ អភិធម្មបិដករមែងវិនាសទៅមុន ក្នុងអភិធម្ម-បិដកនោះ គម្ពីរបដ្ឋាន រមែងអន្តរធានមុនគម្ពីរទាំងឡាយ រមែងអន្តរធានទៅដោយលំដាប់ ធម្មសង្គណីរមែងអន្តរធានទៅ ក្នុងកាលជាខាងក្រោយកាលព្រះអភិធម្មបិដកនោះអន្តរធានទៅអស់ហើយ បិដកទាំង ២ ក្រៅអំពី

នេះ តាំងនៅដរាបណា សាសនាក៏ឈ្មោះថាតាំងនៅនោះឯង ។

បណ្តាបិដក ២ ដ៏សេសនោះ កាលសុត្តន្តបិដកអន្តរធានទៅ អង្គុត្តរនិកាយរមែងអន្តរធានតាំងអំពីឯកាទសកនិបាត ចុះមករហូតដល់ឯកនិបាត ។ លំដាប់នោះ សំយុត្តនិកាយរមែងអន្តរធាន តាំងអំពីចក្កបេយ្យាល ចុះមករហូតដល់ឱឃតរណា ( ឱឃតរណសូត្រ ) ។ លំដាប់នោះ មជ្ឈិមនិកាយរមែងអន្តរធានតាំងអំពីឥន្ទ្រិយភាវនាសូត្រ ចុះមករហូតដល់មូលបរិយាយសូត្រ ។ លំដាប់នោះ ទីឃនិកាយរមែងអន្តរធាន តាំងអំពីទសុត្តរសូត្រ ចុះរហូតមកដល់ព្រហ្មជាលសូត្រ ។ សួរថា បុច្ឆានៃគាថា ១ ក្តី ២ ក្តី រមែងប្រព្រឹត្តទៅយូរ តែពាក្យបុច្ឆានោះ រមែងមិនអាចញុំាងព្រះសាសនាឲ្យតាំងនៅដូចជាសភិយបុច្ឆា និងអាឡវកបុច្ឆា ។ បានឮថា បុច្ឆាទាំងនេះមានក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ក៏មិនអាចញុំាងសាសនា ឲ្យតាំងនៅបានក្នុងចន្លោះ ។

កាលបិដកទាំង ២ អន្តរធានទៅហើយ តែព្រះវិន័យតាំងនៅដរាបណា សាសនាក៏ឈ្មោះថា តាំងនៅដរាបនោះ កាលបរិវារ និងខន្ធកៈទាំងឡាយអន្តរធានទៅហើយ តែឧភតោវិភង្គតាំងនៅ សាសនាក៏ឈ្មោះថា តាំងនៅនោះឯង កាលឧភតោវិភង្គអន្តរធានទៅហើយ តែមាតិកាតាំងនៅ សាសនាក៏ឈ្មោះថា តាំងនៅនោះឯង កាលមាតិកាអន្តរធានទៅហើយ តែបាតិមោក្ខ ការបួសជាសាមណេរ បួសជាភិក្ខុ តាំងនៅដរាបណា សាសនាក៏ឈ្មោះថា តាំងនៅ ។ លិង្គ គឺភេទរមែងប្រព្រឹត្តទៅអស់កាលយូរ ។ វង្សនៃសមណៈ

ដែលស្លៀកសំពត់ស មិនអាចទ្រទ្រង់សាសនា ចាប់ពីកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ។ រាប់តាំងពីការចាក់ធ្លុះសច្ចៈនៃបុគ្គលចុងក្រោយ និងតាំងអំពីសីលភេទ គឺការបែកទៅនៃសីលរបស់បុគ្គលចុងក្រោយ សាសនាឈ្មោះថា សាបសូន្យ ។ ចាប់តាំងពីនោះមក ការកើតឡើងនៃព្រះពុទ្ធអង្គដទៃ មិនត្រូវហាម ។

ឈ្មោះថា បរិនិព្វានមាន ៣ គឺកិលេសបរិនិព្វាន ១ ខន្ធបរិនិព្វាន ១ ធាតុបរិនិព្វាន ១ ។ បណ្តានិព្វានទាំងនោះ កិលេសបរិនិព្វានមានហើយត្រង់ពោធិបល្ល័ង្ក ។ ខន្ធបរិនិព្វានមានហើយត្រង់នគរកុសិនារា ។ ធាតុបរិនិព្វាននឹងមានក្នុងអនាគតកាល ។

បានឮថា ក្នុងកាលដែលសាសនាវិនាស ព្រះធាតុទាំងឡាយត្រង់តម្ពបណ្ណិទ្វីប គឺស្រីលង្កា នឹងមកប្រជុំគ្នា ហើយអណ្តែតត្រសែតទៅកាន់មហាចេតិយ បន្ទាប់អំពីមហាចេតិយ នឹងទៅកាន់រាជាយតនៈ គឺដើមកែសក្នុងនាគទីប បន្ទាប់អំពីនោះ ក៏ទៅកាន់មហាពោធិបល្ល័ង្ក ព្រះធាតុទាំងឡាយក្នុងនាគពិភពក្តី ក្នុងទេវលោកក្តី ក្នុងព្រហ្មលោកក្តី នឹងអណ្តែតត្រសែតទៅកាន់មហាពោធិបល្ល័ង្កនោះឯង ព្រះធាតុប្រមាណប៉ុនគ្រាប់ស្ពៃ ក៏មិនបាត់បង់ទៅក្នុងរវាងផ្លូវ ព្រះធាតុទាំងអស់មកប្រជុំគ្នាជាដុំតែមួយ ត្រង់មហាពោធិបល្ល័ង្កដូចដុំមាស ហើយបញ្ចេញឆព្វណ្ណរង្សី ឆព្វណ្ណរង្សីនោះ ផ្សាយទៅមួយម៉ឺនលោកធាតុ ។ លំដាប់នោះ ទេវតាក្នុងម៉ឺនចក្កវាឡ ក៏មកប្រជុំគ្នា ពោលថា ថ្ងៃនេះ ដែលព្រះសាស្តានឹងបរិនិព្វាន ថ្ងៃនេះ សាសនានឹងសាបសូន្យ ឥឡូវ

នេះ ជាការឃើញគ្រាចុងក្រោយរបស់ពួកយើងទាំងឡាយ ដូច្នេះហើយ នឹងធ្វើសេចក្ដីករុណាដ៏ធំក្រៃលែងជាងថ្ងៃដែលព្រះទសពលបរិនិព្វាន វៀរលែងតែព្រះអនាគាមី និងព្រះខីណាស្រពហើយ សត្វដ៏សេស មិនអាចតាំងនៅដោយភាវៈនៃខ្លួន ។ តេជោធាតុក្នុងព្រះធាតុទាំងឡាយ ក៏តាំងឡើង ហើយផ្សាយទៅដល់ព្រហ្មលោក ។ កាលព្រះធាតុមានប្រមាណប៉ុនគ្រាប់ស្ពៃ នៅមាន អណ្ដាតភ្លើងមួយនឹងមាន កាលព្រះធាតុទាំងឡាយ អស់រលីងហើយ អណ្ដាតភ្លើងនោះក៏រលត់ ។ កាលព្រះធាតុទាំងឡាយ សម្ដែងអានុភាពដ៏ធំយ៉ាងនេះ ដោយប្រការដូច្នេះហើយ ក៏អន្តរធានទៅ សាសនា ឈ្មោះថាអន្តរធានទៅហើយ ។ ឈ្មោះថា កាលមិនក្រោយ រមែងមានដរាបដែលព្រះពុទ្ធមិនទាន់អន្តរធានទៅយ៉ាងនេះ ព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គគប្បីកើតឡើងព្រមគ្នា នោះមិនមែនជាឋានៈ ដោយប្រការដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះពុទ្ធទាំងឡាយមិនកើតព្រមគ្នា ឆ្លើយថា ព្រោះមិនមានភាពអស្ចារ្យ ។

ពិតហើយ ព្រះពុទ្ធទាំងឡាយគ្រប់អង្គ សុទ្ធតែជាមនុស្សអស្ចារ្យ ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងជាមនុស្សអស្ចារ្យ បុគ្គលឯក តើគឺនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

ម្យ៉ាងទៀត បើព្រះពុទ្ធ ២ អង្គ ៤ អង្គ ៨ អង្គ ឬ ១៦ អង្គ កើតឡើងព្រមគ្នាសោត មិនគប្បីជាបុគ្គលអស្ចារ្យ ។ ពិតហើយ លាភសក្ការៈ

របស់ចេតិយទាំងពីរ ក្នុងវិហារមួយមិនឱឡារ សូម្បីតែភិក្ខុទាំងឡាយក៏មិន អស្ចារ្យព្រោះមានច្រើន សូម្បីព្រះពុទ្ធទាំងឡាយ ក៏ដូចគ្នា ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងឡាយ មិនកើតឡើងព្រមគ្នា ។ ម្យ៉ាងទៀត ព្រោះព្រះ ធម្មទេសនាក៏ជាសភាវៈមិនប្លែកគ្នាឡើយ ។ ពិតហើយ ព្រះពុទ្ធ ១ អង្គ រមែងសម្តែងធម៌ មានសតិប្បដ្ឋានជាដើមណា ព្រះពុទ្ធអង្គដទៃ សូម្បីកើត ឡើងហើយក៏ទ្រង់សម្តែងនោះឯង ។ លំដាប់នោះ ព្រះធម៌គប្បីមិនមានភាព អស្ចារ្យ តែកាលព្រះពុទ្ធមួយអង្គសម្តែងធម៌ទេសនាក៏រមែងជាធម៌អស្ចារ្យ ។ ម្យ៉ាងទៀត ព្រោះមិនមានវិវាទ ដ្បិតថា កាលព្រះពុទ្ធទាំងឡាយ ទ្រង់កើត ឡើងព្រមគ្នាហើយ សាវកទាំងឡាយ ក៏គប្បីពោលប្រជែងគ្នាថា ព្រះពុទ្ធ របស់ពួកយើងគួរជ្រះថ្លា ព្រះពុទ្ធរបស់ពួកយើង មានសំឡេងពីរោះ មាន លាភ មានបុណ្យ ដូច្នេះ ហាក់បីដូចអន្តេវាសិក មានអាចារ្យច្រើន នឹង ពោលប្រកែកគ្នា ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងឡាយ មិនកើតឡើង ព្រមគ្នា ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះនាគសេនត្ថេរ កាលស្តេចមិលិន្ទទ្រង់សួរហើយ ពោល ហេតុនេះឲ្យពិស្តារហើយ ។

ក្នុងរឿងនោះ លោកបានពោលដូច្នេះថា ព្រះបាទមិលិន្ទត្រាស់សួរថា បពិត្រព្រះនាគសេន ព្រះពុទ្ធវចនៈនេះ ព្រះមានព្រះភាគទ្រង់សម្តែងហើយ ថា ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គ គប្បីកើតឡើង មិនមុនមិនក្រោយ ក្នុងលោកធាតុតែមួយ គឺចក្កវាឡ ១ ដោយហេតុឯណា

ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនបច្ច័យ គឺថា ហេតុនុ៎ះ មិនមានឡើយ ដូច្នេះ បពិត្រព្រះនាគសេន ព្រះតថាគតទាំងពួង កាលទ្រង់សម្តែង រមែងសម្តែងធម៌ទាំងឡាយ ដែលជាចំណែកនៃបញ្ញា ជាគ្រឿងត្រាស់ដឹង ៣៧ ប្រការនោះឯង កាលនឹងត្រាស់ រមែងត្រាស់អរិយសច្ច ៤ កាលនឹងឲ្យសិក្សា រមែងឲ្យសិក្សាក្នុងត្រៃសិក្ខា កាលនឹងប្រៀនប្រដៅរមែងប្រៀនប្រដៅក្នុងកិច្ចបដិបត្តិ ដើម្បីការមិនប្រមាទ បពិត្រព្រះនាគសេន បើឧទ្ទេសរបស់ព្រះតថាគតទាំងពួងដូចគ្នា កថាក៏ដូចគ្នា សិក្ខាក៏ដូចគ្នា ការប្រៀនប្រដៅក៏ដូចគ្នា ព្រោះហេតុអ្វី ទើបព្រះតថាគត ២ អង្គ មិនកើតឡើងក្នុងកាលតែមួយ លោកនេះមានពន្លឺកើតឡើង ដោយការកើតឡើងនៃព្រះពុទ្ធ ១ អង្គក៏ដល់ម្ល៉ោះ បើព្រះពុទ្ធ ២ អង្គកើតឡើងសោត លោកនេះគប្បីមានពន្លឺលើសប្រមាណ ដោយពន្លឺនៃព្រះពុទ្ធទាំង ២ អង្គ ព្រះតថាគតទាំង ២ អង្គ កាលនឹងពោលទូន្មាន ក៏គប្បីពោលទូន្មានដោយងាយ កាលប្រៀនប្រដៅក៏គប្បីប្រៀនប្រដៅដោយងាយ សូមលោកម្ចាស់ សម្តែងហេតុក្នុងសេចក្តីនោះដល់ខ្ញុំ ដោយប្រការដែលខ្ញុំគប្បីអស់សង្ស័យ ។

ព្រះថេរៈទូលថា សូមថ្វាយព្រះពរមហាបពិត្រ លោកធាតុមួយម៉ឺននេះ ទ្រទ្រង់នូវព្រះពុទ្ធបានត្រឹមតែមួយអង្គ ទ្រទ្រង់នូវគុណរបស់ព្រះតថាគតបានត្រឹមតែមួយអង្គប៉ុណ្ណោះ បើព្រះពុទ្ធអង្គទី ២ គប្បីកើតឡើងសោត លោក-ធាតុទាំងមួយម៉ឺននេះ ទ្រទ្រង់មិនបាន គប្បីផ្អៀង គប្បីញាប់ញ័រ គប្បីទោរទៅ គប្បីស្រុតចុះ គប្បីរញ្ជួយ គប្បីបាក់បែកខ្ទេចខ្ទី គប្បីវិនាស គប្បីបែក

ធ្លាយ គប្បីចូលដល់ការតាំងនៅមិនបាន ។

សូមថ្វាយព្រះពរមហាបពិត្រ ប្រៀបដូចទូកដែលមានចំណុះមនុស្សតែម្នាក់ កាលបុរសម្នាក់ឡើងទូកនោះហើយ ទូកនោះ គប្បីឲ្យដល់ត្រើយបាន បើបុរសទី ២ គប្បីមកសោត បុរសនោះ ដូចគ្នាដោយអាយុ ដោយពណ៌សម្បុរ ដោយវ័យ ដោយប្រមាណ ដោយការស្គមការធាត់ ដោយអវយវៈតូចធំទាំងពួង បុរសទី ២ នោះគប្បីឡើងជិះទូកនោះ មហាបពិត្រ តើទូកនោះគប្បីទ្រទ្រង់បុរសទាំង ២ បានឬ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់មិនបានទេ ទូកនោះមិនគប្បីទ្រទ្រង់បាន គប្បីផ្អៀង គប្បីញាប់ញ័រ គប្បីឃ្លេងឃ្លោង គប្បីស្រុតចុះ គប្បីរញ្ជួយ គប្បីបាក់បែក គប្បីវិនាស គប្បីធ្លុះធ្លាយ គប្បីចូលដល់នូវការតាំងនៅមិនបាន គប្បីលិចចុះក្នុងទឹក ។

ព្រះថេរៈទូលថា មហាបពិត្រ យ៉ាងនោះឯង លោកធាតុមួយម៉ឺននេះទ្រទ្រង់នូវព្រះពុទ្ធបានត្រឹមតែមួយអង្គ ទ្រទ្រង់នូវគុណរបស់ព្រះតថាគតបានត្រឹមមួយអង្គ បើព្រះពុទ្ធអង្គទី ២ គប្បីកើតឡើង លោកធាតុមួយម៉ឺនទ្រទ្រង់មិនបាន គប្បីផ្អៀង ។បេ។ គប្បីចូលដល់ការតាំងនៅមិនបាន ។

មហាបពិត្រ ម្យ៉ាងទៀត ប្រៀបដូចបុរសបរិភោគអាហារ តាមត្រូវការរហូតដល់ក ឆ្អែតហើយ បរិបូណ៌ហើយ មិនមានឱកាស ( ទំនេរសម្រាប់ដាក់អាហារដែលលេបចូល ) ដល់នូវភាពជាអ្នកទម្រន់ ដូចអង្គត់ឧស ឱនមិនចុះ បន្ទាប់អំពីការបរិភោគនោះហើយ បរិភោគអាហារប៉ុណ្ណោះទៀត មហាបពិត្រ បុរសនោះ គប្បីមានសេចក្តីសុខឬហ្ន៎ ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ មិនអាចឡើយ បើបុរសនោះបរិ-
ភោគអាហារប្រមាណប៉ុណ្ណោះម្ដងទៀត ក៏គប្បីដល់នូវសេចក្ដីស្លាប់ ដូច្នេះ ។

ព្រះថេរៈទូលថា មហាបពិត្រ យ៉ាងនោះឯង លោកធាតុមួយម៉ឺននេះ ទ្រទ្រង់ព្រះពុទ្ធ បានត្រឹមតែមួយអង្គ ។បេ។ គប្បីចូលដល់ការតាំងនៅមិនបាន ។

ព្រះរាជាត្រាស់ថា បពិត្រព្រះនាគសេន ផែនដីរមែងរង្គោះរង្គើញាប់ញ័រ ដោយទម្ងន់នៃធម៌ហួសប្រមាណឬ ។ ព្រះថេរៈទូលថា សូមថ្វាយព្រះពរ មហាបពិត្រ ក្នុងសេចក្ដីនេះ ប្រៀបដូចរទេះ ២ ដែលពេញដោយរតនៈ បុគ្គលគប្បីជញ្ជូនរតនៈពីរទេះ ១ ដាក់ចូលទៅក្នុងរទេះ ១ ទៀត មហាបពិត្រ តើរទេះនោះ គប្បីទ្រទ្រង់នូវរតនៈនៃរទេះទាំង ២ បានឬ ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ មិនបានទេ ដុំរទេះនោះគប្បីបែក កាំរទេះនោះគប្បីបាក់ ខ្នងកង់ក៏គប្បីប្រេះទៅ ភ្លៅរទេះគប្បីវៀច ។

ព្រះថេរៈទូលថា សូមថ្វាយព្រះពរមហាបពិត្រ រទេះរមែងបាក់បែកដោយទម្ងន់នៃរតនៈហួសប្រមាណឬ ។ ព្រះរាជា ត្រាស់ថា បពិត្រលោកម្ចាស់ យ៉ាងនោះឯង ។ ព្រះថេរៈទូលថា សូមថ្វាយព្រះពរ ផែនដីក៏យ៉ាងនោះឯង រមែងញាប់ញ័រដោយទម្ងន់នៃធម៌លើសប្រមាណ ។

ម្យ៉ាងទៀត មហាបពិត្រ អាត្មានឹងចង្អុលបង្ហាញនូវហេតុនេះ ដើម្បីសម្ដែងកម្លាំងរបស់ព្រះពុទ្ធ សូមទ្រង់ស្ដាប់ហេតុដែលសមគួរដទៃ ដែលជាហេតុមិនឲ្យព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ កើតឡើងក្នុងពេលតែមួយ ។

មហាបពិត្រ បើព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ គប្បីកើតឡើងក្នុងខណៈព្រមគ្នាសោត វិវាទគប្បីកើតដល់បរិស័ទថា ព្រះពុទ្ធរបស់ពួកលោក ព្រះពុទ្ធរបស់ពួកខ្ញុំ បរិស័ទគប្បីបែកគ្នាជា ២ ចំណែក មហាបពិត្រ ប្រៀបដូចវិវាទ កើតដល់បរិស័ទរបស់អមាត្យដែលមានកម្លាំង ២ នាក់ថា នេះជាអមាត្យរបស់ពួកលោក នេះជាអមាត្យរបស់ពួកខ្ញុំ ។ បរិស័ទរមែងបែកជា ២ ចំណែកយ៉ាងណា សូមថ្វាយព្រះពរមហាបពិត្រ យ៉ាងនោះឯង ព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ បើគប្បីកើតឡើងក្នុងខណៈជាមួយគ្នា វិវាទទាំងឡាយគប្បីកើតឡើងដល់បរិស័ទថា ព្រះពុទ្ធរបស់ពួកលោក ព្រះពុទ្ធរបស់ពួកខ្ញុំ បរិស័ទគប្បីបែកចេញជា ២ ចំណែក សូមទ្រង់ស្តាប់ហេតុទី ១ នេះជាហេតុមិនឲ្យព្រះសម្មាសម្ពុទ្ធ ២ អង្គ កើតឡើងក្នុងពេលតែ ១ ។

ព្រះសម្មាសម្ពុទ្ធ ២ អង្គ រមែងមិនកើតឡើងក្នុងខណៈតែមួយ ដោយហេតុណា សូមមហាបពិត្រស្តាប់ហេតុនោះឲ្យក្រៃលែងឡើងទៀត ។

សូមថ្វាយព្រះពរ បើព្រះសម្មាសម្ពុទ្ធ ២ អង្គ គប្បីកើតឡើងក្នុងពេលតែមួយសោត ពាក្យថា ព្រះពុទ្ធជាបុគ្គលដ៏កំពូល ដូច្នេះ នុ៎ះក៏គប្បីជាពាក្យខុស ពាក្យថា ព្រះពុទ្ធជាច្បង ពាក្យថា ព្រះពុទ្ធជាបុគ្គលប្រសើរ ពាក្យថា ព្រះពុទ្ធជាបុគ្គលវិសេស ពាក្យថា ព្រះពុទ្ធជាបុគ្គលឧត្តម ពាក្យថា ព្រះពុទ្ធជាបុគ្គលបវរ ពាក្យថា ព្រះពុទ្ធជាបុគ្គលមិនមានបុគ្គលស្មើ ពាក្យថា ព្រះពុទ្ធ ជាបុគ្គលស្មើនឹងបុគ្គល ដែលមិនមានអ្នកណាស្មើ ពាក្យថា ព្រះពុទ្ធ ជាបុគ្គលមិនមានបុគ្គលប្រដូច ពាក្យថា ព្រះពុទ្ធ ទ្រង់ជាបុគ្គលមិនមានចំណែក

ប្រៀប ពាក្យថា ព្រះពុទ្ធ ជាបុគ្គលមិនមានបុគ្គលប្រៀប ដូច្នេះ ពាក្យនោះក៏គប្បីជាពាក្យខុស មហាបពិត្រ ទ្រង់ទទួលហេតុនេះឯងដោយភាពជាសេចក្តីពិតដែលជាហេតុមិនឲ្យព្រះពុទ្ធ ២ អង្គកើតឡើងក្នុងពេលតែមួយ ។

ម្យ៉ាងទៀត សូមថ្វាយព្រះពរ ការដែលព្រះពុទ្ធកើតឡើងក្នុងលោកមួយអង្គ នេះជាប្រក្រតី ដោយសភាវៈរបស់ព្រះពុទ្ធទាំងឡាយ ព្រោះហេតុអ្វី ព្រោះគុណរបស់ព្រះពុទ្ធជាសព្វញ្ញូ ជារបស់ធំ ។

សូមថ្វាយព្រះពរ វត្ថុដទៃណាដែលជារបស់ធំ វត្ថុនោះ ក៏ជារបស់មួយប៉ុណ្ណោះ មហាបពិត្រ ផែនដីជារបស់ធំ ផែនដីនោះ ជាផែនដីមួយប៉ុណ្ណោះ ភ្នំសិនេរុជារបស់ធំ ភ្នំសិនេរុនោះ ក៏ជារបស់មួយប៉ុណ្ណោះ អាកាសជារបស់ធំ អាកាសនោះ ក៏ជារបស់មួយប៉ុណ្ណោះ សក្កទេវរាជជារបស់ធំ សក្កទេវរាជនោះ ក៏ជាបុគ្គលមួយប៉ុណ្ណោះ មារជារបស់ធំ មារនោះ ក៏ជាបុគ្គលមួយប៉ុណ្ណោះ ព្រហ្មជារបស់ធំ ព្រហ្មនោះ ក៏ជាបុគ្គលមួយប៉ុណ្ណោះ ព្រះអរហន្តសម្មាសម្ពុទ្ធជារបស់ធំ ព្រះអង្គក៏តែមួយអង្គប៉ុណ្ណោះ វត្ថុទាំងនោះ មានផែនដីជាដើម រមែងកើតឡើងក្នុងទីណា ឱកាសរបស់ផែនដីដទៃជាដើម រមែងមិនមានក្នុងទីនោះ ព្រោះហេតុនោះ ទើបព្រះតថាគតអរហន្តសម្មាសម្ពុទ្ធមួយអង្គប៉ុណ្ណោះកើតឡើងក្នុងលោក ។

ព្រះរាជាត្រាស់ថា បពិត្រព្រះនាគសេន បញ្ហាលោកម្ចាស់ដោះស្រាយប្រពៃហើយ ដោយហេតុទាំងឡាយដែលជាគ្រឿងឧបមា ដូច្នេះ ។

បទថា **ឯកិស្សា លោកធាតុយា** បានដល់ ចក្កវាឡមួយ អធិប្បាយ

ថា ដំបូងលោកកាន់យកចក្កវាឡមួយម៉ឺន ដោយបទថា **ឯកិស្សា លោក-ធាតុយា** ដូច្នេះ ។ ការកំណត់ចក្កវាឡមួយម៉ឺនទាំងនោះ ដោយចក្កវាឡមួយនោះឯងក៏គួរ ដ្បិតថា ព្រះពុទ្ធទាំងឡាយ កាលកើតឡើង រមែងកើតក្នុងចក្កវាឡនេះប៉ុណ្ណោះ ។ កាលឋានៈនៃការកើតឡើង របស់ព្រះពុទ្ធទាំងឡាយ ដែលធម្មជាតិហាមហើយ ឋានៈនៃការកើតឡើងនៃស្ដេចចក្កពត្តិទាំងឡាយ ក៏ត្រូវហាមហើយនោះឯងថា ស្ដេចចក្កពត្តិទាំងឡាយ រមែងមិនកើតឡើងក្នុងចក្កវាឡដទៃៗ ក្រៅអំពីចក្កវាឡនេះ ។

ក្នុងបទថា **អបុព្វំ អចរិមំ** បានដល់ ឈ្មោះថា **បុព្វំ** ព្រោះមុនអំពីកាលប្រាកដនៃចក្ករតនៈ ឈ្មោះថា **ចរិមំ** ព្រោះក្រោយអំពីចក្ករតនៈនោះឯងអន្តរធានហើយ ។ ក្នុងពាក្យទាំងនោះ ការអន្តរធាននៃចក្ករតនៈមាន ២ គឺព្រោះការសោយទិវង្គតរបស់ស្ដេចចក្កពត្តិ ឬការទ្រទ្រង់បព្វជ្ជា ។ម្យ៉ាងទៀត ចក្ករតនៈនោះ កាលនឹងអន្តរធាន រមែងអន្តរធានក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃសោយទិវង្គត ឬការបួសរបស់ស្ដេចចក្កពត្តិ បន្ទាប់អំពីនោះការប្រាកដនៃស្ដេចចក្កពត្តិអង្គដទៃ ជាធម្មជាតិមិនបានហាម សួរថា ព្រោះហេតុអ្វីព្រោះស្ដេចចក្កពត្តិ ២ អង្គ មិនបានកើតឡើងព្រមគ្នាក្នុងចក្កវាឡមួយ ឆ្លើយថា ព្រោះការពារនូវវិវាទ ព្រោះមិនជារបស់អស្ចារ្យ និងព្រោះការមានអានុភាពច្រើននៃចក្ករ័តន៍ ។ ពិតហើយ កាលស្ដេចចក្កពត្តិ ២ អង្គកើតឡើងវិវាទគប្បីកើតឡើងថា ស្ដេចរបស់ពួកយើងធំ ស្ដេចរបស់ពួកយើងធំ ដូច្នេះម្យ៉ាងទៀត ស្ដេចចក្កពត្តិនឹងជាបុគ្គលមិនគួរអស្ចារ្យថា ក្នុងទ្វីបមួយមាន

ស្តេចចក្កពត្តិ និងក្នុងទ្វីបមួយទៀតនោះ ក៏មានស្តេចចក្កពត្តិ ដូច្នេះ ម្យ៉ាងទៀត អានុភាពរបស់ចក្ករតន៍ដែលអាចឲ្យនូវភាពជាធំ ដើម្បីភាពជាធំក្នុងទ្វីបទាំង ៤ ដែលមានទ្វីបតូច ២០០០ ជាបរិវារ គប្បីវិនាសទៅ ព្រោះហេតុនោះ ទើបស្តេចចក្កពត្តិ ២ អង្គ មិនកើតឡើងក្នុងចក្កវាឡតែមួយ ព្រោះវិវាទ ព្រោះមិនជាវត្ថុអស្ចារ្យ និងព្រោះអានុភាពច្រើននៃចក្ករតន៍ ។

ក្នុងបទថា **យំ ឥត្ថី អរហំ អស្ស សម្មាសម្ពុទ្ធោ** នេះ អធិប្បាយថា ភាពជាព្រះពុទ្ធដែលអាចឆ្លងលោក ព្រោះញ៉ាំងគុណ គឺសព្វញ្ញូឲ្យកើតឡើងនោះ ចូរស្ទះទុកសិន សូម្បីហេតុត្រឹមតែការតាំងបណិធាន ( ប្រាថ្នាជាព្រះពុទ្ធ ) ក៏រមែងមិនសម្រេចដល់ស្ត្រី ។

អភិនីហាររមែងសម្រេចព្រម ព្រោះធម្មសមោធាន ៨ ប្រការ គឺ

ភាពជាមនុស្ស ១ លិង្គសម្បត្តិ គឺមានភេទជាបុរស ១ មានហេតុ គឺសាងកុសលច្រើនគួរបានជាព្រះអរហន្ត ១ បានជួបព្រះសាស្តា ១ បានបួស ១ បរិបូរណ៍ដោយគុណ គឺបានឈានសមាបត្តិ និងអភិញ្ញា ១ ធ្វើកុសលដ៏ធំក្រៃលែង គឺលះបង់ជីវិត ១ មានឆន្ទៈ ១ ដូច្នេះ ។

ពិតហើយ ធម្មសមោធាននេះ ជាហេតុនៃការដល់ព្រមនៃការតាំងចិត្ត ព្រោះហេតុនោះ ភាពជាព្រះពុទ្ធរបស់ស្ត្រី អាចញ៉ាំងការតាំងចិត្តឲ្យដល់ព្រមនឹងមានមកអំពីណា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ស្ត្រីបានជាព្រះអរហន្តសម្មាសម្ពុទ្ធដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ

មិនមែនជាបច្ច័យ គឺថា ហេតុនុ៎ះ មិនដែលមានឡើយ ដូច្នេះ ។ ម្យ៉ាងទៀត ការសន្សំបុណ្យ ដែលបរិបូរណ៍ដោយអាការទាំងពួងនោះឯង ឲ្យកើតឡើង ព្រោះហេតុនោះ បុរសប៉ុណ្ណោះរមែងជាព្រះសម្មាសម្ពុទ្ធ មិនមែនស្ត្រីឡើយ ។

ក្នុងបទថា **យំ ឥត្ថី រាជា អស្ស ចក្កវត្តិ** ជាដើម អធិប្បាយថា លក្ខណៈទាំងឡាយ គឺមហាបុរិសលក្ខណៈ ៣២ ប្រការរបស់ស្ត្រី ឈ្មោះថា មិនបរិបូណ៌ ព្រោះមិនមានលក្ខណៈទាំងឡាយ មានគុយ្ហប្រទេសលាក់ក្នុងស្រោម ដូចគុយ្ហប្រទេសនៃគោ និងដំរីជាដើម ការដល់ព្រមដោយរតនៈ ៧ ក៏មិនបរិបូណ៌ ព្រោះមិនមានឥត្ថីរតនៈ ម្យ៉ាងទៀត អត្តភាពដែលក្រៃលែងជាងមនុស្សទាំងពួងក៏មិនមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ស្ត្រីបានជាស្តេចចក្កពត្តិ ដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យ គឺថា ហេតុនុ៎ះ មិនដែលមានឡើយ ដូច្នេះ ឋានៈ ៣ ភាពជាសក្កៈជាដើម ជាឋានៈខ្ពស់ ចំណែកភេទស្រី ជាភេទថោកថយ ព្រោះហេតុនោះ ស្រីគប្បីជាសក្កៈជាដើម ព្រះមានព្រះភាគ ទ្រង់បដិសេធហើយ ។

សួរថា ភេទស្រី មិនមានក្នុងព្រហ្មលោកយ៉ាងណា ភេទប្រុសក៏យ៉ាងនោះ ព្រោះហេតុនោះ មិនគួរពោលថា កាលបុរសគប្បីកើតជាព្រហ្ម នោះមិនមែនជាឋានៈ មិនមែនឬ ឆ្លើយថា មិនគប្បីពោល ក៏មិនមែន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុរសក្នុងលោកនេះ កើតឡើងក្នុងព្រហ្មលោកនោះមាន ។ ពិតហើយ ការកើតជាមហាព្រហ្ម ព្រះមានព្រះភាគទ្រង់

បំណងយកក្នុងពាក្យថា ភាពជាព្រហ្ម ។ ឯស្ត្រីចម្រើនឈានក្នុងលោកនេះ ធ្វើកាលកិរិយាហើយ រមែងចូលដល់ភាពជាសម្លាញ់ របស់ព្រហ្មបារិសជ្ជាទាំងឡាយ មិនមែនចូលដល់ភាពជាសម្លាញ់ របស់មហាព្រហ្មឡើយ តែបុរសមិនគប្បីពោលថា មិនកើតក្នុងព្រហ្មបារិសជ្ជានោះ ។ម្យ៉ាងទៀត ក្នុងព្រហ្មលោកនោះសូម្បីភេទទាំងពីរមិនប្រាកដ ព្រហ្មទាំងឡាយក៏មានសណ្ឋានជាបុរសប៉ុណ្ណោះ មិនមានជាសណ្ឋានជាស្រីឡើយ ព្រោះហេតុនោះ ទើបពាក្យដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ជាពាក្យល្អហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **កាយទុច្ចរិតស្ស** ជាដើម ពូជទាំងឡាយមានពូជស្ពៃ និងនទោងព្រៃជាដើម រមែងឲ្យផ្លែមានរសផ្អែមកើតឡើងមិនបាន រមែងឲ្យផ្លែដែលមិនគាប់ចិត្ត ដែលមិនមានរសផ្អែមនោះឯងកើតឡើង យ៉ាងណា កាយទុច្ចរិតជាដើម ក៏យ៉ាងនោះ រមែងមិនឲ្យកើតវិបាកដែលគួរពេញចិត្ត រមែងកើតវិបាកដែលមិនគួរពេញចិត្តនោះឯង ។ ពូជនៃអំពៅ ពូជនៃស្រូវសាលីជាដើម រមែងញុំាងផ្លែដែលគួរពេញចិត្ត មានរសល្អប៉ុណ្ណោះឲ្យកើត មិនញុំាងផ្លែដែលមិនគួរពេញចិត្តមានរសមិនឆ្ងាញ់ឲ្យកើតឡើង យ៉ាងណា កាយសុចរិតជាដើម រមែងឲ្យវិបាកដែលគួរពេញចិត្តឲ្យកើតឡើង ក៏យ៉ាងនោះ សមដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

គេបានពូជបែបណា គេបានផលបែបនោះដែរ អ្នកធ្វើល្អរមែង
បានផលល្អ អ្នកធ្វើអាក្រក់ រមែងបានផលអាក្រក់ ដូច្នេះ ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ដំណើរនុ៎ះ មិនមែនជា

ហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលវិបាករបស់កាយទុច្ចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តគប្បីកើតឡើង ការណ៍នុ៎ះ មិនមានឡើយ ដូច្នេះ ។

បទថា **សមត្តិ** ក្នុងបទថា **កាយទុច្ចរិតសមត្តិ** ជាដើម បានដល់សមត្តិ ៥ យ៉ាង គឺ **អាយូហនសមង្គិតា** ភាពជាអ្នកប្រកបដោយកម្ម ជាគ្រឿងប្រមូលមក ១ **ចេតនាសមង្គិតា** ភាពជាអ្នកប្រកបដោយចេតនា ១ **កម្មសមង្គិតា** ភាពជាអ្នកប្រកបដោយកម្ម ១ **វិបាកសមង្គិតា** ភាពជាអ្នកប្រកបដោយវិបាក ១ **ឧបដ្ឋានសមង្គិតា** ភាពជាអ្នកប្រកបដោយការប្រាកដ ១ ។

ក្នុងការប្រកបទាំងនោះ ក្នុងខណៈនៃការប្រមូលមកនូវកុសលកម្ម និងអកុសលកម្ម ហៅថា **អាយូហនសមង្គិតា** ។ ចេតនាសមង្គិតាក៏ដូចគ្នា ។ សត្វទាំងអស់ មិនសម្រេចអរហត្តដរាបណា ដរាបនោះ ព្រះមានព្រះភាគត្រាស់ហៅថា ភាពជាអ្នកប្រកបដោយកម្ម ព្រោះសំដៅយកកម្មដែលសមគួរដល់វិបាកដែលបានសន្សំក្នុងកាលមុន នេះឈ្មោះថា **កម្មសមង្គិតា** ។ តែវិបាកសមង្គិតា គប្បីជ្រាបក្នុងខណៈនៃការឲ្យផលនោះឯង ។

ដរាបណាសត្វទាំងឡាយ មិនទាន់សម្រេចអរហត្ត ដរាបនោះ និមិត្តនៃការកើតឡើង រមែងប្រាកដយ៉ាងនេះ គឺនរករមែងប្រាកដដោយអាការដែលប្រាកដ មានអណ្ដាតភ្លើងក្នុងលោហកុម្ភីជាដើម ដល់សត្វទាំងនោះដែលចុតិអំពីភពនោះៗ ហើយនឹងកើតឡើងក្នុងនរក ផ្ទៃរបស់មាតារមែងប្រាកដដល់សត្វទាំងឡាយដែលដល់នូវភាពជាគព្ភសេយ្យកសត្វ ទេវលោករមែងប្រាកដ

ដោយអាការដែលប្រាកដ មានដើមកប្បព្រឹក្ស និងវិមានជាដើម ដល់សត្វទាំងឡាយដែលកើតឡើងក្នុងទេវតាទាំងឡាយ ដោយអាការយ៉ាងនេះ ឈ្មោះថា **ឧបដ្ឋានសមង្គិតា** ព្រោះសត្វទាំងនោះ មិនផុតទៅអំពីអាការប្រាកដនៃនិមិត្តក្នុងការកើតដូចពោលមកនេះ ។

ឧបដ្ឋានសមង្គិតានោះឯង រមែងប្រែប្រួលបាន សមង្គីដ៏សេស មិនប្រែប្រួល ។ ពិតហើយ កាលនរកប្រាកដហើយ ទេវលោករមែងប្រាកដក៏បាន កាលទេវលោកប្រាកដហើយ នរករមែងប្រាកដក៏បាន កាលមនុស្សលោកប្រាកដហើយ កំណើតសត្វតិរច្ឆានប្រាកដក៏បាន កាលកំណើតនៃសត្វតិរច្ឆានប្រាកដហើយ មនុស្សលោករមែងប្រាកដក៏បាន ក្នុងសេចក្ដីនេះមានរឿងនេះជាឧទាហរណ៍ដូចតទៅ

បានឮថា នៅឯជើងភ្នំ ឈ្មោះសោណៈ មានធម្មកថិកមួយអង្គ ឈ្មោះសោណត្ថេរ នៅត្រង់អចេលវិហារ[១] បិតារបស់លោកជាព្រានព្រៃ ឈ្មោះសុនខវាជិកៈ ព្រះថេរៈឃាត់បិតាដូចម្ដេច ក៏មិនអាចឲ្យតាំងនៅក្នុងសំវរៈ ទើបគិតថា បិតាគួរអាណិត កុំវិនាសឡើយ ដូច្នេះ ទើបឲ្យបិតាបួសទាំងដែលគាត់មិនចង់បួស បានបួសហើយ ក្នុងកាលឯចាស់ កាលបិតាដេកលើគ្រែសម្រាប់ស្លាប់ នរកបានប្រាកដហើយ គឺមានពួកឆ្កែធំៗ មកអំពីជើងភ្នំសោណៈចោមរោម ហាក់បីដូចចង់ទំពាស៊ី ។ បិតារបស់ព្រះថេរៈ កើតភ័យធំទើបហៅព្រះថេរៈថា នែបាសោណៈ ចូរកូនឃាត់ នែបាសោណៈ ចូរកូន

---

១- ក្នុងទី២ៈ ជាបិប្ផលិវិហារ ។

ឃាត់ ដូច្នេះ ។ ព្រះថេរៈសួរថា តើមានរឿងអ្វី បិតារបស់លោកពោលថា កូនមិនឃើញទេឬ ហើយប្រាប់ហេតុប្រព្រឹត្តទៅនោះ ។

ព្រះថេរៈត្រិះរិះថា បិតារបស់បុគ្គលដូចគ្នានឹងអាត្មាអញ តើនឹងកើតក្នុងនរកបានដូចម្តេច អញនឹងជាទីពឹងរបស់បិតា ដូច្នេះហើយ ឲ្យសាមណេរទាំងឡាយនាំផ្កាផ្សេងៗ មក ហើយធ្វើនូវការបូជា រោយដោយផ្កា និងបូជាត្រង់តាំងដែលជាលានរបស់ព្រះចេតិយ និងលានពោធិព្រឹក្សទាំងឡាយ ហើយនាំបិតាមកកាន់លានព្រៃព្រះចេតិយដោយគ្រែ គឺសែងទាំងគ្រែមក ឲ្យដេកលើគ្រែ រួចពោលនឹងបិតាថា បពិត្រមហាថេរៈ ការបូជារបស់ខ្ញុំនេះ ធ្វើដើម្បីជាប្រយោជន៍ដល់លោកម្ចាស់ សូមលោកម្ចាស់ពោលថា បពិត្រព្រះមានព្រះភាគ នេះជាទុគ្គតបណ្ណាការ ហើយថ្វាយបង្គំព្រះមានព្រះភាគ ញុំាងចិត្តឲ្យជ្រះថ្លា ។

ព្រះថេរៈចាស់នោះ ឃើញការបូជា កាលធ្វើយ៉ាងនោះ ញុំាងចិត្តឲ្យជ្រះថ្លាហើយ ខណៈនោះឯង ទេវលោកប្រាកដហើយ ដល់ព្រះថេរៈចាស់ គឺនន្ទនវ័ន ចិត្តលតាវ័ន មិស្សកវ័ន ផារុសកវ័ន វិមាន និងទេវនាដកៈទាំងឡាយ មានហើយ ហាក់បីដូចឈរចោមរោមព្រះថេរៈនោះ ។ ព្រះថេរៈចាស់នោះពោលថា នែកូនសោណៈ ចូរកូនចៀសចេញទៅ នែកូនសោណៈ ចូរកូនចៀសចេញទៅ ដូច្នេះ ។ ព្រះថេរៈពោលថា តើមានរឿងអ្វី ព្រះថេរៈចាស់ឆ្លើយថា មាតាទាំងឡាយ របស់លោកកំពុងមក ។ ព្រះថេរៈគិតថា ស្ថានសួគ៌ប្រាកដឡើងដល់ព្រះថេរៈចាស់ហើយ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាប

ថា **ឧបដ្ឋានសមង្គិតា** រមែងប្រែប្រួលបាន ដោយប្រការដូច្នេះ ។

បណ្ដាការប្រកបទាំងនោះ បទថា **កាយទុច្ចរិតសមង្គី** ជាដើម ព្រះមានព្រះភាគ ត្រាស់ហើយក្នុងទីនេះ ដោយអំណាចនៃការប្រកបដោយភាពជាអ្នកប្រកបដោយកម្មជាគ្រឿងប្រមូលមក ភាពជាអ្នកប្រកបដោយចេតនា ភាពជាអ្នកប្រកបដោយកម្ម ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

**អធិប្បាយកម្មាំងទី ១ ចប់**

# អធិប្បាយកម្មាំងទី ២

[ ៧៤ ] ក្នុងនិទ្ទេសនៃកម្មាំងទី ២ បទថា **គតិសម្បត្តិប្បដិពាឡ្ហានិ** បានដល់ កម្មសមាទានដែលជាបាបដែលគតិសម្បត្តិហាមឃាត់ ការពារ និងបដិសេធហើយ ។ ក្នុងបទដ៏សេសក៏ន័យនេះឯង ។

ម្យ៉ាងទៀត ក្នុងអធិការនេះ បទថា **គតិសម្បត្តិ** នេះ បានដល់ គតិដែលបរិបូណ៌ គឺទេវលោក និងមនុស្សលោក ។

បទថា **គតិវិបត្តិ** បានដល់ គតិអាក្រក់ គឺអបាយភូមិ ៤ ។ ការសម្រេចដោយល្អក្នុងអត្តភាព ឈ្មោះថា **ឧបធិសម្បត្តិ** ការមានអត្តភាពអាក្រក់ ឈ្មោះថា **ឧបធិវិបត្តិ** ។ កាលដែលបរិបូណ៌ ពោល គឺកាលដែលព្រះរាជាល្អ និងមនុស្សល្អឈ្មោះថា **កាលសម្បត្តិ** ។ កាលដែលវិបត្តិ ពោល

គឺកាលដែលមានព្រះរាជាអាក្រក់ និងមនុស្សអាក្រក់ ឈ្មោះថា **កាលវិបត្តិ** ។ ការប្រកបដោយប្រពៃ ឈ្មោះថា **បយោគសម្បត្តិ** ការប្រកបក្នុងផ្លូវខុស ឈ្មោះថា **បយោគវិបត្តិ** ។

ក្នុងគតិសម្បត្តិជាដើមនោះ បុគ្គលខ្លះបានធ្វើបាបកម្មច្រើន បាបកម្មនោះគប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងគតិវិបត្តិ តែបុគ្គលនោះ កើតឡើងក្នុងគតិសម្បត្តិ គឺក្នុងទេវតា ឬមនុស្សដោយកល្យាណកម្មណាមួយ វារៈនៃអកុសល រមែងមិនមានក្នុងឋានៈបែបនោះ វារៈនៃកុសលប៉ុណ្ណោះ រមែងមានដោយចំណែកមួយ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា កម្មទាំងនោះ គឺបាបកម្មដែលគតិសម្បត្តិហាមឃាត់ ទើបមិនឲ្យផលដល់បុគ្គលនោះ ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើបាបកម្មច្រើន បាបកម្មទាំងនោះ ក៏គប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងឧបធិវិបត្តិ តែបុគ្គលនោះ តាំងនៅក្នុងឧបធិសម្បត្តិ មានសណ្ឋាន និងអវយវៈតូចធំតាំងនៅល្អហើយ មានរូបស្អាត គួរសរសើរ ដូចគ្នានឹងកូនគោដ៏ប្រសើរ ដោយកុសលកម្មណាមួយ បើកើតជាទាសៈក្នុងផ្ទៃរបស់ទាសី អត្តភាពដែលល្អបែបនេះ រមែងមិនសមគួរដល់ការងារដែលសៅហ្មង ព្រោះហេតុនោះ ទើបពួកទាសៈ មិនប្រើឲ្យបុគ្គលនោះធ្វើការងាររបស់អ្នកចិញ្ចឹមសត្វ អ្នកឃ្វាលសេះ អ្នកឃ្វាលគោជាដើម ឲ្យស្លៀកសំពត់សាច់ម៉ដ្ឋ តាំងទុកក្នុងតំណែងជាភណ្ឌាគារិក គឺនាយឃ្លាំងជាដើម បើជាស្រី ពួកទាសៈ មិនឲ្យធ្វើការដាំបាយដោយដៃជាដើម តែនឹងឲ្យសំពត់ និង

គ្រឿងប្រដាប់ ធ្វើស្រីនោះ ឲ្យជាអ្នករៀបចំទីដេក ឬតាំងទុកក្នុងតំណែងជាបុគ្គលស្និទ្ធស្នាល ដូចទេពធីតា ឈ្មោះ សោមទេវី ។

បានឮថា ក្នុងកាលនៃព្រះបាទកាតិករាជ ពួកអមាត្យទាំងឡាយ ចាប់ជនទាំងឡាយជាច្រើន ដែលលួចបរិភោគសាច់គោ បង្ហាញចំពោះព្រះរាជា ជនទាំងនោះ ត្រូវព្រះរាជាត្រាស់សួរថា ពួកអ្នកអាចឲ្យថ្លៃពិន័យឬ ក៏ក្រាបទូលថា ពួកទូលព្រះបង្គំមិនអាច ដូច្នេះ ។ លំដាប់នោះ ទើបពួកអមាត្យឲ្យជនទាំងនោះ សម្អាតត្រង់លានព្រះរាជវាំង ។ កូនស្រីម្នាក់របស់ជនទាំងនោះ មានរូបស្អាត គួរមើល គួរសរសើរ ព្រះរាជាទតឃើញកូនស្រីនោះ ទើបទ្រង់នាំមកតាំងទុកនៅក្នុងតំណែងរាជវល្លភៈ ។ ញាតិទាំងឡាយដ៏សេសក៏មានជីវិតនៅជាសុខ ដោយអានុភាពរបស់ទារិកានោះ ។ ពិតហើយ ក្នុងអត្តភាពបែបនោះ សូម្បីបាបកម្មទាំងឡាយក៏មិនអាចឲ្យផល ។ ព្រះតថាគតរមែងដឹងថា បាបកម្មទាំងឡាយដែលជាឧបធិសម្បត្តិ ហាមឃាត់ ទើបមិនឲ្យផល ដោយប្រការដូច្នេះ ។

បុគ្គលខ្លះធ្វើបាបកម្មច្រើន បាបកម្មទាំងនោះគប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងកាលវិបត្តិ ។ តែបុគ្គលនោះកើតឡើងហើយ ដោយកុសលកម្មណាមួយ ក្នុងកាលមានព្រះរាជាល្អ និងមានមនុស្សល្អ ដែលជាសម័យកើតឡើងនៃមនុស្សក្នុងបឋមកប្ប ឬស្តេចចក្កពត្តិ ឬព្រះពុទ្ធទាំងឡាយ កាលបុគ្គលទាំងនោះកើតឡើងហើយ ក្នុងកាលនោះបែបនោះ ឱកាសដើម្បីឲ្យវិបាករបស់អកុសល រមែងមិនមាន ឱកាសរបស់កុសលតែម្យ៉ាងប៉ុណ្ណោះ

មានដោយចំណែកមួយ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា បាបកម្មទាំងឡាយដែលកាលសម្បត្តិហាមឃាត់ ទើបមិនឲ្យផល ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើបាបកម្មច្រើន បាបកម្មទាំងនោះ គប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងបយោគវិបត្តិ តែបុគ្គលនោះ តាំងនៅក្នុងបយោគ-សម្បត្តិ ដោយកុសលកម្មណាមួយ វៀរចាកបាណាតិបាតជាដើម ហើយញ៉ាំងកាយសុចរិត វចីសុចរិត និងមនោសុចរិតទាំងឡាយឲ្យពេញបរិបូណ៌ ។ ឱកាសនៃការឲ្យផលរបស់អកុសលក្នុងឋានៈបែបនោះរមែងមិនមាន ឱកាសរបស់កុសលប៉ុណ្ណោះ មានដោយចំណែកមួយ ។ ព្រះតថាគតទ្រង់ជ្រាបថា បាបកម្មទាំងឡាយដែលបយោគសម្បត្តិហាមឃាត់ ទើបមិនឲ្យផល ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើបាបកម្មច្រើន បាបកម្មទាំងនោះ មិនគប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងគតិសម្បត្តិ តែបុគ្គលនោះកើតក្នុងគតិវិបត្តិដោយបាបកម្មណាមួយនោះឯង បាបកម្មទាំងនោះចូលដល់ហើយ ក៏ឲ្យដល់បុគ្គលនោះ ក្នុងគតិវិបត្តិនោះគ្រប់ៗ គ្នា គឺឲ្យកើតក្នុងនរក តាមកាលដែលគួរ ក្នុងកំណើតសត្វតិរច្ឆានតាមកាលដែលគួរ ក្នុងបិត្តិវិស័យតាមកាលដែលគួរ ក្នុងអសុរកាយតាមកាលដែលគួរ រមែងមិនឲ្យងើបក្បាលឡើងចាកអបាយអស់កាលយូរ ។ ព្រះតថាគតទ្រង់ជ្រាបថា បាបកម្មទាំងឡាយដែលមិនអាចឲ្យផល ព្រោះគតិសម្បត្តិហាមឃាត់ ដល់គតិវិបត្តិហើយ រមែងឲ្យផលបាន ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀតដែលធ្វើបាបកម្មច្រើន បាបកម្មទាំងនោះមិនគប្បីឲ្យផល ដល់បុគ្គលដែលតាំងនៅក្នុងឧបធិសម្បត្តិ តែបុគ្គលនោះ តាំងនៅក្នុងឧបធិ-វិបត្តិដោយបាបកម្មមួយនោះឯង ឲ្យជាអ្នកមានពណ៌សម្បុរអាក្រក់ មានរូបអាក្រក់ មានសណ្ឋានមិនល្អ គួរខ្ពើម ដូចគ្នានឹងបិសាច ។ បើបុគ្គលនោះកើតជាទាសៈក្នុងផ្ទៃនៃទាសី រមែងគួរដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបពួកចៅហ្វាយឲ្យបុគ្គលនោះធ្វើការងារដែលសៅហ្មងគ្រប់កាល ដោយហោចរហូតដល់ការងាររបស់អ្នកចាក់សំរាម បើជាស្រី បាបកម្មរមែងគួរដល់ស្រីនោះ ព្រោះហេតុនោះ ទើបពួកចៅហ្វាយប្រើនាងឲ្យធ្វើការងារដែលសៅហ្មង មានការជាំបាយដោយដៃជាដើម គ្រប់យ៉ាង ។ សូម្បីកើតក្នុងផ្ទះនៃត្រកូល ( មិនមែនផ្ទះទាសៈ ) រាជបុរសទាំងឡាយ ដែលជាអ្នកទារពន្ធ រមែងធ្វើនូវការសម្គាល់ ( ស្មាន ) ស្រីនេះថាជាទាសីក្នុងផ្ទះ ( របស់ខ្លួន ) ទើបចាប់ចងទៅ ដូចសម្គាល់ ( ស្មាន ) ស្រីម្ចាស់ផ្ទះ ( ប្រពន្ធ ) របស់មហាកុដុម្ពិកៈ ក្នុងស្រុកកោតលវាបី ថាជាទាសីក្នុងផ្ទះ ។ ព្រះតថាគតទ្រង់ជ្រាបថា បាបកម្មទាំងឡាយដែលមិនអាចឲ្យផល ព្រោះត្រូវឧបធិវិបត្តិហាមឃាត់ ដល់ឧបធិវិបត្តិហើយ រមែងឲ្យផល ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើបាបកម្មច្រើន បាបកម្មទាំងនោះ មិនគប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងកាលសម្បត្តិ តែបុគ្គលនោះ កើតក្នុងកាលវិបត្តិដោយបាបកម្មណាមួយ គឺក្នុងកាលដែលមានព្រះរាជាអាក្រក់ មនុស្សអាក្រក់ ឬក្នុងកាលដែលសត្វមានអាយុក្ស័យ ១០ ឆ្នាំ ដែលជាកាលអាក្រក់ឥត

តម្លៃ ក្នុងកាលបែបនោះសូម្បីបញ្ចគោរសរមែងវិនាសទៅដោយច្រើន ស្មៅគែលលក ឈ្មោះថា ជាអាហារដ៏ប្រសើរ ។ បុគ្គលនោះ កើតក្នុងមនុស្សលោកក៏ពិត តែបុគ្គលនោះក៏មានការរស់នៅដូចគ្នានឹងសត្វម្រឹគ ឬសត្វចិញ្ចឹមសម្រាប់ជាអាហារ ក្នុងកាលបែបនេះ ឱកាសនៃការឲ្យផលរបស់កុសលមិនមាន ឱកាសឲ្យផលនៃអកុសលប៉ុណ្ណោះ រមែងមានដោយចំណែកមួយ ។ ព្រះតថាគត ទ្រង់ជ្រាបថា បាបកម្មដែលមិនអាចឲ្យផល ព្រោះត្រូវកាលសម្បត្តិហាមឃាត់ ដល់កាលវិបត្តិហើយរមែងឲ្យផល ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើបាបកម្មច្រើន បាបកម្មនោះ មិនគប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងបយោគសម្បត្តិ តែបុគ្គលនោះតាំងនៅក្នុងបយោគវិបត្តិហើយ រមែងធ្វើអកុសលកម្ម ១០ មានបាណាតិបាតជាដើម ។ រាជបុរសទាំងឡាយ ចាប់បុគ្គលដែលធ្វើកម្មគ្រោតគ្រាត មួយអន្ទើដោយកស្តុតាងបង្ហាញចំពោះព្រះរាជា ព្រះរាជា ទ្រង់ឲ្យធ្វើកម្មករណ៍ជាច្រើន ហើយក៏ឲ្យសម្លាប់ចោល ។ ព្រះតថាគតទ្រង់ជ្រាបថា បាបកម្មដែលមិនអាចឲ្យផល ព្រោះត្រូវបយោគសម្បត្តិហាមឃាត់ ដល់បយោគវិបត្តិហើយ រមែងឲ្យផល ដោយប្រការដូច្នេះ ។

បាបកម្មដែលសម្បត្តិទាំង ៤ គឺគតិសម្បត្តិ ឧបធិសម្បត្តិ កាលសម្បត្តិ បយោគសម្បត្តិហាមឃាត់ ទើបមិនឲ្យផល តែដល់វិបត្តិ ៤ ទើបឲ្យផល ដោយប្រការដូច្នេះ ។

ដូចបុរសពួកខ្លះនោះឯង គប្បីឲ្យព្រះរាជាពេញព្រះរាជហឫទ័យ ដោយ

ការងារណាមួយ ពេលនោះ ព្រះរាជាគប្បីឲ្យឋានន្តរ ហើយក៏ឲ្យជនបទដល់បុរសនោះ បុរសនោះមិនអាចប្រើប្រាស់ជនបទនោះដោយប្រពៃ គប្បីធ្វើឲ្យវិនាសទៅ ដូចកញ្ចប់បាយ ដែលពានរកាន់ទៅហើយ បុរសនោះឃើញវត្ថុដែលគាប់ចិត្តឯណា គឺយាន ឬពាហនៈ ទាសា ឬទាសី ចម្ការ ឬស្រែនៃបុគ្គលណាក៏កាន់យកវត្ថុទាំងពួងនោះដោយកម្លាំងបាយ ពួកមនុស្សមិនអាចពោលនូវពាក្យណាមួយ ដោយសម្គាល់ថា បុរសនេះជារាជវល្លភៈ ដូច្នេះ បុរសនោះ គប្បីប្រព្រឹត្តខុសចំពោះវល្លភៈដែលជារាជមហាមាត្យដទៃ រាជមហាមាត្យនោះ ចាប់បុរសនោះ ឲ្យវាយដំណំហើយឲ្យអូស ដោយខ្នងពាល់ត្រូវផែនដី ចូលទៅគាល់ព្រះរាជា ក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះសម្មតិទេព បុរសឈ្មោះនោះ បំផ្លាញជនបទរបស់ព្រះអង្គ ដូច្នេះ ព្រះរាជាត្រាស់ឲ្យចងដាក់ក្នុងគុក ហើយឲ្យរាជបុរសវាយស្គរប្រកាសក្នុងព្រះនគរថា បុរសឈ្មោះនោះប្លន់ទ្រព្យរបស់អ្នកណា ពួកមនុស្សមកហើយ គប្បីបន្លឺកឡើង ដោយសំឡេងរាប់ពាន់ថា វត្ថុនេះរបស់ខ្ញុំ ដែលបុរសនេះកាន់យកហើយ វត្ថុនេះរបស់ខ្ញុំដែលបុរសនេះកាន់យកហើយ ដូច្នេះ ៗ ព្រះរាជាកាន់តែពិរោធខ្លាំងឡើង ទើបធ្វើបុរសនោះឲ្យលំបាក ក្នុងគុកដោយប្រការផ្សេងៗ ហើយឲ្យប្រហារជីវិត ត្រាស់ថា ចូរពួកអ្នកទៅ ចូរអូសបុរសនោះទៅចោលក្នុងព្រៃខ្មោច ហើយនាំច្រវាក់ត្រឡប់មក បណ្ឌិតគប្បីជ្រាបឧបមាឧបមេយ្យនេះយ៉ាងនេះដូចតទៅ

ក្នុងកាលនៃបុថុជ្ជន សូម្បីកើតក្នុងស្ថានសួគ៌ដោយបុញ្ញកម្មណាមួយនោះ

ឯង ប្រៀបដូចកាលដែលបុរសនោះ ញុំាងព្រះរាជា ឲ្យពេញព្រះហឫទ័យ ដោយការងារឯណានីមួយនោះឯង ហើយបានឋានន្តរ ។ កាលដែលអកុសលកម្មមិនបានឱកាសឲ្យផលក្នុងកាលបុថុជ្ជននេះកើតក្នុងស្ថានសួគ៌ ប្រៀបដូចកាលដែលបុគ្គលណាមួយ មិនអាចពោលពាក្យណាមួយក្នុងកាលបុរសនោះបំផ្លាញជនបទ ហើយកាន់យកទ្រព្យរបស់មនុស្សទាំងឡាយ ។ កាលដែលបុរសនេះឃ្លាតចាកស្ថានសួគ៌ហើយ កើតក្នុងនរក ប្រៀបដូចកាលដែលបុរសនោះក្នុងថ្ងៃមួយប្រព្រឹត្តខុសក្នុងរាជវល្លភៈណាមួយ ត្រូវពួករាជវល្លភៈនោះក្រោធហើយឲ្យវាយ ហើយទូលដល់ព្រះរាជាឲ្យទ្រង់ចងដាក់ក្នុងគុក ។ កាលដែលអកុសលកម្មទាំងពួង មកប្រជុំគ្នាឲ្យផល កាលបុថុជ្ជននោះ កើតក្នុងនរក ប្រៀបដូចការស្រែករបស់មនុស្សទាំងឡាយថា ទ្រព្យនេះ របស់ខ្ញុំ ដែលបុរសនេះ កាន់យកហើយ ទ្រព្យនេះ របស់ខ្ញុំ ដែលបុរសនេះកាន់យកហើយ ។ កាលដែលបុថុជ្ជនងើបក្បាលឡើងអំពីនរកមិនបាន ត្រូវឆេះក្នុងនរកអស់កប្បដោយវិបាកកម្មដទៃទៀត ក្នុងកាលដែលកម្មនីមួយៗ អស់ហើយ ប្រៀបដូចកាលនាំបុរសនោះទៅចោលក្នុងព្រៃខ្មោច ហើយនាំប្រវាក់ត្រឡប់មក ។ ពិតហើយ សត្វដែលត្រូវឆេះក្នុងនរកអស់មួយកប្ប ព្រោះធ្វើកម្មដែលតាំងនៅអស់កប្ប មិនមែនតែម្នាក់ មិនមែនតែ ២ នាក់ មិនមែន ១០០ នាក់ មិនមែន ១០០០ នាក់ បានឮថា សត្វទាំងឡាយដែលត្រូវឆេះដោយអាការយ៉ាងនេះ ហួសប្រមាណនឹងរាប់ ។

ក្នុងពាក្យទាំងឡាយ មានពាក្យថា កម្មសមាទានដ៏ល្អពួកខ្លះ មានគតិ-

វិបត្តិហាមឃាត់ មិនឲ្យផលក៏មានជាដើម បណ្ឌិតគប្បីប្រកបសេចក្តីយ៉ាងនេះ ។

បុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើកុសលកម្មច្រើន កុសលកម្មនោះគប្បីឲ្យផលដល់បុគ្គល ដែលតាំងនៅក្នុងគតិសម្បត្តិ តែបើបុគ្គលនោះ ទៅកើតក្នុងគតិវិបត្តិ គឺក្នុងនរក ឬក្នុងអសុរកាយដោយបាបកម្មឯណានីមួយ ក្នុងឋានៈបែបនេះ កុសលរមែងមិនអាចឲ្យផល អកុសលប៉ុណ្ណោះ ឲ្យផល ដោយចំណែកមួយ ។ ព្រះតថាគតទ្រង់ជ្រាបថា កុសលកម្មទាំងនោះនៃបុគ្គលនោះ ដែលគតិវិបត្តិហាមឃាត់ ទើបមិនឲ្យផល ដូច្នេះ ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត បានធ្វើកុសលកម្មជាច្រើន កុសលកម្មនោះ គប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងឧបធិសម្បត្តិ តែបើបុគ្គលនោះ តាំងនៅក្នុងឧបធិវិបត្តិដោយបាបកម្មឯណានីមួយ ជាអ្នកមានពណ៌សម្បុរអាក្រក់ ដូចគ្នានឹងបិសាច ។ សូម្បីបុគ្គលនោះកើតក្នុងរាជត្រកូលដោយអំណាចឥតអំពីបិតាទៅ រមែងមិនបានរាជសម្បត្តិ ព្រោះថា ប្រយោជន៍អ្វី ដោយរាជសម្បត្តិសម្រាប់បុគ្គលមិនមានសិរីនេះ ។ សូម្បីកើតក្នុងផ្ទះរបស់សេនាបតីជាដើមក៏មិនបានតំណែងសេនាបតី ឬក៏តំណែងសេដ្ឋីជាដើម ។ ដើម្បីការជាក់ច្បាស់នៃអត្ថនេះ គប្បីជ្រាបរឿងព្រះបាទទីបរាជដូចតទៅនេះ

## រឿងព្រះបាទទីបរាជ

បានឮថា ព្រះរាជា កាលព្រះរាជបុត្តប្រសូតហើយ ទ្រង់ជ្រះថ្លាក្នុងព្រះទេវី ទើបទ្រង់ប្រទានពរ ព្រះទេវីក៏ទទួលពរទុក ។ ក្នុងកាលព្រះរាជកុមារ

មានព្រះជន្ម ៧ ឆ្នាំ បានឲ្យរាជបុរសនាំមាន់មកដល់គ្នាត្រង់លានព្រះរាជវាំង មាន់មួយហើរទៅហើយ ទម្លាយព្រះនេត្រទាំងពីររបស់ព្រះរាជកុមារ ។ ព្រះទេវីជាព្រះមាតាព្រះតម្រិះថា អញនឹងទូលសូមរាជសម្បត្តិ ក្នុងកាលព្រះរាជឱរសមានព្រះជន្មបាន ១៥ ឬ ១៦ ឆ្នាំ ទើបយាងទៅគាល់ព្រះរាជា ទូលថា បពិត្រព្រះសម្មតិទេព ក្នុងកាលព្រះរាជកុមារប្រសូតហើយ ទ្រង់បានប្រទានពរដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់ទទួលពរនោះ ហើយរង់ចាំ ឥឡូវនេះ ខ្ញុំម្ចាស់នឹងទទួលយកពរនោះ ដូច្នេះ ព្រះរាជាត្រាស់ថា សាធុទេវី ចូរនាងទទួលយកចុះ ព្រះទេវីទូលថា បពិត្រព្រះសម្មតិទេព របស់ណាមួយ ឈ្មោះថា ខ្ញុំម្ចាស់មិនបានហើយអំពីសម្នាក់របស់ព្រះអង្គមិនមាន តែឥឡូវនេះ ខ្ញុំម្ចាស់សូមរាជសម្បត្តិដើម្បីព្រះរាជឱរសរបស់ខ្ញុំម្ចាស់ ព្រះរាជាត្រាស់ថា នែទេវី បុត្តរបស់នាង មានអវយវៈមិនសមប្រកប យើងមិនអាចឲ្យរាជសម្បត្តិដល់បុត្តរបស់នាងបានឡើយ ដូច្នេះ ព្រះទេវីទូលថា ទ្រង់មិនអាចប្រទានពរដែលគាប់ចិត្តដល់ខ្ញុំម្ចាស់ ហេតុអ្វីក៏ទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ ក្នុងកាលមុន ។ ព្រះរាជាកាលត្រូវបៀតបៀនយ៉ាងក្រៃលែង ទើបត្រាស់ថា យើងអាចឲ្យរាជសម្បត្តិ ក្នុងលង្កាទ្វីបទាំងមូល ដល់ឱរសរបស់នាង ចូរឲ្យរាជបុរសលើកស្វេតច្ឆត្រត្រង់នាគទីបហើយសោយរាជ្យចុះ ហើយទ្រង់បញ្ជូនទៅកាន់នាគទីប ទើបរាជបុត្តនោះបានព្រះនាមថា ព្រះបាទទីប បើព្រះបាទទីបរាជ មិនមានចក្ខុពិការសោត ទ្រង់នឹងបានរាជសម្បត្តិ ដែលចោមរោមដោយសម្បត្តិទាំងពួងក្នុងតម្ពបណ្ណិទ្វីបទាំងមូលដែលមានទំហំ ១៥០ យោជន៍ជាប្រមាណ ។

ព្រះតថាគតទ្រង់ជ្រាបថា កុសលកម្មទាំងឡាយ ដែលឧបធិវិបត្តិហាមឃាត់ ទើបមិនឲ្យផល ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត បានធ្វើកុសលកម្មជាច្រើន កុសលកម្មនោះ គប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងកាលសម្បត្តិ តែបុគ្គលនោះ កើតក្នុងកាល-វិបត្តិដោយបាបកម្មឯណានីមួយ គឺក្នុងកាលនៃព្រះរាជាអាក្រក់ និងមនុស្សអាក្រក់ ក្នុងកាលអាក្រក់ ( ខាងចុងកប្ប ) មិនមានតម្លៃ មានអាយុតិចក្នុងកាលបែបនោះ កុសលកម្មមិនអាចឲ្យផល ។ ព្រះតថាគតទ្រង់ជ្រាបថា កុសលកម្មដែលកាលវិបត្តិហាមឃាត់ រមែងមិនឲ្យផល ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើកុសលកម្មច្រើន កុសលកម្មទាំងនោះ គប្បីឲ្យផលដល់បុគ្គល ដែលតាំងនៅក្នុងបយោគសម្បត្តិ តែបើបុគ្គលនេះ តាំងនៅក្នុងបយោគវិបត្តិ គឺរមែងសម្លាប់សត្វ ។បេ។ រមែងញុាំងកាពជាអ្នកទ្រុស្តសីលទាំងពួងឲ្យពេញ ព្រោះហេតុនោះ ទើបត្រកូលទាំងឡាយ សូម្បីមានជាតិស្មើគ្នា ក៏រមែងមិនធ្វើអាវាហៈ និងវិវាហមង្គលជាមួយត្រកូលដែលទ្រុស្តសីលនោះ រមែងវៀរឆ្ងាយ ដោយគិតថា បុរសបែបនេះ ជាអ្នកលេងស្រី ជាអ្នកលេងសុរា ជាអ្នកលេងល្បែង កុសលកម្មមិនអាចឲ្យផល ។

ព្រះតថាគតទ្រង់ជ្រាបថា កុសលកម្មដែលបយោគវិបត្តិហាមឃាត់ហើយ រមែងមិនឲ្យផល ដោយប្រការដូច្នេះ ។

កុសលកម្មដែលឲ្យផល ព្រោះអាស្រ័យសម្បត្តិ ៤ តែមិនឲ្យផលព្រោះត្រូវវិបត្តិ ៤ ហាមឃាត់ហើយ ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើកុសលកម្មជាច្រើន កុសលកម្មនោះមិនគប្បីឲ្យផល ដល់បុគ្គលដែលតាំងនៅក្នុងគតិវិបត្តិ តែបើបុគ្គលនោះ កើតក្នុងគតិសម្បត្តិ ដោយកុសលកម្មឯណានីមួយនោះឯង ។ ក្នុងគតិសម្បត្តិនោះ កម្មទាំងនោះចូលដល់ហើយ រមែងឲ្យផលដល់បុគ្គលនោះគ្រប់ៗ គ្រា គឺឲ្យកើតក្នុងមនុស្សលោកតាមកាលដែលគួរ ឲ្យកើតក្នុងទេវលោកតាមកាលដែលគួរ ។

ព្រះតថាគតទ្រង់ជ្រាបថា កុសលកម្មដែលមិនអាចឲ្យផល ព្រោះគតិ-វិបត្តិហាមឃាត់ ចូលដល់គតិសម្បត្តិហើយ រមែងឲ្យផលបាន ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើកុសលច្រើន កុសលកម្មនោះ មិនគប្បីឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងឧបធិវិបត្តិ តែបើបុគ្គលនោះតាំងនៅក្នុងឧបធិសម្បត្តិ ដោយកុសលកម្មឯណានីមួយនោះ គឺមានរូបស្អាតគួរមើល ដូចគ្នានឹងកូនគោដ៏ប្រសើរ កុសលកម្មទាំងឡាយរមែងឲ្យផល ព្រោះបុគ្គលនោះតាំងនៅក្នុងឧបធិសម្បត្តិ ។ បើបុគ្គលនោះកើតក្នុងរាជត្រកូល កាលព្រះជេដ្ឋាដទៃមានជនទាំងឡាយ រមែងអភិសេកបុគ្គលនោះឯង ក្នុងរាជសម្បត្តិដោយសង្ឃឹមថា អត្តភាពរបស់ព្រះរាជបុត្តនេះរុងរឿង កាលយើងលើកស្វេតច្ឆត្រឡើងឲ្យដល់ព្រះរាជបុត្តនេះហើយ ផាសុកនឹងមានដល់សត្វលោក ដូច្នេះ ។ បុគ្គលនោះកើតក្នុងផ្ទៃនៃឧបរាជជាដើម ដោយកាលកន្ទង់ទៅនៃបិតា ( បិតាស្លាប់ទៅ ) រមែងបានភាពជាឧបរាជ ជាតំណែងសេនាបតី តំណែងនាយឃ្លាំង ឬតំណែងសេដ្ឋី ។ ព្រះតថាគត ទ្រង់ជ្រាបថា កុសលកម្មដែលមិនអាចឲ្យ

ផល ព្រោះឧបធិវិបត្តិហាមឃាត់ ចូលដល់ឧបធិសម្បត្តិហើយ រមែងឲ្យផល បាន ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត ធ្វើកុសលកម្មជាច្រើន កុសលកម្មទាំងនោះ មិនគប្បី ឲ្យផលដល់បុគ្គលដែលតាំងនៅក្នុងកាលវិបត្តិ តែបុគ្គលនោះ កើតក្នុងកាល-សម្បត្តិដោយកុសលកម្មឯណានីមួយ គឺក្នុងកាលនៃព្រះរាជាល្អ និងមនុស្សល្អ ។ កុសលកម្ម រមែងឲ្យផលដល់បុគ្គលដែលកើតដោយភាពបរិបូណ៌នៃ កាលបែបនោះ ក្នុងសេចក្តីនេះ គប្បីពោលរឿងរបស់ព្រះថេរៈ ឈ្មោះ មហាសោណៈជាឧទាហរណ៍ដូចតទៅនេះ

# រឿងព្រះមហាសោណត្ថេរ

បានឮថា ភិក្ខុមានចំនួន ១២០០០ រូប អាស្រ័យនៅត្រង់ចិត្តលបព៌ត ដែលមានភ័យអំពីព្រាហ្មណ៍ជាចោរ ឈ្មោះតិស្សៈ ។ ក្នុងតិស្សមហាវិហារ ក៏ដូចគ្នា ។ ក្នុងមហាវិហារទាំង ២ ពួកកណ្តុរស៊ីស្បៀងដែលបានរក្សា ៣ ឆ្នាំត្រឹមតែមួយរាត្រី សល់តែអង្កាម ។ ភិក្ខុសង្ឃត្រង់ចិត្តលបព៌ត គិតថា ស្បៀងក្នុងតិស្សមហាវិហារនឹងមាន ពួកយើងនឹងទៅអាស្រ័យក្នុងទីនោះ ទើប ចេញអំពីវិហារទៅ ។ ចំណែកភិក្ខុសង្ឃក្នុងតិស្សមហាវិហារគិតថា ស្បៀង ក្នុងចិត្តលបព៌តនឹងមាន ពួកយើងនឹងអាស្រ័យនៅក្នុងទីនោះ ទើបចេញអំពី វិហារទៅ ។ ភិក្ខុទាំង ២ ពួកមកជួបគ្នាត្រង់ច្រាំងនៃជ្រោះជ្រៅមួយកន្លែង ទើបសួរនូវគ្នានិងគ្នាហើយ ដឹងថាស្បៀងអស់ហើយ នាំគ្នាពោលថា ពួកយើង

ទៅក្នុងទីនោះនឹងធ្វើអ្វីកើត ប្រមូលភិក្ខុ ២៤០០០ រូប ចូលទៅកាន់ព្រៃនៃ ជ្រោះជ្រៅ អង្គុយហើយបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ដោយ ឥរិយាបថអង្គុយនោះឯង ។ ខាងក្រោយ កាលភ័យស្ងប់ហើយ ភិក្ខុសង្ឃ អាស្រ័យសក្កទេវរាជ ប្រមូលព្រះធាតុទាំងឡាយ ធ្វើជាចេតិយបញ្ចុះ ។

សុម្បីតិស្សព្រាហ្មណ៍ដែលជាចោរ ក៏ទម្លាយជនបទហើយ ។ ភិក្ខុសង្ឃ ប្រជុំគ្នាប្រឹក្សាហើយ ទើបបញ្ជូនព្រះថេរៈ ៨ រូបទៅកាន់សម្នាក់របស់សក្ក-ទេវរាជទូលថា សូមទ្រង់ហាមឃាត់នូវចោរ ដូច្នេះ ។ សក្កទេវរាជត្រាស់ថា បពិត្រលោកម្ចាស់ ចោរកើតឡើងហើយ ញោមមិនអាចហាម សូមភិក្ខុ សង្ឃឆ្លងសមុទ្រទៅកាន់ត្រើយដទៃ ខ្ញុំនឹងធ្វើការរក្សាសមុទ្រ ។ ភិក្ខុសង្ឃទៅ កាន់នាគទីប ( កោះលង្កា ) អំពីទិសទាំងពួង ឲ្យចងក្បូនធំ ៣ ផ្ទាំង ត្រង់ កំពង់ឈ្មោះជម្ពុកោលៈ ក្បូនទី ១ លិចចូលក្នុងទឹក ភិក្ខុសង្ឃអង្គុយលើ ក្បូនមួយទៀត ព្រះថេរៈទាំង ៣ រូប ដែលជាប្រធាននៃបរិស័ទទាំងនោះ គឺព្រះចូឡសីវត្ថេរ ដែលជំនាញក្នុងសំយុត្តនិកាយ ព្រះឥសិទត្តត្ថេរ និងព្រះ មហាសោណត្ថេរ ។ បណ្តាព្រះថេរៈទាំងនោះ ព្រះថេរៈ ២ រូប ពោលនិមន្ត ព្រះមហាសោណត្ថេរថា អាវុសោមហាសោណៈ សូមលោកម្ចាស់ឡើងកាន់ ក្បូនធំចុះ ដូច្នេះ ព្រះមហាសោណត្ថេរពោលថា បពិត្រលោកម្ចាស់ ចុះ លោកម្ចាស់វិញ ។ ព្រះថេរៈទាំង ២ ពោលថា អាវុសោ ការស្លាប់ក្នុងទឹក ក្តី ការស្លាប់លើគោកក្តីក៏ដូចគ្នានោះឯង ។ ពួកខ្ញុំមិនទៅឡើយ តែអាវុសោ អាស្រ័យក្បូននោះហើយនឹងបន្តសាសនាក្នុងអនាគត សូមអាវុសោនិមន្តទៅ

ចុះ ។ កាលព្រះមហាសោណត្ថេរពោលថា បពិត្រលោកម្ចាស់ បើលោក-ម្ចាស់ទាំង ២ មិនទៅ ខ្ញុំក៏មិនទៅ កាលព្រះថេរៈទាំង ២ ពោលអស់វារៈ ៣ ដង មិនអាចលើក គឺមិនអាចឲ្យព្រះថេរៈឡើងក្បួនបានទើបនាំគ្នាត្រឡប់ ។

លំដាប់នោះ ព្រះចូឡសីវត្ថេរ ពោលនឹងព្រះឥសិទត្តត្ថេរថា អាវុសោ ឥសិទត្តៈ ក្នុងអនាគតព្រោះអាស្រ័យព្រះមហាសោណៈ ការបន្តនៃសាសនានឹងតាំងមាំ សូមលោកកុំលែងដៃព្រះសោណត្ថេរអំពីដៃ ( កុំបោះបង់ ) ។ ព្រះឥសិទត្តៈសួរថា បពិត្រលោកម្ចាស់ ចុះលោកម្ចាស់វិញ ព្រះចូឡសីវត្ថេរពោលថា ខ្ញុំនឹងទៅថ្វាយបង្គំមហាចេតិយ ហើយពោលទូន្មានព្រះថេរៈទាំង ២ ក៏ត្រាច់ចារិកទៅតាមលំដាប់ រហូតដល់មហាវិហារ ។ សម័យនោះ មហាវិហារទទេចាកភិក្ខុសង្ឃ ដើមល្ហុងខ្មែរ ដុះឡើងត្រង់លានព្រះចេតិយ ចេតិយមានគុម្ពឈើទាំងឡាយ ចោមរោមហើយ មានវល្លិព័ទ្ធព័ន្ធហើយ ។ ព្រះថេរៈថ្វាយបង្គំមហាចេតិយ សម្តែងសេចក្តីគោរពចំពោះព្រះពុទ្ធ ដូចគង់ព្រះជន្មនៅ ហើយចូលទៅកាន់សាលាទិសខាងលិច កាលសម្លឹងមើល អន្លុយពិចារណាថា ទីបញ្ចុះព្រះសរីរធាតុ របស់ព្រះសាស្តាដែលដល់ហើយនូវសភាពធំក្រៃលែងដោយលាភសក្ការៈ ដោយយសដ៏ធំបែបនេះ មិនមានទីពឹងហើយហ្ន៎ ដូច្នេះ ។

លំដាប់នោះ ទេវតាដែលអាស្រ័យនៅត្រង់ដើមឈើ មិនឆ្ងាយអំពីនោះ កាន់យកនាឡិអង្ករ និងស្ករអំពៅ ទៅកាន់សម្នាក់របស់ព្រះថេរៈ ជារូបរបស់មនុស្សអ្នកដើរផ្លូវឆ្ងាយ ហើយសាកសួរព្រះថេរៈថា បពិត្រលោកម្ចាស់

លោកម្ចាស់និមន្តទៅទីណា ដូច្នេះ ។

ព្រះថេរៈ ពោលថា អើឧបាសក អាត្មាទៅកាន់ទិសទក្សិណ ទេវតា ពោលថា បពិត្រលោកម្ចាស់ ខ្ញុំក៏បំណងនឹងទៅក្នុងទីនោះឯង យើងនឹងទៅព្រមគ្នា ព្រះថេរៈពោលថា អាត្មាមានកម្លាំងតិចមិនអាចទៅតាមអធ្យាស្រ័យរបស់អ្នកបានទេ នែឧបាសក ចូរអ្នកទៅមុនចុះ ទេវតាពោលថា ខ្ញុំនឹងទៅតាមអធ្យាស្រ័យរបស់លោកម្ចាស់ ហើយបានទទួលយកបាត្រ និងចីវររបស់ព្រះថេរៈមកកាន់ ។ ក្នុងកាលឡើងកាន់ទំនប់ស្រះទឹកឈ្មោះតិស្សៈ ព្រះថេរៈឲ្យយកបាត្រមក ទេវតាក៏ធ្វើទឹកផឹកប្រគេន កាលព្រះថេរៈផឹកទឹកហើយនោះឯង ល្មមមានកម្លាំង ទេវតាបង្រួញផែនដីឲ្យដល់វិហារបាក់បែកមួយខ្នង ក្នុងទីក្បែរវេណុនទី ហើយបោសសម្អាតទីកន្លែងប្រគេនព្រះថេរៈ ។ ស្អែកឡើងព្រះថេរៈលុបមុខស្រេចបាច់ ទេវតាដាំបបរប្រគេន កាលព្រះថេរៈឆាន់បបរហើយ ទេវតាក៏ដាំបាយបន្អែមចូលទៅប្រគេន ព្រះថេរៈពោលថា ឧបាសកចូរអ្នកទុកដើម្បីខ្លួនចុះ ហើយយកដៃបិទបាត្រ ។ ទេវតាពោលថា ខ្ញុំទៅមិនឆ្ងាយ ហើយទើបយកកត្តដាក់ក្នុងបាត្ររបស់ព្រះថេរៈនោះឯង កាលព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយ ទេវតាកាន់យកបាត្រ និងចីវរដើម្បីធ្វើដំណើរទៅកាន់ផ្លូវដែលត្រូវទៅ បង្រួញផែនដីនាំទៅជិតស្ទឹងជជ្ជរនទីហើយពោលថា បពិត្រលោកម្ចាស់ នុ៎ះជាទីលំនៅរបស់ពួកមនុស្សដែលអាស្រ័យស្លឹកឈើរស់នៅផ្សែងកំពុងប្រាកដ ខ្ញុំនឹងទៅខាងមុខ ថ្វាយបង្គំព្រះថេរៈហើយមកកាន់លំនៅរបស់ខ្លួន ព្រះថេរៈអាស្រ័យពួកមនុស្សដែលបរិភោគបន្លែរស់ នៅហើយអស់

កាលនៃភ័យទាំងពួង ។

ចំណែកព្រះឥសិទត្តត្ថេរ កាលចារិកទៅដោយលំដាប់ក៏ដល់អទ្បជនបទ ។ ពួកមនុស្សក្នុងជនបទនោះ នាំគ្នាពុះផ្លែស្រគំស្រគាល កាន់យកគ្រាប់ក្នុងផ្លែបោះសម្បកចោលទៅ ។ ព្រះថេរៈពោលថា អាវុសោ មហាសោណៈ ភិក្ខាហារមែងប្រាកដ ហើយឲ្យព្រះមហាសោណៈយកបាត្រ និងចីវរមក ឃ្លុំចីវរហើយនាំបាត្រចេញមក ហើយឈរ ។ ក្មេងស្រីអ្នកស្រុកម្នាក់ ឃើញព្រះថេរៈឈរ គិតថា ប្រយោជន៍ណាមួយនឹងមានដោយផ្លែស្រគំនេះ បោសខ្សាច់ចេញហើយយកផ្លែស្រគំ និងសម្បកស្រគំ ដាក់ក្នុងបាត្រ ប្រគេនព្រះថេរៈហើយ ។ ព្រះថេរៈទាំង ២ ឆាន់ហើយអស់ ៧ ថ្ងៃ ដោយអាហារនោះឯង ។

ព្រះថេរៈទាំង ២ ធ្វើដំណើរដល់ស្រះឈ្មោះថា ចោរិយៈ លំដាប់នោះមនុស្សទាំងឡាយកាន់យកផ្កាកុមុទ បានបោះទងផ្កាកុមុទទាំងឡាយ ហើយទៅ ។ ព្រះថេរៈពោលថា នែមហាសោណៈ ភិក្ខាហាររមែងប្រាកដហើយ ឲ្យនាំបាត្រ និងចីវរមក ឃ្លុំចីវរហើយ ក៏កាន់បាត្រចេញមកឈរ ។ ក្មេងអ្នកស្រុកធ្វើនូវការសម្អាតទងផ្កាកុមុទ ហើយដាក់ក្នុងបាត្រប្រគេន ។ ព្រះថេរៈទាំង ២ ឆាន់ហើយអស់ ៧ ថ្ងៃ ដោយអាហារនោះឯង ។ ព្រះថេរៈទាំង ២ កាលត្រាច់ទៅដោយលំដាប់ បានដល់ទ្វារផ្ទះមួយ ក្នុងលំនៅរបស់មនុស្សអាស្រ័យស្លឹកឈើរស់នៅ ។

មាតា និងបិតារបស់ទារិកាម្នាក់ក្នុងផ្ទះនោះ កាលទៅព្រៃបានផ្តាំថា នែ

នាង បើលោកម្ចាស់អង្គណាមួយមកក្នុងទីនេះ ចូរនាងកុំឲ្យលោកទៅក្នុងទីណា គប្បីប្រាប់លំនៅដល់លោក ដូច្នេះ ។ ទារិកាឃើញព្រះថេរៈទាំង ២ ហើយក៏ទទួលបាត្រ និមន្តឲ្យគង់ ។ ឈ្មោះថា ធញ្ញជាតិក្នុងផ្ទះមិនមាន ។ ទើបទារិកានោះ កាន់យកកាំបិតទៅស្ងោះសម្បកទំពាំងបាយជូរ និងដើមចេកព្រៃ មួយអន្ទើដោយវល្លិ និងស្ងឹកទំពាំងបាយជូរមកចងជា ៣ ដុំ ដាក់មួយដុំក្នុងបាត្ររបស់ព្រះឥសិទត្តត្ថេរ ដាក់មួយដុំក្នុងបាត្ររបស់ព្រះមហាសោណត្ថេរ លាដៃចេញទៅដោយបំណងថា អញនឹងដាក់ដុំដែលសល់ ក្នុងបាត្ររបស់ព្រះឥសិទត្តត្ថេរ តែដៃបែរជាទៅដាក់ក្នុងបាត្ររបស់ព្រះមហាសោណត្ថេរវិញ ។ ព្រះឥសិទត្តត្ថេរពោលថា កម្មដែលឲ្យនូវផលព្រោះដុំទំពាំងបាយជូរ និងចេកព្រៃក្នុងសម័យមានភ័យអំពីចោរ ដែលជាព្រាហ្មណ៍ឈ្មោះតិស្សៈ នឹងប្រាកដផល មានប្រមាណដរាបណា ព្រោះការដល់ព្រមនៃទេសកាល ។ ព្រះថេរៈទាំង ២ ក៏ឆាន់សម្បកឈើទាំងនោះរួមគ្នា ទៅកាន់លំនៅហើយ ។ ទារិកានោះក៏ប្រាប់មាតា និងបិតាដែលមកអំពីព្រៃថា មានព្រះថេរៈមកហើយ ២ រូប ខ្ញុំប្រាប់ទីលំនៅដល់លោកហើយ ។ មាតា និងបិតាទាំង ២ នោះ ក៏ទៅកាន់សម្នាក់របស់ព្រះថេរៈទាំង ២ ថ្វាយបង្គំហើយក៏ទទួលបដិញ្ញា ដោយពាក្យថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយ នៅក្នុងទីនេះឯង សូម្បីព្រះថេរៈទាំងពីរក៏អាស្រ័យជនទាំងនោះរស់នៅហើយ អស់កាលដែលមានភ័យទាំងពួង ។

កាលចោរដែលជាព្រាហ្មណ៍ឈ្មោះតិស្សៈស្លាប់ហើយ បិតុមហារាជ ក៏

ឲ្យធ្វើរាជវិធីលើកស្វេតច្ឆត្រឡើង ។ ភិក្ខុសង្ឃឯងនាយសមុទ្ទ បានដំណឹងថា ភ័យស្ងប់ហើយ ជនបទសម្បូរហើយ ក៏ឡើងសំពៅឆ្លងសមុទ្ទ ឡើងត្រង់កំពង់ឈ្មោះថា មហាតិដ្ឋៈ ត្រាច់សួរថា ព្រះមហាសោណត្ថេរនៅក្នុងទីណា ដូច្នេះហើយ បានទៅកាន់សម្នាក់របស់ព្រះថេរៈ ។ ព្រះថេរៈមានភិក្ខុសង្ឃ ៥០០ ជាបរិវារ ដល់វិហារឈ្មោះមណ្ឌលារាម ក្នុងស្រុកកាលកៈ ។ ក្នុងសម័យនោះ ក្នុងស្រុកកាលកៈនោះមានត្រកូល ៧០០ នៅអាស្រ័យ ។ ក្នុងពេលយប់ ទេវតាទាំងឡាយ ត្រាច់ទៅប្រាប់ដល់មនុស្សទាំងឡាយថា ព្រះមហាសោណត្ថេរ មានភិក្ខុជាបរិវារ ៥០០ មកដល់មណ្ឌលារាមវិហារហើយ អ្នកទាំងឡាយក្នុងផ្ទះនីមួយៗ ចូរប្រគេនបិណ្ឌបាតដែលជារបស់មានតម្លៃ ១ កហាបណៈ មួយអន្ទើដោយសំពត់សាដក ៩ ហត្ថ ។ ស្អែកឡើង ព្រះថេរៈទាំងឡាយចូលទៅកាន់ស្រុកកាលកៈដើម្បីបិណ្ឌបាត មនុស្សទាំងឡាយនិមន្តឲ្យគង់ ហើយបានប្រគេនបបរ ។ ព្រះថេរៈឈ្មោះតិស្សភូតិនៅក្នុងមណ្ឌលារាម បានគង់ជាព្រះសង្ឃត្ថេរ ។

មហាឧបាសកម្នាក់ថ្វាយបង្គំព្រះសង្ឃត្ថេរ ហើយសាកសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់អង្គណាឈ្មោះមហាសោណត្ថេរ ។ សម័យនោះ ព្រះមហាសោណត្ថេរជាភិក្ខុថ្មី ទើបអង្គុយក្នុងខាងចុង ព្រះសង្ឃត្ថេរ លាដៃចង្អុលហើយពោលថា នែឧបាសក ភិក្ខុនោះ ឈ្មោះថា មហាសោណៈ ដូច្នេះ ។ ឧបាសកថ្វាយបង្គំព្រះមហាសោណៈនោះហើយ សូមទទួលបាត្រអំពីលោក តែព្រះថេរៈមិនឲ្យ ។ ព្រះតិស្សភូតិត្ថេរ ពោលថា អាវុសោ

សោណៈ ពួកយើងក៏មិនជ្រាបដូចដែលលោកមិនជ្រាបនោះឯង ទេវតាទាំងឡាយ រមែងឲ្យចម្អិនកត្តដើម្បីអ្នកមានបុណ្យទាំងឡាយ ចូរអាវុសោ លែងគឺឲ្យបាត្រ ចូរធ្វើនូវការសង្គ្រោះសព្រហ្មចារីទាំងឡាយ ដូច្នេះ ព្រះសោណៈក៏ឲ្យបាត្រហើយ ។ មហាឧបាសកកាន់យកបាត្រទៅហើយ ឲ្យពេញដោយបិណ្ឌបាតដែលមានតម្លៃគួរដល់ ១ កហាបណៈ ហើយធ្វើសំពត់សាដក ៩ ហត្ថឲ្យជាទម្របាត្រ នាំមកដាក់ក្នុងដៃរបស់ព្រះថេរៈ ។ ឧបាសកដទៃទៀតក៏រៀបចំបិណ្ឌបាត និងសំពត់សាដកទុកក្នុងដៃរបស់ព្រះថេរៈ សរុបហើយពួកឧបាសក បានប្រគេនសំពត់សាដក ៧០០ និងបិណ្ឌបាត ៧០០ សម្រាប់ដល់ព្រះមហាសោណត្ថេរប៉ុណ្ណោះ ។

ព្រះមហាសោណត្ថេរចាត់ចែងវត្ថុទាំងនោះ ដល់ភិក្ខុសង្ឃស្រេចបាច់ហើយក៏ទៅកាន់វិហារដោយលំដាប់ កាលខ្ទុរមាត់ លុបមុខហើយ ក៏ថ្វាយបង្គំមហាពោធិព្រឹក្ស ថ្វាយបង្គំមហាចេតិយ ឈរត្រង់ថូបារាម ឃុំចីវរហើយ នាំភិក្ខុជាបរិវារចូលទៅកាន់ព្រះនគរតាមទ្វារទិសទក្សិណ បានអាហារបិណ្ឌបាតដែលមានតម្លៃគួរដល់ ៦០ កហាបណៈ ក្នុងរវាងនោះ អំពីទ្វាររហូតដល់វឡញ្ជនសាលា ។ តាំងពីកាលនោះមក ប្រមាណនៃគ្រឿងសក្ការៈរាប់មិនបាន ។

ក្នុងកាលវិបត្តិ សូម្បីតែសម្បកផ្លែស្រគំ ទងកុមុទ ក៏រកបានដោយក្រ តែក្នុងកាលសម្បត្តិ មានលាភសន្ទឹកសន្ធាប់បែបនេះកើតឡើងហើយ ដោយប្រការដូច្នេះ ។

# រឿងវត្តពុកនិគ្រោធ

ភ័យអំពីចោរឈ្មោះតិស្សៈជាព្រាហ្មណ៍ កើតឡើងក្នុងកាលដែលព្រះវត្តពុកនិគ្រោធត្ថេរ នៅជាសាមណេរ ។ សាមណេរ និងឧបជ្ឈាយ៍របស់សាមណេរ មិនបានទៅកាន់ខាងនាយសមុទ្ទ តែទៅកាន់ប្រទេសជាយដែនដោយគិតថា ពួកយើងនឹងចូលទៅអាស្រ័យមនុស្ស ដែលមានស្លឹកឈើជាអាហារ ដូច្នេះ សាមណេរជាអ្នកអត់អាហារមក ៧ ថ្ងៃ ឃើញផ្លែត្នោតត្រង់ដើមត្នោត ក្បែរស្រុកមួយ ទើបពិតព្រះថេរៈថា សូមលោកម្ចាស់ បន្តង់សិនខ្ញុំនឹងឲ្យផ្លែត្នោតធ្លាក់ចុះមក ដូច្នេះ ។ ឧបជ្ឈាយ៍ពោលថា នែសាមណេរ អ្នកជាបុគ្គលមានកម្លាំងតិច កុំឡើងឡើយ សាមណេរពិតថា បពិត្រលោកម្ចាស់ខ្ញុំនឹងឡើង ដូច្នេះហើយ កាន់កូនកាំបិតតូចឡើងដើមត្នោត ផ្ដើមនឹងកាត់ផ្លែត្នោត ផ្លែកាំបិតក៏ជ្រុះមកដី ។

ព្រះថេរៈគិតថា សាមណេរនេះឡើងដើមត្នោតបានដោយលំបាក ឥឡូវនេះ នឹងធ្វើដូចម្ដេចហ្ន៎ ។ សាមណេរហែកស្លឹកត្នោត ហើយច្រៀកតូចៗចងដងកាំបិតទម្លាក់ចុះមករហូតដល់ដី ហើយពិតព្រះថេរៈថា បពិត្រលោកម្ចាស់ ជាការល្អហ្ន៎ បើលោកម្ចាស់សៀតកាំបិត ចូលក្នុងដងកាំបិតនេះ ។ ព្រះថេរៈគិតថា សាមណេរជាអ្នកឈ្លាសក្នុងឧបាយ បានសៀតផ្លែកាំបិតឲ្យហើយ ។ សាមណេរនោះស្រាវខ្សែឡើង ហើយយកកាំបិតកាត់ផ្លែត្នោតទាំងឡាយ ឲ្យធ្លាក់ចុះមក ។ ព្រះថេរៈឲ្យសាមណេរ បោះកាំបិតមកហើយ ចិតផ្លែត្នោត ដែលធ្លាក់ចុះមក ហើយពោលនឹងសាមណេរ ក្នុងពេលដែលលោកចុះមកថា នែសាមណេរអ្នកមានកម្លាំងតិច ចូរបរិភោគផ្លែត្នោតមុនចុះ

ដូច្នេះ សាមណេរពិតថា បើលោកម្ចាស់មិនឆាន់ផ្លែត្នោតនេះ ខ្ញុំក៏មិនបរិភោគ ដូច្នេះហើយ យកកាំបិតចិតផ្លែត្នោត នាំបាត្រចេញមកដាក់គ្រាប់ត្នោត ប្រគេនព្រះថេរៈហើយ ទើបខ្លួនឯងឆាន់ឯក្រោយ ។ ជនទាំង ២ នៅក្នុងទីនោះឯង ដរាបណាផ្លែត្នោតមិនមាន កាលផ្លែត្នោតអស់ហើយ ក៏ទៅកាន់វិហារបាក់បែកមួយ ក្នុងទីដែលជាលំនៅរបស់ពួកមនុស្សអាស្រ័យស្លឹកឈើរស់នៅដោយលំដាប់ ។

សាមណេរបោសសម្អាតទីលំនៅសម្រាប់ព្រះថេរៈ ។ ព្រះថេរៈឲ្យឱវាទដល់សាមណេរ ហើយក៏ចូលទៅកាន់វិហារ ។ សាមណេរគិតថា អត្តភាពទាំងឡាយដែលវិនាសហើយ ក្នុងភាពខ្ជិលច្រអូសប្រមាណមិនបាន អញនឹងធ្វើការបម្រើព្រះពុទ្ធទាំងឡាយ ទើបទៅកាន់លានព្រះចេតិយដកស្មៅ សាមណេរនោះទន់ខ្សោយ ព្រោះអត់អាហារមក ៧ ថ្ងៃ ក៏ដួលចុះ ខណៈដេកនោះឯង ក៏នៅតែដកស្មៅ ។

មនុស្សមួយពួកត្រាច់ទៅក្នុងព្រៃ បានឃ្មុំមួយសម្បុក កាន់យកឧស មួយអន្ទើដោយស្លឹកឈើ ឃើញស្មៅរង្គើគិតថា ទុំះម្រឹគឬហ្ន៎ ទើបទៅក្នុងទីជិតពោលថា បពិត្រសាមណេរ តើលោកធ្វើអ្វី សាមណេរឆ្លើយថា ឧបាសកអាត្មាដកស្មៅ ពួកមនុស្សពោលថា បពិត្រលោកម្ចាស់ ជនដទៃណាមួយមានឬ សាមណេរពោលថា ឧបាសកទាំងឡាយមាន ឧបជ្ឈាយ៍របស់អាត្មានៅក្នុងបន្ទប់ ឧបាសកពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រគេនរបស់នេះដល់ព្រះមហាថេរៈ ហើយគប្បីបរិភោគចុះ ហើយក៏ប្រគេនសម្បុក

ឃ្មុំដល់សាមណេរ ហើយប្រាប់ទីលំនៅរបស់ខ្លួន ពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំដើរបណ្តើរ កាប់មែកឈើបណ្តើរ សូមលោកម្ចាស់នាំព្រះថេរៈទៅដោយសញ្ញាមែកឈើនោះ ដូច្នេះហើយ នាំគ្នាត្រឡប់ទៅ ។

សាមណេរកាន់សម្បុកឃ្មុំ ហើយទៅកាន់លំនៅរបស់ព្រះថេរៈ ឈរខាងក្រៅពិតថា បពិត្រលោកម្ចាស់ ខ្ញុំសូមថ្វាយបង្គំ ព្រះថេរៈក៏នៅស្ងៀមដោយគិតថា សាមណេរត្រូវសេចក្តីស្រេកឃ្លានជុតពេលហើយ ទើបមកសាមណេរក៏ពិតម្តងទៀតថា បពិត្រលោកម្ចាស់ ខ្ញុំសូមថ្វាយបង្គំ ។ ព្រះថេរៈពោលថា នែសាមណេរ អ្នកមិនឲ្យភិក្ខុចាស់ដេកតាមសប្បាយ ព្រោះហេតុអ្វី សាមណេរពោលថា លោកម្ចាស់គួរបើកទ្វារ ព្រះថេរៈក៏ក្រោកឡើងបើកទ្វារ ហើយសួរថា នែសាមណេរ អ្នកបានអ្វីមក សាមណេរពោលថា ពួកមនុស្សឲ្យសម្បុកឃ្មុំ សូមលោកម្ចាស់ឆាន់សម្បុកឃ្មុំ ។ ព្រះថេរៈពោលថា នែសាមណេរ ការបរិភោគយ៉ាងនេះ ពួកយើងនឹងលំបាក ពួកយើងគួរធ្វើឲ្យជារបស់គួរផឹក ហើយទើបផឹក សាមណេរក៏ធ្វើឲ្យទៅជារបស់គួរផឹក ហើយប្រគេនដល់ព្រះថេរៈ ។

លំដាប់នោះ ព្រះថេរៈពោលថា នែសាមណេរ អ្នកសួរដល់លំនៅនៃមនុស្សឬទេ សាមណេរពិតថា បពិត្រលោកម្ចាស់ ពួកមនុស្សប្រាប់ឯង ។ ព្រះថេរៈពោលថា នែសាមណេរ បើយើងទៅពេលព្រឹកនឹងលំបាក យើងនឹងទៅពេលថ្ងៃនេះឯង ព្រះថេរៈឲ្យសាមណេរកាន់បាត្រ និងចីវរចេញទៅ ។ ជនទាំង ២ ទៅហើយ នៅអាស្រ័យក្នុងទីមិនឆ្ងាយអំពីលំនៅនៃពួកមនុស្ស ។

ក្នុងពេលរាត្រី សាមណេរគិតថា តាំងពីអញបួសហើយមិនធ្លាប់ទទួលអរុណក្នុងស្រុក ទើបកាន់យកបាត្រចូលទៅក្នុងព្រៃ ដើម្បីទទួលអរុណ ។ ព្រះមហាថេរៈកាលមិនឃើញសាមណេរក្នុងទីដេក ទើបគិតថា សាមណេរនឹងត្រូវមនុស្សស៊ីមនុស្ស ចាប់ទៅហើយ ។ សាមណេរទទួលអរុណក្នុងព្រៃហើយ យកបាត្រដងទឹក កាន់ឈើស្ទន់ត្រឡប់មក ។ ព្រះថេរៈសួរថា សាមណេរអ្នកទៅឯណា អ្នកធ្វើឲ្យភិក្ខុចាស់ពិការ ចូរអ្នកទទួលទណ្ឌកម្ម ។ សាមណេរពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទទួលទណ្ឌកម្ម ។ ព្រះថេរៈលុបមុខហើយ ឃ្លុំចីវរហើយ ។ ជនទាំង ២ បាននាំគ្នាទៅកាន់លំនៅរបស់មនុស្សទាំងឡាយ ។ មនុស្សទាំងឡាយ ក៏បានប្រគេនអាហារ មានត្រាវផ្លែឈើ និងស្លឹកឈើដែលជាគ្រឿងបរិភោគរបស់ខ្លួន ។ ព្រះថេរៈឆាន់ស្រេចហើយ ទៅកាន់វិហារ ។ សាមណេរនាំទឹកមកហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងលាងជើងរបស់លោកម្ចាស់ដើម្បីជាទណ្ឌកម្ម ព្រះថេរៈពោលថា នែសាមណេរ អ្នកទៅណា ក្នុងពេលយប់ ធ្វើខ្ញុំឲ្យកើតពិការ ដូច្នេះ ។ សាមណេរពិតថា បពិត្រលោកម្ចាស់ ខ្ញុំមិនធ្លាប់ឲ្យអរុណរះក្នុងស្រុក ទើបទៅកាន់ព្រៃដើម្បីអរុណ ។ ព្រះថេរៈពោលថា អើសាមណេរ ទណ្ឌកម្មមិនសមគួរដល់អ្នក តែគួរដល់ខ្ញុំ ដូច្នេះហើយ នៅក្នុងទីនោះឯង ។ ម្យ៉ាងទៀតព្រះថេរៈបានដាស់តឿនសាមណេរថា ខ្ញុំជាមនុស្សចាស់ហើយ បុគ្គលណាមួយមិនអាចដឹងថា រឿងនេះនឹងមាន អ្នកគប្បីរក្សាខ្លួន ។ បានឮថា ព្រះថេរៈជាព្រះអនាគាមី ។ ក្នុងកាលក្រោយមក ពួកមនុស្សស៊ីសាច់មនុស្ស

ចាប់ព្រះថេរៈធ្វើជាអាហារហើយ ។

សាមណេររក្សាខ្លួនបាន កាលភ័យស្ងប់ហើយ ជាបុគ្គលដែលសង្ឃឲ្យកាន់យកឧបជ្ឈាយ៍ក្នុងទីបែបនោះឲ្យឧបសម្បទា ហើយរៀនពុទ្ធវចនៈ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ទើបមហាជនហៅថា វត្តពូកនិគ្រោធត្ថេរ ដែលមានន័យថា ព្រះថេរៈជាអ្នកមាំទាំដូចដើមជ្រៃ ។ ព្រះបាទបិតុមហារាជ ទ្រង់គ្រងរាជសម្បត្តិហើយ ។ ភិក្ខុទាំងឡាយដែលមកហើយអំពីនាយសមុទ្ទ សួរថា ព្រះថេរៈឈ្មោះវត្តពូកនិគ្រោធ នៅឯណា ហើយចូលទៅកាន់សម្នាក់របស់ព្រះថេរៈនោះ ពួកនៃភិក្ខុដ៏ច្រើនចោមរោមលោកហើយ ព្រះថេរៈនោះ កាលមហាភិក្ខុចោមរោមហើយ ក៏និមន្តទៅកាន់មហាវិហារដោយលំដាប់ ថ្វាយបង្គំមហាពោធិ៍ មហាចេតិយ និងថូបារាម ហើយចូលទៅកាន់នគរ ។ ត្រៃចីវរកើតឡើងក្នុងទី ៩ កន្លែងដល់ព្រះថេរៈ ដែលកំពុងនិមន្តទៅ រហូតដល់ទ្វារទិសទក្សិណនោះឯង ។ ចាប់តាំងអំពីកាលដែលព្រះថេរៈ ចូលទៅខាងក្នុងនគរ សក្ការៈជាច្រើនកើតឡើងហើយ ។ ក្នុងកាលវិបត្តិ សូម្បីតែផ្លៃត្នោតត្រាវ ដំឡូង និងស្លឹកឈើ ក៏រកបានដោយក្រ ក្នុងកាលសម្បត្តិ មហាលាភបែបនេះ កើតឡើងហើយ ដោយប្រការដូច្នេះ ។

ព្រះតថាគតទ្រង់ជ្រាបថា កុសលកម្មទាំងឡាយ មិនអាចឲ្យផល ព្រោះត្រូវកាលវិបត្តិហាមឃាត់ លុះដល់កាលសម្បត្តិហើយ រមែងឲ្យផលបានដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត បានធ្វើកុសលកម្មច្រើន កុសលកម្មទាំងនោះ មិនគប្បី

ឲ្យផលដល់បុគ្គល ដែលតាំងនៅក្នុងបយោគវិបត្តិ តែបុគ្គលនោះ តាំងនៅចំពោះក្នុងសមាបយោគដោយកុសលកម្មណាមួយ គឺរមែងបំពេញសុចរិត ៣ រមែងរក្សាសីល ៥ សីល ១០ កាលបុគ្គលនោះកើតក្នុងកាលសម្បត្តិ ព្រះរាជាទាំងឡាយ រមែងបញ្ជូនរាជកញ្ញាទាំងឡាយ ដែលប្រកបដោយគ្រឿងអលង្ការទាំងពួង ដោយព្រះតម្រិះថា រាជកញ្ញាទាំងនោះ សមគួរដល់បុគ្គលនោះ រមែងបញ្ជូនបណ្ណាការនោះៗ មានរបស់ដែលមានតម្លៃ យាន ពាហនៈ កែវមណី មាស និងប្រាក់ជាដើម ឲ្យដល់បុគ្គលនោះ ដោយព្រះតម្រិះថា បណ្ណាការនេះ សមគួរដល់បុគ្គលនោះ ។ ទោះបីបុគ្គលនោះចូលដល់បព្វជ្ជា រមែងមានយសធំ មានអានុភាពធំ ។ ក្នុងសេចក្ដីនោះ មានរឿងនេះជាឧទាហរណ៍ដូចតទៅ

## រឿងព្រះបាទកូដកណ្ណរាជ

បានឮថា ព្រះបាទកូដកណ្ណរាជ ទ្រង់រាប់អានព្រះចូឡសុធម្មត្ថេរ ដែលអាស្រ័យនៅក្នុងកណ្ណគាមក្បែរភ្នំ ។ ព្រះរាជានោះ កាលប្រថាប់នៅក្បែរអូរដែលមានផ្កាឧប្បល ត្រាស់ឲ្យនិមន្តព្រះថេរៈមក ព្រះថេរៈមកហើយ អាស្រ័យនៅក្នុងវិហារ ឈ្មោះមាលាករម ។ ព្រះរាជាត្រាស់សួរមាតារបស់ព្រះថេរៈថា ព្រះថេរៈរមែងពេញចិត្តក្នុងអាហារប្រភេទណា ។ មាតារបស់ព្រះថេរៈក្រាបទូលថា បពិត្រមហារាជ ព្រះថេរៈចូលចិត្តមើមត្រាវ ។ ព្រះរាជាត្រាស់ឲ្យរាជបុរស កាន់យកមើមត្រាវទៅកាន់វិហារ កាលប្រគេនដល់ព្រះថេរៈ មិនអាចងើបមុខឡើង ។ ព្រះរាជា កាលយាងចេញទៅហើយ

ត្រាស់សួរព្រះទេវី ខាងក្រៅបរិវេណវិហារថា ព្រះថេរៈមានរូបរាងដូចម្ដេច ព្រះទេវីក្រាបទូលថា ព្រះអង្គជាប្រុស មិនអាចងើបមុខ តើខ្ញុំម្ចាស់នឹងអាចដូចម្ដេច ខ្ញុំម្ចាស់ក៏មិនដឹងថា លោកដូចម្ដេចដែរ ព្រះរាជាទ្រង់ទះព្រះហស្ដត្រាស់ថា យើងមិនហ៊ានងើបមុខសម្លឹងមើលគហបតីបុត្ត ដែលរួចផុតពលី ( អ្នកបួស ) ក្នុងដែនរបស់យើង លោកដ៏ចម្រើនឈ្មោះថា ព្រះពុទ្ធ-សាសនា ជារបស់ធំហ្ន៎ ។ ព្រះរាជាទ្រង់ពេញព្រះរាជហឫទ័យក្នុងព្រះថេរៈឈ្មោះចូឡនាគ ដែលជាអ្នកទ្រទ្រង់ព្រះត្រៃបិដកផងដែរ ។ បួសមួយកើតឡើងត្រង់ម្រាមដៃរបស់ព្រះថេរៈនោះ ។ ព្រះរាជាយាងទៅកាន់វិហារដោយតាំងព្រះហឫទ័យថា អញនឹងសួរសុខទុក្ខព្រះថេរៈ ទើបយាងទៅកាន់វិហារ ទ្រង់បឺតម្រាមដៃរបស់ព្រះថេរៈ ព្រោះសេចក្ដីស្រឡាញ់ដ៏មានកម្លាំង បួសបែកហើយ ក្នុងព្រះឱស្ឋនោះឯង ទ្រង់មិនខ្ជាក់ខ្ទុះ និងឈាម ទ្រង់លេបចូលទៅហើយដូចទឹកអម្រឹត ព្រោះសេចក្ដីស្រឡាញ់ក្នុងព្រះថេរៈ ។ ក្នុងកាលក្រោយមកទៀត ព្រះថេរៈមានអាពាធជាទម្ងន់ ដេកលើគ្រែសម្រាប់ស្លាប់ ព្រះរាជាទ្រង់យាងទៅហើយ ទ្រង់ទូលភាជនៈដីដែលគេដុត ដែលដាក់របស់ស្មោកគ្រោក ( ឧច្ចារៈ ) លើព្រះសិរសា ទ្រង់ត្រាច់ខ្សឹកខ្សួលថា ក្លៀវទេះគឺព្រះធម៌បាក់ហើយ ។

ឈ្មោះថា ព្រះរាជាដែលជាធំក្នុងផែនដី ទ្រង់យកសិរសាទូលភាជនៈដីដុតដែលដាក់របស់ស្មោកគ្រោកត្រាច់ទៅ ផ្លូវអ្វីជាអ្នកនាំទៅ ឆ្លើយថា សមា-បយោគ ជាអ្នកនាំទៅ ។

ព្រះតថាគតទ្រង់ជ្រាបថា កុសលកម្មទាំងឡាយមិនអាចឲ្យផល ព្រោះបយោគវិបត្តិហាមឃាត់ ចូលដល់បយោគសម្បត្តិហើយ រមែងឲ្យផលបាន ដោយប្រការដូច្នេះ ។ កុសលកម្មដែលវិបត្តិ ៤ ហាមឃាត់មិនឲ្យផល ចូលដល់សម្បត្តិ ៤ ហើយរមែងឲ្យផល ដោយប្រការដូច្នេះ ។ នេះឧបមាធ្វើអត្ថឲ្យជាក់ច្បាស់ ក្នុងសេចក្ដីនេះដូចតទៅ

បានឮថា មហារាជមួយអង្គ ទ្រង់ពិរោធនឹងអមាត្យម្នាក់ ដោយហេតុមានប្រមាណតិចតួច ទើបឲ្យចងអមាត្យនោះ ដាក់ក្នុងគុក ។ ញាតិទាំងឡាយរបស់អមាត្យនោះ ដឹងភាពដែលព្រះរាជាពិរោធហើយ ពួកគេមិនពោលពាក្យណាមួយ កាលព្រះរាជាទ្រង់ប្រាសចាកពិរោធហើយ ទើបក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាបថា អមាត្យនោះ មិនមានកំហុស ។ ព្រះរាជាទ្រង់ឲ្យលែងហើយ បានព្រះរាជទានតំណែងដល់អមាត្យនោះ ឲ្យត្រឡប់ជាប្រក្រតី ។ ពេលនោះ ប្រមាណនៃគ្រឿងបណ្ណាការទាំងឡាយគ្រប់ទិស ក៏មកកាន់អមាត្យនោះរាប់មិនអស់ មនុស្សទាំងឡាយមិនអាចនឹងរាប់ ។

ក្នុងសេចក្ដីនោះ កាលដែលបុថុជ្ជនកើតក្នុងនរក គប្បីជ្រាបថា ប្រៀបដូចកាលដែលអមាត្យនោះត្រូវព្រះរាជាពិរោធ ដោយហេតុបន្តិចបន្តួចហើយឲ្យចងដាក់ក្នុងគុក ។ កាលដែលបុថុជ្ជននោះ កើតក្នុងស្ថានសួគ៌ ប្រៀបដូចកាលដែលក្នុងវេលាតមក ញាតិទាំងឡាយ របស់អមាត្យនោះ ញុំាងព្រះរាជាឲ្យយល់ព្រម ហើយព្រះរាជាទ្រង់ប្រទានតំណែងដូចដើម ។ ការដែលកុសលកម្មទាំងឡាយចូលដល់សម្បត្តិ ៤ ហើយនាំទៅកាន់ទីសុខ អំពី

ទីដែលជាសុខនោះឯងយ៉ាងនេះ គឺអំពីទេវលោកមកកាន់មនុស្សលោក អំពីមនុស្សលោកទៅកាន់ទេវលោក ហើយឲ្យវិបាកដែលជាសុខអស់សែនកប្បហើយឲ្យដល់ព្រះនិព្វាន គប្បីជ្រាប ប្រៀបដូចកាលដែលអមាត្យនោះ មិនអាចរាប់គ្រឿងបណ្ណាការដ៏សន្ធឹកសន្ធាប់បាន ។

បណ្ឌិតកាលសម្តែងកម្លាំងទី ២ ដោយអំណាចនៃបាលី ដោយអាការយ៉ាងនេះហើយ គប្បីសម្តែងដោយន័យរបស់បដិសម្ភិទាមគ្គថា កម្មមានរួចហើយ វិបាក ( ផល ) របស់កម្មមានរួចហើយ ដូច្នេះ ។ បណ្តាបទទាំងនោះ ពាក្យថា កម្មមានរួចហើយ បានដល់ កម្មដែលសន្សំហើយក្នុងអតីតមានហើយក្នុងអតីតនោះឯង ។ ពាក្យថា ផលរបស់កម្មមានហើយ លោកពោលសំដៅយកកម្មដែលជាហេតុឲ្យផលក្នុងអតីត ។

បណ្តាកម្មទាំងឡាយ មានទិដ្ឋធម្មវេទនីយកម្មជាដើម ដែលបុគ្គលសន្សំហើយ ទោះបីច្រើន ទិដ្ឋធម្មវេទនីយកម្មណាមួយឲ្យផល ទិដ្ឋធម្មវេទនីយ-កម្មដ៏សេសរមែងមិនឲ្យផល ឧបបជ្ជវេទនីយកម្មណាមួយឲ្យបដិសន្ធិហើយ ឧបបជ្ជវេទនីយកម្មដ៏សេស រមែងមិនឲ្យផល ។ សត្វកើតក្នុងនរក ដោយអនន្តរិយកម្មមួយ អនន្តរិយកម្មដ៏សេស រមែងមិនឲ្យផល ។ បុគ្គលកើតក្នុងព្រហ្មលោកដោយសមាបត្តិណាមួយ បណ្តាសមាបត្តិ ៨ សមាបត្តិដ៏សេស រមែងមិនឲ្យផល លោកពោលថា វិបាករបស់កម្មមិនទាន់មានហើយ សំដៅយកពាក្យដូចពោលមកនេះ ។

បុគ្គលណាធ្វើកម្មជាកុសល និងអកុសលច្រើន អាស្រ័យកល្យាណមិត្ត

ហើយរមែងសម្រេចអរហត្ត កម្មវិបាកបុគ្គលនោះ ទើបឈ្មោះថា មិនមានហើយ ។ កម្មណាដែលសន្សំហើយក្នុងអតីត រមែងឲ្យផលក្នុងបច្ចុប្បន្ន កម្មនោះ ឈ្មោះថា កម្មមានរួចហើយ វិបាករបស់កម្ម កំពុងមាន ។ កម្មណារមែងដល់នូវភាពជាអវិបាក គឺមិនទាន់ឲ្យផល ដោយន័យមុននោះឯង កម្មនោះ ឈ្មោះថា កម្មមានរួចហើយ វិបាករបស់កម្មនឹងមាន ។ កម្មណាសន្សំហើយ នឹងដល់ភាពជាអវិបាកដោយន័យមុននោះឯង កម្មនោះ ឈ្មោះថា កម្មមានរួចហើយ វិបាករបស់កម្ម នឹងមិនទាន់មាន ។ កម្មណា ដែលសន្សំក្នុងបច្ចុប្បន្នហើយ រមែងឲ្យផលក្នុងបច្ចុប្បន្ននោះ កម្មនោះ ឈ្មោះថា កម្មកំពុងមាន វិបាករបស់កម្មក៏កំពុងមាន ។ កម្មណាដល់នូវភាពជាអវិបាក ដោយន័យមុននោះឯង កម្មនោះ ឈ្មោះថា កម្មកំពុងមាន វិបាករបស់កម្មមិនទាន់មាន ។ កម្មណា ដែលសន្សំហើយក្នុងបច្ចុប្បន្ន នឹងឲ្យផលក្នុងអនាគត កម្មនោះ ឈ្មោះថា កម្មកំពុងមាន វិបាករបស់កម្មនឹងមាន ។ កម្មណា នឹងដល់នូវភាពជាអវិបាក ដោយន័យមុននោះឯង កម្មនោះ ឈ្មោះថា កម្មកំពុងមាន វិបាករបស់កម្ម នឹងមិនទាន់មាន ។ កម្មណា សូម្បីខ្លួនឯងជាអនាគត សូម្បីវិបាកនៃកម្មនោះ ក៏ជាអនាគត កម្មនោះ ឈ្មោះថា កម្មនឹងមាន វិបាករបស់កម្ម នឹងមាន ។ កម្មណា ខ្លួនឯងនឹងមាន នឹងដល់នូវភាពជាអវិបាក ដោយន័យមុននោះឯង កម្មនោះ ឈ្មោះថា កម្មនឹងមាន វិបាករបស់កម្ម នឹងមិនទាន់មាន ។

បទថា **ឥទំ តថាគតស្ស** បណ្ឌិតគប្បីជ្រាបញាណជាគ្រឿងកំណត់ដឹង

នូវការផ្សេងគ្នានៃវិបាករបស់ព្រះតថាគត ដោយអាការទាំងពួងនេះថា ជាកម្លាំងទី ២ ព្រោះអត្ថថា មិនញាប់ញ័រ ដូច្នេះ ។

## អធិប្បាយកម្លាំងទី ២ ចប់

# អធិប្បាយកម្លាំងទី ៣

[ ៧៥ ] ក្នុងនិទ្ទេសនៃកម្លាំងទី ៣ របស់ព្រះតថាគត បទថា **មគ្គោ** ឬ **បដិបទា** ជាឈ្មោះរបស់កម្មនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **និរ-យគាមិនី** ជាដើម ដូចតទៅនេះ ឈ្មោះថា **និរយ** ព្រោះអត្ថថា ជាទីមិនគួរពេញចិត្ត ព្រោះអត្ថថា ជាទីដែលមិនមានការត្រេកអរ ។ ឈ្មោះថា **តិរច្ឆាន** ព្រោះអត្ថថា រំកិលអត្តភាពទៅដោយទទឹង មិនលាត្រង់ទៅលើ ។ តិរច្ឆាននោះឯង ឈ្មោះថា **តិរច្ឆានយោនិ** ។ ឈ្មោះថា **បិត្តិ** ព្រោះភាពជាអ្នកលះទៅហើយ អធិប្បាយថា ព្រោះភាពដែលខ្លួន លះលោកនេះទៅហើយ ។ ប្រេតនោះឯង ឈ្មោះថា **បិត្តិវិសយ** ។ ឈ្មោះថា **មនុស្ស** ព្រោះភាពជាអ្នកមានចិត្តខ្ពស់ មនុស្សនោះឯង ឈ្មោះថា **មនុស្សលោក** ។

ឈ្មោះថា **ទេវ** ព្រោះអត្ថថា ត្រេកអរដោយបញ្ចកាមគុណ ឬដោយការរុងរឿងដោយឋានៈ មានប្រការដ៏ក្រៃលែង ។ **ទេវ** នោះឯង ឈ្មោះថា **ទេវលោក** ។ តណ្ហា ព្រះមានព្រះភាគត្រាស់ហៅថា **វាន** គឺគ្រឿងរួបរឹត

**វាន** នោះ មិនមានក្នុងទីនោះ ព្រោះហេតុនោះ ទើបទីនោះ ឈ្មោះថា **និព្វាន** ។ ឈ្មោះថា **និរយគាមី** ព្រោះអត្ថថា រមែងទៅកាន់នរក ។ បទថា **និរយគាមី** នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់មគ្គ ។ ម្យ៉ាងទៀត បដិបទា ឈ្មោះថា **និរយគាមិនី** ។ ក្នុងបទដ៏សេសក៏មានន័យនេះឯង ។

ព្រះតថាគតទ្រង់ជ្រាបបដិបទាទាំងពួងនេះ ។

សេចក្តីនេះដូចម្តេច កាលជនទាំងឡាយ នៅក្នុងស្រុកទាំងមូល រួមគ្នាសម្លាប់ជ្រូក ១ ឬម្រឹគ ១ ចេតនារបស់ជនទាំងអស់មានជីវិតិន្ទ្រិយនៃសត្វដទៃជាអារម្មណ៍នោះឯង តែកម្មនោះរមែងផ្សេងគ្នាក្នុងខណៈនៃការព្យាយាមរបស់បុគ្គលទាំងនោះឯង ព្រោះថា ក្នុងជនទាំងនោះ ជនម្នាក់មានការពេញចិត្តកើតឡើងហើយ រមែងធ្វើការសម្លាប់ដោយយកចិត្តទុកដាក់ បុគ្គលម្នាក់ទៀត រមែងធ្វើព្រោះអ្នកដទៃបង្ខំដោយពាក្យថា ចូរអ្នកមក ចូរអ្នកធ្វើការសម្លាប់ បុគ្គលម្នាក់មិនហាមឃាត់ ត្រាច់ទៅ ហាក់បីដូចមានការពេញចិត្តរួមគ្នា ។ ក្នុងជនទាំងនោះ ជនម្នាក់កើតក្នុងនរកដោយកម្មនោះឯង ជនម្នាក់កើតក្នុងកំណើតសត្វតិរច្ឆាន ជនម្នាក់កើតក្នុងបិត្តិវិស័យ ។

ព្រះតថាគតទ្រង់ជ្រាបបុគ្គលនោះ ក្នុងខណៈនៃការព្យាយាមនោះឯងថា បុគ្គលនេះនឹងកើតក្នុងនរក បុគ្គលនេះនឹងកើតក្នុងកំណើតសត្វតិរច្ឆាន បុគ្គលនេះនឹងកើតក្នុងបិត្តិវិស័យ ព្រោះបុគ្គលនោះ ព្យាយាមហើយដោយទំនងនេះ រមែងទ្រង់ជ្រាបថា បណ្តាអ្នកកើតក្នុងនរក បុគ្គលនេះ នឹងកើតក្នុងមហានរក ៨ រណ្តៅ បុគ្គលនេះ នឹងកើតក្នុងឧស្សទនរក ១៦ រណ្តៅ ទ្រង់រមែងដឹងថា

បណ្ដាបុគ្គលដែលទៅកើតក្នុងកំណើតតិរច្ឆាន បុគ្គលនេះ នឹងកើតជាសត្វមិនមានជើង បុគ្គលនេះ នឹងកើតជាសត្វជើង ២ បុគ្គលនេះ នឹងកើតជាសត្វជើង ៤ បុគ្គលនេះ នឹងកើតជាសត្វជើងច្រើន ទ្រង់ជ្រាបថា បណ្ដាបុគ្គលដែលទៅកើតក្នុងបិត្តិវិស័យ បុគ្គលនេះ នឹងជានិជ្ឈាមតណ្ហិកប្រេត គឺប្រេតដែលត្រូវបំណាច់ដុតរោល បុគ្គលនេះ នឹងកើតជាខុប្បិបាសិកប្រេត គឺប្រេតដែលស្រេកឃ្លាន បុគ្គលនេះ នឹងកើតជាបរទត្តូបជីវិប្រេត គឺប្រេតអាស្រ័យទានអ្នកដទៃចិញ្ចឹមជីវិត ទ្រង់ជ្រាបថា បណ្ដាកម្មទាំងនោះ កម្មនេះ មិនអាចទាញមកនូវបដិសន្ធិ កម្មនេះ មានកម្លាំងគ្រោតគ្រាត និងមានផលទាក់ទងក្នុងបដិសន្ធិដែលកម្មដទៃឲ្យហើយ ។

ម្យ៉ាងទៀត កាលជនទាំងឡាយ ដែលនៅក្នុងស្រុកទាំងមូល រួមគ្នាប្រគេនចង្ហាន់បិណ្ឌបាត ចេតនារបស់ជនទាំងអស់ រមែងមានបិណ្ឌបាតជាអារម្មណ៍នោះ តែកម្មនោះ រមែងផ្សេងគ្នាដោយន័យមុននោះឯង ក្នុងខណៈនៃសេចក្ដីព្យាយាម របស់បុគ្គលទាំងនោះ ។ ក្នុងជនទាំងនោះ ជនពួកខ្លះរមែងកើតក្នុងទេវលោក ជនពួកខ្លះ រមែងកើតក្នុងមនុស្សលោក ។ ព្រះតថាគតទ្រង់ជ្រាបបុគ្គលនោះក្នុងខណៈនៃសេចក្ដីព្យាយាមនោះឯងថា បុគ្គលនេះ នឹងកើតក្នុងមនុស្សលោក បុគ្គលនេះ នឹងកើតក្នុងទេវលោក ព្រោះបុគ្គលនោះព្យាយាមហើយដោយទំនងនេះ ទ្រង់រមែងជ្រាបថា បណ្ដាបុគ្គលដែលកើតក្នុងទេវលោក បុគ្គលនេះ នឹងកើតក្នុងបរនិម្មិតវសវត្តីទាំងឡាយ បុគ្គលនេះ នឹងកើតក្នុងនិម្មានរតីទាំងឡាយ បុគ្គលនេះ នឹងកើតក្នុងតុសិតទាំងឡាយ

បុគ្គលនេះ នឹងកើតក្នុងយាមាទាំងឡាយ បុគ្គលនេះ នឹងកើតក្នុងតាវត្តិង្សទាំងឡាយ បុគ្គលនេះ នឹងកើតក្នុងចាតុម្មហារាជិកាទាំងឡាយ បុគ្គលនេះ នឹងកើតក្នុងភុម្មទេវតាទាំងឡាយ ចំណែកបុគ្គលនេះ នឹងកើតជាទេវរាជដែលចម្រើនបំផុត បុគ្គលនេះ នឹងកើតជាអ្នកបម្រើ មានតំណែងទី ២ ទី ៣ នៃទេវរាជនោះ ៗ ទ្រង់ជ្រាបថា បណ្តាបុគ្គលដែលកើតក្នុងមនុស្សទាំងឡាយ បុគ្គលនេះ នឹងកើតក្នុងខត្តិយត្រកូល បុគ្គលនេះ នឹងកើតក្នុងព្រាហ្មណត្រកូល បុគ្គលនេះ នឹងកើតក្នុងត្រកូលអ្នកជំនួញ បុគ្គលនេះ នឹងកើតក្នុងត្រកូលសូទ្រៈ បុគ្គលនេះ នឹងកើតជាព្រះរាជាក្នុងមនុស្សទាំងឡាយ បុគ្គលនេះ នឹងកើតជាអ្នកបម្រើតំណែងទី ២ ទី ៣ របស់ព្រះរាជានោះ ៗ ទ្រង់ជ្រាបថា បណ្តាកម្មទាំងនោះ កម្មនេះ នឹងមិនអាចទាញមកនូវបដិសន្ធិ កម្មនេះ មានកម្លាំងថោកថយមិនឲ្យផលទាក់ទង ព្រោះបដិសន្ធិដែលកម្មដទៃឲ្យហើយ ៗ

ម្យ៉ាងទៀត កាលព្រះយោគាវចរទាំងឡាយ ផ្តើមតាំងវិបស្សនានោះឯងព្រះតថាគត រមែងទ្រង់ជ្រាបថា វិបស្សនាដែលបុគ្គលប្រារព្ធហើយ ដោយទំនងនោះ បុគ្គលនេះ នឹងសម្រេចអរហត្ត បុគ្គលនេះ មិនអាចសម្រេចអរហត្តបុគ្គលនេះ នឹងបានជាអនាគាមីប៉ុណ្ណោះ បុគ្គលនេះ នឹងបានជាសកទាគាមីប៉ុណ្ណោះ បុគ្គលនេះ នឹងបានជាសោតាបន្នប៉ុណ្ណោះ បុគ្គលនេះ មិនអាចធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផល បុគ្គលនេះ នឹងតាំងនៅក្នុងវិបស្សនា មានត្រឹមតែលក្ខណៈជាអារម្មណ៍ប៉ុណ្ណោះ បុគ្គលនេះ នឹងតាំងនៅក្នុងបច្ចយបរិគ្គហញ្ញាណប៉ុណ្ណោះ បុគ្គលនេះ នឹងតាំងនៅក្នុងនាមរូបបរិគ្គហញ្ញាណប៉ុណ្ណោះ បុគ្គល

នេះ នឹងតាំងនៅក្នុងអរូបបរិគ្គហញ្ញាណប៉ុណ្ណោះ បុគ្គលនេះ នឹងកំណត់បាន ត្រឹមតែមហាភូតប៉ុណ្ណោះ បុគ្គលនេះ មិនអាចកំណត់អ្វីមួយបានឡើយ ។

កាលព្រះយោគាវចរទាំងឡាយធ្វើកសិណបរិកម្ម ព្រះតថាគត រមែងទ្រង់ជ្រាបថា កសិណបរិកម្មនៃបុគ្គលនេះ នឹងប្រព្រឹត្តទៅត្រឹមបរិកម្មប៉ុណ្ណោះ មិនអាចធ្វើនិមិត្តឲ្យកើតឡើង បុគ្គលនេះ អាចឲ្យនិមិត្តកើតឡើង តែមិនអាចសម្រេចអប្បនា បុគ្គលនេះ នឹងសម្រេចអប្បនា ហើយធ្វើឈានឲ្យជាបាទផ្តើមវិបស្សនាហើយ នឹងកាន់យកអរហត្ត ដូច្នេះ ។

**អធិប្បាយកម្លាំងទី ៣ ចប់**

# អធិប្បាយកម្លាំងទី ៤

[ ៧៦ ] ក្នុងនិទ្ទេសនៃកម្លាំងទី ៤ របស់ព្រះតថាគត បទថា **ឧនេកធាតុ-នានាធាតុំ** អធិប្បាយថា ព្រះតថាគត រមែងទ្រង់ជ្រាបហេតុផ្សេងៗ នៃខន្ធ ៥ យ៉ាងនេះថា នេះឈ្មោះថា រូបក្ខន្ធ ។បេ។ នេះឈ្មោះថា វិញ្ញាណក្ខន្ធ ។ បណ្តាខន្ធទាំងនោះ ព្រះតថាគតទ្រង់ជ្រាបខន្ធនីមួយៗ មានការផ្សេងគ្នាយ៉ាងនេះ គឺរូបក្ខន្ធមាន ១ ។បេ។ រូបក្ខន្ធមាន ១១ វេទនាខន្ធមាន ១ ។បេ។ វេទនាខន្ធមានច្រើនយ៉ាង សញ្ញាខន្ធមាន ១ ។បេ។ សញ្ញាខន្ធមានច្រើនយ៉ាង សង្ខារក្ខន្ធមាន ១ ។បេ។ សង្ខារក្ខន្ធមានច្រើនយ៉ាង វិញ្ញាណក្ខន្ធមាន ១ ។បេ។ វិញ្ញាណក្ខន្ធមានច្រើនយ៉ាង ។

បទថា **អាយតននានត្តំ** អធិប្បាយថា ព្រះតថាគតទ្រង់ជ្រាបការផ្សេងគ្នានៃអាយតនៈយ៉ាងនេះថា នេះឈ្មោះថា **ចក្ខាយតន ។បេ។** នេះឈ្មោះថា **ធម្មាយតន** ក្នុងអាយតនៈទាំងនោះ អាយតនៈ ១០ ជាកាមាវចរ អាយតនៈ ២ ប្រព្រឹត្តទៅក្នុងភូមិ ៤ ។

បទថា **ធាតុនានត្តំ** អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបការផ្សេងគ្នានៃធាតុយ៉ាងនេះថា នេះឈ្មោះថា **ចក្ខុធាតុ ។បេ។** នេះឈ្មោះថា **មនោ-វិញ្ញាណធាតុ** ក្នុងធាតុទាំងនោះ ធាតុ ១៦ ជាកាមាវចរ ធាតុ ២ ប្រព្រឹត្តទៅក្នុងភូមិ ៤ ។

បទថា **អនេកធាតុំ នានាធាតុំ លោកំ** នេះ ព្រះតថាគត ទ្រង់កាន់យកដើម្បីសម្តែងថា ព្រះតថាគតទ្រង់ជ្រាបការផ្សេងគ្នានៃលោក គឺឧបាទិន្នកសង្ខារនេះត្រឹមតែមួយប៉ុណ្ណោះ ក៏មិនមែន ទ្រង់ជ្រាបការផ្សេងគ្នានៃលោក គឺអនុបាទិន្នកសង្ខារផងដែរនោះឯង ។

ព្រះបច្ចេកពុទ្ធទាំងឡាយ និងព្រះអគ្គសាវកទាំង ២ រមែងដឹងការផ្សេងគ្នានៃលោក គឺឧបាទិន្នកសង្ខារដោយឯកទេសប៉ុណ្ណោះ មិនដឹងដោយពិស្តារ តែមិនជ្រាបការផ្សេងគ្នានៃអនុបាទិន្នកសង្ខារ ។ ឯព្រះសព្វញ្ញុពុទ្ធ ទ្រង់ជ្រាបការផ្សេងគ្នានៃលោក គឺអនុបាទិន្នកសង្ខារយ៉ាងនេះថា ដើមឈើនេះ មានពណ៌ស ព្រោះមានធាតុឈ្មោះនេះច្រើន ដើមឈើនេះមានពណ៌ខ្មៅ ... ដើមឈើនេះ មានសម្បករលោង ... ដើមឈើនេះ មានសម្បកក្រាស់ ... ដើមឈើនេះមានសម្បកស្តើង ព្រោះមានធាតុឈ្មោះនេះច្រើន ស្លឹកនៃដើមឈើ

នេះមានរូបយ៉ាងនេះ ដោយអំណាចនៃពណ៌ និងសណ្ឋានជាដើម ព្រោះមានធាតុឈ្មោះនេះច្រើន តែផ្កានៃដើមឈើនេះ មានពណ៌ខៀវ ព្រោះមានធាតុឈ្មោះនេះច្រើន មានពណ៌លឿង ... មានពណ៌ក្រហម ... មានពណ៌ស ... មានក្លិនក្រអូប ... មានក្លិនស្អុយ ... ផ្លែនៃដើមឈើនេះមានផ្លែតូច ព្រោះមានធាតុឈ្មោះនេះច្រើន មានផ្លែធំ ... មានផ្លែវែង ... មានផ្លែខ្លី ... មានផ្លែមូល ... មានសណ្ឋានល្អ ... មានសណ្ឋានមិនល្អ ... មានផ្លែរលោង ... មានផ្លែគ្រោតគ្រាត ... មានក្លិនក្រអូប ... មានក្លិនស្អុយ ... មានរសផ្អែម ... មានរសល្វីង ... មានរសជូរ ... មានរសហឹរ ... មានរសចត់ ព្រោះមានធាតុឈ្មោះនេះច្រើន ហើយបន្ទារបស់ដើមឈើនេះស្រួច ព្រោះមានធាតុឈ្មោះនេះច្រើន មិនស្រួច ... ត្រង់ ... វៀច ... មានពណ៌ក្រហម ... មានពណ៌ខ្មៅ ... មានពណ៌ខៀវ ... មានពណ៌ស ... ព្រោះថា ញាណនេះជាកម្លាំងនៃព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះ មិនមែនជាកម្លាំងនៃជនទាំងឡាយដទៃ ដូច្នេះឯង ។

**អធិប្បាយកម្លាំងទី ៤ ចប់**

# អធិប្បាយកម្លាំងទី ៥

[ ៧៧ ] ក្នុងនិទ្ទេសកម្លាំងទី ៥ របស់ព្រះតថាគត បទថា **ហីនាធិមុត្តិកា** បានដល់ មានអធ្យាស្រ័យថោកទាប ។ បទថា **បណីតាធិមុត្តិកា** បានដល់ មានអធ្យាស្រ័យល្អ ។ បទថា **សេវន្តិ** បានដល់ រមែងអាស្រ័យ

រមែងជាប់ចិត្ត ។ បទថា **ភជន្តិ** បានដល់ ចូលទៅជិត ។ បទថា **បយិរុបាសន្តិ** បានដល់ ចូលទៅរករឿយៗ ។ ពិតហើយ បើអាចារ្យ និងឧបជ្ឈាយ៍មិនមានសីល សទ្ធិវិហារិកមានសីល សទ្ធិវិហារិកទាំងនោះ រមែងមិនចូលទៅជិតអាចារ្យ និងឧបជ្ឈាយ៍របស់ខ្លួន រមែងចូលទៅរកភិក្ខុដែលប្រព្រឹត្តសមគួរ ដូចគ្នានឹងខ្លួនប៉ុណ្ណោះ ។ បើអាចារ្យ និងឧបជ្ឈាយ៍ ជាអ្នកប្រព្រឹត្តសមគួរ សទ្ធិវិហារិកជាអ្នកប្រព្រឹត្តមិនសមគួរ សទ្ធិវិហារិកទាំងនោះមិនចូលទៅជិតអាចារ្យ និងឧបជ្ឈាយ៍ រមែងចូលទៅជិតភិក្ខុដែលមានអធ្យាស្រ័យអាក្រក់ដូចខ្លួនប៉ុណ្ណោះ ។

ដើម្បីសម្ដែងថា ការចូលទៅសេពគប់ គប់រក ចូលទៅអង្គុយជិតដោយអាការយ៉ាងនេះ មានក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន មានហើយសូម្បីក្នុងអតីតកាល នឹងមានក្នុងអនាគតកាល ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អតីតម្បិ អទ្ធានំ** ជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

សួរថា បុគ្គលដែលទ្រុស្តសីល ចូលទៅសេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលទ្រុស្តសីលផងគ្នា បុគ្គលមានសីលចូលសេពគប់ គប់រក ចូលទៅអង្គុយជិតអ្នកមានសីលផងគ្នា បុគ្គលមានបញ្ញាថោកថយ ចូលទៅសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងបុគ្គលមានបញ្ញាថោកថយផងគ្នា បុគ្គលមានបញ្ញាល្អចូលទៅសេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលមានបញ្ញាល្អផងគ្នា ។ សួរថា អ្វីកំណត់ ឆ្លើយថា អជ្ឈាសយធាតុ ( អធ្យា-

ស្រ័យ ) រមែងកំណត់ ។

បានឮថា ភិក្ខុទាំងឡាយមានចំនួនច្រើន ត្រាច់ទៅកាន់ស្រុកមួយ ជាការទៅដើម្បីភិក្ខាជាគណៈ ។ ពួកមនុស្សនាំអាហារជាច្រើនដាក់បាត្រពេញ ហើយប្រគេន ហើយក៏បញ្ជូនទៅដោយពាក្យថា សូមលោកម្ចាស់ទាំងឡាយ ឆាន់អាហារតាមចំណែករបស់លោកម្ចាស់ទាំងឡាយ ។ ភិក្ខុទាំងឡាយ ក៏ពោលថា អាវុសោ ពួកមនុស្សប្រកបការងារ ដែលប្រកបដោយធាតុ ។ ព្រះថេរៈឈ្មោះចូឡាភយៈ អ្នកទ្រទ្រង់ព្រះត្រៃបិដក កាលទៅព្រមជាមួយភិក្ខុ ៥០០ រូប ដើម្បីថ្វាយបង្គំព្រះចេតិយក្នុងនាគទីប ជាបុគ្គលដែលមនុស្សទាំងឡាយក្នុងស្រុកមួយនិមន្តហើយ ក៏មានភិក្ខុដែលប្រព្រឹត្តមិនសមគួរមួយរូបទៅជាមួយព្រះថេរៈ ។ ក្នុងវិហារក្បែរខាង ក៏មានភិក្ខុដែលប្រព្រឹត្តមិនសមគួរមួយរូប ។ កាលភិក្ខុសង្ឃទាំង ២ ពួក ចូលមកកាន់ស្រុក ជនទាំង ២ នោះ គឺភិក្ខុដែលជាម្ចាស់ទីកដី និងភិក្ខុអាគន្តុកៈ មិនធ្លាប់ឃើញគ្នានឹងគ្នាអំពីមុនក៏ពិត តែភិក្ខុទាំង ២ នោះក៏ចូលគ្នាបាន បានឈរជជែកគ្នាសើចក្នុងទីមួយកន្លែង ។ ព្រះថេរៈឃើញហើយ ទើបពោលថា ធាតុសំយុត្ត ដែលព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបត្រាស់ទុកហើយ ។

កាលពោលថា អធ្យាស្រ័យកំណត់យ៉ាងនេះហើយ គប្បីសម្ដែងអត្ថនោះឯង ដោយធាតុសំយុត្ត ( សំយុត្តនិកាយ និទានវគ្គ ) ថា

ព្រះមានព្រះភាគ ទ្រង់ផ្ទំលើសយនាសម្រាប់អ្នកជំងឺត្រង់ភ្នំគិជ្ឈកូដ ទ្រង់ទតឃើញភិក្ខុទាំងឡាយ មានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាដើម ដែល

ចោមរោមដើម្បីជាប្រយោជន៍ដល់ការមើលថែព្រះអង្គ ភិក្ខុនីមួយៗ ដើរចង្ក្រម ជាមួយបរិស័ទរបស់ខ្លួន ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញសារីបុត្តកំពុងចង្ក្រមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកមានបញ្ញាច្រើន ដូច្នេះ ។ ចំណែករឿងទាំងអស់ គប្បីឲ្យពិស្តារ ។

**អធិប្បាយកម្លាំងទី ៥ ចប់**

# អធិប្បាយកម្លាំងទី ៦

[ ៧៨ ] ក្នុងនិទ្ទេសនៃកម្លាំងទី ៦ របស់ព្រះតថាគត បទថា **អាសយំ** បានដល់ សត្វទាំងឡាយរមែងប្រាថ្នា រមែងអាស្រ័យក្នុងសភាវៈណា សភាវៈនោះជាទីអាស្រ័យនៃសត្វទាំងឡាយ គឺជាទិដ្ឋិគតៈក្តី ជាយថាភូតញ្ញាណក្តី ។ បទថា **អនុសយំ** បានដល់ កិលេសដែលដេកត្រាំក្នុងខន្ធសន្តាន ដែលមិនទាន់លះបាន ។ បទថា **ចរិតំ** បានដល់ កុសល និងអកុសល ដែលមានកាយសង្ខារជាដើមតាក់តែងហើយ ។ បទថា **អធិមុត្តឹ** បានដល់ អជ្ឈាស្រ័យ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អប្បរជក្ខេ** ជាដើមដូចតទៅនេះ ឈ្មោះថា មានធូលី គឺកិលេសក្នុងភ្នែកតិច ព្រោះអត្ថថា ធូលី គឺរាគៈ

ទោសៈ មោហៈ ក្នុងភ្នែក គឺបញ្ញានៃសត្វទាំងនោះមានតិច គឺមានតិចតួច ។ ឈ្មោះថា មានធូលី គឺកិលេសក្នុងភ្នែកមានច្រើន ព្រោះធូលី គឺរាគៈ ទោសៈ មោហៈនោះឯងមានច្រើន ។ ព្រះមានព្រះភាគ ទ្រង់សំដែងនូវសត្វទាំងឡាយ ដែលមានកិលេសតិច និងមានកិលេសច្រើន ដោយបទទាំង ២ នេះ ។ ឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើម នៃបុគ្គលណាចាស់ក្លា បុគ្គលទាំងនោះ ឈ្មោះថា **តិក្ខិន្ទ្រិយេ** ។ ឥន្ទ្រិយទាំងនោះ នៃបុគ្គលណាទន់ខ្សោយ បុគ្គលនោះឈ្មោះថា **មុទិន្ទ្រិយេ** ។ កោដ្ឋាស មានអាសយជាដើមនៃបុគ្គលណាល្អ បុគ្គលនោះឈ្មោះថា **ស្វាការា** ។ កោដ្ឋាសទាំងនោះនៃបុគ្គលណា វិបរិត បុគ្គលនោះឈ្មោះថា **ទ្វាការា** ។ បុគ្គលពួកណាកំណត់ហេតុដែលអ្នកដទៃពោល និងដឹកនាំហើយ អាចដឹងបានដោយងាយ បុគ្គលនោះ ឈ្មោះថា **សុវិញ្ញាបយេ** ។ បើវិបរិតខុសអំពីនេះ ឈ្មោះថា **ទុវិញ្ញាបយេ** ។ បុគ្គលណាជាបុគ្គលសមគួរ គឺជាអ្នកដល់ព្រមដោយធម៌ជាឧបនិស្ស័យ ដើម្បីចាក់ធ្លុះនូវមគ្គផល បុគ្គលនោះឈ្មោះថា **ភព្វា** ។ បើវិបរិតខុសអំពីនេះ ឈ្មោះថា **អភព្វា** ។

ព្រះមានព្រះភាគ កាលទ្រង់តាំងមាតិកានៃញាណជាកម្លាំងទី ៦ ដោយអាការយ៉ាងនេះហើយ ឥឡូវនេះ កាលចែកអត្ថតាមលំដាប់ទើបត្រាស់បទថា **កតមោ ច សត្តានំ អាសយោ** ជាដើម ។ អត្ថនៃបទថា **សស្សតោ លោកោ** ជាដើម ក្នុងបទថា **កតមោ ច សត្តានំ អាសយោ** នោះ ខ្ញុំបានពោលទុកហើយក្នុងនិក្ខេបកណ្ឌខាងដើមនោះឯង ។ម្យ៉ាងទៀត បទថា

**ឥតិ ភវទិដ្ឋិសន្និស្សិតា វា** បានដល់ សត្វទាំងឡាយ ដែលអាស្រ័យ សស្សតទិដ្ឋិ ដោយអាការយ៉ាងនេះ ។ ពិតហើយ សស្សតទិដ្ឋិ ហៅថា ភវទិដ្ឋិ ក្នុងទីនេះឧច្ឆេទទិដ្ឋិហៅថា **វិភវទិដ្ឋិ** ព្រោះថា សត្វទាំងឡាយដែល មានការយល់ខុសយ៉ាងនេះ តែងអាស្រ័យទិដ្ឋិទាំង ២ នេះប៉ុណ្ណោះ ព្រោះ ថា ទិដ្ឋិទាំងអស់ ព្រះមានព្រះភាគទ្រង់សង្គ្រោះដោយសស្សតទិដ្ឋិ និងឧច្ឆេទ- ទិដ្ឋិ ដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ ( ក្នុងសំយុត្តនិកាយ និទាន- វគ្គ ) ថា ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែអាស្រ័យនូវចំណែកពីរ យ៉ាង គឺអត្ថិភាព ( សស្សតទិដ្ឋិ ) ១ នត្ថិភាព ( ឧច្ឆេទទិដ្ឋិ ) ១ ក្នុង ទិដ្ឋិទាំង ២ នោះ ការឃើញថា ទៀង ឈ្មោះថា អត្ថិភាព ការឃើញថា ដាច់សូន្យ ឈ្មោះថា នត្ថិភាព នេះជាអាសយៈនៃសត្វទាំងឡាយដែលជា បុថុជ្ជនអាស្រ័យវដ្តៈ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីសម្តែងអាសយៈនៃសត្វដែលបរិសុទ្ធ ដែលមិនអាស្រ័យវដ្តៈ ទើបត្រាស់បទថា **ឯតេ វា បន ឧភោ អន្តេ អនុបគម្ម** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯតេ វា បន** បានដល់ ( ទិដ្ឋិ ) ទាំង នោះឯង ។ បទថា **ឧភោ អន្តេ** បានដល់ ទីបំផុត ២ យ៉ាង គឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ បទថា **អនុបគម្ម** បានដល់ មិនកាន់យកហើយ ។ បទ ថា **ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ** បានដល់ ក្នុងភាវៈដែល ជាបច្ច័យនៃគ្នានិងគ្នា និងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នានិងគ្នាកើត

ឡើង ។ បទថា **អនុលោមិកា ខន្តិ** បានដល់ វិបស្សនាញាណ ។ បទថា **យថាភូតំ វា ញាណំ** បានដល់ មគ្គញ្ញាណ ។ ព្រះមានព្រះភាគទ្រង់អធិប្បាយថា សត្វទាំងឡាយ មិនចូលទៅអាស្រ័យទីបំផុតទាំងពីរ គឺសស្សតទិដ្ឋិ និងទាំងឧច្ឆេទទាំងនេះហើយ បានវិបស្សនាក្នុងបដិច្ចសមុប្បាទ និងក្នុងធម៌អាស្រ័យគ្នានិងគ្នាកើតឡើងឯណា និងបានមគ្គញ្ញាណដែលក្រៃលែងជាងវិបស្សនាញាណនោះឯណា នេះហៅថា អាសយៈរបស់សត្វទាំងឡាយ គឺនេះឈ្មោះថា អាសយៈរបស់សត្វទាំងឡាយ ដែលអាស្រ័យវដ្តៈ និងមិនអាស្រ័យវដ្តៈ ពាក្យនេះ គឺទីនៅអាស្រ័យ ទើបឈ្មោះថា ( របស់សត្វទាំងឡាយ ) នេះជាពាក្យអធិប្បាយដែលទូទៅរបស់លោកអាចារ្យទាំងឡាយ ។

ចំណែកអាចារ្យវិតណ្ឌវាទី គឺអាចារ្យដែលមានប្រក្រតី ពោលជំទាស់ពោលថា ធម្មតាមគ្គទម្លាយទីលំនៅប្រព្រឹត្តទៅ ហេតុអ្វីទើបលោកពោលថា មគ្គជាលំនៅ គប្បីឆ្លើយនឹងអាចារ្យនោះថា លោកសូធ្យអរិយវាស រឿងលំនៅរបស់ព្រះអរិយៈដែរឬទេ បើអាចារ្យវិតណ្ឌវាទីពោលថា ខ្ញុំបានសូធ្យ គប្បីពោលនឹងអាចារ្យវិតណ្ឌវាទីនោះថា លោកមិនដឹង ព្រោះលោកមិនបានសូធ្យ បើអាចារ្យវិតណ្ឌវាទីពោលថា ខ្ញុំកំពុងសូធ្យ គប្បីពោលថា សូមលោកនាំសូត្រមក បើអាចារ្យវិតណ្ឌវាទីនាំមក នុ៎ះជាការល្អ បើមិននាំមកទេ ក៏គប្បីនាំមកឯងថា ម្នាលភិក្ខុទាំងឡាយ អរិយវាស ( ធម៌ជាគ្រឿងអប់រំដ៏ប្រសើរ ) នេះមាន ១០ យ៉ាង ដែលពួកព្រះអរិយៈបានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ដូច្នេះជាដើម ។ ពិតហើយ សូត្រនេះរមែង

*សបញ្ជាក់ថា មគ្គជាទីនៅអាស្រ័យ ព្រោះហេតុនោះ ទើបពាក្យនោះ ជាពាក្យដែលព្រះមានព្រះភាគត្រាស់ល្អហើយនោះឯង ។*

*ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់ជ្រាបអាសយៈរបស់សត្វទាំងឡាយ នេះឈ្មោះថា ទ្រង់ជ្រាបក្នុងខណៈដែលគួរឃើញខុសទាំងនេះ មិនប្រព្រឹត្តទៅ និងក្នុងខណៈដែលវិបស្សនាញាណ និងមគ្គញ្ញាណទាំងនេះ មិនប្រព្រឹត្តទៅនេះឯង ។ ពាក្យនេះ ព្រះសារីបុត្តបានអធិប្បាយ ( ក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា យថាភូតញ្ញាណ រមែងដឹងនូវបុគ្គលអ្នកសេពកាម គឺដឹងនូវបុគ្គលអ្នកសេពកាមថា បុគ្គលនេះធ្ងន់ក្នុងកាម ដេកត្រាំក្នុងកាម ចុះចិត្តស៊ប់ក្នុងកាម ដឹងនូវបុគ្គលអ្នកសេពនូវនេក្ខម្មៈថា បុគ្គលនេះ ធ្ងន់ក្នុងនេក្ខម្មៈ ដេកត្រាំក្នុងនេក្ខម្មៈ ចុះចិត្តស៊ប់ក្នុងនេក្ខម្មៈ ដឹងនូវបុគ្គលអ្នកសេពនូវព្យាបាទ ។បេ។ ដឹងនូវបុគ្គលសេពនូវអព្យាបាទ ។បេ។ ដឹងនូវបុគ្គលអ្នកសេពនូវថីនមិទ្ធៈ ។បេ។ ដឹងនូវបុគ្គលអ្នកសេពនូវអាលោកសញ្ញាថា បុគ្គលនេះធ្ងន់ក្នុងអាលោកសញ្ញា ដេកត្រាំក្នុងអាលោកសញ្ញា ចុះចិត្តស៊ប់ក្នុងអាលោកសញ្ញា ដូច្នេះ ។*

*គប្បីជ្រាបក្នុងនិទ្ទេសនៃអនុស័យដូចតទៅនេះ ឈ្មោះថា* **កាមរាគានុស័យ** *ព្រោះអត្ថថា កាមរាគៈនោះផង ជាធម៌ដេកត្រាំ ព្រោះអត្ថថា មិនទាន់លះបានផង ។ សូម្បីក្នុងបទដ៏សេសទាំងឡាយ ក៏ន័យនេះឯង ។ បទថា* **យំ លោកេ បិយរូបំ** *បានដល់ រូបណាដែលឲ្យនូវការស្រឡាញ់កើតឡើងក្នុងលោកនេះ ។ បទថា* **សាតរូបំ** *បានដល់ រូបដែលញុំាងការ*

ពេញចិត្តឲ្យកើតឡើង មានការពេញចិត្តជាបទដ្ឋាន ដែលជាអារម្មណ៍ដែលគួរប្រាថ្នា ។ បទថា **ឯត្ថ សត្តានំ រាគានុសយោ អនុសេតិ** សេចក្តីថា រាគានុស័យរបស់សត្វទាំងឡាយ រមែងដេកត្រាំក្នុងអារម្មណ៍ដែលគួរប្រាថ្នានេះ ព្រោះអត្ថថា មិនទាន់លះបាន ប្រៀបដូចកាលសត្វលិចក្នុងទឹកហើយ ទឹកប៉ុណ្ណោះរមែងមានខាងក្រោម ខាងលើ និងដោយជុំវិញយ៉ាងណា ឈ្មោះថា ការកើតឡើងនៃរាគៈក្នុងអារម្មណ៍ដែលគួរប្រាថ្នា ដែលសត្វទាំងឡាយប្រព្រឹត្តសន្សំមកហើយក៏យ៉ាងនោះឯង ការកើតឡើងនៃបដិឃៈ ព្រោះអារម្មណ៍ដែលមិនគួរប្រាថ្នា ក៏ដូចគ្នា ។ បទថា **ឥតិ ឥមេសុ ទ្វីសុ ធម្មេសុ** បានដល់ ក្នុងធម៌ដែលជាឥដ្ឋារម្មណ៍ដែលមានកាមរាគៈ និងក្នុងធម៌ដែលជាអនិដ្ឋារម្មណ៍ ដែលមានបដិឃៈទាំងពីរនេះ ដោយអាការយ៉ាងនេះ ។ បទថា **អវិជ្ជា អនុបតិតា** បានដល់ អវិជ្ជាជាធម៌សម្បយុត្តដោយកាមរាគៈ និងបដិឃៈធ្លាក់ទៅហើយដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ ។ បទថា **តទេកដ្ឋោ** បានដល់ ឈ្មោះថា តាំងនៅក្នុងទីជាមួយគ្នាដោយអំណាចតាំងនៅក្នុងឋានៈជាមួយគ្នាដោយសម្បយុត្តជាមួយអវិជ្ជានោះ ។ បទថា **មានោ ច ទិដ្ឋិ ច វិចិកិច្ឆា ច** បានដល់ មានៈ ៩ យ៉ាង ទិដ្ឋិ ៦២ យ៉ាង និងវិចិកិច្ឆាមានវត្ថុ ៨ ។ ភវរាគានុស័យក្នុងទីនេះគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សង្គ្រោះដោយកាមរាគានុស័យនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃចរិត ដូចតទៅនេះថា បុញ្ញាភិសង្ខារ គឺចេតនា ១៣ អបុញ្ញាភិសង្ខារ គឺចេតនា ១២ អនេញ្ជាភិសង្ខារ គឺចេតនា

៤ ។

ក្នុងអភិសង្ខារទាំងនោះ អភិសង្ខារដែលជាកាមាវចរជាបរិត្តភូមិ ក្រៅអំពីនេះ ជាមហាភូមិ គឺភូមិមានអារម្មណ៍ធំ ។

ម្យ៉ាងទៀត ក្នុងអភិសង្ខារទាំង ៣ នោះ អភិសង្ខារណាមួយមានវិបាកតិច គប្បីជ្រាបថា ជាបរិត្តភូមិ មានវិបាកច្រើន គប្បីជ្រាបថា ជាមហាភូមិដូច្នេះ ។

ក្នុងនិទ្ទេសនៃអធ្យាស្រ័យ ( អធិមុត្តិ ) ខ្ញុំបានប្រកាសហើយ ខាងដើមនោះឯង ។

សួរថា អធ្យាស្រ័យនេះ ព្រះមានព្រះភាគ ត្រាស់ខាងដើមហើយ ព្រោះហេតុអ្វីទើបកាន់យកទៀត ឆ្លើយថា ព្រោះអធ្យាស្រ័យនេះ ព្រះមានព្រះភាគទ្រង់កាន់យកដោយចែកចេញខាងដើម ដោយអំណាចនៃការសម្ដែងញាណដែលជាកម្លាំងអធ្យាស្រ័យក្នុងទីនេះ ទ្រង់កាន់យកដើម្បីសម្ដែងភាវៈដែលសត្វទាំងឡាយ ជាអ្នកមានឥន្ទ្រិយចាស់ក្លា និងឥន្ទ្រិយទន់ខ្សោយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃសត្វទាំងឡាយដែលមានធូលី គឺកិលេសក្នុងភ្នែកក្រាស់ដូចតទៅនេះ បទថា **ឧស្សទគតានិ** បានដល់ ដល់នូវភាពបរិបូណ៌ បើពោលដោយអំណាចនៃលំដាប់ក្នុងការប្រហារហើយ និទ្ទេសនេះទ្រង់អធិប្បាយច្បាស់លំដាប់ ។ បទថា **អនុស្សទគតានិ** បានដល់ មិនបរិបូណ៌ ។

ឈ្មោះថា **ឥន្ទ្រិយ** គឺធម៌ដែលជាឧបនិស្ស័យ ព្រះមានព្រះភាគត្រាស់

ក្នុងនិទ្ទេសនៃសត្វដែលមានឥន្ទ្រិយចាស់ក្លា និងមានឥន្ទ្រិយទន់ខ្សោយ ។ បណ្ឌិតគប្បីជ្រាបការប្រកបសេចក្តីថា ក្នុងបទថា **តិក្ខិន្ទ្រិយមុទិន្ទ្រិយ** នេះ ក្នុងនិទ្ទេសដោយច្បាស់លំដាប់តាមន័យដែលពោលហើយខាងដើមនោះឯង ។

ក្នុងនិទ្ទេសនៃអាការអាក្រក់ជាដើម ក៏ដូចគ្នា ។ បទថា **ទាចាសយា** បានដល់ មានអជ្ឈាស្រ័យជាអកុសល ។ បទថា **ទាបចរិតា** បានដល់ បរិបូរណ៍ដោយអបុញ្ញាភិសង្ខារ ។ បទថា **ទាចាធិមុត្តិកា** បានដល់ ត្រេកអរក្រៃលែងក្នុងសក្កាយ ( ឧបាទានក្ខន្ធ ៥ ) គឺមានអជ្ឈាស្រ័យក្នុងវដ្ដៈ ។

ក្នុងនិទ្ទេសនៃអាការល្អ អនុស័យ ឈ្មោះថា ល្អ មិនមាន ហេតុនោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា អនុស័យល្អ ពាក្យដ៏សេស គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃភព្វបុគ្គល និងអភព្វបុគ្គលដូចតទៅ

បទថា **កម្មាវរណេន** បានដល់ ដោយអនន្តរិយកម្ម ៥ យ៉ាង ។ បទថា **កិលេសាវរណេន** បានដល់ ដោយនិយតមិច្ឆាទិដ្ឋិ ។ បទថា **វិបា-កាវរណេន** បានដល់ ដោយអហេតុកបដិសន្ធិ ។ ព្រោះការចាក់ធ្លុះនូវអរិយមគ្គ មិនមានដល់បុគ្គលជាទុហេតុកៈ ហេតុនោះ ទុហេតុកបដិសន្ធិ ក៏គប្បីជ្រាបថាជាគ្រឿងរាំង គឺវិបាកដូចគ្នា ។ បទថា **អស្សទ្ធា** បានដល់ វៀរចាកសទ្ធាក្នុងព្រះពុទ្ធជាដើម ។ បទថា **អច្ឆន្ទិកា** បានដល់ វៀរចាកឆន្ទៈក្នុងកុសលនៃបុគ្គលដែលប្រាថ្នា ដើម្បីធ្វើ ។ មនុស្សទាំងឡាយ អ្នក

ឧត្តរកុរុទ្វីប ចូលទៅកាន់ឋានៈនៃបុគ្គលមិនមានធនៈ ។ បទថា **ទុប្បញ្ញា** បានដល់ ជាអ្នកសាបសូន្យចាកកវង្គប្បញ្ញា ។ កាលភវង្គប្បញ្ញា សូម្បីបរិបូណ៌ ភវង្គនៃបុគ្គលណាមិនជាបាទដល់លោកុត្តរ បុគ្គលនោះក៏ឈ្មោះថាមានបញ្ញាថោកថយនោះឯង ។ បទថា **អភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ** បានដល់ មិនគួរឈានចុះកាន់មគ្គ ពោល គឺសម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ។ បទថា **ឧ កម្មាវរណេន** ជាដើម បណ្ឌិតគប្បីជ្រាបដោយន័យដែលផ្ទុយគ្នាតាមដែលពោលហើយ ។ ញាណនេះ គប្បីចែកចេញជា ២ ញាណ គឺឥន្ទ្រិយបរោបរិយត្តិញាណ និងអាសយានុសយញ្ញាណ ។ ពិតហើយ ញាណនេះ ឥន្ទ្រិយបរោបរិយត្តិញាណ ព្រះមានព្រះភាគ ក៏ទ្រង់ចែកដោយអាសយានុសយញ្ញាណ ព្រោះហេតុនោះ ទើបញាណទាំង ២ នេះ ចាត់ជាញាណដូចគ្នា ឈ្មោះថាញាណជាកម្លាំង ១ ។

**អធិប្បាយកម្លាំងទី ៦ ចប់**

# អធិប្បាយកម្លាំងទី ៧

[ ៧៩ ] ក្នុងនិទ្ទេសនៃកម្លាំងទី ៧ របស់ព្រះតថាគត បុគ្គលណាសម្លឹងព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ឈាយី** ជន ៤ ពួកដែលចូលឈាន ព្រះមានព្រះភាគត្រាស់ហៅថា **ចត្តារោ ឈាយី** ។ ក្នុងជនទាំងនោះ ក្នុងបុគ្គល ៤ ពួកដំបូង បុគ្គលទី ១ បានសមាបត្តិនោះឯង

រមែងសម្គាល់ថា អញមិនបាន រមែងសម្គាល់កម្មដ្ឋានដែលមាន ថាមិនមែនកម្មដ្ឋាន បុគ្គលនេះគប្បីជ្រាបថា ជាអ្នកបានឈានមិនស្ទាត់ជំនាញ ដូច្នេះ ។

បុគ្គលទី ២ មិនបានសមាបត្តិ រមែងសម្គាល់ថា អញបានសមាបត្តិ រមែងសម្គាល់វត្ថុដែលមិនមែនកម្មដ្ឋាននោះឯង ថាជាកម្មដ្ឋាន បុគ្គលនេះគប្បីជ្រាបថា ឈ្មោះថា **ធិទ្ធាឈាយី** គឺបុគ្គលចូលឈានដេកលក់ បុគ្គលនេះដេកលក់ហើយភ្ញាក់ឡើង ក៏សម្គាល់យ៉ាងនេះ ។

បុគ្គលទី ៣ បានសមាបត្តិ សម្គាល់ថា អញបានសមាបត្តិ រមែងសម្គាល់កម្មដ្ឋាននោះឯង ថាជាកម្មដ្ឋានមាន បុគ្គលនេះគប្បីជ្រាបថា បានឈានដែលស្ទាត់ជំនាញហើយ ។

បុគ្គលទី ៤ មិនបានឈានសម្គាល់ថា អញបានឈាន រមែងសម្គាល់វត្ថុដែលមិនមែនកម្មដ្ឋាននោះឯង ថាមិនមែនកម្មដ្ឋាន ។

ក្នុងទីនេះ ជន ២ ពួក មិនបានឈានយ៉ាងនេះឯង ព្រះមានព្រះភាគត្រាស់ហៅថា **ឈាយី** ព្រោះជនទាំងនោះសង្គ្រោះចូលក្នុងអ្នកចម្រើនឈានទាំងឡាយ ។

ក្នុងបុគ្គល ៤ ពួក ពួកទី ២ បុគ្គលកាលសង្កត់នូវធម៌ដែលជាសត្រូវចំពោះសមាធិដោយសេចក្តីព្យាយាមដែលប្រព្រឹត្តទៅជាមួយសង្ខារ ឈ្មោះថា ចូលឈានយឺតយូរ ។ បុគ្គលនោះតាំងនៅក្នុងឈានអស់វារៈនៃចិត្ត ១ ឬ ២ ហើយក៏ចេញដោយរហ័ស ឈ្មោះថា ចេញរហ័ស ។ បុគ្គលជម្រះធម៌ជាសត្រូវចំពោះសមាធិបានដោយងាយ ឈ្មោះថា ចូលឈានរហ័ស ។

បុគ្គលមិនចេញចាកឈាន តាមដែលកំណត់ ឲ្យពេលវេលាកន្លងទៅយូរ ហើយទើបចេញអំពីឈាន ឈ្មោះថា ចេញយឺតយូរ ។ ជនទាំង ២ ពួក ក្រៅអំពីនេះ គប្បីជ្រាបដោយន័យនេះឯង ។ ជនទាំង ៤ ពួកនេះ ជាអ្នកបានសមាបត្តិនោះឯង ។

ក្នុងបុគ្គល ៤ ពួក ពួកទី ៣ បុគ្គលឈ្លាសក្នុងការកំណត់ចែកអង្គឈានយ៉ាងនេះថា ឈាននេះមានអង្គ ៥ ឈាននេះ មានអង្គ ៤ ដូច្នេះ ឈ្មោះថា ជាអ្នកឈ្លាសក្នុងការធ្វើចិត្តឲ្យទីងទីងក្នុងសមាធិ តែមិនឈ្លាសដើម្បីសង្កត់នីវរណៈទាំងឡាយ ហើយឲ្យចិត្តតាំងនៅក្នុងធម៌ ជាគ្រឿងរក្សាចិត្ត ឈ្មោះថា ជាអ្នកឈ្លាសក្នុងការចូលសមាបត្តិ តែមិនឈ្លាសក្នុងការធ្វើចិត្តឲ្យទីងទីង ។ ជន ៣ ពួក ក្រៅអំពីនេះ គប្បីជ្រាបដោយន័យនេះឯង ។ បុគ្គល ៤ ពួកនេះ ជាអ្នកបានសមាបត្តិទាំងអស់ ។

ឥឡូវនេះ បុគ្គលទាំងនេះអាស្រ័យឈានពួកណា ឈ្មោះថា **ឈាយី** ដើម្បីសម្តែងឈានទាំងនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ចត្តារិ ឈានានិ** ជាដើម ។ បណ្តាពាក្យទាំងនោះ ឈាន ៤ និងវិមោក្ខ ៣ ពោលដោយអត្ថ ខ្ញុំបានអធិប្បាយទុកហើយ ក្នុងអដ្ឋកថាធម្មសង្គណី ខាងដើមនោះឯង ។ អត្ថនៃវិមោក្ខនៃបទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយក្នុងទីនោះដូចគ្នា ។ មួយវិញទៀត ក្នុងទីនេះ វិមោក្ខ ៧ តាមលំដាប់ ឈ្មោះថា វិមោក្ខ ព្រោះរួចផុតវិសេសចាកធម៌ដែលជាសត្រូវ និងព្រោះបង្អោនទៅក្នុងអារម្មណ៍ក្នុងខណៈដែលចិត្តជាអប្បនាហើយ ។ វិមោក្ខទី ៨ ឈ្មោះ

ថា **អបគតវិមោក្ខ** ព្រោះរួចផុតវិសេសហើយដោយសញ្ញាវេទយិតនិរោធដោយប្រការទាំងពួង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសមាធិទាំងឡាយដែលជាចតុក្កន័យ និងបញ្ចកន័យដូចតទៅនេះ

សមាធិក្នុងបឋមជ្ឈាន ឈ្មោះថា ប្រព្រឹត្តទៅដោយវិតក្កនិងវិចារ ។ ក្នុងបញ្ចកន័យ សមាធិក្នុងទុតិយជ្ឈាន ឈ្មោះថា ជាសមាធិមិនមានវិតក្ក មានត្រឹមតែវិចារ ។ ក្នុងចតុក្កន័យក្តី ក្នុងបញ្ចកន័យក្តី ។ សមាធិក្នុងឈានទាំង ៣ ខាងលើ ឈ្មោះថា សមាធិមិនមានវិតក្ក មិនមានវិចារ ។ ពិតហើយក្នុងសមាបត្តិទាំងឡាយ ពាក្យថា សមាធិក្តី ជាឈ្មោះរបស់សមាបត្តិ ៨ ដោយលំដាប់ ព្រោះហេតុអ្វី ព្រោះមានសភាវៈនៃចិត្តមានអារម្មណ៍ ។ ពាក្យថា សមាធិ មិនជាឈ្មោះរបស់និរោធសមាបត្តិ ព្រោះមិនមានសភាវៈដែលចិត្ត មានអារម្មណ៍តែមួយនោះ ។ បទថា **ហានភាគិយោ ធម្មោ** បានដល់ ការដែលសញ្ញាមនសិការរបស់ព្រះយោគាវចរ ដែលចេញចាកបឋមជ្ឈានជាដើម ដែលមិនស្ទាត់ជំនាញ ស្ទុះទៅកាន់កាមជាដើម ។ បទថា **វិសេសភាគិយោ ធម្មោ** បានដល់ សញ្ញាមនសិការរបស់ព្រះយោគាវចរដែលចេញចាកបឋមជ្ឈានជាដើម ដែលស្ទាត់ជំនាញហើយ ស្ទុះទៅកាន់ទុតិយជ្ឈាន ។ ការស្ទុះទៅនៃឈាន ដែលស្ទាត់ជំនាញហើយ ឈ្មោះថាការចេញដែលព្រះមានព្រះភាគត្រាស់ដោយពាក្យថា **វោទានម្បិ** វុដ្ឋានំនេះ ។ ពិតហើយ ឈានដែលស្ទាត់ជំនាញដែលជាខាងក្រោមៗ រមែង

*ជាបទដ្ឋានដល់ឈានខាងលើៗ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា* **វោទានម្បិ វុដ្ឋានំ** ។ *ឈ្មោះថា ការចេញចាកកវគ្គ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយដោយបទថា* **តម្ហា តម្ហា សមាធិម្ហា វុដ្ឋានម្បិ វុដ្ឋានំ** ។ *ពិតហើយ ការចេញចាកឈានទាំងអស់ រមែងចេញចាកនិរោធសមាបត្តិ ដោយផលសមាបត្តិតែម្យ៉ាង ។ នេះឈ្មោះថាការចេញដែលជាបាលីមុត្តកៈ ដូច្នេះឯង ។*

**អធិប្បាយកម្លាំងទី ៧ចប់**

# អធិប្បាយកម្លាំងទី ៨

*[ ៨០ ] ក្នុងនិទ្ទេសនៃកម្លាំងទី ៨ របស់ព្រះតថាគត បទទាំងពួងមានបទថា* **បុព្វេនិវាសំ** *ជាដើម ខ្ញុំពោលពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។*

**អធិប្បាយកម្លាំងទី ៨ ចប់**

# អធិប្បាយកម្លាំងទី ៩

*[ ៨១ ] ក្នុងនិទ្ទេសនៃកម្លាំងទី ៩ របស់ព្រះតថាគត ពាក្យទាំងពួងមានបទថា* **ទិព្វេន ចក្ខុនា** *ជាដើម ខ្ញុំពោលពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។*

**អធិប្បាយកម្លាំងទី ៩ ចប់**

# អធិប្បាយកម្លាំងទី ១០

[ ៨២ ] ក្នុងនិទ្ទេសនៃកម្លាំងទី ១០ របស់ព្រះតថាគត បទថា **ចេតោវិមុត្តិ** បានដល់ ផលសមាធិ ។ បទថា **បញ្ញាវិមុត្តិ** បានដល់ ផលញ្ញាណ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។ នេះជាពាក្យអធិប្បាយដែលប្រើទូទៅរបស់អាចារ្យទាំងឡាយ ក្នុងពាក្យទាំងនេះ ប្រមាណប៉ុណ្ណោះ ។

ចំណែកបរវាទីពោលថា ឈ្មោះថា **ទសពលញ្ញាណ** ចែកចេញជាចំណែក ១ មិនមាន នេះជាប្រភេទនៃសព្វញ្ញុតញ្ញាណទាំងនោះ ។ សេចក្តីនោះ មិនគប្បីឃើញយ៉ាងនោះ ព្រោះថា ទសពលញ្ញាណមួយបែប សព្វញ្ញុតញ្ញាណមួយបែប ។ ទសពលញ្ញាណរមែងដឹងនូវកិច្ចរៀងៗ ខ្លួនប៉ុណ្ណោះ ឯសព្វញ្ញុតញ្ញាណ រមែងដឹងនូវកិច្ចដែលទសពលញ្ញាណដឹងហើយនោះផង កិច្ចដ៏សេសអំពីទសពលញ្ញាណដឹងហើយនោះផង ។

ពិតហើយ បណ្តាទសពលញ្ញាណ ញាណទី ១ រមែងដឹងនូវធម៌ជាហេតុ និងមិនមែនជាហេតុប៉ុណ្ណោះ ។

ញាណទី ២ ដឹងនូវការផ្សេងគ្នានៃកម្ម និងវិបាកប៉ុណ្ណោះ ។

ញាណទី ៣ ដឹងការកំណត់នៃការប្រព្រឹត្តទៅរបស់កម្មប៉ុណ្ណោះ ។

ញាណទី ៤ ដឹងហេតុនៃការផ្សេងគ្នារបស់ធាតុប៉ុណ្ណោះ ។

ញាណទី ៥ ដឹងនូវអធិមុត្តិ គឺអធ្យាស្រ័យរបស់សត្វទាំងឡាយប៉ុណ្ណោះ ។

ញាណទី ៦ ដឹងនូវភាពដែលឥន្ទ្រិយទាំងឡាយ ជាធម្មជាតចាស់ក្លា និងទន់ខ្សោយប៉ុណ្ណោះ ។

ញាណទី ៧ ដឹងនូវការសៅហ្មងជាដើម របស់សត្វទាំងឡាយប៉ុណ្ណោះ មួយអន្លើដោយឈានជាដើមប៉ុណ្ណោះ ។

ញាណទី ៨ ដឹងនូវការបន្តនៃខន្ធដែលធ្លាប់អាស្រ័យមកហើយ ក្នុងកាលមុនប៉ុណ្ណោះ ។

ញាណទី ៩ ដឹងនូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយប៉ុណ្ណោះ ។

ញាណទី ១០ ដឹងនូវការកំណត់សច្ចៈប៉ុណ្ណោះ ។

ឯសព្វញ្ញុតញ្ញាណ ដឹងទូទៅនូវធម៌ដែលទសពលញ្ញាណទាំងនោះគប្បីដឹងផង ដឹងនូវធម៌ដ៏ក្រៃលែងជាងទសពលញ្ញាណនោះផង តែសព្វញ្ញុតញ្ញាណនោះ រមែងធ្វើកិច្ចទាំងពួងនៃទសពលញ្ញាណទាំងនោះ មិនបានទាំងអស់ ព្រោះថា សព្វញ្ញុតញ្ញាណនោះ ជាឈានតែមិនអាចជាអប្បនា ជាឥទ្ធិតែមិនអាចសម្តែងឫទ្ធិ ជាមគ្គ តែមិនអាចញុំាងកិលេសឲ្យអស់ទៅ ដូច្នេះ ។

ម្យ៉ាងទៀត បរវាទី គប្បីសួរយ៉ាងនេះថា ឈ្មោះថា ទសពលញ្ញាណនេះ ប្រព្រឹត្តទៅជាមួយវិតក្ក និងវិចារ មិនមានវិតក្ក មានត្រឹមតែវិចារ មិនមានវិតក្ក មិនមានវិចារ ជាកាមាវចរ ជារូបាវចរ ជាអរូបាវចរ ជាលោកិយ ឬជាលោកុត្តរ ដូច្នេះ ។ បើលោកដឹង ក៏នឹងពោលថា ញាណទាំង ៧ តាមលំដាប់ គឺតាំងអំពីឋានាឋានញ្ញាណជាដើម ប្រព្រឹត្តទៅដោយវិតក្ក និងវិចារ ដូច្នេះ បន្ទាប់អំពីនោះ នឹងពោលថា ញាណទាំង ២ ខាងមុខ គឺ

*បុព្វេនិវាសានុស្សតិញ្ញាណ និងចុតូបបាតិញ្ញាណ មិនមានវិតក្ក មិនមានវិចារ ដូច្នេះ បន្ទាប់អំពីនោះ ក៏នឹងពោលថា អាសវក្ខយញ្ញាណប្រព្រឹត្តទៅដោយវិតក្ក និងវិចារក៏មាន មិនមានវិតក្ក មានតែវិចារក៏មាន មិនមានវិតក្ក មិនមានវិចារក៏មាន ដូច្នេះ ដោយទំនងនោះ ក៏នឹងពោលទៀតថា ញាណ ៧ ដោយលំដាប់ តាំងអំពីឋានាឋានញ្ញាណជាដើម ជាកាមាវចរ ញាណ ២ បន្ទាប់អំពីនោះ ជារូបាវចរ ញាណ ១ ចុងក្រោយ ជាលោកុត្តរ ដូច្នេះ តែនឹងពោលថា សព្វញ្ញុតញ្ញាណ ប្រព្រឹត្តទៅជាមួយវិតក្ក និងវិចារប៉ុណ្ណោះ ជាកាមាវចរប៉ុណ្ណោះ ជាលោកិយប៉ុណ្ណោះ ដូច្នេះ ។*

*ដោយប្រការដូច្នេះ ទើបទសពលញ្ញាណមួយបែប សព្វញ្ញុតញ្ញាណជាញាណមួយបែប ដូច្នេះឯង ។៚*

## **អដ្ឋកថាញាណវិភង្គ ចប់**

# អភិធម្មបិដក

## ខុទ្ទកវត្ថុវិភង្គ

[ ៨៣ ] សេចក្តីស្រវឹងព្រោះជាតិ សេចក្តីស្រវឹងព្រោះគោត្ត សេចក្តីស្រវឹងព្រោះការមិនមានរោគ សេចក្តីស្រវឹងព្រោះវ័យ សេចក្តីស្រវឹងព្រោះជីវិត សេចក្តីស្រវឹងព្រោះលាភ សេចក្តីស្រវឹងព្រោះសក្ការៈ សេចក្តីស្រវឹងព្រោះការគោរព សេចក្តីស្រវឹងព្រោះខ្លួនជាប្រធាន សេចក្តីស្រវឹងព្រោះបរិវារ សេចក្តីស្រវឹងព្រោះភោគៈ សេចក្តីស្រវឹងព្រោះវណ្ណៈ សេចក្តីស្រវឹងព្រោះការចេះដឹង សេចក្តីស្រវឹងព្រោះបញ្ញា សេចក្តីស្រវឹង ព្រោះដឹងរាត្រី សេចក្តីស្រវឹង ព្រោះប្រព្រឹត្តបិណ្ឌបាត សេចក្តីស្រវឹងព្រោះការណ៍គេមើលងាយមិនបាន សេចក្តីស្រវឹងព្រោះឥរិយាបថ សេចក្តីស្រវឹងព្រោះឫទ្ធិ សេចក្តីស្រវឹងព្រោះយស សេចក្តីស្រវឹងព្រោះសីល សេចក្តីស្រវឹងព្រោះឈាន សេចក្តីស្រវឹង ព្រោះសិល្បសាស្ត្រ សេចក្តីស្រវឹងព្រោះកម្ពស់ សេចក្តីស្រវឹងព្រោះទំហំ សេចក្តីស្រវឹងព្រោះទ្រង់ទ្រាយ សេចក្តីស្រវឹងព្រោះសរីរៈពេញលេញ សេចក្តីស្រវឹង សេចក្តីប្រមាទ សេចក្តីចចេស សេចក្តីប្រណាំងវាសនា សេចក្តីប្រាថ្នាក្រៃពេក សេចក្តីប្រាថ្នាធំ សេចក្តីប្រាថ្នាលាមក កិលេសជាតដូចស្នែង សេចក្តីតិះដៀល ការឃ្លេងឃ្លោង ( ហឹហា ) សេចក្តីប្រព្រឹត្តមិនស្មោះស្មើ សេចក្តីមិនត្រេកអរ សេចក្តីខ្ជិលច្រអូស សេចក្តីមិតពត់ សេចក្តីស្រវឹងព្រោះភត្ត ភាពនៃចិត្តរួញរា ការកុហក ការរួសរាយ ការធ្វើនូវនិមិត្ត ការធ្វើនូវសេចក្តីគំរាម ការទាក់លាភដោយលាភ សេចក្តីប្រកាន់ថា អញប្រសើរជាងគេ សេចក្តីប្រកាន់ថា អញស្មើ

នឹងគេ សេចក្ដីប្រកាន់ថា អញថោកទាបជាងគេ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញប្រសើរជាងគេ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញស្មើនឹងគេ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញថោកទាបជាងគេ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញប្រសើរជាងគេ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញស្មើនឹងគេ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញថោកទាបជាងគេ សេចក្ដីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញប្រសើរជាងគេ សេចក្ដីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញស្មើនឹងគេ សេចក្ដីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញថោកទាបជាងគេ សេចក្ដីប្រកាន់ សេចក្ដីមើលងាយគេ សេចក្ដីប្រកាន់ក្រៃលែង សេចក្ដីប្រកាន់ថោកថយ សេចក្ដីប្រកាន់លើសលុប សេចក្ដីប្រកាន់ថា អញមាន សេចក្ដីប្រកាន់ខុស សេចក្ដីទឹកដល់ញាតិ សេចក្ដីទឹកដល់ជនបទ សេចក្ដីទឹកដល់ការមិនស្លាប់ សេចក្ដីទឹកប្រកបដោយសេចក្ដីអាណិតអាសូរដល់អ្នកដទៃ សេចក្ដីទឹកប្រកបដោយលាភសក្ការៈ និងសេចក្ដីសរសើរ សេចក្ដីទឹកប្រកបដោយការណ៍ដែលគេមើលងាយមិនបាន ។

[ ៨៤ ] សេចក្ដីក្រោធ ១ ការចងសេចក្ដីក្រោធទុក ១ សេចក្ដីលុបគុណ ១ ការវាយឫកស្មើ ១ សេចក្ដីច្រណែន ១ សេចក្ដីកំណាញ់ ១ សេចក្ដីបិទបាំងទោសរបស់ខ្លួន ១ សេចក្ដីអួតអាង ១ អវិជ្ជា ១ ភវតណ្ហា ១ ភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ សស្សតទិដ្ឋិ ១ ឧច្ឆេទទិដ្ឋិ ១ អន្តវាទិដ្ឋិ ១ អនន្តវាទិដ្ឋិ ១ បុព្វន្តានុទិដ្ឋិ ១ អបរន្តានុទិដ្ឋិ ១ សេចក្ដីមិនខ្មាសបាប ១

សេចក្តីមិនក្តៅនឹងបាប ១ ការប្រដៅក្រ ១ ភាពអ្នកមានមិត្តអាក្រក់ ១ អាការមិនត្រង់ ១ សេចក្តីមិនទន់ភ្លន់ ១ សេចក្តីមិនអត់សង្កត់ ១ សេចក្តីមិនស្លូតបូត ១ សម្តីមិនពីរោះ ១ ការមិនទទួលរាក់ទាក់ ១ ភាពអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ១ ភាពអ្នកមិនដឹងប្រមាណក្នុងភោជន ១ ភាពអ្នកភ្លេចស្មារតី ១ ភាពអ្នកមិនដឹងខ្លួន ១ វិបត្តិនៃសីល ១ វិបត្តិនៃទិដ្ឋិ ១ សំយោជនៈខាងក្នុង ១ សំយោជនៈខាងក្រៅ ១ ។

[ ៨៥ ] អកុសលមូល ៣ អកុសលវិតក្ក ៣ អកុសលសញ្ញា ៣ អកុសលធាតុ ៣ ទុច្ចរិត ៣ អាសវៈ ៣ សញ្ញោជនៈ ៣ តណ្ហា ៣ តណ្ហាដទៃទៀត ៣ តណ្ហាដទៃទៀត ៣ ការស្វែងរក ៣ ការធ្វើងធ្វៃ ៣ ភ័យ ៣ ងងឹត ៣ លទ្ធិដូចជាកំពង់ ៣ កង្វល់ ៣ ទីទួល ៣ មន្ទិល ៣ ធម្មជាតមិនរាបស្មើ ៣ ធម្មជាតមិនរាបស្មើដទៃទៀត ៣ ភ្លើង ៣ ទឹកចត់ ៣ ទឹកចត់ដទៃទៀត ៣ សេចក្តីយល់ឃើញថាគួរត្រេកអរ សេចក្តីយល់ឃើញថាជាខ្លួន សេចក្តីយល់ឃើញខុស សេចក្តីមិនត្រេកអរ សេចក្តីបៀតបៀន ការប្រព្រឹត្តនូវអំពើមិនមែនធម៌ ការប្រដៅក្រ ភាពអ្នកមានមិត្តអាក្រក់ សញ្ញាផ្សេងៗ សេចក្តីរាយមាយ សេចក្តីខ្ជិល សេចក្តីប្រមាទ សេចក្តីមិនសន្តោស សេចក្តីមិនដឹងខ្លួន សេចក្តីប្រាថ្នាធំ សេចក្តីមិនខ្មាសបាប សេចក្តីមិនក្តៅនឹងបាប សេចក្តីប្រមាទ សេចក្តីមិនអើពើ ការប្រដៅក្រ ភាពនៃបុគ្គលមានមិត្តអាក្រក់ សេចក្តីមិនជឿ ការមិនធ្វើដឹងឮពាក្យ ( ស្តាប ) សេចក្តីខ្ជិល សេចក្តីរាយមាយ សេចក្តីមិនសង្រួម សេចក្តីទ្រុស្តសីល សេចក្តីមិនប្រាថ្នា

ដើម្បីឃើញព្រះអរិយៈ សេចក្ដីមិនប្រាថ្នាដើម្បីស្ដាប់ព្រះសទ្ធម្ម ភាពនៃបុគ្គលមានចិត្តប្រណាំងប្រជែង សេចក្ដីភ្លេចស្មារតី សេចក្ដីមិនដឹងខ្លួន សេចក្ដីរាយមាយនៃចិត្ត ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ការសេពផ្លូវខុស ភាពនៃចិត្តរួញរា ។

[ ៨៦ ] អាសវៈ ៤ គន្ថៈ ៤ ឱឃៈ ៤ យោគៈ ៤ ឧបាទាន ៤ តណ្ហុប្បាទា ៤ ការលុះក្នុងអគតិ ៤ ការស្វែងរកខុស ៤ វោហារមិនប្រសើរ ៤ វោហារមិនប្រសើរដទៃទៀត ៤ ទុច្ចរិត ៤ ទុច្ចរិតដទៃទៀត ៤ ភ័យ ៤ ភ័យដទៃទៀត ៤ ភ័យដទៃទៀត ៤ ភ័យដទៃទៀត ៤ ទិដ្ឋិ ៤ ។

[ ៨៧ ] សញ្ញោជនៈជាចំណែកខាងក្រោម ៥ សញ្ញោជនៈជាចំណែកខាងលើ ៥ មច្ឆរិយៈ ៥ កិលេសជាគ្រឿងជំពាក់ ៥ សរ ៥ បង្គោលចិត្ត ៥ ចំណងរបស់ចិត្ត ៥ នីវរណៈ ៥ អនន្តរិយកម្ម ៥ ទិដ្ឋិ ៥ ពៀរ ៥ សេចក្ដីវិនាស ៥ ទោសនៃសេចក្ដីមិនអត់ធន់ ៥ ភ័យ ៥ ទិដ្ឋធម្មនិព្វានវាទ ៥ ។

[ ៨៨ ] មូលនៃវិវាទ ៦ ឆន្ទរាគ ៦ ជាធម៌អាស្រ័យនូវផ្ទះ គឺកាមគុណ វិរោធវត្ថុ ( ហេតុនៃសេចក្ដីក្រោធ ) ៦ ពួកនៃតណ្ហា ៦ អគារវៈ ( សេចក្ដីមិនគោរព ) ៦ បរិហានិយធម៌ ( ធម៌ដែលនាំឲ្យសាបសូន្យ ) ៦ បរិហានិយធម៌ដទៃទៀត ៦ ធម៌ជាទីពិចារណាដោយសោមនស្ស ៦ ធម៌ជាទីពិចារណាដោយទោមនស្ស ៦ ធម៌ជាទីពិចារណាដោយឧបេក្ខា ៦ សោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ទោមនស្ស ៦ ដែលអាស្រ័យ

នូវផ្ទះ គឺកាមគុណ ឧបេក្ខា ៦ ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ទិដ្ឋិ ៦ ។

[ ៨៩ ] អនុសយក្កិលេស ៧ បរិយុដ្ឋានក្កិលេស ៧ សញ្ញោជនៈ ៧ អសទ្ធម្ម ៧ ទុច្ចរិត ៧ មានៈ ៧ ទិដ្ឋិ ៧ ។

[ ៩០ ] កិលេសវត្ថុ ៨ កុសីតវត្ថុ ៨ សេចក្តីចង្អៀតចង្អល់ចិត្ត ព្រោះលោកធម៌ ៨ វោហារមិនប្រសើរ ៨ មិច្ឆត្តធម៌ ៨ ទោសរបស់បុរស ៨ អសញ្ញិវាទ ៨ នេវសញ្ញិនាសញ្ញិវាទ ៨ ។

[ ៩១ ] អាឃាតវត្ថុ ( ហេតុនៃគំនុំ ) ៩ មន្ទិលរបស់បុរស ៩ មានៈ ៩ ធម៌មានតណ្ហាជាមូល ៩ សេចក្តីញាប់ញ័រ ៩ សេចក្តីសម្គាល់ ៩ សេចក្តីឃ្វេងឃ្វាង ៩ សេចក្តីយឺតយូរ ៩ សង្ខតធម៌ ៩ ។

[ ៩២ ] កិលេសវត្ថុ ១០ អាឃាតវត្ថុ ១០ អកុសលកម្មបថ ១០ សញ្ញោជនៈ ១០ មិច្ឆត្តធម៌ ១០ មិច្ឆាទិដ្ឋិមានវត្ថុ ១០ អន្តគាហិកទិដ្ឋិ មានវត្ថុ ១០ ។

[ ៩៣ ] តណ្ហាវិចរិត ( ការប្រព្រឹត្តនៃតណ្ហា ) ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្នុង តណ្ហាវិចរិត ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្រៅ ត្រូវជាតណ្ហាវិចរិត ៣៦ ព្រោះប្រមូលរួបរួមតណ្ហាវិចរិតទាំង ២ ពួកនោះក្នុងទីជាមួយគ្នា តណ្ហាវិចរិតជាអតីត ៣៦ តណ្ហាវិចរិតជាអនាគត ៣៦ តណ្ហាវិចរិតជាបច្ចុប្បន្ន ៣៦ ត្រូវជាតណ្ហាវិចរិត ១០៨ ព្រោះប្រមូលរួបរួមតណ្ហាវិចរិតទាំងអស់នោះក្នុងទីជាមួយគ្នា ដោយប្រការដូច្នេះ មួយវិញទៀត ទិដ្ឋិទាំង ៦២ ណា ទិដ្ឋិទាំង ៦២ នោះ ព្រះមានព្រះភាគ បានសម្តែងហើយ ក្នុង

វេយ្យាករណ៍ ក្នុងព្រហ្មជាលសូត្រ ។

**មាតិកា ចប់**

[ ៩៤ ] បណ្តាសេចក្តីស្រវឹងទាំងនោះ សេចក្តីស្រវឹងព្រោះជាតិ តើដូចម្តេច ។ ការស្រវឹង អាការស្រវឹង ភាពនៃសេចក្តីស្រវឹង ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ ព្រោះអាស្រ័យជាតិ នេះហៅថា សេចក្តីស្រវឹងព្រោះជាតិ ។

[ ៩៥ ] បណ្តាសេចក្តីស្រវឹងទាំងនោះ សេចក្តីស្រវឹងព្រោះគោត្ត តើដូចម្តេច ។ ព្រោះអាស្រ័យគោត្ត ។បេ។ ព្រោះអាស្រ័យភាពមិនមានរោគ ។បេ។ ព្រោះអាស្រ័យវ័យ ។បេ។ ព្រោះអាស្រ័យជីវិត ។បេ។ ព្រោះអាស្រ័យលាភ ។បេ។ ព្រោះអាស្រ័យសក្ការៈ ។បេ។ ព្រោះអាស្រ័យការគោរព ។បេ។ ព្រោះអាស្រ័យការប្រកាន់ខ្លួន ថាជាប្រធាន ។បេ។ ព្រោះអាស្រ័យបរិវារ ។បេ។ ព្រោះអាស្រ័យភោគៈ ។បេ។ ព្រោះអាស្រ័យវណ្ណៈ ។បេ។ ព្រោះអាស្រ័យការចេះដឹង ។បេ។ ព្រោះអាស្រ័យបញ្ញា ។បេ។ ព្រោះអាស្រ័យការដឹងរាត្រី ។បេ។ ព្រោះអាស្រ័យភាពអ្នកប្រព្រឹត្តបិណ្ឌបាត ។បេ។ ព្រោះអាស្រ័យការមិនមានគេមើលងាយ ។បេ។ ព្រោះអាស្រ័យឥរិយាបថ ។បេ។ ព្រោះអាស្រ័យឫទ្ធិ ។បេ។ ព្រោះអាស្រ័យយស ។បេ។ ព្រោះអាស្រ័យសីល ។បេ។ ព្រោះអាស្រ័យឈាន ។បេ។ ព្រោះអាស្រ័យសិល្បសាស្ត្រ ។បេ។ ព្រោះអាស្រ័យកម្ពស់ ។បេ។ ព្រោះ

អាស្រ័យទំហំ ។បេ។ ព្រោះអាស្រ័យទ្រទ្រង់ទ្រាយ ។បេ។ ការស្រវឹងអាការស្រវឹង ភាពនៃសេចក្តីស្រវឹង ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ ព្រោះអាស្រ័យការពេញលេញ នេះហៅថា សេចក្តីស្រវឹង ព្រោះការពេញលេញ ។

[ ៩៦ ] បណ្តាធម៌ទាំងនោះ សេចក្តីស្រវឹង តើដូចម្តេច ។ ការស្រវឹងអាការស្រវឹង ភាពនៃសេចក្តីស្រវឹង ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ណា នេះហៅថា សេចក្តីស្រវឹង ។

[ ៩៧ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រមាទ តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្តក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណ ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តមិនទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែសក្នុងការចម្រើននូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រមាទ ។

[ ៩៨ ] បណ្តាធម៌ទាំងនោះ សេចក្តីចចេស តើដូចម្តេច ។ ការចចេស អាការចចេស ភាពនៃសេចក្តីចចេស សេចក្តីរឹងរូស សេចក្តីអាក្រក់ ភាព

នៃចិត្តរឹងកំព្រឹស ភាពនៃចិត្តមិនទន់ភ្លន់ណា នេះហៅថា សេចក្តីចចេស ។

[ ៩៩ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រណាំងវាសនា តើដូចម្តេច ។ ការប្រណាំងប្រជែង ការប្រណាំងប្រជែងតប អាការប្រណាំងប្រជែង អាការប្រណាំងប្រជែងតប ភាពនៃសេចក្តីប្រណាំងប្រជែងតបណា នេះហៅថា សេចក្តីប្រណាំងវាសនា ។

[ ១០០ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រាថ្នាដ៏ក្រៃលែង តើដូចម្តេច ។ សេចក្តីប្រាថ្នាដ៏ក្រៃលែងនៃបុគ្គលមិនសន្តោសដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ដោយកាមគុណទាំង ៥ សេចក្តីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាដ៏ក្រៃលែង តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រាថ្នាដ៏ក្រៃលែង ។

[ ១០១ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រាថ្នាធំ តើដូចម្តេច ។ សេចក្តីប្រាថ្នាដ៏ក្រៃលែងនៃបុគ្គលមិនសន្តោស ដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ឬដោយកាមគុណទាំង ៥ សេចក្តីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាធំ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកនៃចិត្ត មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រាថ្នាធំ ។

[ ១០២ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រាថ្នាដ៏លាមក តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា ប្រាថ្នាថា ជនចូរដឹងនូវអញ

ថាជាអ្នកមានសទ្ធា ជាអ្នកទ្រុស្តសីល ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានសីល ជាអ្នកចេះដឹងតិច ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកចេះដឹងច្រើន ជាអ្នកត្រេកអរក្នុងការប្រឡូកប្រឡល់ដោយពួក ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកស្ងប់ស្ងាត់ ជាអ្នកខ្ជិលច្រអូស ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានព្យាយាមប្រឹងប្រែង ជាអ្នកភ្លេចស្មារតី ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានស្មារតីតម្កល់ខ្ជាប់ ជាអ្នកមានចិត្តមិនតម្កល់មាំ ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកឥតបញ្ញា ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានបញ្ញា ជាអ្នកមិនទាន់អស់អាសវៈ ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកអស់អាសវៈ សេចក្តីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាដ៏លាមក តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តមានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រាថ្នាដ៏លាមក ។

[ ១០៣ ] បណ្តាធម៌ទាំងនោះ កិលេសជាតដូចស្នែង តើដូចម្តេច ។ កិលេសជាតដូចស្នែង សេចក្តីស្រឡាញ់ ការឈ្លោសវៃ សេចក្តីឆ្លៀវឆ្លាស អាការប៉ិនប្រសប់ សេចក្តីប៉ិនប្រសប់ណា នេះហៅថា កិលេសជាត ដូចស្នែង ។

[ ១០៤ ] បណ្តាធម៌ទាំងនោះ សេចក្តីតិះដៀល តើដូចម្តេច ។ ការតិះដៀល អាការតិះដៀល ភាពនៃសេចក្តីតិះដៀល ការលោក អាការលោក ភាពនៃសេចក្តីលោក ការស្ងិតស្ងាញ សេចក្តីប្រាថ្នាល្អណា នេះហៅថា

សេចក្ដីតិះដៀល ។

[ ១០៥ ] បណ្ដាធម៌ទាំងនោះ ការឃ្មេងឃ្មោង ( ហីហា ) តើដូចម្ដេច ។ ការតាក់តែងចីវរ ការតាក់តែងបាត្រ ការតាក់តែងសេនាសនៈ ការតាក់តែង ការស្អិតស្អាងនូវកាយដ៏ស្អុយនេះក្ដី នូវបរិក្ខារទាំងឡាយខាងក្រៅក្ដី ការលេង ការប្រឡែង ការជាប់ជំពាក់ សេចក្ដីជាប់ជំពាក់ ការឃ្មេងឃ្មោង សេចក្ដីឃ្មេងឃ្មោង នេះហៅថា ការឃ្មេងឃ្មោង ។

[ ១០៦ ] បណ្ដាធម៌ទាំងនោះ សេចក្ដីប្រព្រឹត្តមិនស្មោះស្មើ តើដូចម្ដេច ។ ការកាន់យកដោយមិនអនុលោម ការញុំាងសុខ ឲ្យប្រព្រឹត្តទៅដោយកិរិយាធ្វើឲ្យជាសត្រូវ ការមិនអើពើ សេចក្ដីមិនអើពើ សេចក្ដីមិនគោរព សេចក្ដីមិនក្រោតក្រែងក្នុងមាតាក្ដី ក្នុងបិតាក្ដី ក្នុងបុគ្គលច្បងក្ដី ក្នុងបងប្អូនក្ដី ក្នុងអាចារ្យទាំងឡាយក្ដី ក្នុងឧបជ្ឈាយ៍ក្ដី ក្នុងព្រះពុទ្ធក្ដី ក្នុងសាវកទាំងឡាយក្ដី ក្នុងបុគ្គលដែលគួរគោរពទាំងឡាយណាមួយក្ដី នេះហៅថា សេចក្ដីប្រព្រឹត្តមិនស្មោះស្មើ ។

[ ១០៧ ] បណ្ដាធម៌ទាំងនោះ សេចក្ដីមិនត្រេកអរ តើដូចម្ដេច ។ ការមិនត្រេកអរ អាការមិនត្រេកអរ សេចក្ដីមិនត្រេកអរចំពោះ អាការមិនត្រេកអរចំពោះ ការអផ្សុក សេចក្ដីសោប់សល់ក្នុងសេនាសនៈដ៏ស្ងាត់ក្ដី ក្នុងធម៌ទាំងឡាយជាកុសលដ៏លើសលុបណាមួយក្ដី នេះហៅថា សេចក្ដីមិនត្រេកអរ ។

[ ១០៨ ] បណ្ដាធម៌ទាំងនោះ សេចក្ដីខ្ជិលច្រអូស តើដូចម្ដេច ។ ការ

ប្រអូស អាការប្រអូស សេចក្ដីប្រអូសនៃចិត្ត ការខ្ជិល អាការខ្ជិល ភាពនៃសេចក្ដីខ្ជិលណា នេះហៅថា សេចក្ដីខ្ជិលប្រអូស ។

[ ១០៩ ] បណ្ដាធម៌ទាំងនោះ សេចក្ដីមិតពត់ តើដូចម្ដេច ។ ការមិតពត់ ការមិតពត់រឿយៗ ការមិតពត់ទៅមុខ ការមិតពត់ទៅក្រោយ ការមិតពត់ជុំវិញ ការមិតពត់ឲ្យត្រង់ ការឈឺចាប់នៃកាយណា នេះហៅថា សេចក្ដីមិតពត់ ។

[ ១១០ ] បណ្ដាធម៌ទាំងនោះ សេចក្ដីស្រវឹងព្រោះភត្ត តើដូចម្ដេច ។ បុគ្គលអ្នកបរិភោគ មានសេចក្ដីជប់ព្រោះភត្ត មានសេចក្ដីលំបាកព្រោះភត្ត មានសេចក្ដីហេលហល់ព្រោះភត្ត មានភាពនៃកាយមិនគួរដល់ការងារ ( ព្រោះអាស្រ័យភត្ត ) ណា នេះហៅថា សេចក្ដីស្រវឹងព្រោះភត្ត ។

[ ១១១ ] បណ្ដាធម៌ទាំងនោះ ភាពនៃសេចក្ដីរួញរា តើដូចម្ដេច ។ ភាពនៃចិត្តមិនគួរ ភាពនៃចិត្តមិនគួរដល់ការងារ ការរួញថយ ការរួញចូល ការលឹប.ល. អាការលឹប.ល. ភាពនៃសេចក្ដីលឹប.ល. ការក្រាញនៅ អាការក្រាញនៅ ភាពនៃសេចក្ដីក្រាញនៅនៃចិត្តណា នេះហៅថា ភាពនៃចិត្តរួញរា ។

[ ១១២ ] បណ្ដាធម៌ទាំងនោះ ការកុហក តើដូចម្ដេច ។ ការប្រុងប្រៀបខាងដើម អាការប្រុងប្រៀប ការរៀបចំនូវឥរិយាបថ ការធ្វើមុខស្រពោន ការមានមុខស្រពោន ការធ្វើគេឲ្យស្ងើច អាការធ្វើគេឲ្យស្ងើច ភាពនៃសេចក្ដីធ្វើគេឲ្យស្ងើចដោយការសេពនូវបច្ច័យក្តី ដោយការខ្សឹបខ្សៀវក្ដីរបស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និងការសរសើរ មានសេចក្ដីប្រាថ្នាលាមក មាន

សេចក្ដីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការកុហក ។

[ ១១៣ ] បណ្ដាធម៌ទាំងនោះ ការរួសរាយ តើដូចម្ដេច ។ ការរាក់ទាក់រក ការនិយាយរាក់ទាក់ចំពោះជនដទៃ ការនិយាយល្បួង ការនិយាយលើក ការនិយាយបញ្ជោរ ការនិយាយចងចិត្តត្រកូល ការបញ្ចើច ការបញ្ជោរត្រកូល ការបញ្ចើចបញ្ជោរត្រកូលរឿយៗ ការនិយាយចាក់បណ្ដាយ ការប្រព្រឹត្តបន្ទាបខ្លួនកាយ ការប្រើវាចាដូចសម្លសណ្ដែកបាយ ការបីពទារករបស់ត្រកូលណានៃភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និងសេចក្ដីសរសើរ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការរួសរាយ ។

[ ១១៤ ] បណ្ដាធម៌ទាំងនោះ ការធ្វើនូវនិមិត្ត តើដូចម្ដេច ។ និមិត្ត ការធ្វើនូវនិមិត្ត ការនិយាយបំភ្លឺ ការធ្វើនូវសេចក្ដីបញ្ឆិតបញ្ឆៀង ការនិយាយខ្សឹបខ្សៀវ ការនិយាយវាសវាងចំពោះពួកជនដទៃណា របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និងការសរសើរ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការធ្វើនូវនិមិត្ត ។

[ ១១៥ ] បណ្ដាធម៌ទាំងនោះ ការធ្វើនូវសេចក្ដីគំរាម តើដូចម្ដេច ។ ការជេរ ( ដោយអក្កោសវត្ថុ ១០ ) ការបន្តុះបង្អាប់ ការតិះដៀល ការនិយាយឃាត់ ការនិយាយឃាត់រឿយៗ ការនិយាយចំអកឡកឡឺយ ការនិយាយចំអកឡកឡឺយរឿយៗ ចំពោះជនដទៃ ការញុំាងទាយក ឲ្យដល់នូវទោស ការញុំាងទាយកឲ្យដល់នូវទោសរឿយៗ ការដឹកនាំនូវទោស ការ

ពោលពាក្យដូចជាស៊ីសាច់ខ្នងនៃជនដទៃណា របស់ភិក្ខុអ្នកអាស្រ័យលាភ-សក្ការៈ និងសេចក្ដីសរសើរ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការធ្វើនូវសេចក្ដីគំរាម ។

[ ១១៦ ] បណ្ដាធម៌ទាំងនោះ ការទាក់លាភដោយលាភ តើដូចម្ដេច ។ ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និងសេចក្ដីសរសើរ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ នាំយកនូវអាមិស ដែលខ្លួនបានហើយអំពីផ្ទះនេះទៅឲ្យផ្ទះឯណោះ ឬនាំយកនូវអាមិសដែលខ្លួនបានហើយអំពីផ្ទះឯណោះមកឲ្យផ្ទះនេះ ការប្រាថ្នា ការស្វែងរក ការស្វែងរករឿយៗ ការគន់រក ការរិះរក ការស្វែងរកញឹកញាប់នូវអាមិសដោយអាមិស មានសភាពយ៉ាងនេះណា នេះហៅថា ការទាក់លាភដោយលាភ ។

[ ១១៧ ] បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់ថា អញប្រសើរជាងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ដំឡើងមានះឲ្យប្រព្រឹត្តទៅដោយជាតិក្ដី ដោយគោត្តក្ដី ដោយភាពនៃខ្លួនជាកុលបុត្តក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី ដោយទីតាំងនៃវិជ្ជាក្ដី ដោយការចេះដឹងក្ដី ដោយបញ្ញាក្ដី ដោយវត្ថុណាមួយក្ដី ការមើលងាយគេ អាការមើលងាយគេ ភាពនៃសេចក្ដីមើលងាយគេ ការធ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្ដីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្ដីប្រកាន់ថា អញប្រសើរជាងគេ ។

[ ១១៨ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ថា អញស្មើនឹងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ជំឡើងមានះ ឲ្យប្រព្រឹត្តទៅដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយទីតាំងនៃវិជ្ជាក្តី ដោយការចេះដឹងក្តី ដោយបញ្ញាក្តី ដោយវត្ថុណាមួយក្តី ការមើលងាយគេ អាការមើលងាយគេ ភាពនៃសេចក្តីមើលងាយគេ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់ថា អញស្មើនឹងគេ ។

[ ១១៩ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ថា អញថោកទាបជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ញុំាងមានះថោកថយឲ្យប្រព្រឹត្តទៅដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយទីតាំងនៃវិជ្ជាក្តី ដោយការចេះដឹងក្តី ដោយបញ្ញាក្តី ដោយវត្ថុណាមួយក្តី ការប្រកាន់ថោកថយ អាការប្រកាន់ថោកថយ ភាពនៃសេចក្តីប្រកាន់ថោកថយ ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់ថា អញថោកទាបជាងគេ ។

[ ១២០ ] បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ជាអញប្រសើរជាងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រសើរជាងគេ ដោយជាតិក្ដី ដោយគោត្តក្ដី ដោយភាពនៃខ្លួនជាកុលបុត្តក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី ដោយទីតាំងនៃវិជ្ជាក្ដី ដោយការចេះដឹងក្ដី ដោយបញ្ញាក្ដី ដោយវត្ថុណាមួយក្ដី តម្កល់ខ្លួនទុកជា ប្រសើរជាងជនដទៃ បុគ្គលនោះ ញ៉ាំងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុកជា ប្រសើរជាងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្ដីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្ដីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ជាអញប្រសើរជាងគេ ។

[ ១២១ ] បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ជាអញស្មើនឹងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រសើរជាងគេ ដោយជាតិក្ដី ដោយគោត្តក្ដី ដោយភាពនៃខ្លួនជាកុលបុត្តក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី ដោយទីតាំងនៃវិជ្ជាក្ដី ដោយការចេះដឹងក្ដី ដោយបញ្ញាក្ដី ដោយវត្ថុណាមួយក្ដី តម្កល់ខ្លួនទុកជាស្មើនឹងជនដទៃ បុគ្គលនោះញ៉ាំងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុកជា ស្មើនឹងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្ដីមើលងាយ

ការធ្វើនង្គ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្ដីប្រាថ្នានៃចិត្តដូចជាទង់ មានភាពយ៉ាងនេះណា នេះហៅថា សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថាអញស្មើនឹងគេ ។

[ ១២២ ] បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថាអញថោកទាបជាងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រសើរជាងគេ ដោយជាតិក្ដី ដោយគោត្តក្ដី ដោយភាពនៃខ្លួនជាកុលបុត្តក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី ដោយទីតាំងនៃវិជ្ជាក្ដី ដោយការចេះដឹងក្ដី ដោយបញ្ញាក្ដី ដោយវត្ថុណាមួយក្ដី តម្កល់ខ្លួនទុកថា ថោកទាបជាងជនដទៃវិញ បុគ្គលនោះ ញុំាងមានះថោកទាបឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុកថា ថោកទាបជាងជនដទៃនោះ ការមើលងាយថោកទាប អាការមើលងាយថោកទាប ភាពនៃសេចក្ដីមើលងាយថោកទាប ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្ដីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្ដីមើលងាយខ្លួន មានសភាពយ៉ាងនេះណា នេះហៅថា សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថាអញថោកទាបជាងគេ ។

[ ១២៣ ] បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេ ថាអញប្រសើរជាងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្មើនឹងគេ ដោយជាតិក្ដី ដោយគោត្តក្ដី ដោយភាពនៃខ្លួនជាកុលបុត្តក្ដី ។បេ។ ដោយវត្ថុណាមួយក្ដី តម្កល់ខ្លួនទុកថា ប្រសើរជាងជនដទៃបុគ្គលនោះ ញុំាងមានះ

ឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុកថា ប្រសើរជាងគេនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ សេចក្តីឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេ ថាអញប្រសើរជាងគេ ។

[ ១២៤ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេ ថាអញស្មើនឹងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្មើនឹងគេ ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុកថា ស្មើនឹងជនដទៃ បុគ្គលនោះ ញុំាងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុកថា ស្មើនឹងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេ ថាអញស្មើនឹងគេ ។

[ ១២៥ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេ ថាអញថោកទាបជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្មើនឹងគេ ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុកថា ថោកទាបជាងជនដទៃវិញ បុគ្គលនោះ ញុំាងមានះថោកទាបឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក

ថា ថោកទាបជាងជនដទៃនោះ ការមើលងាយថោកទាប អាការមើលងាយថោកទាប ភាពនៃសេចក្តីមើលងាយថោកទាប ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេ ថាអញថោកទាបជាងគេ ។

[ ១២៦ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថាអញប្រសើរជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកថោកទាបជាងគេ ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុកថា ប្រសើរជាងជនដទៃ បុគ្គលនោះ ញុំាងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុកថា ប្រសើរជាងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការធ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថាអញប្រសើរជាងគេ ។

[ ១២៧ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថាអញស្មើនឹងគេ តើដូចម្តេច ។ បុគ្គលពួក ខ្លះក្នុងលោកនេះ ជាអ្នកថោកទាបជាងគេដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុកថា ស្មើនឹងជនដទៃ បុគ្គលនោះ ញុំាងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុកថា ស្មើនឹងជនដទៃ

នោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការធ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្ត ដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថាអញស្មើនឹងគេ ។

[ ១២៨ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថាអញថោកទាបជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកថោកទាបជាងគេ ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុកថា ថោកទាបជាងជនដទៃ បុគ្គលនោះ ញុំាងមានះដ៏ថោកទាបឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុកថា ថោកទាបជាងជនដទៃនោះ ការមើលងាយថោកទាប អាការមើលងាយថោកទាប ភាពនៃសេចក្តីមើលងាយថោកទាប ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថាអញថោកទាបជាងគេ ។

[ ១២៩ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ តើដូចម្តេច ។ ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការធ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ណា នេះហៅថា សេចក្តីប្រកាន់ ។

[ ១៣០ ] បណ្តាធម៌ទាំងនោះ សេចក្តីមើលងាយគេ តើដូចម្តេច ។

បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមើលងាយបុគ្គលទាំងឡាយដទៃ ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីមើលងាយគេ ។

[ ១៣១ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ក្រៃលែង តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ កាលមុនតម្កល់ខ្លួនទុកថា ស្មើនឹងជនដទៃ កាលជាខាងក្រោយមក តម្កល់ខ្លួនទុកថា ប្រសើរជាងជនដទៃវិញ មិនតម្កល់ខ្លួនទុកថា ថោកទាបជាងជនដទៃ ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់ក្រៃលែង ។

[ ១៣២ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ថោកថយ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ញុំាងមានះឲ្យប្រព្រឹត្តទៅ ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ដោយភាពនៃខ្លួន មានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយទីតាំងនៃវិជ្ជាក្តី ដោយការចេះដឹងក្តី ដោយបញ្ញា ដោយវត្ថុណាមួយក្តី ការប្រកាន់ដ៏ថោកថយ អាការប្រកាន់ដ៏ថោកថយ ភាពនៃសេចក្តីប្រកាន់ដ៏

ថោកថយ ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់ថោកថយ ។

[ ១៣៣ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់លើសលុប តើដូចម្តេច ។ សេចក្តីសម្គាល់ក្នុងសច្ចៈទាំង ៤ ដោយខ្លួនមិនទាន់ដល់ ថាបានដល់ហើយ សេចក្តីសម្គាល់ក្នុងកិច្ចដែលខ្លួនមិនទាន់ធ្វើ ថាបានធ្វើហើយ សេចក្តីសម្គាល់ក្នុងសច្ចៈទាំង ៤ ដែលខ្លួនមិនទាន់ត្រាស់ដឹង ថាបានត្រាស់ដឹងហើយ សេចក្តីសម្គាល់ក្នុងសច្ចៈទាំង ៤ ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ហើយ ថាបានធ្វើឲ្យជាក់ច្បាស់ហើយ ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្ត ដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រកាន់លើសលុប ។

[ ១៣៤ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ថា អញមាន តើដូចម្តេច ។ សេចក្តីប្រកាន់ក្នុងរូបថា អញមាន សេចក្តីពេញចិត្តក្នុងរូបថា អញមាន អនុស័យក្នុងរូបថា អញមាន សេចក្តីប្រកាន់ក្នុងវេទនា ។បេ។ ក្នុងសញ្ញា ។បេ។ ក្នុងសង្ខារទាំងឡាយ ។បេ។ ក្នុងវិញ្ញាណថា អញមាន សេចក្តីពេញចិត្តក្នុងវិញ្ញាណថា អញមាន អនុស័យក្នុងវិញ្ញាណថា អញមាន ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់

មានសភាពយ៉ាងនេះណា នេះហៅថា សេចក្ដីប្រកាន់ថា អញមាន ។

[ ១៣៥ ] បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់ខុស តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ញ៉ាំងមានះឲ្យប្រព្រឹត្តទៅដោយការងារដ៏លាមកក្ដី ដោយសិល្បសាស្ត្រដ៏លាមកក្ដី ដោយទីតាំងនៃវិជ្ជាដ៏លាមកក្ដី ដោយការចេះដឹងដ៏លាមកក្ដី ដោយបញ្ញាដ៏លាមកក្ដី ដោយសីលដ៏លាមកក្ដី ដោយវត្តដ៏លាមកក្ដី ដោយសីល និងវត្តដ៏លាមកក្ដី ដោយទិដ្ឋិដ៏លាមកក្ដី ដោយវត្ថុណាមួយក្ដី ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្ដីប្រកាន់ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្ដីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្ដីប្រកាន់ខុស ។

[ ១៣៦ ] បណ្ដាធម៌ទាំងនោះ សេចក្ដីនឹកដល់ញាតិ តើដូចម្ដេច ។ សេចក្ដីនឹក សេចក្ដីជញ្ជឹង ។បេ។ សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ប្រាវព្ធពួកញាតិ នេះហៅថា សេចក្ដីនឹកដល់ញាតិ ។

[ ១៣៧ ] បណ្ដាធម៌ទាំងនោះ សេចក្ដីនឹកដល់ជនបទ តើដូចម្ដេច ។ សេចក្ដីនឹក សេចក្ដីជញ្ជឹង ។បេ។ សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ប្រាវព្ធនូវជនបទ នេះហៅថា សេចក្ដីនឹកដល់ជនបទ ។

[ ១៣៨ ] បណ្ដាធម៌ទាំងនោះ សេចក្ដីនឹកដល់ការមិនស្លាប់ តើដូចម្ដេច ។ សេចក្ដីនឹក សេចក្ដីជញ្ជឹង ។បេ។ សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ មិនប្រកបដោយអំពើ ដែលបុគ្គលធ្វើបានដោយកម្រក្ដី ប្រកបដោយទិដ្ឋិក្ដី នេះហៅថា សេចក្ដីនឹកដល់ការមិនស្លាប់ ។

[ ១៣៩ ] បណ្តាធម៌ទាំងនោះ សេចក្តីទឹកប្រកបដោយសេចក្តីអាណិតអាសូរដល់អ្នកដទៃ តើដូចម្តេច ។ ភិក្ខុពួកខ្លះ ក្នុងលោកនេះ នៅប្រទ្បូកប្រទ្បំដោយគ្រហស្ថ មានសេចក្តីត្រេកអរជាមួយគ្នា មានសេចក្តីសោកជាមួយគ្នា កាលបើគ្រហស្ថដល់នូវសេចក្តីសុខ ខ្លួនក៏ដល់នូវសេចក្តីសុខដែរ កាលបើគ្រហស្ថដល់នូវសេចក្តីទុក្ខ ខ្លួនក៏ដល់នូវសេចក្តីទុក្ខដែរ កាលបើគ្រហស្ថមានកិច្ចដែលគួរធ្វើកើតឡើងហើយ ក៏ដល់នូវការជួយប្រកបដោយខ្លួនឯងដែរ សេចក្តីទឹក សេចក្តីជញ្ជឹង ។បេ។ សេចក្តីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ក្នុងកិច្ចអម្បាលនោះណា នេះហៅថា សេចក្តីទឹកប្រកបដោយសេចក្តីអាណិតអាសូរដល់អ្នកដទៃ ។

[ ១៤០ ] បណ្តាធម៌ទាំងនោះ សេចក្តីទឹកប្រកបដោយលាភសក្ការៈ និងសេចក្តីសរសើរ តើដូចម្តេច ។ សេចក្តីទឹក សេចក្តីជញ្ជឹង ។បេ។ សេចក្តីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ប្រារព្ធលាភសក្ការៈ និងសេចក្តីសរសើរ នេះហៅថា សេចក្តីទឹកប្រកបដោយលាភសក្ការៈ និងសេចក្តីសរសើរ ។

[ ១៤១ ] បណ្តាធម៌ទាំងនោះ សេចក្តីទឹកប្រកបដោយការណ៍ដែលគេមើលងាយមិនបាន តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ គិតថា ជនដទៃកុំមើលងាយអញដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកុលបុត្តក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយទីតាំងនៃវិជ្ជាក្តី ដោយ

ការបេះដឹងក្តី ដោយបញ្ញាក្តី ដោយវត្ថុណាមួយក្តី សេចក្តីទឹក សេចក្តីជញ្ជីង ។បេ។ សេចក្តីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ក្នុងគំនិតថា ជនដទៃកុំមើលឃើញអញនោះណា នេះហៅថា សេចក្តីទឹកប្រកបដោយការណ៍ដែលគេមើលឃើញមិនបាន ។

## ធម្មិតូក ១ ចប់ ។

[ ១៤២ ] បណ្តាធម៌ទាំងនោះ សេចក្តីក្រោធ តើដូចម្តេច ។ ការក្រោធ អាការក្រោធ ភាពនៃសេចក្តីក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃសេចក្តីប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃសេចក្តីព្យាបាទ សេចក្តីខឹង សេចក្តីខឹងខ្លាំង សេចក្តីកាច ការខឹង សេចក្តីអាក់អន់ចិត្តណា នេះហៅថា សេចក្តីក្រោធ ។ បណ្តាធម៌ទាំងនោះ ការចងសេចក្តីក្រោធទុក តើដូចម្តេច ។ សេចក្តីក្រោធក្នុងកាលជាខាងដើម ការចងសេចក្តីក្រោធទុកក្នុងកាលជាខាងក្រោយ ការចងសេចក្តីក្រោធទុក អាការចងសេចក្តីក្រោធទុក ភាពនៃការចងសេចក្តីក្រោធទុក ការតម្កល់សេចក្តីក្រោធទុកជាលំដាប់ ការតម្កល់សេចក្តីក្រោធទុកជាប្រក្រតី ការតម្កល់សេចក្តីក្រោធទុករឿយៗ ការប្រៀបផ្ទឹមរឿយៗ ការចងទុករឿយៗ ការធ្វើសេចក្តីក្រោធឲ្យមាំណា នេះហៅថា ការចងសេចក្តីក្រោធទុក ។

[ ១៤៣ ] បណ្តាធម៌ទាំងនោះ សេចក្តីលុបគុណ តើដូចម្តេច ។ ការលុបគុណ អាការលុបគុណ ភាពនៃសេចក្តីលុបគុណ សេចក្តីមើលងាយគុណ ការធ្វើនូវសេចក្តីមើលងាយគុណណា នេះហៅថា សេចក្តីលុបគុណ ។ បណ្តា

ធម៌ទាំងនោះ ការវាយឫកស្មើ តើដូចម្តេច ។ ការលើកខ្លួនផ្ទឹម អាការលើកខ្លួនផ្ទឹម ភាពនៃសេចក្តីលើកខ្លួនផ្ទឹម ការប្រណាំងវាសនា ហេតុនៃសេចក្តីវិវាទ ការប្រកាន់ជាគូ ការមិនលះបង់ណា នេះហៅថា ការវាយឫកស្មើ ។

[ ១៤៤ ] បណ្តាធម៌ទាំងនោះ សេចក្តីប្រណែន តើដូចម្តេច ។ ការប្រណែន អាការប្រណែន ភាពនៃសេចក្តីប្រណែន ការឈ្នានីស អាការឈ្នានីស ភាពនៃសេចក្តីឈ្នានីសណា ក្នុងលាភសក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជារបស់ជនដទៃ នេះហៅថា សេចក្តីប្រណែន ។ បណ្តាធម៌ទាំងនោះ សេចក្តីកំណាញ់ តើដូចម្តេច ។ សេចក្តីកំណាញ់ ៥ យ៉ាង គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្តីសរសើរ ១ កំណាញ់ធម៌ ១ ការកំណាញ់ អាការកំណាញ់ ភាពនៃសេចក្តីកំណាញ់ សេចក្តីប្រាថ្នាផ្សេងៗ សេចក្តីកំណាញ់រឹង សេចក្តីកំណាញ់ស្វិត ភាពនៃចិត្តមិនយកចិត្តគេ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីកំណាញ់ ។

[ ១៤៥ ] បណ្តាធម៌ទាំងនោះ សេចក្តីបិទបាំងទោសរបស់ខ្លួន តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តម្កល់ទុកនូវសេចក្តីប្រាថ្នាដ៏លាមក ព្រោះបិទបាំងនូវអំពើទុច្ចរិតនោះ ជាហេតុប្រាថ្នាថា ពួកជនទីមួយ កុំដឹងនូវអាត្មាអញឡើយ ត្រិះរិះថា ពួកជនទីមួយ កុំដឹងនូវអាត្មាអញឡើយ ពោលវាចាថា ពួកជនទីមួយ កុំដឹងនូវអាត្មាអញឡើយ ខ្នះខ្នែងដោយកាយថា ពួក

ជននីមួយ កុំដឹងនូវអាត្មាអញឡើយ ការបិទបាំងទោសរបស់ខ្លួន ភាពនៃបុគ្គលបិទបាំងទោសរបស់ខ្លួន ការធ្វើនូវអំពើអាក្រក់ ហើយបិទបាំងទុកឲ្យកន្លងហួសទៅ ការបញ្ឆោត ការបោកប្រាស ការគេចកែ ការពន្វេះពន្វាង ការបិទបាំង ការលាក់បំពួន ការគ្របទុក ការគ្របលុប ការមិនធ្វើឲ្យច្បាស់ ការមិនធ្វើឲ្យប្រាកដ ការបិទបាំងខ្លាំង ការធ្វើនូវអំពើអាក្រក់ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីបិទបាំងទោសរបស់ខ្លួន ។ បណ្តាធម៌ទាំងនោះ សេចក្តីអួតអាង តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកអួតអាង ជាអ្នកអួតអាងខ្លាំង ការអួតអាង អាការអួតអាង សេចក្តីអួតអាង សេចក្តីរឹងរូស អាការរឹងរូស អាការប៉ុនប្រសប់ សេចក្តីប៉ុនប្រសប់ មានក្នុងបុគ្គលនោះណា នេះហៅថា សេចក្តីអួតអាង ។

[ ១៤៦ ] បណ្តាធម៌ទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនយល់ ។បេ។ គន្លឹះ គឺអវិជ្ជា សេចក្តីវង្វេង ឫសគល់នៃអកុសលណា នេះហៅថា អវិជ្ជា ។ បណ្តាធម៌ទាំងនោះ ភវតណ្ហា តើដូចម្តេច ។ សេចក្តីប្រាថ្នាភពក្នុងភពទាំងឡាយ តម្រេកក្នុងភព សេចក្តីស្រើបស្រាលក្នុងភព សេចក្តីប្រាថ្នាក្នុងភព សេចក្តីស្នេហាក្នុងភព សេចក្តីអន្ទះអន្ទែង ក្នុងភព សេចក្តីជ្រប់ក្នុងភព ការចុះចិត្តស៊ប់ក្នុងភពណា នេះហៅថា ភវតណ្ហា ។

[ ១៤៧ ] បណ្តាធម៌ទាំងនោះ ភវទិដ្ឋិ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាខ្លួនក្តី លោកក្តី នឹងមាន នេះហៅថា ភវទិដ្ឋិ ។ បណ្តាធម៌ទាំងនោះ

វិភវទិដ្ឋិ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាខ្លួនក្តី លោកក្តី នឹងមិនមាន នេះហៅថា វិភវទិដ្ឋិ ។

[ ១៤៨ ] បណ្តាធម៌ទាំងនោះ សស្សតទិដ្ឋិ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាខ្លួនក្តី លោកក្តីទៀង នេះហៅថា សស្សតទិដ្ឋិ ។ បណ្តាធម៌ទាំងនោះ ឧច្ឆេទទិដ្ឋិ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាខ្លួនក្តី លោកក្តី នឹងសូន្យ នេះហៅថា ឧច្ឆេទទិដ្ឋិ ។

[ ១៤៩ ] បណ្តាធម៌ទាំងនោះ អន្តវាទិដ្ឋិ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាខ្លួនក្តី លោកក្តី មានទីបំផុត នេះហៅថា អន្តវាទិដ្ឋិ ។ បណ្តាធម៌ទាំងនោះ អនន្តវាទិដ្ឋិ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាខ្លួនក្តី លោកក្តី មិនមានទីបំផុត នេះហៅថា អនន្តវាទិដ្ឋិ ។

[ ១៥០ ] បណ្តាធម៌ទាំងនោះ បុព្វន្តានុទិដ្ឋិ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណា កើតឡើងប្រារព្ធនូវទីបំផុតខាងដើម នេះហៅថា បុព្វន្តានុទិដ្ឋិ ។ បណ្តាធម៌ទាំងនោះ អបរន្តានុទិដ្ឋិ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស

ណាកើតឡើង ប្រារព្ធនូវទីបំផុតខាងចុង នេះហៅថា អបរន្តានុទិដ្ឋិ ។

[ ១៥១ ] បណ្តាធម៌ទាំងនោះ សេចក្តីមិនខ្មាសបាប តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនខ្មាស ដោយហេតុដែលគួរខ្មាស មិនខ្មាសដោយការជួបប្រទះនឹងពួកអកុសលធម៌ដ៏លាមក នេះហៅថា សេចក្តីមិនខ្មាសបាប ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនក្តៅនឹងបាប តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនតក់ស្លុតដោយហេតុដែលគួរតក់ស្លុត មិនតក់ស្លុតដោយការជួបប្រទះនឹងពួកអកុសលធម៌ដ៏លាមក នេះហៅថា សេចក្តីមិនក្តៅនឹងបាប ។

[ ១៥២ ] បណ្តាធម៌ទាំងនោះ ការប្រដៅក្រ តើដូចម្តេច ។ ការប្រដៅក្រ អាការប្រដៅក្រ ភាពនៃសេចក្តីប្រដៅក្រ ការកាន់យកនូវអំពើដែលគួរខ្ពើម ( អំពើផ្តេសផ្តាស ) ការពេញចិត្ត ក្នុងធម៌ជាសត្រូវ ការមិនអើពើ សេចក្តីមិនអើពើ សេចក្តីមិនគោរព សេចក្តីមិនស្តាប់បង្គាប់ ចំពោះពាក្យប្រកបដោយធម៌ដែលគេពោល នេះហៅថា ការប្រដៅក្រ ។ បណ្តាធម៌ទាំងនោះ ភាពអ្នកមានមិត្តអាក្រក់ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកមិនមានសទ្ធា ទ្រុស្តសីល ចេះដឹងតិច មានសេចក្តីកំណាញ់ ឥតបញ្ញា ការសេព ការសេពមិនដាច់ ការសេពរឿយៗ ការគប់រក ការគប់រករឿយៗ ការគប់ប្រសព្វ ការគប់ប្រសព្វរឿយៗ ការបែររេទៅរកបុគ្គលទាំងឡាយនោះណា នេះហៅថា ភាពនៃអ្នកមានមិត្តអាក្រក់ ។

[ ១៥៣ ] បណ្តាធម៌ទាំងនោះ អាការមិនត្រង់ តើដូចម្តេច ។ អាការមិនត្រង់ ភាពនៃអាការមិនត្រង់ ភាពនៃសេចក្តីវៀចវេរ ភាពនៃសេចក្តីកោង

ភាពនៃសេចក្តីក្ងិកក្ងក់ណា នេះហៅថា អាការមិនត្រង់ ។ បណ្តាធម៌ទាំង នោះ សេចក្តីមិនទន់ភ្លន់ តើដូចម្តេច ។ សេចក្តីមិនទន់ភ្លន់ អាការនៃ សេចក្តីមិនទន់ភ្លន់ សេចក្តីរឹងរូស សេចក្តីអាក្រក់ ភាពនៃសេចក្តីរឹងរូស ភាព នៃបុគ្គលមានចិត្តគគ្រឹសគគ្រូស ភាពនៃបុគ្គលមានចិត្តរឹងកំព្រឹស ភាព នៃបុគ្គលមានចិត្តមិនទោរទន់ណា នេះហៅថា សេចក្តីមិនទន់ភ្លន់ ។

[ ១៥៤ ] បណ្តាធម៌ទាំងនោះ សេចក្តីមិនអត់សង្កត់ តើដូចម្តេច ។ សេចក្តីមិនអត់សង្កត់ ភាពនៃសេចក្តីមិនអត់ធន់ ភាពនៃសេចក្តីមិនអត់ធ្មត់ សេចក្តីកាច ការពោលពាក្យមិនល្អ សេចក្តីមិនត្រេកអរនៃចិត្តណា នេះ ហៅថា សេចក្តីមិនអត់សង្កត់ ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនស្លូតបូត តើដូចម្តេច ។ ការប្រព្រឹត្តកន្លងប្រកបដោយកាយ ការប្រព្រឹត្តកន្លងប្រកប ដោយវាចា ការប្រព្រឹត្តកន្លងប្រកបដោយកាយ និងវាចា នេះហៅថា សេចក្តីមិនស្លូតបូត សូម្បីការទ្រុស្តសីលទាំងអស់ ក៏ឈ្មោះថា សេចក្តីមិន ស្លូតបូតដែរ ។

[ ១៥៥ ] បណ្តាធម៌ទាំងនោះ សម្តីមិនពីរោះ តើដូចម្តេច ។ វាចាណា ជាវាចារដិបរដុប គ្រោតគ្រាត ហឹរក្តៅដល់ជនដទៃ ខ្ទាំងខ្ទប់ដល់ជនដទៃ ជិតសេចក្តីក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិ បុគ្គលពោលនូវវាចា មាន សភាពដូច្នោះ ភាពនៃបុគ្គលមានវាចាមិនល្អិត ភាពនៃបុគ្គលមានវាចាមិន ពីរោះ ភាពនៃបុគ្គលមានវាចាអាក្រក់ណាក្នុងវាចានោះ នេះហៅថា សម្តី មិនពីរោះ ។ បណ្តាធម៌ទាំងនោះ ការមិនទទួលរាក់ទាក់ តើដូចម្តេច ។

ការទទួលរាក់ទាក់មាន ២ យ៉ាង គឺការទទួលរាក់ទាក់ដោយអាមិសៈ ១ ការទទួលរាក់ទាក់ដោយធម៌ ១ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនទទួលរាក់ទាក់ដោយអាមិសប្បដិសន្ថារៈក្តី ដោយធម្មប្បដិសន្ថារៈក្តី នេះហៅថាការមិនទទួលរាក់ទាក់ ។

[ ១៥៦ ] បណ្តាធម៌ទាំងនោះ ភាពនៃអ្នកមិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានឃើញនូវរូបដោយចក្ខុហើយ កាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏មិនប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ បានឮនូវសំឡេង ដោយត្រចៀកហើយ ។បេ។ បានហិតក្លិន ដោយច្រមុះហើយ ។បេ។ បានជញ្ជក់ជញ្ជាប់នូវរស ដោយអណ្តាតហើយ ។បេ។ បានពាល់ត្រូវផ្សព្វដោយកាយហើយ ។បេ។ បានដឹងច្បាស់នូវធម្មារម្មណ៍ ដោយចិត្តហើយ កាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវមនិន្ទ្រិយណា ក៏មិនប្រព្រឹត្តដើម្បីសង្រួមនូវមនិន្ទ្រិយនោះ មិនរក្សានូវមនិន្ទ្រិយ មិនដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ការមិនបិទ ការមិនគ្រប់គ្រង ការមិនរក្សា ការមិនសង្រួមនូវឥន្ទ្រិយទាំង ៦ នេះណា នេះ

ហៅថា ភាពនៃអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ។ បណ្ដាធម៌ទាំងនោះ ភាពនៃអ្នកមិនដឹងប្រមាណក្នុងភោជន តើដូចម្ដេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ មិនពិចារណាដោយឧបាយនៃបញ្ញា តែងលេបនូវអាហារដើម្បីលេង ដើម្បីស្រវឹង ដើម្បីតាក់តែង ដើម្បីស្អិតស្អាង ភាពនៃអ្នកមិនសន្ដោស ភាពនៃអ្នកមិនដឹងប្រមាណ ការមិនពិចារណាភោជនក្នុងសេចក្ដីមិនដឹងប្រមាណក្នុងភោជននោះណា នេះហៅថា ភាពនៃអ្នកមិនដឹងប្រមាណក្នុងភោជន ។

[ ១៥៧ ] បណ្ដាធម៌ទាំងនោះ ភាពនៃអ្នកភ្លេចស្មារតី តើដូចម្ដេច ។ ការមិនមានស្មារតី ការមិនរឭកឃើញ ការមិននឹកឃើញ ការមិនរឭកសេចក្ដីមិនរឭក សេចក្ដីមិនចងចាំ សេចក្ដីភ្លេចភ្លាំង សេចក្ដីវង្វេងណា នេះហៅថា ភាពនៃអ្នកភ្លេចស្មារតី ។ បណ្ដាធម៌ទាំងនោះ ភាពនៃអ្នកមិនដឹងខ្លួន តើដូចម្ដេច ។ សេចក្ដីមិនដឹង សេចក្ដីមិនយល់ ។បេ។ គន្លឹះ គឺអវិជ្ជា សេចក្ដីវង្វេង ឫសគល់នៃអកុសលណា នេះហៅថា ភាពនៃអ្នកមិនដឹងខ្លួន ។

[ ១៥៨ ] បណ្ដាធម៌ទាំងនោះ វិបត្តិនៃសីល តើដូចម្ដេច ។ ការប្រព្រឹត្តកន្លងប្រកបដោយកាយ ការប្រព្រឹត្តកន្លងប្រកបដោយវាចា ការប្រព្រឹត្តកន្លងប្រកបដោយកាយ និងវាចា នេះហៅថា វិបត្តិនៃសីល សូម្បីភាពនៃការទ្រុស្តសីលទាំងអស់ ក៏ឈ្មោះថា វិបត្តិនៃសីលដែរ ។ បណ្ដាធម៌ទាំងនោះ វិបត្តិនៃទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់

ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាមិនមានផល ។បេ។ ពួកសមណព្រាហ្មណ៍ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះផង នូវលោកដទៃផង ដោយបញ្ញារបស់ខ្លួន ហើយប្រកាសមិនមានទេ នេះហៅថា វិបត្តិនៃទិដ្ឋិ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ក៏ឈ្មោះថា វិបត្តិនៃទិដ្ឋិដែរ ។

[ ១៥៩ ] បណ្តាធម៌ទាំងនោះ សញ្ញោជនៈខាងក្នុង តើដូចម្តេច ។ សញ្ញោជនៈ ៥ ជាចំណែកខាងក្រោម ហៅថា សញ្ញោជនៈខាងក្នុង សញ្ញោជនៈ ៥ ជាចំណែកខាងលើ ហៅថា សញ្ញោជនៈខាងក្រៅ ។

## ពួកធម៌ ២ ចប់ ។

[ ១៦០ ] បណ្តាធម៌ទាំងនោះ អកុសលមូល ៣ តើដូចម្តេច ។ លោភៈ ទោសៈ មោហៈ ។ បណ្តាអកុសលមូល ៣ នោះ លោភៈ តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង សេចក្តីត្រេកអរ សេចក្តីត្រេកត្រអាល សេចក្តីរីករាយ សេចក្តីស្រើបស្រាល តម្រេកខ្លាំងនៃចិត្ត សេចក្តីប្រាថ្នា សេចក្តីងល់ងប់ សេចក្តីជ្រប់ សេចក្តីចង់បាន សេចក្តីចង់បានខ្លាំង សេចក្តីជាប់ជំពាក់ គឺតណ្ហា ភក់ គឺតណ្ហា សេចក្តីស្វែងរក សេចក្តីបិទបាំង តណ្ហាជាគ្រឿងញុំាងសត្វឲ្យកើត តណ្ហាជាគ្រឿងញុំាងសត្វឲ្យកើតព្រម តណ្ហាជាគ្រឿងចាក់ស្រេះ ធម្មជាតិមានបណ្តាញ ធម្មជាតិផ្សាយទៅ ធម្មជាតិដែលផ្សាយទៅផ្សេងៗ ធម្មជាតិជាគ្រឿងលក់ ធម្មជាតិដ៏ទូលាយ ធម្មជាតិជាគ្រឿងប្រមូល ធម្មជាតិជាគម្រប់ពីរ សេចក្តីតាំងទុក ធម្មជាតិជាគ្រឿងនាំ

សត្វទៅកាន់ភព ព្រៃធំ គឺតណ្ហា ព្រៃតូច គឺតណ្ហា សេចក្ដីស្និទ្ធស្នាល សេចក្ដីស្នេហា សេចក្ដីអាឡោះអាល័យ ផៅពង្ស គឺតណ្ហា ការសង្ឃឹម អាការសង្ឃឹម ភាពនៃសេចក្ដីសង្ឃឹម សេចក្ដីប្រាថ្នារូប សេចក្ដីប្រាថ្នាសំឡេង សេចក្ដីប្រាថ្នាក្លិន សេចក្ដីប្រាថ្នារស សេចក្ដីប្រាថ្នាផ្សព្វ សេចក្ដីប្រាថ្នាលាភ សេចក្ដីប្រាថ្នាទ្រព្យ សេចក្ដីប្រាថ្នាកូន សេចក្ដីប្រាថ្នាជីវិត ការប៉ុនប៉ង អាការប៉ុនប៉ង សេចក្ដីប៉ង បំណង អាការបំណង ភាពនៃសេចក្ដីប៉ង ការចង់បាន អាការចង់បាន ភាពនៃសេចក្ដីចង់បាន សេចក្ដីស្ងិតស្ងាញ សេចក្ដីប្រាថ្នាល្អ តម្រេកក្នុងអធម៌ សេចក្ដីលោភហួសហេតុ សេចក្ដីអាល័យ ការផ្ដេកផ្ដិត សេចក្ដីប្រាថ្នា សេចក្ដីស្រឡាញ់ សេចក្ដីប្រាថ្នាខ្លាំង សេចក្ដីប្រាថ្នាកាម សេចក្ដីប្រាថ្នាភព សេចក្ដីប្រាថ្នាប្រាសចាកភព សេចក្ដីប្រាថ្នារូបភព សេចក្ដីប្រាថ្នាអរូបភព សេចក្ដីប្រាថ្នា ការរម្ងត់ សេចក្ដីប្រាថ្នារូប សេចក្ដីប្រាថ្នាសំឡេង សេចក្ដីប្រាថ្នាក្លិន សេចក្ដីប្រាថ្នារស សេចក្ដីប្រាថ្នាផ្សព្វ សេចក្ដីប្រាថ្នាធម៌ ឱឃៈ ( ធម៌ញុំាងសត្វឲ្យលង់នៅក្នុងវដ្ដៈ ) យោគៈ ( ធម៌ញុំាងសត្វឲ្យជាប់នៅក្នុងវដ្ដៈ ) គន្ថៈ ( ធម៌ដោតក្រងសត្វទុកក្នុងវដ្ដៈដោយអំណាចចុតិ និងបដិសន្ធិ ) សេចក្ដីប្រកាន់មាំ ធម្មជាតិជាគ្រឿងរាំង ធម្មជាតិជាគ្រឿងឃាត់ ធម្មជាតិជាគ្រឿងបិទ ធម្មជាតិជាគ្រឿងចង សភាពជាគ្រឿងចូលទៅធ្វើឲ្យសៅហ្មង កិលេសជាគ្រឿងដេកនៅរឿយៗ កិលេសជាតជាគ្រឿងគ្របសង្កត់នូវចិត្ត តណ្ហាដូចជាវល្លិ សេចក្ដីស្ងិតស្ងាញ ឫសគល់នៃសេចក្ដីទុក្ខ ធម្មជាតិជាហេតុនៃទុក្ខ សភាពមានទុក្ខ

ជាដែនកើតមុន អន្ទាក់ គឺមារ សន្ទូច គឺមារ វិស័យ គឺមារ ស្ទឹង គឺតណ្ហា សំណាញ់ គឺតណ្ហា ខ្នោះ គឺតណ្ហា សមុទ្ទ គឺតណ្ហា សេចក្តីសម្ងំរំពៃ សេចក្តីចង់បាន ឫសគល់នៃអកុសលណា នេះហៅថា សេចក្តីលោភ ។ បណ្តាអកុសលមូលទាំងនោះ ទោសៈ តើដូចម្តេច ។ សេចក្តីគុំកួនតែងកើតឡើងថា បុគ្គលឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ សេចក្តីគុំកួនតែងកើតឡើងថា បុគ្គលឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ សេចក្តីគុំកួនតែងកើតឡើងថា បុគ្គលឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ សេចក្តីគុំកួនតែងកើតឡើងថា បុគ្គលឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនជាប្រយោជន៍ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ សេចក្តីគុំកួនតែងកើតឡើងថា បុគ្គលឯណោះ បានប្រព្រឹត្តហើយនូវអំពើជាប្រយោជន៍ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ មួយវិញទៀត សេចក្តីគុំកួនតែងកើតឡើងក្នុងទីមិនមែនជាហេតុ សេចក្តីគុំកួននៃចិត្ត សេចក្តីចង្អៀតចង្អល់ សេចក្តីតានតឹង សេចក្តីថ្នាំងថ្នាក់ សេចក្តីខឹង សេចក្តីខឹងខ្លាំង សេចក្តីខឹងក្រៃលែង សេចក្តីប្រទូស្ត សេចក្តីប្រទូស្តខ្លាំង សេចក្តីប្រទូស្តក្រៃលែង ការព្យាបាទនៃចិត្ត សេចក្តីប្រទូស្តក្នុងចិត្ត ការក្រោធ អាការក្រោធ ភាពនៃសេចក្តីក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃសេចក្តីប្រទូស្ត ការ

ព្យាបាទ អាការព្យាបាទ ភាពនៃសេចក្តីព្យាបាទ ការពិរោធ ការពិរោធផ្សេងៗ សេចក្តីកាច ការទឹង សេចក្តីអាក់អន់ចិត្ត មានសភាពយ៉ាងនេះណា នេះហៅថា ទោសៈ ។ បណ្តាអកុសលមូលទាំង ៣ នោះ មោហៈ តើដូចម្តេច ។ សេចក្តីមិនដឹងក្នុងទុក្ខ សេចក្តីមិនដឹងក្នុងហេតុដែលនាំឲ្យកើតទុក្ខ សេចក្តីមិនដឹងក្នុងការរលត់ទុក្ខ សេចក្តីមិនដឹងក្នុងបដិបទា ជាដំណើរដល់នូវការរលត់ទុក្ខ សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម សេចក្តីមិនដឹងក្នុងទីបំផុតខាងចុង សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម និងទីបំផុតខាងចុង សេចក្តីមិនដឹងក្នុងធម៌ទាំងឡាយ ដែលកើតឡើងព្រោះអាស្រ័យធម៌នេះជាបច្ច័យ សេចក្តីមិនដឹង សេចក្តីមិនយល់ ។បេ។ គន្លឹះ គឺអវិជ្ជា សេចក្តីវង្វេង ឫសគល់នៃអកុសលមានសភាពយ៉ាងនេះណា នេះហៅថា មោហៈ ។ នេះអកុសលមូល ៣ ។

[ ១៦១ ] បណ្តាធម៌ទាំងនោះ អកុសលវិតក្ក ៣ តើដូចម្តេច ។ កាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ ។ បណ្តាអកុសលវិតក្កទាំង ៣ នោះ កាមវិតក្ក តើដូចម្តេច ។ សេចក្តីត្រិះរិះ សេចក្តីជញ្ជឹងប្រកបដោយកាម ។បេ។ សេចក្តីត្រិះរិះខុស នេះហៅថា កាមវិតក្កៈ ។ បណ្តាអកុសលវិតក្កៈទាំង ៣ នោះ ព្យាបាទវិតក្កៈ តើដូចម្តេច ។ សេចក្តីត្រិះរិះ សេចក្តីជញ្ជឹងប្រកបដោយព្យាបាទ ។បេ។ សេចក្តីត្រិះរិះខុស នេះហៅថា ព្យាបាទវិតក្ក ។ បណ្តាអកុសលវិតក្កទាំង ៣ នោះ វិហឹសាវិតក្ក តើដូចម្តេច ។ សេចក្តីត្រិះរិះ សេចក្តីជញ្ជឹងប្រកបដោយការបៀតបៀន ។បេ។ សេចក្តីត្រិះ

ត្រិះរិះខុស នេះហៅថា វិហឹសាវិតក្ក ។ នេះអកុសលវិតក្ក ៣ ។

[ ១៦២ ] បណ្ដាធម៌ទាំងនោះ អកុសលសញ្ញា ៣ តើដូចម្ដេច ។ កាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហឹសាសញ្ញា ១ ។ បណ្ដាអកុសលសញ្ញាទាំង ៣ នោះ កាមសញ្ញា តើដូចម្ដេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃសេចក្ដីសម្គាល់ប្រកបដោយកាម នេះហៅថា កាមសញ្ញា ។ បណ្ដាអកុសលសញ្ញាទាំង ៣ នោះ ព្យាបាទសញ្ញា តើដូចម្ដេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃសេចក្ដីសម្គាល់ ប្រកបដោយព្យាបាទ នេះហៅថា ព្យាបាទសញ្ញា ។ បណ្ដាអកុសលសញ្ញាទាំង ៣ នោះ វិហឹសាសញ្ញា តើដូចម្ដេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃសេចក្ដីសម្គាល់ ប្រកបដោយការបៀតបៀន នេះហៅថា វិហឹសាសញ្ញា ។ នេះអកុសលសញ្ញា ៣ ។

[ ១៦៣ ] បណ្ដាធម៌ទាំងនោះ អកុសលធាតុ ៣ តើដូចម្ដេច ។ កាមធាតុ ១ ព្យាបាទធាតុ ១ វិហឹសាធាតុ ១ ។ បណ្ដាអកុសលធាតុទាំង ៣ នោះ កាមធាតុ តើដូចម្ដេច ។ ការជញ្ជឹងក្នុងកាម ឈ្មោះថា កាមធាតុ ។ ការជញ្ជឹងក្នុងព្យាបាទ ឈ្មោះថា ព្យាបាទធាតុ ។ ការជញ្ជឹងក្នុងសេចក្ដីបៀតបៀន ឈ្មោះថា វិហឹសាធាតុ ។ បណ្ដាវិតក្កទាំង ៣ នោះ កាមវិតក្ក តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីជញ្ជឹងប្រកបដោយកាម ។បេ។ សេចក្ដីត្រិះរិះខុស នេះហៅថា កាមវិតក្ក ។ បណ្ដាវិតក្កទាំង ៣ នោះ ព្យាបាទវិតក្ក តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីជញ្ជឹងប្រកបដោយព្យាបាទ ។បេ។ សេចក្ដីត្រិះរិះខុស នេះហៅថា ព្យាបាទវិតក្ក ។ បណ្ដាវិតក្កទាំង ៣ នោះ

វិហឹសាវិតក្ក តើដូចម្តេច ។ សេចក្តីត្រិះរិះ សេចក្តីជញ្ជឹងប្រកបដោយការបៀតបៀន ។បេ។ សេចក្តីត្រិះរិះខុស នេះហៅថា វិហឹសាវិតក្ក ។ នេះអកុសលធាតុ ៣ ។

[ ១៦៤ ] បណ្តាធម៌ទាំងនោះ ទុច្ចរិត ៣ តើដូចម្តេច ។ កាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ បណ្តាទុច្ចរិតទាំង ៣ នោះ កាយទុច្ចរិត តើដូចម្តេច ។ ការសម្លាប់សត្វ ការកាន់យកទ្រព្យដែលគេមិនបានឲ្យ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ នេះហៅថា កាយទុច្ចរិត ។ បណ្តាទុច្ចរិតទាំង ៣ នោះ វចីទុច្ចរិត តើដូចម្តេច ។ ការពោលពាក្យកុហក វាចាញុះញង់ វាចាអាក្រក់ ការពោលពាក្យរោយរាយ នេះហៅថា វចីទុច្ចរិត ។ បណ្តាទុច្ចរិតទាំង ៣ នោះ មនោទុច្ចរិត តើដូចម្តេច ។ ការសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ការគុំគួនគេ សេចក្តីយល់ខុស នេះហៅថា មនោទុច្ចរិត ។ បណ្តាទុច្ចរិតទាំង ៣ នោះ កាយទុច្ចរិត តើដូចម្តេច ។ កាយកម្មជាអកុសល ឈ្មោះថា កាយទុច្ចរិត ។ វចីកម្មជាអកុសល ឈ្មោះថា វចីទុច្ចរិត ។ មនោកម្មជាអកុសល ឈ្មោះថា មនោទុច្ចរិត ។ បណ្តាទុច្ចរិតទាំង ៣ នោះ កាយកម្មជាអកុសល តើដូចម្តេច ។ អាការក្លែងដោយកាយជាអកុសល ឈ្មោះថា កាយកម្មជាអកុសល ។ អាការក្លែងដោយវាចាជាអកុសល ឈ្មោះថា វចីកម្មជាអកុសល ។ អាការក្លែងដោយចិត្តជាអកុសល ឈ្មោះថា មនោកម្មជាអកុសល ។ នេះទុច្ចរិត ៣ ។

[ ១៦៥ ] បណ្តាធម៌ទាំងនោះ អាសវៈ ៣ តើដូចម្តេច ។ កាមាសវៈ

១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ បណ្តាអាសវៈទាំង ៣ នោះ កាមាសវៈ តើដូចម្តេច ។ សេចក្តីពេញចិត្តនឹងកាមក្នុងកាមទាំងឡាយ ។បេ។ សេចក្តីជ្រប់ក្នុងកាមណា នេះហៅថា កាមាសវៈ ។ បណ្តាអាសវៈទាំង ៣ នោះ ភវាសវៈ តើដូចម្តេច ។ សេចក្តីពេញចិត្តនឹងភពក្នុងភពទាំងឡាយ ។បេ។ សេចក្តីជ្រប់ក្នុងភពណា នេះហៅថា ភវាសវៈ ។ បណ្តាអាសវៈទាំង ៣ នោះ អវិជ្ជាសវៈ តើដូចម្តេច ។ សេចក្តីមិនដឹងក្នុងទុក្ខ ។បេ។ គន្លឹះ គឺអវិជ្ជា សេចក្តីវង្វេង ឫសគល់នៃអកុសល នេះហៅថា អវិជ្ជាសវៈ ។ នេះអាសវៈ ៣ ។

[ ១៦៦ ] បណ្តាធម៌ទាំងនោះ សញ្ញោជនៈ ៣ តើដូចម្តេច ។ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ ។ បណ្តាសញ្ញោជនៈ ទាំង ៣ នោះ សក្កាយទិដ្ឋិ តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិនបានជួបប្រទះនឹងពួកព្រះអរិយៈ មិនឈ្លាសវៃ ក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូប ថាជាខ្លួន ពិចារណាឃើញនូវខ្លួន ថាមានរូបខ្លះ ពិចារណាឃើញនូវរូប ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងរូបខ្លះ រមែងពិចារណាឃើញនូវវេទនា ។បេ។ នូវសញ្ញា ។បេ។ នូវសង្ខារទាំងឡាយ ។បេ។ នូវវិញ្ញាណ ថាជាខ្លួន ពិចារណាឃើញនូវខ្លួន ថាមានវិញ្ញាណខ្លះ ពិចារណាឃើញនូវវិញ្ញាណ ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញ

នូវខ្លួន ថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា នេះហៅថា សក្កាយទិដ្ឋិ ។ បណ្តាសញ្ញោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្តេច ។ បុគ្គលងឿងឆ្ងល់សង្ស័យក្នុងព្រះសាស្តា ងឿងឆ្ងល់សង្ស័យក្នុងព្រះធម៌ ងឿងឆ្ងល់សង្ស័យក្នុងព្រះសង្ឃ ងឿងឆ្ងល់សង្ស័យក្នុងសិក្ខា ងឿងឆ្ងល់សង្ស័យក្នុងទីបំផុតខាងដើម ងឿងឆ្ងល់សង្ស័យក្នុងទីបំផុតខាងចុង ងឿងឆ្ងល់សង្ស័យក្នុងទីបំផុតខាងដើម និងខាងចុង ងឿងឆ្ងល់សង្ស័យក្នុងធម៌ទាំងឡាយ ដែលកើតឡើងអាស្រ័យនូវគ្នានិងគ្នាព្រោះធម៌នេះជាបច្ច័យ ការងឿងឆ្ងល់ អាការងឿងឆ្ងល់ភាពនៃសេចក្តីងឿងឆ្ងល់ ។បេ។ ភាពនៃចិត្តរឹងត្អឹង គំនូសនៃចិត្តមានសភាពយ៉ាងនេះណា នេះហៅថា វិចិកិច្ឆា ។ បណ្តាសញ្ញោជនៈទាំង ៣ នោះ សីលព្វតបរាមាស តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ខាងក្រៅសាសនានេះ មានទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាសេចក្តីបរិសុទ្ធព្រោះសីល សេចក្តីបរិសុទ្ធិព្រោះវត្ត សេចក្តីបរិសុទ្ធព្រោះសីល និងវត្ត នេះហៅថា សីលព្វតបរាមាស ។ នេះសញ្ញោជនៈ ៣ ។

[ ១៦៧ ] បណ្តាធម៌ទាំងនោះ តណ្ហា ៣ តើដូចម្តេច ។ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ បណ្តាតណ្ហាទាំង ៣ នោះ ភវតណ្ហា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រព្រឹត្តទៅ មួយអន្លើដោយភវទិដ្ឋិ នេះហៅថា ភវតណ្ហា ។ បណ្តាតណ្ហាទាំង ៣ នោះ វិភវតណ្ហា

តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រព្រឹត្តទៅមួយអន្លើដោយឧច្ឆេទទិដ្ឋិ នេះហៅថា វិភវតណ្ហា ។ តណ្ហាដ៏សេស ឈ្មោះថា កាមតណ្ហា ។ បណ្តាតណ្ហាទាំង ៣ នោះ កាមតណ្ហា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រកបដោយកាមធាតុ នេះហៅថា កាមតណ្ហា ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រកបដោយរូបធាតុ និងអរូបធាតុ នេះហៅថា ភវតណ្ហា ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត ប្រព្រឹត្តទៅមួយអន្លើដោយឧច្ឆេទទិដ្ឋិ នេះហៅថា វិភវតណ្ហា ។ នេះតណ្ហា ៣ ។

[ ១៦៨ ] បណ្តាធម៌ទាំងនោះ តណ្ហា ៣ ដទៃទៀត តើដូចម្តេច ។ កាមតណ្ហា ១ រូបតណ្ហា ១ អរូបតណ្ហា ១ ។ បណ្តាតណ្ហាទាំង ៣ នោះ កាមតណ្ហា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រកបដោយកាមធាតុ នេះហៅថា កាមតណ្ហា ។ បណ្តាតណ្ហាទាំង ៣ នោះ រូបតណ្ហា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រកបដោយរូបធាតុ នេះហៅថា រូបតណ្ហា ។ បណ្តាតណ្ហាទាំង ៣ នោះ អរូបតណ្ហា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រកបដោយអរូបធាតុ នេះហៅថា អរូបតណ្ហា ។ នេះតណ្ហា ៣ ។

[ ១៦៩ ] បណ្តាធម៌ទាំងនោះ តណ្ហា ៣ ដទៃទៀត តើដូចម្តេច ។ រូបតណ្ហា ១ អរូបតណ្ហា ១ និរោធតណ្ហា ១ ។ បណ្តាតណ្ហាទាំង ៣ នោះ រូបតណ្ហា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត

ប្រកបដោយរូបធាតុ នេះហៅថា រូបតណ្ហា ។ បណ្តាតណ្ហាទាំង ៣ នោះ អរូបតណ្ហា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយអរូបធាតុ នេះហៅថា អរូបតណ្ហា ។ បណ្តាតណ្ហាទាំង ៣ នោះ និរោធតណ្ហា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំង នៃចិត្តប្រព្រឹត្តទៅ មួយអន្លើដោយឧច្ឆេទទិដ្ឋិ នេះហៅថា និរោធតណ្ហា ។ នេះតណ្ហា ៣ ។

[ ១៧០ ] បណ្តាធម៌ទាំងនោះ ការស្វែងរក ៣ តើដូចម្តេច ។ ការស្វែងរកកាម ១ ការស្វែងរកភព ១ ការស្វែងរកព្រហ្មចរិយៈ ១ ។ បណ្តាការស្វែងរកទាំង ៣ នោះ ការស្វែងរកកាម តើដូចម្តេច ។ សេចក្តីពេញចិត្តនឹងកាមក្នុងកាមទាំងឡាយ ។បេ។ សេចក្តីជ្រប់ក្នុងកាមណា នេះហៅថា ការស្វែងរកកាម ។ បណ្តាការស្វែងរកទាំង ៣ នោះ ការស្វែងរកភព តើដូចម្តេច ។ សេចក្តីពេញចិត្តនឹងភពក្នុងភពទាំងឡាយ ។បេ។ សេចក្តីជ្រប់ក្នុងភពណា នេះហៅថា ការស្វែងរកភព ។ បណ្តាការស្វែងរកទាំង ៣ នោះ ការស្វែងរកព្រហ្មចរិយៈ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសមានសភាពយ៉ាងនេះណា ដូច្នេះថា លោកទៀងខ្លះ ថាលោកមិនទៀងខ្លះ ។បេ។ ថាសត្វខាងមុខអំពីសេចក្តីស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ នេះហៅថា ការស្វែងរកព្រហ្មចរិយៈ ។ បណ្តាការស្វែងរកទាំង ៣ នោះ ការស្វែងរកកាម តើដូចម្តេច ។ សេចក្តីត្រេកអរក្នុងកាម កាយកម្ម វចីកម្ម មនោកម្មជាអកុសល

ដែលតាំងនៅក្នុងទីជាមួយគ្នានឹងសេចក្ដីត្រេកអរ ក្នុងកាមនោះ នេះហៅថា ការស្វែងរកកាម ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកភព តើដូចម្ដេច ។ សេចក្ដីត្រេកអរក្នុងភព កាយកម្ម វចីកម្ម មនោកម្មជាអកុសលដែលតាំងនៅក្នុងទីជាមួយគ្នានឹងសេចក្ដីត្រេកអរក្នុងភពនោះ នេះហៅថា ការស្វែងរកភព ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកព្រហ្មចរិយៈ តើដូចម្ដេច ។ អន្តគ្គាហិកទិដ្ឋិ ( ទិដ្ឋិដែលកាន់យកនូវទីបំផុត ) កាយកម្ម វចីកម្ម មនោកម្មជាអកុសល ដែលតាំងនៅក្នុងទីជាមួយគ្នានឹងអន្តគ្គាហិកទិដ្ឋិនោះ នេះហៅថា ការស្វែងរកព្រហ្មចរិយៈ ។ នេះការស្វែងរក ៣ ។

[ ១៧១ ] បណ្ដាធម៌ទាំងនោះ ការធ្វើងខ្ពស់ ៣ តើដូចម្ដេច ។ ការធ្វើងខ្ពស់ ព្រោះតាំងខ្លួនថា អញប្រសើរជាងគេ ១ ការធ្វើងខ្ពស់ ព្រោះតាំងខ្លួនថា អញស្មើនឹងគេ ១ ការធ្វើងខ្ពស់ ព្រោះតាំងខ្លួនថា អញថោកទាបជាងគេ ១ ។ នេះការធ្វើងខ្ពស់ ៣ ។

[ ១៧២ ] បណ្ដាធម៌ទាំងនោះ ភ័យ ៣ តើដូចម្ដេច ។ ភ័យព្រោះជាតិ ១ ភ័យព្រោះជរា ១ ភ័យព្រោះមរណៈ ១ ។ បណ្ដាភ័យទាំង ៣ នោះ ភ័យព្រោះជាតិ តើដូចម្ដេច ។ ភ័យ ហេតុដែលគួរភ័យ សេចក្ដីខ្លាច សេចក្ដីព្រឺរោម សេចក្ដីតក់ស្លុតនៃចិត្ត ព្រោះអាស្រ័យជាតិ នេះហៅថា ភ័យព្រោះជាតិ ។ បណ្ដាភ័យទាំង ៣ នោះ ភ័យព្រោះជរា តើដូចម្ដេច ។ ភ័យ ហេតុដែលគួរភ័យ សេចក្ដីខ្លាច សេចក្ដីព្រឺរោម សេចក្ដីតក់ស្លុតនៃចិត្តព្រោះ

អាស្រ័យជរា នេះហៅថា ភ័យព្រោះជរា ។ បណ្តាភ័យទាំង ៣ នោះ ភ័យព្រោះមរណៈ តើដូចម្តេច ។ ភ័យ ហេតុដែលគួរភ័យ សេចក្តីខ្លាច សេចក្តីព្រឺរោម សេចក្តីតក់ស្លុតនៃចិត្ត ព្រោះអាស្រ័យមរណៈ នេះហៅថា ភ័យព្រោះមរណៈ ។ នេះភ័យ ៣ ។

[ ១៧៣ ] បណ្តាធម៌ទាំងនោះ ងងឹត ៣ តើដូចម្តេច ។ បុគ្គលងឿងឆ្ងល់សង្ស័យ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ព្រោះប្រារព្ធនូវកាលជាអតីត ១ បុគ្គលងឿងឆ្ងល់សង្ស័យ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ព្រោះប្រារព្ធនូវកាលជាអនាគត ១ បុគ្គលងឿងឆ្ងល់សង្ស័យ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ព្រោះប្រារព្ធនូវកាលជាបច្ចុប្បន្ន ១ នេះងងឹត ៣ ។

[ ១៧៤ ] បណ្តាធម៌ទាំងនោះ លទ្ធិដូចជាកំពង់ ៣ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈក្តី ជាព្រាហ្មណ៍ក្តី រមែងពោលយ៉ាងនេះ យល់ឃើញយ៉ាងនេះថា បុរសបុគ្គលនេះ រមែងទទួលនូវអារម្មណ៍ណាមួយ ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី អារម្មណ៍ទាំងអស់នោះ មានអំពើដែលខ្លួនធ្វើទុកក្នុងកាលមុនជាហេតុ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈក្តី ជាព្រាហ្មណ៍ក្តី រមែងពោលយ៉ាងនេះ ឃើញយ៉ាងនេះថា បុរសបុគ្គលនេះ រមែងទទួលនូវអារម្មណ៍ណាមួយ ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី អារម្មណ៍ទាំងអស់នោះ មានការតាក់តែងរបស់ព្រះឥសូរជាហេតុ មួយវិញទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈក្តី ជាព្រាហ្មណ៍ក្តី រមែងពោលយ៉ាងនេះ យល់ឃើញយ៉ាងនេះថា បុរសបុគ្គល

នេះ រមែងទទួលនូវអារម្មណ៍ណាមួយ ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី អារម្មណ៍ទាំងអស់នោះ មិនមានហេតុ មិនមានបច្ច័យ នេះលទ្ធិដូចជាកំពង់ ៣ ។

[ ១៧៥ ] បណ្តាធម៌ទាំងនោះ កន្ទល់ ៣ តើដូចម្តេច ។ រាគៈជាកន្ទល់ ១ ទោសៈជាកន្ទល់ ១ មោហៈជាកន្ទល់ ១ នេះកន្ទល់ ៣ ។

[ ១៧៦ ] បណ្តាធម៌ទាំងនោះ ទីទួល ៣ តើដូចម្តេច ។ រាគៈជាទីទួល ១ ទោសៈជាទីទួល ១ មោហៈជាទីទួល ១ នេះទីទួល ៣ ។

[ ១៧៧ ] បណ្តាធម៌ទាំងនោះ មន្ទិល ៣ តើដូចម្តេច ។ រាគៈជាមន្ទិល ១ ទោសៈជាមន្ទិល ១ មោហៈជាមន្ទិល ១ នេះមន្ទិល ៣ ។

[ ១៧៨ ] បណ្តាធម៌ទាំងនោះ ធម្មជាតមិនរាបស្មើ ៣ តើដូចម្តេច ។ រាគៈ ជាធម្មជាតមិនរាបស្មើ ១ ទោសៈ ជាធម្មជាតមិនរាបស្មើ ១ មោហៈ ជាធម្មជាតមិនរាបស្មើ ១ នេះធម្មជាតមិនរាបស្មើ ៣ ។

[ ១៧៩ ] បណ្តាធម៌ទាំងនោះ ធម្មជាតមិនរាបស្មើ ៣ ដទៃទៀត តើដូចម្តេច ។ ធម្មជាតមិនរាបស្មើ គឺកាយ ១ ធម្មជាតមិនរាបស្មើ គឺវាចា ១ ធម្មជាតមិនរាបស្មើ គឺចិត្ត ១ នេះធម្មជាតមិនរាបស្មើ ៣ ។

[ ១៨០ ] បណ្តាធម៌ទាំងនោះ ភ្លើង ៣ តើដូចម្តេច ។ ភ្លើង គឺរាគៈ ១ ភ្លើង គឺទោសៈ ១ ភ្លើង គឺមោហៈ ១ នេះភ្លើង ៣ ។

[ ១៨១ ] បណ្តាធម៌ទាំងនោះ ទឹកចត់ ៣ តើដូចម្តេច ។ ទឹកចត់ គឺរាគៈ ១ ទឹកចត់ គឺទោសៈ ១ ទឹកចត់ គឺមោហៈ ១ នេះទឹកចត់ ៣ ។

[ ១៨២ ] បណ្តាធម៌ទាំងនោះ ទឹកចត់ ៣ ដទៃទៀត តើដូចម្តេច ។ ទឹកចត់ គឺកាយ ១ ទឹកចត់ គឺវាចា ១ ទឹកចត់ គឺចិត្ត ១ នេះទឹកចត់ ៣ ។

[ ១៨៣ ] បណ្តាធម៌ទាំងនោះ សេចក្តីយល់ឃើញថា គួរត្រេកអរ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈក្តី ជាព្រាហ្មណ៍ក្តី រមែងពោលយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន បុគ្គលនោះ តែងដល់នូវភាពជាអ្នកធ្លាក់ចុះក្នុងកាមទាំងឡាយ នេះហៅថា សេចក្តីយល់ឃើញថា គួរត្រេកអរ ។ បណ្តាធម៌ទាំងនោះ សេចក្តីយល់ឃើញថា ជាខ្លួន តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនជួបប្រទះនឹងពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួន ក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួន ក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូប ថាជាខ្លួន ពិចារណាឃើញនូវខ្លួន ថាមានរូបខ្លះ ពិចារណាឃើញនូវរូប ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងរូបខ្លះ រមែងពិចារណាឃើញនូវវេទនា ។បេ។ នូវសញ្ញា ។បេ។ នូវសង្ខារទាំងឡាយ ។បេ។ នូវវិញ្ញាណ ថាជាខ្លួន ពិចារណាឃើញនូវខ្លួន ថាមានវិញ្ញាណខ្លះ រមែងពិចារណាឃើញនូវវិញ្ញាណ ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីយល់ឃើញថា ជាខ្លួន ។ បណ្តាធម៌ទាំងនោះ សេចក្តីយល់ឃើញខុស តើ

ដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថាទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជា មិនមានផល ។បេ។ ពួកសមណព្រាហ្មណ៍ ដែលបានធ្វើឲ្យជាក់ច្បាស់នូវលោកនេះផង នូវលោកដទៃផង ដោយបញ្ញារបស់ខ្លួន ហើយសម្តែង មិនមានទេ នេះហៅថា សេចក្តីយល់ឃើញខុស ។ សស្សតទិដ្ឋិ ឈ្មោះថា អស្សាទទិដ្ឋិ ។ សក្កាយទិដ្ឋិ ឈ្មោះថា អត្តានុទិដ្ឋិ ។ ឧច្ឆេទទិដ្ឋិ ឈ្មោះថា មិច្ឆាទិដ្ឋិ ។

[ ១៨៤ ] បណ្តាធម៌ទាំងនោះ សេចក្តីមិនត្រេកអរ តើដូចម្តេច ។ ការមិនត្រេកអរ សេចក្តីមិនត្រេកអរ ការមិនរីករាយ សេចក្តីមិនរីករាយ សេចក្តីអផ្សុក សេចក្តីសោប់សេល់ក្នុងសេនាសនៈដ៏ស្ងាត់ក្តី ក្នុងធម៌ជាកុសលដ៏លើសលុបដទៃទៀតក្តី នេះហៅថា សេចក្តីមិនត្រេកអរ ។ បណ្តាធម៌ទាំងនោះ សេចក្តីបៀតបៀន តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ តែងបៀតបៀននូវសត្វទាំងឡាយ ដោយវត្ថុណាមួយ គឺដៃក្តី ដុំដីក្តី ដំបងក្តី គ្រឿងសស្ត្រាក្តី ខ្សែក្តី ការធ្វើឲ្យលំបាក ការធ្វើឲ្យលំបាកខ្លាំង ការបៀតបៀន កាបៀតបៀនខ្លាំង ការប្រទូស្ត ការប្រទូស្តខ្លាំង ការបៀតបៀននូវសត្វដទៃ មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីបៀតបៀន ។ បណ្តាធម៌ទាំងនោះ ការប្រព្រឹត្តនូវអំពើមិនមែនធម៌ តើដូចម្តេច ។ ការប្រព្រឹត្តមិនស្មើដោយកាយ ឈ្មោះថា ការប្រព្រឹត្តនូវអំពើមិនមែនធម៌ ការប្រព្រឹត្តមិនស្មើដោយវាចា ឈ្មោះថា ការប្រព្រឹត្តនូវអំពើមិនមែនធម៌ ការប្រព្រឹត្តមិន

ស្មើដោយចិត្ត ឈ្មោះថា ការប្រព្រឹត្តនូវអំពើមិនមែនធម៌ នេះហៅថា ការប្រព្រឹត្តនូវអំពើមិនមែនធម៌ ។

[ ១៨៥ ] បណ្ដាធម៌ទាំងនោះ ការប្រដៅក្រ តើដូចម្ដេច ។ ការប្រដៅក្រ អាការប្រដៅក្រ ភាពនៃសេចក្ដីប្រដៅក្រ ការកាន់យកនូវអំពើដែលគួរខ្ពើម ( អំពើផ្ដេសផ្ដាស ) ការពេញចិត្តក្នុងធម៌ជាសត្រូវ ការមិនអើពើ សេចក្ដីមិនអើពើ សេចក្ដីមិនគោរព សេចក្ដីមិនស្ដាប់បង្គាប់ ចំពោះពាក្យប្រកបដោយធម៌ដែលគេពោល នេះហៅថា ការប្រដៅក្រ ។ បណ្ដាធម៌ទាំងនោះ ភាពជាអ្នកមានមិត្តអាក្រក់ តើដូចម្ដេច ។ បុគ្គលទាំងឡាយណា ជាអ្នកមិនមានសទ្ធា ទ្រុស្ដសីល ចេះដឹងតិច មានសេចក្ដីកំណាញ់ ឥតប្រាជ្ញា ការសេព ការសេពមិនដាច់ ការសេពរឿយៗ ការគប់រក ការគប់រករឿយៗ ការភប់ប្រសព្វ ការភប់ប្រសព្វរឿយៗ នូវបុគ្គលទាំងឡាយនោះ ការបែររេទៅរកបុគ្គលនោះណា នេះហៅថា ភាពជាអ្នកមានមិត្តអាក្រក់ ។ បណ្ដាធម៌ទាំងនោះ សញ្ញាផ្សេងៗ តើដូចម្ដេច ។ សេចក្ដីសម្គាល់ក្នុងកាម សេចក្ដីសម្គាល់ក្នុងព្យាបាទ សេចក្ដីសម្គាល់ក្នុងការបៀតបៀន នេះហៅថា សញ្ញាផ្សេងៗ សូម្បីសេចក្ដីសម្គាល់ក្នុងអកុសលទាំងអស់ ក៏ឈ្មោះថា សញ្ញាផ្សេងៗ ដែរ ។

[ ១៨៦ ] បណ្ដាធម៌ទាំងនោះ សេចក្ដីរាយមាយ តើដូចម្ដេច ។ សេចក្ដីរាយមាយនៃចិត្ត ការមិនស្ងប់នៃចិត្ត ការរវើរវាយនៃចិត្ត សេចក្ដីប្រែប្រួលនៃចិត្តណា នេះហៅថា សេចក្ដីរាយមាយ ។ បណ្ដាធម៌ទាំងនោះ សេចក្ដី

ខិល តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្ត ទៅក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណទាំង ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែសក្នុងការចម្រើននូវធម៌ជាកុសល នេះហៅថា សេចក្តីខិល ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រមាទ តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្តទៅក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណទាំង ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែសក្នុងការចម្រើននូវធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រមាទ ។

[ ១៨៧ ] បណ្តាធម៌ទាំងនោះ សេចក្តីមិនសន្តោស តើដូចម្តេច ។ សេចក្តីប្រាថ្នាដ៏ក្រៃលែង នៃបុគ្គលមិនសន្តោស ដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ឬដោយកាមគុណទាំង ៥ សេចក្តីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្តីប្រាថ្នា សេចក្តីមិនសន្តោស តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃ

ចិត្ត មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីមិនសន្តោស ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនដឹងខ្លួន តើដូចម្តេច ។ សេចក្តីមិនដឹង សេចក្តីមិនយល់ ។បេ។ គន្លឹះ គឺអវិជ្ជា សេចក្តីវង្វេង ឫសគល់នៃអកុសលណា នេះហៅថា សេចក្តីមិនដឹងខ្លួន ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រាថ្នាធំ តើដូចម្តេច ។ សេចក្តីប្រាថ្នាដ៏ក្រៃលែងនៃបុគ្គលមិនសន្តោសដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ឬដោយកាមគុណទាំង ៥ សេចក្តីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាធំ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រាថ្នាធំ ។

[ ១៨៨ ] បណ្តាធម៌ទាំងនោះ សេចក្តីមិនខ្មាសបាប តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនខ្មាស ដោយវត្ថុដែលគួរខ្មាស មិនខ្មាសដោយការជួបប្រទះនឹងពួកអកុសលធម៌ដ៏លាមក នេះហៅថា សេចក្តីមិនខ្មាសបាប ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនក្តៅនឹងបាប តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនតក់ស្លុត ដោយវត្ថុដែលគួរតក់ស្លុត មិនតក់ស្លុតដោយការជួបប្រទះនឹងពួកអកុសលធម៌ដ៏លាមក នេះហៅថា សេចក្តីមិនក្តៅនឹងបាប ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រមាទ តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្តទៅក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណទាំងប្រាំក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការ

មិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកប រឿយៗ ការធ្វេសប្រហែសក្នុងការចម្រើននូវធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រមាទ ។

[ ១៨៩ ] បណ្តាធម៌ទាំងនោះ សេចក្តីមិនអើពើ តើដូចម្តេច ។ ការមិនអើពើ សេចក្តីមិនអើពើ សេចក្តីមិនគោរព សេចក្តីមិនស្តាប់បង្គាប់ ការមិនកាន់យក អាការមិនកាន់យក ភាពនៃសេចក្តីមិនកាន់យក ការមិនមានប្រក្រតី ការមិនធ្វើនូវសេចក្តីឱនលំទោនណា នេះហៅថា សេចក្តីមិនអើពើ ។ បណ្តាធម៌ទាំងនោះ ការប្រដៅក្រ តើដូចម្តេច ។ ការប្រដៅក្រ អាការប្រដៅក្រ ភាពនៃសេចក្តីប្រដៅក្រ ការកាន់យកនូវអំពើដែលគួរខ្ពើម ( អីពើផ្តេសផ្តាស ) ការពេញចិត្តក្នុងធម៌ជាសត្រូវ ការមិនអើពើ សេចក្តីមិនអើពើ សេចក្តីមិនគោរព សេចក្តីមិនស្តាប់បង្គាប់ ចំពោះពាក្យប្រកបដោយធម៌ដែលគេពោល នេះហៅថា ការប្រដៅក្រ ។ បណ្តាធម៌ទាំងនោះ ភាពជាអ្នកមានមិត្តអាក្រក់ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកមិនមានសទ្ធា ទ្រុស្តសីល ចេះដឹងតិច មានសេចក្តីកំណាញ់ ឥតបញ្ញា ការសេព ការសេពមិនដាច់ ការគប់រក ការគប់រករឿយៗ ការកប់ប្រសព្វ ការកប់ប្រសព្វរឿយៗ នូវបុគ្គលទាំងឡាយនោះ ការបែរទៅរកបុគ្គលនោះណា នេះហៅថា ភាពជាអ្នកមានមិត្តអាក្រក់ ។

[ ១៩០ ] បណ្តាធម៌ទាំងនោះ សេចក្តីមិនជឿ តើដូចម្តេច ។ បុគ្គល

ពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា មិនជឿព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី សេចក្តីមិនជឿ ការមិនជឿ ការមិនចុះចិត្តស៊ប់ ការមិនជ្រះថ្លាខ្ជាំង មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីមិនជឿ ។ បណ្តាធម៌ទាំងនោះ ការមិនធ្វើដឹងឮពាក្យ ( ស្អូម ) តើដូចម្តេច ។ សេចក្តីកំណាញ់ ៥ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្តីសរសើរ ១ កំណាញ់ធម៌ ១ ការកំណាញ់ អាការកំណាញ់ សេចក្តីកំណាញ់ សេចក្តីប្រាថ្នាផ្សេងៗ សេចក្តីកំណាញ់រឹង សេចក្តីស្វិតស្វាញ ភាពនៃចិត្តមិនយកចិត្តគេ មានសភាពយ៉ាងនេះណា នេះហៅថា ការមិនធ្វើដឹងឮពាក្យ ( ស្អូម ) ។ បណ្តាធម៌ទាំងនោះ សេចក្តីខ្ជិល តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្ត ទៅក្នុងកាយទុច្ចរិតក្តី វចីទុច្ចរិតក្តី មនោទុច្ចរិតក្តី ក្នុងកាមគុណទាំង ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែសក្នុងការចម្រើននូវធម៌ជាកុសល នេះហៅថា សេចក្តីខ្ជិល ។

[ ១៩១ ] បណ្តាធម៌ទាំងនោះ សេចក្តីរាយមាយ តើដូចម្តេច ។ សេចក្តីរាយមាយនៃចិត្ត ការមិនស្ងប់រម្ងាប់នៃចិត្ត ការរវើរវាយនៃចិត្ត សេចក្តីប្រែប្រួលនៃចិត្តណា នេះហៅថា សេចក្តីរាយមាយ ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនសង្រួម តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ឃើញនូវរូប

ដោយចក្ខុ ហើយកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈា និង ទោមនស្សដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គលដែល មិនបានសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ មិនប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវ សេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយ ច្រមុះ ។បេ។ ជញ្ជក់រសដោយអណ្តាត ។បេ។ ពាល់ត្រូវផ្សព្វ ដោយ កាយ ។បេ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ហើយកាន់យកនូវនិមិត្ត កាន់ យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុ មិនបានសង្រួមនូវមនិន្ទ្រិយណា ក៏មិនប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ មិនរក្សានូវមនិន្ទ្រិយ មិនដល់នូវសេចក្តីសង្រួម ក្នុងមនិន្ទ្រិយ នេះហៅថា សេចក្តីមិនសង្រួម ។ បណ្តាធម៌ទាំងនោះ សេចក្តីទ្រុស្តសីល តើដូចម្តេច ។ ការប្រព្រឹត្តកន្លងប្រកបដោយកាយ ការប្រព្រឹត្តកន្លងប្រកបដោយវាចា ការ ប្រព្រឹត្តកន្លង ប្រកបដោយកាយ និងប្រកបដោយវាចា នេះហៅថា សេចក្តី ទ្រុស្តសីល ។

[ ១៩២ ] បណ្តាធម៌ទាំងនោះ សេចក្តីមិនប្រាថ្នាដើម្បីឃើញព្រះអរិយៈ តើដូចម្តេច ។ បណ្តាបុគ្គលទាំងនោះ ព្រះអរិយៈ តើដូចម្តេច ។ ព្រះពុទ្ធ ទាំងឡាយក្តី សាវករបស់ព្រះពុទ្ធក្តី ហៅថា ព្រះអរិយៈ ការមិនប្រាថ្នាដើម្បី ឃើញ ការមិនប្រាថ្នាដើម្បីជួប ការមិនប្រាថ្នាដើម្បីទៅកាន់ទីជិត ការមិន

ប្រាថ្នាដើម្បីទៅជាមួយនឹងព្រះអរិយៈទាំងឡាយនេះណា នេះហៅថា សេចក្ដីមិនប្រាថ្នាដើម្បីឃើញព្រះអរិយៈ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីមិនប្រាថ្នាដើម្បីស្ដាប់នូវព្រះសទ្ធម្ម តើដូចម្ដេច ។ បណ្ដាធម៌ទាំងនោះ ព្រះសទ្ធម្ម តើដូចម្ដេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ នេះហៅថា ព្រះសទ្ធម្ម សេចក្ដីមិនប្រាថ្នាដើម្បីស្ដាប់ សេចក្ដីមិនប្រាថ្នាដើម្បីឮ សេចក្ដីមិនប្រាថ្នាដើម្បីរៀន សេចក្ដីមិនប្រាថ្នាដើម្បីទ្រទ្រង់នូវព្រះសទ្ធម្មនេះណា នេះហៅថា សេចក្ដីមិនប្រាថ្នាដើម្បីស្ដាប់នូវព្រះសទ្ធម្ម ។ បណ្ដាធម៌ទាំងនោះ ភាពនៃបុគ្គលមានចិត្តប្រណាំងប្រជែង តើដូចម្ដេច ។ បណ្ដាធម៌ទាំងនោះ សេចក្ដីប្រណាំងប្រជែង តើដូចម្ដេច ។ ការប្រណាំងប្រជែង ការប្រណាំងប្រជែងរឿយៗ អាការប្រណាំងប្រជែង អាការប្រណាំងប្រជែងរឿយៗ ភាពនៃសេចក្ដីប្រណាំងប្រជែងរឿយៗ ការធ្មើងធ្មៃ ការមើលងាយ ការពេបជ្រាយ ការស្វែងរកទោសណា នេះហៅថា ភាពនៃបុគ្គលមានចិត្តប្រណាំងប្រជែង ។

[ ១៩៣ ] បណ្ដាធម៌ទាំងនោះ ការភ្លេចស្មារតី តើដូចម្ដេច ។ ការមិនមានស្មារតី ការមិនរឭកឃើញ ការមិននឹកឃើញ ការមិនរឭក សេចក្ដីមិនរឭក សេចក្ដីមិនចងចាំ សេចក្ដីភ្លេចភ្លាំង សេចក្ដីវង្វេងណា នេះហៅថា ការភ្លេចស្មារតី ។ បណ្ដាធម៌ទាំងនោះ សេចក្ដីមិនដឹងខ្លួន តើដូចម្ដេច ។ សេចក្ដីមិនដឹង សេចក្ដីមិនយល់ ។បេ។ គន្លឹះ គឺអវិជ្ជា សេចក្ដីវង្វេង ឫសគល់នៃអកុសលណា នេះហៅថា សេចក្ដីមិនដឹងខ្លួន ។ បណ្ដាធម៌ទាំងនោះ

សេចក្តីរីករាយនៃចិត្ត តើដូចម្តេច ។ សេចក្តីអណ្តែតអណ្តូងនៃចិត្ត ការមិនស្ងប់រម្ងាប់នៃចិត្ត សេចក្តីរាយមាយនៃចិត្ត ការប្រែប្រួលនៃចិត្តណា នេះហៅថា សេចក្តីរាយមាយនៃចិត្ត ។

[ ១៩៤ ] បណ្តាធម៌ទាំងនោះ ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ តើដូចម្តេច ។ ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ក្នុងរបស់ដែលមិនទៀង ថាទៀង ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ក្នុងរបស់ដែលជាទុក្ខ ថាសុខ ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ក្នុងរបស់ដែលមិនមែនខ្លួន ថាខ្លួន ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ក្នុងរបស់មិនស្អាត ថាស្អាត មួយទៀត ការរំពឹង ការរំពឹងរឿយៗ ការផ្គងចិត្តទុក ការតម្រង់ចិត្តទុក ការធ្វើទុកក្នុងចិត្តដោយខុសចាកសច្ចៈ នេះហៅថា ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ។ បណ្តាធម៌ទាំងនោះ ការសេពផ្លូវខុស តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ផ្លូវខុស តើដូចម្តេច ។ សេចក្តីយល់ខុស តម្រិះខុស វាចាខុស ការងារខុស ការចិញ្ចឹមជីវិតខុស ការព្យាយាមខុស សេចក្តីរឭកខុស ការតម្កល់ចិត្តខុស នេះហៅថា ផ្លូវខុស ការសេព ការសេពមិនដាច់ ការសេពព្រមការគប់រក ការគប់រករឿយៗ សេចក្តីគប់រក សេចក្តីគប់រករឿយៗ នូវផ្លូវខុសនេះ ការបែរទៅរកផ្លូវខុសនេះណា នេះហៅថា ការសេពផ្លូវខុស ។ បណ្តាធម៌ទាំងនោះ ភាពនៃចិត្តរួញរា តើដូចម្តេច ។ ភាពមិនគួរ ភាពមិនគួរដល់ការងារ ការរួញថយ ការរួញចូល ការលីប-ល អាការលីប-ល ភាពនៃសេចក្តីលីប-ល ការក្រាញនៅ អាការក្រាញនៅ ភាពនៃសេចក្តីក្រាញ

នៅនៃចិត្តណា នេះហៅថា ភាពនៃចិត្តរួញរា ។

ពួកធម៌ ៣ ចប់ ។

[ ១៩៥ ] បណ្ដាធម៌ទាំងនោះ អាសវៈ ៤ តើដូចម្ដេច ។ កាមាសវៈ ១ ភវាសវៈ ១ ទិដ្ឋាសវៈ ១ អវិជ្ជាសវៈ ១ បណ្ដាអាសវៈទាំង ៤ នោះ កាមាសវៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នាកាម ក្នុងកាមទាំងឡាយ ។បេ។ ការជ្រុលជប់ក្នុងកាមណា នេះហៅថា កាមាសវៈ ។ បណ្ដាអាសវៈទាំង ៤ នោះ ភវាសវៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នាភពក្នុងភពទាំងឡាយ ។បេ។ ការជ្រុលជប់ក្នុងភពណា នេះហៅថា ភវាសវៈ ។ បណ្ដាអាសវៈទាំង ៤ នោះ ទិដ្ឋាសវៈ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ ការប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ដូច្នេះថា លោកទៀងក្ដី ។បេ។ ថា សត្វខាងមុខអំពីសេចក្ដីស្លាប់កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្ដី នេះហៅថា ទិដ្ឋាសវៈ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ឈ្មោះថា ទិដ្ឋាសវៈ ។ បណ្ដាអាសវៈទាំង ៤ នោះ អវិជ្ជាសវៈ តើដូចម្ដេច ។ ការមិនដឹងក្នុងទុក្ខ ។បេ។ គន្ថិៈ គឺអវិជ្ជា សេចក្ដីវង្វេង ឫសគល់នៃអកុសល នេះហៅថា អវិជ្ជាសវៈ ។ នេះអាសវៈ ៤ ។

[ ១៩៦ ] បណ្ដាធម៌ទាំងនោះ គន្ថៈ ( ធម៌ជាគ្រឿងចាក់ស្រែះ ) ៤ តើដូចម្ដេច ។ អភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ ១ ។ បណ្ដាគន្ថៈទាំង ៤ នោះ អភិជ្ឈាកាយគន្ថៈ តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ សេចក្ដី

សម្ងំនរំពៃ សេចក្តីលោភ ឫសគល់នៃអកុសលណា នេះហៅថា អភិជ្ឈាកាយគន្ថៈ ។ បណ្តាគន្ថៈទាំង ៤ នោះ ព្យាបាទកាយគន្ថៈ តើដូចម្តេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ ។បេ។ សេចក្តីកាច ការខឹង សេចក្តីមិនត្រេកអរនៃចិត្ត នេះហៅថា ព្យាបាទកាយគន្ថៈ ។ បណ្តាគន្ថៈទាំង ៤ នោះ សីលព្វតបរាមាសកាយគន្ថៈ តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅសាសនានេះ មានទិដ្ឋិដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ដូច្នេះថា សេចក្តីបរិសុទ្ធព្រោះសីល សេចក្តីបរិសុទ្ធព្រោះវត្ត សេចក្តីបរិសុទ្ធព្រោះសីល និងវត្ត នេះហៅថា សីលព្វតបរាមាសកាយគន្ថៈ ។ បណ្តាគន្ថៈទាំង ៤ នោះ ឥទំសច្ចាភិនិវេសកាយគន្ថៈ តើដូចម្តេច ។ ទិដ្ឋិដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងខុស មានសភាពយ៉ាងនេះណា ដូច្នេះថា លោកទៀង សេចក្តីយល់នេះពិត សេចក្តីយល់ដទៃជាមោឃក្តី ថាលោកមិនទៀង សេចក្តីយល់នេះពិត សេចក្តីយល់ដទៃជាមោឃក្តី ។បេ។ ថាសត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន សេចក្តីយល់នេះពិត សេចក្តីយល់ដទៃជាមោឃក្តី នេះហៅថា ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ លើកលែងតែសីលព្វបរាមាសកាយគន្ថៈចេញ ក៏ឈ្មោះថា ឥទំសច្ចាភិនិវេសកាយគន្ថៈដែរ ។ នេះគន្ថៈ ៤ ។

[ ១៩៧ ] បណ្តាធម៌ទាំងនោះ ឱឃៈ ៤ តើដូចម្តេច ។បេ។ យោគៈ ។បេ។

ឧបាទាន ៤ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ បណ្តាឧបាទានទាំង ៤ នោះ កាមុបាទាន តើដូចម្តេច ។ សេចក្តីប្រាថ្នានូវកាម ក្នុងកាមទាំងឡាយ ។បេ។ ការផ្គុលផប់ក្នុងកាមណា នេះហៅថា កាមុបាទាន ។ បណ្តាឧបាទានទាំង ៤ នោះ ទិដ្ឋុបាទាន តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ដូច្នេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជា មិនមានផល ។បេ។ សមណព្រាហ្មណ៍ទាំងឡាយ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ហើយសម្តែង មិនមានទេ នេះហៅថា ទិដ្ឋុបាទាន ។ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ លើកតែសីលព្វតុបាទាន និងអត្តវាទុបាទានចេញ ក៏ឈ្មោះថា ទិដ្ឋុបាទានដែរ ។ បណ្តាឧបាទានទាំង ៤ នោះ សីលព្វតុបាទាន តើដូចម្តេច ។ សមណព្រាហ្មណ៍ទាំងឡាយ ខាងក្រៅសាសនានេះ មានទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ដូច្នេះថា សេចក្តីបរិសុទ្ធព្រោះសីល សេចក្តីបរិសុទ្ធព្រោះវត្ត សេចក្តីបរិសុទ្ធព្រោះសីល និងវត្ត នេះហៅថា សីលព្វតុបាទាន ។ បណ្តាឧបាទានទាំង ៤ នោះ អត្តវាទុបាទាន តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានឃើញពួកសប្បុរស មិនឈ្លាសក្នុងធម៌របស់ពួកសប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់ពួកសប្បុរស រមែងពិចារណា

ឃើញនូវរូប ថាជាខ្លួន ពិចារណាឃើញនូវខ្លួន ថាមានរូបខ្លះ ពិចារណាឃើញនូវរូប ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងរូបខ្លះ ពិចារណាឃើញនូវវេទនា ។បេ។ នូវសញ្ញា ។បេ។ នូវសង្ខារទាំងឡាយ ។បេ។ នូវវិញ្ញាណ ថាជាខ្លួន ពិចារណាឃើញនូវខ្លួនថា មានវិញ្ញាណខ្លះ ពិចារណាឃើញនូវវិញ្ញាណ ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា នេះហៅថា អត្តវាទុបាទាន ។ នេះឧបាទាន ៤ ។

[ ១៩៨ ] បណ្តាធម៌ទាំងនោះ តណ្ហុបាទា ៤ តើដូចម្តេច ។ តណ្ហានៃភិក្ខុ កាលនឹងកើត រមែងកើតឡើងព្រោះហេតុនៃចីវរខ្លះ តណ្ហានៃភិក្ខុ កាលនឹងកើត រមែងកើតឡើងព្រោះហេតុនៃបិណ្ឌបាតខ្លះ តណ្ហានៃភិក្ខុ កាលនឹងកើត រមែងកើតឡើងព្រោះហេតុនៃសេនាសនៈខ្លះ តណ្ហានៃភិក្ខុ កាលនឹងកើត រមែងកើតឡើងព្រោះហេតុនៃសេចក្តីចម្រើន និងសេចក្តីវិនាសដូច្នេះៗខ្លះ នេះតណ្ហុបាទា ៤ ។

[ ១៩៩ ] បណ្តាធម៌ទាំងនោះ ការលុះក្នុងអគតិ ៤ តើដូចម្តេច ។ បុគ្គលដល់នូវការលម្អៀង ព្រោះស្រឡាញ់ ១ ដល់នូវការលម្អៀងព្រោះស្អប់ ១ ដល់នូវការលម្អៀង ព្រោះវង្វេង ១ ដល់នូវការលម្អៀង ព្រោះខ្លាច ១ សេចក្តីលម្អៀង ការលុះក្នុងសេចក្តីលម្អៀង ការលុះដោយឆន្ទៈ ការលុះដោយពួក ការលុះដូចជាទឹក មានសភាពយ៉ាងនេះណា នេះការលុះអគតិ ៤ ។

[ ២០០ ] បណ្តាធម៌ទាំងនោះ ការស្វែងរកខុស ៤ តើដូចម្តេច ។ ការស្វែងរកខុសដោយសញ្ញា ការស្វែងរកខុសដោយចិត្ត ការស្វែងរកខុសដោយទិដ្ឋិ ក្នុងវត្ថុមិនទៀង ថាទៀង ១ ការស្វែងរកខុសដោយសញ្ញា ការស្វែងរកខុសដោយចិត្ត ការស្វែងរកខុសដោយទិដ្ឋិ ក្នុងវត្ថុជាទុក្ខ ថាសុខ ១ ការស្វែងរកខុសដោយសញ្ញា ការស្វែងរកខុសដោយចិត្ត ការស្វែងរកខុសដោយទិដ្ឋិ ក្នុងសភាវៈមិនមែនខ្លួន ថាជាខ្លួន ១ ការស្វែងរកខុសដោយសញ្ញា ការស្វែងរកខុសដោយចិត្ត ការស្វែងរកខុសដោយទិដ្ឋិ ក្នុងវត្ថុមិនស្អាត ថាស្អាត ១ នេះការស្វែងរកខុស ៤ ។

[ ២០១ ] បណ្តាធម៌ទាំងនោះ វោហារមិនប្រសើរ ៤ តើដូចម្តេច ។ ការពោលថា ឃើញក្នុងហេតុដែលមិនបានឃើញ ១ ការពោលថា ឮក្នុងហេតុដែលមិនបានឮ ១ ការពោលថា លិទ្ធភ្លក្សក្នុងហេតុដែលមិនបានលិទ្ធភ្លក្ស ១ ការពោលថា ដឹងក្នុងហេតុដែលមិនបានដឹង ១ នេះវោហារមិនប្រសើរ ៤ ។

[ ២០២ ] បណ្តាធម៌ទាំងនោះ វោហារមិនប្រសើរ ៤ ដទៃទៀត តើដូចម្តេច ។ ការពោលថា មិនឃើញក្នុងហេតុដែលបានឃើញ ១ ការពោលថា មិនឮក្នុងហេតុដែលបានឮ ១ ការពោលថា មិនបានលិទ្ធភ្លក្សក្នុងហេតុដែលបានលិទ្ធភ្លក្ស ១ ការពោលថា មិនបានដឹងក្នុងហេតុដែលបានដឹង ១ នេះ វោហារមិនប្រសើរ ៤ ។

[ ២០៣ ] បណ្តាធម៌ទាំងនោះ ទុច្ចរិត ៤ តើដូចម្តេច ។ បាណាតិបាត

១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ នេះទុច្ចរិត ៤ ។

[ ២០៤ ] បណ្ដាធម៌ទាំងនោះ ទុច្ចរិត ៤ ដទៃទៀត តើដូចម្ដេច ។ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ នេះទុច្ចរិត ៤ ។

[ ២០៥ ] បណ្ដាធម៌ទាំងនោះ ភ័យ ៤ តើដូចម្ដេច ។ ជាតិភ័យ ១ ជរាភ័យ ១ ព្យាធិភ័យ ១ មរណភ័យ ១ នេះភ័យ ៤ ។

[ ២០៦ ] បណ្ដាធម៌ទាំងនោះ ភ័យ ៤ ដទៃទៀត តើដូចម្ដេច ។ រាជ-ភ័យ ១ ចោរភ័យ ១ អគ្គិភ័យ ១ ឧទកភ័យ ១ នេះភ័យ ៤ ។

[ ២០៧ ] បណ្ដាធម៌ទាំងនោះ ភ័យ ៤ ដទៃទៀត តើដូចម្ដេច ។ ភ័យអំពីរលក ១ ភ័យអំពីក្រពើ ១ ភ័យអំពីអន្លង់ទឹក ១ ភ័យអំពីត្រីសាហាវ ១ នេះភ័យ ៤ ។

[ ២០៨ ] បណ្ដាធម៌ទាំងនោះ ភ័យ ៤ ដទៃទៀត តើដូចម្ដេច ។ ភ័យអំពីសេចក្ដីតិះដៀលខ្លួនឯង ១ ភ័យអំពីសេចក្ដីតិះដៀលរបស់បុគ្គលដទៃ ១ ភ័យអំពីអាជ្ញា ១ ភ័យអំពីទុគ្គតិ ១ នេះភ័យ ៤ ។

[ ២០៩ ] បណ្ដាធម៌ទាំងនោះ ទិដ្ឋិ ៤ តើដូចម្ដេច ។ ទិដ្ឋិតែងកើតឡើងដោយទៀងទាត់មាំមួនថា សុខ និងទុក្ខ គឺខ្លួនឯងធ្វើ ១ ទិដ្ឋិតែងកើតឡើងដោយទៀងទាត់មាំមួនថា សុខ និងទុក្ខ គឺអ្នកដទៃធ្វើ ១ ទិដ្ឋិតែងកើតឡើងដោយទៀងទាត់មាំមួនថា សុខ និងទុក្ខ គឺខ្លួនឯងធ្វើផង អ្នកដទៃធ្វើផង ១ ទិដ្ឋិតែងកើតឡើងដោយទៀងទាត់មាំមួនថា សុខ និងទុក្ខមិនមែនខ្លួនឯងធ្វើ មិន

មែនអ្នកដទៃធ្វើ គឺកើតឡើងដោយអាស្រ័យហេតុ ១ នេះទិដ្ឋិ ៤ ។

ពួកធម៌ ៤ ចប់ ។

[ ២១០ ] បណ្ដាធម៌ទាំងនោះ សំយោជនៈជាចំណែកខាងក្រោម ៥ តើដូចម្ដេច ។ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ កាមច្ឆន្ទៈ ១ ព្យាបាទ ១ នេះសំយោជនៈ ជាចំណែកខាងក្រោម ៥ ។

[ ២១១ ] បណ្ដាធម៌ទាំងនោះ សំយោជនៈជាចំណែកខាងលើ ៥ តើដូចម្ដេច ។ រូបរាគៈ ១ អរូបរាគៈ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ នេះសំយោជនៈ ជាចំណែកខាងលើ ៥ ។

[ ២១២ ] បណ្ដាធម៌ទាំងនោះ មច្ឆរិយៈ ៥ តើដូចម្ដេច ។ អាវាសមច្ឆរិយៈ ១ កុលមច្ឆរិយៈ ១ លាភមច្ឆរិយៈ ១ វណ្ណមច្ឆរិយៈ ១ ធម្មមច្ឆរិយៈ ១ នេះមច្ឆរិយៈ ៥ ។

[ ២១៣ ] បណ្ដាធម៌ទាំងនោះ កិលេសជាគ្រឿងជំពាក់ ៥ តើដូចម្ដេច ។ កិលេសជាគ្រឿងជំពាក់ គឺរាគៈ ១ កិលេសជាគ្រឿងជំពាក់ គឺទោសៈ ១ កិលេសជាគ្រឿងជំពាក់ គឺមោហៈ ១ កិលេសជាគ្រឿងជំពាក់ គឺមានះ ១ កិលេសជាគ្រឿងជំពាក់ គឺទិដ្ឋិ ១ នេះកិលេសជាគ្រឿងជំពាក់ ៥ ។

[ ២១៤ ] បណ្ដាធម៌ទាំងនោះ សរ ៥ តើដូចម្ដេច ។ សរ គឺរាគៈ ១ សរ គឺទោសៈ ១ សរ គឺមោហៈ ១ សរ គឺមានះ ១ សរ គឺទិដ្ឋិ ១ នេះសរ ៥ ។

[ ២១៥ ] បណ្តាធម៌ទាំងនោះ បង្គោលចិត្ត ៥ តើដូចម្តេច ។ បុគ្គលសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ១ បុគ្គលសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះធម៌ ១ បុគ្គលសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសង្ឃ ១ បុគ្គលសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងសិក្ខា ១ បុគ្គលក្រោធ អាក់អន់ចិត្ត មានចិត្តបង់គំនុំ មានចិត្តរឹងត្អឹង ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ១ នេះបង្គោលចិត្ត ៥ ។

[ ២១៦ ] បណ្តាធម៌ទាំងនោះ ចំណងរបស់ចិត្ត ៥ តើដូចម្តេច ។ បុគ្គលមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រវល់ក្រវាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាម ១ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រវល់ក្រវាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាយ ១ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រវល់ក្រវាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងរូប ១ បរិភោគត្រាតែឆ្អែតពេញពោះ ហើយប្រកបរឿយៗ នូវសេចក្តីសុខក្នុងទីដេក នូវសេចក្តីសុខ ( ក្នុងការដេកប្រែប្រួល ) ទៅខាងស្តាំ ខាងឆ្វេង នូវសេចក្តីសុខក្នុងការដេកលក់

សីប់ ១ ប្រព្រឹត្តព្រហ្មចរិយៈ ព្រោះប្រាថ្នានូវពួកទេវតាណាមួយថា អាត្មាអញនឹងបានជាទេវតា ( មានសក្តិធំ ) ឬទេវតា ( មានសក្តិតូច ) ណាមួយដោយសីលនេះក្តី ដោយវត្តនេះក្តី ដោយតបៈនេះក្តី ដោយព្រហ្មចរិយៈនេះក្តី នេះចំណងរបស់ចិត្ត ៥ ។

[ ២១៧ ] បណ្តាធម៌ទាំងនោះ នីវរណៈ ៥ តើដូចម្តេច ។ កាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ នេះនីវរណៈ ៥ ។

[ ២១៨ ] បណ្តាធម៌ទាំងនោះ អនន្តរិយកម្ម ៥ តើដូចម្តេច ។ បុគ្គលផ្តាច់បង់មាតាចាកជីវិត ១ ផ្តាច់បង់បិតាចាកជីវិត ១ ផ្តាច់បង់ព្រះអរហន្តចាកជីវិត ១ បុគ្គលមានចិត្តប្រទូស្ត ញុំាងព្រះលោហិតរបស់ព្រះតថាគតឲ្យកើតឡើង ១ បំបែកសង្ឃ ១ នេះអនន្តរិយកម្ម ៥ ។

[ ២១៩ ] បណ្តាធម៌ទាំងនោះ ទិដ្ឋិ ៥ តើដូចម្តេច ។ បុគ្គល ១ ពួក ប្រកាសយ៉ាងនេះថា ខ្លួនមានសញ្ញា មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ១ បុគ្គល ១ ពួក ប្រកាសយ៉ាងនេះថា ខ្លួនមិនមានសញ្ញា មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ១ បុគ្គល ១ ពួក ប្រកាសយ៉ាងនេះថា ខ្លួនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ១ បុគ្គល ១ ពួក បញ្ញត្តិនូវសេចក្តីដាច់សូន្យ សេចក្តីវិនាស សេចក្តីមិនចម្រើនរបស់សត្វដែលកើតមាន ១ បុគ្គល ១ ពួក ប្រកាសនូវព្រះនិព្វានក្នុងបច្ចុប្បន្ន ១ នេះទិដ្ឋិ ៥ ។

[ ២២០ ] បណ្ដាធម៌ទាំងនោះ ពៀរ ៥ តើដូចម្ដេច ។ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ នេះពៀរ ៥ ។

[ ២២១ ] បណ្ដាធម៌ទាំងនោះ សេចក្ដីវិនាស ៥ តើដូចម្ដេច ។ សេចក្ដីវិនាសញាតិ ១ សេចក្ដីវិនាសភោគៈ ១ សេចក្ដីវិនាស គឺរោគ ១ សេចក្ដីវិនាសសីល ១ សេចក្ដីវិនាស គឺទិដ្ឋិ ១ នេះសេចក្ដីវិនាស ៥ ។

[ ២២២ ] បណ្ដាធម៌ទាំងនោះ ទោសនៃសេចក្ដីមិនអត់ធន់ ៥ តើដូចម្ដេច ។ បុគ្គលអ្នកមិនអត់ធន់ រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តនៃជនច្រើនគ្នា ១ ច្រើនដោយពៀរ ១ ច្រើនដោយទោស ១ វង្វេងធ្វើមរណកាល ១ បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ រមែងចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក ១ នេះទោសនៃការមិនអត់ធន់ ៥ ។

[ ២២៣ ] បណ្ដាធម៌ទាំងនោះ ភ័យ ៥ តើដូចម្ដេច ។ ភ័យអំពីការចិញ្ចឹមជីវិត ១ ភ័យអំពីគេមិនសរសើរ ១ ភ័យអំពីសេចក្ដីកោតញញើតក្នុងបរិស័ទ ១ ភ័យអំពីសេចក្ដីស្លាប់ ១ ភ័យអំពីទុគ្គតិ ១ នេះភ័យ ៥ ។

[ ២២៤ ] បណ្ដាធម៌ទាំងនោះ ការពោលនូវព្រះនិព្វានក្នុងបច្ចុប្បន្ន ៥ តើដូចម្ដេច ។ បុគ្គលពួក ១ ក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន កាលណាបើខ្លួននេះឆ្អែតស្កប់ស្កល់ ឲ្យគេបម្រើដោយកាមគុណ ៥ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង ទើបខ្លួននេះ ឈ្មោះថា អត្តភាពដល់នូវព្រះ

និព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង សមណៈ ឬព្រាហ្មណ៍ពួក ១ បញ្ញត្តិនូវព្រះនិព្វានក្នុងបច្ចុប្បន្នថា ជាគុណយ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននោះមិនមានទេ នែអ្នកចម្រើន តែថា ខ្លួននេះមិនមែនដល់នូវដល់ព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះទេ ពាក្យដែលខ្ញុំថាដូច្នោះ តើព្រោះហេតុអ្វី ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុថា កាមទាំងឡាយ មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា មានសេចក្តីសោកខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើង ព្រោះកាមទាំងឡាយនោះ ប្រែប្រួលទៅប្រព្រឹត្តទៅដោយប្រការដទៃ ម្នាលអ្នកដ៏ចម្រើន ខ្លួននេះឯង កាលណាបានស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះ ឈ្មោះថា បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ជាគុណយ៉ាងក្រៃលែង សមណៈ ឬព្រាហ្មណ៍ពួក ១ បញ្ញត្តនូវព្រះនិព្វាន ជាគុណយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថា ខ្លួននេះមិនមែនដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះ

ទេ ពាក្យដែលខ្ញុំថាដូច្នោះ តើព្រោះហេតុអ្វី ព្រោះហេតុថា ចិត្តដែលប្រកប ដោយវិតក្ក និងវិចារ មាននៅក្នុងបឋមជ្ឈានទោះ បឋមជ្ឈាននុ៎ះ នៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមានវិតក្ក និងវិចារនុ៎ះនៅឡើយ ម្នាលអ្នកដ៏ ចម្រើន កាលបើខ្លួននេះ បានរម្ងាប់វិតក្ក និងវិចារអស់ហើយ ។បេ។ បាន ដល់ទុតិយជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើប ខ្លួននេះ ឈ្មោះថា បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាង ក្រៃលែង សមណៈ ឬព្រាហ្មណ៍ពួក ១ បញ្ញត្តនូវព្រះនិព្វានក្នុងបច្ចុប្បន្នថា ជាគុណជាតយ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ខ្ញុំមិននិយាយថា ខ្លួននុ៎ះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថា ខ្លួននេះ មិនមែនបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណេះទេ ពាក្យ ដែលខ្ញុំថាយ៉ាងនោះ តើព្រោះហេតុអ្វី ព្រោះហេតុថា បីតិជាទីកើតឡើងនៃ ចិត្ត មានក្នុងទុតិយជ្ឈានទោះនៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមាន បីតិនោះនៅឡើយ ម្នាលអ្នកដ៏ចម្រើន កាលណាបើខ្លួននេះ ព្រោះអស់ទៅ នៃបីតិ ។បេ។ ក៏បានដល់នូវតតិយជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមាន ប្រមាណប៉ុណ្ណេះ ទើបខ្លួននេះ ឈ្មោះថា បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង សមណៈ ឬព្រាហ្មណ៍ពួក ១ បញ្ញត្តនូវ ព្រះនិព្វានក្នុងបច្ចុប្បន្នថា ជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាន

នៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថា ខ្លួននេះ មិនមែនបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណេះទេ ពាក្យដែលខ្ញុំនិយាយនោះ តើព្រោះហេតុអ្វី ព្រោះហេតុថា សេចក្តីអើពើ ឬសេចក្តីក្ដួចកាន់នៃចិត្តថា សុខរមែងមានក្នុងតតិយជ្ឈាននោះ ឯតតិយជ្ឈាននុ៎ះ នៅប្រាកដជាឈានគ្រោតគ្រាត ព្រោះមានសុខនៅឡើយ ម្នាលអ្នកដ៏ចម្រើន កាលណាបើខ្លួននេះបានលះបង់នូវសុខផង ។បេ។ ហើយបានដល់នូវចតុត្ថជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះឯង ទើបខ្លួន ឈ្មោះថា បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង សមណៈ ឬព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថា ជាគុណជាតយ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ នេះទិដ្ឋធម្មនិព្វានវាទ ៥ ។

## ពួកធម៌ ៥ ចប់ ។

[ ២២៥ ] បណ្ដាធម៌ទាំងនោះ មូលនៃវិវាទ ៦ តើដូចម្ដេច ។ សេចក្តីក្រោធ ១ សេចក្តីលុបគុណ ១ សេចក្តីច្រណែន ១ សេចក្តីអួតអាង ១ សេចក្តីប្រាថ្នាដ៏លាមក ១ ការស្ទាបអង្អែលទិដ្ឋិរបស់ខ្លួន ១ នេះមូលនៃវិវាទ ៦ ។

[ ២២៦ ] បណ្តាធម៌ទាំងនោះ ឆន្ទរាគៈ ៦ ជាធម៌អាស្រ័យនូវផ្ទះ គឺកាមគុណ តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ក្នុងរូបទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។ ក្នុងសំឡេងទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។ ក្នុងក្លិនទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។ ក្នុងរសទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។ ក្នុងផោដ្ឋព្វៈទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ក្នុងធម៌ទាំងឡាយជាទីគាប់ចិត្ត ១ នេះឆន្ទរាគៈ ៦ ជាធម៌អាស្រ័យនូវផ្ទះ គឺកាមគុណ ។

[ ២២៧ ] បណ្តាធម៌ទាំងនោះ វិរោធវត្ថុ ( ហេតុនៃសេចក្តីក្រោធ ) ៦ តើដូចម្តេច ។ គំនុំ ការចងគំនុំតបនៃចិត្ត ។បេ។ សេចក្តីកាច ការខឹង ការអាក់អន់ចិត្តក្នុងរូបទាំងឡាយមិនជាទីគាប់ចិត្ត ១ ក្នុងសំឡេងទាំងឡាយមិនជាទីគាប់ចិត្ត ១ ។បេ។ ក្នុងក្លិនមិនជាទីគាប់ចិត្ត ១ ។បេ។ ក្នុងរសមិនជាទីគាប់ចិត្ត ១ ។បេ។ ក្នុងផ្សព្វទាំងឡាយមិនជាទីគាប់ចិត្ត ១ ។បេ។ គំនុំ ការចងគំនុំនៃចិត្ត ។បេ។ សេចក្តីកាច ការពោលពាក្យអសុរោះ ការអាក់អន់ចិត្តក្នុងធម៌ទាំងឡាយមិនជាទីគាប់ចិត្ត ១ នេះវិរោធវត្ថុ ៦ ។

[ ២២៨ ] បណ្តាធម៌ទាំងនោះ ពួកនៃតណ្ហា ៦ តើដូចម្តេច ។ រូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ នេះពួកនៃតណ្ហា ៦ ។

[ ២២៩ ] បណ្តាធម៌ទាំងនោះ អគារវៈ ( សេចក្តីមិនគោរព ) ៦ តើ

ដូចម្តេច ។ បុគ្គលមិនមានសេចក្តីគោរពកោតក្រែងក្នុងព្រះសាស្តា ១ ក្នុងព្រះធម៌ ១ ។បេ។ ក្នុងព្រះសង្ឃ ១ ។បេ។ ក្នុងសិក្ខា ១ ។បេ។ ក្នុងអប្បមាទ ។បេ។ មិនមានសេចក្តីគោរពកោតក្រែងក្នុងបដិសណ្ឋារៈ ១ នេះអគារវៈ ៦ ។

[ ២៣០ ] បណ្តាធម៌ទាំងនោះ បរិហានិយធម៌ ( ធម៌ដែលនាំឲ្យសាបសូន្យ ) ៦ តើដូចម្តេច ។ សេចក្តីត្រេកអរក្នុងកាម ១ សេចក្តីត្រេកអរក្នុងការនិយាយពាក្យរោយរាយ ១ សេចក្តីត្រេកអរ ក្នុងការដេកលក់ ១ សេចក្តីត្រេកអរ ក្នុងការប្រឡូកប្រឡំដោយពួក ១ សេចក្តីត្រេកអរ ក្នុងការជាប់ជំពាក់ ១ សេចក្តីត្រេកអរ ក្នុងបបញ្ចធម៌ ១ នេះបរិហានិយធម៌ ៦ ។

[ ២៣១ ] បណ្តាធម៌ទាំងនោះ បរិហានិយធម៌ ៦ ដទៃទៀត តើដូចម្តេច ។ សេចក្តីត្រេកអរ ក្នុងការងារ ១ សេចក្តីត្រេកអរ ក្នុងការនិយាយពាក្យរោយរាយ ១ សេចក្តីត្រេកអរ ក្នុងការដេកលក់ ១ សេចក្តីត្រេកអរ ក្នុងការប្រឡូកប្រឡំ ( ដោយពួក ) ១ សេចក្តីប្រដៅក្រ ១ ភាពអ្នកមានមិត្តអាក្រក់ ១ នេះបរិហានិយធម៌ ៦ ។

[ ២៣២ ] បណ្តាធម៌ទាំងនោះ ធម៌ជាទីពិចារណាដោយសោមនស្ស ៦ តើដូចម្តេច ។ បុគ្គលឃើញរូបដោយចក្ខុ ហើយពិចារណានូវរូបជាទីតាំងនៃសោមនស្ស ១ ឮសំឡេងដោយត្រចៀក ១ ។បេ។ ធុំក្លិនដោយច្រមុះ ១ ។បេ។ លិទ្ធភ្លក្សរសដោយអណ្តាត ១ ។បេ។ ប៉ះពាល់ផ្សព្វដោយកាយ ១ ។បេ។ ដឹងនូវធម៌ដោយចិត្ត ហើយពិចារណានូវធម៌ជាទីតាំងនៃសោមនស្ស ១ នេះ

ធម៌ជាទីពិចារណាដោយសោមនស្ស ៦ ។

[ ២៣៣ ] បណ្ដាធម៌ទាំងនោះ ធម៌ជាទីពិចារណាដោយទោមនស្ស ៦ តើដូចម្ដេច ។ បុគ្គលឃើញរូបដោយចក្ខុ ហើយពិចារណានូវរូបជាទីតាំងនៃទោមនស្ស ១ ឮសំឡេងដោយត្រចៀក ១ ។បេ។ ធុំក្លិនដោយច្រមុះ ១ ។បេ។ លិទ្ធភ្លក្សរសដោយអណ្ដាត ១ ។បេ។ ប៉ះពាល់ផ្សព្វដោយកាយ ១ ។បេ។ ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយពិចារណានូវធម៌ជាទីតាំងនៃទោមនស្ស ១ នេះធម៌ជាទីពិចារណាដោយទោមនស្ស ៦ ។

[ ២៣៤ ] បណ្ដាធម៌ទាំងនោះ ធម៌ជាទីពិចារណាដោយឧបេក្ខា ៦ តើដូចម្ដេច ។ បុគ្គលឃើញរូបដោយចក្ខុ ហើយពិចារណានូវរូបជាទីតាំងនៃឧបេក្ខា ១ ឮសំឡេងដោយត្រចៀក ១ ។បេ។ ធុំក្លិនដោយច្រមុះ ១ ។បេ។ លិទ្ធភ្លក្សរសដោយអណ្ដាត ១ ។បេ។ ប៉ះពាល់ផ្សព្វដោយកាយ ១ ។បេ។ ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយពិចារណានូវធម៌ជាទីតាំងនៃឧបេក្ខា ១ នេះធម៌ជាទីពិចារណាដោយឧបេក្ខា ៦ ។

[ ២៣៥ ] បណ្ដាធម៌ទាំងនោះ សោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ តើដូចម្ដេច ។ សេចក្ដីត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ត្រេកអរ ជាសុខកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ត្រេកអរ ជាសុខកើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះ គឺកាមគុណក្នុងរូបទាំងឡាយជាទីគាប់ចិត្ត ១ ក្នុងសំឡេងទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។ ក្នុងក្លិនទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។

ក្នុងរសទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។ ក្នុងផ្សព្វទាំងឡាយជាទីគាប់ចិត្ត ១ ។បេ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខកើតអំពីសម្ផស្សនៃចិត្តដែលអាស្រ័យនូវផ្ទះ គឺកាម-គុណក្នុងធម៌ទាំងឡាយជាទីគាប់ចិត្ត ១ នេះសោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ។

[ ២៣៦ ] បណ្តាធម៌ទាំងនោះ ទោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនឆ្ងាញ់ពិសា ជាទុក្ខកើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ក្នុងរូបទាំងឡាយមិនជាទីគាប់ចិត្ត ១ ក្នុងសំឡេងទាំងឡាយមិនជាទីគាប់ចិត្ត ១ ។បេ។ ក្នុងក្លិនទាំងឡាយមិនជាទីគាប់ចិត្ត ១ ។បេ។ ក្នុងរសទាំងឡាយមិនជាទីគាប់ចិត្ត ១ ។បេ។ ក្នុងផ្សព្វទាំងឡាយមិនជាទីគាប់ចិត្ត ១ ។បេ។ សេចក្តីមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនឆ្ងាញ់ពិសា ជាទុក្ខកើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះ គឺកាមគុណក្នុងធម៌ទាំងឡាយមិនជាទីគាប់ចិត្ត ១ នេះទោមនស្ស ៦ អាស្រ័យនូវផ្ទះ គឺកាមគុណ ។

[ ២៣៧ ] បណ្តាធម៌ទាំងនោះ ឧបេក្ខា ៦ ដែលអាស្រ័យនូវផ្ទះ គឺកាម-

គុណ តើដូចម្តេច ។ សេចក្តីធ្លាញ់ពិសា ក៏មិនមែន សេចក្តីមិនធ្លាញ់ពិសា ក៏មិនមែន ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនមែនទុក្ខ មិនមែនសុខ កើតអំពីសម្ផស្សនៃចិត្ត វេទនាមិនមែនទុក្ខ មិនមែនសុខ កើតអំពីសម្ផស្សនៃចិត្តដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ក្នុងរូបទាំងឡាយ ដែលជាទីតាំងនៃឧបេក្ខា ១ ក្នុងសំឡេងទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១ ។បេ។ ក្នុងក្លិនទាំងឡាយ ដែលជាទីតាំងនៃឧបេក្ខា ១ ។បេ។ ក្នុងរសទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១ ។បេ។ ក្នុងផ្សព្វទាំងឡាយ ដែលជាទីតាំងនៃឧបេក្ខា ១ ។បេ។ សេចក្តីធ្លាញ់ពិសា ក៏មិនមែន សេចក្តីមិនធ្លាញ់ពិសា ក៏មិនមែន ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនមែនទុក្ខ មិនមែនសុខ កើតអំពីសម្ផស្សនៃចិត្ត វេទនាមិនមែនទុក្ខ មិនមែនសុខ កើតអំពីសម្ផស្សនៃចិត្តដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ក្នុងធម៌ទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១ នេះឧបេក្ខា ៦ ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ។

[ ២៣៨ ] បណ្តាធម៌ទាំងនោះ ទិដ្ឋិ ៦ តើដូចម្តេច ។ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើងដោយទៀងទាត់ មាំមួនថា អញមានខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើងដោយទៀងទាត់ មាំមួនថា អញមិនមានខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើងដោយទៀងទាត់ មាំមួនថា អញស្គាល់ច្បាស់នូវខ្លួនដោយខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើងដោយទៀងទាត់ មាំមួនថា អញស្គាល់ច្បាស់នូវសភាពមិនមែនខ្លួនដោយខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើងដោយទៀងទាត់ មាំមួនថា អញស្គាល់

ច្បាស់នូវខ្លួន ដោយសភាពមិនមែនខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើងដោយទៀងទាត់ មាំមួនថា ខ្លួនរបស់អញនេះជាអ្នកពោល អ្នកទទួលផល រមែងទទួលនូវវិបាកនៃធម៌ល្អ និងអាក្រក់ អស់កាលដ៏វែងក្នុងអារម្មណ៍នោះៗ ខ្លួននោះមិនកើតឡើងហើយ ក៏មិនមែន ខ្លួននោះនឹងមិនកើតឡើង ក៏មិនមែន ជាសភាវៈទៀង ស្ថិតស្ថេរ មាំមួន មិនប្រែប្រួលជាធម្មតា ១ នេះទិដ្ឋិ ៦ ។

ពួកធម៌ ៦ ចប់ ។

[ ២៣៩ ] បណ្ដាធម៌ទាំងនេះ អនុសយក្កិលេស ៧ តើដូចម្ដេច ។ កាមរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ នេះអនុស័យ ៧ ។

[ ២៤០ ] បណ្ដាធម៌ទាំងនោះ បរិយុដ្ឋានក្កិលេស ៧ តើដូចម្ដេច ។ កាមរាគបរិយុដ្ឋាន ១ បដិឃបរិយុដ្ឋាន ១ មានបរិយុដ្ឋាន ១ ទិដ្ឋិបរិយុដ្ឋាន ១ វិចិកិច្ឆាបរិយុដ្ឋាន ១ ភវរាគបរិយុដ្ឋាន ១ អវិជ្ជាបរិយុដ្ឋាន ១ នេះបរិយុដ្ឋានក្កិលេស ៧ ។

[ ២៤១ ] បណ្ដាធម៌ទាំងនោះ សញ្ញោជនៈ ៧ តើដូចម្ដេច ។ កាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ នេះសញ្ញោជនៈ ៧ ។

[ ២៤២ ] បណ្ដាធម៌ទាំងនោះ អសទ្ធម្ម ( ធម៌របស់អសប្បុរស ) ៧

តើដូចម្តេច ។ បុគ្គលមិនមានសទ្ធា ១ មិនមានហិរិ ១ មិនមានឱត្តប្បៈ ១ ចេះដឹងតិច ១ មានសេចក្តីខ្ជិល ១ ភ្លេចស្មារតី ១ មិនមានបញ្ញា ១ នេះ អសទ្ធម្ម ៧ ។

[ ២៨៣ ] បណ្តាធម៌ទាំងនោះ ទុច្ចរិត ៧ តើដូចម្តេច ។ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ នេះទុច្ចរិត ៧ ។

[ ២៨៤ ] បណ្តាធម៌ទាំងនោះ មានះ ៧ តើដូចម្តេច ។ មានះ ១ អតិមានះ ១ មានាតិមានះ ១ ឱមានះ ១ អធិមានះ ១ អស្មិមានះ ១ មិច្ឆាមានះ ១ នេះមានះ ៧ ។

[ ២៨៥ ] បណ្តាធម៌ទាំងនោះ ទិដ្ឋិ ៧ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ខ្លួននេះមានរូបកើតអំពីមហាភូតរូប កកើតអំពីមាតាបិតា លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅរមែងមិនមាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះឯង ឈ្មោះថា ដាច់សូន្យប្រាកដ ។ សមណៈ ឬព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមានទុំះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួនទុំះ មិនមានទេ ម្នាល

អ្នកដ៏ចម្រើន តែថា ខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ។ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃទៀត មានរូបជាទិព្វ ជាកាមាវចរទេវតា ( ត្រាច់ទៅក្នុងកព ) មានកវឡិង្ការាហារជាចំណី អ្នកមិនដឹង អ្នកមិនឃើញនូវខ្លួននោះឡើយ ឯខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្ដីស្លាប់ទៅ មិនកើតទៀតទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត សមណៈ ឬព្រាហ្មណ៍ពួក ១ បញ្ញត្តនូវសេចក្ដីដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថា ខ្លួននុ៎ះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ នែអ្នកដ៏ចម្រើន មានខ្លួនដទៃទៀត មានរូបជាទិព្វ សម្រេចដោយឈានចិត្ត មានអវយវៈធំតូចគ្រប់សព្វ មានឥន្ទ្រិយមិនថោកទាប គឺមានឥន្ទ្រិយពេញលេញ អ្នកមិនដឹង មិនឃើញនូវខ្លួននោះឡើយ ឯខ្ញុំ ទើបដឹង ទើបឃើញនូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្ដីស្លាប់ទៅ មិនកើតទៀតទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ

ទើបខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថា ខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃ ដែលចូលទៅកាន់អាកាសានញ្ចាយតនភព មានអារម្មណ៍ថា អាកាសមិនមានទីបំផុត ដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា គឺសេចក្តីសម្គាល់ក្នុងរូប ព្រោះអស់ទៅនៃបដិឃសញ្ញា គឺសេចក្តីសម្គាល់ក្នុងអារម្មណ៍ ដែលជាទីខ្ទាំងខ្ទប់ចិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា គឺសេចក្តីសម្គាល់ក្នុងអារម្មណ៍ផ្សេងៗ ដោយសព្វគ្រប់ អ្នកមិនដឹង មិនឃើញនូវខ្លួននោះឡើយ ខ្ញុំ ទើបដឹង ទើបឃើញនូវខ្លួននុ៎ះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះ ហៅថា ជាសភាវៈដាច់សូន្យដោយពិត សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វ ដែលមាននៅដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិន

និយាយថា ខ្លួនទុំះមិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថា ខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃ ដែលកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈានដោយសព្វគ្រប់ ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនកព មានអារម្មណ៍ថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ អ្នកមិនដឹង មិនឃើញនូវខ្លួននោះឡើយ ខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតឡើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត សមណព្រាហ្មណ៍ពួក ១ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមានទុំះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួនទុំះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថា ខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យ ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃដែលកន្លងបង់នូវវិញ្ញាណញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនកព មានអារម្មណ៍ថា អ្វីតិចតួចក៏មិនមាន ដូច្នេះ អ្នកមិនដឹង មិនឃើញនូវខ្លួននោះឡើយ ឯខ្ញុំ ទើបដឹង ទើបឃើញនូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពី

សេចក្ដីស្លាប់ទៅ មិនកើតទៀតឡើយ ម្នាលអ្នកដ៏ចម្រើន ខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង សមណ-ព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្ដីសូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថា ខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃដែលកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈានដោយសព្វគ្រប់ ហើយចូលទៅកាន់នេវសញ្ញានា-សញ្ញាយតនភព អ្នកមិនដឹង មិនឃើញនូវខ្លួននោះឡើយ ឯខ្ញុំ ទើបដឹង ទើបឃើញនូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្ដីស្លាប់ មិនកើតទៀតឡើយ ម្នាលអ្នកដ៏ចម្រើន ខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង សមណព្រាហ្មណ៍ពួក ១ បញ្ញត្តនូវសេចក្ដីដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ នេះទិដ្ឋិ ៧ ។

## ពួកធម៌ ៧ ចប់ ។

[ ២៨៦ ] បណ្ដាធម៌ទាំងនោះ កិលេសវត្ថុ ៨ តើដូចម្ដេច ។ លោភៈ

១ ទោសៈ ១ មោហៈ ១ មានៈ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ ថីនៈ ១ ឧទ្ធច្ចៈ ១ នេះកិលេសវត្ថុ ៨ ។

[ ២៤៧ ] បណ្ដាធម៌ទាំងនោះ កុសីតវត្ថុ ( ហេតុនៃបុគ្គលខ្ជិល ) ៨ តើដូចម្ដេច ។ ការងារ ( មានវាស់កាត់ចីវរជាដើម ) ភិក្ខុក្នុងសាសនានេះត្រូវធ្វើ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ការងារដែលអញត្រូវធ្វើ មុខជានឹងមាន តែកាលបើអញធ្វើការងារ ( នោះ ) កាយនឹងលំបាក បើដូច្នោះ មានតែអញដេកសិន ភិក្ខុនោះក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះកុសីតវត្ថុទី ១ ។ មួយទៀត ការងារភិក្ខុធ្វើរួចហើយ ភិក្ខុនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា អញបានធ្វើការងាររួចហើយ តែកាលដែលអញកំពុងធ្វើការងារ កាយលំបាកទៅហើយ បើដូច្នោះ មានតែអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះកុសីតវត្ថុទី ២ ។ មួយទៀត ភិក្ខុត្រូវដើរផ្លូវ ភិក្ខុនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងត្រូវដើរផ្លូវ តែបើអាត្មាអញដើរផ្លូវ កាយនឹងលំបាក បើដូច្នោះ មានតែអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវធម៌ ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌

ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះកុសីតវត្ថុទី ៣ ។ មួយទៀត ភិក្ខុដើរផ្លូវរួចហើយ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញបានដើរផ្លូវរួចហើយ តែកាលដែលអាត្មាអញដើរផ្លូវ កាយលំបាកទៅហើយ បើដូច្នោះមានតែអញដេកសិន ភិក្ខុនោះក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះកុសីតវត្ថុទី ៤ ។ មួយទៀត ភិក្ខុត្រាច់ទៅកាន់ស្រុកក្ដី និគមក្ដី ដើម្បីបិណ្ឌបាត តែមិនបានភោជនដ៏សៅហ្មង ឬថ្លៃថ្លាឲ្យបរិបូណ៌ដរាបដល់ឆ្អែតទេ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញ កាលដែលដើរទៅកាន់ស្រុក ឬនិគមក្ដី ដើម្បីបិណ្ឌបាត មិនបានភោជនដ៏សៅហ្មង ឬថ្លៃថ្លា ឲ្យបរិបូណ៌ដរាបដល់ឆ្អែតសោះ កាយរបស់អាត្មាអញនោះ លំបាកទៅហើយ ធ្វើការងារមិនកើតទេ បើដូច្នោះ មានតែអញដេកសិន ភិក្ខុនោះក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះកុសីតវត្ថុទី ៥ ។ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត បានភោជនដ៏សៅហ្មង ឬថ្លៃថ្លា បរិបូណ៌ដរាបដល់ឆ្អែត ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញ កាលដែលដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត បានភោជនដ៏សៅហ្មង ឬថ្លៃថ្លា បរិបូណ៌ដរាបដល់ឆ្អែតដែរហើយ តែកាយរបស់អាត្មាអញនោះធ្ងន់ ធ្វើការងារមិនកើត ទំនង

ដូចជាសណ្តែកដែលត្រូវទឹក បើដូច្នោះ មានតែអាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះកុសីតវត្ថុទី ៦ ។ មួយទៀត ភិក្ខុកើតអាពាធបន្តិចបន្តួច ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកើតអាពាធបន្តិចបន្តួចនេះហើយ អាត្មាអញគួរតែដេក បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះកុសីតវត្ថុទី ៧ ។ មួយទៀត ភិក្ខុជាសះស្បើយអំពីជំងឺហើយ តែទើបនឹងសះស្បើយមិនយូរប៉ុន្មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញសះស្បើយអំពីជំងឺហើយ តែសះស្បើយមិនទាន់យូរប៉ុន្មាន កាយរបស់អាត្មាអញនោះ នៅមិនទាន់មានកម្លាំង ធ្វើការងារមិនទាន់កើត បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនប្រារព្ធព្យាយាមដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះកុសីតវត្ថុទី ៨ ។ នេះកុសីតវត្ថុ ៨ ។

[ ២៤៨ ] បណ្តាធម៌ទាំងនោះ សេចក្តីចង្អៀតចង្អល់ចិត្ត ព្រោះលោកធម៌ ៨ តើដូចម្តេច ។ សេចក្តីត្រេកត្រអាលក្នុងលាភ ( ការបាន ) ១

សេចក្តីថ្នាំងថ្នាក់ក្នុងអលាភ ( ការមិនបាន ) ១ សេចក្តីត្រេកត្រអាលក្នុងយស ១ សេចក្តីថ្នាំងថ្នាក់ក្នុងអយស ( ការមិនមានយស ) ១ សេចក្តីត្រេកត្រអាលក្នុងពាក្យសរសើរ ១ សេចក្តីថ្នាំងថ្នាក់ក្នុងពាក្យតិះដៀល ១ សេចក្តីត្រេកត្រអាលក្នុងសុខ ១ សេចក្តីថ្នាំងថ្នាក់ក្នុងទុក្ខ ១ នេះសេចក្តីចង្អៀតចង្អល់ចិត្ត ព្រោះលោកធម៌ ៨ ។

[ ២៤៩ ] បណ្តាធម៌ទាំងនោះ វោហារមិនប្រសើរ ៨ តើដូចម្តេច ។ ការពោលថា ឃើញក្នុងហេតុដែលមិនបានឃើញ ១ ការពោលថា បានឮក្នុងហេតុដែលមិនបានឮ ១ ការពោលថា បានលិទ្ធភ្លក្សក្នុងហេតុដែលមិនបានលិទ្ធភ្លក្ស ១ ការពោលថា បានដឹងក្នុងហេតុដែលមិនបានដឹង ១ ការពោលថា មិនបានឃើញក្នុងហេតុដែលបានឃើញ ១ ការពោលថា មិនបានឮក្នុងហេតុដែលបានឮ ១ ការពោលថា មិនបានលិទ្ធភ្លក្សក្នុងហេតុដែលបានលិទ្ធភ្លក្ស ១ ការពោលថា មិនបានដឹងក្នុងហេតុដែលបានដឹង ១ នេះវោហារមិនប្រសើរ ៨ ។

[ ២៥០ ] បណ្តាធម៌ទាំងនោះ មិច្ឆត្តធម៌ ( សេចក្តីខុស ) ៨ តើដូចម្តេច ។ ការយល់ខុស ១ ត្រិះរិះខុស ១ វាចាខុស ១ ការងារខុស ១ ការចិញ្ចឹមជីវិតខុស ១ ព្យាយាមខុស ១ ការរឭកខុស ១ ការតម្កល់ចិត្តខុស ១ នេះមិច្ឆត្តធម៌ ៨ ។

[ ២៥១ ] បណ្តាធម៌ទាំងនោះ ទោសរបស់បុរស ៨ តើដូចម្តេច ។ ពួកភិក្ខុក្នុងសាសនានេះ ចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវ

ពួកភិក្ខុចោទដោយអាបត្តិ ក៏ដោះស្រាយដោយអស្សតិ ( ការគ្មានស្មារតី ) ថា ខ្ញុំនឹកមិនឃើញ ខ្ញុំនឹកមិនឃើញ នេះទោសរបស់បុរសទី ១ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏និយាយគេចកែនឹងភិក្ខុអ្នកចោទវិញថា ប្រយោជន៍អ្វី អ្នកជាមនុស្សល្ងង់ មិនឈ្លាស មកស្តីថាឲ្យយើង អម្បាលយ៉ាងអ្នក ហ៊ានសម្គាល់យើងថា គួរនឹងស្តីថាបាន នេះទោសរបស់បុរសទី ២ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏ត្រឡប់លើកពាក្យ របស់អ្នកចោទវិញថា លោកឯងត្រូវអាបត្តិឈ្មោះនេះ ចូរលោកសម្តែងមុនសិនទៅ នេះទោសរបស់បុរសទី ៣ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏បិទបាំងនូវហេតុដទៃ ដោយហេតុដទៃ យកពាក្យខាងក្រៅ មកបញ្ចេញធ្វើនូវសេចក្តីក្រោធខឹង មិនត្រេកអរ ឲ្យប្រាកដឡើង នេះទោសរបស់បុរសទី ៤ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏និយាយច្រវាដៃក្នុងកណ្តាលសង្ឃ នេះទោសរបស់បុរសទី ៥ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏នៅស្ងៀម ធ្វើសង្ឃឲ្យលំបាក នេះទោសរបស់បុរសទី ៦ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏មិនអើពើនឹងសង្ឃ មិនអើពើនឹងភិក្ខុអ្នកចោទ ជាបុគ្គលមានអាបត្តិ ដើរចៀសចេញទៅ

តាមប្រាថ្នា នេះទោសរបស់បុរសទី ៧ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផង គ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏និយាយយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ លោកខ្វល់ខ្វាយនឹងខ្ញុំហួសប្រមាណធ្វើអ្វី ឥឡូវនេះ ខ្ញុំនឹងលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ភិក្ខុនោះលុះលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបហើយ ក៏និយាយយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ ឥឡូវនេះ លោកទាំងឡាយចូរជាអ្នកមានចិត្តត្រេកអរចុះ នេះទោសរបស់បុរសទី ៨ នេះទោសរបស់បុរស ៨ ។

[ ២៥២ ] បណ្តាធម៌ទាំងនោះ អសញ្ញីវាទ ៨ តើដូចម្តេច ។ ខ្លួនមានរូប មិនមានរោគខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយបញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមិនមានរូប មិនមានរោគខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានរូបខ្លះ មិនមានរូបខ្លះ មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែន មិនមានរោគខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានទីបំផុត មិនមានរោគខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមិនមានទីបំផុត មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ

បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ នេះអសញ្ញីវាទ ៨ ។

[ ២៥៣ ] បណ្តាធម៌ទាំងនោះ នេវសញ្ញីនាសញ្ញីវាទ ៨ តើដូចម្តេច ។ ខ្លួនមានរូប មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ១ ខ្លួនមិនមានរូប មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ១ ខ្លួនមានរូបខ្លះ មិនមានរូបខ្លះ មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ១ ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែន មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ១ ខ្លួនមានទីបំផុត មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញា ក៏មិនមែន ១ ខ្លួនមិនមានទីបំផុត មិនមានរោគ ខាងមុខអំពីសេចក្តី

ស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ១ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ១ ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ១ នេះនេវសញ្ញីនាសញ្ញីវាទ ៨ ។

ពួកធម៌ ៨ ចប់ ។

[ ២៥៤ ] បណ្ដាធម៌ទាំងនោះ អាឃាតវត្ថុ ( ហេតុនៃគំនុំ ) ៩ តើដូចម្ដេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនមានប្រយោជន៍ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនមានប្រយោជន៍ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនមានប្រយោជន៍ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនមានប្រយោជន៍ ដល់ជនជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនមានប្រយោជន៍ដល់ជនជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនមានប្រយោជន៍ដល់ជនជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមានប្រយោជន៍ ដល់ជនមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ១ ជនឯណោះ កំពុងប្រព្រឹត្តនូវ

អំពើមានប្រយោជន៍ ដល់ជនមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ១ ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមានប្រយោជន៍ ដល់ជនមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ១ នេះអាឃាតវត្ថុ ៩ ។

[ ២៥៥ ] បណ្ដាធម៌ទាំងនោះ មន្ទិលរបស់បុរស ៩ តើដូចម្ដេច ។ សេចក្ដីក្រោធ ១ សេចក្ដីលុបគុណ ១ សេចក្ដីប្រណែន ១ សេចក្ដីកំណាញ់ ១ ការលាក់ពុតត្បុត ១ សេចក្ដីអួតអាង ១ ការពោលពាក្យមិនពិត ១ សេចក្ដីប្រាថ្នាដ៏លាមក ១ សេចក្ដីយល់ឃើញខុស ១ នេះមន្ទិលរបស់បុរស ៩ ។

[ ២៥៦ ] បណ្ដាធម៌ទាំងនោះ មានះ ៩ យ៉ាង តើដូចម្ដេច ។ សេចក្ដីប្រកាន់របស់បុគ្គលប្រសើរជាងគេថា អញប្រសើរជាងគេ ១ សេចក្ដីប្រកាន់របស់បុគ្គលប្រសើរជាងគេថា អញស្មើនឹងគេ ១ សេចក្ដីប្រកាន់របស់បុគ្គលប្រសើរជាងគេថា អញថោកទាបជាងគេ ១ សេចក្ដីប្រកាន់របស់បុគ្គលស្មើនឹងគេថា អញប្រសើជាងគេ ១ សេចក្ដីប្រកាន់របស់បុគ្គលស្មើនឹងគេថា អញស្មើនឹងគេ ១ សេចក្ដីប្រកាន់របស់បុគ្គលស្មើនឹងគេថា អញថោកទាបជាងគេ ១ សេចក្ដីប្រកាន់របស់បុគ្គលថោកទាបជាងគេថា អញប្រសើរជាងគេ ១ សេចក្ដីប្រកាន់របស់បុគ្គលថោកទាបជាងគេថា អញស្មើនឹងគេ ១ សេចក្ដីប្រកាន់ របស់បុគ្គលថោកទាបជាងគេថា អញថោកទាបជាងគេ ១ នេះមានះ ៩ ។

[ ២៥៧ ] បណ្ដាធម៌ទាំងនោះ ធម៌មានតណ្ហាជាមូល ៩ តើដូចម្ដេច ។

ការស្វែងរក ( កើតមាន ) ព្រោះអាស្រ័យតណ្ហា ១ លាភ ( កើតមាន ) ព្រោះអាស្រ័យការស្វែងរក ១ សេចក្តីត្រិះរិះ ( កើតមាន ) ព្រោះអាស្រ័យលាភ ១ ឆន្ទរាគ ( កើតមាន ) ព្រោះអាស្រ័យសេចក្តីត្រិះរិះ ១ សេចក្តីចូលចិត្តខ្លាំង ( កើតមាន ) ព្រោះអាស្រ័យឆន្ទរាគ ១ សេចក្តីប្រកាន់ ( កើតមាន ) ព្រោះអាស្រ័យសេចក្តីចូលចិត្តខ្លាំង ១ សេចក្តីកំណាញ់ ( កើតមាន ) ព្រោះអាស្រ័យសេចក្តីប្រកាន់ ១ ការរក្សា ( កើតមាន ) ព្រោះអាស្រ័យសេចក្តីកំណាញ់ ១ ការកាន់ដំបង កាន់សស្ត្រាវុធ ឈ្លោះទាស់ទែង ជជែកគ្នាថា ឯងៗ ការពោលពាក្យញុះញង់ ការពោលពាក្យកុហក អកុសលធម៌ដ៏លាមកដ៏ច្រើន ( កើតមាន ) ព្រោះការរក្សាជាហេតុ ១ នេះពួកធម៌មានតណ្ហាជាមូល ៩ ។

[ ២៥៨ ] បណ្តាធម៌ទាំងនោះ សេចក្តីញាប់ញ័រ ៩ តើដូចម្តេច ។ ពាក្យថា មាន នេះជាសេចក្តីញាប់ញ័រ ១ ពាក្យថា អញមាន នេះជាសេចក្តីញាប់ញ័រ ១ ពាក្យថា អញនេះមាន នេះជាសេចក្តីញាប់ញ័រ ១ ពាក្យថា អញនឹងមាន នេះជាសេចក្តីញាប់ញ័រ ១ ពាក្យថា អញនឹងមានរូប នេះជាសេចក្តីញាប់ញ័រ ១ ពាក្យថា អញនឹងមិនមានរូប នេះជាសេចក្តីញាប់ញ័រ ១ ពាក្យថា អញនឹងមានសញ្ញា នេះជាសេចក្តីញាប់ញ័រ ១ ពាក្យថា អញនឹងមិនមានសញ្ញា នេះជាសេចក្តីញាប់ញ័រ ១ ពាក្យថា អញនឹងមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន នេះជាសេចក្តីញាប់ញ័រ ១ នេះសេចក្តីញាប់ញ័រ ៩ ។

[ ២៥៩ ] បណ្ដាធម៌ទាំងនោះ សេចក្ដីសម្គាល់ ៩ សេចក្ដីឃ្លេងឃ្លោង ៩ ដំណើរឃើតឃូរ ៩ សង្ខតធម៌ ( ធម៌ដែលបច្ច័យប្រជុំតាក់តែង ) ៩ តើដូចម្ដេច ។ ពាក្យថា មាន នេះជាសង្ខតធម៌ ១ ពាក្យថា អញមាន នេះជាសង្ខតធម៌ ១ ពាក្យថា អញនេះមាន នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមាន នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមានរូប នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមិនមានរូប នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមានសញ្ញា នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមិនមានសញ្ញា នេះជាសង្ខត-ធម៌ ១ ពាក្យថា អញនឹងមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន នេះជាសង្ខតធម៌ ១ នេះសង្ខតធម៌ ៩ ។

ពួកធម៌ ៩ ចប់ ។

[ ២៦០ ] បណ្ដាធម៌ទាំងនោះ កិលេសវត្ថុ ១០ តើដូចម្ដេច ។ លោភៈ ១ ទោសៈ ១ មោហៈ ១ មានះ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ ថីនៈ ១ ឧទ្ធច្ចៈ ១ អហិរិកៈ ១ អនោត្តប្បៈ ១ នេះកិលេសវត្ថុ ១០ ។

[ ២៦១ ] បណ្ដាធម៌ទាំងនោះ អាឃាតវត្ថុ ១០ យ៉ាង តើដូចម្ដេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនមានប្រយោជន៍ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនមានប្រយោជន៍ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនមានប្រយោជន៍ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនមានប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ពេញចិត្ត របស់

អញ ១ ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនមានប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនមានប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមានប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ១ ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមានប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ១ ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមានប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ១ ឬថា គំនុំកើតឡើងក្នុងទីមិនគួរ ១ នេះអាឃាតវត្ថុ ១០ ។

[ ២៦២ ] បណ្ដាធម៌ទាំងនោះ អកុសលកម្មបថ ១០ តើដូចម្ដេច ។ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ នេះអកុសលកម្មបថ ១០ ។

[ ២៦៣ ] បណ្ដាធម៌ទាំងនោះ សញ្ញោជនៈ ១០ តើដូចម្ដេច ។ កាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ សីលព្វតបរាមាសសញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ ឥស្សាសញ្ញោជនៈ ១ មច្ឆរិយសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ នេះសញ្ញោជនៈ ១០ ។

[ ២៦៤ ] បណ្ដាធម៌ទាំងនោះ មិច្ឆត្តធម៌ ( សេចក្ដីខុស ) ១០ តើ

ដូចម្តេច ។ មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្ប ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តៈ ១ មិច្ឆាអាជីវៈ ១ មិច្ឆាវាយាមៈ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ មិច្ឆាញាណ ១ មិច្ឆាវិមុត្តិ ១ នេះមិច្ឆត្តធម៌ ១០ ។

[ ២៦៥ ] បណ្តាធម៌ទាំងនោះ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ តើដូចម្តេច ។ ទានដែលបុគ្គលឲ្យហើយ មិនមានផល ១ ការបូជាធំមិនមានផល ១ ការបូជាតូចមិនមានផល ១ ផលវិបាកនៃកម្មដែលសត្វធ្វើល្អ និងធ្វើអាក្រក់មិនមាន ១ លោកនេះមិនមាន ១ លោកដទៃមិនមាន ១ មាតាមិនមានគុណ ១ បិតាមិនមានគុណ ១ សត្វជាឱបបាតិកកំណើតមិនមាន ១ សមណព្រាហ្មណ៍ទាំងឡាយក្នុងលោក អ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ ដែលបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯងនូវលោកនេះ និងលោកខាងមុខហើយប្រកាសមិនមាន ១ នេះមិច្ឆាទិដ្ឋិមានវត្ថុ ១០ ។

[ ២៦៦ ] បណ្តាធម៌ទាំងនោះ អន្តគ្គាហិកទិដ្ឋិ ( ទិដ្ឋិដែលប្រកាន់ថាលោកមានទីបំផុត ) មានវត្ថុ ១០ តើដូចម្តេច ។ លោកទៀង ១ លោកមិនទៀង ១ លោកមានទីបំផុត ១ លោកមិនមានទីបំផុត ១ ជីវិតក៏គឺសរីរៈ ១ ជីវិតដទៃសរីរៈដទៃ ១ សត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀត ១ សត្វខាងមុខអំពីសេចក្តីស្លាប់មិនកើតទៀត ១ សត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀតក៏មាន មិនកើតទៀតក៏មាន ១ សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ១ ។ នេះអន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ។

**ពួកធម៌ ១០ ចប់ ។**

[ ២៦៧ ] បណ្តាធម៌ទាំងនោះ តណ្ហាវិចរិត ( ការប្រព្រឹត្តនៃតណ្ហា ) ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្នុង តើដូចម្តេច ។ តណ្ហាវិចរិតថា អញមាន ១ តណ្ហាវិចរិតថា អញមានដោយប្រការនេះ ១ តណ្ហាវិចរិតថា អញមានយ៉ាងនេះ ១ តណ្ហាវិចរិតថា អញមានដោយប្រការដទៃ ១ តណ្ហាវិចរិតថា អញនឹងមាន ១ តណ្ហាវិចរិតថា អញនឹងមានដោយប្រការនេះ ១ តណ្ហា-វិចរិតថា អញនឹងមានយ៉ាងនេះ ១ តណ្ហាវិចរិតថា អញនឹងមានដោយប្រការដទៃ ១ តណ្ហាវិចរិតថា អញទៀង ១ តណ្ហាវិចរិតថា អញសុខស្រួល ១ តណ្ហាវិចរិតថា អញគួរមាន ១ តណ្ហាវិចរិតថា អញគួរមានដោយប្រការនេះ ១ តណ្ហាវិចរិតថា អញគួរមានយ៉ាងនេះ ១ តណ្ហា-វិចរិតថា អញគួរមានដោយប្រការដទៃ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមាន ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមានដោយប្រការនេះ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមានយ៉ាងនេះ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមានដោយប្រការដទៃ ១ ។

[ ២៦៨ ] ចុះតណ្ហាវិចរិតថា អញមាន តើដូចម្តេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទៈថា អញមាន បាននូវមានះថា អញមាន បាននូវទិដ្ឋិថា អញមាន កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរយឺតយូរនេះក៏មានថាអញមានដោយប្រការនេះខ្លះ ថាអញមានយ៉ាងនេះខ្លះ ថាអញមានដោយប្រការដទៃខ្លះ ។

[ ២៦៩ ] ចុះតណ្ហាវិចរិតថា អញមានដោយប្រការនេះ តើដូចម្ដេច ។ ដំណើរនៃតណ្ហាថា អញជាក្សត្រ ឬថាអញជាព្រាហ្មណ៍ ថាអញជាអ្នកជំនួញ ឬថាអញជាអ្នកគ្រួ ថាអញជាគ្រហស្ថ ឬថាអញជាបព្វជិត ថាអញជាទេវតា ឬថាអញជាមនុស្ស ថាអញមានរូប ឬថាអញមិនមានរូប ថាអញមានសញ្ញា ឬថាអញមិនមានសញ្ញា ថាអញមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញមានដោយប្រការនេះ ។

[ ២៧០ ] ចុះតណ្ហាវិចរិតថា អញមានយ៉ាងនេះ តើដូចម្ដេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញក៏ជាក្សត្រយ៉ាងនោះដែរ ឬថាបុគ្គលនោះ ជាព្រាហ្មណ៍យ៉ាងណា អញក៏ជាព្រាហ្មណ៍យ៉ាងនោះដែរ ថាបុគ្គលនោះជាអ្នកជំនួញយ៉ាងណា អញក៏ជាអ្នកជំនួញយ៉ាងនោះដែរ ឬថាបុគ្គលនោះជាអ្នកគ្រួយ៉ាងណា អញក៏ជាអ្នកគ្រួយ៉ាងនោះដែរ ថាបុគ្គលនោះជាគ្រហស្ថយ៉ាងណា អញក៏ជាគ្រហស្ថយ៉ាងនោះដែរ ឬថាបុគ្គលនោះជាបព្វជិតយ៉ាងណា អញក៏ជាបព្វជិតយ៉ាងនោះដែរ ថាបុគ្គលនោះជាទេវតាយ៉ាងណា អញក៏ជាទេវតាយ៉ាងនោះដែរ ឬថាបុគ្គលនោះជាមនុស្សយ៉ាងណា អញក៏ជាមនុស្សយ៉ាងនោះដែរ ថាបុគ្គលនោះមានរូបយ៉ាងណា អញក៏មានរូបយ៉ាងនោះដែរ ឬថាបុគ្គលនោះមិនមានរូបយ៉ាងណា អញក៏មិនមានរូបយ៉ាងនោះដែរ ថាបុគ្គលនោះមានសញ្ញាយ៉ាងណា អញក៏មានសញ្ញាយ៉ាងនោះដែរ ឬថា បុគ្គលនោះមិនមានសញ្ញាយ៉ាងណា អញក៏មិនមានសញ្ញាយ៉ាងនោះដែរ ថាបុគ្គលនោះមានសញ្ញាក៏មិនមែន

មិនមានសញ្ញាក៏មិនមែនយ៉ាងណា អញជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនោះដែរ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញមានយ៉ាងនេះ ។

[ ២៧១ ] ចុះតណ្ហាវិចរិតថា អញមានដោយប្រការដទៃ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញមិនមែនជាក្សត្រ យ៉ាងនោះទេ ឬថា បុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញមិនមែនជាព្រាហ្មណ៍ យ៉ាងនោះទេ ថាបុគ្គលនោះជាអ្នកជំនួញយ៉ាងណា អញមិនមែនជាអ្នកជំនួញយ៉ាងនោះទេ ឬថា បុគ្គលនោះជាអ្នកគ្រួយ៉ាងណា អញមិនមែនជាអ្នកគ្រួយ៉ាងនោះទេ ថាបុគ្គលនោះជាគ្រហស្ថយ៉ាងណា អញមិនមែនជាគ្រហស្ថយ៉ាងនោះទេ ឬថា បុគ្គលនោះជាបព្វជិតយ៉ាងណា អញមិនមែនជាបព្វជិតយ៉ាងនោះទេ ថាបុគ្គលនោះជាទេវតាយ៉ាងណា អញមិនមែនជាទេវតា យ៉ាងនោះទេ ឬថា បុគ្គលនោះជាមនុស្សយ៉ាងណា អញមិនមែនជាមនុស្សយ៉ាងនោះទេ ថាបុគ្គលនោះមានរូបយ៉ាងណា អញមិនមានរូបយ៉ាងនោះទេ ឬថាបុគ្គលនោះមិនមានរូបយ៉ាងណា អញមិនមែនមិនមានរូបយ៉ាងនោះទេ ថាបុគ្គលនោះ មានសញ្ញាយ៉ាងណា អញមិនមានសញ្ញាយ៉ាងនោះទេ ឬថា បុគ្គលនោះ មិនមានសញ្ញាយ៉ាងណា អញមិនមែនមិនមានសញ្ញាយ៉ាងនោះទេ ថាបុគ្គលនោះ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងណា អញមិនមែនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនយ៉ាងនោះទេ យ៉ាងនេះឈ្មោះថា តណ្ហាវិចរិតថា អញ

មានដោយប្រការដទៃ ។

[ ២៧២ ] ចុះតណ្ហាវិចរិតថា អញនឹងមាន តើដូចម្តេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទៈថា អញនឹងមាន បាននូវមានះថា អញនឹងមាន បាននូវទិដ្ឋិថា អញនឹងមាន កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរយឺតយូរនេះក៏មានថា អញនឹងមានដោយប្រការនេះខ្វះ ថាអញនឹងមានយ៉ាងនេះខ្វះ ថាអញនឹងមានដោយប្រការដទៃខ្វះ ។

[ ២៧៣ ] ចុះតណ្ហាវិចរិតថា អញនឹងមានដោយប្រការនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាថា អញនឹងជាក្សត្រ ឬថា អញនឹងជាព្រាហ្មណ៍ ថាអញនឹងជាអ្នកជំនួញ ឬថា អញនឹងជាអ្នកគ្រួ ថាអញនឹងជាគ្រហស្ថ ឬថា អញនឹងជាបព្វជិត ថាអញនឹងជាទេវតា ឬថា អញនឹងជាមនុស្ស ថាអញនឹងជាបុគ្គលមិនមានរូប ឬថា អញនឹងជាបុគ្គលមានរូប ថាអញនឹងជាបុគ្គលមានសញ្ញា ឬថា អញនឹងជាបុគ្គលមិនមានសញ្ញា ថាអញនឹងជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញនឹងមានដោយប្រការនេះ ។

[ ២៧៤ ] ចុះតណ្ហាវិចរិតថា អញនឹងមានយ៉ាងនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញនឹងបានជាក្សត្រយ៉ាងនោះដែរ ឬថា បុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញនឹងបានជាព្រាហ្មណ៍ យ៉ាងនោះដែរ ។បេ។ ថាបុគ្គលនោះ

មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនយ៉ាងណា អញនឹងមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនយ៉ាងនេះដែរ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញនឹងមានយ៉ាងនេះ ។

[ ២៧៥ ] ចុះតណ្ហាវិចរិតថា អញនឹងមាន ដោយប្រការដទៃ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញនឹងមិនមែនជាក្សត្រយ៉ាងនោះទេ ឬថា បុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញនឹងមិនមែនជាព្រាហ្មណ៍យ៉ាងនោះទេ ។បេ។ ថាបុគ្គលនោះមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនយ៉ាងណា អញនឹងមិនមែនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនោះទេ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញនឹងមានដោយប្រការដទៃ ។

[ ២៧៦ ] ចុះតណ្ហាវិចរិតថា អញទៀង តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នាថា អញជាបុគ្គលទៀង មាំមួន ប្រាកដ មិនប្រែប្រួលជាធម្មតា យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិត ថាអញទៀង ។

[ ២៧៧ ] ចុះតណ្ហាវិចរិតថា អញសុខស្រួល តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នាថា អញនឹងដាច់សូន្យ នឹងវិនាស នឹងមិនកើតទៀត យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិត ថាអញសុខស្រួល ។

[ ២៧៨ ] ចុះតណ្ហាវិចរិត ថាអញគួរមាន តើដូចម្តេច ។ បុគ្គលធ្វើ

នូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទៈថា អញគួរមាន បាននូវមានះថា អញគួរមាន បាននូវទិដ្ឋិថា អញគួរមាន កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរឃើតឃូរនេះ ក៏មានថា អញគួរមានដោយប្រការនេះខ្លះ ថាអញគួរមានយ៉ាងនេះខ្លះ ថាអញគួរមានដោយប្រការដទៃខ្លះ ។

[ ២៧៩ ] ចុះតណ្ហាវិចរិតថា អញគួរមានដោយប្រការនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាថា អញគួរតែជាក្សត្រ ឬថាអញគួរតែជាព្រាហ្មណ៍ ថាអញគួរតែជាអ្នកជំនួញ ឬថាអញគួរតែជាអ្នកគ្រូ ថាអញគួរតែជាគ្រហស្ថ ឬថាអញគួរតែជាបព្វជិត ថាអញគួរតែជាទេវតា ឬថាអញគួរតែជាមនុស្ស ថាអញគួរតែជាបុគ្គលមានរូប ឬថាអញគួរតែជាបុគ្គលមិនមានរូប ថាអញគួរតែជាបុគ្គលមានសញ្ញា ឬថាអញគួរតែជាបុគ្គលមិនមានសញ្ញា ថាអញគួរតែជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនេះ ឈ្មោះថាតណ្ហាវិចរិតថា អញគួរមានដោយប្រការនេះ ។

[ ២៨០ ] ចុះតណ្ហាវិចរិតថា អញគួរមានយ៉ាងនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញគួរតែជាក្សត្រយ៉ាងនោះដែរ ឬថា បុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញគួរតែជាព្រាហ្មណ៍យ៉ាងនោះដែរ ។បេ។ ថាបុគ្គលនោះមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងណា អញគួរតែជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនោះដែរ យ៉ាងនេះ

ឈ្មោះថា តណ្ហាវិចរិតថា អញគួរមានយ៉ាងនេះ ។

[ ២៨១ ] ចុះតណ្ហាវិចរិតថា អញគួរមានដោយប្រការដទៃ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះ ជាក្សត្រយ៉ាងណា អញគួរតែមិនមែនជាក្សត្រយ៉ាងនោះទេ ឬថាបុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញគួរតែមិនមែនជាព្រាហ្មណ៍ យ៉ាងនោះទេ ។បេ។ ថាបុគ្គលនោះមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនយ៉ាងណា អញគួរតែមិនមែនជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនោះទេ យ៉ាងនេះឈ្មោះថា តណ្ហាវិចរិតថា អញគួរមានដោយប្រការដទៃ ។

[ ២៨២ ] ចុះតណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមាន តើដូចម្តេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នាហើយបាននូវឆន្ទៈថា អម្បាលយ៉ាងអញគួរមាន បាននូវមានះថា អម្បាលយ៉ាងអញគួរមាន បាននូវទិដ្ឋិថា អម្បាលយ៉ាងអញ គួរមាន កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរយឺតយូរនេះក៏មានថា អម្បាលយ៉ាងអញគួរមានដោយប្រការនេះខ្លះ ថាអម្បាលយ៉ាងអញគួរមានយ៉ាងនេះខ្លះ ថាអម្បាលយ៉ាងអញ គួរមានដោយប្រការដទៃខ្លះ ។

[ ២៨៣ ] ចុះតណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមានដោយប្រការនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាថា អម្បាលយ៉ាងអញ គួរតែជាក្សត្រ ឬថាអម្បាលយ៉ាងអញ គួរតែជាព្រាហ្មណ៍ ថាអម្បាលយ៉ាងអញ គួរតែជាអ្នកជំនួញ ឬថាអម្បាលយ៉ាងអញ គួរតែជាអ្នកគ្រួ ថាអម្បាលយ៉ាងអញ គួរ

តែជាគ្រហស្ថ ឬថាអម្បាលយ៉ាងអញ គួរតែជាបព្វជិត ថាអម្បាលយ៉ាងអញ គួរតែជាទេវតា ឬថាអម្បាលយ៉ាងអញ គួរតែជាមនុស្ស ថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមានរូប ឬថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមិនមានរូប ថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមានសញ្ញា ឬថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមិនមានសញ្ញា ថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញគួរមានដោយប្រការនេះ ។

[ ២៨៤ ] ចុះតណ្ហាវិចរិតថា អញគួរមានយ៉ាងនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អម្បាលយ៉ាងអញ ក៏គួរជាក្សត្រយ៉ាងនោះដែរ ឬថាបុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អម្បាលយ៉ាងអញ ក៏គួរជាព្រាហ្មណ៍ យ៉ាងនោះដែរ ។បេ។ ថាបុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែនយ៉ាងណា អម្បាលយ៉ាងអញ ក៏គួរជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនយ៉ាងនោះដែរ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានយ៉ាងនេះ ។

[ ២៨៥ ] ចុះតណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានដោយប្រការដទៃ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អម្បាលយ៉ាងអញ គួរតែមិនមែនជាក្សត្រយ៉ាងនោះទេ ឬថាបុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អម្បាលយ៉ាងអញគួរ

តែមិនមែនជាព្រាហ្មណ៍យ៉ាងនោះទេ ។បេ។ ថាបុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែនយ៉ាងណា អម្បាលយ៉ាងអញ គួរតែមិនមែនមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនោះទេ យ៉ាងនេះឈ្មោះថា តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានដោយប្រការដទៃ ។ នេះតណ្ហាវិចរិត ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្នុង ។

[ ២៨៦ ] បណ្ដាធម៌ទាំងនោះ តណ្ហាវិចរិត ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្រៅ តើដូចម្ដេច ។ តណ្ហាវិចរិតថា អញមានដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញនឹងមាន ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញនឹងមានដោយប្រការនេះដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញនឹងមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញនឹងមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញទៀង ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញសុខស្រួល ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញគួរមាន ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញគួរមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញគួរមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អញគួរមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមាន ដោយខន្ធ-

បញ្ចក:នេះ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានដោយប្រការនេះ ដោយខន្ធបញ្ចក:នេះ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានយ៉ាងនេះ ដោយខន្ធបញ្ចក:នេះ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានដោយប្រការដទៃ ដោយខន្ធបញ្ចក:នេះ ១ ។

[ ២៨៧ ] ចុះតណ្ហាវិចរិតថា អញមាន ដោយខន្ធបញ្ចក:នេះ តើដូចម្តេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទ:ថា អញមាន ដោយខន្ធបញ្ចក:នេះ បាននូវមាន:ថា អញមាន ដោយខន្ធបញ្ចក:នេះ បាននូវទិដ្ឋិថា អញមាន ដោយខន្ធបញ្ចក:នេះ កាលបើធម៌មានឆន្ទ:ជាដើមនោះមាន ដំណើរយឺតយូរនេះក៏មានថា អញមានដោយប្រការនេះ ដោយខន្ធបញ្ចក:នេះខ្លះ ថាអញមានយ៉ាងនេះ ដោយខន្ធបញ្ចក:នេះខ្លះ ថាអញមានដោយប្រការដទៃ ដោយខន្ធបញ្ចក:នេះខ្លះ ។

[ ២៨៨ ] ចុះតណ្ហាវិចរិតថា អញមានដោយប្រការនេះ ដោយខន្ធបញ្ចក:នេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាថា អញជាក្សត្រដោយហេតុនេះ ឬថាអញជាព្រាហ្មណ៍ដោយហេតុនេះ ថាអញជាអ្នកជំនួញដោយហេតុនេះ ឬថាអញជាអ្នកគ្រួដោយហេតុនេះ ថាអញជាគ្រហស្ថដោយហេតុនេះ ឬថាអញជាបព្វជិតដោយហេតុនេះ ថាអញជាទេវតាដោយហេតុនេះ ឬថា អញជាមនុស្សដោយហេតុនេះ ថាអញមានរូបដោយហេតុនេះ ឬថា អញមិនមានរូបដោយហេតុនេះ ថាអញមានសញ្ញាដោយហេតុនេះ ឬថា អញមិនមានសញ្ញា

ដោយហេតុនេះ ថាអញមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនដោយហេតុនេះ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះ ។

[ ២៨៩ ] ចុះតណ្ហាវិចរិតថា អញមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញក៏ជាក្សត្រយ៉ាងនោះ ដោយហេតុនេះដែរ ឬថាបុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញក៏ជាព្រាហ្មណ៍យ៉ាងនោះ ដោយហេតុនេះដែរ ។បេ។ ថាបុគ្គលនោះ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនយ៉ាងណា អញក៏ជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនយ៉ាងនោះ ដោយហេតុនេះដែរ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ ។

[ ២៩០ ] ចុះតណ្ហាវិចរិតថា អញមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញមិនមែនជាក្សត្រយ៉ាងនោះ ដោយហេតុនេះទេ ឬថា បុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញមិនមែនជាព្រាហ្មណ៍យ៉ាងនោះ ដោយហេតុនេះទេ ។បេ។ ថាបុគ្គលនោះមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងណា អញមិនមែនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនោះ ដោយហេតុនេះទេ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ ។

[ ២៩១ ] ចុះតណ្ហាវិចរិតថា អញនឹងមាន ដោយខន្ធបញ្ចកៈនេះ តើដូចម្ដេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទៈថា អញនឹងមានដោយហេតុនេះ បាននូវមានះថា អញនឹងមានដោយហេតុនេះ បាននូវទិដ្ឋិថា អញនឹងមានដោយហេតុនេះ កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរយឺតយូរនេះក៏មានថា អញនឹងមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះខ្លះ ថាអញនឹងមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះខ្លះ ថាអញនឹងមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះខ្លះ ។

[ ២៩២ ] ចុះតណ្ហាវិចរិតថា អញនឹងមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះ តើដូចម្ដេច ។ ដំណើរនៃតណ្ហាថា អញនឹងបានជាក្សត្រដោយហេតុនេះ ឬថា អញនឹងបានជាព្រាហ្មណ៍ដោយហេតុនេះ ថាអញនឹងបានជាអ្នកជំនួញដោយហេតុនេះ ថាអញនឹងបានជាអ្នកគ្រួដោយហេតុនេះ ថាអញនឹងបានជាគ្រហស្ថដោយហេតុនេះ ឬថាអញនឹងបានជាបព្វជិតដោយហេតុនេះ ថាអញនឹងបានជាទេវតាដោយហេតុនេះ ឬថា អញនឹងបានជាមនុស្សដោយហេតុនេះ ថាអញនឹងជាបុគ្គលមានរូបដោយហេតុនេះ ឬថាអញនឹងជាបុគ្គលមិនមានរូបដោយហេតុនេះ ថាអញនឹងជាបុគ្គលមានសញ្ញាដោយហេតុនេះ ឬថា អញនឹងជាបុគ្គលមិនមានសញ្ញា ដោយហេតុនេះ ថាអញនឹងជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ដោយហេតុនេះ យ៉ាងនេះឈ្មោះថា តណ្ហាវិចរិតថា អញនឹងមានដោយប្រការនេះ ដោយខន្ធបញ្ចកៈ

នេះ ។

[ ២៩៣ ] ចុះតណ្ហាវិចរិតថា អញនឹងមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញនឹងបានជាក្សត្រយ៉ាងនោះដោយហេតុនេះដែរ ឬថា បុគ្គលនោះ ជាព្រាហ្មណ៍យ៉ាងណា អញនឹងបានជាព្រាហ្មណ៍យ៉ាងនោះ ដោយហេតុនេះដែរ ។បេ។ ថាបុគ្គលនោះ មានសញ្ញាក៏មិនមែនមិនមានសញ្ញាក៏មិនមែន យ៉ាងណា អញនឹងបានជាបុគ្គលមានសញ្ញាក៏មិនមែនមិនមានសញ្ញា ក៏មិនមែន យ៉ាងនោះ ដោយហេតុនេះដែរ យ៉ាងនេះឈ្មោះថា តណ្ហាវិចរិតថា អញនឹងមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ ។

[ ២៩៤ ] ចុះតណ្ហាវិចរិតថា អញនឹងមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញនឹងមិនមែនជាក្សត្រយ៉ាងនោះដោយហេតុនេះទេ ឬថា បុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញនឹងមិនមែនជាព្រាហ្មណ៍យ៉ាងនោះ ដោយហេតុនេះទេ ។បេ។ ថាបុគ្គលនោះ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងណា អញនឹងមិនមែនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាងនោះ ដោយហេតុនេះទេ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញនឹងមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ ។

[ ២៩៥ ] ចុះតណ្ហាវិចរិតថា អញទៀង ដោយខន្ធបញ្ចកៈនេះ តើដូច

ម្ដេច ។ ដំណើរនៃតណ្ហា ព្រោះធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឲ្យបែកចេញពីគ្នាថា អញជាបុគ្គលទៀងទាត់ មាំមួន ប្រាកដ មិនប្រែប្រួលជាធម្មតាដោយហេតុនេះ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញជាបុគ្គលទៀង ដោយខន្ធបញ្ចកៈនេះ ។

[ ២៩៦ ] ចុះតណ្ហាវិចរិតថា អញសុខស្រួល ដោយខន្ធបញ្ចកៈនេះ តើដូចម្ដេច ។ ដំណើរនៃតណ្ហា ព្រោះធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឲ្យបែកចេញពីគ្នាថា អញទីងដាច់សូន្យ នឹងវិនាស នឹងមិនកើតទៀត ដោយហេតុនេះ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញសុខស្រួល ដោយខន្ធបញ្ចកៈនេះ ។

[ ២៩៧ ] ចុះតណ្ហាវិចរិតថា អញគួរមាន ដោយខន្ធបញ្ចកៈនេះ តើដូចម្ដេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទៈថា អញគួរមាន ដោយខន្ធបញ្ចកៈនេះ បាននូវមានះថា អញគួរមាន ដោយខន្ធបញ្ចកៈនេះ បាននូវទិដ្ឋិថា អញគួរមាន ដោយខន្ធបញ្ចកៈនេះ កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរយឺតយូរនេះ ក៏កើតមានថា អញគួរមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះខ្លះ ថាអញគួរមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះខ្លះ ថាអញគួរមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះខ្លះ ។

[ ២៩៨ ] ចុះតណ្ហាវិចរិតថា អញគួរមានដោយប្រការនេះ ដោយខន្ធបញ្ចកនេះ តើដូចម្ដេច ។ ដំណើរនៃតណ្ហាថា អញគួរជាក្សត្រដោយហេតុ

នេះ ឬថា អញគួរជាព្រាហ្មណ៍ដោយហេតុនេះ ថាអញគួរជាអ្នកជំនួញដោយហេតុនេះ ឬថា អញគួរជាអ្នកគ្រួដោយហេតុនេះ ថាអញគួរជាគ្រហស្ថដោយហេតុនេះ ឬថា អញគួរជាបព្វជិតដោយហេតុនេះ ថាអញគួរជាទេវតាដោយហេតុនេះ ឬថា អញគួរជាមនុស្សដោយហេតុនេះ ថាអញគួរជាបុគ្គលមានរូបដោយហេតុនេះ ឬថា អញគួរជាបុគ្គលមិនមានរូបដោយហេតុនេះ ថាអញគួរជាបុគ្គលមានសញ្ញា ដោយហេតុនេះ ឬថា អញគួរជាបុគ្គលមិនមានសញ្ញាដោយហេតុនេះ ថាអញគួរជាបុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ដោយហេតុនេះ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញគួរមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះ ។

[ ២៩៩ ] ចុះតណ្ហាវិចរិតថា អញគួរមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អញគួរតែជាក្សត្រយ៉ាងនោះ ដោយហេតុនេះដែរ ឬថា បុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញគួរតែជាព្រាហ្មណ៍យ៉ាងនោះ ដោយហេតុនេះដែរ ។បេ។ ថាបុគ្គលនោះមានសញ្ញាក៏មិនមែន មិនមានសញ្ញា ក៏មិនមែនយ៉ាងណា អញគួរតែជាបុគ្គលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែនយ៉ាងនោះ ដោយហេតុនេះដែរ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញគួរមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ ។

[ ៣០០ ] ចុះតណ្ហាវិចរិតថា អញគួរមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹង

បុគ្គលដទៃថា បុគ្គលនោះ ជាក្សត្រយ៉ាងណា អញគួរតែមិនមែនជាក្សត្រយ៉ាងនោះ ដោយហេតុនេះទេ ឬថា បុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អញគួរតែមិនមែនជាព្រាហ្មណ៍យ៉ាងនោះ ដោយហេតុនេះទេ ។បេ។ ថាបុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងណា អញគួរតែមិនមែនមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនោះ ដោយហេតុនេះទេ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញគួរមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ ។

[ ៣០១ ] ចុះតណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមាន ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទៈថា អម្បាលយ៉ាងអញគួរមានដោយហេតុនេះ បាននូវមានះថា អម្បាលយ៉ាងអញ គួរមានដោយហេតុនេះ បាននូវទិដ្ឋិថា អម្បាលយ៉ាងអញ គួរមានដោយហេតុនេះ កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរយឺតយូរនេះក៏មានថា អម្បាលយ៉ាងអញ គួរមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះខ្លះ ថាអម្បាលយ៉ាងអញ គួរមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះខ្លះ ថាអម្បាលយ៉ាងអញ គួរមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះខ្លះ ។

[ ៣០២ ] ចុះតណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាថា អម្បាលយ៉ាងអញគួរតែជាក្សត្រដោយហេតុនេះ ឬថាអម្បាលយ៉ាងអញ គួរតែជាព្រាហ្មណ៍

ដោយហេតុនេះ ថាអម្បាលយ៉ាងអញ គួរតែជាអ្នកជំនួញដោយហេតុនេះ ឬថា អម្បាលយ៉ាងអញ គួរតែជាអ្នកគ្រួដោយហេតុនេះ ថាអម្បាលយ៉ាងអញ គួរតែជាគ្រហស្ថដោយហេតុនេះ ឬថា អម្បាលយ៉ាងអញ គួរតែជាបព្វជិតដោយហេតុនេះ ថាអម្បាលយ៉ាងអញ គួរតែជាទេវតាដោយហេតុនេះ ឬថា អម្បាលយ៉ាងអញ គួរតែជាមនុស្សដោយហេតុនេះ ថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមានរូប ដោយហេតុនេះ ឬថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមិនមានរូបដោយហេតុនេះ ថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមានសញ្ញាដោយហេតុនេះ ឬថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមិនមានសញ្ញាដោយហេតុនេះ ថាអម្បាលយ៉ាងអញ គួរតែជាបុគ្គលមានសញ្ញា ក៏មិនមែនមិនមានសញ្ញាក៏មិនមែនដោយហេតុនេះ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានដោយប្រការនេះ ដោយខន្ធបញ្ចកៈនេះ ។

[ ៣០៣ ] ចុះតណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រយ៉ាងណា អម្បាលយ៉ាងអញ គួរតែជាក្សត្រយ៉ាងនោះ ដោយហេតុនេះដែរ ឬថាបុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អម្បាលយ៉ាងអញ គួរតែជាព្រាហ្មណ៍យ៉ាងនោះ ដោយហេតុនេះដែរ ។បេ។ ថាបុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងណា អម្បាលយ៉ាងអញ គួរតែជាបុគ្គលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែនយ៉ាងនោះ ដោយហេតុនេះដែរ យ៉ាងនេះឈ្មោះថា តណ្ហាវិចរិតថា

អម្បាលយ៉ាងអញ គួរមានយ៉ាងនេះ ដោយខន្ធបញ្ចកៈនេះ ។

[ ៣០៤ ] ចុះតណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះ ជាក្សត្រយ៉ាងណា អម្បាលយ៉ាងអញ គួរតែមិនមែនជាក្សត្រយ៉ាងនោះ ដោយហេតុនេះទេ ឬថាបុគ្គលនោះជាព្រាហ្មណ៍យ៉ាងណា អម្បាលយ៉ាងអញ គួរតែមិនមែនជាព្រាហ្មណ៍យ៉ាងនោះ ដោយហេតុនេះទេ ។បេ។ ថាបុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងណា អម្បាលយ៉ាងអញ គួរតែមិនមែនមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែនយ៉ាងនោះ ដោយហេតុនេះទេ យ៉ាងនេះឈ្មោះថា តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមានដោយប្រការដទៃ ដោយខន្ធបញ្ចកៈនេះ ។ នេះតណ្ហាវិចរិត ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្រៅ ។

[ ៣០៥ ] តណ្ហាវិចរិត ១៨ នេះ អាស្រ័យនូវខន្ធបញ្ចកៈខាងក្នុង តណ្ហាវិចរិត ១៨ នេះ អាស្រ័យនូវខន្ធបញ្ចកៈខាងក្រៅ ត្រូវជាតណ្ហាវិចរិត ៣៦ ព្រោះប្រមូលរួបរួមតណ្ហាវិចរិតទាំងពីរពួកនោះ ក្នុងទីជាមួយគ្នា ។ តណ្ហាវិចរិត ៣៦ ខាងអតីត តណ្ហាវិចរិត ៣៦ ខាងអនាគត តណ្ហាវិចរិត ៣៦ ខាងបច្ចុប្បន្ន មានសភាពយ៉ាងនេះ ត្រូវជាតណ្ហាវិចរិត ១០៨ ព្រោះប្រមូលរួបរួមតណ្ហាវិចរិតទាំងអស់នោះ ក្នុងទីជាមួយគ្នា ដូចបានរៀបរាប់មកនេះ ។

[ ៣០៦ ] បណ្ដាធម៌ទាំងនោះ ទិដ្ឋិ ៦២ តើដូចម្ដេច ។ ( ទិដ្ឋិ ៦២ ) ដែលព្រះមានព្រះភាគសម្ដែងហើយក្នុងវេយ្យាករណ៍ ឈ្មោះព្រហ្មជាលសូត្រ គឺសស្សតវាទ ៤ ឯកច្ចសស្សតិកវាទ ៤ អន្តានន្តិកវាទ ៤ អមរាវិក្ខេបិកវាទ ៤ អធិច្ចសមុប្បន្និកវាទ ២ សញ្ញិវាទ ១៦ អសញ្ញិវាទ ៨ នេវសញ្ញិនាសញ្ញិវាទ ៨ ឧច្ឆេទវាទ ៧ ទិដ្ឋធម្មនិព្វានវាទ ៥ នេះទិដ្ឋិ ៦២ ដែលព្រះមានព្រះភាគ សម្ដែងហើយក្នុងវេយ្យាករណ៍ ឈ្មោះព្រហ្មជាលសូត្រ ។

## ខុទ្ទកវត្ថុវិភង្គ ចប់

# អដ្ឋកថា

## ខុទ្ទកវត្ថុវិភង្គ

## ឯកកមាតិកាជាដើម

[ ៨៣ ] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់តាំងបឋមមាតិកាទុកក្នុងខុទ្ទក-វត្ថុវិភង្គ ដែលជាលំដាប់នៃញាណវិភង្គនោះហើយ ទ្រង់ធ្វើពាក្យអធិប្បាយដោយលំដាប់នៃបទ ដែលទ្រង់តាំងទុក ។

កំណត់មាតិកាក្នុងខុទ្ទវត្ថុវិភង្គនោះ ដូចតទៅនេះថា ជាបឋម ព្រះមានព្រះភាគ ទ្រង់តាំងធម៌ពួកទី ១ ទុក ៧៣ បទ មានពាក្យថា **ជាតិមទោ** ជាដើម បន្ទាប់អំពីនោះ គប្បីជ្រាបថា ទ្រង់តាំងធម៌ពួក ២ ទុក ១៨ ពួក មានបទថា **កោធោ ច ឧបនាហោ ច** ជាដើម ។ ទ្រង់តាំងធម៌ពួក ៣ ទុក ៣៥ ពួក មានអកុសលមូល ៣ ជាដើម ។ ទ្រង់តាំងធម៌ពួក ៤ ទុក ១៤ ពួក មានអាសវៈ ៤ ជាដើម ។ ទ្រង់តាំងធម៌ពួក ៥ ទុក ១៥ ពួក មានឱរម្ភាគិយសំយោជនៈ ៥ ជាដើម ទ្រង់តាំងធម៌ពួក ៦ ទុក ១៤ ពួក មានវិវាទមូល ៦ ជាដើម ។ ទ្រង់តាំងធម៌ពួក ៧ ទុក ៧ ពួក មានអនុស័យ ៧ ជាដើម ។ ទ្រង់តាំងធម៌ពួក ៨ ទុក ៨ ពួក មានកិលេសវត្ថុ ៨ ជាដើម ទ្រង់តាំងធម៌ពួក ៩ ទុក ៩ ពួក មានអាឃាតវត្ថុ ៩ ជាដើម ។ ទ្រង់តាំងធម៌ពួក ១០ ទុក ៧ ពួក មានកិលេសវត្ថុ ១០ ជាដើម ។ ទ្រង់តាំងតណ្ហាវិចរិត ១៨ ប្រាំមួយពួក មានបទថា **អជ្ឈត្តិកស្ស ឧបាទាយ អដ្ឋារស តណ្ហាវិចរិតានិ** ជាដើម ជាកំណត់បទមាតិកាមុន ។

## ឯកកនិទ្ទេស

[ ៩៤-១៤១ ] ឥឡូវនេះ គប្បីជ្រាបសេចក្តីក្នុងនិទ្ទេសវារនៃមាតិកាតាមដែលទ្រង់តាំងទុក ដែលទ្រង់ផ្តើមដោយន័យថា **តត្ថ កតមោ ជាតិមទោ** ជាដើម ។

បទថា **ជាតឹ បដិច្ច** បានដល់ ព្រោះអាស្រ័យជាតិ ។ ក្នុងឯកកមាតិកានេះ ព្រះមានព្រះភាគត្រាស់ការអាស្រ័យមាន ព្រោះហេតុនោះ គប្បីជ្រាបអត្ថក្នុងមាតិកានេះថា កាលជាតិមាន ដូច្នេះ ។ ក្នុងបទថា **គោត្តំ បដិសច្ច** ជាដើមក៏ន័យនេះឯង ។ ឈ្មោះថា **មទោ** ដោយអំណាចនៃសេចក្តីស្រវឹង ។ អាការនៃសេចក្តីស្រវឹង ឈ្មោះថា **មជ្ជនា** ។ សភាពដែលស្រវឹង ឈ្មោះថា **មជ្ជិតត្តំ** ។ បទថា **មានោ មញ្ញនា** ជាដើម មានអត្ថដូចពោលហើយក្នុងអដ្ឋកថានៃធម្មសង្គហៈនោះឯង ។ បទថា **អយំ វុច្ចតិ** បានដល់ កាលជាតិមាន ការប្រកាន់ខ្លួនដែលដល់អាការនៃកិរិយាស្រវឹង ដែលកើតឡើងព្រោះអាស្រ័យជាតិនោះឯង ហៅថា **ជាតិមទោ** ។ ការប្រកាន់ខ្លួន[1]នេះរមែងកើតឡើងដល់វណ្ណៈទាំង ៤ មានក្សត្រជាដើម ។ ពិតហើយ ក្សត្រជាអ្នកសម្បូរដោយជាតិ រមែងប្រកាន់ខ្លួនថា បុគ្គលដទៃដូចអញ រមែងមិនមានក្សត្រដ៏សេស វៀរអាត្មាអញ កើតឡើងឯក្រោយ ឯអាត្មាអញជាក្សត្របន្តសន្តតិវង្ស ដូច្នេះ ។ ព្រាហ្មណ៍ជាដើមក៏ន័យនេះឯង ។

---

១- បិដកខ្មែរ ជាការមើលងាយ ។

*ក្នុងនិទ្ទេសនៃការស្រវឹងក្នុងគោត្តជាដើម ក៏គប្បីជ្រាបអត្ថដោយន័យនេះដូចគ្នា ព្រោះថា សូម្បីក្សត្រ ក៏ប្រកាន់ខ្លួនថា អញជាក្សត្រកោណ្ឌញ្ញគោត្ត អញជាក្សត្រអាទិច្ចគោត្ត ដូច្នេះ ។ សូម្បីព្រាហ្មណ៍ក៏ប្រកាន់ខ្លួនថា អញជាព្រាហ្មណ៍កស្សបគោត្ត អញជាព្រាហ្មណ៍ភារទ្វាជគោត្ត ដូច្នេះ ។ សូម្បីវេស្សៈ សូម្បីសូទ្រៈ ក៏អាស្រ័យត្រកូល និងគោត្តរបស់ខ្លួន ហើយធ្វើនូវការប្រកាន់ខ្លួន ។ ប្រជុំជន ( ជនដែលមានសិប្បៈ ឬចំណេះដឹងដូចគ្នា ) ១៨ ពួក ក៏ធ្វើនូវការប្រកាន់ខ្លួនថា អញកើតក្នុងប្រជុំជនមួយដែលមិនលាយឡំ ។*

*បណ្តាការស្រវឹងក្នុងការមិនមានរោគជាដើម ការប្រកាន់ខ្លួន ដែលកើតឡើងដោយអំណាចនៃការស្រវឹងថា អញមិនមានរោគ ជនទាំងឡាយដ៏សេសវៀរអាត្មាអញហើយ មានរោគច្រើន ជំងឺតម្កាត់របស់អញត្រឹមតែរយៈពេលខ្វីក៏មិនមាន ឈ្មោះថា* **អារោគ្យមទោ** *។*

*ការប្រកាន់ខ្លួន ដែលកើតឡើងដោយអំណាចនៃសេចក្តីស្រវឹងថា អញនៅក្មេង អត្តភាពសត្វទាំងឡាយដ៏សេស ដូចគ្នានឹងដើមឈើដែលតាំងនៅត្រង់មាត់ជ្រោះ ឯអញតាំងនៅក្នុងបឋមវ័យ ដូច្នេះ ឈ្មោះថា* **យោព្វនមទោ** *។*

*ការប្រកាន់ខ្លួនដែលកើតឡើង ដោយអំណាចការស្រវឹងថា អាត្មាអញជាអ្នករស់នៅយូរ ហើយអញកំពុងរស់នៅយូរ អញនឹងរស់នៅយូរ អញជាសុខហើយ អញកំពុងជាសុខ អញនឹងជាសុខ ដូច្នេះ ឈ្មោះថា* **ជីវិតមទោ** *។*

ការប្រកាន់ខ្លួនដែលកើតឡើង ដោយអំណាចសេចក្តីស្រវឹងថា អាត្មាអញមានលាភច្រើន សត្វទាំងឡាយដ៏សេសមានលាភតិច លាភទាំងឡាយរបស់អាត្មាអញ ប្រមាណមិនបាន ដូច្នេះ ឈ្មោះថា **លាភមទោ ។**

ការប្រកាន់ខ្លួនដែលកើតឡើងដោយអំណាចសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស រមែងបានបច្ច័យអន់ៗ ចំណែកអាត្មាអញបានបច្ច័យ មានចីវរជាដើមដែលប្រណីត ដែលគេធ្វើល្អហើយ ដូច្នេះ ឈ្មោះថា **សក្ការ-មទោ ។**

ការប្រកាន់ខ្លួនដែលកើតឡើង ដោយអំណាចសេចក្តីស្រវឹងថា ជនទាំងឡាយដើរជាន់ខ្នងជើងរបស់ភិក្ខុទាំងឡាយដ៏សេសទៅ មិនថ្វាយបង្គំ ដោយគិតថា បុគ្គលនេះជាសមណៈដូច្នេះខ្លះ តែពួកគេទាំងនោះ គ្រាន់តែឃើញអញហើយ រមែងថ្វាយបង្គំ រមែងសម្គាល់អញថា ជាទីគោរព ដូចឆត្រថ្មធំ រមែងសម្គាល់អញថា ជាអ្នកគួរចូលទៅរកបានដោយក្រដូចគំនរភ្លើង ឈ្មោះថា **គរុការមទោ ។**

ការប្រកាន់ខ្លួន ដែលកើតឡើងដោយអំណាចសេចក្តីស្រវឹងថា បញ្ហាដែលកើតឡើងហើយ រមែងកាត់ក្តីបាន ដោយមាត់របស់អញប៉ុណ្ណោះ ភិក្ខុទាំងឡាយ កាលត្រាច់ទៅបិណ្ឌបាត ក៏ធ្វើអញប៉ុណ្ណោះ ឲ្យនៅអំពីខាងមុខហើយដើរចោមរោមទៅ ឈ្មោះថា **បុរេក្ខារមទោ ។**

ការប្រកាន់ខ្លួនដែលកើតឡើងដល់អ្នកគ្រប់គ្រងផ្ទះ ដែលមានបរិវារច្រើនដោយអំណាចសេចក្តីស្រវឹងថា បុរស ១០០ ខ្លះ បុរស ១០០០ ខ្លះ រមែង

ហោមរោមអញ ដូច្នេះ ចំណែកដែលកើតឡើង ដល់អ្នកមិនគ្រប់គ្រងផ្ទះ ដោយអំណាចសេចក្តីស្រវឹងថា សមណៈ ១០០ ខ្លះ សមណៈ ១០០០ ខ្លះ រមែងហោមរោមអញ សមណៈដ៏សេសមានបរិវារតិច អញមានបរិវារច្រើន ផង មានបរិវារល្អផង ឈ្មោះថា **បរិវារមទោ** ។

ភោគសម្បត្តិ លោកកាន់យកដោយ **លាភ** សព្ទ នោះឯងក៏ពិត តែ លោកក៏កាន់យកគំនរនៃទ្រព្យដែលកប់ទុក ព្រោះហេតុនោះ ការប្រកាន់ខ្លួន ដែលកើតឡើងដោយអំណាចនៃការស្រវឹងថា សត្វទាំងឡាយដ៏សេសរមែង មិនបានទ្រព្យត្រឹមតែប្រើប្រាស់ដើម្បីខ្លួន ឯអញមានទ្រព្យកប់ទុករាប់មិនបាន ឡើយ ឈ្មោះថា **ភោគមទោ** ។

បទថា **វណ្ណំ បដិច្ច** បានដល់ អាស្រ័យវណ្ណៈ គឺពណ៌សម្បុរនៃសរីរៈ ខ្លះ វណ្ណៈ គឺគុណខ្លះ មានះកើតឡើងដោយអំណាចនៃការស្រវឹងថា សត្វ ទាំងឡាយដ៏សេស មានពណ៌សម្បុរមិនល្អ មានរូបមិនស្អាត ឯអញមាន រូបស្អាតគួរជ្រះថ្លា សត្វទាំងឡាយដ៏សេស មិនមានគុណ មិនជាទីសរសើរ ឯអញមានកិត្តិសព្ទ ផ្សាយប្រាកដទៅ ក្នុងទេវតា និងមនុស្សទាំងឡាយថា ព្រោះហេតុនេះ ព្រះថេរៈជាពហូសូត ព្រោះហេតុនេះ ព្រះថេរៈជាអ្នកមាន សីល ព្រោះហេតុនេះ ព្រះថេរៈជាអ្នកប្រកបដោយធុតង្គគុណ ព្រោះហេតុ នេះ ដូច្នេះ ឈ្មោះថា **វណ្ណមទោ** ។

មានះដែលកើតឡើងដោយអំណាចសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏ សេស មានការសិក្សាតិច តែអញមានការសិក្សាច្រើន ឈ្មោះថា **សុត-**

**មទោ ។**

*មានះដែលកើតឡើងដោយអំណាចសេចក្ដីស្រវឹងថា សត្វទាំងឡាយដ៏សេស មិនមានបដិភាណ អាត្មាអញ មានបដិភាណរាប់មិនបាន ឈ្មោះថា* **បដិភាណមទោ ។**

*មានះដែលកើតឡើងដោយអំណាចសេចក្ដីស្រវឹងថា អញជាអ្នកដឹងរាត្រីយូរ អញរមែងដឹងវង្សរបស់ព្រះពុទ្ធអង្គនោះ រមែងដឹងវង្សនៃព្រះរាជាអង្គនោះ រមែងដឹងវង្សនៃជនបទនោះ រមែងដឹងវង្សនៃស្រុកនោះ រមែងដឹងនូវការកំណត់ទាំងពេលយប់ និងពេលថ្ងៃ រមែងដឹងនូវការប្រកបឫក និងយាម ឈ្មោះថា* **រត្តញ្ញូមទោ ។**

*មានះដែលកើតឡើង ដោយអំណាចសេចក្ដីស្រវឹងថា ភិក្ខុទាំងឡាយកាន់យកបិណ្ឌបាតជាវត្តខាងក្រោយ តែអញសមាទានបិណ្ឌបាត ជាវត្តតាំងអំពីបួស ឈ្មោះថា* **បិណ្ឌបាតិកមទោ ។**

*មានះកើតឡើងដោយអំណាចសេចក្ដីស្រវឹងថា សត្វទាំងឡាយដ៏សេសជាអ្នកត្រូវមើលងាយ អញមិនមានអ្នកណាមើលងាយ ឈ្មោះថា* **អនវញ្ញាតមទោ ។**

*មានះកើតឡើងដោយអំណាចសេចក្ដីស្រវឹងថា ឥរិយាបថរបស់សត្វទាំងឡាយដ៏សេស មិនគួរជ្រះថ្លា ឯឥរិយាបថរបស់អញ គួរជ្រះថ្លា ឈ្មោះថា* **ឥរិយាបថមទោ ។**

*មានះដែលកើតឡើង ដោយអំណាចសេចក្ដីស្រវឹងថា សត្វទាំងឡាយដ៏*

សេស ដូចគ្នានឹងក្អែកបាក់ស្លាប ឯអញមានឫទ្ធិច្រើន មានអានុភាពច្រើន ឬថា អញនឹងធ្វើវត្ថុណាមួយ វត្ថុនោះរមែងសម្រេច ឈ្មោះថា **ឥទ្ធិមទោ** ។

យស លោកកាន់យកដោយ **បរិវារ** សព្ទ នោះឯង តែក្នុងទីនេះ លោកកាន់យកការស្រវឹងក្នុងឧបដ្ឋាក ( មានអ្នកបម្រើច្រើន ) ការស្រវឹងនោះ បណ្ឌិតគប្បីសម្តែងដោយបុគ្គលដែលគ្រប់គ្រងផ្ទះខ្វះ បុគ្គលដែលមិនគ្រប់គ្រងផ្ទះខ្វះ ។ អ្នកគ្រប់គ្រងផ្ទះពួកខ្វះ ជាប្រធានរបស់ប្រជុំជន ១ ក្នុងប្រជុំជន ១៨ ពួក មានះដែលកើតឡើងដល់បុគ្គលនោះ ដោយអំណាចសេចក្តីស្រវឹងថា អញនឹងតែងតាំងបុរសទាំងឡាយដ៏សេស ហើយអញនឹងគ្រប់គ្រងរក្សា ឯអ្នកមិនគ្រប់គ្រងផ្ទះខ្វះ ជាធំក្នុងវត្តណាមួយ ការប្រកាន់ខ្លួនកើតឡើងដល់លោកដោយអំណាចសេចក្តីស្រវឹងថា ភិក្ខុទាំងឡាយដ៏សេសប្រព្រឹត្តទៅក្នុងឱវាទរបស់អញ អញជាប្រធាន ឈ្មោះថា **យសមទោ** ។

មានះដែលកើតឡើងដោយអំណាចសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស ជាអ្នកទ្រុស្តសីល ឯអញជាអ្នកមានសីល ឈ្មោះថា **សីលមទោ** ។

មានះដែលកើតឡើង ដោយអំណាចសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស មិនមានឯកគ្គតាចិត្ត ក្នុងកាលត្រឹមតែការផឹកទឹករបស់មាន់ ឯអញបានឧបចារសមាធិ ឬអប្បនាឈាន ឈ្មោះថា **ឈានមទោ** ។

មានះដែលកើតឡើងដោយអំណាចសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស មិនមានសិប្បៈ តែអញមានសិប្បៈ ឈ្មោះថា **សិប្បមទោ** ។

មានះដែលកើតឡើង ដោយអំណាចសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏

សេស មានទ្រង់ទ្រាយទាប តែអញ មានទ្រង់ទ្រាយខ្ពស់ ឈ្មោះថា **អារោហមទោ** ។

មានះដែលកើតឡើង ដោយអំណាចសេចក្តីស្រវឹងថា សត្វទាំងឡាយដ៏សេស មានទ្រង់ទ្រាយទាបពេក ខ្ពស់ពេក តែអញមានទ្រង់ទ្រាយសមរម្យ ល្មម ដូចដើមជ្រៃ ឈ្មោះថា **បរិណាហមទោ** ។

មានះដែលកើតឡើងដោយអំណាចសេចក្តីស្រវឹងថា ទ្រង់ទ្រាយនៃសត្វទាំងឡាយដ៏សេស មានរូបរាងប្លែក មិនគួរសរសើរ តែអញមានរូបរាងគួរត្រេកអរ គួរជ្រះថ្លា ឈ្មោះថា **សណ្ឋានមទោ** ។

មានះដែលកើតឡើង ដោយអំណាចសេចក្តីស្រវឹងថា រាងកាយនៃសត្វទាំងឡាយដ៏សេស មានទោសច្រើន តែរាងកាយរបស់អញ មិនមានទោសសូម្បីប៉ុនចុងសក់ ឈ្មោះថា **ចារិបូរិមទោ**[1] ។

ព្រះមានព្រះភាគ កាលត្រាស់នូវមានះ គឺការប្រកាន់ខ្លួន ដែលប្រព្រឹត្តទៅដោយវត្ថុដោយឋានៈនេះ មានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមានះ ដែលមិនមានវត្ថុដែលកើតឡើងនោះឯង ទើបត្រាស់បទថា **តត្ថ កតមោ មទោ** ជាដើម ពាក្យនោះ មានអត្ថងាយយល់ហើយ ។

[ ៩៧ ] ក្នុងនិទ្ទេសនៃសេចក្តីប្រមាទ បទថា **ចិត្តស្ស វោស្សគ្គោ** បានដល់ ការលែងចិត្ត ព្រោះការមិនសង្កត់ដោយសតិ ក្នុងឋានៈទាំងឡាយ

---

១- ចាប់ពីពាក្យថា ជាតិមទោ រហូតដល់ពាក្យថា បារិបូរិមទោ មាននៅក្នុងមាតិកា ត្រង់លេខឃ្នាប ៨៣ ឯណោះ ។

នេះមានប្រមាណប៉ុណ្ណេះ អធិប្បាយថា វៀរចាកសតិ ។ បទថា **វោស្សគ្គា-នុប្បទានំ** បានដល់ ការធ្វើឲ្យច្រើនដោយការបណ្ដោយចិត្តទៅ គឺបណ្ដោយចិត្តទៅរឿយៗ ។ បទថា **អសក្កច្ចកិរិយតា** បានដល់ ការធ្វើដោយមិនគោរព ដោយអំណាចនៃការធ្វើដោយមិនគោរពដល់បុគ្គល ឬគោរពក្នុងទេយ្យធម៌ ក្នុងការបម្រើនកុសលធម៌ទាំងឡាយ មានការឲ្យទានជាដើមទាំងនោះ ។ ការប្រព្រឹត្តទៅជាប់តគ្នា ឈ្មោះថា **សាតច្ច** ។ ការមិនប្រព្រឹត្តទៅជាប់តគ្នា ឈ្មោះថា **អសាតច្ច** ។ អាការដែលធ្វើដោយមិនជាប់តគ្នា ឈ្មោះថា **អសាតច្ចកិរិយតា** ។ មិនមែនការធ្វើដោយមិនឈប់ ឈ្មោះថា **អនដ្ឋិតកិរិយតា** ។ ក្នុងសេចក្ដីនេះ ប្រៀបដូចសត្វបង្កួយ រត់ទៅបន្តិចហើយឈប់បន្តិច រមែងមិនរត់ជាប់តគ្នា យ៉ាងណា សេចក្ដីនេះក៏យ៉ាងនោះឯង បុគ្គលណាឲ្យទានក្ដី ធ្វើការបូជាក្ដី ស្ដាប់ធម៌ក្ដី ធ្វើសមណធម៌មួយថ្ងៃក្ដី លុះយូរទើបធ្វើទៀត រមែងមិនធ្វើជាប់ត ព្រះមានព្រះភាគត្រាស់ហៅការធ្វើរបស់បុគ្គលនោះថា ការមិនមាំទាំ ។ បទថា **ឱលីនវុត្តិតា** បានដល់ ការប្រព្រឹត្តធូរថយ ព្រោះមិនមានការប្រព្រឹត្តពង្រីកចេញទៅ ពោល គឺការធ្វើមិនប្រកបរឿយៗ នោះឯង ។ បទថា **និក្ខិត្តច្ឆន្ទតា** បានដល់ ឆន្ទៈក្នុងការប្រកបសេចក្ដីព្យាយាម ក្នុងការធ្វើកុសលជាសភាវៈ ដែលបុគ្គលនោះបោះបង់ហើយ ។ បទថា **និក្ខិត្តធុរតា** បានដល់ ការដាក់ធុរៈ គឺសេចក្ដីព្យាយាម អធិប្បាយថា មានឆន្ទៈក្នុងចិត្តបោះបង់ហើយ ។ បទថា **អនធិដ្ឋានំ** បានដល់ មិនមានការតាំងចិត្តមាំក្នុងការធ្វើកុសល ។

បទថា **អននុយោគោ** បានដល់ ការមិនប្រកបនូវសេចក្ដីព្យាយាមរឿយៗ ។ ការមិនមានសតិ ឈ្មោះថា **បមាទោ** ។ បទថា **យោ ឯវរូបោ បមាទោ** នេះ ជាការសម្ដែងអាការ ដោយការមិនមានព្រំដែននៃបរិយាយដោយអត្ថ និងបរិយាយដោយព្យញ្ជនៈ ។ មានពាក្យអធិប្បាយថា ការប្រមាទនេះដែលសម្ដែងហើយអំពីដើម ការប្រមាទឯណាសូម្បីដទៃ ក៏មានអាការយ៉ាងនេះ មានជាតិយ៉ាងនេះ ដល់នូវការរាប់ថា កិរិយាដែលប្រមាទ ដល់នូវការរាប់ថា សភាពដែលប្រមាទដោយអំណាចនៃភាវៈដែលប្រមាទហើយនេះហៅថា អាការធ្វេសប្រហែស តែបើពោលដោយលក្ខណៈ សេចក្ដីប្រមាទនេះ មានការបណ្ដោយសតិទៅក្នុងកាមគុណ ៥ ជាលក្ខណៈ បណ្ឌិតគប្បីជ្រាបសេចក្ដីប្រមាទថា ជាការបោះបង់សតិនោះឯង ។

[ ៩៨ ] ក្នុងនិទ្ទេសនៃសេចក្ដីចចេស ឈ្មោះថា **ថម្ភោ** ព្រោះអត្ថថា រឹងរូស ការរឹងរបស់ចិត្ត ហាក់បីដូចសំពត់មានសាច់រឹង ដោយបាយម៉ានព្រះមានព្រះភាគ ត្រាស់ទុកក្នុងទីនេះ ។ អាការនៃភាពចចេស ឈ្មោះថា **ថម្ភនា** ។ ភាវៈដែលចចេសហើយ ឈ្មោះថា **ថម្ភិតត្តំ** ។ ភាពនៃបុគ្គលអាក្រក់ ឈ្មោះថា **ធារុសិយំ** ។ ភាវៈដែលចិត្តរឹងកំព្រឹសនោះឯង ដោយអំណាចនៃការមិនធ្វើសេចក្ដីឱនលំទោននោះ ដល់បុគ្គលដែលគួរឱនលំទោនមានធ្វើការអភិវាទជាដើម ឈ្មោះថា **ឧជុចិត្តតា** ។ ភាពនៃចិត្តរឹងត្អឹង មិនជាធម្មជាតទន់ភ្លន់ ឈ្មោះថា **អមុទុតា** ។ បទថា **អយំ វុច្ចតិ** នេះ ព្រះមានព្រះភាគត្រាស់ហៅថា **ថម្ភោ** ដែលជាហេតុឲ្យបុគ្គលប្រកបហើយ ដូច

គ្មានទឹងពស់ថ្លាន់លេបយាមទន្ល័ល[១] ដូចគ្មានទឹងជង់ដែលពេញដោយខ្យល់ កាលឃើញព្រះចេតិយ ឬបុគ្គលដែលចាស់ជាង ក៏មិនអាចឱន រមែងដើរត្រង់ទៅ សេចក្តីចចេសនោះ បណ្ឌិតគប្បីជ្រាបថា មានការប៉ោងឡើងនៃចិត្តជាលក្ខណៈ ។

[ ៩៩ ] ក្នុងនិទ្ទេសនៃការប្រណាំងវាសនា ឈ្មោះថា **សារម្ភោ** ដោយអំណាចការតម្កើងខ្លួន ។ ការប្រណាំងប្រជែងតប ដែលផ្សាយចេញទៅ ឈ្មោះថា **បដិសារម្ភោ** ។ អាការនៃការប្រណាំងប្រជែង ឈ្មោះថា **សារម្ភនា** ។ កិរិយាដែលប្រណាំងប្រជែងតប ឈ្មោះថា **បដិសារម្ភនា** ។ ភាវៈនៃសេចក្តីប្រណាំងប្រជែងតប ឈ្មោះថា **បដិសារម្ភិតត្តំ** ។ បទថា **អយំ វុច្ចតិ** នេះ ព្រះមានព្រះភាគត្រាស់ហៅថា សេចក្តីប្រណាំងវាសនា ។ ពោលដោយលក្ខណៈ ការប្រណាំងវាសនាដែលព្រះមានព្រះភាគត្រាស់ថា មានការធ្វើឲ្យក្រៃលែងជាងជាលក្ខណៈ ជាហេតុឲ្យបុគ្គលប្រកបហើយធ្វើវត្ថុនោះៗ ឲ្យជាទ្វេគុណ ។ ដូចជាបុគ្គលគ្រប់គ្រងផ្ទះ កាលបុគ្គលរៀបចំវត្ថុខាងក្នុងផ្ទះត្រឹមតែមួយយ៉ាង បុគ្គលដែលប្រណាំងវាសនាដទៃ រមែងរៀបចំវត្ថុ ២ យ៉ាង បុគ្គលប្រណាំងវាសនាដទៃទៀត រមែងរៀបចំវត្ថុ ៤ យ៉ាង បុគ្គលប្រណាំងវាសនាដទៃទៀត រមែងរៀបចំវត្ថុ ៨ យ៉ាង បុគ្គលដែលប្រណាំងវាសនាដទៃទៀត រមែងរៀបចំវត្ថុ ១៦ យ៉ាង ។

បុគ្គលមិនគ្រប់គ្រងផ្ទះ ដែលបុគ្គលមួយរូប រៀនពុទ្ធវចនៈ ១ និកាយ

---

១- ពស់ថ្លាន់ដែលលេបយាមទន្ល័ល រមែងមានខ្លួនរឹង បទបែនមិនបាន ។

បុគ្គលប្រណាំងវាសនាដទៃគិតថា អញនឹងទៅមុនភិក្ខុនោះ ដូច្នេះ ទើបរៀន ២ និកាយ បុគ្គលប្រណាំងវាសនាដទៃទៀត រមែងរៀន ៣ និកាយ បុគ្គលប្រណាំងវាសនាដទៃទៀត រមែងរៀន ៤ និកាយ ឬ ៥ និកាយ ។ ការរៀនពុទ្ធវចនៈនោះ មិនគួរដោយអំណាចនៃការប្រណាំងវាសនា ។ ព្រោះថា ការប្រណាំងវាសនានោះជាអកុសល ជាផ្លូវឲ្យសត្វទៅកាន់នរក តែបើពោលដោយអំណាចខាងកុសល កាលបុគ្គលប្រគេនសលាកភត្តមួយសម្រាប់ បុគ្គលដទៃគួរប្រគេន ២ សម្រាប់ កាលបុគ្គលប្រគេន ២ សម្រាប់ បុគ្គលដទៃគួរប្រគេន ៤ សម្រាប់ ។ កាលភិក្ខុដទៃរៀនពុទ្ធវចនៈ ១ និកាយ ការដែលភិក្ខុដទៃគិតថា កាលអាត្មាអញ រៀនពុទ្ធវចនៈ ២ និកាយ ហើយស្វាយធ្យាយ ផាសុករមែងមាន ដូច្នេះហើយ តាំងនៅក្នុងចំណែកវិវដ្តៈ រៀនពុទ្ធវចនៈនោះ ឲ្យក្រៃលែងឡើង គួរ ។

[ ១០០ ] ក្នុងនិទ្ទេសនៃសេចក្តីប្រាថ្នាដ៏ក្រៃលែងអត្ថនៃបទថា **ឥតរីតរ** ក្នុងអរិយវង្សសូត្រ មានអត្ថថា របស់អាក្រក់ៗ ដោយប្រការណា របស់ភិក្ខុដែលមិនកាន់យកដោយប្រការនោះ ហើយមិនត្រេកអរដោយមានចីវរជាដើមដែលបានមក ឬថារបស់គ្រហស្ថដែលមិនកាន់យកដោយប្រការនោះ ហើយមិនបានត្រេកអរដោយរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ដែលខ្លួនបាន ។ បទថា **ភិយ្យោកម្យតា** បានដល់ ការប្រាថ្នាឲ្យវិសេសជាភិយ្យោភាព ។ ឈ្មោះថា **ឥច្ឆា** ព្រោះអំណាចនៃសេចក្តីប្រាថ្នា ។ សេចក្តីប្រាថ្នានោះឯង ឈ្មោះថា **ឥច្ឆាគតំ** ឬ **ឥច្ឆាការោ** ។ ភាវៈនៃសេចក្តីប្រាថ្នាដ៏ក្រៃលែង

របស់ខ្លួន ឈ្មោះថា **អតិច្ឆតា** ។ បទថា **រាគោ** ជាដើម មានអត្ថតាមដែលពោលហើយខាងដើមនោះឯង ។ បទថា **អយំ វុច្ចតិ** នេះ ព្រះមានព្រះភាគ ត្រាស់ហៅថា **អតិច្ឆតា** ។ បទថា **អត្រិច្ឆតា** ក៏ជាឈ្មោះរបស់អតិច្ឆតានោះឯង តែបើពោលដោយលក្ខណៈ **អតិច្ឆតា** នេះ បានដល់ការមិនត្រេកអរក្នុងលាភរបស់ខ្លួន និងការប្រាថ្នាក្នុងលាភរបស់អ្នកដទៃសេចក្ដីនេះ មានការចង់បានលើសប្រមាណ ជាលក្ខណៈ ។ ពិតហើយសម្រាប់បុគ្គល ដែលមានសេចក្ដីប្រាថ្នាដ៏ក្រៃលែង សូម្បីវត្ថុដែលប្រណីតដែលខ្លួនបានហើយរមែងប្រាកដហាក់បីដូចរបស់អាក្រក់ សូម្បីវត្ថុមិនប្រណីតដែលបុគ្គលដទៃបានហើយ ប្រាកដហាក់ដូចជារបស់ប្រណីត ។ បបរក្ដី ភត្តក្ដី នំក្ដី ដែលឆ្អិនហើយ ក្នុងភាជន៍តែមួយ ដែលគេដាក់ក្នុងបាត្ររបស់ខ្លួនរមែងប្រាកដហាក់បីដូចជារបស់អាក្រក់ ដែលគេដាក់ក្នុងបាត្ររបស់អ្នកដទៃប្រាកដហាក់បីដូចជារបស់ប្រណីត ។ ម្យ៉ាងទៀត សេចក្ដីប្រាថ្នាដ៏ក្រៃលែងនេះ រមែងមានដល់បព្វជិតទាំងឡាយ រមែងមានដល់គ្រហស្ថទាំងឡាយរមែងមានដល់សត្វតិរច្ឆានទាំងឡាយ ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបរឿងទាំងឡាយនេះជាឧទាហរណ៍ដូចតទៅ

បានឮថា កុដុម្ពិកៈម្នាក់និមន្តភិក្ខុនី ៣០ រូបប្រគេនភត្ត ដែលធ្វើអំពីនំព្រះសង្ឃថេរី ប្ដូរនំក្នុងបាត្រជាមួយភិក្ខុនីទាំងពួង ហើយក្នុងខាងក្រោយបានទំពាធាន់ចំណិតនំដើម ( នំដែលទទួលដំបូង ) ដែលខ្លួនបានហើយនោះ ។

ព្រះបាទពារាណសី ទ្រង់ព្រះតម្រិះថា អញនឹងសោយសាច់ដែលអាំង

ដោយរងើកភ្លើង ដូច្នេះ ទើបទ្រង់នាំព្រះទេវីទៅប្រពាតព្រៃ ទតឃើញកិន្នរីមួយរូប ទ្រង់បោះបង់ព្រះទេវី យាងទៅតាមស្នាមជើងកិន្នរីនោះទៅ ព្រះទេវីក៏យាងទៅកាន់អាស្រមបទ បួសជាតបស្វិនី ធ្វើកសិណបរិកម្មបានសមាបត្តិ ៨ និងអភិញ្ញា ៥ ហើយអង្គុយ ឃើញព្រះរាជាកំពុងយាងមក ទើបហោះទៅក្នុងអាកាស ។ ទេវតាដែលអាស្រ័យនៅត្រង់ដើមឈើ បានពោលគាថា ( ក្នុងខុទ្ទកនិកាយជាតក ) នេះថា

បុគ្គលមានសេចក្តីប្រាថ្នាលើសលុប រមែងសាបសូន្យចាក
ប្រយោជន៍ ព្រោះលោភហួសហេតុផង ព្រោះសេចក្តីស្រវឹង
ក្នុងការចង់បានហួសហេតុផង ដូចយើងសាបសូន្យចាករាជ-
ធីតា ឈ្មោះអសិតាភូ ដូច្នេះ[១] ។

ទេវតាបានធ្វើការចំអកព្រះរាជាថា ព្រះអង្គកាលប្រាថ្នាចន្ទកិន្នរី ទ្រង់បោះបង់ព្រះរាជធីតា ឈ្មោះអសិតាភូ ទើបវិនាសហើយយ៉ាងណា បុគ្គលកាលលោភហួសហេតុ រមែងធ្វើខ្លួនឲ្យវិនាស លំបាកព្រោះសេចក្តីលោភហួសហេតុ ក៏យ៉ាងនោះ ។

ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមកស្សបៈ មានសេដ្ឋីបុត្តម្នាក់ឈ្មោះថា មិត្តវិន្ទុកៈ ជាបុគ្គលមិនមានសទ្ធា មិនជ្រះថ្លា ជាបុគ្គលដែលមាតាអង្វរថា នែកូន ថ្ងៃនេះ ចូររក្សាឧបោសថសីល ចូរស្តាប់ធម៌អស់រាត្រីក្នុងវិហារ ហើយម៉ែនឹងឲ្យទ្រព្យ ១០០០ ដល់ឯង ដូច្នេះ ។ ព្រោះសេចក្តី

---

១- បិដកខ្មែរ គាថានេះ ព្រះរាជាជាអ្នកពោល ។

លោកក្នុងទ្រព្យ ទើបសមាទានអដ្ឋង្គឧបោសថសីល ហើយទៅកាន់វិហារ កំណត់ទីថា ទីនេះមិនមានភ័យ ហើយដេកខាងក្រោមធម្មាសនៈ កាលដេកអស់រាត្រីហើយ ក៏ត្រឡប់ទៅផ្ទះ មាតារបស់គេដាំបបរឲ្យអំពីព្រលឹម ។ មិត្តវិន្ទុកៈនោះ សូមទ្រព្យ ១០០០ ជាមុននោះឯង ទើបបរិភោគបបរជាក្រោយ ។

លំដាប់នោះ មិត្តវិន្ទុកៈ មានបរិវិតក្កថា អញនឹងប្រមូលទ្រព្យ ទើបប្រាថ្នាឡើងសំពៅទៅកាន់សមុទ្ទ ។ គ្រានោះ មាតាបានឃាត់ថា នែកូន ក្នុងត្រកូលរបស់យើងមានទ្រព្យ ៤០ កោដិ ចូរកូនកុំទៅឡើយ ដូច្នេះ បុរសនោះមិនស្តាប់ពាក្យរបស់មាតា ក៏ដើរទៅនោះឯង ទើបមាតាទៅរាំង អំពីខាងមុខ ខណៈនោះឯង មិត្តវិន្ទុកៈមានការខឹងក្រោធ គិតថា មាតានេះ មកឈររាំងមុខអញ ទើបយកជើងធាក់មាតាឲ្យដួល ធ្វើមាតាឲ្យនៅក្នុងចន្លោះ ( ដើរកន្លងមាតា ) ទៅហើយ មាតាក្រោកឡើងពោលថា នែកូន បាកុំគិតយ៉ាងនេះថា កាលអញធ្វើកម្មបែបនេះក្នុងមាតាដូចគ្នានឹងយើង ទៅហើយនឹងមានសេចក្តីសុខក្នុងទីដែលទៅ ។

លុះមិត្តវិន្ទុកៈឡើងសំពៅទៅ ក្នុងថ្ងៃទី ៧ សំពៅក៏កឿង ។ លំដាប់នោះ មនុស្សទាំងឡាយពោលថា បុរសអាក្រក់នឹងមានក្នុងសំពៅនេះដោយពិត ចូរអ្នកទាំងឡាយចាប់ស្លាក ដូច្នេះ ស្លាកដែលពួកជនទាំងនោះចាប់ ក៏ធ្លាក់ដល់មិត្តវិន្ទុកៈនោះឯង អស់វារៈ ៣ ដង ទើបមនុស្សទាំងនោះ ចាប់មិត្តវិន្ទុកៈនោះដាក់លើក្បូន ហើយបណ្តែតទៅក្នុងសមុទ្ទ ក្បូនរបស់មិត្តវិន្ទុកៈ

បានអណ្តែតទៅដល់កោះមួយ មិត្តវិន្ទុកៈសោយសម្បត្តិជាមួយនាងវិមានិក-ប្រេតទាំងឡាយ សូម្បីត្រូវនាងវិមានិកប្រេតទាំងឡាយអង្វរថា សូមលោកកុំទៅទៀតឡើយ ដូច្នេះ កាលឃើញសម្បត្តិ ២ ដង របស់សម្បត្តិនោះ បានឃើញបុរសម្នាក់ មានខុរចក្ក ( វិលពីលើក្បាល ) ដោយលំដាប់ចក្កនោះ ប្រាកដដូចផ្កាឈូក មិត្តវិន្ទុកៈ ក៏ពោលនឹងបុរសនោះថា លោកដ៏ចម្រើន សូមលោកឲ្យផ្កាឈូកដែលលោកប្រដាប់នេះដល់ខ្ញុំ ដូច្នេះ បុរសនោះពោលថា បពិត្រលោកម្ចាស់ នេះមិនមែនផ្កាឈូកទេ នេះជាខុរចក្ក មិត្តវិន្ទុកៈពោលថា សូមលោកកុំបញ្ឆោតខ្ញុំឡើយ ខ្ញុំមិនធ្លាប់ឃើញផ្កាឬ អ្នកលាបស្រឡាបដោយចន្ទក្រហម ទើបមិនត្រូវការឲ្យផ្កាឈូកដែលជាគ្រឿងប្រដាប់នោះដល់ខ្ញុំ ដូច្នេះ បុរសនោះគិតថា ជននេះ ជាអ្នកធ្វើកម្មដូចអញនោះឯង ទើបប្រាថ្នានឹងសោយផលនៃកម្មនោះ ដូច្នេះ លំដាប់នោះ បុរសដែលមានខុរចក្កខែត្រង់ក្បាលនោះ ក៏ពោលថា ណ្ហើយចុះ ខ្ញុំនឹងឲ្យ ដូច្នេះហើយ យកខុរចក្កដាក់លើក្បាលរបស់មិត្តមិន្ទុកៈ ហើយទៅ ។

ព្រះសាស្តាទ្រង់ជ្រាបសេចក្តីនោះហើយ ទើបត្រាស់គាថា ( ក្នុងខុទ្ទក-និកាយជាតក ) នេះថា

អ្នក ( ចេញ ) អំពីវិមានិកប្រេត ៤ បានវិមានិកប្រេត ៨
( ចេញ ) អំពីវិមានិកប្រេត ៨ បានវិមានិកប្រេត ១៦
( ចេញ ) អំពីវិមានិកប្រេត ១៦ បានវិមានិកប្រេត ៣២
( ក៏នៅតែមិនស្កប់ស្កល់ ) ចក្រក៏វិលលើក្បាលនៃបុរស

កាលប្រាថ្នាក្នុងទីនោះៗ ទើបមកដល់កង់ចក្រ កង់ចក្រវែង
វិលលើក្បាលបុគ្គល ដែលមានសេចក្តីប្រាថ្នា គ្របសង្កត់
ដូច្នេះ(១) ។

អមាត្យម្នាក់ មានការប្រាថ្នាច្រើន ឈានកន្លងព្រំដែនរបស់ខ្លួន ចូលទៅកាន់ដែនរបស់អ្នកដទៃ ត្រូវគេវាយក្នុងទីនោះ ក៏រត់ទៅកាន់លំនៅរបស់តាបសម្នាក់ អធិដ្ឋានអង្គឧបោសថហើយដេក អមាត្យនោះ ត្រូវតាបសសួរថា អ្នកធ្វើកម្មអ្វីមក ទើបបុរសនោះពោលគាថា ( ក្នុងខុទ្ទកនិកាយជាតក ) នេះថា

ខ្ញុំមើលងាយនូវលំនៅរបស់ខ្លួន បានចូលទៅកាន់ស្រុកនៃមល្ល-
ជនព្រោះតែសេចក្តីប្រាថ្នាលើសលុប គ្រានោះ ពួកជនចេញមក
ពីស្រុកហើយ ក៏វាយខ្ញុំដោយដំបង ។ ខ្ញុំនោះបែកក្បាល ប្រឡាក់
ឈាមអស់ទាំងខ្លួន ហើយត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ
ព្រោះហេតុនោះ បានជាខ្ញុំរក្សាឧបោសថ កុំឲ្យសេចក្តីប្រាថ្នា
លើសលុប គ្របសង្កត់បានទៀតឡើយ ដូច្នេះ(២) ។

[ ១០១ ] ក្នុងនិទ្ទេសនៃសេចក្តីប្រាថ្នាធំ បុគ្គលឈ្មោះថា **មហិច្ឆតា** ព្រោះអត្ថថា ប្រាថ្នាច្រើន ឬសេចក្តីប្រាថ្នារបស់បុគ្គលនោះ មានច្រើន ភាពនៃបុគ្គលមានសេចក្តីប្រាថ្នាច្រើននោះ ឈ្មោះថា **មិហច្ឆតា** បើពោល

---

២-បិដកខ្មែរ គាថានេះ ខ្លាឃ្មុំជាអ្នកពោល ។

១- បិដកខ្មែរ គាថានេះ ទេវបុត្តពោធិសត្វ ជាអ្នកពោល ។

ដោយលក្ខណៈ ការប្រកាសគុណដែលមិនមានពិត និងការមិនស្គាល់ប្រមាណក្នុងការទទួល និងការបរិភោគ នេះជាលក្ខណៈនៃសេចក្ដីប្រាថ្នាច្រើន ។

ពិតហើយ ឈ្មួញរែកាន់យកទំនិញ និងគ្រឿងប្រដាប់ដោយដៃ និងដាក់វត្ថុដែលគួរដាក់ ត្រង់ថ្នក់ ហើយពោលឃោសនា អញ្ជើញមហាជនដែលកំពុងឃើញនោះឯងថា ចូរនាំងកាន់យកវត្ថុឈ្មោះនោះ វត្ថុឈ្មោះនោះ ដូច្នេះ យ៉ាងណា សេចក្ដីនេះក៏យ៉ាងនោះឯង បុគ្គលដែលមានសេចក្ដីប្រាថ្នាច្រើន រមែងប្រាថ្នាដើម្បីប្រកាសសីល ឬការសិក្សាពុទ្ធវចនៈ ឬធុតង្គគុណដោយហោចសូម្បីតែការនៅព្រៃជាវត្តរបស់ខ្លួន ទោះមានប្រមាណតិច ដល់មហាជនដែលដឹងនោះឯង កាលប្រកាសហើយ កាលមហាជនសរសើរបង្អោនបច្ច័យសូម្បីច្រើនរទេះមកឲ្យក៏មិនពោលឃាត់ថា ល្មមហើយ រមែងទទួលឯង ។ ពិតហើយ បុគ្គលណាមួយក៏មិនអាចញ៉ាំងវត្ថុទាំង ៣ ឲ្យឆ្អែតឲ្យពេញ គឺភ្លើង រមែងមិនឆ្អែតដោយឧស សមុទ្ទមិនឆ្អែតដោយទឹក បុគ្គលដែលមានការប្រាថ្នាច្រើន រមែងមិនឆ្អែតដោយបច្ច័យទាំងឡាយ ។

> វត្ថុទាំង ៣ នេះ គឺគំនរភ្លើង ១ មហាសមុទ្ទ ១ បុគ្គល
> ប្រាថ្នាច្រើន ១ ទោះបីបុគ្គលណាមួយ ឲ្យបច្ច័យទាំងឡាយ
> ច្រើន ក៏មិនគប្បីឲ្យឆ្អែត ឲ្យពេញបាន ដូច្នេះ ។

ពិតហើយ បុគ្គលប្រាថ្នាច្រើន មិនអាចកាន់យកចិត្តសូម្បីតែមាតាបង្កើតបាន ( សូម្បីតែម្ដាយបង្កើតក៏មិនអាចឲ្យបុគ្គលនោះស្កប់ស្កល់បាន ) នឹង

ពោលថ្មីដល់ទឹកចិត្តរបស់បុគ្គលដែលជាឧបដ្ឋាកនោះ ក្នុងសេចក្តីនេះ មានរឿងនេះជាឧទាហរណ៍

បានឮថា ភិក្ខុកំលោះមួយរូប ជាប់ចិត្តនឹងនំដែលធ្វើដោយម្សៅ លំដាប់នោះ មាតារបស់ភិក្ខុនោះ កាលពិសោធបដិបទារបស់កូននោះ គិតថា បើកូនរបស់អញ ដឹងប្រមាណក្នុងការទទួលសោត អញនឹងទំនុកបម្រុងកូននោះដោយនំទាំងឡាយនោះឯងអស់កាល ៣ ខែ ដូច្នេះ ទើបសាកល្បងក្នុងថ្ងៃចូលវស្សាដំបូង បានប្រគេននំមួយដុំ កាលនំមួយដុំអស់ហើយ ទើបប្រគេននំដុំទី ២ កាលដុំទី ២ អស់ហើយ ក៏ប្រគេនដុំទី ៣ ភិក្ខុកំលោះមិនឃាត់ថាបានហើយ ទំពាធាន់នោះឯង មាតាដឹងនូវភាពដែលកូនប្រុសនោះមិនស្គាល់ប្រមាណ ទើបពោលថា នំក្នុងរយៈពេល ៣ ខែ កូនរបស់ខ្ញុំទំពាធាន់អស់ហើយក្នុងថ្ងៃនេះឯង ដូច្នេះ តាំងអំពីថ្ងៃនោះមក ឧបាសិកាមិនបានប្រគេនសូម្បីតែមួយដុំទៀតឡើយ ។

ព្រះបាទតិស្សមហារាជ កាលថ្វាយទានដល់ភិក្ខុសង្ឃត្រង់ចេតិយបព៌តរាល់ៗ ថ្ងៃ កាលអ្នកជនបទក្រាបទូលថា បពិត្រមហារាជ ទ្រង់គប់រកចំពោះក្នុងទីមួយប៉ុណ្ណោះឬ ការថ្វាយទានក្នុងទីដទៃមិនសមគួរដល់ព្រះអង្គឬ ដូច្នេះ ក្នុងថ្ងៃទី ២ បន្ទាប់អំពីថ្ងៃនោះ ទើបថ្វាយមហាទានក្នុងក្រុងអនុរាធបុរី ។ ក្នុងភិក្ខុទាំងនោះ មិនមានសូម្បីតែភិក្ខុមួយរូបដែលដឹងប្រមាណក្នុងការទទួល ។ របស់ទំពា របស់បរិភោគ ដែលភិក្ខុមួយរូបៗ ទទួលហើយ មនុស្ស ២ ឬ ៣ នាក់ ទើបលើកទៅបាន ។ ព្រះរាជាឲ្យនិមន្តភិក្ខុសង្ឃត្រង់ចេតិយបព៌ត

ក្នុងថ្ងៃទី ២ ក្នុងវេលាដែលភិក្ខុទាំងឡាយ មកកាន់ព្រះរាជវាំង ក៏ត្រាស់ថា សូមលោកម្ចាស់ទាំងឡាយឲ្យបាត្រ ភិក្ខុសូម្បីត្រឹមតែមួយរូប ក៏មិនបានឲ្យបាត្រ ដោយពោលថា កុំឡើយមហារាជ ភិក្ខុទាំងឡាយ នឹងទទួលភិក្ខាដោយប្រមាណរបស់ខ្លួនប៉ុណ្ណោះ ដូច្នេះ ភិក្ខុទាំងឡាយ ទទួលភិក្ខាដែលសមគួរដល់ប្រមាណរបស់ខ្លួននោះឯង ។ គ្រានោះ ព្រះរាជាត្រាស់ថា អ្នកទាំងឡាយចូរមើល បណ្ដាភិក្ខុទាំងឡាយរបស់ពួកអ្នក មិនមានសូម្បីត្រឹមតែមួយរូបដែលដឹងប្រមាណ ម្សិលមិញវត្ថុណាមួយក៏មិនសល់ តែថ្ងៃនេះ ភិក្ខុទទួលល្មមប្រមាណដល់ខ្លួន ទើបរបស់សល់ច្រើន ដូច្នេះ ។ ព្រះរាជាទ្រង់ពេញព្រះរាជហឫទ័យចំពោះភិក្ខុទាំងនោះ ដែលដឹងប្រមាណ ទ្រង់មិនពេញព្រះហឫទ័យចំពោះភិក្ខុក្រៅអំពីនេះ ដែលមិនដឹងប្រមាណ ។

[ ១០២ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃសេចក្ដីប្រាថ្នាដ៏លាមក ដូចតទៅនេះ សួរថា ក្នុងបទថា **អស្សទ្ធោ សមានោ សទ្ធោតិ មំ ជនោ ជានាតុ** ជាដើម បុគ្គលកាលប្រាថ្នាយ៉ាងនេះ រមែងធ្វើដូចម្ដេច ឆ្លើយថា បុគ្គលមិនមានសទ្ធា រមែងសម្ដែងអាការនៃបុគ្គលមានសទ្ធា បុគ្គលទ្រុស្ត-សីលជាដើម រមែងសម្ដែងអាការ របស់អ្នកមានសីលជាដើម ។ សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា ជាបឋម នឹងឆ្លើយអំពីបុគ្គល មិនមានសទ្ធាជាមុន ក្នុងថ្ងៃមានមហោស្រពធំ ភិក្ខុកាន់យកអំបោសទៅបោសវិហារ តើបសំរាម ក្នុងពេលដែលពួកមនុស្សមកកាន់វិហារ កាលដឹងថា មនុស្សទាំងឡាយ ឃើញការធ្វើរបស់លោកហើយ ក៏ទៅកាន់លានព្រះចេតិយ សូម្បី

ក្នុងទីនោះក៏បោសហើយកើបសំរាម កៀរខ្សាច់ ធ្វើផ្ទៃដីឲ្យស្មើ លាងអាសនៈទាំងឡាយ ស្រោចទឹកត្រង់ពោធិព្រឹក្ស ។ មនុស្សទាំងឡាយ ឃើញលោកហើយសម្គាល់ថា ភិក្ខុដទៃដែលសម្អាតវិហារ ប្រហែលជាមិនមាន ភិក្ខុនេះប៉ុណ្ណោះ រមែងសម្អាតវិហារនេះ លោកជាព្រះថេរៈមានសទ្ធា ដូច្នេះ ក្នុងវេលាត្រឡប់ និមន្តភិក្ខុនោះហើយ ទើបត្រឡប់ ។

បុគ្គលទ្រុស្តសីលក៏ចូលទៅរកព្រះវិនយធរ រមែងសួរក្នុងទីចំពោះមុខនៃឧបដ្ឋាកទាំងឡាយថា បពិត្រលោកម្ចាស់ កាលខ្ញុំដើរទៅ គោទាំងឡាយភ័យហើយរត់ទៅ ធ្វើឲ្យស្មៅទាំងឡាយដាច់ កាលខ្ញុំកំពុងបោសធ្វើឲ្យស្មៅដាច់ កាលខ្ញុំកំពុងចង្ក្រម សត្វតូចៗ រមែងស្លាប់ កាលខ្ញុំស្តោះទឹកមាត់ព្រោះមិនមានស្មារតី ទឹកមាត់ក៏ធ្លាក់ចុះលើចុងស្មៅ ទោសណាមួយ រមែងមានក្នុងរឿងនោះដែរឬទេ ដូច្នេះ កាលព្រះវិនយធរ ពោលថា អើ អាវុសោមិនត្រូវអាបត្តិដល់បុគ្គលដែលមិនក្លែង មិនមានស្មារតី និងមិនដឹងឡើយដូច្នេះហើយ ពោលសរសើរព្រះវិនយធរថា បពិត្រលោកម្ចាស់ ទោសទាំងនេះ ប្រាកដដល់ខ្ញុំហាក់បីដូចជារបស់ធ្ងន់ លោកម្ចាស់ពិចារណាប្រពៃហើយ ដូច្នេះ ។ មនុស្សទាំងឡាយស្តាប់ពាក្យនោះហើយជ្រះថ្លាថា លោកម្ចាស់របស់ពួកយើងរង្កៀសសូម្បីហេតុមានប្រមាណប៉ុណ្ណោះ តើលោកនឹងធ្វើកម្មគ្រោតគ្រាតដទៃបានដូចម្តេច ភិក្ខុអ្នកមានសីល ដូចភិក្ខុនេះមិនមាន ដូច្នេះហើយក៏ធ្វើសក្ការៈ ។

បុគ្គលអ្នកសិក្សាតិច ក៏អង្គុយពោលត្រង់កណ្តាលឧបដ្ឋាកថា ភិក្ខុរូប

នោះ ទ្រទ្រង់ព្រះត្រៃបិដក ភិក្ខុនោះទ្រទ្រង់និកាយ ៤ តែភិក្ខុទាំងនោះសុទ្ធតែជាកូនសិស្សរបស់អាត្មា ភិក្ខុទាំងនោះ រៀនធម៌ក្នុងសម្នាក់អាត្មា ដូច្នេះ ពួកមនុស្សជ្រះថ្លាថា ភិក្ខុជាពហុស្សូតដូចលោកម្ចាស់របស់យើង មិនមានបានឮថា ភិក្ខុនោះ រៀនធម៌ក្នុងសម្នាក់របស់លោកម្ចាស់នៃយើង ដូច្នេះ ទើបធ្វើនូវសក្ការៈ ។

បុគ្គលត្រេកអរដោយពួកគណៈ ក្នុងថ្ងៃដែលមានមហោស្រពធំ ញុំាងបុគ្គលឲ្យកាន់យកតាំង គឺទីអង្គុយវែង និងខ្នើយ ពូថៅ អង្គុយសម្រាកអស់ថ្ងៃត្រង់គល់ឈើខាងចុងវិហារ ។ មនុស្សទាំងឡាយមកហើយសួរថា ព្រះថេរៈទៅណា ដូច្នេះ ។ ឈ្មោះថា គណ្ឋិកបុត្តដែលពោលពាក្យមិនច្បាស់លាស់នោះឯងមាន ដោយហេតុនោះ ទើបពួកជនទាំងនោះពោលថា ព្រះថេរៈមិនអង្គុយក្នុងទីនេះ ក្នុងកាលបែបនេះ រមែងនៅក្នុងទីចង្ក្រមវែង និងក្នុងទីសម្រាកពេលថ្ងៃ ត្រង់ខាងចុងវិហារ ដូច្នេះ ។ ភិក្ខុនោះ ក៏ញុំាងកាលកន្លះថ្ងៃឲ្យកន្លងទៅ ធ្វើសម្បុកពីងពាងឲ្យជាប់ត្រង់ថ្ងាស ឲ្យបុគ្គលកាន់យកតាំងមកអង្គុយត្រង់បរិវេណទ្វារ មនុស្សទាំងឡាយ រមែងពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ទៅឯណា ពួកខ្ញុំមកហើយ មិនឃើញលោកម្ចាស់ ដូច្នេះ ។ ភិក្ខុនោះ ញុំាងមនុស្សឲ្យដឹងថា ខ្លួនជាអ្នកគាប់ចិត្តក្នុងទីស្ងប់ស្ងាត់ដោយពាក្យថា អើ ឧបាសកទាំងឡាយ ខាងក្នុងវិហារនេះ ប្រឡូកប្រឡំ ទីនេះជាទីត្រាច់ចុះឡើងរបស់ភិក្ខុកំលោះ និងសាមណេរទាំងឡាយ អាត្មាមកអង្គុយក្នុងទីសម្រាកពេលថ្ងៃ ក្នុងទីចង្ក្រមបណ្តាយ ៦០ ហត្ថ ដូច្នេះ ។

ភិក្ខុខិលប្រអូស អង្គុយកណ្តាលឧបដ្ឋាករមែងពោលថា ឧបាសកទាំងឡាយ ពួកអ្នកឃើញឧក្កាបាត គឺការធ្លាក់នៃគប់ភ្លើង ( អាចម៍ផ្កាយ ឬផ្កាយដុះកន្ទុយ ) ហើយឬ ដូច្នេះ ពួកមនុស្សសួរថា បពិត្រលោកម្ចាស់ ពួកខ្ញុំមិនឃើញឧក្កាបាត មានក្នុងពេលណានោះឡើយ ដូច្នេះ ទើបភិក្ខុនោះពោលថា ក្នុងពេលដែលចង្រ្កមរបស់ពួកអាត្មា ហើយទើបសួរថា ពួកអ្នកបានឮសំឡេងញាប់ញ័ររបស់ផែនដីដែរឬ ដូច្នេះ កាលអ្នកស្រុកពោលថា ពួកខ្ញុំមិនបានឮសំឡេងញាប់ញ័រនៃផែនដី មានក្នុងកាលណា ដូច្នេះ ក៏ពោលថា ក្នុងពេលពួកអាត្មា ឈរផ្អែកបង្ហូរក្តារ កំណត់អារម្មណ៍ ក្នុងមជ្ឈិមយាម ហើយសួរថា ពន្លឺធំនោះមានហើយ ពួកអ្នកឃើញពន្លឺនោះហើយឬ ដូច្នេះ កាលពួកមនុស្សសួរថា ពន្លឺធំនោះមានក្នុងពេលណា ដូច្នេះក៏ពោលថា ក្នុងពេលដែលបញ្ចប់ការចង្រ្កមរបស់អាត្មា ដូច្នេះ ។ ពួកមនុស្សជ្រះថ្លាហើយគិតថា ព្រះថេរៈរបស់យើងទាំងឡាយ ចង្រ្កមអស់យាមទាំង ៣ ភិក្ខុអ្នកប្រារព្ធព្យាយាមដូចលោកម្ចាស់របស់យើងមិនមាន ដូច្នេះហើយក៏ធ្វើសក្ការៈ ។

ភិក្ខុមិនមានសតិ ក៏អង្គុយត្រង់កណ្តាលឧបដ្ឋាកពោលថា អាត្មារៀនទីឃនិកាយក្នុងកាលឈ្មោះនោះ រៀនមជ្ឈិមនិកាយក្នុងកាលឈ្មោះនោះ រៀនសំយុត្តនិកាយ អង្គុត្តរនិកាយក្នុងកាលឈ្មោះនោះ ឈ្មោះថា ការសម្លឹងមើលដទៃក្នុងចន្លោះៗ រមែងមិនមាន បែបផែនដែលជំនាញ ( រត់មាត់ ) ហើយ រមែងមកក្នុងទីដែលអាត្មាប្រាថ្នាហើយ ឯពួកភិក្ខុដទៃទាំងនេះ ធ្វើមាត់ម្លុបៗ ដូចមាត់ពពែ ដូច្នេះ ។ ពួកមនុស្សទាំងឡាយជ្រះថ្លាហើយ គិត

ថា បុគ្គលដទៃដែលមានសតិប្រាកដដូចលោកម្ចាស់របស់យើងមិនមាន ទើបធ្វើសក្ការៈ ។

ភិក្ខុមានចិត្តមិនតាំងមាំ ក៏រមែងសួរបញ្ហា ក្នុងព្រះអដ្ឋកថាចារ្យ ក្នុងទីចំពោះមុខនៃឧបដ្ឋាកទាំងឡាយ គឺរមែងសួរថា ឈ្មោះថា កសិណ ចម្រើនដូចម្ដេច ឈ្មោះថា និមិត្ត កើតឡើងបានដោយកម្មដ្ឋានប៉ុន្មានយ៉ាង ឧបចារៈកើតឡើងបានដោយកម្មដ្ឋានប៉ុន្មានយ៉ាង អប្បនា ឡើងបានដោយកម្មដ្ឋានប៉ុន្មានយ៉ាង បឋមជ្ឈានមានអង្គប៉ុន្មាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈានមានអង្គប៉ុន្មាន ដូច្នេះ កាលព្រះអដ្ឋកថាចារ្យ ( អ្នករៀនអដ្ឋកថា ) ទាំងនោះ ពោលដោយសមគួរ ដល់ការសិក្សារបស់ខ្លួន ភិក្ខុនោះក៏ធ្វើនូវការញញឹម ក្នុងពេលដែលត្រូវសួរថា អាវុសោ ចម្លើយបែបនេះ មិនត្រូវឬទើបចង្អុលដល់ភាពដែលខ្លួនបានសមាបត្តិថា បពិត្រលោកម្ចាស់ សេចក្ដីនេះរមែងត្រឹមត្រូវ ដូច្នេះ ។ មនុស្សទាំងឡាយនាំគ្នាជ្រះថ្លាគិតថា លោកម្ចាស់របស់ពួកយើងបានសមាបត្តិ ហើយទើបធ្វើសក្កាៈ ។

ភិក្ខុមានបញ្ញាថោកថយ អង្គុយកណ្ដាលឧបដ្ឋាកទាំងឡាយ ពោលថាពួកអាត្មាលះបង់បរិយត្តិដោយគិតថា កាលអាត្មាពិនិត្យមើលបញ្ចត្ថយសូត្រក្នុងមជ្ឈិមនិកាយ មគ្គ មួយអន្ទើដោយឫទ្ធិនោះឯង មកហើយ ឈ្មោះថាបរិយត្តិ មិនជារបស់ដែលធ្វើបានដោយលំបាកសម្រាប់ពួកអាត្មា ការដាក់ចិត្តក្នុងបរិយត្តិ មិនផុតអំពីទុក្ខទេ ដូច្នេះ រមែងសម្ដែងនូវភាពដែលខ្លួនជាបុគ្គលមានបញ្ញាច្រើន កាលភិក្ខុនោះពោលយ៉ាងនេះ ឈ្មោះថា រមែងទម្លាយ

នូវសាសនារបស់ខ្លួន ។ ឈ្មោះថា មហាចោរដូចបុគ្គលនេះ រមែងមិនមាន ព្រោះថា បុគ្គលដែលទ្រទ្រង់នូវបរិយត្តិ រមែងមិនផុតចាកទុក្ខមិនមាន ។

ភិក្ខុមិនទាន់អស់អាសវៈ ឃើញទារកក្នុងស្រុកហើយសួរថា មាតាបិតារបស់ពួកឯង រមែងពោលថា អាត្មាដូចម្តេច ពួកទារកពោលថា មាតាបិតារបស់ខ្ញុំពោលថា លោកម្ចាស់ជាព្រះអរហន្ត ភិក្ខុនោះ សម្តែងនូវភាពដែលខ្លួនជាអ្នកមានអាសវៈអស់ហើយ ដោយពាក្យថា បុគ្គលណាមិនអាចបោកគហបតីបុត្តដែលឈ្លាសវៃបាន ដូច្នេះ ។ ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបភិក្ខុដទៃទៀតដែលសម្តែងខ្លួនជាព្រះអរហន្ត មានអរហន្តពួនពាង និងអរហន្តពួរជ្រៃជាដើម ។

បានឮថា ភិក្ខុកុហកមួយរូប កប់ពាងធំទុកក្នុងបន្ទប់របស់ខ្លួន រមែងចូលទៅក្នុងពាង ក្នុងពេលដែលពួកមនុស្សមករក ទើបមនុស្សទាំងឡាយសួរគ្នាថា ព្រះថេរៈទៅណា ដូច្នេះ កាលភិក្ខុដទៃពោលថា ព្រះថេរៈនៅក្នុងបន្ទប់ ពួកមនុស្សក៏ចូលទៅរក មិនឃើញក៏ចេញមក ពោលថា មិនមានព្រះថេរៈ ដូច្នេះ កាលភិក្ខុនោះ ពោលថា ព្រះថេរៈនៅក្នុងបន្ទប់នោះឯង ដូច្នេះ ពួកមនុស្សក៏ចូលទៅទៀត ព្រះថេរៈចេញពីពាង ហើយអង្គុយលើតាំង ។ លំដាប់នោះ កាលមនុស្សទាំងឡាយពោលថា បពិត្រលោកម្ចាស់ ជំពូងពួកខ្ញុំមិនឃើញ ហើយចេញទៅ តើលោកម្ចាស់ទៅឯណា ដូច្នេះ ភិក្ខុនោះសម្តែងនូវភាពដែលខ្លួនជាអ្នកមានអាសវៈអស់ហើយ ដោយពាក្យថា សមណៈទាំងឡាយ រមែងទៅកាន់ទីដែលខ្លួនប្រាថ្នា ដូច្នេះ ។

ភិក្ខុកុហកមួយរូបទៀត អាស្រ័យបណ្ណសាលាក្បែរភ្នំមួយ ដើមជ្រៃមួយមានត្រង់ញកភ្នំ ខាងក្រោយបណ្ណសាលា ឫសរបស់ដើមជ្រៃនោះចាក់មកដល់ផែនដីក្នុងចំណែកដទៃ មនុស្សទាំងឡាយ ធ្វើដំណើរមកតាមផ្លូវ តែងនិមន្តភិក្ខុនោះដើម្បីភត្តាហារ ភិក្ខុនោះ កាន់យកបាត្រ និងចីវរ ហើយសម្រូតមកតាមឫសជ្រៃនោះ ហើយប្រាកដខ្លួនក្បែរទ្វារស្រុក ។ លំដាប់នោះ ពួកមនុស្សដែលមកដល់ក្រោយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មកតាមផ្លូវណា ដូច្នេះ ភិក្ខុនោះ សម្ដែងភាពដែលខ្លួនជាអ្នកមានអាសវៈអស់ហើយដោយពាក្យថា ផ្លូវដែលសមណៈមកហើយ មិនសមគួរនឹងសួរ សមណៈទាំងឡាយ រមែងមកតាមផ្លូវដែលខ្លួនប្រាថ្នានោះឯង ។ បុរសអ្នកឈ្លាសក្នុងការស្ដាប់ម្នាក់ ដឹងថា ភិក្ខុនោះ ជាអ្នកកុហក ទើបគិតថា អញនឹងលបមើលភិក្ខុនេះ ។ ថ្ងៃមួយ គាត់ឃើញភិក្ខុនោះសួតាមឫសជ្រៃ ទើបកាប់ឫសជ្រៃខាងក្រោយបន្សល់ទុកតែបន្តិច ។ ភិក្ខុអ្នកកុហកនោះ គិតថា អញនឹងចាប់ឫសជ្រៃចុះទៅ ទើបធ្លាក់ចុះ បាត្រក៏បែក ភិក្ខុនោះជ្រាបថាបុគ្គលណាមួយដឹងរឿងរបស់ខ្លួនហើយ ទើបគេចទៅ ដូច្នេះ ។

ភាពនៃបុគ្គលប្រាថ្នាលាមក ឈ្មោះថា **ចាបិច្ឆតា** កាលពោលដោយលក្ខណៈ បណ្ឌិតគប្បីជ្រាបថា ការសរសើរគុណដែលមិនមានពិត និងមិនដឹងប្រមាណក្នុងការទទួល សេចក្ដីនេះ ជាលក្ខណៈនៃការប្រាថ្នាលាមក ។

[ ១០៣ ] ក្នុងនិទ្ទេសនៃកិលេសជាតដូចស្នែង ឈ្មោះថា **សិង្គ** ព្រោះអត្ថថា ជាគ្រឿងមុត ។ ពាក្យថា **សិង្គ** នេះ ជាឈ្មោះរបស់ការមុត គឺ

កិលេស ពោល គឺភាពដែលវាចានោះ ជាគ្រឿងចាក់ដោតរបស់អ្នកទគរ ។ ភាវៈនៃការពោលចាក់ដោត ឈ្មោះថា **សង្ការតា** ឬ **សង្ការការណាកាកោ** ។ ភាពនៃបុគ្គលពោលវាចា ៤ ជ្រុង ( វាចាដែលធ្វើឲ្យអ្នកដទៃឈឺចាប់ ) ឈ្មោះថា **ចតុរតា** ។ ពាក្យថា **ចាតុរិយំ** ក៏មានន័យដូចគ្នា ។ ការពោល ភាវៈនៃការពោលវាចាធ្វើឲ្យអ្នកដទៃឈឺចាប់យ៉ាងមាំ ឈ្មោះថា **បរិក្ខតតា** ពាក្យនេះ ជាឈ្មោះរបស់ភាវៈនៃការនិយាយចាក់ដោតយ៉ាងមាំទាំ ដែលរៀបពាក្យត្រៀមទុកជាមុននោះឯង ពាក្យក្រៅអំពីនេះ ជាវេវចនៈរបស់បទថា **បរិក្ខតតា** នោះឯង ។ ភាវៈនៃការពោលចាក់ដោត ព្រោះអំណាចនៃកិលេសនោះឯង ទើបព្រះមានព្រះភាគត្រាស់ទុកថា ដោយពាក្យទាំងអស់ដោយអាការយ៉ាងនេះៗ ។

[ ១០៤ ] ក្នុងនិទ្ទេសនៃសេចក្ដីតិះដៀល ការពោលតិះដៀល ឈ្មោះថា **តិន្តិណំ** ។ អាការនៃការប្រព្រឹត្តតិះដៀល ឈ្មោះថា **តិន្តិណាយនា** ។ ភាពនៃបុគ្គលអ្នកប្រព្រឹត្តដោយការតិះដៀល គឺជាអ្នកដល់ព្រមដោយការតិះដៀល ឈ្មោះថា **តិន្តិណាយិត្តំ** ។ ភាពនៃបុគ្គលអ្នកលោភលន់ ឈ្មោះថា **លោលុប្បំ** ។ ពីរបទក្រៅអំពីនេះ ( គឺបទថា **លោលុប្បាយនា លោលុប្បា-យិត្តំ** ) ជាពាក្យអធិប្បាយនៃកិរិយាអាការរបស់បទថា **លោលុប្បំ** នោះឯង ។ បទថា **បុច្ឆញ្ជិកតា** បានដល់ ការប្រព្រឹត្តឱនលំទោន ព្រោះការញាប់ញ័រក្នុងឋានៈនៃប្រយោជន៍ ដែលគួរបាន ឬមិនគួរបាន ។ បទថា **សាធុកម្យតា** បានដល់ ការប្រាថ្នាដែលនឹងបានវត្ថុដែលប្រណីត ។ ដោយ

ពាក្យទាំងពួងយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់អាការនៃការនិយាយតិះដៀលដោយអំណាចនៃកិលេសថា នេះរបស់អ្នក នេះរបស់ខ្ញុំ ដូចគ្នានឹងការព្រុសរបស់ឆ្កែ ដែលកំពុងផឹកទឹកបាយត្រង់ស្នូក ព្រោះឃើញឆ្កែដទៃដូច្នេះ ។

[ ១០៥ ] ក្នុងនិទ្ទេសនៃការឃ្លេងឃ្លោង ( ហ៊ឺហា ) ការតាក់តែងចីវរដោយការៈធ្វើឲ្យរៀបរយជាផ្នត់ជាក្លីជាដើម ឈ្មោះថា **ចីវរមណ្ឌនា** ។ ការតាក់តែងបាត្រ ដោយការធ្វើឲ្យមានពណ៌ ដូចពណ៌នៃកែវមណី ឈ្មោះថា **បត្តមណ្ឌនា** ។ ការតាក់តែងសេនាសនៈដែលជារបស់បុគ្គលដោយចិត្រកម្មជាដើម ឈ្មោះថា **សេនាសនមណ្ឌនា** ។ បទថា **ឥមស្ស វា បូតិកាយស្ស** បានដល់ កាយរបស់មនុស្សនេះ ។ ដូចឆ្កែចចក ទោះបីកើតក្នុងថ្ងៃនោះ ដើងនៅទន់ក៏ដោយ ក៏គេហៅថា ចចកចាស់នោះឯង វល្លិផោមមានទំហំប៉ុនភ្លៅ ក៏ដល់នូវការរាប់ថា ជាវល្លិស្អុយនោះឯង យ៉ាងណា កាយមនុស្ស ទោះមានពណ៌ដូចមាស ព្រះមានព្រះភាគ ក៏ត្រាស់ហៅថា កាយស្អុយនោះឯង ។ ការតាក់តែងកាយដែលស្អុយនោះ ដោយគ្រឿងអាភរណៈមានសម្លៀកបំពាក់ជាដើមដែលមានពណ៌ក្រហម ពណ៌លឿងជាដើម ពេញរាងកាយ ឈ្មោះថា **មណ្ឌនា** ។ បទថា **ពាហិរានំ វា បរិក្ខារំ** បានដល់ ការតាក់តែងបរិក្ខារដែលក្រៅអំពីបាត្រ និងចីវរ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីនេះ យ៉ាងនេះថា ការតាក់តែងដែលព្រះមានព្រះភាគត្រាស់ថា ការតាក់តែងចីវរ ការតាក់តែងបាត្រ គឺការ

តាក់តែងកាយដោយបរិក្ខារទាំងនោះ ឬការតាក់តែងបរិក្ខារខាងក្រៅអំពីកាយទាំងនោះ ដោយអំណាចនៃការតាក់តែងហើយបង្ហាញ ។ ក្នុងបទថា **មណ្ឌនា វិភូសនា** នេះ គប្បីជ្រាបថា ឈ្មោះថា **មណ្ឌនា** ដោយអំណាចនៃការញុំាងទីដែលខ្វះខាត ឲ្យពេញ ឈ្មោះថា **វិភូសនា** ដោយអំណាចនៃការប្រោះព្រំស្បែកជាដើម ។ ការលេងដែលត្រេកអរ ឈ្មោះថា **កេឡនា** ( ប្រឡែងគ្នា ) ។ អាការលេងត្រេកអរ ឈ្មោះថា **បរិកេឡនា** ។ ការប្រកបដោយការត្រេកអរ ឈ្មោះថា **គិទ្ធិកតា** ។ បទថា **គិទ្ធិកត្តំ** ជាវេវចនៈរបស់បទថា **គិទ្ធិកតា** ។ ភាវៈនៃបុគ្គលអ្នកតាក់តែង ឈ្មោះថា **ចបលតា** ។ បទថា **ចាបល្យំ** ក៏យ៉ាងនោះ ។ បទថា **ឥទំ វុច្ចតិ** នេះ ព្រះមានព្រះភាគត្រាស់ហៅថា កិរិយាតាក់តែងដែលជាហេតុឲ្យបុគ្គលប្រកបហើយ ទោះបីមានអាយុរាប់រយឆ្នាំ រមែងដូចជាទារកដែលកើតក្នុងថ្ងៃនោះដូច្នេះ ។

[ ១០៦ ] ក្នុងនិទ្ទេសនៃសេចក្ដីប្រព្រឹត្តមិនស្មោះស្មើ ការប្រព្រឹត្តមិនស្របតាម ឈ្មោះថា **វិប្បដិកូលគ្គាហិតា** ។ ការប្រព្រឹត្តតាមសប្បាយដោយការធ្វើឲ្យជំទាស់ ដែលជាសត្រូវផ្សេងៗ ឈ្មោះថា **វិបច្ចនីកសាតតា** ។ ភាពនៃបុគ្គលដែលមិនអើពើ ឈ្មោះថា **អនាទរិយំ** ។ បទថា **អនាទរិយតា** ក៏ដូចគ្នា ។ ភាពនៃបុគ្គលមិនគោរព ឈ្មោះថា **អគារវតា** ។ ភាពជាអ្នកមិនធ្វើតាមពាក្យរបស់បុគ្គលដែលចម្រើន ឈ្មោះថា **អប្បដិស្សវតា** ។ បទថា **អយំ វុច្ចតិ** នេះ ព្រះមានព្រះភាគទ្រង់ហៅ

ឈ្មោះសេចក្តីប្រព្រឹត្តមិនស្មោះស្មើ អធិប្បាយថា ភាពជាអ្នកមានជីវិតដែលមិនសមគួរ ។ បុគ្គលដែលប្រកបដោយការប្រព្រឹត្តមិនស្មោះស្មើ សូម្បីត្រឡប់មកហើយ ក៏មិនក្រឡេកមើលមាតា ឬបិតាដែលមានជំងឺ រមែងទាស់ទែងជាមួយមាតាព្រោះហេតុនៃទ្រព្យរបស់បិតា រមែងទាស់ទែងជាមួយបិតាព្រោះហេតុនៃទ្រព្យរបស់មាតា រមែងប្រព្រឹត្តទៅដោយមិនសមគួរ រមែងទាស់ទែងបងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី ព្រោះហេតុនៃទ្រព្យរបស់មាតាបិតា រមែងពោលវាចាអស់សេចក្តីខ្មាស រមែងមិនធ្វើវត្ត និងបដិវត្តដល់អាចារ្យ និងឧបជ្ឈាយ៍ មិនបម្រើកិច្ចឈឺ រមែងបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ រមែងស្តោះទឹកមាត់ខ្ទះ ញើសសម្បោរខ្ទះ រមែងបាំងឆត្រ រមែងពាក់ស្បែកជើងដើរចូលទៅក្នុងទីដែលជាព្រំដែនចេតិយ នៃព្រះមានព្រះភាគ រមែងមិនខ្មាសក្នុងសាវករបស់ព្រះពុទ្ធ រមែងមិនគោរពកោតក្រែងក្នុងសង្ឃ មិនញុាំងហិរិឱត្តប្បៈ ឲ្យតាំងឡើងក្នុងបុគ្គលដែលគួរគោរព ត្រឹមតែមាតា និងបិតាជាដើម ។ ការធ្វើទាំងពួងនោះ របស់បុគ្គលដែលប្រព្រឹត្តយ៉ាងនេះឯង ឈ្មោះថា ការប្រព្រឹត្តមិនស្មោះស្មើក្នុងវត្ថុទាំងឡាយ មានពាក្យថា ក្នុងមាតាជាដើម ។

[ ១០៧ ] ក្នុងនិទ្ទេសនៃសេចក្តីមិនត្រេកអរ បទថា **បន្តេសុ** បានដល់ទីឆ្ងាយ ឬទីស្ងាត់ ។ បទថា **អធិកុសលេសុ** បានដល់ ក្នុងធម៌ គឺសមថៈ និងវិបស្សនា ។ បទថា **អរតិ** ជាពាក្យបដិសេធសេចក្តីត្រេកអរ ។ អាការនៃការមិនត្រេកអរ ឈ្មោះថា **អរតិតា** ។ ភាពនៃបុគ្គលមិនត្រេកអរ

ក្រៃលែង ឈ្មោះថា **អនភិរតិ** ។ អាការនៃការមិនត្រេកអរក្រៃលែង ឈ្មោះថា **អនភិរមណា** ។ អាការនៃការរំខាន ឈ្មោះថា **ឧក្កណ្ឋិតា** ។ ការតក់ស្លុតដោយអំណាចនៃការរំខាននោះឯង ឈ្មោះថា **បរិតស្សិតា** ។

[ ១០៨ ] ក្នុងនិទ្ទេសនៃសេចក្តីខ្ជិលច្រអូស ការខ្ជិលច្រអូស ដោយកំណើត ឈ្មោះថា **តន្ទិ** ។ អាការនៃការខ្ជិលច្រអូស ឈ្មោះថា **តន្ទិយនា** ។ ភាវៈដែលចិត្តត្រូវភាពខ្ជិលច្រអូសគ្របសង្កត់ ឈ្មោះថា **តន្ទិមនកតា** ។ ភាពនៃការខ្ជិលច្រអូស ឈ្មោះថា **អាលស្យំ** ។ អាការនៃការប្រព្រឹត្តខ្ជិលច្រអូស ឈ្មោះថា **អាលស្យាយនា** ភាពនៃអ្នកប្រព្រឹត្តខ្ជិលច្រអូស ឈ្មោះថា **អាលស្យាយិតត្តំ** ។ ការខ្ជិលច្រអូសផ្លូវកាយដោយអំណាចនៃកិលេស ព្រះមានព្រះភាគត្រាស់ដោយបទទាំងអស់នេះ ដោយអាការយ៉ាងនេះ ។

[ ១០៩ ] ក្នុងនិទ្ទេសនៃសេចក្តីមីតពត់ ការមីតពត់កាយ ឲ្យកម្រើក ឈ្មោះថា **ជម្ភនា** ។ ការសណ្តូកកាយរឿយៗ ឈ្មោះថា **វិជម្ភនា** ។ ការបង្អោនកាយទៅខាងមុខ ឈ្មោះថា **អានមនា** ។ ការបង្អោនកាយទៅខាងក្រោយ ឈ្មោះថា **វិនមនា** ។ ការបង្អោនកាយដោយជុំវិញ ឈ្មោះថា **សន្នមនា** ។ ការបញ្ឈរកាយត្រង់ឡើងទៅលើដូចជាងតម្បាញ ដែលឈរក្នុងទីត្បាញសំពត់ ចាប់ត្រង់ទីណាមួយ ហើយក៏តាំងកាយឲ្យត្រង់ ឈ្មោះថា **បណាមនា** ។ ជំងឺតម្កាត់ដែលកើតឡើងហើយ ឈ្មោះថា **ព្យាធិយកំ** ។ ការមីតពត់កាយឲ្យកម្រើកនោះឯងដោយអំណាចនៃកិលេស ព្រះមានព្រះភាគត្រាស់ដោយបទទាំងអស់នេះ ដោយប្រការដូច្នេះ ។

[ ១១០ ] ក្នុងនិទ្ទេសនៃសេចក្តីស្រវឹងព្រោះភត្ត បទថា **ភុត្តាវិស្ស** បានដល់ របស់បុគ្គលបរិភោគអាហារស្រេចហើយ ។ ការមិនសប្បាយទាក់ទងដោយការបរិភោគអាហារ ឈ្មោះថា **ភត្តមុច្ឆា** ។ ពិតហើយ បុគ្គលហាក់បីដូចដល់នូវការសុបសៅ ព្រោះអាហារមានកម្លាំង ។ ភាពជាបុគ្គលលំបាកព្រោះអាហារ ឈ្មោះថា **ភត្តកិលមថោ** ។ ការក្រវល់ក្រវាយព្រោះអាហារ ឈ្មោះថា **ភត្តបរិឡាហោ** ។ ពិតហើយ ក្នុងសម័យនោះបុគ្គលមានឥន្ទ្រិយ ត្រូវសេចក្តីក្តៅក្រហាយកើតឡើងទម្លាយហើយ រាងកាយទ្រុឌទ្រោម ។ បទថា **កាយទុដ្ឋុល្លំ** បានដល់ ភាពដែលកាយមិនគួរដល់ការងារព្រោះអាស្រ័យអាហារ ។

[ ១១១ ] ក្នុងនិទ្ទេសនៃភាពនៃចិត្តរួញរា មានអត្ថដូចពោលហើយក្នុងអដ្ឋកថានៃធម្មសង្គហៈខាងដើមនោះឯង ។ អាការដែលចិត្តមានជំងឺ ដោយអំណាចនៃកិលេសគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយ ដោយបទទាំងអស់នេះ ដោយប្រការដូច្នេះ ។

[ ១១២ ] ក្នុងនិទ្ទេសនៃការកុហក បទថា **លាភសក្ការសិលោកសន្និស្សិតស្ស** អធិប្បាយថា របស់ភិក្ខុដែលប្រាថ្នា គឺត្រូវការលាភសក្ការៈនិងកេរ្តិ៍ឈ្មោះ ។ បទថា **បាបិច្ឆស្ស** បានដល់ ដែលត្រូវការសម្តែងសេចក្តីល្អដែលខ្លួនមិនមាន ។ បទថា **ឥច្ឆាបកតស្ស** អធិប្បាយថា ដែលត្រូវគ្របសង្កត់ហើយដោយចំណង់ គឺត្រូវការចង់បានរុករានហើយ ។

ខាងមុខអំពីនេះទៅ ព្រោះកុហនវត្ថុ ៣ មកក្នុងមហានិទ្ទេស ដោយ

អំណាចនៃភិក្ខុដែលបោកបញ្ឆោត ដោយបំណងនឹងសេពបច្ច័យ ១ ដោយការនិយាយកោស ១ ដោយអាស្រ័យឥរិយាបថ ១ ព្រោះហេតុនោះដើម្បីសម្តែងកុហនវត្ថុទាំង ៣ នោះ ទើបព្រះមានព្រះភាគ ត្រាស់ពាក្យថា **បច្ចយប្បដិសេវនសង្ខាតេន វា** ដូច្នេះជាដើម ។ ក្នុងសេចក្តីនោះ ការធ្វើឲ្យបុគ្គលដទៃវង្វេងដោយការដែលភិក្ខុត្រូវនិមន្តដោយបច្ច័យទាំងឡាយ មានចីវរជាដើម កាលលោកមានសេចក្តីប្រាថ្នាបច្ច័យនោះពិតៗ តែអាស្រ័យសេចក្តីប្រាថ្នាលាមក ទើបធ្វើជាបដិសេធ ដោយការដែលលោកជ្រាបថាគហបតីទាំងនោះជាអ្នកមានសទ្ធាតាំងមាំល្អហើយក្នុងខ្លួន កាលគហបតីទាំងនោះគិតថា ឱ លោកម្ចាស់របស់យើង មានសេចក្តីប្រាថ្នាតិច រមែងមិនត្រូវការទទួលរបស់ណាមួយ បើលោកគប្បីទទួលរបស់ណាមួយ ត្រឹមតែបន្តិចបន្តួចនោះជាការដែលពួកយើងបានល្អហើយហ្ន៎ ដូច្នេះហើយ បង្អោនបច្ច័យទាំងឡាយ មានចីវរជាដើម ដែលប្រណីតដោយឧបាយផ្សេងៗ ទៀត ទើបធ្វើឲ្យជាក់ច្បាស់នូវភាពដែលខ្លួនបំណងនឹងអនុគ្រោះគហបតីទាំងនោះ ទើបទទួល ចាប់តាំងអំពីនោះ ជាហេតុឲ្យជនទាំងនោះ បង្អោនបច្ច័យពេញៗ រទេះ គប្បីជ្រាបថា ជាកុហនវត្ថុទាក់ទងដោយការសេពបច្ច័យ ។ សមដូចពាក្យដែលព្រះសារីបុត្តត្ថេរ ពោលក្នុងមហានិទ្ទេសថា

កុហនវត្ថុខាងការសេពបច្ច័យ តើដូចម្តេច ។ ពួកគហបតីក្នុងសាសនានេះ រមែងនិមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ។ ភិក្ខុនោះ មានសេចក្តីប្រាថ្នាអាក្រក់ ត្រូវសេចក្តីប្រាថ្នា

គ្របសង្កត់ហើយ ជាអ្នកមានសេចក្តីត្រូវការនូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ អាស្រ័យនូវសេចក្តីប្រាថ្នាដ៏លើសលុប ទើបហាមឃាត់ចីវរ ហាមឃាត់បិណ្ឌបាត ហាមឃាត់សេនាសនៈ ហាមឃាត់គិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ភិក្ខុនោះបានពោលយ៉ាងនេះថា សមណៈមានប្រយោជន៍អ្វី ដោយចីវរមានថ្លៃច្រើន ការប្រើប្រាស់ចីវរដ៏សមគួរដល់សមណៈនុ៎ះ គឺសមណៈត្រូវតែរើសកំណាត់សំពត់ទាំងឡាយអំពីព្រៃស្មសាន ឬអំពីគំនរសំរាម ឬអំពីពានផ្សារមកធ្វើជាសង្ឃាដីប្រើប្រាស់ សមណៈមានប្រយោជន៍អ្វី ដោយបិណ្ឌបាតមានថ្លៃច្រើន ការចិញ្ចឹមជីវិតដ៏សមគួរដល់សមណៈនោះ គឺសមណៈត្រូវតែចិញ្ចឹមជីវិតដោយពុំនូតបាយ ដោយការដើរទៅដើម្បីសូម សមណៈមានប្រយោជន៍អ្វីដោយសេនាសនៈមានថ្លៃច្រើន ការនៅដ៏សមគួរដល់សមណៈនុ៎ះ គឺសមណៈត្រូវតែជាអ្នកនៅជិតគល់ឈើ ឬនៅក្នុងព្រៃស្មសាន ឬក៏នៅក្នុងទីវាល សមណៈមានប្រយោជន៍អ្វីដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ មានថ្លៃច្រើន ការធ្វើឱសថដ៏សមគួរដល់សមណៈនុ៎ះ គឺសមណៈត្រូវតែធ្វើថ្នាំដោយមូត្រផ្អូម ឬដោយចំណិតសម៉ តាំងអំពីនោះមក ភិក្ខុនោះ ក៏ទ្រទ្រង់ចីវរដ៏សៅហ្មង បរិភោគបិណ្ឌបាតដ៏សៅហ្មង សេពសេនាសនៈដ៏សៅហ្មង សេពគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏សៅហ្មង ។ ពួកគហបតីដឹងភិក្ខុនោះ យ៉ាងនេះថា សមណៈនេះ មានសេចក្តីប្រាថ្នាតិច មានសន្តោស ស្ងប់ស្ងាត់ មិនច្របូកច្របល់ ( ដោយពួក ) ប្រារព្ធព្យាយាម ពោលធុតគុណ ក៏រឹងរឹតតែនិមន្ត ដោយចីវរ បិណ្ឌបាត

សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ភិក្ខុនោះពោលយ៉ាងនេះថា កុលបុត្តមានសទ្ធាតែងប្រសព្វនូវបុណ្យដ៏ច្រើនព្រោះធម៌ ៣ យ៉ាងមានចំពោះមុខ គឺកុលបុត្តមានសទ្ធាតែងប្រសព្វនូវបុណ្យដ៏ច្រើន ព្រោះសទ្ធាមានចំពោះមុខ ១ កុលបុត្តមានសទ្ធាតែងប្រសប់នូវបុណ្យដ៏ច្រើន ព្រោះទេយ្យធម៌មានចំពោះមុខ ១ កុលបុត្តមានសទ្ធា តែងប្រសប់នូវបុណ្យដ៏ច្រើន ព្រោះពួកទក្ខិណេយ្យបុគ្គល មានចំពោះមុខ ១ សទ្ធានេះរបស់ពួកអ្នក ក៏មានផង ទេយ្យធម៌នេះក៏មានព្រមផង ទាំងអាត្មាក៏ជាអ្នកទទួល បើអាត្មាមិនទទួលទេ ពួកអ្នកនឹងជាបុគ្គលសាបសូន្យ ចាកបុណ្យយ៉ាងនេះ អាត្មាមិនមានសេចក្តីត្រូវការដោយទេយ្យធម៌នេះទេ ប៉ុន្តែអាត្មាទទួល ដើម្បីអនុគ្រោះដល់ពួកអ្នកតែម្យ៉ាង តាំងអំពីនោះមក ភិក្ខុនោះក៏ទទួលចីវរច្រើនផង ទទួលបិណ្ឌបាតច្រើនផង ទទួលសេនាសនៈច្រើនផង ទទួលគិលានប្បច្ចយភេសជ្ជបរិក្ខារច្រើនផង ។ កិរិយាធ្វើមុខស្រពោន ភាពនៃភិក្ខុធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តទៅនៃភិក្ខុកុហក ភាពនៃភិក្ខុកុហក ឯណាមានសភាពយ៉ាងនេះ នេះលោកហៅថា កុហនវត្ថុខាងការសេព ( បច្ច័យ ) ។

ការធ្វើឲ្យមហាជនវង្វេងដោយប្រការនោះៗ ដោយវាចា ដែលសម្តែងដល់ការសម្រេចឧត្តរិមនុស្សធម៌របស់ភិក្ខុ ដែលមានការប្រាថ្នាលាមកនោះឯង គប្បីជ្រាបថា ការកុហកដោយនិយាយកោស ដូចព្រះសារីបុត្តត្ថេរពោលថា

កុហនវត្ថុខាងការខ្សឹបជិត តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មាន

សេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ប្រាថ្នាសេចក្តីសរសើរថា អ្នកផងទាំងសរសើរអញយ៉ាងនេះ ក៏ពោលវាចាដែលអាស្រ័យអរិយធម៌ ពោលថា សមណៈណាទ្រទ្រង់ចីវរមានសភាពយ៉ាងនេះ សមណៈនោះមានសក្តិធំ ពោលថា សមណៈណា ទ្រទ្រង់បាត្រមានសភាពយ៉ាងនេះ ទ្រទ្រង់ផ្តិលជាវិការនៃលោហៈ ទ្រទ្រង់ធម្មក្រក ទ្រទ្រង់តម្រងទឹក ទ្រទ្រង់កូនសោរ ទ្រទ្រង់ស្បែកជើង ទ្រទ្រង់វត្ថពន្ធចង្កេះ ទ្រទ្រង់សំពត់អាយោគ សមណៈនោះមានសក្តិធំ ។ ពោលថា ឧបជ្ឈាយ៍របស់សមណៈណា មានសភាពយ៉ាងនេះ សមណៈនោះ មានសក្តិធំ ។ ពោលថា អាចារ្យរបស់សមណៈណា មានសភាពយ៉ាងនេះ ពួកភិក្ខុរបស់សមណៈណា មានសភាពយ៉ាងនេះ មានឧបជ្ឈាយ៍ស្មើគ្នា មានអាចារ្យស្មើគ្នា ជាមិត្ត មិត្តឃើញព្រមជាសម្លាញ់ សមណៈនោះ មានសក្តិធំ ។ ពោលថា សមណៈណា នៅក្នុងវិហារមានសភាពយ៉ាងនេះ សមណៈនោះមានសក្តិធំ ។ ពោលថា សមណៈណា នៅក្នុងបន្ទាមានសភាពយ៉ាងនេះ នៅក្នុងប្រាសាទ នៅក្នុងប្រាសាទមានកំពូល នៅក្នុងគុហា នៅក្នុងទីជ្រកកោន នៅក្នុងកុដិ នៅក្នុងផ្ទះមានកំពូល នៅក្នុងប៉ម នៅក្នុងរោង នៅក្នុងថែវ នៅក្នុងរោងឆាន់ នៅក្នុងបារាំ នៅជិតគល់ឈើ សមណៈនោះ មានសក្តិធំ ។ មួយទៀត សមណៈជាអ្នកស្រឡូតស្រឡាត់ពេក មានមុខស្រពោនក្រៃពេក ជាអ្នកកុហកក្រៃពេក រួសរាយក្រៃពេក ត្រូវគេសរសើរ ដោយអំណាចមាត់ ( របស់ខ្លួន ) ថា សមណៈនេះ បានវិហារសមាបត្តិទាំងឡាយដ៏ស្ងប់ស្ងាត់នេះ មានសភាព

យ៉ាងនេះ ពោលពាក្យប្រាកដដូច្នោះ ជាពាក្យដ៏ជ្រៅ លំបាកយល់ ដ៏ល្អិត កំបាំង ជាវាចាប្រកបដោយសុញ្ញតនិព្វាន ជាលោកុត្តរ ។ កិរិយាធ្វើមុខស្រពោន ភាពនៃភិក្ខុជាអ្នកធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តទៅនៃភិក្ខុកុហក ភាពនៃភិក្ខុកុហកឯណា មានសភាពយ៉ាងនេះ នេះលោកហៅថា កុហនវត្ថុខាងការខ្សឹបជិត ( និយាយកោស ) ។

ការធ្វើឲ្យប្រទ្បំដោយឥរិយាបថ ដែលធ្វើដើម្បីបំណងឲ្យអ្នកដទៃសរសើរខ្លួនរបស់ភិក្ខុដែលមានការប្រាថ្នាលាមកនោះឯង គប្បីជ្រាបថា កុហកអាស្រ័យឥរិយាបថ ដូចព្រះសារីបុត្តត្ថេរពោលថា

កុហនវត្ថុខាងឥរិយាបថ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ ហើយប្រាថ្នាសេចក្តីសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏រៀបចំទំនងដើរ រៀបចំទំនងឈរ ក៏រៀបចំទំនងអង្គុយ រៀបចំទំនងដេក ប្រុងប្រៀបហើយ ទើបដើរទៅ ប្រុងប្រៀបឈរ ប្រុងប្រៀបអង្គុយ ប្រុងប្រៀបសម្រេចការដេក ដើរទៅហាក់ដូចជាមានចិត្តតាំងមាំ ឈរហាក់ដូចជាមានចិត្តតាំងមាំ អង្គុយហាក់ដូចជាមានចិត្តតាំងមាំ សម្រេចការដេកហាក់ដូចជាមានចិត្តតាំងមាំ ហាក់ដូចជាចូលឈាន ក្នុងទីចំពោះមុខ ( នៃអ្នកផង ) ។ ការតាំងទុកខាងដើម អាការនៃការតាំងទុក ការរៀបចំឥរិយាបថ កិរិយាធ្វើមុខស្រពោន ភាពនៃភិក្ខុអ្នកធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តទៅនៃភិក្ខុកុហក ភាពនៃភិក្ខុកុហកឯណា មានសភាពយ៉ាងនេះ នេះលោកហៅថា កុហនវត្ថុខាង

*ឥរិយាបថ ដូច្នេះ ។*

*ក្នុងបទទាំងនោះ បទថា* **បច្ចយប្បដិសេវនសង្ខាតេន** *បានដល់ បណ្ឌិត គប្បីកាន់យក យ៉ាងនេះថា ការសេពបច្ច័យ គឺដោយការសេពបច្ច័យ ។ បទថា* **សាមន្តជប្បិតេន** *បានដល់ ដោយការពោលក្នុងទីជិត ។ បទថា* **ឥរិយាបថស្ស** *បានដល់ ឥរិយាបថទាំង ៤ ។ បទថា* **អដ្ឋបនា** *បានដល់ ការផ្តើមឥរិយាបថ ឬការតាំងឥរិយាបថ ដោយការយកចិត្តទុកដាក់ ។ បទថា* **ឋបនា** *បានដល់ អាការដែលតម្កល់ឥរិយាបថ ។ បទថា* **សណ្ឋបនា** *បានដល់ ការរៀបចំឥរិយាបថ ។ មានពាក្យអធិប្បាយថា ការធ្វើឥរិយាបថឲ្យគួរជាទីជ្រះថ្លា ។ បទថា* **ភាកុដិកា** *បានដល់ ការធ្វើមុខស្រពោនដោយការសម្តែងថា ខ្លួនជាអ្នកមានសេចក្តីព្យាយាមតឹងតែង អធិប្បាយថា ធ្វើមុខស្រពោន ។ ការធ្វើមុខស្រពោនរបស់បុគ្គលនោះ មានជាប្រក្រតី ហេតុនោះ បុគ្គលនោះ ឈ្មោះថា* **ភាកុដិកា** *ភាវៈនៃបុគ្គលមានមុខស្រពោន ឈ្មោះថា* **ភាកុដិយំ** ។ *ការធ្វើឲ្យវង្វេង ( ប្រឡំ ) ឈ្មោះថា* **កុហនា** ។ *កិរិយានៃការកុហក ឈ្មោះថា* **កុហាយនា** ។ *ភាវៈនៃបុគ្គលដែលកុហក ឈ្មោះថា* **កុហិតត្តំ** ។

*[ ១១៣ ] ក្នុងនិទ្ទេសនៃការរួសរាយ ការដែលភិក្ខុឃើញពួកមនុស្សមកកាន់វិហារ ហើយពោលរាក់ទាក់មុនយ៉ាងនេះថា អ្នកដ៏ចម្រើន អ្នកទាំងឡាយ មកដើម្បីប្រយោជន៍អ្វី មកដើម្បីនិមន្តភិក្ខុទាំងឡាយឬ បើអ្នកទាំងឡាយមកដោយបំណងយ៉ាងនេះសោត ចូរអ្នកត្រឡប់ អាត្មានឹងនាំពួកភិក្ខុ*

ទៅតាមក្រោយ ឈ្មោះថា **អាលបនា** ។ ម្យ៉ាងទៀត ការពោលណែនាំបង្អោនចូលមករកខ្លួនយ៉ាងនេះថា អាត្មាឈ្មោះតិស្សៈ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងអាត្មា មហាមាត្យរបស់ព្រះរាជានោះៗ ក៏ជ្រះថ្លាក្នុងអាត្មា ឈ្មោះថា **អាលបនា** ។ កាលត្រូវសួរហើយពោល មានប្រការតាមដែលពោលហើយនោះឯង ឈ្មោះថា **លបនា** ។ ការដែលភិក្ខុខ្លាចគហបតីទាំងឡាយធុញទ្រាន់ និយាយពាក្យល្អៗ រមែងឲ្យឱកាសដល់គហបតី ឈ្មោះថា **សល្លបនា**។ ការពោលសរសើរ ឲ្យខ្ពស់ឡើងយ៉ាងនេះថា កុដុម្ពិកៈជាធំ នាយសំពៅជាធំ ទានបតីជាធំ ឈ្មោះថា **ឧល្លបនា** ។ ការពោលធ្វើឲ្យខ្ពស់ដោយចំណែកទាំងពួង ឈ្មោះថា **សមុល្លបនា** ។ ការនិយាយពាក្យផ្អែម ចងទុកឲ្យធ្ងន់ឡើងយ៉ាងនេះថា ឧបាសកទាំងឡាយ ក្នុងកាលមុនក្នុងកាលបែបនេះ ពួកអ្នករមែងឲ្យទាន ឥឡូវនេះ ពួកអ្នកមិនឲ្យទានឬ រហូតពួកមនុស្សឆ្លើយថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងឲ្យ តែមិនទាន់បានឱកាសជាដើម ឈ្មោះថា **ឧន្នហនា** មានពាក្យអធិប្បាយថា និយាយចងជើង ។ ម្យ៉ាងទៀត ភិក្ខុឃើញបុគ្គលកាន់អំពៅមក ទើបសួរថា អើ ឧបាសក អំពៅនេះអ្នកបានមកពីណា ឧបាសកឆ្លើយថា ខ្ញុំយកមកពីចម្ការអំពៅ ភិក្ខុនោះសួរថា អំពៅក្នុងចម្ការនោះប្រហែលជាមានរសផ្អែម ។ ឧបាសកក៏ពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ទំពាអំពៅនេះនឹងបានដឹង ។ ភិក្ខុនោះពោលថា ឧបាសក បើអាត្មាពោលថា ចូរអ្នកទាំងឡាយប្រគេនអំពៅដល់ភិក្ខុ ដូច្នេះ រមែងមិនគួរ ។ ការពោលចងជើងរបស់ភិក្ខុដែលពោលកៀងគរបែបនេះឯណា នោះ

ឈ្មោះថា **ឧន្នហនា** ។

ការនិយាយកៀងគរ ( បញ្ចិតបញ្ចៀង ) រឿយៗដោយចំណែកទាំងពួង ឈ្មោះថា **សមុន្នហនា** ។ បទថា **ឧក្លាចនា** បានដល់ ការនិយាយលើកឡើងឲ្យល្អយ៉ាងនេះថា ត្រកូលនេះរមែងស្គាល់អាត្មាល្អនោះឯង បើត្រកូលនេះមានទេយ្យធម៌សោត ក៏នឹងប្រគេនដល់អាត្មា ឈ្មោះថា **ឧក្លាចនា** ។ មានពាក្យអធិប្បាយថា និយាយឲ្យប្រាកដឡើង ។ ក្នុងសេចក្តីនេះ គប្បីពោលដល់រឿងនាងតេលកន្ទរិកាដូចតទៅ

បានឮថា ភិក្ខុ ២ រូប ចូលទៅកាន់ស្រុកមួយ អង្គុយត្រង់សាលាធទាន ឃើញកុមារិកាម្នាក់ ទើបហៅមក ។ លំដាប់នោះ ភិក្ខុមួយរូប ក៏សួរភិក្ខុមួយរូបទៀតថា បពិត្រលោកម្ចាស់ កុមារិកានេះជាកូនរបស់អ្នកណា ភិក្ខុនោះក៏ពោលសរសើរដោយពាក្យថា អាវុសោ នាងជាកូនស្រីរបស់នាងតេលកន្ទរិកា ដែលជាឧបដ្ឋាយិការបស់ខ្ញុំ មាតារបស់នាង កាលខ្ញុំទៅកាន់ផ្ទះ នឹងប្រគេនទឹកដោះថ្លា រមែងប្រគេនទាំងក្អម សូម្បីកុមារិកានេះ ក៏រមែងប្រគេនទឹកដោះថ្លាទាំងក្អម ដូចមាតានោះឯង ។

ការពោលសរសើរម្តងហើយម្តងទៀត ដោយចំណែកទាំងអស់ ឈ្មោះថា **សមុក្លាចនា** ។ បទថា **អនុប្បិយភាណិតា** បានដល់ ការពោលវាចាដែលជាទីស្រឡាញ់រឿយៗ មិនដាក់ចិត្តក្នុងពាក្យដែលសមគួរដល់សច្ចៈ ឬសមគួរដល់ធម៌ឡើយ ។ បទថា **ចាដុកម្យតា** បានដល់ ការប្រព្រឹត្តឱនលំទោន គឺការប្រព្រឹត្តដាក់ខ្លួនឲ្យទាប ។ បទថា **មុគ្គសូប្យតា** បានដល់

វាចាដូចគ្នានឹងសម្លសណ្តែកបាយ ។ ដូចកាលបុគ្គលទាំងឡាយ ស្ងោរសណ្តែកបាយ សណ្តែកចំណែកតិចប៉ុណ្ណោះ រមែងមិនឆ្អិន ចំណែកដ៏សេសឆ្អិនយ៉ាងណា ពាក្យរបស់បុគ្គលណាតិចប៉ុណ្ណោះជាពាក្យពិត ពាក្យដ៏សេសជាពាក្យមិនពិត ក៏យ៉ាងនោះ បុគ្គលនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា ការប្រើវាចាដូចសម្លសណ្តែកបាយ ដូច្នេះ ។ ភាពនៃបុគ្គលមានវាចាលាយលេងលាយមែនដូចគ្នានឹងសម្លសណ្តែកបាយនោះ ឈ្មោះថា **មុគ្គសូប្យតា** ។ ភាវៈនៃបុគ្គល ដែលទទួលចិញ្ចឹមក្មេង ឈ្មោះថា **ចារិភដយតា** ។ ពិតហើយ បុគ្គលណាមើលថែទារកក្នុងត្រកូល គឺពរដោយចង្កេះ ឬបញ្ជិះក ដូចមេដោះក្នុងត្រកូល ការងាររបស់អ្នកមើលថែក្មេងនោះ ឈ្មោះថា **ចារិភដយ** ។ ភាពនៃបុគ្គលអ្នកចិញ្ចឹមក្មេង ឈ្មោះថា **ចារិភដយតា** ។

[ ១១៤ ] ក្នុងនិទ្ទេសនៃការធ្វើនូវនិមិត្ត បទថា **និមិត្តំ** បានដល់ កាយកម្ម វចីកម្មឯណានីមួយ ដែលនាំឲ្យបុគ្គលពួកដទៃប្រគេនបច្ច័យ ។ បទថា **និមិត្តកម្មំ** បានដល់ ភាពជាអ្នកឈ្លាសក្នុងការធ្វើនិមិត្ត ។ ក្នុងសេចក្តីនេះ មានរឿងដូចតទៅ

បានឮថា ភិក្ខុមួយរូប សមាទានបិណ្ឌបាតជាវត្ត ទៅដល់ទ្វារផ្ទះជាងមាសជាឧបដ្ឋាក ជាងមាសសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការអ្វី ដូច្នេះ ភិក្ខុនោះវែកចីវរ ដកដៃចេញ ហើយសម្តែងអាការចិញ្ចាំដោយកាំបិត ។ ជាងមាសប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំយល់ហើយ ទើបបានធ្វើប្រគេន ។ បទថា **ឱភាសោ** បានដល់ ពោលពាក្យដែលទាក់ទងដោយ

បច្ច័យ ។ បទថា **ឱភាសកម្មំ** បានដល់ ការដែលភិក្ខុឃើញអ្នកចិញ្ចឹមកូនគោ ហើយសួរថា កូនគោទាំងនេះ ជាកូនគោទឹកដោះ ឬជាកូនគោតក្កៈ កាលក្មេងទាំងនោះពោលថា បពិត្រលោកម្ចាស់ ជាកូនគោទឹកដោះ ដូច្នេះ ធ្វើនូវការនិយាយទាក់ទងដោយបច្ច័យ ដោយន័យថា ប្រហែលជាមិនមែនកូនគោទឹកដោះទេដឹង បើជាកូនគោទឹកដោះ ពួកភិក្ខុគប្បីបានទឹកដោះខ្លះ កុមារទាំងនោះ ទៅប្រាប់មាតាបិតា ឲ្យប្រគេនទឹកដោះស្រស់ជាដើម ។ បទថា **សាមន្តជប្បា** បានដល់ ការនិយាយបញ្ជិតបញ្ជៀង ។ ក្នុងសេចក្តីនេះ គប្បីពោលរឿងព្រះថេរៈអ្នករៀនជាតកដូចតទៅ

បានឮថា ព្រះថេរៈរៀនជាតកមួយរូប ប្រាថ្នានឹងឆាន់ភត្ត ចូលទៅកាន់ផ្ទះឧបដ្ឋាយិកាហើយអង្គុយ ឧបដ្ឋាយិកានោះមិនបំណងនឹងប្រគេនរបស់ណាមួយ ទើបពោលថា អង្ករមិនមាន ដូច្នេះហើយ ទៅកាន់ផ្ទះរបស់អ្នកជិតខាងធ្វើហាក់ដូចជាទៅខ្ចីអង្ករមក ។ ពេលនោះ ភិក្ខុចូលទៅខាងក្នុងបន្ទប់សម្លឹងមើលឃើញអំពៅផ្អែកត្រង់ជ្រុងទ្វារ ឃើញស្ករអំពៅត្រង់កាជនៈ ឃើញត្រីងៀតក្នុងកំប្រោង ឃើញអង្ករក្នុងថ្លាង ឃើញសប្បិក្នុងក្អមហើយ ក៏ចេញមកអង្គុយ ។

ស្ត្រីមេផ្ទះមកហើយ ក៏ពោលថា ខ្ញុំមិនបានអង្ករ ដូច្នេះ ។ ព្រះថេរៈពោលថា អើ ឧបាសិកា អាត្មាភាពប្រផ្នូលមុនហើយថា ថ្ងៃនេះ ភិក្ខាប្រហែលជាមិនសម្រេច ស្រីនោះសួរថា បពិត្រលោកម្ចាស់ តើប្រផ្នូលអ្វី ដូច្នេះ ព្រះថេរៈពោលថា អាត្មាឃើញពស់ ដូចគ្នានឹងអំពៅដែលទុកត្រង់ជ្រុងទ្វារ

គិតថា នឹងវាយវា កាលពិនិត្យមើលឃើញដុំថ្ម ដូចគ្នានឹងដុំស្ករអំពៅដែលទុកក្នុងភាជន៍ ឃើញពពារពស់ដែលបើកចេញមក ព្រោះគ្រវែងដោយដុំដី ដូចគ្នានឹងត្រីឆៀតដែលទុកក្នុងកំប្រោង កាលពស់ប្រុងនឹងខាំដុំដីឃើញធ្មេញវា ដូចអង្ករក្នុងថ្ងាង ពេលនោះ ពស់ខឹងក្រោធ ឃើញទឹកមាត់ដែលលាយដោយពិសចេញអំពីមាត់ ដូចគ្នានឹងសប្បិដែលទុកក្នុងក្អម ។ ស្រីមេផ្ទះនោះគិតថា អញមិនអាចបញ្ឆោតសមណៈត្រងោលនេះបាន ទើបប្រគេនទឹកអំពៅជាំបាយ មួយអន្ទើដោយសប្បិ ស្ករអំពៅ និងត្រី ដូច្នេះ ។ ការនិយាយបញ្ចិតបញ្ចៀងយ៉ាងនេះ គប្បីជ្រាបថា **សាមន្តជប្បា** ។ បទថា **បរិកថា** បានដល់ ការពោលដោយជុំវិញ ដោយប្រការដែលខ្លួនគប្បីបានរបស់នោះ ។

[ ១១៥ ] ក្នុងនិទ្ទេសការធ្វើនូវសេចក្តីគំរាម បទថា **អក្កោសនា** បានដល់ ការជេរដោយអក្កោសវត្ថុ ១០ ប្រការ ។ បទថា **វម្ភនា** បានដល់ ការពោលកំហែង ។ បទថា **គរហណា** បានដល់ ការពោលលើកទោសឡើងដោយន័យថា បុគ្គលនោះមិនមានសទ្ធា មិនគួរជ្រះថ្លាជាដើម ។ បទថា **ឧក្ខេបនា** បានដល់ ការប្រើវាចាពោលតិះដៀលថា លោកកុំពោលវាចាបែបនេះ ក្នុងទីនេះ ។ ការពោលតិះដៀលដែលប្រព្រឹត្តទៅដោយវត្ថុប្រព្រឹត្តទៅដោយហេតុ ដោយចំណែកទាំងពួង ឈ្មោះថា **សមុក្ខេបនា** ។

ម្យ៉ាងទៀត ការដែលឃើញមនុស្សមិនប្រគេនហើយ ក្លែងនិយាយលើកតម្កើងយ៉ាងនេះថា ឱទានបតី ដូច្នេះ ឈ្មោះថា **ឧក្ខេបនា** ។ ការនិយាយលើកតម្កើងឲ្យច្រើនឡើង យ៉ាងនេះថា ឱទានបតីជាធំ ដូច្នេះ ឈ្មោះថា

**សមុក្កេបនា** ។ ការនិយាយចំអកយ៉ាងនេះថា ជីវិតរបស់អ្នក ស៊ីពូជជាអាហារ ដូច្នេះ ឈ្មោះថា **ខិបនា** ។ ការចំអកឲ្យក្រៃលែងជាងនេះថា អ្នកទាំងឡាយ រមែងពោលបុគ្គលដែលឲ្យវាចាថា មិនមាន ដូច្នេះ ដល់បុគ្គលទាំងពួងអស់កាលជានិច្ចថា មិនមែនទាយក បានដូចម្តេច ឈ្មោះថា **សង្ខិបនា** ។ ការនិយាយចំអកថា មិនមែនទាយក ឬនិយាយតិះដៀលរឿងវិនាស ឈ្មោះថា **ចាបនា** ។ ការនិយាយឲ្យខូចកេរ្តិ៍ឈ្មោះ ដោយចំណែកទាំងពួង ឈ្មោះថា **សម្បាបនា** ។ ការនាំរឿងទៅតិះដៀលអំពីផ្ទះនោះទៅកាន់ផ្ទះនេះ អំពីស្រុកនោះទៅកាន់ស្រុកនេះ អំពីជនបទនោះ ទៅកាន់ជនបទនេះ ដោយគិតថា បុគ្គលរមែងឲ្យដល់អញយ៉ាងនេះ ព្រោះការខ្លាចអំពីការតិះដៀលរបស់អញ ឈ្មោះថា **អវណ្ណហារិកា** ។ ការពោលវាចាពីរោះចំពោះមុខ ក្រោយខ្នងពោលនិន្ទា ឈ្មោះថា **បរិបិដ្ឋិមំសិកតា** ។ ពិតហើយវាចានេះ ដូចបុគ្គលមិនហ៊ានចូលទៅក្នុងទីចំពោះមុខបុគ្គលនោះ ខាំសាច់ខ្នងខាងក្រោយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់វាចាបែបនេះថា **បរិបិដ្ឋិមំសិកតា** ។ បទថា **អយំ វុច្ចតិ និប្បេសិកតា** បានដល់ ការជេរជាដើមនេះ ព្រះមានព្រះភាគត្រាស់ហៅថា ការនិយាយ ការធ្វើនូវសេចក្តីគំរាម ព្រោះលុបនូវសេចក្តីល្អរបស់បុគ្គលដទៃ ដូចបោសរបស់ដោយអំបោសបោល ឬព្រោះជាការបុកបំបែកនូវគុណរបស់អ្នកដទៃ ស្វែងរកលាភដូចបុកគន្ធជាតិរករបស់ក្រអូបយ៉ាងនោះ ។

[ ១១៦ ] ក្នុងនិទ្ទេសនៃការទាក់លាភដោយលាភ ការស្វែងរក ឈ្មោះ

ថា **និជិគីសនតា** ។ បទថា **ឥតោ លទ្ធំ** បានដល់ ដែលខ្លួនបានហើយ អំពីផ្ទះនេះ ។ បទថា **អមុត្រ** បានដល់ ក្នុងផ្ទះឈ្មោះនោះ ។ បទថា **ឯដ្ឋិ** បានដល់ សេចក្តីត្រូវការ ។ បទថា **គវេដ្ឋិ** បានដល់ ការស្វែងរក ។ បទថា **បរិយេដ្ឋិ** បានដល់ ការស្វែងរករឿយៗ ។ ក្នុងរឿងនេះ បណ្ឌិតគប្បីពោលរឿង របស់ភិក្ខុអ្នកឲ្យភិក្ខុដែលខ្លួនបានហើយ ចាប់តាំងអំពីដើមដល់ទារកក្នុងត្រកូលក្នុងទីនោះៗ ហើយទើបបាននូវទឹកដោះស្រស់ និងបបរក្នុងទីបំផុត ហើយទើបទៅ ។ បទថា **ឯសនា** ជាដើម ជាវេវចនៈរបស់បទថា **ឯដ្ឋិ** ជាដើម ព្រោះហេតុនោះ ក្នុងទីនេះ គប្បីជ្រាបការប្រកបយ៉ាងនេះថា បទថា **ឯដ្ឋិ** ស្មើគ្នានឹង **ឯសនា** បទថា **គវេដ្ឋិ** ស្មើគ្នានឹង **គវេសនា** បទថា **បរិយេដ្ឋិ** ស្មើគ្នានឹង **បរិយេសនា** ដូច្នេះ ។

[ ១១៧ ] ក្នុងនិទ្ទេសនៃសេចក្តីប្រកាន់ថា អញប្រសើរជាងគេ បទថា **ជាតិយា** បានដល់ ដល់ព្រមដោយជាតិ មានភាពជាក្សត្រជាដើម ។ បទថា **គោត្តេន** បានដល់ ដោយគោត្តដ៏ឧត្តម មានគោតមគោត្តជាដើម ។ បទថា **កោលបុត្តិយេន** បានដល់ ដោយភាពជាអ្នកមានត្រកូលធំ ។ បទថា **វណ្ណ-បោក្ខរតាយ** បានដល់ ដោយភាពជាអ្នកមានសរីរៈ ដែលដល់ព្រមដោយវណ្ណៈ ។ ពិតហើយ សរីរៈ ហៅថា **បោក្ខរ** អធិប្បាយថា ព្រោះបុគ្គលនោះ ជាអ្នកមានរូបស្អាតដោយវណ្ណសម្បត្តិ ។ បទថា **ធនេន** ជាដើម មានអត្ថងាយយល់ហើយ ។ ក្នុងបទថា **មានំ ជប្បេតិ** បានដល់ ឲ្យមានះប្រព្រឹត្តទៅ គឺធ្វើនូវការប្រកាន់ខ្លួនថា អញប្រសើរជាងគេ ដោយវត្ថុណា

មួយ ក្នុងវត្ថុមានជាតិជាដើមនោះ ។

[ ១១៨ ] ក្នុងនិទ្ទេសនៃសេចក្តីប្រកាន់ថា អញស្មើនឹងគេ បទថា **មានំ ជប្បេតិ** បានដល់ រមែងឲ្យនូវមានះប្រព្រឹត្តទៅថា អញស្មើគ្នាដោយវត្ថុណាមួយ ក្នុងវត្ថុមានជាតិជាដើមនោះឯង ។ នេះជាសេចក្តីផ្សេងគ្នាដោយអត្ថក្នុងនិទ្ទេសនេះ តែក្នុងព្រះបាលីមិនមានការធ្វើពាក្យអធិប្បាយដែលផ្សេងគ្នា ។

[ ១១៩ ] ក្នុងនិទ្ទេសនៃសេចក្តីប្រកាន់ថា អញថោកទាបជាងគេ បទថា **ឱមានំ ជប្បេតិ** បានដល់ ញ៉ាំងមានះឲ្យប្រព្រឹត្តទៅក្នុងចំណែកទាប ។ មានះដ៏លាមកថោកទាប ឈ្មោះថា **ឱមានោ** ។ បទថា **ឱមញ្ញនា ឱមញ្ញិតត្តំ** ជាពាក្យសម្តែងភាវៈនៃកិរិយាអាការ ។ បទថា **ហីឡនា** បានដល់ ការមើលងាយខ្លួនឯង ។ បទថា **ឱហីឡនា** បានដល់ កិរិយាមើលងាយខ្លួនឯងក្រៃលែង ។ បទថា **ឱហីឡតត្តំ** បានដល់ ជាការសម្តែងភាវៈកិរិយាដែលស្អប់ខ្ពើមខ្លួនឯងក្រៃលែងនោះឯង ។ បទថា **អត្តុញ្ញា** បានដល់ ការយល់ថា ខ្លួនថោកទាប ។ បទថា **អត្តាវញ្ញា** បានដល់ ការមើលងាយខ្លួនឯង ។ បទថា **អត្តបរិភវោ** បានដល់ ការមើលងាយខ្លួនឯង ដោយសម្គាល់ថា ការមើលងាយកើតឡើងដល់អញព្រោះសម្បត្តិ មានជាតិជាដើមនោះឯង ។ មានះទាំង ៣ នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃវត្ថុ មានជាតិជាដើម មិនបានអាស្រ័យបុគ្គលដូចពណ៌នាមក ដូច្នេះ ។

ក្នុងមានះទាំង ៣ នោះ មានះនីមួយៗ រមែងកើតឡើងដល់បុគ្គលដែលមានសេចក្តីសម្គាល់ថា ខ្លួនល្អជាងគេ ស្មើគេ ទាបជាងគេទាំង ៣ ។ ក្នុង

មានះទាំងនោះ មានះថា អាត្មាអញជាបុគ្គលប្រសើរជាងគេ ជាមានះតាមសេចក្តីពិត របស់បុគ្គលដែលប្រសើរជាងគេ ជាមានះដែលមិនពិត របស់បុគ្គលដ៏សេស ។ មានះថា អញស្មើគេ ជាមានះតាមសេចក្តីពិត របស់បុគ្គលដែលស្មើគេនោះឯង ជាមានះដែលមិនពិត របស់បុគ្គលដ៏សេស ។ មានះថា អញជាបុគ្គលថោកទាបជាងគេ ជាមានះតាមសេចក្តីពិត របស់បុគ្គលដែលថោកទាបជាងគេនោះឯង ជាមានះដែលមិនពិត របស់បុគ្គលដ៏សេស ។

[ ១២០ ] មានះ ៩ យ៉ាង បទថា **តត្ថ កតមោ សេយ្យស្ស សេយ្យោហមស្មិ** ជាដើម ព្រះមានព្រះភាគត្រាស់អាស្រ័យបុគ្គល ។ ក្នុងមានះទាំងនោះ មានះ ៣ យ៉ាង រមែងកើតដល់បុគ្គលម្នាក់បាន ។

បណ្តាបទទាំងនោះ បទថា **ឧបាតិ** បានដល់ រមែងតាំងទុក ។ បទថា **តំ និស្សាយ** បានដល់ អាស្រ័យការប្រកាន់ខ្លួនដោយភាពជាបុគ្គលប្រសើរជាងគេនោះ ។ ក្នុងការប្រសើរជាងគេនេះ មានះថា បុគ្គលប្រសើរជាងគេ ជាអញប្រសើរជាងគេ រមែងកើតដល់ព្រះរាជាទាំងឡាយ និងបព្វជិតទាំងឡាយ ។ ពិតហើយ ព្រះរាជារមែងធ្វើមានះនេះថា បុគ្គលណាមួយស្មើអញ ដោយដែន ឬដោយទ្រព្យ ឬដោយពាហនៈ មានឬ ដូច្នេះ សូម្បីបព្វជិតក៏ធ្វើមានះនេះថា បុគ្គលណាមួយ ដូចគ្នានឹងអញដោយសីល និងធុតង្គជាដើម មានឬ ដូច្នេះ ។

[ ១២១ ] មានះថា បុគ្គលប្រសើរជាងគេ ជាអញស្មើនឹងគេ ក៏រមែង

កើតឡើងដល់បុគ្គលនោះឯង ។ ពិតហើយ ព្រះរាជា រមែងធ្វើមានះនេះថា អញ និងព្រះរាជាពួកដទៃ មានអ្វីផ្សេងគ្នាដោយដែន ឬដោយទ្រព្យ ដោយពាហនៈ សូម្បីបព្វជិតក៏រមែងធ្វើមានះនេះថា អញ និងភិក្ខុដទៃ មានអ្វីដែលផ្សេងគ្នា ដោយគុណទាំងឡាយ មានសីល និងធុតង្គជាដើម ។

[ ១២២ ] មានះក្នុងបទថា បុគ្គលប្រសើរជាងគេ ថាអញថោកទាបជាងគេ រមែងកើតឡើងដល់ជនទាំងនោះឯង ។ ពិតហើយ ដែន ទ្រព្យពាហនៈជាដើម រមែងមិនសម្បូរដល់ព្រះរាជាណា ព្រះរាជានោះ រមែងធ្វើហេតុត្រឹមតែអាស្រ័យសេចក្ដីសុខ ដែលជាវោហារថា ព្រះរាជារបស់អញដូច្នេះនោះឯង ឲ្យជាមានះថា អញ ឈ្មោះថា ជាព្រះរាជាបានដូចម្ដេច ។ សូម្បីបព្វជិត មានលាភសក្ការៈតិច រមែងធ្វើត្រឹមតែពាក្យថា អញជាព្រះធម្មកថិក អញជាពហូសូត អញជាមហាថេរៈនោះឯង ឲ្យជាមានះថា អញជាបុគ្គលមិនមានលាភសក្ការៈ ឈ្មោះថា ជាធម្មកថិកបានដូចម្ដេច ជាពហូសូតបានដូចម្ដេច ជាមហាថេរៈបានដូចម្ដេច ។

[ ១២៣-១២៥ ] មានះថា បុគ្គលស្មើនឹងគេ ថាអញប្រសើរជាងគេជាដើម រមែងកើតឡើងដល់បុគ្គលទាំងឡាយ មានអមាត្យជាដើម ។ ពិតហើយ អមាត្យរមែងធ្វើមានះទាំងឡាយថា បុគ្គលណា ជារាជបុរសដទៃដូចអញដោយដែន ឬដោយភោគៈ យានពាហនៈជាដើម មានឬ ដូច្នេះ ឬថា របស់អញ និងអមាត្យពួកដទៃ មានអ្វីផ្សេងគ្នា ឬថា អញមានឈ្មោះថាត្រឹមតែអមាត្យប៉ុណ្ណោះ សូម្បីវត្ថុត្រឹមតែរបស់បរិភោគ និងសម្លៀកបំពាក់

របស់អញក៏មិនមាន ឬអញឈ្មោះថា ជាអាមាត្យបានដូចម្ដេច ដូច្នេះ ។

[ ១២៦-១២៨ ] មានះថា បុគ្គលថោកទាបជាងគេ ថាអញប្រសើរជាងគេជាដើម រមែងកើតដល់ជនទាំងឡាយ មានទាសៈជាដើម ។ ពិតហើយ ទាសៈ រមែងធ្វើមានះទាំងឡាយថា អ្នកណា ឈ្មោះថា ទាសៈដទៃស្មើអញខាងមាតា ឬបិតា មានឬ អ្នកដទៃៗ មិនអាចរស់នៅទើបជាទាសៈ ព្រោះអាស្រ័យផ្ទៃជាហេតុ ឯអញ ឈ្មោះថា ជាបុគ្គលប្រសើរជាងគេ ព្រោះមកតាមបវេណី ឬថា អញ និងទាសៈឈ្មោះនោះ មានអ្វីដែលផ្សេងគ្នា ដោយភាពជាទាសៈបរិសុទ្ធទាំង ២ ចំណែក ព្រោះជាទាសៈមកតាមបវេណី ឬថា អញចូលដល់ភាពជាទាសៈ ដោយអំណាចនៃផ្ទៃ តែតំណែងទាសៈរបស់អញ មិនមានតាំងអំពីមាតាបិតា អញ ឈ្មោះថា ជាទាសៈបានដូចម្ដេច ។ ទាសៈ រមែងធ្វើមានះយ៉ាងណា សូម្បីពួកអ្នកចាក់សំរាមនិងមនុស្សចណ្ឌាលជាដើម ក៏រមែងធ្វើមានះទាំងឡាយនេះ យ៉ាងនោះឯង ។

ម្យ៉ាងទៀត ក្នុងមានះទាំងនោះ មានះដែលកើតឡើងក្នុងពាក្យថា បុគ្គលប្រសើរជាងគេ ថាអញប្រសើរជាងគេ ប៉ុណ្ណោះ ជាមានះតាមសេចក្ដីពិត មានះ ២ យ៉ាងក្រៅអំពីនេះ មិនមែនតាមសេចក្ដីពិត ។ មានះដែលកើតឡើងក្នុងពាក្យថា បុគ្គលស្មើនឹងគេថាអញស្មើនឹងគេ និងក្នុងពាក្យថា បុគ្គលថោកទាបជាងគេ ថាអញថោកទាបជាងគេប៉ុណ្ណោះ ជាមានះតាមសេចក្ដីពិត មានះ ២ ក្រៅអំពីនេះ មិនមែនមានះតាមសេចក្ដីពិត ។ ក្នុងមានះទាំងនោះ មានះដែលកើតឡើងតាមសេចក្ដីពិត ជាធម៌ដែលអរហត្តមគ្គ គប្បីសម្លាប់

មានះដែលមិនពិត ជាធម៌ដែលសោតាបត្តិមគ្គ គប្បីសម្លាប់ ។

[ ១២៩ ] ព្រះសាស្តា កាលត្រាស់នូវមានះទាំងឡាយ ដែលប្រព្រឹត្តទៅដោយវត្ថុយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងមានះដែលកើតឡើង ដែលមិនមានវត្ថុ ទើបត្រាស់ពាក្យថា **តត្ថ កតមោ មានោ** ដូច្នេះជាដើម ។

[ ១៣០ ] ក្នុងនិទ្ទេសនៃសេចក្តីមើលងាយគេ ព្រះមានព្រះភាគ មិនកាន់យកបុគ្គល ដោយអំណាចនៃភាពជាបុគ្គលប្រសើរជាដើម តែទ្រង់ចង្អុលបង្ហាញដោយអំណាចនៃវត្ថុ មានជាតិជាដើមនោះឯង ។ បណ្តាបទទាំងនោះ បទថា **អតិមញ្ញតិ** បានដល់ រមែងសម្គាល់ខ្លួនក្រៃលែងថា បុគ្គលដូចគ្នានឹងអញដោយជាតិជាដើម រមែងមិនមាន ។

[ ១៣១ ] ក្នុងនិទ្ទេសនៃសេចក្តីប្រកាន់ក្រៃលែង ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា **យោ ឯវរូបោ** ដើម្បីសម្តែងថា មានះដែលកើតឡើងថា បុគ្គលនេះក្នុងកាលមុន ជាបុគ្គលស្មើអញ ក្នុងឥឡូវនេះ អញប្រសើរជាង បុគ្គលនេះ ថោកទាបជាងអញ ដូច្នេះ ឈ្មោះថា សេចក្តីប្រកាន់ក្រៃលែង ព្រោះប្រៀបធៀបមានះថា ស្មើគ្នាដែលមានក្នុងកាលមុន ដូចមានការៈបន្ថែមឡើង ។

[ ១៣២ ] ក្នុងនិទ្ទេសនៃសេចក្តីប្រកាន់ថោកថយ ដូចគ្នានឹងនិទ្ទេសនៃបុគ្គលថោកទាបជាងគេនោះឯង ។ មានះថា អញជាបុគ្គលថោកទាបជាងគេនោះ ព្រះមានព្រះភាគត្រាស់ដោយអំណាចវេនេយ្យបុគ្គល មានះនេះ ឈ្មោះថា **ឱមានោ** ។ម្យ៉ាងទៀត ក្នុងមានះនេះ បណ្ឌិតគប្បីជ្រាបថា មានះនេះឈ្មោះថា **ឱមានោ** ដោយអំណាចនៃការប្រព្រឹត្តទៅ ដោយធ្វើខ្លួនឲ្យទាប

យ៉ាងនេះថា ឯងមានជាតិ តែជាតិរបស់ឯងដូចជាតិរបស់ក្អែក ឯងមានគោត្ត តែគោត្តរបស់ឯង ដូចគោត្តរបស់មនុស្សចណ្ឌាល ឯងមានសំឡេង តែសំឡេងរបស់ឯង ដូចសំឡេងក្អែក ដូច្នេះ ។

[ ១៣៣ ] ក្នុងនិទ្ទេសនៃសេចក្តីប្រកាន់លើសលុប បទថា **អប្បត្តេ បត្តសញ្ញិតា** បានដល់ កាលដែលខ្លួនមិនទាន់ត្រាស់ដឹងសច្ចៈ ៤ សម្គាល់ថា ខ្លួនសម្រេចហើយ ។ បទថា **អកតេ** បានដល់ ក្នុងកិច្ចដែលគប្បីធ្វើដោយមគ្គ ៤ ដែលខ្លួនមិនទាន់បានធ្វើហើយ ។ បទថា **អនធិគតេ** បានដល់ ក្នុងសច្ចៈ ៤ ដែលខ្លួនមិនទាន់ត្រាស់ដឹង ។ បទថា **អសច្ឆិកតេ** បានដល់ ក្នុងធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យប្រចក្សដោយអរហត្តមគ្គ ។ បទថា **អយំ វុច្ចតិ អធិមានោ** នេះ ព្រះមានព្រះភាគត្រាស់ហៅថា ការសម្គាល់ថា បានសម្រេចធម៌លើសលុបហើយ ។

សួរថា ការសម្គាល់ខ្លួនថា បានធម៌ សម្រេចធម៌លើសលុបនេះ រមែងកើតដល់អ្នកណា មិនកើតដល់អ្នកណា ឆ្លើយថា មិនកើតដល់ព្រះអរិយសាវក ។ ពិតហើយ ព្រះអរិយសាវកនោះ មានសោមនស្សដែលកើតឡើងល្អហើយ ដោយការពិចារណាមគ្គ ផល និព្វាន កិលេសដែលលះហើយ និងកិលេសដែលនៅសេសសល់ មិនមានការសង្ស័យក្នុងការចាក់ធ្លុះអរិយគុណ ព្រោះហេតុនោះ ការសម្គាល់ខ្លួនថា បានសម្រេចធម៌លើសលុប រមែងមិនកើតដល់ព្រះសោតាបន្នជាដើម ដោយអំណាចនៃការសម្គាល់ថា អញជាព្រះសកទាគាមីជាដើម ។ ការសម្គាល់ខ្លួនថា បានសម្រេចធម៌លើស

លុប រមែងមិនកើតឡើងដល់បុគ្គលដែលទ្រុស្តសីល ។ ពិតហើយ បុគ្គលដែលទ្រុស្តសីលនោះ មិនមានសេចក្តីប្រាថ្នាក្នុងការសម្រេចអរិយគុណឡើយ ។ ការសម្គាល់ខ្លួនថា បានសម្រេចធម៌លើសលុប រមែងមិនកើតឡើងដល់បុគ្គលដែលមានសីល ដែលមានកម្មដ្ឋានលះបង់ហើយ ជាអ្នកប្រកបរឿយៗក្នុងភាពជាអ្នកត្រេកអរក្នុងការដេកជាដើម ។

តែការសម្គាល់ខ្លួនថា បានសម្រេចធម៌លើសលុបនោះ រមែងកើតដល់បុគ្គលមានសីលបរិសុទ្ធ ជាអ្នកមិនប្រមាទក្នុងកម្មដ្ឋាន កំណត់នាមរូប ឆ្លងនូវសេចក្តីសង្ស័យបាន ដោយការកំណត់បច្ច័យដែលលើកនាមរូបឡើងកាន់ត្រៃលក្ខណ៍ ហើយពិចារណាសង្ខារទាំងឡាយដែលផ្តើមបំពេញវិបស្សនា ។ ម្យ៉ាងទៀត កាលសេចក្តីសម្គាល់ថា បានសម្រេចធម៌លើសលុប កើតឡើងហើយ បុគ្គលដែលបានសមថៈសុទ្ធៗ ឬបុគ្គលដែលបានវិបស្សនាសុទ្ធៗ រមែងតាំងសេចក្តីសម្គាល់ថា បានសម្រេចធម៌លើសលុបទុកក្នុងចន្លោះ ព្រោះថា បុគ្គលនោះ កាលមិនឃើញកិលេសផ្សាយឡើង ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ រមែងសម្គាល់ថា អញជាព្រះសោតាបន្ន ឬជាព្រះសកទាគាមី ឬជាព្រះអនាគាមី ដូច្នេះ ។ ឯព្រះយោគីដែលបានទាំងសមថៈ និងវិបស្សនា រមែងតាំងសេចក្តីសម្គាល់ថា បានសម្រេចធម៌លើសលុបទុកក្នុងភាពជាព្រះអរហត្តប៉ុណ្ណោះ ព្រោះថា បុគ្គលនោះ សង្កត់កិលេសទាំងឡាយ ទុកហើយដោយកម្លាំងនៃសមាធិ កំណត់សង្ខារទាំងឡាយល្អហើយ ដោយកម្លាំងនៃវិបស្សនា ហេតុនោះ កិលេសទាំងឡាយមិនកើតឡើងអស់ ៦០ ឆ្នាំខ្លះ ៨០

ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ។ ការប្រព្រឹត្តទៅនៃចិត្ត រមែងដូចរបស់ព្រះអរហន្ត កាលលោកមិនឃើញកិលេសផ្សាយឡើង អស់កាលយូរយ៉ាងនេះ ទើបមិនតាំងសេចក្ដីសម្គាល់ថា បានសម្រេចធម៌លើសលុប ទុកក្នុងចន្លោះឡើយ រមែងសម្គាល់ថា អញជាព្រះអរហន្ត ដូច្នេះ ដូចព្រះមហានាគត្ថេរ អ្នកនៅក្នុងឧច្ចមាលង្គៈ និងដូចព្រះមហាទត្តត្ថេរ អ្នកនៅក្នុងហង្កនកៈ និងដូចព្រះចូឡសុមត្ថេរអ្នកនៅក្នុងផ្ទះសម្រាប់ប្រកបសេចក្ដីព្យាយាម ឈ្មោះនិង្កបោណ្ណៈ ក្បែរភ្នំចិត្តលបព៌ត ។ ក្នុងសេចក្ដីនោះ គប្បីជ្រាបការចង្អុលបង្ហាញរឿងត្រឹមតែមួយដូចតទៅ

បានឮថា ព្រះធម្មទិន្នត្ថេរអាស្រ័យនៅក្នុងតលង្គរៈ ជាព្រះខីណាស្រព មានបញ្ញាបែកធ្លាយក្នុងបដិសម្ភិទា បានជាអ្នកឲ្យឱវាទដល់មហាភិក្ខុសង្ឃ ។ ថ្ងៃមួយ ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃរបស់ខ្លួន គិតដល់អាចារ្យរបស់ខ្លួនថា កិច្ចនៃសមណៈរបស់ព្រះមហានាគត្ថេរ ដែលនៅអាស្រ័យត្រង់ឧច្ចតលិង្គៈដែលជាអាចារ្យរបស់អញ ដល់ទីបំផុតហើយឬហ្ន៎ ដូច្នេះ ឃើញថា អាចារ្យរបស់ខ្លួននោះនៅជាបុថុជ្ជន និងដឹងថា បើអាត្មាអញមិនទៅ អាចារ្យរបស់អញនឹងធ្វើកាលកិរិយាដោយភាពជាបុថុជ្ជននោះឯង ដូច្នេះ ទើបហោះទៅកាន់អាកាសដោយឫទ្ធិ ចុះក្នុងទីជិតព្រះមហានាគត្ថេរ ដែលកំពុងអង្គុយសម្រាកក្នុងពេលថ្ងៃ ថ្វាយបង្គំហើយសម្តែងនូវវត្ត ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ កាលអាចារ្យសួរថា នែអាវុសោធម្មទិន្ន ព្រោះហេតុអ្វី ទើបលោកមកក្នុងពេលមិនសមគួរ ដូច្នេះ ព្រះថេរៈឆ្លើយថា បពិត្រលោក

ម្ចាស់ ខ្ញុំមកដើម្បីសួរបញ្ហា ។ គ្រានោះ អាចារ្យពោលថា អាវុសោ ចូរលោកសួរ បើខ្ញុំដឹង នឹងប្រាប់ ដូច្នេះ ទើបសួរបញ្ហា ១០០០ ព្រះថេរៈជាអាចារ្យមិនទាល់ក្នុងបញ្ហាដែលព្រះធម្មទិន្នសួរហើយ ។ ពេលនោះ កាលព្រះធម្មទិន្នពោលថា បពិត្រលោកម្ចាស់ ញាណរបស់លោកម្ចាស់មុតស្រួចពេកណាស់ ធម៌នេះលោកម្ចាស់សម្រេចក្នុងកាលណា ដូច្នេះ អាចារ្យក៏ពោលថា អាវុសោ ក្នុងវស្សាទី ៦០ រាប់ថយក្រោយអំពីនេះ ដូច្នេះ ។ ព្រះធម្មទិន្នពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់នៅប្រើសមាធិដែរឬ ព្រះថេរៈជាអាចារ្យឆ្លើយថា អាវុសោ សេចក្តីនោះមិនធ្ងន់ចិត្ត គឺមិនលំបាកសម្រាប់ខ្ញុំឡើយ ដូច្នេះ ។ ព្រះធម្មទិន្ន ក៏ពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់និម្មិតដំរីមួយ ដូច្នេះ ព្រះថេរៈក៏និម្មិតដំរីសហើយ ព្រះធម្មទិន្នពោលថា ឥឡូវនេះ សូមលោកម្ចាស់ឲ្យដំរីនេះ បើកស្លឹកត្រចៀកមានកន្ទុយត្រង់ទៅក្រោយ យកប្រមោយដាក់ក្នុងមាត់ បន្លឺកោញ្ចនាទគួរឲ្យខ្លាច ស្ទុះមករកលោកម្ចាស់ ។ ព្រះថេរៈដែលជាអាចារ្យ កាលនិម្មិតយ៉ាងនោះហើយ ឃើញនូវអាការដែលគួរខ្លាចរបស់ដំរីដែលស្ទុះមកដោយរហ័ស ក៏ក្រោកឡើងដើម្បីគេចទៅ ។ ព្រះធម្មទិន្នជាព្រះខីណាស្រព ក៏លាដៃចាប់ចីវររបស់អាចារ្យ ហើយពោលថា បពិត្រលោកម្ចាស់ ព្រះខីណាស្រពនៅមានសេចក្តីខ្លាចឬ ទើបអាចារ្យដឹងថា ខ្ញុំនៅជាបុថុជ្ជនក្នុងកាលនោះ ទើបពោលថា អាវុសោធម្មទិន្ន សូមលោកជាទីពឹងរបស់ខ្ញុំ ដូច្នេះហើយ អង្គុយប្រហោងក្បែរជើងរបស់ព្រះធម្មទិន្ន ។ ព្រះធម្មទិន្នពោលថា បពិត្រលោក

ម្ចាស់ ខ្ញុំមកបំណងថា នឹងជាទីពឹងដល់លោកម្ចាស់ សូមលោកម្ចាស់កុំវិតក្ក ឡើយ ដូច្នេះហើយ ប្រាប់កម្មដ្ឋាន ។ ព្រះថេរៈជាអាចារ្យរៀនកម្មដ្ឋានហើយ ក៏ឡើងកាន់ទីចង្ក្រម ឈានជំហានទី ៣ សម្រេចអរហត្តផលដ៏ប្រសើរ ។ បានឮថា ព្រះថេរៈនោះជាបុគ្គលទោសចរិត ។

[ ១៣៤ ] ក្នុងនិទ្ទេសសេចក្តីប្រកាន់ថា អញមាន បទថា **រូបេ អស្មីតិ មនោ** បានដល់ មានការសម្គាល់កើតឡើងថា អញជារូប ។ បទថា **ឆន្ទោ** បានដល់ ការពេញចិត្តអនុលោមតាមមានៈនោះឯង ។ បទថា **អនុសយោ** ក៏ន័យនោះឯង ។ ក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។

[ ១៣៥ ] ក្នុងនិទ្ទេសនៃសេចក្តីប្រកាន់ខុស គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **ចាបកេន វា កម្មាយតនេន** ជាដើម ការងាររបស់ព្រានប្រមង់ ព្រានសន្ទូច និងព្រានព្រៃជាដើម ឈ្មោះថា ការងារដ៏លាមក ។ ការឈ្លាសក្នុងការបង់សំណាញ់ និងដាក់លប ដាក់អន្ទាក់ និងពួយលំពែងជាដើម ឈ្មោះថា សិល្បៈសាស្ត្រដ៏លាមក ។ វិជ្ជាក្នុងការបៀតបៀនសត្វដទៃណាមួយឈ្មោះថា ទីតាំងនៃវិជ្ជាដ៏លាមក ។ ការសិក្សាដែលប្រកបដោយចម្បាំង និងរឿងដណ្តើមនាងសិតាជាដើម ឈ្មោះថា ការចេះដឹងដ៏លាមក ។ ការឈ្លាសក្នុងកំណាព្យកាព្យឃ្លោង ការរាំ ការរាំពត់ពែនជាដើម ដែលប្រកបដោយទុព្ភាសិត ឈ្មោះថា បញ្ញាដ៏លាមក ។ អជសីល គឺសីលបែបពពែ គោសីលជាដើម ឈ្មោះថា សីលដ៏លាមក ។ សូម្បីវត្ត ក៏គឺអជវត្ត និងគោវត្ត ។ ទិដ្ឋិ ៦២ ឯណានីមួយ ឈ្មោះថា ទិដ្ឋិដ៏លាមក ។

[ ១៣៦-១៣៨ ] ក្នុងនិទ្ទេសនៃសេចក្តីនឹកដល់ញាតិជាដើម ការត្រិះរិះដែលកើតឡើងប្រារព្ធញាតិទាំងឡាយ ដោយសេចក្តីស្រឡាញ់ ដែលទាក់ទងក្នុងផ្ទះ អាស្រ័យកាមគុណ ៥ យ៉ាងនេះថា ញាតិទាំងឡាយរបស់អាត្មាអញរស់នៅជាសុខ មានទ្រព្យសម្បត្តិ ដូច្នេះ ឈ្មោះថា **ញាតិវិតក្កោ** ។ ចំណែកការគិតដែលប្រព្រឹត្តទៅយ៉ាងនេះថា ញាតិទាំងឡាយរបស់អញដល់នូវការអស់ទៅ ដល់នូវការវិនាសទៅហើយ ជាអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា មិនឈ្មោះថា ញាតិវិតក្កឡើយ ។

ការត្រិះរិះដែលកើតឡើងដោយអំណាចនៃសេចក្តីស្រឡាញ់ អាស្រ័យផ្ទះ ដល់បុគ្គលដែលត្រេកអរថា ជនបទរបស់យើងទាំងឡាយ មានភិក្ខារកបានងាយ ដល់ព្រមដោយស្រូវ ឈ្មោះថា **ជនបទវិតក្កោ** ។ ឯការត្រិះរិះដែលប្រព្រឹត្តទៅយ៉ាងនេះថា មនុស្សទាំងឡាយ ក្នុងជនបទរបស់ពួកយើងមានសភាព ( ជ្រះថ្លា ) មានសេចក្តីជ្រះថ្លា ដល់នូវការអស់ទៅ ដល់នូវការសូន្យទៅហើយ ដូច្នេះ មិនឈ្មោះថា សេចក្តីនឹកដល់ជនបទ ។

ការត្រិះរិះដើម្បីមិនស្លាប់ ឬការត្រិះរិះដែលមិនស្លាប់ ឈ្មោះថា **អមរ-វិតក្កោ** ។ ក្នុងការត្រិះរិះ ២ យ៉ាងនោះ កាលបុគ្គលធ្វើទុក្ករកិរិយា ដោយត្រិះរិះថា កាលសេចក្តីទុក្ខថមថយកម្លាំង ដោយសេចក្តីព្យាយាម មានការអង្គុយប្រហោងជាដើម អត្តារមែងមានសេចក្តីសុខ មិនស្លាប់ក្នុងភពខាងមុខ វិតក្កដែលប្រកបដោយទុក្ករកិរិយានោះ ឈ្មោះថា សេចក្តីនឹកដល់ការមិនស្លាប់ ។ បុគ្គលដែលមានទិដ្ឋិ ត្រូវអ្នកដទៃសួរបញ្ហាថា លោករមែងពោល

ថា អត្តា និងលោកទៀងឬជាដើម ក៏ពោលវាចាបណ្តោះបណ្តៃ មិនឲ្យស្ងាប់ខ្ជួនថា ការឃើញរបស់អញថា យ៉ាងនេះក៏មិនមែន យ៉ាងនោះក៏មិនមែន យ៉ាងដទៃក៏មិនមែន មិនមែនក៏មិនមែន មិនមែនមិនមែនក៏មិនមែន ។

ការត្រិះរិះដែលប្រកបដោយទិដ្ឋិនោះ របស់បុគ្គលនោះ រមែងមិនស្ងាប់ខ្ជួន ព្រោះមិនតាំងមាំក្នុងចំណែកមួយ ប្រៀបដូចអន្ទង់ដែលបុគ្គលណាមួយមិនអាចចាប់ក្នុងទឹកយកមកសម្លាប់បាន អន្ទង់នោះរមែងគេចទៅ គេចមកមិនឲ្យចាប់ ព្រោះហេតុនោះ ទើបឈ្មោះថា មិនស្ងាប់ខ្ជួន ។ ព្រះមានព្រះភាគត្រាស់ថា **អយំ វុច្ចតិ អមរាវិក្ខេបោ** ព្រោះលោករួមយកវិតក្កទាំង ២ នោះជាមួយគ្នា ។

[ ១៣៩ ] បទថា **បរានុទ្ទយតាបដិសំយុត្តោ** បានដល់ សេចក្តីទឹកប្រកបដោយការស្រឡាញ់ ការអាស្រ័យផ្ទះ ដែលសមគួរនឹងអាណិតអាសូរ ។ បទថា **សហនន្ទិ** ជាដើម បានដល់ កាលឧបដ្ឋាកទាំងឡាយ មានសេចក្តីត្រេកអរ ឬសេចក្តីសោក ភិក្ខុនោះ ក៏ត្រេកអរទ្វេគុណ ឬកើតទុក្ខទ្វេគុណ ជាមួយនឹងឧបដ្ឋាកទាំងនោះ កាលឧបដ្ឋាកទាំងនោះមានសេចក្តីសុខ ភិក្ខុនោះ ក៏មានសេចក្តីសុខទ្វេគុណ កាលឧបដ្ឋាកមានសេចក្តីទុក្ខ ភិក្ខុនោះ ក៏ទុក្ខទ្វេគុណ ។ បទថា **ឧប្បន្នេសុ កិច្ចករណីយេសុ** បានដល់ កាលបុគ្គលដទៃទាំងនោះ មានការងារធំតូចកើតឡើងហើយ ។ បទថា **អត្តនា វា យោគំ អាបជ្ជតិ** បានដល់ ភិក្ខុកាលញ៉ាំងកិច្ចទាំងនោះឲ្យសម្រេច រមែងឈានកន្លងបញ្ញត្តិ រមែងញ៉ាំងសល្លេខប្បដិបត្តិឲ្យវិនាស ។ បទថា **យោ**

**តត្ថ** បានដល់ សេចក្តីទឹកអាស្រ័យផ្ទះ ក្នុងការនៅប្រឡូកប្រឡំនោះ ឬក្នុងការដល់នូវសេចក្តីព្យាយាមជួយធ្វើនោះឯណា នេះឈ្មោះថា សេចក្តីទឹកប្រកបដោយសេចក្តីអាណិតអាសូរដល់អ្នកដទៃ ។

[ ១៤០ ] បទថា **លាភសក្ការសិលោកប្បដិសំយុត្តោ** បានដល់ សេចក្តីទឹកដែលប្រកបដោយលាភមានចីវរជាដើម ដោយសក្ការៈ និងដោយកិត្តិសព្ទ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។

[ ១៤១ ] បទថា **អនវញ្ញត្តិប្បដិសំយុត្តោ** បានដល់ សេចក្តីទឹកដែលកើតឡើងព្រម និងសេចក្តីប្រាថ្នាមិនចង់ឲ្យអ្នកដទៃមើលងាយ យ៉ាងនេះថា ឱហ្ន៎ បុគ្គលដទៃ មិនគប្បីមើលងាយអញ មិនគប្បីពោលបៀតបៀនអញ ។ បទថា **យោ តត្ថ គេហសិតោ** បានដល់ ការទឹកដែលកើតឡើងអាស្រ័យផ្ទះ ពោល គឺកាមគុណ ៥ ក្នុងចិត្តដែលកើតឡើងថា បុគ្គលពួកដទៃគប្បីមើលងាយអញនោះឯណា ។ ពាក្យដ៏សេសក្នុងបទទាំងពួង ប្រាកដច្បាស់ហើយ ។

**អដ្ឋកថាឯកកនិទ្ទេស ចប់**

# ឧក្កដ្ឋនិទ្ទេស

[ ១៤២ ] ក្នុងទុកមាតិកាទាំងឡាយ បណ្ឌិតគប្បីជ្រាបនិទ្ទេសនៃសេចក្ដីក្រោធជាដើម ដោយន័យដែលបានពោលហើយខាងដើមនោះឯង ។ ក្នុងនិទ្ទេសនៃការចងសេចក្ដីក្រោធទុកជាដើម ដែលមិនធ្លាប់ពោល សេចក្ដីក្រោធក្នុងកាលខាងក្រោយ ព្រោះចងសេចក្ដីក្រោធទុកក្នុងកាលមុន ឈ្មោះថា **ឧបនាហោ** ។ អាការនៃការចងសេចក្ដីក្រោធ ឈ្មោះថា **ឧបនយ្ហនា** ។ ភាពនៃបុគ្គលដែលចងសេចក្ដីក្រោធទុក ឈ្មោះថា **ឧបនាហិតត្តំ** ។ បទថា **អដ្ឋបនា** បានដល់ ការតាំងសេចក្ដីក្រោធទុកជាប់តគ្នា ឬតាំងសេចក្ដីក្រោធទុកត្រង់ព្រំដែនរបស់សេចក្ដីក្រោធ ដែលកើតឡើងគ្រាដំបូង ។ម្យ៉ាងទៀត បានដល់ ដោយការកំណត់ព្រំដែននៃសេចក្ដីក្រោធដែលកើតឡើងគ្រាដំបូង ។ ការតាំងសេចក្ដីក្រោធទុកតាមប្រក្រតី ឈ្មោះថា **ឋបនា** ។ ការតាំងសេចក្ដីអាឃាតទុករឿយៗ ដោយចំណែកទាំងពួង ឈ្មោះថា **សណ្ឋបនា** ។ ការមិនបោល ហើយធ្វើឲ្យតែមួយ ដោយសេចក្ដីក្រោធដែលកើតឡើងដំបូង ឈ្មោះថា **អនុសំសន្ទនា** ។ ការបន្តសេចក្ដីក្រោធក្រោយ និងសេចក្ដីក្រោធមុន ឈ្មោះថា **អនុប្បពន្ធនា** ។ ការធ្វើសេចក្ដីក្រោធឲ្យមាំទាំ ឈ្មោះថា **ទឡ្ហីកម្មំ** ។ បទថា **អយំ វុច្ចតិ** សេចក្ដីថា សភាវៈមានការចូលទៅចងទុកជាលក្ខណៈ មានការមិនលះបង់នូវពៀរជាកិច្ចនេះ ព្រះមានព្រះភាគត្រាស់ហៅថា ឧបនាហៈដែលជាហេតុឲ្យបុគ្គលប្រកបហើយមិនអាចលះនូវពៀរ រមែង

ជាប់តាមទៅរឿយៗ ដោយគិតថា បុគ្គលនេះ មិនគួរនិយាយជាមួយអញ យ៉ាងនេះ រមែងឆេះនោះឯង ដូចឧសដែលឆេះទូទៅហើយ រមែងមិនស្អាត ដូចស្បែកខ្លាឃ្មុំ ដែលបុគ្គលធ្វើនូវការសម្អាត និងដូចសំពត់ចាស់ដែលប្រឡាក់ដោយខ្លាញ់ ឬប្រេង ដូច្នោះ ។

[ ១៨៣ ] ឈ្មោះថា **មក្ខោ** ដោយអំណាចនៃភាពជារបស់ប្រឡាក់ប្រឡូស អធិប្បាយថា បុគ្គលសូម្បីប្រព្រឹត្តដោយការលុបគុណ របស់អ្នកដទៃ រមែងធ្វើអ្នកធ្វើឲ្យប្រឡាក់ប្រឡូសមុន ដូចលាមកប្រឡាក់បុគ្គលដែលចាប់គ្រវែងទៅកាន់អ្នកដទៃ ។ ២ បទបន្ទាប់អំពីនោះ គឺបទថា **មក្ខិយនា** និងបទថា **មក្ខិយិតត្តំ** ជាពាក្យអធិប្បាយសភាវៈនៃកិរិយាអាការ ។ ភាពនៃបុគ្គលជាអ្នករឹងត្អឹង ឈ្មោះថា **និដ្ឋុរិយំ** អធិប្បាយថា ការស្តោះទឹកមាត់ដោយពោលថា គុណសូម្បីមានប្រមាណតិច អាស្រ័យបុគ្គលនោះ រមែងមិនមាន ដូច្នេះ ។ ការធ្វើកិរិយាដែលមើលងាយអ្នកមានគុណ ឈ្មោះថា **និដ្ឋុរិយកម្មំ** ។ ពិតហើយ គ្រហស្ថអាស្រ័យគ្រហស្ថ ភិក្ខុអាស្រ័យភិក្ខុរស់នៅ ទីងក្រោធដោយហេតុមានប្រមាណបន្តិចបន្តួចប៉ុណ្ណោះ រមែងធ្វើការមើលងាយ ហាក់បីដូចស្តោះទឹកមាត់ហើយញីដោយជើង ដោយគិតថា គុណមានប្រមាណប៉ុណ្ណោះ អាស្រ័យបុគ្គលនោះ រមែងមិនមាន ។ ការធ្វើនោះ របស់បុគ្គលនោះ ព្រះមានព្រះភាគត្រាស់ហៅថា **និដ្ឋុរិយកម្មំ** ។ បើពោលដោយលក្ខណៈជាដើម មក្ខៈ គឺការលុបគុណនេះ មានការលុបគុណរបស់អ្នកដទៃជាលក្ខណៈ មានការញុំាងគុណរបស់អ្នកដទៃឲ្យវិនាសជាកិច្ច មាន

ការបិទបាំងកិរិយាអាការដែលបុគ្គលដទៃធ្វើល្អហើយ ជាអាការប្រាកដ ។

សភាវៈណារមែងវាយឫកស្មើ ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា **បលាសោ** អធិប្បាយថា សម្តែងគុណរបស់អ្នកដទៃ ធ្វើឲ្យស្មើនឹងគុណរបស់ខ្លួន ។ ការប្រព្រឹត្តនៃការវាយឫកស្មើ ឈ្មោះថា **បលាសាយនា** ។ ការវាយឫកស្មើនោះផង ជាអាហារ ព្រោះនាំមកនូវការឈ្នះរបស់ខ្លួនផង ព្រោះហេតុនោះ ទើបឈ្មោះថា **បលាសាហារោ** ។ បទថា **វិវាទដ្ឋានំ** បានដល់ហេតុនៃការទាស់ទែងគ្នា ។ ការកាន់យកធុរៈស្មើគ្នា ឈ្មោះថា **យុគ្គាហោ** ។ ការមិនលះធុរៈដែលខ្លួនកាន់យកហើយ ឈ្មោះថា **អប្បដិនិស្សគ្គោ** ។ បើពោលដោយលក្ខណៈជាដើម បលាសៈ មានការវាយឫកស្មើ និងមានការប្រណាំងប្រជែងជាលក្ខណៈ មានការធ្វើគុណទាំងឡាយរបស់ខ្លួនឲ្យស្មើគ្នានឹងគុណរបស់អ្នកដទៃជាកិច្ច មានការប្រាកដដោយប្រមាណនៃគុណ របស់អ្នកដទៃជាអាការប្រាកដ ។ ពិតហើយ បុគ្គលដែលវាយឫកស្មើ រមែងមិនឲ្យធុរៈដល់បុគ្គលទី ២ រមែងធ្វើឲ្យស្មើគ្នា តាំងនៅ គឺកាលភិក្ខុរូបដទៃ នាំព្រះសូត្រទាំងឡាយ និងការណៈទាំងឡាយជាច្រើនហើយ ក្នុងវេលាសន្ទនាធម៌ ភិក្ខុនោះរមែងនឹងពោលពង្រីកសេចក្តីចេញទៅនូវគុណរបស់ខ្លួន ឲ្យស្មើជាមួយនឹងអ្នកដទៃថា ក្នុងវាទៈរបស់លោក និងវាទៈរបស់ខ្ញុំ ហេតុដែលបែកផ្សេងគ្នា ឈ្មោះថា មានឬ ពាក្យសម្តីរបស់ពួកយើងដូចគ្នានឹងពួកលោកនោះឯង ប្រៀបដូចដុំមាសដែលបាក់ត្រង់កណ្តាល ក៏ដូចគ្នាមិនមែនឬ ដូច្នេះ ។

[ ១៨៤ ] និទ្ទេសនៃឥស្សា គឺសេចក្តីប្រណែន និងមច្ឆរិយៈ គឺសេចក្តី

កំណាញ់ មានអត្ថដូចខ្ញុំពោលហើយនោះឯង ។

[ ១៤៥ ] ក្នុងនិទ្ទេសនៃសេចក្តីបិទបាំងទោសរបស់ខ្លួន បទថា **វាចំ ភាសតិ** បានដល់ ភិក្ខុនោះឯង ពោលហាក់បីដូចជាស្ងប់ស្ងៀមហើយថា ពួកភិក្ខុដែលកន្លងល្មើសបញ្ញត្តិ រមែងធ្វើនូវភារៈធ្ងន់ តែបញ្ញត្តដែលខ្ញុំកន្លងល្មើសហើយ រមែងមិនមាន ។ បទថា **កាយេន បរក្កមតិ** បានដល់ ភិក្ខុនោះ តែងធ្វើវត្តបដិបត្តិដោយកាយ ដោយគិតថា បុគ្គលណាមួយ កុំបីដឹងនូវបាបកម្មនេះដែលអញធ្វើហើយ ដូច្នេះ ។ លក្ខណៈនេះ ឈ្មោះថា **មាយា** ហាក់បីដូចជាមាយាករ ( អ្នកលេងកល ) ព្រោះការបិទបាំងនូវទោសដែលខ្លួនមាន ភាពនៃបុគ្គលមានមាយា ឈ្មោះថា **មាយាវិតា** ។ ឈ្មោះថា **អច្ចាសរា** ព្រោះអត្ថថា ជាហេតុឲ្យសត្វទាំងឡាយស្ទុះទៅ ព្រោះខ្លួនធ្វើហើយបិទបាំងបាបទុកទៀត ។ ឈ្មោះថា **វញ្ចនា** ព្រោះអត្ថថា រមែងបញ្ឆោតដោយសម្តែងជាប្រការដទៃ ដោយការធ្វើផ្លូវកាយ និងវាចា ។ សត្វទាំងឡាយ រមែងធ្វើនូវការបោកប្រាស អធិប្បាយថា រមែងធ្វើខុសដោយកិរិយានោះ ព្រោះហេតុនោះ កិរិយានោះ ឈ្មោះថា **និកតិ** ។ ឈ្មោះថា **វិកិរណា** ព្រោះគេចកែនូវបាបទាំងឡាយដោយពាក្យថា ខ្ញុំមិនបានធ្វើយ៉ាងនេះ ។ ឈ្មោះថា **បរិហរណា** ព្រោះការពង្វេះពង្វាងដោយពាក្យថា ខ្ញុំមិនបានធ្វើយ៉ាងនេះ ។ ឈ្មោះថា **គុហណា** ព្រោះការបិទបាំងដោយកាយជាដើម ។ ការលាក់បំពួន ដោយចំណែកទាំងពួង ឈ្មោះថា **បរិគុហណា** ។ ឈ្មោះថា **ឆាទនា** ព្រោះអត្ថថា ការគ្របទុកនូវបាបដោយកាយកម្ម និងវចី-

កម្ម ហាក់បីដូចបុគ្គលគ្របលាមកទុកដោយស្មៅ និងស្លឹកឈើទាំងឡាយ ។ ការគ្របលុប ដោយចំណែកទាំងពួង ឈ្មោះថា **បរិច្ឆាទនា** ។ ឈ្មោះថា **អនុត្តានីកម្មំ** ព្រោះការមិនធ្វើឲ្យច្បាស់ ។ ឈ្មោះថា **អនាវិកម្មំ** ព្រោះអត្ថថា ការមិនធ្វើឲ្យប្រាកដ ។ ការបិទបាំងខ្ជាំង ឈ្មោះថា **វោច្ឆាទនា** ។ ឈ្មោះថា **បាបកិរិយា** ព្រោះធ្វើនូវអំពើអាក្រក់ទៀត ដោយអំណាចការបិទបាំងបាបដែលខ្លួនធ្វើហើយ ។ បទថា **អយំ វុច្ចតិ** សេចក្ដីថា ធម្មជាតដែលមានការបិទបាំងបាប ដែលធ្វើទុកជាលក្ខណៈនេះ ព្រះមានព្រះភាគត្រាស់ហៅថា **មាយា** ដែលជាហេតុឲ្យបុគ្គលប្រកបហើយ ហាក់បីដូចរងើកភ្លើង ដែលបិទបាំងដោយផេះ ហាក់ដូចដង្គត់ឈើដែលទឹកបិទបាំង និងដូចសស្ត្រាដែលបុគ្គលរុំដោយចម្រៀកសំពត់ ។

បទថា **សឋោ** បានដល់ ជាអ្នកមិនពោលដោយប្រពៃ ព្រោះសម្ដែងគុណ ដែលខ្លួនមិនមាន ។ ការអួតអាងដោយចំណែកទាំងពួង ឈ្មោះថា **បរិសឋោ** ។ បទថា **យំ តត្ថ** បានដល់ ការអួតជាដើមឯណាមានក្នុងបុគ្គលនោះ ។ ការវៀចវេរ គឺការសម្ដែងគុណដែលមិនមាន ឈ្មោះថា **សឋំ** ។ អាការនៃការអួតអាង ឈ្មោះថា **សឋតា** ។ បទថា **កក្ខរតា** បានដល់ ភាពដែលបុគ្គលមានសម្ផស្សរឹងមិនគួរពាល់ត្រូវ ដូចដើមឈូក ។ បទថា **កក្ខរិយំ** ជាវេវចនៈរបស់បទថា **កក្ខរតា** នោះឯង ។ ការកោងដែលមាំទាំ ដូចជីកកប់ ( សសរខឿន ) តាំងទុក ព្រះមានព្រះភាគត្រាស់ដោយពាក្យទាំង ២ គឺ **បរិក្ខត្តតា បារិក្ខត្តិយំ** ។ បទថា **ឥទំ វុច្ចតិ** សេចក្ដីថា

ធម្មជាតមានការប្រកាសគុណ ដែលមិនមានរបស់ខ្លួនជាលក្ខណៈនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា **សាឋេយ្យ** ។ ការអួតដែលជាហេតុឲ្យបុគ្គលណាមួយ មិនអាចដឹងពោះដឹងខ្នងរបស់បុគ្គលដែលប្រកបព្រម ( ឈ្មោះថា សាឋេយ្យៈ ) ។ បុគ្គលអួតអាង រមែងដូចជ្រូកយក្ខ ដែលលោកពោលថា

**វាមេន សូករោ ហោតិ ទក្ខិណេន អជាមិគោ**
**សរេន នេលកោ ហោតិ វិសាណេន ជរគ្គវោ ។**

យក្ខនោះ រមែងកាឡាខ្លួនខាងឆ្វេងជាជ្រូក ខាងស្តាំជាពពែ
សំឡេងជាចៀម ស្នែងជាគោចាស់ ដូច្នេះ ។

[ ១៤៦-១៥២ ] និទ្ទេសនៃអវិជ្ជាជាដើម មានអត្ថដូចបានពោលហើយនោះឯង ។

[ ១៥៣ ] ក្នុងនិទ្ទេសនៃអាការមិនត្រង់ ការមិនស្មោះត្រង់ អាការនៃការមិនស្មោះត្រង់ ឈ្មោះថា **អនាជ្ជវោ** ។ ភាពនៃការមិនត្រង់ ឈ្មោះថា **អនាជ្ជវតា** ។ ការកោង ដូចគ្នានឹងរង្វង់ព្រះចន្ទ ឈ្មោះថា **ជិម្ហតា** ។ ការវៀចដូចទឹកនោមគោឈ្មោះថា **វង្កតា** ។ ការក្ងិកក្ងក់ដូចគ្នានឹងយាមនង្គ័ល ឈ្មោះថា **កុដិលតា** ។ ការវៀចវេរនៃកាយ វាចា និងចិត្តនោះឯង ព្រះមានព្រះភាគត្រាស់ដោយបទទាំងពួងនេះ ។

ក្នុងនិទ្ទេសនៃសេចក្តីមិនទន់ភ្លន់ ការមិនទន់ភ្លន់ ភាវៈដែលមិនទន់ភ្លន់ ឈ្មោះថា **អមុទុតា** ។ អាការនៃការមិនទន់ភ្លន់ ឈ្មោះថា **អមទ្ទវតា** ។ ភាវៈដែលរឹងត្អឹង ឈ្មោះថា **កក្ខឡិយំ** ។ ភាពដែលគ្រោតគ្រាត ឈ្មោះថា

**ជារុសិយំ** ព្រោះមិនមានការស្រឡាញ់ដែលធ្វើនូវការទន់ភ្លន់ ។ ភាវៈដែលចិត្តត្រង់ ឈ្មោះថា **ឧជុចិត្តតា** ព្រោះការមិនប្រព្រឹត្តឱនលំទោន ។ ព្រះមានព្រះភាគត្រាស់ **អមុទុតា** សព្ទ ដដែលទៀត ដើម្បីពង្រីកសព្ទថា **ឧជុ-ចិត្តតា** នោះ ឲ្យជាក់ច្បាស់ថា **ឧជុចិត្តតា** គឺការមិនទន់ភ្លន់ មិនមែន **ឧជុចិត្តតា** គឺការស្មោះត្រង់ ។

[ ១៥៤-១៥៨ ] បណ្ឌិតគប្បីជ្រាបនិទ្ទេសនៃសេចក្តីមិនអត់សង្កត់ជាដើម ដោយផ្ទុយគ្នានឹងនិទ្ទេសនៃសេចក្តីអត់សង្កត់ជាដើម ។

[ ១៥៩ ] ក្នុងនិទ្ទេសនៃសញ្ញោជនៈ បទថា **អជ្ឈត្តំ សញ្ញោជនំ** បានដល់ កាមភព ។ បទថា **ពហិទ្ធា** បានដល់ រូបភព និងអរូបភព ។ ពិតហើយ សត្វទាំងឡាយ រមែងអាស្រ័យនៅក្នុងកាមភព អស់កាលបន្តិចបន្តួច គឺអាស្រ័យនៅអស់កាលដែលជាចំណែកទី ៤ នៃកប្បប៉ុណ្ណោះ ក្នុងចំណែកនៃកប្បទាំង ៣ ដ៏សេសក្រៅអំពីនេះ កាមភព រមែងទទេ ។

សត្វទាំងឡាយរមែងអាស្រ័យក្នុងរូបភព និងអរូបភពអស់កាលដ៏ច្រើនក៏ពិត តែព្រោះចុតិ និងបដិសន្ធិនៃសត្វទាំងឡាយនោះមានច្រើន ក្នុងកាមភព ឯក្នុងរូបភព និងអរូបភពមានតិច ចុតិ និងបដិសន្ធិក្នុងទីណាមានច្រើន ក្នុងទីនោះ អាល័យក្តី ការប្រាថ្នាក្តី ការចង់បានក្តី រមែងមានច្រើន ចុតិ និងបដិសន្ធិក្នុងទីណាមានតិច ក្នុងទីនោះ ក៏មានអាល័យជាដើមតិច ព្រោះហេតុនោះ ទើបកាមភព ឈ្មោះថា ខាងក្នុង ឯរូបភព និងអរូបភព ឈ្មោះថា ខាងក្រៅ ដោយហេតុនោះ ចំណងក្នុងកាមភព ពោលគឺខាងក្នុង ឈ្មោះថា

សំយោជនៈខាងក្នុង ចំណងក្នុងរូបភព និងអរូបភព ពោល គឺខាងក្រៅ ឈ្មោះថា សញ្ញោជនៈខាងក្រៅ ។

បណ្ដាសញ្ញោជនៈទាំងនោះ ខាងក្នុងក្ដី ខាងក្រៅក្ដី នីមួយៗ មាន ៥ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សញ្ញោជនៈ ៥ ជាចំណែកខាងក្រោម សញ្ញោជនៈ ៥ ជាចំណែកខាងលើ ដូច្នេះ ។ ក្នុងសេចក្ដីនោះ គប្បីជ្រាបវចនត្ថៈដូចតទៅ

កាមធាតុ ព្រះមានព្រះភាគត្រាស់ហៅថា **ឱរំ** ខាងក្រោម ។ សញ្ញោជនៈពួកណា រមែងសេពនូវធម៌ខាងក្រោមនោះ ដោយឲ្យសម្រេចការកើតឡើងក្នុងកាមធាតុនោះ ព្រោះហេតុនោះ ទើបសញ្ញោជនៈនោះ ឈ្មោះថា ឱរម្ភាគិយៈ ។ រូបធាតុនិងអរូបធាតុ ព្រះមានព្រះភាគត្រាស់ហៅថា **ឧទ្ធំ** ខាងលើ ។ សញ្ញោជនៈពួកណា រមែងសេពនូវធម៌ខាងលើនោះ ដោយឲ្យសម្រេចការកើតឡើង ក្នុងរូបធាតុ និងអរូបធាតុនោះ ព្រោះហេតុនោះ ទើបសញ្ញោជនៈនោះ ឈ្មោះថា ឧទ្ធម្ភាគិយៈ ។

**ទុកនិទ្ទេស ចប់**

## តិកនិទ្ទេស

[ ១៦០-១៦៣ ] ក្នុងតិកនិទ្ទេសគប្បីជ្រាបថា ការប្រកបនៃវដ្ដមូល ៣ ព្រះមានព្រះភាគ ត្រាស់ទុកដោយអកុសលមូល ៣ ។ ក្នុងវិតក្កជាដើម

វិតក្ក ទ្រង់ត្រាស់ដោយអំណាចនៃសេចក្ដីត្រិះរិះ សញ្ញា ទ្រង់ត្រាស់ដោយអំណាចនៃការចាំ ធាតុ ទ្រង់ត្រាស់ដោយអត្ថនៃសភាវៈ ។

[ ១៦៨ ] ក្នុងនិទ្ទេសនៃទុច្ចរិត ទុច្ចរិតន័យទី ១ ព្រះមានព្រះភាគទ្រង់ចែកដោយអំណាចនៃកម្មបថ ។ ន័យទី ២ ទ្រង់ចែកដោយអំណាចនៃកម្មដែលសង្គ្រោះចូលក្នុងអកុសលទាំងអស់ ។ ន័យទី ៣ ទ្រង់ចែកដោយអំណាចនៃចេតនាដែលកើតឡើងហើយ ។

[ ១៦៩ ] ក្នុងនិទ្ទេសនៃអាសវៈ ព្រះមានព្រះភាគ ត្រាស់អាសវៈ ៣ ប៉ុណ្ណោះ ដោយបរិយាយនៃព្រះសូត្រ ។

[ ១៧០ ] ក្នុងនិទ្ទេសនៃការស្វែងរក ពោលដោយសង្ខេប ការត្រេកអរដោយការស្វែងរកកាម ដែលព្រះមានព្រះភាគត្រាស់ ដោយន័យថា **តត្ថ កតមា កាមេសនា** ជាដើម គប្បីជ្រាបថា ជាការស្វែងរកកាម ។ ការត្រេកអរដោយការស្វែងរកភព ដែលព្រះមានព្រះភាគ ត្រាស់ដោយន័យថា **យោ ភវេសុ ភវច្ឆន្ទោ** គប្បីជ្រាបថា ជាការស្វែងរកភព ។ ការយល់ខុសដែលស្វែងរកព្រហ្មចរិយៈ ដែលឃើញប្រពៃ តាមអធ្យាស្រ័យនៃទិដ្ឋិដែលព្រះមានព្រះភាគត្រាស់ដោយន័យថា **សស្សតោ លោកោ** គប្បីជ្រាបថា ការស្វែងរកព្រហ្មចរិយៈ ។ ព្រោះរាគៈ និងទិដ្ឋិប៉ុណ្ណោះជាឯសនាដោយចំណែកមួយក៏មិនមែន សូម្បីកម្មដែលតាំងនៅក្នុងឋានៈជាមួយរាគៈ និងទិដ្ឋិនោះ ក៏ជាឯសនាដូចគ្នា ហេតុនោះ ដើម្បីសម្ដែងនូវកម្មនោះ ទើបព្រះមានព្រះភាគទ្រង់ចែកន័យទី ២ ។ បណ្ដាបទទាំងនោះ បទថា **តទេកដ្ឋំ**

គប្បីជ្រាបថា ជាកម្មដែលតាំងនៅក្នុងឋានៈតែមួយជាមួយនឹងធម៌ដែលសម្បយុត្តដោយរាគៈ និងទិដ្ឋិនោះ គឺក្នុងពាក្យនោះ កម្មដែលតាំងនៅក្នុងឋានៈមួយជាមួយកាមរាគៈ រមែងប្រព្រឹត្តទៅ ដល់សត្វដែលអន្ទោលទៅក្នុងកាមភពទាំងឡាយប៉ុណ្ណោះ ឯកម្មដែលតាំងនៅក្នុងឋានៈតែមួយជាមួយនឹងភវរាគៈ រមែងប្រព្រឹត្តទៅដល់មហាព្រហ្មទាំងឡាយ ។ ក្នុងកាលដែលចេញហើយចាកសមាបត្តិ ចង្រ្កម ត្រេកអរក្នុងអន្តរឈាន អកុសលកាយកម្ម រមែងកើតក្នុងកាលត្រេកអរបន្លឺវាចាថា ឱសុខហ្ន៎ ! ឱសុខហ្ន៎ ! ដូច្នេះ អកុសលវចីកម្មរមែងកើតក្នុងកាលដែលមិនធ្វើអង្គនៃកាយ និងអង្គនៃវាចាឲ្យកម្រើកត្រេកអរតាមផ្លូវចិត្តប៉ុណ្ណោះ អកុសលមនោកម្មរមែងកើត ។ អកុសលកម្មទាំងនោះ រមែងកើតដោយអំណាចការដើរចង្រ្កមជាដើម ដល់បុគ្គលទាំងអស់ដែលមានការយល់ខុស ដោយអំណាចនៃអន្តគ្គាហិកទិដ្ឋិនោះឯង ។

[ ១៧១ ] ក្នុងនិទ្ទេសនៃការធ្វើងឆ្ងៃ លក្ខណៈនៃអាការ ក្នុងពាក្យថា ការតាំងនៅនៃអាការ ក្នុងពាក្យថា អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលដូចម្តេចថា ជាអ្នកមានសីល ហៅបុគ្គលដូចម្តេចថា ជាអ្នកមានបញ្ញា ដូច្នេះជាដើម ឈ្មោះថា **វិធា** ។ កោដ្ឋាសក្នុងពាក្យថា ញាណវត្ថុមានប្រការ ១ ដូច្នេះជាដើម ឈ្មោះថា **វិធា** ។ មានះនោះ ក្នុងពាក្យថា បុគ្គលណាមិនញាប់ញ័រក្នុងមានះដូច្នេះជាដើម ឈ្មោះថា **វិធា** ។ ក្នុងទីនេះ មានះនោះឯង ឈ្មោះថា **វិធា** ។ ពិតហើយ មានះនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅថា **វិធា** ព្រោះការចាត់ចែង ការតាក់តែង ដោយអំណាចនៃការប្រកាន់ខ្លួនថា

ប្រសើរជាងគេជាដើម ។ មួយវិញទៀត ឈ្មោះថា **វិធា** ព្រោះអត្ថថា ការតាំងទុក ព្រោះហេតុនោះ វិធា គឺមានះ ការតាំងទុក គឺមានះដែលកើតឡើងយ៉ាងនេះថា យើងជាបុគ្គលប្រសើរជាងគេ គប្បីជ្រាបថា ការធ្មើងធ្មៃ ព្រោះតាំងខ្លួនថា អញប្រសើរជាងគេ ដូច្នេះ ។ ក្នុងពាក្យដ៏សេស ក៏ន័យនេះឯង ។

បទថា **ជាតឹ បដិច្ច ភយំ** បានដល់ ភ័យដែលកើតឡើង ព្រោះអាស្រ័យការកើត គឺជាតិជាបច្ច័យ ។ ពាក្យថា **ភយានកំ** ប្រែថា ភ័យដែលគួរខ្លាច នេះជានិទ្ទេសនៃអាការ ។ ពាក្យថា **ឆម្ភិតត្តំ** ប្រែថា ការតក់ស្លុតនៃចិត្ត បានដល់ ការញាប់ញ័រនៃខ្លួនព្រោះអំណាចនៃភ័យ ។ ពាក្យថា **លោមហំសោ** ប្រែថា ព្រឺរោមព្រឺស្បែក បានដល់ ការដែលរោមទាំងឡាយបះឡើងទៅខាងលើ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការខ្លាចដោយកិច្ច ដោយបទទាំង ២ យ៉ាងនេះហើយ ទ្រង់ក៏សម្តែងការខ្លាចដោយសភាវៈ គឺការតក់ស្លុតនៃចិត្តទៀត ។

[ ១៧២ ] ក្នុងនិទ្ទេសនៃភ័យ បទថា **ជាតឹ បដិច្ច ភយំ** បានដល់ការភ័យដែលកើតឡើង ព្រោះការកើតជាបច្ច័យ ។ បទថា **ភយានកំ** ជាការសម្តែងដល់អាការ ។ បទថា **ឆម្ភិតត្តំ** បានដល់ ញ័រខ្លួនដោយអំណាចសេចក្តីភ័យ ។ បទថា **លោមហំសោ** បានដល់ ភាពដែលរោមទាំងឡាយជារបស់បះឡើង គឺបះឡើងទៅខាងលើ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការភ័យដោយកិច្ច ដោយពាក្យទាំងពីរនេះហើយ ទ្រង់សម្តែងការ

ភ័យ ដោយសការៈដដែលទៀតថា **ចេតសោ ឧត្រាសោ** ដូច្នេះ ។

[ ១៧៣ ] ក្នុងនិទ្ទេសនៃងងឹត អវិជ្ជា ព្រះមានព្រះភាគត្រាស់ដោយបំណងយកវិចិកិច្ឆាជាប្រធាន ។ ព្រោះវចនៈថា ការងងឹត ការវង្វេង ឱឃៈ គឺអវិជ្ជាជាភ័យធំ ដូច្នេះ ទើបអវិជ្ជា ឈ្មោះថា **តម** ។ ព្រះមានព្រះភាគទ្រង់សម្តែងតមៈដោយបំណងយកវិចិកិច្ឆាជាប្រធាន ព្រោះសម្តែងបានដោយងាយដោយអំណាចនៃអទ្ធានទាំង ៣ ។ ក្នុងអទ្ធានទាំងនោះ កាលបុគ្គលសង្ស័យថា ក្នុងអតីតកាល អញជាក្សត្រឬហ្ន៎ ឬថាជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ជាមនុស្សខ្មៅ ជាមនុស្សស ជាមនុស្សតឿ ជាមនុស្សខ្ពស់ ដូច្នេះ ឈ្មោះថា រមែងសង្ស័យ ប្រារព្ធអតីតអទ្ធាន ។ កាលសង្ស័យថា ក្នុងអនាគតកាល អញនឹងកើតជាក្សត្រឬហ្ន៎ ឬថា នឹងកើតជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ។បេ។ ជាមនុស្សខ្ពស់ ដូច្នេះ ឈ្មោះថា រមែងសង្ស័យប្រារព្ធអនាគតអទ្ធាន ។ កាលសង្ស័យថា ក្នុងបច្ចុប្បន្ននេះ អញជាក្សត្រឬហ្ន៎ ឬជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ឬសង្ស័យថា អញមានរូបដូចម្តេច មានវេទនា មានសញ្ញា មានសង្ខារ មានវិញ្ញាណដូចម្តេច ឈ្មោះថា សង្ស័យប្រារព្ធនូវបច្ចុប្បន្នអទ្ធាន ។

ក្នុងតមនិទ្ទេសនោះ បុគ្គលជាក្សត្រឈ្មោះថា មិនដឹងខ្លួនថាជាក្សត្រ ។បេ។ ឬថាជាសូទ្រៈ ឈ្មោះថា មិនដឹងថាខ្លួនជាសូទ្រៈ រមែងមិនមានក៏ពិត តែជនទាំងអស់ ដែលកាន់លទ្ធិថា ជីវៈមាន ស្តាប់ការបែងចែកវណ្ណៈជាដើមនៃជីវៈរបស់ក្សត្រជាដើម កាលសន្និះសង្ស័យ ឈ្មោះថា រមែងសង្ស័យយ៉ាង

នេះថា ជីវៈខាងក្នុងរបស់យើងទាំងឡាយ ដូចម្តេចហ្ន៎ មានពណ៌ខៀវឬហ្ន៎ ឬមានពណ៌លឿង ឬពណ៌ក្រហម ឬពណ៌ស ឬជា ៤ ជ្រុង ឬជា ៦ ជ្រុង ឬជា ៨ ជ្រុង ដូច្នេះ ។

[ ១៧៤ ] បទថា **តិត្ថាយតនានិ** បានដល់ អាយតនៈ គឺពាក្យប្រៀនប្រដៅដែលជាលទ្ធិ ឬអាយតនៈ គឺពាក្យប្រៀនប្រដៅរបស់តិរ្ថិយទាំងឡាយ ។ ក្នុងអាយតនៈទាំងនោះ ទិដ្ឋិ ៦២ ឈ្មោះថា តិត្ថៈ គឺកំពង់ជាទីចូល ។ ទិដ្ឋិទាំងនោះរមែងគួរ រមែងគាប់ចិត្តដល់ជនទាំងឡាយណា ជនទាំងឡាយនោះ ឈ្មោះថា ជាតិរ្ថិយ ។ អត្ថនៃអាយតនៈ ខ្ញុំពោលហើយនោះឯង ។ ក្នុងតិត្ថាយតនៈទាំងនោះ ព្រោះជនទាំងពួងដែលមានការយល់ខុស កាលកើត រមែងកើតឡើងក្នុងឋានៈទាំង ៣ នេះប៉ុណ្ណោះ កាលប្រជុំក៏រមែងប្រជុំប្រមូលមកក្នុងឋានៈទាំង ៣ នោះឯង ដ្បិតថា ឋានៈទាំង ៣ [១] នេះឯង ជាមូលហេតុក្នុងការដែលជនទាំងនោះ មានការយល់ខុស ដូច្នោះហេតុទាំង ៣ នោះ ឈ្មោះថា តិត្ថាយតនៈ ព្រោះអត្ថថា ជាលទ្ធិផង ជាអាយតនៈ ដោយអត្ថមានពាក្យជាដើមថា ជាប្រកតកើតផង ។ ដោយអត្ថនោះឯង ពាក្យថា អាយតនៈ របស់តិរ្ថិយទាំងឡាយ ដូច្នេះ ក៏ឈ្មោះថា តិត្ថាយតនៈ ។ បទថា **បុរិសបុគ្គលោ** បានដល់ សត្វ ។ ម្យ៉ាងទៀត បុគ្គលណាមួយពោលថា បុរសក្តី បុគ្គលក្តី ឈ្មោះថា ពោលដល់សត្វនោះឯងក៏ពិត តែកថានេះ ឈ្មោះថា សម្មតិកថា ។ ព្រះមានព្រះភាគ រមែង

---

១- ឋានៈ ៣ បុព្វេកតហេតុ ១ ឥស្សរនិម្មានហេតុ ១ អហេតុអប្បច្ចយា ១ ។

ត្រាស់ហៅដោយប្រការដែលសត្វទាំងនោះដឹង ។ បទថា **បដិសំវេទេតិ** បានដល់ រមែងដឹងវេទនាដែលកើតឡើងក្នុងសន្តានរបស់ខ្លួនផង រមែងធ្វើផង ឬរមែងសោយវេទនាដែលខ្លួនដឹងហើយនោះ ។

បទថា **បុព្វេ កតហេតុ** បានដល់ ព្រោះហេតុដែលខ្លួនធ្វើហើយក្នុងកាលមុន អធិប្បាយថា បុគ្គលនោះ រមែងសោយវេទនា ដោយកម្មប្បច្ច័យដែលខ្លួនធ្វើហើយក្នុងកាលមុននោះឯង ។ នេះជាលទ្ធិនៃនិគ្រន្ថនៃអចេលក៍ ។ ពួកនិគ្រន្ថទាំងនោះ មានប្រក្រតីពោលយ៉ាងនេះ តែរមែងទទួលការសោយវិបាកតែម្យ៉ាងប៉ុណ្ណោះ ។ ក្នុងអាពាធ ៨ យ៉ាង មានអាពាធដែលកើតអំពីប្រមាត់ជាសមុដ្ឋានជាដើម ជនទាំងនោះបដិសេធអាពាធ ៧ យ៉ាង ទទួលយកតែអាពាធទី ៨ ប៉ុណ្ណោះ[១] ក្នុងកម្ម ៣ យ៉ាង មានទិដ្ឋធម្មវេទនីយកម្មជាដើម ជនទាំងនោះ បដិសេធកម្ម ២ យ៉ាង ទទួលយកតែអបរាបរវេទនីយកម្មតែម្យ៉ាងប៉ុណ្ណោះ ។ ក្នុងចេតនា ៤ យ៉ាង ពោល គឺកុសល អកុសល វិបាក និងកិរិយា រមែងទទួលយកតែចេតនាដែលជាវិបាកប៉ុណ្ណោះ ។ បទថា **ឥស្សរនិម្មានហេតុ** បានដល់ ព្រោះហេតុនៃការជប់របស់ព្រះអាទិទេព អធិប្បាយថា រមែងសោយវេទនាបាន ព្រោះអាទិទេព គឺព្រះព្រហ្ម ឬព្រះបជាបតីនិម្មិតឲ្យ ។

---

*១- អាពាធកើតអំពីប្រមាត់ ១ អាពាធកើតអំពីខ្យល់ ១ អាពាធកើតអំពីស្លេស្ម ១ អាពាធកើតអំពីការប្រជុំ ១ អាពាធកើតអំពីការប្រែប្រួលរដូវ ១ អាពាធកើតអំពីឥរិយាបថមិនស្មើ ១ អាពាធកើតអំពីការធ្វើសេចក្តីព្យាយាមខ្លាំងពេក ១ អាពាធកើតអំពីកម្ម ១ ។*

នេះជាលទ្ធិរបស់ព្រាហ្មណ៍ ។ ពិតហើយ មានពាក្យអធិប្បាយរបស់ពួកព្រាហ្មណ៍ទាំងនោះដូចតទៅ

បុគ្គលណាមួយ មិនអាចសោយវេទនាទាំង ៣ នេះបាន ព្រោះហេតុដែលខ្លួនឯងធ្វើទុកហើយ ឬព្រោះហេតុដែលបុគ្គលដទៃធ្វើឲ្យ ក្នុងបច្ចុប្បន្ន ឬព្រោះហេតុដែលខ្លួនធ្វើទុកហើយក្នុងកាលមុន ឬព្រោះមិនមានហេតុ មិនមានបច្ច័យ តែបុគ្គលរមែងសោយវេទនាទាំងនេះបាន ព្រោះហេតុដែលព្រះអាទិទេពជាធំនិម្មិតឲ្យប៉ុណ្ណោះ ដូច្នេះ ។

ម្យ៉ាងទៀត ពួកព្រាហ្មណ៍ទាំងនោះ មានប្រក្រតីពោលយ៉ាងនេះ គឺមិនព្រមទទួលយកអាពាធសូម្បីតែ ១ ក្នុងអាពាធ ៨ ដែលពោលខាងដើម រមែងឃាត់អាពាធទាំងអស់ ។ ក្នុងកោដ្ឋាសទាំងពួង មានទិដ្ឋធម្មវេទនីយ-កម្មជាដើមក៏ដូចគ្នា មិនព្រមទទួលកោដ្ឋាសសូម្បីតែមួយ រមែងហាមកោដ្ឋាសទាំងអស់ ។

បទថា **អហេតុអប្បច្ចយា** បានដល់ វៀរហេតុ និងបច្ច័យ អធិប្បាយថា រមែងសោយវេទនា ដោយមិនមានហេតុឡើយ ។ នេះជាលទ្ធិរបស់អាជីវក ។ អាជីវកទាំងនោះ ជាអ្នកមានប្រក្រតីពោលយ៉ាងនោះ ក៏មិនព្រមទទួលក្នុងហេតុទាំងឡាយតាមដែលពោលហើយខាងដើម និងក្នុងអាពាធទាំងឡាយ មានព្យាធិជាដើម សូម្បីត្រឹមតែមួយ រមែងបដិសេធទាំងអស់ ។

[ ១៧៥ ] បលិពោធទាំងឡាយ ឈ្មោះថា **កិញ្ចនា** ។ បទថា **រាគោ កិញ្ចនំ** បានដល់ រាគៈ កាលកើតឡើងរមែងចងសត្វ រមែងឲ្យសត្វកង្វល់

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅរាគៈថា **កិញ្ចនំ ។** ក្នុងទោសៈនិងមោហៈ ក៏ន័យនេះឯង ។

[ ១៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អង្គណានិ** នេះដូចតទៅ

ភូមិបទេសក្នុងអាគតដ្ឋាន ( ក្នុងខុទ្ទកនិកាយជាតក ) យ៉ាងនេះថា **ឧទង្គណោ តត្ថ បបំ អវិន្ទុំ** កាលដីក ( ផែនដី ) ត្រង់ផ្លូវខ្សាច់ ឬក្នុងទីទួលបាននូវទឹកត្រង់ផ្លូវនោះ ដូច្នេះ ឈ្មោះថា អង្គណៈ ។ មន្ទិល ឬកក់ឯណាទីមួយដែលមកក្នុងអាគតដ្ឋាន ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា **តស្សេវ រជស្ស វា អង្គណស្ស វា បហានាយ វាយមតិ** តែងព្យាយាមជម្រះធូលី ឬមុននោះចេញ ដូច្នេះ ឈ្មោះថា អង្គណៈ ។ កិលេសដែលក្រាស់ មានប្រការផ្សេងៗ មកក្នុងអាគតដ្ឋានថា **សាង្គណោវ សមានោ** អាត្មាអញមានអង្គណៈក្នុងខ្លួន ដូច្នេះ ឈ្មោះថា អង្គណៈ ( ទីទួល ) ។ ក្នុងទីនេះ បំណងយកកិលេសដូចទីទួលនោះ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា **រាគោ អង្គណំ** ជាដើម ។

[ ១៧៧ ] បទថា **មលានិ** បានដល់ កិលេសដែលធ្វើឲ្យសៅហ្មង ។ បទថា **រាគោ មលំ** អធិប្បាយថា រាគៈកាលកើតឡើង រមែងធ្វើចិត្តឲ្យសៅហ្មង រមែងឲ្យកាន់យកនូវភាពល្អក់កករ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅរាគៈថា **មន្ទិល ។** កិលេសទាំង ២ ដ៏សេសក្រៅអំពីនេះ ក៏ន័យនេះឯង ។

[ ១៧៨ ] ក្នុងនិទ្ទេសនៃធម្មជាតមិនរៀបស្មើ ព្រោះសត្វទាំងឡាយរមែងភ្លាំងភ្លាត់ក្នុងកិលេសទាំងឡាយ មានរាគៈជាដើម និងក្នុងទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ឯសត្វទាំងឡាយប្រព្រឹត្តភ្លាំងភ្លាត់ទៅហើយរមែងធ្លាក់ទៅអំពីសាសនាខ្លះ អំពីសុគតិខ្លះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **រាគោ វិសមំ** ជាដើម ព្រោះការប្រព្រឹត្តភ្លាំងភ្លាត់ ជាហេតុឲ្យធ្លាក់ទៅ ។

[ ១៨០ ] បទថា **អគ្គិ** បានដល់ ឈ្មោះថា ភ្លើង ព្រោះអត្ថថា ដុត ។ បទថា **រាគគ្គិ** អធិប្បាយថា រាគៈកាលកើតឡើង រមែងដុតសត្វ ញុំាំងសត្វឲ្យឆេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **អគ្គិ** ។ សូម្បីទោសៈ និងមោហៈ ក៏ន័យនេះឯង ។ ក្នុងអគ្គិនិទ្ទេសនោះ មានរឿងជាឧទាហរណ៍ដូចតទៅ

បានឮថា ភិក្ខុនីក្រមុំមួយរូប ទៅកាន់រោងឧបោសថក្នុងវិហារឈ្មោះចិត្តលបព៌ត ឈរមើលរូបរបស់អ្នកយាមទ្វារ ។ លំដាប់នោះ រាគៈកើតឡើងខាងក្នុងរបស់នាង នាងត្រូវភ្លើង គឺរាគៈនោះឯងឆេះហើយក៏ធ្វើកាលកិរិយា ។ ភិក្ខុនីទាំងឡាយកាលនឹងទៅ ពោលថា ភិក្ខុនីក្រមុំរូបនេះ កំពុងឈរ ចូរពួកនាងហៅនាងមក ។ ភិក្ខុនីមួយរូបដើរទៅហើយ ពោលថា នាងឈរធ្វើអ្វីហើយចាប់ដៃ ភិក្ខុនីក្រមុំនោះ គ្រាត្រូវចាប់ប៉ុណ្ណោះ ក៏ដួលចុះទៅ នេះជារឿងនៃការឆេះរបស់រាគៈ ។

ឯភ្លើង គឺទោសៈ គប្បីជ្រាបដូចជាទេវតាមួយពួកដែលមានឈ្មោះថា

**មនោបទោសិក** ព្រោះការផុតរបស់ទោសៈ ទើបត្រូវច្យុតិ ។ ភ្លើង គឺមោហៈ គប្បីជ្រាបដូចទេវតាមួយពួក ដែលមានឈ្មោះថា **ខិឌ្ឌាបទោសិក** ព្រោះ ការផុតរបស់មោហៈក៏ត្រូវច្យុតិ ។ ពិតហើយ ការវង្វេងគ្មានសតិ រមែងមាន ដល់ទេវតា ឈ្មោះថា **ខិឌ្ឌាបទោសិក** ទាំងនោះ ដោយអំណាចនៃមោហៈ ព្រោះហេតុនោះ កាលទេវតាទាំងនោះ ញុំាងកាលវេលាបរិភោគអាហារឲ្យ កន្លងទៅហើយ ក៏ធ្វើកាលកិរិយាដោយអំណាចនៃការសប្បាយនោះ ។

[ ១៨១ ] បទថា **កាសាវ** បានដល់ ទឹកដែលមិនមានតម្លៃ គឺមិន មានរស ។ វត្ថុដែលប្រណីតដែលមានឱជៈត្រឹមតែម្យ៉ាង ក្នុងកិលេសទាំង ឡាយ មានរាគៈជាដើម ក្នុងទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម មិន មាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **រាគោ កាសាវោ** ជា ដើម ។

[ ១៨៣ ] បទថា **អស្សាទទិដ្ឋិ** បានដល់ ទិដ្ឋិដែលសម្បយុត្តដោយ ការត្រេកអរ ។ បទថា **នត្ថិ កាមេសុ ទោសោ** បានដល់ សមណ-ព្រាហ្មណ៍ខាងក្រៅ រមែងពោលថា ទោសក្នុងការសេពវត្ថុកាមដោយកិលេស-កាម រមែងមិនមាន ។ បទថា **បាតព្យតំ** បានដល់ ការផឹក គឺការ បរិភោគ ការលេប ។ ពិតហើយ សមណព្រាហ្មណ៍នោះ មានប្រក្រតី ពោលយ៉ាងនេះ ទើបបរិភោគកិលេសកាមក្នុងវត្ថុកាមទាំងឡាយ ហាក់បីដូច បុគ្គលកំពុងផឹក កំពុងលេបនូវអាហារ ។ ការយល់ខុសប្រព្រឹត្តទៅតាមអត្តា ឈ្មោះថា អត្តានុទិដ្ឋិ ។

ទិដ្ឋិដ៏លាមក ឈ្មោះថា មិច្ឆាទិដ្ឋិ ។ ឥឡូវនេះ ដើម្បីសម្តែងសេចក្តីនោះ ព្រោះក្នុងទិដ្ឋិទាំងនោះ ទិដ្ឋិទី ១ ជាសស្សតទិដ្ឋិ ទិដ្ឋិទី ២ ជាសក្កាយ-ទិដ្ឋិ ទិដ្ឋិទី ៣ ជាឧច្ឆេទទិដ្ឋិ ទើបព្រះមានព្រះភាគត្រាស់ថា **សស្សតទិដ្ឋិ អស្សាទទិដ្ឋិ** ជាដើម ។

[ ១៨៤ ] និទ្ទេសនៃសេចក្តីមិនត្រេកអរ និងនិទ្ទេសនៃសេចក្តីបៀតបៀន មានអធិប្បាយតាមដែលពោលហើយនោះឯង ។

ការប្រព្រឹត្តមិនជាធម៌ ឈ្មោះថា **អធម្មចរិយា** អធិប្បាយថា ការធ្វើនូវវត្ថុដែលមិនមែនជាធម៌ ។ ការប្រព្រឹត្តដែលមិនស្មើ ឈ្មោះថា **វិសម-ចរិយា** ។ ម្យ៉ាងទៀត ឈ្មោះថា **វិសមចរិយា** ព្រោះអត្ថថា ការប្រព្រឹត្តកម្មដែលមិនស្មើ ។

[ ១៨៥ ] និទ្ទេសនៃការប្រដៅក្រ និងនិទ្ទេសនៃភាពជាអ្នកមានមិត្តអាក្រក់ មានអធិប្បាយតាមដែលពោលមកហើយនោះឯង ។ សញ្ញាទាំងឡាយ ក្នុងការផ្សេងគ្នា ឈ្មោះថា **នានត្តសញ្ញា** ព្រោះការប្រព្រឹត្តទៅក្នុងនិមិត្តនិងអារម្មណ៍ច្រើន ។ ម្យ៉ាងទៀត ព្រោះកាមសញ្ញាមួយបែប ព្យាបាទ-សញ្ញាជាដើម ក៏មួយបែប ហេតុនោះ ទើបឈ្មោះថា **នានត្តសញ្ញា** ព្រោះអត្ថថា មានសញ្ញាផ្សេងៗ គ្នា ។

[ ១៨៦-១៨៨ ] ការប្រព្រឹត្តធូរថយ ការមិនអាចប្រកបរឿយៗ ក្នុងការការចម្រើនកុសលធម៌នៃបុគ្គលដែលបណ្តោយចិត្តទៅក្នុងកាមគុណ ៥ ឈ្មោះថា **កោសជ្ជំ** ។ បណ្ឌិតគប្បីជ្រាបភាពនៃបុគ្គលដែលប្រមាទហើយ ដោយ

អំណាចនៃការស្រវឹង ឈ្មោះថា **បមាទោ** ។

ក្នុងនិទ្ទេសនៃសេចក្តីមិនសន្តោស ការមិនសន្តោសជាដើម មានអត្ថតាមដែលពោលហើយនោះឯង ។

[ ១៨៩ ] ក្នុងនិទ្ទេសនៃសេចក្តីមិនអើពើ ការមិនអើពើ ភាពនៃបុគ្គលដែលមិនអើពើដោយអំណាចនៃការមិនអើពើចំពោះឱវាទ ឈ្មោះថា **អនាទរិយំ** ។ អាការនៃការមិនអើពើ ឈ្មោះថា **អានាទរតា** ។ ភាពជាអ្នកមិនគោរព ឈ្មោះថា **អគារវតា** ព្រោះអត្ថថា មិននៅដោយមានបុគ្គលដែលគួរគោរព ។ ឈ្មោះថា **អប្បតិស្សវតា** ព្រោះអត្ថថា មិននៅដោយមានបុគ្គលជាប្រធាន ។ បទថា **អគ្គហោ** បានដល់ មិនទទួលយកឱវាទ ។ បទថា **អគ្គហណា** បានដល់ អាការនៃការមិនកាន់យក ។ ភាពនៃបុគ្គលដែលប្រព្រឹត្តទៅដោយមិនកាន់យក ឈ្មោះថា **អគ្គហិតត្តំ** ។ ភាពនៃបុគ្គលដែលមិនមានសីល ឈ្មោះថា **អសីល្យំ** ។ បទថា **អចិត្តីការោ** បានដល់ ការមិនធ្វើសេចក្តីគោរពកោតក្រែង ។

[ ១៩០ ] ភាពនៃបុគ្គលមិនមានសទ្ធា ឈ្មោះថា **អស្សទ្ធិយំ** ។ អាការនៃភាពជាអ្នកមិនមានសទ្ធា ឈ្មោះថា **អសទ្ទហនា** ។ ការមិនដាក់ចិត្តស្របតាមកាន់យក ឈ្មោះថា **អនោកប្បនា** ។ ឈ្មោះថា **អនភិប្បសាទោ** ព្រោះអត្ថថា មិនជ្រះថ្លាក្រៃលែង ។

បទថា **អវទញ្ញុតា** បានដល់ ការមិនដឹងដល់ពាក្យថា សូមលោកឲ្យទាន សូមលោកធ្វើបុណ្យ ព្រោះអំណាចនៃការកំណាញ់ដ៏ស្វិតស្វាញ ។

[ ១៩២ ] ក្នុងបទថា **ពុទ្ធា ច ពុទ្ធសាវកា ច** នេះ សូម្បីព្រះបច្ចេកពុទ្ធ ទ្រង់ក៏កាន់យកដោយពាក្យថា **ពុទ្ធ** នោះឯង ។ ភាពជាបុគ្គលមិនទៅកាន់ទីជិតនៃព្រះអរិយៈទាំងនោះ ឈ្មោះថា **អសមេតុកម្យតា** បានដល់ ពោធិបក្ខិយធម៌ ៣៧ ឈ្មោះថា ព្រះសទ្ធម្ម ។ ភាពជាបុគ្គលមិនត្រូវការស្តាប់នូវព្រះសទ្ធម្មនោះ ។ ភាពជាអ្នកមិនសិក្សាធម៌ ឈ្មោះថា **អនុគ្គហេតុកម្យតា** ។ ភាពជាបុគ្គលគិតគ្នេរក្នុងការប្រណាំងប្រជែង ឈ្មោះថា **ឧចារម្ភចិត្តតា** ។ ព្រោះបើពោលដោយអត្ថ ភាពជាបុគ្គលមានចិត្តប្រណាំងប្រជែងនោះ ជាការគិតប្រណាំងប្រជែងនោះឯង ព្រោះហេតុនោះ ដើម្បីសម្តែងការគិតប្រណាំងប្រជែងនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា **តត្ថ កតមោ ឧចារម្ភោ** ជាដើម ។ ក្នុងសេចក្តីនោះ ឈ្មោះថា **ឧចារម្ភោ** រមែងមានដោយអំណាចនៃការអួតអាង ។ ការគិតប្រណាំងប្រជែង កើតឡើងរឿយៗ ឈ្មោះថា **អនុចារម្ភោ** ។ អាការនៃការគិតប្រណាំងប្រជែង ឈ្មោះថា **ឧចារម្ភណា** ។ ភាពនៃបុគ្គល ដែលគិតប្រណាំងប្រជែងរឿយៗ ឈ្មោះថា **អនុចារម្ភិតត្តំ** ។

បទថា **ឧញ្ញា** បានដល់ ការឆ្មើងឆ្មៃ ។ បទថា **អវញ្ញា** បានដល់ ការមើលងាយ ។ ការពេបជ្រាយ ឈ្មោះថា **បរិភវោ** ។ ភាពជាអ្នកស្វែងរកទោស ឈ្មោះថា **រន្ធគវេសិតា** ។ ម្យ៉ាងទៀត បុគ្គលណារមែងស្វែងរកនូវកំហុស ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **រន្ធគវេសិតា** ។ ភាពនៃបុគ្គលអ្នកស្វែងរកទោសនោះ ឈ្មោះថា **រន្ធគវេសី** ។ ភាវៈជា

*រន្ធគវេសី ( ការស្វែងរក ) នោះ ឈ្មោះថា* **រន្ធគវេសិតា** ។ *បទថា* **អយំ វុច្ចតិ** *សេចក្តីថា សភាវៈដែលមានការឃ្លាំមើលទោសរបស់អ្នកដទៃ ជាលក្ខណៈនេះ ព្រះមានព្រះភាគត្រាស់ហៅថា* **ឧចារម្ភោ** *ដែលជាហេតុឲ្យបុគ្គលប្រកបហើយលុបគុណរបស់អ្នកដទៃគ្រប់យ៉ាង ហើយតាំងនៅក្នុងវត្ថុដែលមិនមែនជាគុណទាំងឡាយ ប្រៀបដូចជាងដេរប៉ះ វែកសំពត់ចេញ ហើយរកមើលតែទីធ្លុះ ។*

*[ ១៩៤ ] បទថា* **អយោនិសោមនសិការោ** *បានដល់ ធ្វើទុកក្នុងចិត្ត ដោយឧបាយមិនមែនប្រាជ្ញា ។ បទថា* **អនិច្ចេ និច្ចំ** *អធិប្បាយថា មនសិការដែលប្រព្រឹត្តទៅក្នុងវត្ថុដែលមិនទៀងយ៉ាងនេះថា វត្ថុនេះជារបស់ទៀងពិត ។ សូម្បីក្នុងបទថា* **ទុក្ខេ សុខំ** *ជាដើមក៏ន័យនេះ ។ បទថា* **សច្ចវិប្បដិកូលេន វា** *បានដល់ មនសិការដោយមិនអនុលោមតាមសច្ចៈទាំង ៤ ។ សូម្បីបទទាំងពួង មានបទថា* **ចិត្តស្ស អាវជ្ជនា** *ជាដើម ក៏ជាវេវចនៈនៃអាវជ្ជនចិត្តនោះឯង ។ ពិតហើយ អាវជ្ជនៈ ឈ្មោះថា* **អាវជ្ជនា** *ព្រោះញ៉ាំងភវង្គឲ្យវិលទៅ ។ ឈ្មោះថា* **អនាវជ្ជនា** *ព្រោះឲ្យវិលទៅរឿយៗ ។ ចិត្តណា រមែងគិតដល់អារម្មណ៍ ព្រោះហេតុនោះ ទើបចិត្តនោះ ឈ្មោះថា* **អាភោគោ** ។ *ចិត្តណារមែងប្រមូលមកនូវអារម្មណ៍ដទៃ ក្រៅអំពីអារម្មណ៍របស់ភវង្គ ព្រោះហេតុនោះ ទើបចិត្តនោះ ឈ្មោះថា* **សមន្នាហារោ** ។ *សភាវៈណាធ្វើអារម្មណ៍នោះឯង ទុកក្នុងចិត្តដែលកំពុងកើតឡើងចំពោះខ្លួនឯង ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា* **មនសិការោ** ។ *បទថា* **ករោតិ**

បានដល់ រមែងតាំងទុក ។ បទថា **អយំ វុច្ចតិ** សេចក្តីថា សភាវៈដែលធ្វើទុកក្នុងចិត្ត ដោយឧបាយដែលមិនមែនប្រាជ្ញា ដែលមានមនសិការខុសទំនងជាលក្ខណៈ នេះព្រះមានព្រះភាគត្រាស់ហៅថា **អយោនិសោមនសិការោ** ដែលមានអំណាចធ្វើឲ្យបុគ្គល មិនអាចពិចារណាសច្ចៈទាំងឡាយមានទុក្ខសច្ចជាដើម តាមសេចក្តីពិតបាន ។

ក្នុងនិទ្ទេសនៃកាសេពផ្លូវខុស ព្រះមានព្រះភាគ ត្រាស់ការសេពរបស់បុគ្គលដែលសេពផ្លូវខុសឯណា ការសេពផ្លូវខុស ដូច្នេះ ដើម្បីសម្តែងផ្លូវខុសនោះ ទើបទ្រង់ធ្វើទុតិយបុច្ឆាថា **តត្ថ កតមោ កុម្មគ្គសេវនា ។** ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

**តិកនិទ្ទេស ចប់**

## ចតុក្កនិទ្ទេស

[ ១៩៨ ] ក្នុងនិទ្ទេសនៃមាតិកាពួក ៤ ក្នុងតណ្ហុបាទា បទថា **ចីវរហេតុ** សេចក្តីថា តណ្ហារមែងកើតឡើងព្រោះចីវរជាហេតុយ៉ាងនេះថា អញនឹងបានចីវរដែលគាប់ចិត្តក្នុងទីណា ។ **ឥតិ** សព្ទ ក្នុងបទថា **ឥតិ ភវាភវហេតុ** នេះ ជានិបាត ចុះក្នុងអត្ថនៃនិទស្សនៈ គឺឧទាហរណ៍ អធិប្បាយថា តណ្ហារមែងកើត ព្រោះចីវរជាហេតុយ៉ាងណា តណ្ហាក៏រមែងកើតព្រោះ

បច្ច័យដទៃ ដែលប្រណីត និងប្រណីតក្រៃលែងជាង ជាហេតុ ក៏យ៉ាងនោះ វត្ថុទាំងឡាយ មានប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើមដែលប្រណីត និងប្រណីតក្រៃលែងជាង ព្រះមានព្រះភាគទ្រង់បំណងយកក្នុងបទថា **ភវាភវោ** នេះ ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សម្ដែងអរិយវង្ស ៤ តាមលំដាប់ដើម្បីប្រយោជន៍ដល់ការលះនូវការកើតឡើងនៃតណ្ហា ៤ នេះ ។

[ ១៩៩ ] ក្នុងការលុះអគតិ បទថា **ឆន្ទាគតឹ គច្ឆតិ** អធិប្បាយថា បុគ្គលរមែងលម្អៀង គឺរមែងធ្វើនូវវត្ថុដែលមិនគួរធ្វើ ព្រោះឆន្ទៈ គឺព្រោះសេចក្ដីស្រឡាញ់ ។ ក្នុងបទដទៃៗ ក៏ន័យនេះឯង ។ ក្នុងអគតិទាំងនោះ បុគ្គលណារមែងធ្វើបុគ្គលដែលមិនមែនជាម្ចាស់ទ្រព្យ ឲ្យជាម្ចាស់ទ្រព្យដោយអំណាចនៃការពេញចិត្ត គឺសេចក្ដីស្រឡាញ់ថា បុគ្គលនេះជាមិត្តក្ដី ជាមិត្តធ្លាប់ឃើញក្ដី ជាមិត្តរួមបរិភោគក្ដី ជាញាតិក្ដីរបស់អញ ឬបុគ្គលនេះ រមែងឲ្យសំណូកដល់អញ ដូច្នេះ បុគ្គលនេះឈ្មោះថា បុគ្គលដល់នូវការលម្អៀងព្រោះស្រឡាញ់ ។

បុគ្គលណា ធ្វើម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យដោយអំណាចដែលជារបស់មានម្ចាស់ ឲ្យជារបស់មិនមានម្ចាស់ ដោយអំណាចនៃពៀរជាប្រក្រតី ( ធ្លាប់ស្អប់អំពីមុន ) ឬដោយអំណាចនៃសេចក្ដីក្រោធដែលកើតឡើងក្នុងខណៈនោះថា បុគ្គលនេះជាសត្រូវរបស់អញ ដូច្នេះ បុគ្គលនេះ ឈ្មោះថា ដល់នូវការលម្អៀង ព្រោះស្អប់ ។

បុគ្គលណាពោលពាក្យផ្ដេសផ្ដាស ធ្វើម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យ

ព្រោះជាមនុស្សល្ងង់ខ្លៅ ព្រោះជាមនុស្សមិនមានបញ្ញា បុគ្គលនេះ ឈ្មោះថា ដល់នូវការលម្អៀងព្រោះវង្វេង ។

បុគ្គលណា មានការខ្លាចថា អ្នកនេះជារាជវល្លភៈក្តី ជាអ្នកប្រព្រឹត្តមិនរាបសា គប្បីធ្វើសេចក្តីវិនាសឲ្យដល់អញ ដូច្នេះ រមែងធ្វើបុគ្គលមិនមែនម្ចាស់ទ្រព្យឲ្យជាម្ចាស់ទ្រព្យ នេះឈ្មោះថា ដល់នូវការលម្អៀង ព្រោះខ្លាច ។

ម្យ៉ាងទៀត បុគ្គលណាកាលបែងចែករបស់ណាមួយ ក្នុងឋានៈដែលគួរបែងចែក រមែងឲ្យច្រើនដោយអំណាចនៃសេចក្តីស្រឡាញ់ថា បុគ្គលនេះជាមិត្តក្តី ជាមិត្តធ្លាប់ឃើញក្តី ជាមិត្តរួមបរិភោគក្តីរបស់អញ ដូច្នេះ រមែងឲ្យតិចដោយអំណាចនៃទោសៈថា បុគ្គលនេះជាសត្រូវរបស់អញ មិនដឹងរបស់ដែលឲ្យហើយ ឬមិនទាន់បានឲ្យ ព្រោះខ្លួនល្ងង់ខ្លៅ ទើបឲ្យរបស់តិចដល់បុគ្គលខ្លះ ឲ្យរបស់ច្រើនដល់បុគ្គលខ្លះ ជាអ្នកខ្លាចថា កាលអញមិនឲ្យវត្ថុនេះ បុគ្គលនេះ គប្បីធ្វើសេចក្តីវិនាសដល់អញ រមែងឲ្យរបស់ច្រើន ដល់បុគ្គលខ្លះ បុគ្គល ៤ ពួកនេះ ឈ្មោះថា រមែងលម្អៀង ព្រោះស្រឡាញ់ជាដើម តាមលំដាប់ ។ ព្រះអរិយៈទាំងឡាយ រមែងមិនប្រព្រឹត្តទៅដោយធម្មជាតនោះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **អគតិ** ។ ជនទាំងឡាយមិនមែនព្រះអរិយៈ រមែងដល់នូវការលម្អៀងដោយធម្មជាតនេះ ព្រោះហេតុនោះ ទើបធម្មជាតនេះ ឈ្មោះថា **អគតិគមនំ** ។ បទទាំង ២ នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចជាពាក្យទូទៅនៃអគតិគមនៈ ទាំង ៤ ។ ការលម្អៀងព្រោះស្រឡាញ់ ឈ្មោះថា **ឆន្ទាគមនំ** ។ ឆន្ទាគមនៈនេះ

ព្រះមានព្រះភាគ ត្រាស់ដោយអំណាច មិនទូទៅដល់ធម៌ មានទោសៈជាដើម ។ ការលម្អៀង ព្រោះមិនសាមគ្គីគ្នា ដោយបំណងដល់សេចក្តីស្រឡាញ់បក្ខពួករបស់ខ្លួន និងទីងក្រោធក្នុងបក្ខពួករបស់បុគ្គលដទៃ ឈ្មោះថា **វគ្គគមនំ** ។ ការលម្អៀងព្រោះជាបក្ខពួកនេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចទូទៅដល់ធន្ទៈ និងទោសៈ ។ ឈ្មោះថា **វារិគមនំ** ព្រោះអត្ថថា លុះទៅដូចជាទឹកដែលហូរទៅកាន់ទីទាប ការលុះទៅដូចទឹកហូរនេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចទូទៅដល់ការលម្អៀងទាំង ៤ ។

[ ២០០ ] ក្នុងការស្វែងរកខុស ឈ្មោះថា **វិបរិយេសា** ព្រោះអត្ថថា ស្វែងរកវត្ថុដែលមិនទៀងជាដើមដោយវិបរិត ដោយន័យថា ទៀងជាដើម ។ ការយល់ខុសព្រោះសញ្ញា ឈ្មោះថា **សញ្ញាវិបរិយេសោ** ។ ក្នុងការយល់ខុសទាំង ២ ក្រៅអំពីនេះ ក៏ន័យនេះ ។ ការយល់ខុសទាំងនោះ មាន ៤ ដោយអំណាចនៃវត្ថុ ៤ ( មិនទៀង ជាទុក្ខ មិនមែនខ្លួន មិនស្អាត ) ទើបជា ១២ ដោយអំណាចនៃសញ្ញាជាដើម ក្នុងវត្ថុពួកណា ការយល់ខុស ៨ ក្នុងវត្ថុទាំងនោះ រមែងលះបានដោយសោតាបត្តិមគ្គ ។ សញ្ញាវិបល្លាស និងចិត្តវិបល្លាស ក្នុងវត្ថុដែលមិនស្អាតថាស្អាត គប្បីជ្រាបថា រមែងស្រាលស្តើងដោយសកទាគាមិមគ្គ និងរមែងលះបានដោយអនាគាមិមគ្គ ។ សញ្ញាវិបល្លាស និងចិត្តវិបល្លាសក្នុងវត្ថុដែលជាទុក្ខថាជាសុខ គប្បីជ្រាបថា រមែងលះបានដោយអំណាចនៃអរហត្តមគ្គ ។

[ ២០១-២០២ ] ក្នុងវោហារដែលមិនប្រសើរ បទថា **អនរិយវោហារា**

បានដល់ វោហាររបស់បុគ្គលដែលមិនមែនជាអរិយៈ គឺរបស់បុគ្គលដែលថោកថយ ។ បទថា **ទិដ្ឋវាទិតា** បានដល់ ជាអ្នកមានប្រក្រតីពោលយ៉ាងនេះថា វត្ថុនេះខ្ញុំឃើញហើយ ។ ក្នុងពាក្យនេះ បណ្ឌិតគប្បីជ្រាបអត្ថដោយអំណាចនៃចេតនាដែលញ៉ាំងវាចានោះៗ ឲ្យតាំងឡើង ។ មានពាក្យពោលដូចគ្នាថា លោកពោលដោយចេតនាជាមួយនឹងសំឡេង ដូច្នេះក៏មាន ។ ក្នុងចតុក្កៈនៃអរិយវោហារទី ២ ក៏មានន័យនេះ ។ ពិតហើយ ឈ្មោះថាព្រះអរិយៈមិនឃើញ ហើយពោលថា ខ្ញុំឃើញ ឬថាឃើញ ហើយពោលថាខ្ញុំមិនឃើញ រមែងមិនមាន ។ បុគ្គលមិនមែនព្រះអរិយៈប៉ុណ្ណោះ រមែងពោលយ៉ាងនេះ ព្រោះហេតុនោះ កាលបុគ្គលពោលយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ចេតនា ៨ មួយអន្លើដោយសំឡេង ឈ្មោះថា វោហារមិនប្រសើរ ៨ ។

[ ២០៣ ] ក្នុងទុច្ចរិតទាំងឡាយ ចតុក្កៈនៃទុច្ចរិតទី ១ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃចេតនាដែលជាបាប ។ ចតុក្កៈទី ២ ត្រាស់ដោយអំណាចនៃវចីទុច្ចរិត ។

[ ២០៥-២០៨ ] ក្នុងភ័យទាំងឡាយ ក្នុងចតុក្កៈនៃភ័យទី ១ ភ័យដែលកើតឡើងព្រោះអាស្រ័យការកើត ឈ្មោះថា **ជាតិភយំ ។** សូម្បីក្នុងភ័យដ៏សេសក៏ន័យនេះឯង ។ ក្នុងចតុក្កៈនៃភ័យទី ២ ភ័យកើតឡើងអំពីព្រះរាជាឈ្មោះថា **រាជភយំ ។** សូម្បីភ័យដ៏សេសក៏ន័យនេះឯង ។ ចតុក្កៈនៃភ័យទី ៣ បទថា **ចត្តារិ ភយានិ** បានដល់ ភ័យដែលព្រះមានព្រះភាគ ត្រាស់

ដោយបុគ្គលដែលចុះទឹកក្នុងមហាសមុទ្ទ ។

បានឮថា ក្នុងមហាសមុទ្ទ រលក ឈ្មោះថា **មហិន្ទ** ដែលតាំងឡើងខាងលើ ៦០ យោជន៍ ។ រលក ឈ្មោះថា **គង្គា** តាំងឡើងខាងលើ ៥០ យោជន៍ ។ រលក ឈ្មោះថា **រោហណា** តាំងឡើងខាងលើ ៤០ យោជន៍ ។ ភ័យដែលកើតឡើងព្រោះអាស្រ័យរលកទាំងឡាយបែបនេះ ឈ្មោះថា **"ឩមិភយំ** ។ ភ័យកើតអំពីក្រពើ ឈ្មោះថា **កុម្ភីលភយំ** ។ ភ័យកើតអំពីអន្ទង់ទឹកកួច ឈ្មោះថា **អាវដ្ដភយំ** ។ ត្រីកាច ហៅថា **សុសុកា** ។ ភ័យដែលកើតឡើងអំពីត្រីកាចនោះ ឈ្មោះថា **សុសុកាភយំ** ។

ក្នុងចតុក្កៈនៃភ័យទី ៤ បទថា **អត្តានុវាទភយំ** បានដល់ ភ័យដែលកើតឡើងដល់បុគ្គលដែលធ្វើបាបកម្មតិះដៀលខ្លួន ។ បទថា **បរានុវាទភយំ** បានដល់ ភ័យដែលកើតឡើងអំពីការតិះដៀលរបស់អ្នកដទៃ ។ បទថា **ទណ្ឌភយំ** បានដល់ ភ័យដែលកើតឡើង ព្រោះអាស្រ័យអាជ្ញាដែលព្រះរាជាឲ្យប្រព្រឹត្តទៅដល់បុគ្គលដែលគ្រប់គ្រងផ្ទះ និងព្រោះអាជ្ញា គឺព្រះវិន័យដល់បុគ្គលមិនគ្រប់គ្រងផ្ទះ ។ បទថា **ទុគ្គតិភយំ** បានដល់ ភ័យដែលកើតឡើង ព្រោះអាស្រ័យអបាយភូមិ ៤ ។ ឈ្មោះថា មហាភ័យ ១៦ ព្រះមានព្រះភាគត្រាស់ហើយ ដោយចតុក្កៈនីមួយៗ ៤ ដោយប្រការដូច្នេះ ។

[ ២០៩ ] ព្រះមានព្រះភាគត្រាស់ **តិម្ពរុកទិដ្ឋិ**[១] ក្នុងទិដ្ឋិចតុក្កៈ ។ ក្នុងទិដ្ឋិទាំងនោះ ។ បទថា **សយំ កតំ សុខទុក្ខំ** បានដល់ ការយល់ខុស

---

១- សេចក្ដីពិស្ដារ សូមមើលក្នុងតិម្ពរុក្ខសូត្រ បិដកខ្មែរលេខ ៣១ លេខឃ្នាប ៥៣ ឯណោះ ។

ដែលកើតឡើងថា វេទនាដែលវេទនានោះឯងធ្វើដល់បុគ្គលដែលឃើញវេទនាដោយភាពជាអត្តា ជាតួខ្លួន កាលបើយ៉ាងនោះ វេទនានោះក៏នឹងប្រាកដថាមានក្នុងកាលមុន ព្រោះហេតុនោះ ទើបទិដ្ឋិនេះ ឈ្មោះថា សស្សតទិដ្ឋិ ។ បទថា **សច្ចតោ ថេតតោ** បានដល់ ដោយសច្ចៈ ដោយថាវរៈ ។ បទថា **បរំ កតំ** បានដល់ ការយល់ខុសដែលកើតឡើង វេទនានេះដែលវេទនាដទៃធ្វើឲ្យដល់បុគ្គលដែលឃើញខ្លួនមានវេទនា មានហេតុនៃវេទនាដទៃអំពីវេទនា ដែលកើតឡើងចំពោះមុខ ។ កាលបើយ៉ាងនេះ ការដាច់សូន្យនៃវេទនាដែលកើតឡើងមុន គឺនៃវេទនាដែលធ្វើ រមែងប្រាកដ ព្រោះហេតុនោះទើបទិដ្ឋិនេះ ឈ្មោះថា **ឧច្ឆេទទិដ្ឋិ** ។ បទថា **សយំ កតញ្ច បរកតញ្ច** បានដល់ ទិដ្ឋិដែលកើតឡើងដល់បុគ្គលដែលប្រកាន់ថា សុខទុក្ខ ខ្លួនធ្វើពាក់កណ្តាល អ្នកដទៃធ្វើឲ្យពាក់កណ្តាល ដោយអត្ថតាមដែលពោលហើយនោះឯង ទើបទិដ្ឋិនេះ ឈ្មោះថា **សស្សតទិដ្ឋិ** និង **ឧច្ឆេទទិដ្ឋិ** ។ ទិដ្ឋិទី ៤ដែលកើតឡើងដល់បុគ្គលដែលប្រកាន់ថា សុខទុក្ខ មិនមានហេតុ កាលបើយ៉ាងនោះ ទើបទិដ្ឋិនេះឈ្មោះថា **អហេតុកទិដ្ឋិ** ។ បទដ៏សេសក្នុងទិដ្ឋិនិទ្ទេសនេះមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយនោះឯង ។

**ចតុក្កនិទ្ទេស ចប់**

# បញ្ចកនិទ្ទេស

[ ២១០-២១៤ ] ក្នុងនិទ្ទេសនៃពួក ៥ ព្រោះសំយោជនៈទាំងឡាយមានសក្កាយទិដ្ឋិជាដើម ដែលបុគ្គលណាមិនទាន់លះបាន សំយោជនៈទាំងនេះក៏នឹងប្រាទបុគ្គលទាំងនោះ ដែលកើតក្នុងភវគ្គភូមិ ឲ្យទៅក្នុងកាមភពនោះឯង ព្រោះហេតុនោះ ទើបសំយោជនៈទាំងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា សំយោជនៈជាចំណែកខាងក្រោម ។ ដោយហេតុនេះ ទើបសំយោជនៈទាំង ៥ នេះមិនហាមបុគ្គលឲ្យទៅកាន់ភវគ្គភូមិ តែរមែងនាំបុគ្គលដែលទៅហើយនោះឲ្យត្រឡប់មកកាន់ភពនេះទៀត ។ សំយោជនៈខាងលើ ៥ មានរូបរាគៈជាដើម ក៏មិនបានហាមបុគ្គលដែលទៅកាន់ភវគ្គភូមិ តែរមែងឲ្យត្រឡប់មកកាន់ភពនេះទៀត ។ កិលេស ៥ មានរាគៈជាដើម ត្រាស់ហៅថា **សង្គា** ព្រោះអត្ថថា ធ្វើឲ្យជាប់ជំពាក់ ម្យ៉ាងទៀត ត្រាស់ហៅថា **សល្លា** ព្រោះអត្ថថា ចូលទៅចាក់ដោត ។

[ ២១៥ ] បទថា **ចេតោខិលា** បានដល់ ភាពដែលចិត្តជាធម្មជាតរឹង ភាពដែលចិត្តដូចជាគំនរសំរាម ភាពដែលចិត្តដូចជាជន្ទត់ឈើ ។ បទថា **សត្ថរិ កង្ខតិ** បានដល់ សង្ស័យក្នុងព្រះសរីរកាយ ឬក្នុងព្រះគុណរបស់ព្រះសាស្តា ។ បុគ្គលកាលសង្ស័យក្នុងព្រះសរីរៈ តែងសង្ស័យថា ព្រះសរីរៈ ឈ្មោះថា ប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ៣២ ប្រការនោះ មានឬមិនមានហ្ន៎ ដូច្នេះ ។ កាលសង្ស័យក្នុងព្រះគុណ តែងសង្ស័យថា ព្រះ

សព្វញ្ញុតញ្ញាណដែលអាចដឹងអតីត អនាគត និងបច្ចុប្បន្ន មានឬមិនមានហ្ន៎ ដូច្នេះ ។ បទថា **វិចិកិច្ឆតិ** បានដល់ បុគ្គលកាលគិតរមែងលំបាក រមែងជួបនូវសេចក្ដីទុក្ខ រមែងមិនអាចកាត់សម្រេចបាន ។ បទថា **នាធិមុច្ចតិ** បានដល់ រមែងបានចំពោះនូវការបង្អោនចិត្តជឿថា វត្ថុនេះយ៉ាងនេះ ដូច្នេះ ។ បទថា **ន សម្បសីទតិ** បានដល់ បុគ្គលឈមចុះកាន់ព្រះគុណទាំងឡាយហើយ រមែងមិនអាចជ្រះថ្លា ជាអ្នកល្អក់កករ ដោយភាពជាអ្នកអស់នូវសេចក្ដីសង្ស័យ ។

បទថា **ធម្មេ** បានដល់ រមែងសង្ស័យក្នុងព្រះបរិយត្តិធម៌ ក្នុងបដិវេធ-ធម៌ អធិប្បាយថា កាលសង្ស័យក្នុងព្រះបរិយត្តិធម៌ រមែងសង្ស័យថា ជនទាំងឡាយ រមែងពោលថា ព្រះត្រៃបិដក គឺព្រះពុទ្ធវចនៈ មាន ៨៤០០០ ព្រះធម្មក្ខន្ធនោះ មាន ឬមិនមានហ្ន៎ ដូច្នេះ កាលសង្ស័យក្នុងបដិវេធធម៌ រមែងសង្ស័យថា ជនទាំងឡាយ រមែងពោលថា ផលដែលហូរចេញអំពីវិបស្សនា ឈ្មោះថា មគ្គ ផលដែលហូរចេញអំពីមគ្គ ឈ្មោះថា ផល ការលះសង្ខារទាំងឡាយ ឈ្មោះថា ព្រះនិព្វាន សេចក្ដីនោះ មាន ឬមិនមានហ្ន៎ ដូច្នេះ ។

បទថា **សង្ឃេ កង្ខតិ** បានដល់ សង្ស័យថា ឈ្មោះថា សង្ឃ ជាពួកនៃព្រះអរិយបុគ្គល ៨ គឺបុគ្គលដែលតាំងនៅក្នុងមគ្គ ៤ ផល ៤ ដែលបដិបត្តិបដិបទាយ៉ាងនេះ ដោយអំណាចបទថា លោកបដិបត្តិដោយត្រង់ជាដើម មាន ឬមិនមានហ្ន៎ ។

កាលសង្ស័យក្នុងសិក្ខា រមែងសង្ស័យថា បុគ្គលទាំងឡាយ ពោលថា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ដូច្នេះ សិក្ខានោះ មាន ឬមិនមានហ្ន៎ ។

[ ២១៦ ] គប្បីជ្រាបវិគ្គហៈក្នុងបទថា **ចេតសោ វិនិពន្ធា** ដូចតទៅនេះ ឈ្មោះថា ចេតសោវិនិពន្ធៈ ព្រោះអត្ថថា ចងចិត្តទុកដូចបុគ្គលកាន់ទុកក្នុងកណ្ដាប់ដៃ ។ បទថា **កាមេ** បានដល់ ក្នុងវត្ថុកាមខ្លះ ក្នុងកិលេស-កាមខ្លះ ។ បទថា **កាយេ** បានដល់ ក្នុងកាយរបស់ខ្លួន ។ បទថា **រូបេ** បានដល់ ក្នុងរូបខាងក្រៅ ។ បទថា **យាវទត្ថំ** បានដល់ តាមដែលខ្លួនត្រូវការ ។ បទថា **ឧទរាវទេហកំ** បានដល់ ពេញពោះ ។ ពិតហើយ អាហារពេញពោះនោះ ព្រះមានព្រះភាគត្រាស់ហៅថា ឧទរាវទេហកៈ ព្រោះការបរិភោគអាហារ រហូតឆ្អែតស្កប់ស្កល់ ។ បទថា **សេយ្យសុខំ** បានដល់ រកសេចក្ដីសុខលើគ្រែ និងតាំង ឬសេចក្ដីសុខដែលទាក់ទងក្នុងឧណ្ហភូមិ ។ បទថា **បស្សសុខំ** បានដល់ សេចក្ដីសុខរបស់បុគ្គលដែលដេកត្រឡប់ទៅត្រឡប់មកខាងស្ដាំ ឬខាងឆ្វេង របស់បុគ្គលដែលដេកប្រែខ្លួនទៅមកយ៉ាងណា សេចក្ដីសុខដែលកើតឡើងហើយក្នុងទីនេះ ក៏យ៉ាងនោះ ។ បទថា **មិទ្ធសុខំ** បានដល់ សេចក្ដីសុខក្នុងការដេកលក់ ។ បទថា **អនុយុត្តោ** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ។ បទថា **បណិធាយ** បានដល់ ត្រូវការហើយ ។ ក្នុងបទថា **សីលេន** ជាដើម បទថា **សីលំ** បានដល់ ចតុប្បារិសុទ្ធិសីល ។ បទថា **វត្តំ** បានដល់ ការសមាទានវត្ត ។ បទថា

**តបោ** បានដល់ ការប្រព្រឹត្តតបៈ ។ បទថា **ព្រហ្មចរិយំ** បានដល់ វៀរមេថុនធម្ម ។

បទថា **ទេវោ វា ភវិស្សាមិ** បានដល់ អាត្មាអញនឹងជាទេវតាដែលមានសក្តិធំ ។ បទថា **ទេវញ្ញតរោ វា** បានដល់ ឬជាទេវតាមានសក្តិតូចអង្គណាមួយ ដូច្នេះ ។

[ ២១៧ ] ធម៌ទាំងឡាយដែលឈ្មោះថា នីវរណៈ ព្រោះអត្ថថា រមែងរាំង រមែងបិទបាំងនូវកុសលធម៌ទាំងឡាយ ។

[ ២១៨ ] បទថា **មាតា ជីវិតា វោរោបិតា ហោតិ** បានដល់ មនុស្សប៉ុណ្ណោះ សម្លាប់មាតារបស់ខ្លួនជាមនុស្ស សូម្បីបិតាក៏ជាមនុស្សយ៉ាងនោះឯង ។ ព្រះអរហន្តក៏ជាព្រះអរហន្តមនុស្សនោះឯង ។ បទថា **ទុដ្ឋេន ចិត្តេន** បានដល់ ចិត្តគិតនឹងសម្លាប់ ។

[ ២១៩ ] បទថា **សញ្ញី** បានដល់ ដល់ព្រមដោយសញ្ញា ។ បទថា **អរោគោ** បានដល់ ទៀងពិត ។ បទថា **ឥត្ថេកេ អភិវទន្តិ** កាត់បទជា **ឥត្ថំ ឯកេ អភិវទន្តិ** អធិប្បាយថា សមណព្រាហ្មណ៍ពួកមួយ រមែងពោលយ៉ាងនេះ ។ សញ្ញីវាទ ១៦ ព្រះមានព្រះភាគត្រាស់ទុកដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ បទថា **អសញ្ញី** បានដល់ វៀរចាកសញ្ញា ។ អសញ្ញីវាទ ៨ ព្រះមានព្រះភាគ ត្រាស់ទុកដោយបទថា អសញ្ញីនេះ ។ នេវសញ្ញីនាសញ្ញីវាទ ៨ ព្រះមានព្រះភាគត្រាស់ដោយបទទី ៣ ។ បទថា **សតោ វា បន សត្តស្ស** បានដល់ ម្យ៉ាងទៀត របស់សត្វដែលមាននោះ

ឯង ។ បទថា **ឧច្ឆេទំ** បានដល់ ការចូលទៅកាត់ ។ បទថា **វិនាសំ** បានដល់ ការមិនឃើញ ។ បទថា **វិភវំ** បានដល់ ការប្រាសចាកភព ។ បទទាំងអស់នេះជាវេវចនៈនៃគ្នានិងគ្នា ។

ក្នុងសេចក្ដីនោះ មនុស្ស ២ នាក់ គឺបុគ្គលបានឈាន ១ មិនបានឈាន ១ រមែងកាន់យកឧច្ឆេទទិដ្ឋិ ។ ក្នុងបុគ្គល ២ ពួកនោះ ឈានលាភីបុគ្គល ឃើញចុតិរបស់ព្រះអរហន្តដោយទិព្វចក្ខុ តែមិនឃើញបដិសន្ធិ ឬឈានលាភីបុគ្គលណា អាចឃើញត្រឹមតែចុតិប៉ុណ្ណោះ មិនអាចឃើញបដិសន្ធិ បុគ្គលនោះ រមែងកាន់យកនូវឧច្ឆេទទិដ្ឋិ ។

បុគ្គលមិនបានឈាន រមែងកាន់យកការដាច់សូន្យ ព្រោះគិតថា អ្នកណាហ្ន៎ នឹងដឹងនូវបរលោក ដូច្នេះហើយ ទើបវិលវល់ក្នុងកាមសុខ ឬព្រោះការត្រិះរិះជាដើមថា សត្វទាំងឡាយ ប្រៀបដូចស្លឹកឈើ ដែលជ្រុះហើយ រមែងមិនដុះឡើងទៀត ក្នុងសេចក្ដីនេះឧច្ឆេទវាទ ៧ ដែលកើតឡើងកំណត់ដោយប្រការនោះផង ដោយប្រការដទៃផង ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃតណ្ហា និងទិដ្ឋិទាំងឡាយ ។ ពិតហើយ នេះជាពាក្យសរុបឧច្ឆេទវាទទាំងនោះ ។ បច្ចក្ខធម៌ គឺធម៌ដែលឃើញប្រចក្ស ព្រះមានព្រះភាគត្រាស់ហៅថា ទិដ្ឋធម៌ ក្នុងព្រះតម្រាស់ថា **ទិដ្ឋធម្មនិព្វានំ វា បនេកេ** ដូច្នេះ ។ ពាក្យនេះ ជាឈ្មោះរបស់អត្តភាពដែលបុគ្គលបានចំពោះក្នុងទីនោះៗ ។ និព្វានក្នុងទិដ្ឋធម៌ ឈ្មោះថា ព្រះនិព្វានក្នុងបច្ចុប្បន្ន អធិប្បាយថា ការចូលទៅស្ងប់នៃទុក្ខក្នុងអត្តភាពនេះ នោះឯង ។ នេះជាពាក្យសរុបវាទៈថា ទិដ្ឋធម្មនិព្វាន

៥ ប្រការ ។

[ ២២០-២២២ ] បទថា **វេរា** បានដល់ ចេតនាដែលអាក្រក់ ។ បទថា **ព្យសនា** បានដល់ សេចក្ដីវិនាសទាំងឡាយ ។

បទថា **អក្ខន្តិយា** បានដល់ នៃការមិនអត់ធន់ ។ បទថា **អប្បិយោ** បានដល់ មិនគប្បីជាទីស្រឡាញ់ព្រោះជារបស់គួររង្កៀសក្នុងការឃើញ ក្នុងការស្ដាប់ ។ ឈ្មោះថា **អមនាបោ** ព្រោះអត្ថថា ជាទីដែលចិត្តមិនហូរទៅព្រោះគិតក៏គួររង្កៀស ។ បទថា **វេរពហុលោ** បានដល់ ពៀរមានច្រើន ។ បទថា **វជ្ជពហុលោ** បានដល់ ទោសមានច្រើន ។

[ ២២៣ ] ភ័យដែលកើតឡើងព្រោះអាស្រ័យអាជីវៈ គឺការញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ឈ្មោះថា អាជីវកភយៈ ។ អាជីវកភ័យនោះ រមែងមានដល់បុគ្គលគ្រប់គ្រងផ្ទះខ្វះ ដល់បុគ្គលមិនគ្រប់គ្រងផ្ទះខ្វះ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលអ្នកគ្រប់គ្រងផ្ទះ រមែងធ្វើកម្មជាអកុសលច្រើន ព្រោះហេតុនៃអាជីវៈជាដំបូង បន្ទាប់អំពីនោះ ភ័យរមែងកើតដល់បុគ្គលនោះ កាលនរកប្រាកដក្នុងវេលាជិតស្លាប់ ។ ចំណែកបុគ្គលមិនគ្រប់គ្រងផ្ទះសោត កាលធ្វើអនេសនា គឺការស្វែងរកចិញ្ចឹមជីវិតក្នុងផ្លូវដែលមិនសមគួរជាច្រើន បន្ទាប់អំពីនោះ ភ័យរមែងកើតដល់បុគ្គលនោះ កាលនរកប្រាកដក្នុងពេលជិតស្លាប់ នេះឈ្មោះថា អាជីវកភ័យ ។ បទថា **អសិលោកភយំ** បានដល់ ភ័យគឺការតិះដៀល ។ បទថា **បរិសសារជ្ជភយំ** បានដល់ កាលបុគ្គលធ្វើបាបទុកហើយ ចូលទៅកាន់ទីប្រជុំជន ភ័យគឺការតក់ស្លុតរមែងកើតឡើង នេះ

ឈ្មោះថា បរិសសារជ្ជភ័យ ។ ភ័យទាំង ២ ក្រៅអំពីនេះ គឺមរណភ័យ ទុគ្គតិភ័យ ប្រាកដជាក់ច្បាស់ហើយ ។

[ ២២៤ ] ក្នុងទិដ្ឋធម្មនិព្វានវាទ បទថា **បញ្ចហិ កាមគុណេហិ** បានដល់ ដោយអំណាចនៃកាមគុណ ៥ មានរូបជាទីពេញចិត្តជាដើម ឬដោយការជាប់ជំពាក់ទាំងឡាយ ។ បទថា **សមប្បិតោ** បានដល់ ជាប់ស្អិតហើយ ចុះស៊ប់ហើយដោយល្អ ។ បទថា **សមង្គីភូតោ** បានដល់ ប្រកបហើយ ។ បទថា **បរិចារេតិ** បានដល់ ញុំាងឥន្ទ្រិយទាំងឡាយ ឲ្យប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅព្រម តាមសប្បាយ គឺបង្អោនទូទៅក្នុងកាមទាំងឡាយនោះ ។ម្យ៉ាងទៀត រមែងសេពគប់ រមែងត្រេកអរ រមែងស្ទុះទៅក្នុងកាមទាំងនោះ ។ កាមគុណក្នុងទីនេះមាន ២ យ៉ាង គឺជារបស់មនុស្ស និងជារបស់ទិព្វ ។ កាមគុណដែលជារបស់មនុស្ស បណ្ឌិតគប្បីឃើញ ដូចកាមគុណរបស់ព្រះបាទមន្ធាតុរាជ កាមគុណដែលជារបស់ទិព្វ គប្បីឃើញដូចគ្នានឹងកាមគុណរបស់ទេវរាជ ក្នុងស្ថានសួគ៌ជាន់បរនិម្មិតវសវត្តី ។ សមណព្រាហ្មណ៍ទាំងនោះ រមែងពោលបុគ្គលដែលដល់នូវការឃើញបែបនេះថា បរមទិដ្ឋធម្មនិព្វាន បណ្តាបទទាំងនោះ បទថា **បរមទិដ្ឋធម្មនិព្វានំ** បានដល់ ព្រះនិព្វានក្នុងបច្ចុប្បន្នជាគុណយ៉ាងក្រៃលែង គឺឧត្តម ។

ក្នុងវារៈទី ២ គប្បីជ្រាបថា កាមទាំងឡាយ ដែលឈ្មោះថា **អនិច្ចា** ព្រោះអត្ថថា មានហើយត្រឡប់ជាមិនមាន ឈ្មោះថា **ទុក្ខា** ព្រោះអត្ថថា បៀតបៀន ។ ឈ្មោះថា **វិបរិណាមធម្មា** ព្រោះអត្ថថា លះនូវប្រក្រតី

ការៈ ។ បទថា **តេសំ វិបរិណាមញ្ញថាភាវា** បានដល់ ព្រោះភាពដែលកាមទាំងនោះជារបស់ដទៃ ពោល គឺមានការប្រែប្រួលទៅ ។ ការសោយសោក ការយំរៀបរាប់ សេចក្តីទុក្ខទោមនស្ស **ឧបាយាស** សេចក្តីចង្អៀតចង្អល់ រមែងកើតឡើងដោយន័យដែលពោលទុកថា អញមានវត្ថុណាហើយ អញក៏បែរជាមិនមានវត្ថុនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ **សោក** មានការដុតខាងក្នុងជាលក្ខណៈ **បរិទេវ** មានការយំរៀបរាប់ អាស្រ័យសេចក្តីសោកនោះ ជាលក្ខណៈ **ទុក្ខ** មានការបៀតបៀនកាយជាលក្ខណៈ **ទោមនស្ស** មានការបង្អៀតបង្អល់ចិត្តជាលក្ខណៈ **ឧបាយាស** មានការតានតឹងចិត្ត ជាលក្ខណៈ ។ បទថា **វិតក្កិតំ** បានដល់ វិតក្កដែលប្រព្រឹត្តទៅដោយអំណាចនៃការលើកឡើង ។ បទថា **វិចារិតំ** បានដល់ វិចារដែលប្រព្រឹត្តទៅដោយអំណាចនៃការផ្គង ។ បទថា **ឯតេន ឯតំ** បានដល់ បឋមជ្ឈាននេះ រមែងប្រាកដគ្រោតគ្រាត ដូចបន្ទាដោយវិតក្ក និងដោយវិចារនេះ ។ បទថា **បីតិគតំ** បានដល់ បីតិនោះឯង ។ បទថា **ចេតសោ ឧប្បិលាវិតំ** បានដល់ ការធ្វើចិត្តឲ្យរីក ។ បទថា **ចេតសោ អាភោគោ** បានដល់ ចេញចាកឈានហើយមនសិការ គឺធ្វើទុកក្នុងចិត្ត ដល់សេចក្តីសុខនោះរឿយៗ ។ ពាក្យដ៏សេសក្នុងទីទាំងពួងមានអត្ថងាយយល់ហើយ ។

**បញ្ចកនិទ្ទេស ចប់**

# ជក្កនិទ្ទេស

[ ២២៥ ] ក្នុងនិទ្ទេសនៃពួក ៦ បុគ្គលក្រោធហើយ រមែងដល់នូវការឈ្លោះ ការវិវាទ ការប្រកែកគ្នា ដោយអំណាចនៃសេចក្តីក្រោធ ឬថាបុគ្គលប្រកាន់តែការយល់ឃើញរបស់ខ្លួន ក៏រមែងដល់នូវការឈ្លោះ ការវិវាទ ការប្រកែកគ្នា ព្រោះប្រកាន់តែការយល់ឃើញរបស់ខ្លួន ព្រោះហេតុនោះ សេចក្តីក្រោធជាដើម ព្រះមានព្រះភាគត្រាស់ថា មូលនៃវិវាទ ។

[ ២២៦-២២៧ ] ក្នុងនិទ្ទេសនៃធន្ទភាគៈ ព្រះមានព្រះភាគត្រាស់ដោយសរុបថា **ឆន្ទភាគា គេហស្សិតា ធម្មា** ព្រោះធម៌ទាំងឡាយ អាស្រ័យផ្ទះគឺកាម ដូច្នេះហើយ ដើម្បីទ្រង់សម្តែងធម៌នោះ ដោយប្រភេទទៀត ទើបត្រាស់ថា **មនាបិយេសុ រូបេសុ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **មនាបិយេសុ** បានដល់ ការញុំាងចិត្តឲ្យចម្រើន គឺការប្រាថ្នា ។

ការខឹងក្រោធនោះឯង ឈ្មោះថា វិរោធវត្ថុ ។ បទថា **អមនាបិយេសុ** បានដល់ ដែលមិនគួរប្រាថ្នា ។

[ ២២៨ ] ក្នុងអគារវៈទាំងឡាយ បទថា **អគារវោ** បានដល់ វៀរចាកសេចក្តីគោរព ។ បទថា **អប្បតិស្សោ** បានដល់ ដែលមិនស្តាប់បង្គាប់ មិនប្រព្រឹត្តឱនលំទោន ។ ក្នុងសេចក្តីនេះ កាលព្រះសាស្តាគង់ព្រះជន្មនៅឡើយ ភិក្ខុណាមិនទៅកាន់ទីបម្រើក្នុងកាលទាំង ៣ កាលព្រះសាស្តាមិនពាក់ស្បែក

ព្រះបាទចង្ក្រម ភិក្ខុណាពាក់ស្បែកជើងចង្ក្រម កាលព្រះសាស្តាចង្ក្រម ក្នុងទីទាប ភិក្ខុណាចង្ក្រមក្នុងទីខ្ពស់ កាលព្រះសាស្តាប្រថាប់ក្នុងទីទាប ភិក្ខុណានៅក្នុងទីខ្ពស់ ភិក្ខុណាឃ្លុំបិទបាំងស្មាទាំង ២ ភិក្ខុណាបាំងឆត្រ ពាក់ស្បែកជើង ងូតទឹក បន្ទោបង់ឧច្ចារបស្សាវៈ ក្នុងទីដែលព្រះសាស្តាទ្រង់ទតឃើញ ឬកាលព្រះសាស្តាបរិនិព្វានហើយ ភិក្ខុណាមិនទៅថ្វាយបង្គំព្រះចេតិយ ធ្វើការងារទាំងពួងដូចពោលហើយ ក្នុងទីដែលមើលឃើញព្រះចេតិយ ភិក្ខុនេះឈ្មោះថា មិនមានសេចក្តីគោរពកោតក្រែងក្នុងព្រះសាស្តា ។

ភិក្ខុណា កាលសង្ឃប្រកាសធម៌ រមែងទៅដោយសេចក្តីគោរព ក៏មិនមែន រមែងមិនស្តាប់ធម៌ដោយគោរព ។ រមែងសន្ទនាគ្នា រមែងរៀនដោយគោរព ប្រាប់ដោយគោរពក៏មិនមែន ភិក្ខុនេះ ឈ្មោះថា មិនមានសេចក្តីគោរពកោតក្រែងក្នុងធម៌ ។

ភិក្ខុណា មិនបានទទួលការអារាធនាអំពីភិក្ខុដែលជាថេរៈ ឲ្យសម្តែងធម៌ ហើយសម្តែងធម៌ ឆ្លើយបញ្ហា ដើរ ឈរ អង្គុយ ជ្រៀតបៀតភិក្ខុដែលមានវស្សាចាស់ជាង ឬអង្គុយត្របោមក្បាលជង្គង់ដោយខ្សែក្តី ដោយដៃក្តី ឃ្លុំជិតស្មាទាំង ២ ក្នុងកណ្តាលសង្ឃ បាំងឆត្រ ពាក់ស្បែកជើង ភិក្ខុនេះឈ្មោះថា មិនគោរពក្នុងសង្ឃ ពិតហើយ ភិក្ខុធ្វើសេចក្តីមិនគោរពក្នុងភិក្ខុសូម្បីត្រឹមតែមួយរូប ក៏ឈ្មោះថា មិនគោរពក្នុងសង្ឃដូចគ្នា ។

ភិក្ខុដែលមិនបំពេញសិក្ខា ៣ ឲ្យបរិបូណ៌ ឈ្មោះថា មិនមានសេចក្តីគោរពកោតក្រែងក្នុងសិក្ខា ។

ភិក្ខុមិនតាមចម្រើនលក្ខណៈនៃសេចក្ដីមិនប្រមាទ ឈ្មោះថា មិនមានសេចក្ដីគោរពកោតក្រែងក្នុងអប្បមាទ ។

កាលមិនធ្វើបដិសណ្ឋារៈ ២ យ៉ាង គឺអាមិសបដិសណ្ឋារៈ ១ ធម្មបដិ-សណ្ឋារៈ ១ ឈ្មោះថា មិនមានសេចក្ដីគោរពកោតក្រែងក្នុងបដិសណ្ឋារៈ ។

[ ២៣០ ] បទថា **បរិហានិយា ធម្មា** បានដល់ ធម៌ទាំងឡាយដែលធ្វើនូវសេចក្ដីសាបសូន្យ ។ បទថា **កម្មារាមតា** បានដល់ ជាអ្នកប្រកបហើយ ខ្វល់ខ្វាយហើយ ដោយសេចក្ដីត្រេកអរក្រៃលែងក្នុងនវកម្ម គឺការកសាង ឬក្នុងការងារទាំងឡាយ មានការគិតដល់ចីវរជាដើម ។ បទថា **ភស្សារាមតា** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងការសន្ទនាដោយអំណាចនៃពាក្យដែលជាតិរច្ឆានកថា ។ បទថា **និទ្ទារាមតា** បានដល់ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងការដេក ។ បទថា **សង្គណិការាមតា** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងការប្រឡូកប្រឡំដោយពួកដោយគណៈ ។ បទថា **សំសគ្គារាមតា** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងការនៅរួមគ្នា ៥ យ៉ាង គឺរួមស្ដាប់ រួមមើល រួមសន្ទនា រួមបរិភោគ និងរួមគ្នាដោយកាយ ។ បទថា **បបញ្ចារាមតា** បានដល់ ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងធម៌ដែលញ៉ាំងសត្វឲ្យយឺតយូរ គឺតណ្ហា មានះ និងទិដ្ឋិ ។

[ ២៣២-២៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សោមនស្សុបវិចារា** ជាដើម ដូចតទៅនេះ ធម៌ទាំងឡាយឈ្មោះថា សោមនស្សុបវិចារ ព្រោះ

*អត្ថថា រមែងគិតព្រមជាមួយសោមនស្ស ។ បទថា* **ចក្ខុនា រូបំ ទិស្វា** *បានដល់ ឃើញរូបដោយចក្ខុវិញ្ញាណ ។ បទថា* **សោមនស្សដ្ឋានិយំ** *បានដល់ ជាហេតុនៃសោមនស្សដោយអំណាចនៃអារម្មណ៍ ។ ក្នុងបទថា* **ឧបវិចរតិ** *បានដល់ រមែងគិតដល់ដោយការប្រព្រឹត្តទៅនៃវិចារក្នុងរូបជាដើមនោះ ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងចក្កៈទាំង ៣ គឺសោមនស្សុបវិចារ ទោមនស្សុបវិចារ និងឧបេក្ខូបវិចារ ដោយន័យនេះថា វិតក្ក ឬធម៌ដែលសម្បយុត្តដោយវិតក្កនោះ ។*

[ ២៣៥-២៣៧ ] *បទថា* **គេហសិតានិ** *បានដល់ អាស្រ័យហើយនូវកាមគុណ ។ បទថា* **សោមនស្សានិ** *បានដល់ សេចក្តីសុខផ្លូវចិត្ត ។ បទថា* **ទោមនស្សានិ** *បានដល់ សេចក្តីទុក្ខផ្លូវចិត្ត ។ បទថា* **ឧបេក្ខា** *បានដល់ ឧបេក្ខាដែលសម្បយុត្តដោយអញ្ញាណ គឺមោហៈ ។ ពាក្យថា* **អញ្ញាណុបេក្ខា** *ក៏ជាឈ្មោះរបស់គេហសិតឧបេក្ខា ៦ នោះឯង ។*

[ ២៣៨ ] **វា** *សព្វ ក្នុងបទទាំងពួង មានបទថា* **អត្ថិ មេ អត្តាតិ វា** *( ជាដើម ) នេះជានិបាតកំណត់អត្ថ ។ មានពាក្យអធិប្បាយថា ការឃើញខុសរមែងកើតឡើងយ៉ាងនេះក្តី ។ សស្សតទិដ្ឋិរមែងប្រកាន់ថា ខ្លួនមានក្នុងកាលទាំងពួងក្នុងបទថា* **អត្ថិ មេ អត្តា** *នេះ ។ បទថា* **សច្ចតោ ថេតតោ** *បានដល់ ដោយពិត ដោយមាំទាំ ។ មានពាក្យអធិប្បាយដោយការមាំទាំពិតប្រាកដថា នេះ ( ប៉ុណ្ណោះ ) ពិត ។ បទថា* **នត្ថិ មេ អត្តា** *បានដល់ ទិដ្ឋិនេះ ឈ្មោះថា ឧច្ឆេទទិដ្ឋិ ព្រោះកាន់យកការមិនមានក្នុងទីនោះៗ នៃសត្វ*

ដែលប្រាកដ ។

ម្យ៉ាងទៀត ទិដ្ឋិនេះ ឈ្មោះថា សស្សតទិដ្ឋិ ព្រោះប្រកាន់ថា អត្តាមាន ក្នុងកាលទាំង ៣ កាលប្រកាន់អត្តាដែលជាបច្ចុប្បន្នប៉ុណ្ណោះថាមាន ។ ជា ឧច្ឆេទទិដ្ឋិ សូម្បីទិដ្ឋិខាងក្រោយ ជាឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ថា អត្តា ក្នុង អតីត និងអនាគតមិនមាន ដូច្នេះ ដូចទិដ្ឋិរបស់បុគ្គលដែលប្រកាន់ថា របស់ បូជាយញ្ញមានផេះជាទីបំផុត ។ កាលប្រកាន់ថា អត្តាក្នុងអតីតប៉ុណ្ណោះ មិន មាន ដូច្នេះ ជាសស្សតទិដ្ឋិ ចំពោះរបស់បុគ្គលដែលមានការយល់ឃើញថា អត្តាកើតឡើងឯង១ ។ បទថា **អត្តនា វា អត្តានំ សញ្ជានាមិ** បានដល់ មានការយល់ឃើញយ៉ាងនេះថា អញស្គាល់អត្តានេះដោយអត្តានេះ ព្រោះ ប្រកាន់ខន្ធទាំងឡាយថាជាអត្តា ហើយស្គាល់ខន្ធដ៏សេសដោយសញ្ញា ដោយ សំដៅដល់សញ្ញាខន្ធ ដូច្នេះ ។ បទថា **អត្តនា វា អនត្តានំ** បានដល់ មានការយល់ឃើញយ៉ាងនេះ ព្រោះប្រកាន់សញ្ញាខន្ធនោះឯង ថាជាអត្តា ប្រកាន់ខន្ធ ៤ ក្រៅអំពីនេះថា ជាអនត្តា ដូច្នេះហើយ ទើបស្គាល់ខន្ធទាំង នោះដោយសញ្ញា ។ បទថា **អនត្តនា វា អត្តានំ** បានដល់ មានការ យល់ឃើញយ៉ាងនេះថា ព្រោះប្រកាន់សញ្ញាខន្ធថាជាអនត្តា និងប្រកាន់ខន្ធ ៤ ក្រៅអំពីនេះថាជាអត្តា ដូច្នេះហើយ ទើបស្គាល់ខន្ធទាំងនោះដោយសញ្ញា ។ ទិដ្ឋិទាំងពួងជាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិនោះឯង ។ ការយល់ឃើញថា ជា អ្នកពោល អ្នកទទួលផលជាដើម ជាអាការនៃការប្រកាន់មាំដោយសស្សត- ទិដ្ឋិនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យទាំងនោះដូចតទៅ

ឈ្មោះថា **វទោ** ព្រោះអត្ថថា រមែងពោល អធិប្បាយថា អ្នកធ្វើវចី-កម្ម ។ ឈ្មោះថា **វេទេយ្យោ** ព្រោះអត្ថថា រមែងសោយ អធិប្បាយថា អត្តារមែងដឹង និងរមែងសោយ ។ ឥឡូវនេះ អត្តានោះ រមែងសោយវិបាកណា ដើម្បីសម្តែងវិបាកនោះ ទើបព្រះមានព្រះភាគត្រាស់ថា រមែងទទួលនូវវិបាកនៃធម៌ល្អ និងអាក្រក់អស់កាលដ៏វែងជាដើម ។ បណ្តាបទទាំងនោះ បទថា **តត្រ តត្រ** បានដល់ ក្នុងកំណើត ក្នុងគតិ ក្នុងឋិតិ ក្នុងនិវាស និងនិកាយទាំងឡាយ ឬថា ក្នុងអារម្មណ៍ទាំងឡាយនោះៗ ។ បទថា **ទីឃរត្តំ** បានដល់ អស់កាលយូរ ។ បទថា **បច្ចនុភោតិ** បានដល់ រមែងសោយចំពោះ ។ បទថា **ន សោ ជាតោ នាហោសិ** បានដល់ អត្តានោះ ឈ្មោះថាមិនកើត ព្រោះការមិនកើតជាធម្មតា អធិប្បាយថា អត្តានេះ មានក្នុងកាលសព្វកាលនោះឯង ។ ដោយហេតុនោះ ទើបឈ្មោះថា អត្តាមិនមានហើយក្នុងអតីត អត្តានឹងមិនមានក្នុងអនាគត ព្រោះថា អត្តាណាកើតឡើងហើយ អត្តានោះមានហើយ តែអត្តាណានឹងកើត អត្តានោះក៏នឹងមាន ដូច្នេះ ។

ម្យ៉ាងទៀត បទថា **ន សោ ជាតោ នាហោសិ** បានដល់ អត្តានោះមិនកើត មិនមានហើយសូម្បីក្នុងអតីត ។ មិនកើត និងមិនមាន សូម្បីក្នុងអនា-គតកាល ព្រោះអត្តានោះ មានទៅសព្វកាល ។ បទថា **និច្ចោ** បានដល់ វៀរចាកការកើត ការរលត់ ។ បទថា **ធុវោ** បានដល់ ជាសភាវៈមាំទាំ ជាវត្ថុមានសារៈ ។ បទថា **សស្សតោ** បានដល់ ប្រកបដោយកាលទាំងពួង ។ បទថា **អវិបរិណាមធម្មោ** បានដល់ ធម៌ដែលមិនលះនូវភាពជាប្រក្រតី

របស់ខ្លួនជាធម្មតា គឺរមែងមិនដល់នូវការប្រព្រឹត្តទៅដោយប្រការដទៃ ដូចបង្គោលមិនលះនូវប្រក្រតីភាពរបស់ខ្លួន ដូច្នោះ ។ ឈ្មោះថា ទិដ្ឋិដែលប្រព្រឹត្តទៅជាមួយអាសវៈទាំងពួងនេះ ព្រះមានព្រះភាគ ត្រាស់ហើយដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយនោះឯង ។

**ឆក្កនិទ្ទេស ចប់**

## សត្តកនិទ្ទេស

[ ២៣៩-២៤៤ ] ក្នុងនិទ្ទេសនៃធម៌ពួក ៧ សភាវធម៌ទាំងឡាយ រមែងដេកត្រាំ ព្រោះអត្ថថា មានកម្លាំង ព្រោះអត្ថថា លះមិនទាន់បាន ព្រោះហេតុនោះ ទើបសភាវធម៌ទាំងនោះ ឈ្មោះថា អនុស័យ គឺកិលេសដែលដេកត្រាំក្នុងសន្តាន ។

សភាវធម៌ទាំងឡាយណា រមែងប្រកបសត្វទុក រមែងឲ្យសត្វបន្តនៅក្នុងវដ្តៈ ព្រោះហេតុនោះ ទើបសភាវធម៌នោះ ឈ្មោះថា សំយោជនៈ គឺកិលេសជាគ្រឿងប្រកបសត្វទុកក្នុងវដ្តៈ ។

សភាវធម៌ណា រមែងកើតរឹតរុំចិត្តដោយអំណាចផ្សាយឡើង ព្រោះហេតុនោះ ទើបសភាវធម៌នោះ ឈ្មោះថា បរិយុដ្ឋាន គឺកិលេសដែលប្រទូស្តចិត្ត ។ បរិយុដ្ឋាន គឺកាមរាគៈ ឈ្មោះថា កាមរាគបរិយុដ្ឋាន ។ ក្នុងពាក្យដ៏សេស

ក៏ន័យនេះឯង ។

ធម៌ទាំងឡាយដែលមិនមែនរបស់សប្បុរស ឬធម៌ទាំងឡាយ ដែលមិនស្ងប់ ព្រោះអត្ថថា ជាធម៌ដ៏លាមក ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា អសទ្ធម្ម ។

ចរិតទាំងឡាយដែលទោសទាំងឡាយ មានរាគៈជាដើម ប្រទូស្តហើយ ព្រោះហេតុនោះ ទើបចរិតទាំងនោះ ឈ្មោះថា ទុច្ចរិត ។ ធម៌ទាំងឡាយរមែងប្រកាន់ខ្លួន ដោយអាការនោះៗ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា មានៈ ។

[ ២៤៥ ] បទថា **រូបី** បានដល់ មានរូប ។ បទថា **ចាតុមហាភូតិកោ** បានដល់ សម្រេចដោយមហាភូតរូប ៤ ។ អត្តានោះជារបស់មាតានិងបិតា ព្រោះហេតុនោះ ទើបឈ្មោះថា មាតាបេត្តិកៈ ។ មាតាបេត្តិកៈនោះ តើដូចម្តេច គឺសុក្កៈ និងលោហិត ។ ឈ្មោះថា **មាតាបេត្តិកសម្ភវោ** ព្រោះអត្ថថា កើតមានឡើងក្នុងមាតាបេត្តិកៈ ។ សមណៈក្តី ព្រាហ្មណ៍ក្តី ពួកខ្លះ ក្នុងលោកនេះ រមែងពោលអត្តភាពនៃមនុស្ស ដោយបំណាងដល់រូបកាយថា ជាអត្តា ។ ក្នុងវារៈទី ២ សមណៈក្តី ព្រាហ្មណ៍ក្តី ពួកទីពីរបដិសេធការយល់ឃើញនោះ តែទទួលអត្តភាពដែលជាទិព្វ ។ បទថា **ទិព្វោ** បានដល់ អត្តាដែលកើតឡើងក្នុងទេវលោក ។ បទថា **កាមាវចរោ** បានដល់ អត្តាដែលទាក់ទងក្នុងស្ថានសួគ៌ ៦ ជាន់ ។ អត្តាណា រមែងបរិភោគដុំបាយ ព្រោះហេតុនោះ អត្តានោះ ឈ្មោះថា **កពឡិង្ការភក្ខោ** មានកវឡិង្ការាហារ

ជាចំណី ។ បទថា **មនោមយោ** បានដល់ កើតឡើងដោយចិត្តដែលជាឈាន ។ បទថា **សព្វង្គបច្ចង្គី** បានដល់ ប្រកបដោយអវយវៈតូចធំទាំងពួង ។ បទថា **អហីនិន្ទ្រិយោ** បានដល់ មានឥន្ទ្រិយបរិបូណ៌ ។ ឥន្ទ្រិយពួកណាមានក្នុងព្រហ្មលោក ពាក្យថា មានឥន្ទ្រិយមិនថោកទាប ( ខ្វះខាត ) នោះ ដោយអំណាចនៃឥន្ទ្រិយទាំងនោះ និងដោយអំណាចនៃសណ្ឋានរបស់ឥន្ទ្រិយក្រៅអំពីនេះ ។ បទថា **អាកាសានញ្ចាយតនូបគោ** បានដល់ ជាអ្នកចូលដល់នូវភាពនៃអាកាសានញ្ចាយតនៈ ។ ក្នុងពាក្យទាំងឡាយ ក្រៅអំពីនេះ ក៏ន័យនេះឯង ។ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយនោះឯង ។

### សត្តកនិទ្ទេស ចប់

## អដ្ឋកនិទ្ទេស

[ ២៤៧ ] ក្នុងនិទ្ទេសនៃពួក ៨ កិលេសវត្ថុ គឺកិលេសទាំងឡាយនោះឯង ។ បទថា **កុសីតវត្ថូនិ** បានដល់ វត្ថុជាទីតាំង គឺគោលអាងរបស់អ្នកខ្ជិលច្រអូស អធិប្បាយថា ជាហេតុនៃការខ្ជិលច្រអូស ។ បទថា **កម្មំ កត្តព្វំ ហោតិ** បានដល់ ការងារដែលត្រូវធ្វើ មានការចាត់ចែងចីវរជាដើម ។ បទថា **ន វីរិយំ អារភតិ** បានដល់ មិនប្រារព្ធព្យាយាមទាំង ២ យ៉ាង ។

បទថា **អប្បត្តស្ស** បានដល់ ដើម្បីដល់នូវធម៌ គឺឈាន វិបស្សនា មគ្គ និង ផលដែលមិនទាន់ដល់ ។ បទថា **អនធិគតស្ស** បានដល់ ដើម្បីសម្រេច ធម៌ដែលមិនទាន់សម្រេចនោះឯង ។ បទថា **អសច្ឆិកតស្ស** បានដល់ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវធម៌នោះៗ ឯង ដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ បទ ថា **ឥទំ បឋមំ** បានដល់ ការលិចចុះយ៉ាងនេះថា ណ្ហើយចុះ អញនឹងដេក ដូច្នេះ នេះជាកុសីតវត្ថុប្រការទី ១ ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយ ន័យនេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **មាសាចិតំ មញ្ញេ** សណ្តែកដែលឲ្យសើម ហើយ ឈ្មោះថា សណ្តែកត្រាំ អធិប្បាយថា សណ្តែកត្រាំសើមហើយជា របស់ធ្ងន់យ៉ាងណា កាយរមែងធ្ងន់ ក៏យ៉ាងនោះ ។

បទថា **គិលានា វុដ្ឋិតោ ហោតិ** បានដល់ ភិក្ខុទើបនឹងជាអំពីជំងឺ ។

[ ២៤៨-២៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អដ្ឋសុ លោកធម្មេសុ** ឈ្មោះថា លោកធម៌ ព្រោះអត្ថថា ជាធម៌របស់សត្វលោក ។ សត្វលោក ទាំងឡាយ ឈ្មោះថា ផុតចាកលោកធម៌ទាំងនេះ មិនមានឡើយ លោក-ធម៌ទាំងនេះ រមែងមានដល់ព្រះពុទ្ធទាំងឡាយ ( ផងដែរ ) ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា លោកធម៌ ដូច្នេះ ។ បទថា **បដិឃាតោ** បានដល់ អាការថ្ពាំងថ្នាក់ចិត្ត ។ បទថា **លាភេ សរាគោ** បានដល់ សេចក្តី ត្រេកអរដែលកើតឡើងដោយអំណាចនៃសោមនស្ស ដែលអាស្រ័យកាម-គុណយ៉ាងនេះថា អញបានលាភ ដូច្នេះ ទើបការត្រេកអរនោះ ឈ្មោះថា

សេចក្តីថ្នាំងថ្នាក់ ។ បទថា **អលាភេ បដិវិរោធោ** បានដល់ សេចក្តីមិនត្រេកអរដែលកើតឡើងហើយដោយអំណាចនៃទោមនស្សថា អញរមែងមិនបានលាភ ដូច្នេះ ការមិនត្រេកអរនោះរមែងថ្នាំងថ្នាក់ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បដិឃាត** ។ ក្នុងយសជាដើម បណ្ឌិតគប្បីជ្រាបការកើតឡើងនៃលោកធម៌ទាំងនោះយ៉ាងនេះថា អញមានបរិវារច្រើន អញមានបរិវារតិច អញបានទទួលការសរសើរ អញបានទទួលការនិន្ទា អញដល់សេចក្តីសុខ អញដល់នូវសេចក្តីទុក្ខ ដូច្នេះ ។ បទថា **អនរិយវោហារា** បានដល់ វោហាររបស់បុគ្គលដែលមិនមែនព្រះអរិយៈ ។

[ ២៥១ ] ទោសទាំងឡាយរបស់បុរស ឈ្មោះថា បុរិសទោស ។ បទថា **ន សរាមិ** បានដល់ រមែងកែខ្លួន រមែងដោះខ្លួន ដោយអាងនូវភាពជាអ្នកមិនមានសតិ យ៉ាងនេះថា អញរឭកមិនបាន កំណត់មិនបាននូវឋានៈនៃកម្មនេះដែលអញធ្វើហើយ ។ បទថា **ចោទកំយេវ បដិប្ផរតិ** បានដល់ ជាអ្នកជំទាស់គ្នា ផ្សាយទៅ គឺរមែងតាំងនៅដោយភាពជាបុគ្គលឈ្មោះប្រកែកគ្នា ។ បទថា **កិន្នុ ខោ តុយ្ហំ** បានដល់ កិក្ខុនោះ សម្តែងថា ប្រយោជន៍អ្វីហ្ន៎ ដោយវាចាដល់លោកដែលជាមនុស្សល្ងង់ខ្លៅ មិនឈ្លាស មិនដឹងវត្ថុនៃអាបត្តិ មិនស្គាល់ការចោទ អធិប្បាយថា កិក្ខុនោះ រមែងសង្កត់សង្កិនដោយវាទៈថា សូម្បីលោក ក៏មិនស្គាល់អាបត្តិណាមួយ និងសម្គាល់ខ្ញុំថា គួរពោលបានឬ ។

បទថា **បច្ចារោបេតិ** សេចក្តីថា រមែងពោលលើកអាបត្តិឡើងថា លោក

នោះឯងត្រូវអាបត្តិជាដើម ។ បទថា **បដិករោហិ** បានដល់ រមែងសម្តែង ថា ចូរលោកសម្តែងទេសនាគាមិនី គឺសម្តែងអាបត្តិតាំងអំពីថុល្លច្ច័យរហូត ដល់អាបត្តិតូចបំផុត ចូរចេញចាកវុដ្ឋានគាមិនី គឺចេញចាកអាបត្តិសង្ឃាទិ-សេស បន្ទាប់អំពីនោះ តាំងមាំនៅក្នុងសេចក្តីបរិសុទ្ធហើយ ទើបចោទអ្នក ដទៃបាន ។

បទថា **អញ្ញេនញ្ញំ បដិចរតិ** បានដល់ រមែងបន្ទប់នូវហេតុដទៃដោយ ហេតុដទៃ ឬពោលបន្ទប់នូវពាក្យដទៃ ដោយពាក្យដទៃ អធិប្បាយថា លោកត្រូវភិក្ខុចោទថា លោកត្រូវអាបត្តិ រមែងពោលថា អ្នកណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិដូចម្តេច ត្រូវអាបត្តិព្រោះវត្ថុអ្វី លោកនិយាយនឹង អ្នកណា និយាយរឿងអ្វី ។ ម្យ៉ាងទៀត កាលភិក្ខុពោលថា អាបត្តិណា មួយបែបនេះ លោកឃើញឬ ភិក្ខុនោះក្លែងផ្ទៀងត្រចៀកចូលទៅនិយាយថា ខ្ញុំមិនបានឮ ។ បទថា **ពហិទ្ធា កថំ អបនាមេតិ** បានដល់ លោកត្រូវ សួរថា លោកត្រូវអាបត្តិឈ្មោះនេះឬ ក៏ពោលថា ខ្ញុំនឹងទៅកាន់នគរបាដលិ-បុត្ត កាលពួកភិក្ខុពោលទៀតថា ពួកយើងមិនសួរការទៅកាន់នគរបាដលិបុត្ត របស់លោកទេ ក៏ពោលថា ចេញអំពីនគរបាដលិបុត្តនោះ ខ្ញុំទៅកាន់នគរ រាជគ្រឹះ ។ ពួកភិក្ខុពោលថា ទោះលោកទៅកាន់នគររាជគ្រឹះក្តី ទៅកាន់ ព្រាហ្មណគ្រឹះក្តី លោកក៏ត្រូវអាបត្តិហើយ ដូច្នេះ ។ លោកកាលពោលពាក្យ ថា សាច់ជ្រូកក៏ខ្ញុំបានហើយក្នុងទីនោះជាដើម ឈ្មោះថា យកពាក្យខាងក្រៅ មកបញ្ចេញ ។ បទថា **កោបំ** បានដល់ ភាពជាបុគ្គលខឹងក្រោធ ។ បទថា

**ធោសំ** បានដល់ សេចក្ដីក្រោធ ។ ពាក្យទាំង ២ នេះ ជាឈ្មោះរបស់សេចក្ដីក្រោធនោះឯង ។ បទថា **អប្បច្ចយំ** បានដល់ កិរិយាមិនត្រេកអរ ។ ពាក្យនេះ ជាឈ្មោះនៃទោមនស្ស ។ បទថា **ចាតុក្ករោតិ** បានដល់ រមែងសម្ដែង រមែងប្រកាស ។ បទថា **ពាហាវិក្ខេបកំ ភណតិ** បានដល់ គ្រវីដៃបដិសេធ និយាយពាក្យឥតខ្មាស ។ បទថា **វិហេសេតិ** បានដល់ រមែងបៀតបៀន រមែងធ្វើឲ្យលំបាក ។ បទថា **អនាទរិយំ** បានដល់ មិនកាន់យកដោយការគោរពកោតក្រែង គឺមើលងាយ អធិប្បាយថា មិនអើពើ ។ បទថា **អតិពាឡ្ហំ** បានដល់ ធ្ងន់ហួសប្រមាណ ។ បទថា **មយិ ព្យាវដា** បានដល់ ដល់នូវការខ្វល់ខ្វាយក្នុងអញ ។ បទថា **ហីនាយាវត្តិស្សា** បានដល់ វិលត្រឡប់ទៅដើម្បីភាពជាគ្រហស្ថដែលជាភេទថោកទាប អធិប្បាយថា ជាគ្រហស្ថ ។ បទថា **អត្តមនា ហោថ** បានដល់ រមែងពោលដោយបំណងថា ចូរអ្នកទាំងឡាយមានចិត្តត្រេកអរ ចូរបានវត្ថុដែលខ្ញុំគប្បីបាន ចូរនៅក្នុងទីដែលខ្ញុំគប្បីនៅ ការនៅជាផាសុក ខ្ញុំធ្វើហើយ ដើម្បីលោកទាំងឡាយ ។

[ ២៥២ ] វាទៈដែលប្រព្រឹត្តទៅថា មិនមានសញ្ញា ឈ្មោះថា អសញ្ញីវាទ ។ អសញ្ញីវាទនោះ មានដល់បុគ្គលទាំងនោះ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **អសញ្ញីវាទា** ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **រូបី អត្តា** ជាដើម ដូចតទៅនេះថា ការយល់ខុសថា ខ្លួនមានរូប រមែងកើតដល់បុគ្គលដែលបានឈាន ព្រោះប្រកាន់កសិណរូប ថាជាអត្តា ។ រមែង

កើតឡើងដល់បុគ្គលដែលមិនបានឈាន ដោយហេតុត្រឹមតែការត្រិះរិះប៉ុណ្ណោះ ដូចកើតដល់ពួកអាជីវក ។ ការយល់ខុសថា ខ្លួនមិនមានរូប រមែងកើតឡើងដល់បុគ្គលដែលបានឈានប៉ុណ្ណោះ ព្រោះកាន់យកនិមិត្តក្នុងអរូបសមា-បត្តិ ថាជាអត្តា ។ រមែងកើតឡើងដល់បុគ្គលដែលមិនបានឈាន ដោយហេតុត្រឹមតែការត្រិះរិះតែម្យ៉ាង ដូចការយល់ខុសរបស់ពួកនិគ្រន្ថ ។ ក្នុងទីនេះ បណ្ឌិតមិនគប្បីស្វាបសួរកហេតុឲ្យពិតប្រាកដ ក្នុងការកើតនៃអត្តាដែលមិនមានសញ្ញានោះឯង ព្រោះថា បុគ្គលដែលមានការយល់ខុស ហាក់ដូចជាមនុស្សឆ្កួត រមែងប្រកាន់អ្វីក៏បាន ។ បទថា **រូបី ច អរូបី ច** ទ្រង់ត្រាស់ទុក ដោយអំណាចការកាន់យករូបជ្ឈាន និងអរូបជ្ឈានលាយឡំគ្នា ។ មិច្ឆាទិដ្ឋិនេះ រមែងកើតដល់បុគ្គលដែលបានរូបាវចរ និងអរូបាវចរសមាបត្តិខ្លះ ដល់បុគ្គលត្រិះរិះឯងខ្លះ ។

បទថា **នេវ រូបី នារូបី** បានដល់ ការយល់ខុសរបស់បុគ្គលដែលនឹកគិត ដោយចំណែកមួយប៉ុណ្ណោះ ។ បទថា **អន្តវា** បានដល់ ទិដ្ឋិរបស់បុគ្គលដែលកាន់យកបរិត្តកសិណ គឺកសិណមានដោយភាពជាអត្តា ។ បទថា **អនន្តវា** បានដល់ ទិដ្ឋិរបស់បុគ្គលដែលកាន់យកកសិណ មានអា-រម្មណ៍មិនមានប្រមាណដោយភាពជាអត្តា ។ បទថា **អន្តវា ច អនន្តវា ច** បានដល់ ទិដ្ឋិដែលកើតឡើងព្រោះកាន់យកកសិណ ដែលមានទីបំផុតក្នុងខាងលើ និងខាងក្រោម និងកាន់យកកសិណដែលមិនមានទីបំផុត ខាងទទឹងថាជាអត្តា ។ បទថា **នេវន្តវា នានន្តវា** បានដល់ ទិដ្ឋិរបស់បុគ្គលដែល

*នឹកគិតនោះឯង ។ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។*

**អដ្ឋកនិទ្ទេស ចប់**

## នវកនិទ្ទេស

*[ ២៥៦-២៥៦ ] ក្នុងនិទ្ទេសនៃពួក ៩ បទថា* **នវ អាឃាតវត្ថូនិ** *ព្រះមានព្រះភាគ ត្រាស់ហើយដោយអំណាចនៃការកើតឡើង ក្នុងសត្វទាំងឡាយនោះឯង ។ ឈ្មោះថា* **បុរិសមលានិ** *ព្រោះជាមន្ទិលរបស់បុរសទាំងឡាយ ។ បទថា* **នវវិធា** *បានដល់ មានចំណែក ៩ ឬមាន ៩ ប្រភេទ ។*

*[ ២៥៧ ] បទថា* **តណ្ហំ បដិច្ច** *បានដល់ ព្រោះអាស្រ័យតណ្ហា ។ បទថា* **បរិយេសនា** *បានដល់ ការស្វែងរកអារម្មណ៍ មានរូបជាដើម ។ ពិតហើយ កាលតណ្ហានៅមាន អារម្មណ៍មានរូបជាដើមនោះក៏មាន ។ បទថា* **លាភោ** *បានដល់ ការបានអារម្មណ៍ មានរូបជាដើម ។ ពិតហើយ កាលការស្វែងរកនៅមាន ការបានអារម្មណ៍ មានរូបជាដើមក៏នៅមាន ។*

*វិនិច្ឆ័យមាន ៤ គឺញាណ តណ្ហា ទិដ្ឋិ និងវិតក្ក ។*

*ក្នុងវិនិច្ឆ័យទាំងនោះ វិនិច្ឆ័យនេះ ដោយព្រះបាលី ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា គប្បីដឹងនូវសេចក្ដីសុខដែលថោកថយ លុះដឹងនូវសេចក្ដីសុខដែលថោកថយហើយ គប្បីប្រកបរឿយៗ នូវសេចក្ដីសុខក្នុងសន្តាន*

ដូច្នេះ ឈ្មោះថា ញាណវិនិច្ឆ័យ ។

តណ្ហាវិចរិត ១០៨ ដែលមកហើយ ( ក្នុងខុទ្ទនិកាយ មហានិទ្ទេស ) យ៉ាងនេះថា ត្រង់ពាក្យថា វិនិច្ឆ័យ បានដល់ វិនិច្ឆ័យ ២ គឺតណ្ហាវិនិច្ឆ័យ ១ ទិដ្ឋិវិនិច្ឆ័យ ១ ដូច្នេះ ឈ្មោះថា តណ្ហាវិនិច្ឆ័យ ។ ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិវិនិច្ឆ័យ ។ ការត្រិះរិះនោះឯង ព្រះមានព្រះភាគត្រាស់ហៅថា វិនិច្ឆ័យ ក្នុងវិភង្គនេះ មកក្នុងព្រះសូត្រ ( ទីឃនិកាយ មហាវគ្គ ) ថា បពិត្រទេវា-នមិន្ទ ឆន្ទៈមានវិតក្កៈ ( សេចក្តីត្រិះរិះ ) ជាដើមហេតុ ដូច្នេះ ។

ពិតហើយ បុគ្គលណាបានលាភហើយ រមែងវិនិច្ឆ័យលាភ ដែលគួរពេញចិត្ត មិនគួរពេញចិត្ត និងវត្ថុដែលល្អ មិនល្អ ដោយការត្រិះរិះនោះឯង វត្ថុមានប្រមាណប៉ុណ្ណេះនឹងមានដល់អញ ដើម្បីការបម្រើននៃរូបារម្មណ៍ វត្ថុមានប្រមាណប៉ុណ្ណេះនឹងមានដល់អញ ដើម្បីសេចក្តីចម្រើននៃសទ្ទារម្មណ៍ជាដើម វត្ថុមានប្រមាណប៉ុណ្ណេះ នឹងមានដល់អញ វត្ថុមានប្រមាណប៉ុណ្ណេះ នឹងមានដល់អ្នកដទៃ អញនឹងបរិភោគ មានប្រមាណប៉ុណ្ណេះ នឹងរក្សាទុកប្រមាណប៉ុណ្ណេះ ដូច្នេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សេចក្តីត្រិះរិះ ( កើតមាន ) ព្រោះអាស្រ័យលាភ ដូច្នេះ ។

បទថា **ឆន្ទរាគោ** បានដល់ រាគៈដែលមានកម្លាំងខ្សោយផង ដែលមានកម្លាំងខ្លាំងផង រមែងកើតក្នុងវត្ថុដែលត្រិះរិះដោយអកុសលវិតក្កយ៉ាងនេះ ។ ពាក្យថា ឆន្ទៈ ក្នុងវិភង្គនេះ ជាឈ្មោះនៃរាគៈ ដែលមានកម្លាំងខ្សោយ ។ បទថា **អជ្ឈោសានំ** បានដល់ ការប្រកាន់ដែលមានកម្លាំងខ្លាំង ថាជាអញ

ជារបស់អញ ដូច្នេះ ។ បទថា **បរិគ្គហោ** បានដល់ ការធ្វើនូវការហួងហែង ដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ បទថា **មច្ឆរិយំ** បានដល់ ការមិនអត់ធន់ ដើម្បីឲ្យជារបស់សាធារណៈដល់ជនដទៃ ។ ដោយហេតុនោះឯង ទើបអាចារ្យក្នុងកាលមុនពោលអត្ថនៃសេចក្តីកំណាញ់នេះទុក យ៉ាងនេះថា ដែលហៅថា សេចក្តីកំណាញ់ ព្រោះការកំណាញ់ប្រព្រឹត្តទៅថា សេចក្តីអស្ចារ្យនេះ ចូរមានដល់អញប៉ុណ្ណោះ កុំមានដល់បុគ្គលដទៃ ដូច្នេះ ។ បទថា **អារក្ខោ** បានដល់ ការរក្សាដោយល្អដោយអំណាចនៃការការពារនូវវត្ថុនោះៗ ដោយការបិទទ្វារ និងរក្សាទុកក្នុងហឹបជាដើម ។ ឈ្មោះថា អធិករណៈ ព្រោះអត្ថថា បន្តរឿងឡើង ។ ពាក្យថា អធិករណៈ នេះ ជាឈ្មោះរបស់ហេតុ ។ បទថា **អារក្ខាធិករណំ** នេះ ជានបុំសកលិង្គ អធិប្បាយថា ព្រោះជាហេតុនៃការរក្សា ។

ព្រោះការបៀតបៀនសត្វ មានចាប់ដំបងជាដើម ទ្រង់ត្រាស់ទុក ដើម្បីហាមអកុសលធម៌ដទៃៗ ។ ការចាប់ដំបង ឈ្មោះថា **ទណ្ឌាទានំ** ។ ការចាប់សស្ត្រា ដែលមានមុខតែម្ខាងជាដើម ឈ្មោះថា **សត្ថាទានំ** ។ ការឈ្លោះដោយកាយក្តី ឈ្លោះដោយវាចាក្តី ឈ្មោះថា **កលហោ** ។ ការទាស់ទែងមុនៗ ឈ្មោះថា **វិគ្គហោ** ។ ការទាស់ទែងក្រោយៗ ឈ្មោះថា **វិវាទោ** ។ បទថា **តុវំ តុវំ** ជាពាក្យដែលមិនគោរព លោកកែសព្ទនេះថា **តុំ តុំ** ដូច្នេះ ។

[ ២៥៨-២៥៩ ] ការរញ្ជួយ ការញាប់ញ័រ ឈ្មោះថា **ឥញ្ជិតានិ** ។

ព្រះមានព្រះភាគ ត្រាស់មានះនោះឯងទុក ដោយពាក្យទាំងពួង មានពាក្យថា ថា **អស្មីតិ ឥញ្ជិតមេតំ** ជាដើម ។ ពិតហើយ មានះដែលប្រព្រឹត្តទៅហើយថា **អហំ** ( អញ ) ក៏ឈ្មោះថា **ឥញ្ជិតំ** នោះឯង ។ មានះដែលប្រព្រឹត្តទៅថា **អយមហំ** ( នេះជាអញ ) ក៏ឈ្មោះថា **ឥញ្ជិតំ** នោះឯង ។ មានះដែលប្រព្រឹត្តទៅថា **នេវសញ្ញីនាសញ្ញី ភវិស្សំ** អញនឹងមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ក៏ឈ្មោះថា **ឥញ្ជិតំ** នោះឯង ។ មានះនោះឯង ព្រះមានព្រះភាគត្រាស់ទុកដោយពួក ៩ ដ៏សេស ។

មានះ ព្រះមានព្រះភាគត្រាស់ថា ឈ្មោះថា **ឥញ្ជិត** ព្រោះការញាប់ញ័រ ។ ឈ្មោះថា **មញ្ញិត** ព្រោះការសម្គាល់ខ្លួន ។ ឈ្មោះថា **ផន្ទិត** ព្រោះការអន្ទះអន្ទែង ។ ឈ្មោះថា **បបញ្ចិត** ព្រោះជាធម៌ញ៉ាំងសត្វឲ្យយឺតយូរ ។ ឈ្មោះថា **សង្ខត** ព្រោះត្រូវការតាក់តែង ដោយហេតុនោះៗ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

**នវកនិទ្ទេស ចប់**

## ទសកនិទ្ទេស

[ ២៦០-២៦១ ] ក្នុងនិទ្ទេសនៃពួក ១០ កិលេសវត្ថុ ១០ នោះឯង ឈ្មោះថា **កិលេសវត្ថូនិ** ។ ក្នុងនិទ្ទេសនៃពួក ១០ នេះ អាឃាតវត្ថុ ព្រះ

មានព្រះភាគ ត្រាស់បន្ថែមដោយអាឃាតដែលកើតឡើងក្នុងឋានៈ ដែលមិនសមគួរ មានដង្គត់ឈើ បន្ទាមុតជាដើម ដែលបុគ្គលមិនគប្បីឲ្យក្រោធដោយអំណាចនៃពាក្យជាដើមថា គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនមានប្រយោជន៍ដល់អញ ។

[ ២៦៤ ] ក្នុងមិច្ឆត្តៈ ១០ បទថា **មិច្ឆាញាណំ** បានដល់ មោហៈដែលកើតឡើង ដោយអាការដែលពិចារណាថា អញធ្វើល្អហើយ ព្រោះធ្វើបាបដោយអំណាចនៃការគិតរកឧបាយ ក្នុងការធ្វើបាបទាំងឡាយ ។ បទថា **មិច្ឆាវិមុត្តិ** បានដល់ ការសម្គាល់ថា បានរួចផុតរបស់បុគ្គល ដែលមិនទាន់រួចផុតនោះឯង ។ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

**ទសកនិទ្ទេស ចប់**

# តណ្ហាវិចរិតនិទ្ទេស

[ ២៦៧ ] ក្នុងនិទ្ទេសនៃតណ្ហាវិចរិត បទថា **តណ្ហាវិចរិតានិ** បានដល់ការប្រាកដនៃតណ្ហា ការប្រព្រឹត្តទៅទូទៅនៃតណ្ហា ។ បទថា **អជ្ឈត្តិកស្ស ឧបាទាយ** បានដល់ អាស្រ័យបញ្ចក្ខន្ធខាងក្នុង ។ បទថា **អជ្ឈត្តិកស្ស** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **អស្មីតិ ហោតិ** បានដល់ តណ្ហាថា ជាអញ ដូច្នេះ ព្រោះអាស្រ័យខន្ធបញ្ចកៈ ក្នុងខាងក្នុងណា និងប្រកាន់ការប្រជុំនៃបញ្ចក្ខន្ធនោះ ដោយអំណាចនៃតណ្ហា មានះ ទិដ្ឋិ អធិប្បាយថា កាលការប្រជុំនៃបញ្ចក្ខន្ធនោះនៅមាន ការប្រកាន់ថាអញមាន ទើបមាន ។ ក្នុងបទថា **ឥត្ថស្មីតិ ហោតិ** ជាដើម កាលការកាន់យកដោយការប្រជុំគ្នាយ៉ាងនេះថា អញមាន បន្ទាប់អំពីនោះ ការប្រកាន់រមែងមាន ២ យ៉ាង គឺការប្រកាន់ដោយការមិនប្រៀបធៀប និងការប្រកាន់ដោយការប្រៀបធៀប ។ ក្នុង ២ យ៉ាងនោះ ពាក្យថា ដោយការមិនប្រៀបធៀប បានដល់ការមិនអាស្រ័យអាការដទៃ ប្រកាន់ថា អញមានដោយប្រការដូច្នេះ ព្រោះធ្វើភាវៈនៃខ្លួនប៉ុណ្ណោះ ឲ្យជាអារម្មណ៍ អធិប្បាយថា ការប្រកាន់ដោយអំណាចនៃតណ្ហា មានះ ទិដ្ឋិនោះឯង យ៉ាងនេះថា បណ្ដាក្សត្រជាដើម អញជាយ៉ាងនេះ ។ នេះជាការប្រកាន់ដោយការមិនប្រៀបធៀប ។ ឯការប្រកាន់ដោយការប្រៀបធៀបមាន ២ យ៉ាង គឺដោយការប្រៀបធៀបស្មើជាមួយខ្លួន និងមិនស្មើជាមួយខ្លួន ។ ដើម្បីសម្ដែងការប្រកាន់នោះ ទើបព្រះមានព្រះភាគ

ត្រាស់ថា **ឯវស្មិ** និងត្រាស់ថា **អញ្ញថាស្មិ** ។ បណ្តាបទទាំងនោះ ការប្រកាន់ថា **ឯវស្មិ** នេះជាការប្រកាន់ដោយប្រៀបធៀបស្មើនឹងខ្លួន អធិប្បាយថា ក្សត្រនេះយ៉ាងណា ព្រាហ្មណ៍នេះយ៉ាងណា អញក៏យ៉ាងនោះ ដូច្នេះ ។ បទថា **អញ្ញថាស្មិ** នេះ ជាការប្រកាន់ដោយប្រៀបធៀប ដោយការមិនស្មើគ្នាជាមួយខ្លួន អធិប្បាយថា ក្សត្រនេះយ៉ាងណា ព្រាហ្មណ៍នេះយ៉ាងណា អាត្មាអញដទៃ គឺថោកទាបជាង ឬក្រៃលែងជាងជនទាំងនោះ ដូច្នេះ ។ តណ្ហាវិចរិត ៤ នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃបច្ចុប្បន្ននោះឯង ។ ឯតណ្ហាវិចរិត ៤ មានបទថា **ភវិស្សំ** ជាដើម ត្រាស់ទុកដោយអំណាចនៃអនាគត ។ បណ្ឌិតគប្បីជ្រាបអត្ថនៃតណ្ហាទាំងនោះ ដោយន័យដែលពោលហើយ ក្នុងចតុក្កៈខាងដើមនោះឯង ។

បទថា **អស្មិ** បានដល់ អញទៀង ។ បទថា **សាតស្មិ** បានដល់ អញមិនទៀង ។ ព្រះបាលីថា **អស្សស្មិ** ឬ **សតស្មិ** ដូច្នេះក៏មាន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ ដូចតទៅនេះ ឈ្មោះថា **អសំ** ព្រោះអត្ថថា មាន ពាក្យថា មាន នេះ ជាឈ្មោះរបស់ពាក្យថា ទៀង ឈ្មោះថា **សតំ** ព្រោះអត្ថថា សូន្យ ។ ពាក្យថា សូន្យ នេះ ជាឈ្មោះរបស់ពាក្យថា មិនទៀង ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបបទទាំង ២ នេះថា ព្រះមានព្រះភាគ ត្រាស់ទុកដោយអំណាចនៃសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ បទទាំង ៤ ខាងមុខអំពីនេះ មានបទថា **សិយំ** ជាដើម គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃសេចក្តីសង្ស័យ និងសេចក្តីកន្ទល់ ។ បទទាំងនោះ គប្បី

ជ្រាបអត្ថដោយន័យដែលពោលទុកក្នុងចតុក្កៈ ខាងដើមនោះឯង ។ បទទាំង ៤ មានបទថា **អចាហំ សិយំ** ជាដើម ព្រះមានព្រះភាគ ត្រាស់ទុកដោយអំណាចនៃការកំណត់សេចក្តីប្រាថ្នាយ៉ាងនេះថា អញគប្បីមានឈ្មោះដូច្នេះខ្លះ ពាក្យទាំង ៤ នោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងចតុក្កៈដំបូងនោះឯង ។

ក្នុងបទទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះ

បណ្ឌិតគប្បីចង្អុលបង្ហាញនូវតណ្ហាវិចរិតធម៌ទាំង ១៨ នេះ
គឺ ២ បទ ឈ្មោះថា ទិដ្ឋិសីសៈ គឺមានទិដ្ឋិជាប្រធាន ៤
បទ ជាសុទ្ធសីសៈ បទនីមួយៗ មាន ៣ ទើបជា ១២
បទ ជាសីសមូលកៈ ដូច្នេះ ។

ពិតហើយ ក្នុងតណ្ហាវិចរិតទាំងនោះ តណ្ហាវិចរិត ២ បទ ដែលព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ឈ្មោះថា ទិដ្ឋិសីសៈ ។ ទាំង ៤ បទនេះ គឺ **អស្មិ** តណ្ហាវិចរិតថា អញមាន ១ **ភវិស្សំ** តណ្ហាវិចរិតថា អញនឹងមាន ១ **សិយំ** តណ្ហាវិចរិតថា អញគួរមាន ១ **អចាហំ សិយំ** តណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមាន ១ ឈ្មោះថា សុទ្ធសីសៈប៉ុណ្ណោះ ។ ១២ បទ គឺបទនីមួយៗ ៣ មានបទថា **ឥត្ថស្មិ** ជាដើម ឈ្មោះថា សីសមូលកៈ ព្រោះហេតុនោះ គប្បីជ្រាបតណ្ហាវិចរិតធម៌ទាំងនោះយ៉ាងនេះ គឺ ២ បទ ឈ្មោះថា ទិដ្ឋិសីសៈ ៤ បទ ឈ្មោះថា សុទ្ធសីសៈ ១២ បទ ឈ្មោះថា សីសមូលកៈ ដូច្នេះ ។

[ ២៦៨ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីចែកធម៌ទាំងនោះ ដោយលំដាប់ ទើបផ្តើមបទថា **កថញ្ច អស្មីតិ ហោតិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **កិញ្ចិ ធម្មំ អនវការី ករិត្វា** អធិប្បាយថា មិនធ្វើនូវការចែកធម៌ណាមួយ សូម្បីត្រឹមតែម្យ៉ាង គឺមិនកាន់យកត្រឹមតែមួយ ក្នុងធម៌ទាំងឡាយ មានរូប និងវេទនាជាដើម បានដល់ កាន់យករួមគ្នានោះឯង ។ បទថា **អស្មីតិ ឆន្ទំ បដិលភតិ** បានដល់ កាន់យកបញ្ចក្ខន្ធរួមគ្នាទាំងអស់ ហើយរមែងបាននូវតណ្ហា ថាអញ ដូច្នេះ ។ ក្នុងពាក្យថា មានះ ទិដ្ឋិ ក៏មានន័យដូច្នេះ ។ ក្នុងធម៌ទាំងនោះ គឺតណ្ហា មានះ ទិដ្ឋិ និទ្ទេសនេះជាតណ្ហា-វិចរិតនិទ្ទេសក៏ពិត តែមានះ ទិដ្ឋិ ក៏វៀរចាកតណ្ហាមិនបាន ព្រោះហេតុនោះក្នុងតណ្ហាវិចរិតនិទ្ទេសនេះ ទើបព្រះមានព្រះភាគត្រាស់មានះ និងទិដ្ឋិទុកផងដែរ ដោយអំណាចកិលេសដែលតាំងនៅក្នុងទីជាមួយគ្នានឹងតណ្ហានោះ ។ ម្យ៉ាងទៀត ធម៌ជាគ្រឿងយឺតយូរទាំង ៣ គឺតណ្ហា មានះ ទិដ្ឋិ ព្រះមានព្រះភាគ ទ្រង់លើកឡើងសម្តែងដោយមានតណ្ហាជាប្រធាន ។ ឯមានះ និងទិដ្ឋិព្រះមានព្រះភាគ ទ្រង់កាន់យកដើម្បីអធិប្បាយតណ្ហានោះ ដោយសមគួរដល់ធម៌ដែលលើកឡើងសម្តែងប៉ុណ្ណោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ជាគ្រឿងយឺតយូរ គឺតណ្ហា ទើបត្រាស់ទុកយ៉ាងនេះ ដើម្បីសម្តែងធម៌ជាគ្រឿងយឺតយូរដ៏សេស គឺមានះ និងទិដ្ឋិជាមួយធម៌ជាគ្រឿងយឺតយូរ គឺតណ្ហានោះឯង ។ បទថា **តស្មិំ សតិ ឥមានិ បបញ្ចិតានិ** អធិប្បាយថា កាលធម៌ជាគ្រឿងយឺតយូរ ៣ យ៉ាង ដែលព្រះមានព្រះភាគ ត្រាស់ទុក

ដោយន័យថា **អស្មីតិ ឆន្ទំ បដិលភតិ** ជាដើមនោះ មានធម៌ជាគ្រឿងយឺតយូរ មានបទថា **ឥត្ថស្មីតិ វា** ជាដើមនេះ រមែងមានទៀត ។

[ ២៦៩ ] ក្នុងបទទាំងឡាយ មានបទថា **ខត្តិយោស្មី** ជាដើម បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះថា អញជាស្តេច ដោយសេនាមាត្យជាដើមអភិសេក អញជាព្រាហ្មណ៍ ព្រោះភាពជាបុរោហិត ដោយការរៀនមន្តជាដើម អញជាវេស្សៈ ដោយការរក្សាស្រែ និងគោជាដើម អញជាតិសូទ្រៈ ដោយភាពជាអ្នកស្វែងរកអាហារ អញជាអ្នកគ្រប់គ្រងផ្ទះ ដោយលក្ខណៈនៃគ្រហស្ថដូច្នេះ ។ បទថា **ឯវំ ឥត្ថស្មីតិ ហោតិ** អធិប្បាយថា តណ្ហាថា អញជាប្រក្រតីដោយប្រការយ៉ាងនេះ ព្រោះធ្វើប្រក្រតីនៃស្តេចជាដើម ក្នុងជនទាំងឡាយ មានស្តេចជាដើម ឲ្យកើតឡើងក្នុងខ្លួនយ៉ាងនោះ ។

[ ២៧០ ] ក្នុងបទថា **យថា សោ ខត្តិយោ** ជាដើម គប្បីជ្រាបអត្ថដោយន័យនេះថា ជននោះជាក្សត្រ ដោយសេនាមាត្យជាដើម អភិសេកយ៉ាងណា អញក៏ជាក្សត្រយ៉ាងនោះ ។

[ ២៧១-២៨៥ ] ក្នុងន័យទី ២ គប្បីជ្រាបដោយន័យនេះថា បុគ្គលនោះជាក្សត្រ ដោយសេនាមាត្យជាដើមអភិសេក យ៉ាងណា តែអាត្មាអញ មិនជាក្សត្រយ៉ាងនោះឡើយ តែអញថោកទាបជាង ឬប្រសើរជាងជនទាំងនោះ ។ ក្នុងនិទ្ទេសនៃបទថា **ភវិស្សំ** ជាដើម ក៏មានន័យនេះឯង ។

[ ២៨៦ ] ព្រះមានព្រះភាគ កាលទ្រង់ចែកតណ្ហាវិចរិតអាស្រ័យបញ្ចក្ខន្ធខាងក្នុងយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីចែកតណ្ហាវិចរិត អាស្រ័យបញ្ចក្ខន្ធ

ខាងក្រៅ ទើបត្រាស់បទថា **តត្ថ កតមានិ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ពាហិរស្ស ឧបាទាយ** បានដល់ អាស្រ័យបញ្ចក្ខន្ធខាងក្រៅ ។ ពិតហើយ បទថា **ពាហិរស្ស ឧបាទាយ** នេះ ក៏ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **ឥមិនា** បានដល់ ដោយរូបនេះ ។បេ។ ឬថាដោយវិញ្ញាណនេះ ។ បទដ៏សេស បណ្ឌិតគប្បីជ្រាបអត្ថដោយន័យដែលពោលហើយ ក្នុងឧទ្ទេសវារៈមុននោះឯង ។

[ ២៨៧ ] ក្នុងនិទ្ទេសវារ បទថា **អវការី ករិត្វា** បានដល់ ធ្វើការចែកបញ្ចក្ខន្ធ ។ ក្នុងបទទាំងឡាយ មានបទថា **ឥមិនា អស្មីតិ ឆន្ទំ បដិ-លភតិ** ជាដើម បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា បុគ្គលកាន់យកបញ្ចក្ខន្ធដោយឯកទ្ទេសយ៉ាងនេះថា ដោយរូបនេះ ។បេ។ ឬថា ដោយវិញ្ញាណនេះហើយរមែងបានឆន្ទៈថា អញជាដើម ។

[ ២៨៨-២៨៩ ] ក្នុងបទទាំងឡាយ មានបទថា **ឥមិនា ខត្តិយោស្មិ** ជាដើម គប្បីជ្រាបអត្ថដោយន័យមុននោះឯងយ៉ាងនេះថា អញជាក្សត្រដោយឆត្រ ឬដោយព្រះខ័ន ឬដោយសេនាមាត្យអភិសេក ដូច្នេះ ។ ក្នុងសេចក្ដីនេះ ការឃើញគ្នា គឺត្រឹមតែបទថា **ឥមិនា** ប៉ុណ្ណោះ ពាក្យដែលលោកពោលថា **ឥមិនា** ដូច្នេះ នោះឯងក៏ជាការផ្សេងគ្នា ក្នុងបទថា **យថា សោ ខត្តិ-យោ** ជាដើម ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអត្ថក្នុងបទទាំងពួង ដោយប្រកបយ៉ាងនេះថា កាលប្រកបបទយ៉ាងនេះថា គេជាក្សត្រដោយអំណាចនៃរូបនោះយ៉ាងណា សូម្បីអាត្មាអញក៏យ៉ាងនោះ គឺជាក្សត្រដោយព្រះខ័ន ឬ

ដោយឆត្រ ឬដោយសេនាមាត្យអភិសេកនេះ ។

[ ២៩៥-៣០៤ ] បទថា **ឥមិនា និច្ចោស្មិ** បានដល់ មិនចែកបញ្ចក្ខន្ធចេញអំពីគ្នា ហើយកាន់យកធម៌ណាមួយ ក្នុងរូបជាដើមនោះឯងថាជាអញ ហើយរមែងសម្គាល់ថា អញទៀង អញស្ថិតស្ថេរដោយព្រះខ័ននេះ ឬដោយឆត្រ ដូច្នេះ ។ ក្នុងបទថា **ឧច្ឆេទទិដ្ឋិ** ក៏មានន័យដូច្នេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង គប្បីជ្រាបដោយន័យដែលពោលហើយ ។

[ ៣០៥ ] បទថា **ឥតិ ឯវរូបានិ អតីតានិ ឆត្តឹស** បានដល់ តណ្ហាវិចរិតក្នុងអតីតរបស់បុគ្គលទីមួយៗ មាន ៣៦ ។ បទថា **អនាគតានិ ឆត្តឹស** បានដល់ តណ្ហាវិចរិតក្នុងអនាគតនៃបុគ្គលទីមួយៗ នោះឯង មាន ៣៦ ។ បទថា **បច្ចុប្បន្នានិ ឆត្តឹស** បានដល់ តណ្ហាវិចរិតក្នុងបច្ចុប្បន្នរបស់បុគ្គលទីមួយៗ ឬថា ស្មើគ្នាដែលនឹងរកបានរបស់បុគ្គលច្រើននាក់ ក៏មាន ៣៦ ។ បណ្ឌិតគប្បីជ្រាបតណ្ហាវិចរិតរបស់សត្វទាំងពួង ដោយចំណែកមួយប៉ុណ្ណោះថា ក្នុងអតីតមាន ៣៦ ក្នុងអនាគតមាន ៣៦ ក្នុងបច្ចុប្បន្នមាន ៣៦ ។ តែសត្វទាំងឡាយដែលផ្សេងគ្នាដោយតណ្ហា មានះ ទិដ្ឋិ ដែលមិនដូចគ្នា មិនមានទីបំផុត ។ម្យ៉ាងទៀត ក្នុងបទថា **អដ្ឋសតំ តណ្ហាវិចរិតំ ហោតិ** នេះ បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីនេះ យ៉ាងនេះថា ជាតណ្ហាវិចរិតដែលរាប់បាន ១០៨ ។ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

**តណ្ហាវិចរិតនិទ្ទេស ចប់**

## ទិដ្ឋិគតនិទ្ទេស

[ ៣០៦ ] ក្នុងនិទ្ទេសនៃទិដ្ឋិគតៈ បទថា **ព្រហ្មជាលេ វេយ្យាករណេ** បានដល់ វេយ្យាករណៈ ឈ្មោះថា ព្រហ្មជាលៈ ដែលជាសូត្រទី ១ នៃគម្ពីរទីឃនិកាយ ។ បទថា **វុត្តានិ ភគវតា** បានដល់ ដែលព្រះសាស្ដាត្រាស់ដោយព្រះអង្គឯង ។ ក្នុងបទថា **ចត្តារោ សស្សតវាទា** ជាដើម បណ្ឌិតគប្បីជ្រាបប្រភេទ និងអត្ថនៃទិដ្ឋិដោយន័យដែលពោលហើយក្នុងព្រហ្មជាលសូត្រ មានពាក្យថា ចុះពួកសមណព្រាហ្មណ៍ដ៏ចម្រើននោះ ជាសស្សតវាទ បញ្ញត្តនូវខ្លួន និងលោក ថាទៀង ដោយហេតុ ៤ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ដូច្នេះជាដើម ។

**អដ្ឋកថាខុទ្ទកវិភង្គ ចប់**

# អភិធម្មបិដក

## ធម្មហទយវិភង្គ

[ ៣០៧ ] ខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន សច្ចៈប៉ុន្មាន ឥន្ទ្រិយប៉ុន្មាន ហេតុប៉ុន្មាន អាហារប៉ុន្មាន ផស្សៈប៉ុន្មាន វេទនាប៉ុន្មាន សញ្ញាប៉ុន្មាន ចេតនាប៉ុន្មាន ចិត្តប៉ុន្មាន ។

[ ៣០៨ ] ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ សច្ចៈ ៤ ឥន្ទ្រិយ ២២ ហេតុ ៩ អាហារ ៤ ផស្សៈ ៧ វេទនា ៧ សញ្ញា ៧ ចេតនា ៧ ចិត្ត ៧ ។

[ ៣០៩ ] បណ្តាធម៌ទាំងនោះខន្ធ ៥ តើដូចម្តេច ។ រូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ នេះហៅថា ខន្ធ ៥ ។

[ ៣១០ ] បណ្តាធម៌ទាំងនោះ អាយតនៈ ១២ តើដូចម្តេច ។ ចក្ខាយតនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ សទ្ទាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ នេះហៅថា អាយតនៈ ១២ ។

[ ៣១១ ] បណ្តាធម៌ទាំងនោះ ធាតុ ១៨ តើដូចម្តេច ។ ចក្ខុធាតុ ១ រូបធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតធាតុ ១ សទ្ទធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានធាតុ ១ គន្ធធាតុ ១ ឃានវិញ្ញាណធាតុ ១ ជិវ្ហាធាតុ ១ រសធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយធាតុ ១ ផោដ្ឋព្វធាតុ ១ កាយ-

វិញ្ញាណធាតុ ១ មនោធាតុ ១ ធម្មធាតុ ១ មនោវិញ្ញាណធាតុ ១ នេះហៅថា ធាតុ ១៨ ។

[ ៣១២ ] បណ្ដាធម៌ទាំងនោះ សច្ចៈ ៤ តើដូចម្ដេច ។ ទុក្ខសច្ច ១ សមុទយសច្ច ១ មគ្គសច្ច ១ និរោធសច្ច ១ នេះហៅថា សច្ចៈ ៤ ។

[ ៣១៣ ] បណ្ដាធម៌ទាំងនោះ ឥន្ទ្រិយ ២២ តើដូចម្ដេច ។ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ នេះហៅថា ឥន្ទ្រិយ ២២ ។

[ ៣១៤ ] បណ្ដាធម៌ទាំងនោះ ហេតុ ៩ តើដូចម្ដេច ។ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ ។ បណ្ដាហេតុទាំងនោះ កុសលហេតុ ៣ តើដូចម្ដេច ។ អលោភៈជាកុសលហេតុ ១ អទោសៈជាកុសលហេតុ ១ អមោហៈជាកុសលហេតុ ១ នេះកុសលហេតុ ៣ ។ បណ្ដាហេតុទាំងនោះ អកុសលហេតុ ៣ តើដូចម្ដេច ។ លោភៈជាអកុសលហេតុ ១ ទោសៈជាអកុសលហេតុ ១ មោហៈជាអកុសលហេតុ ១ នេះអកុសលហេតុ ៣ ។ បណ្ដាហេតុទាំងនោះ អព្យាកតហេតុ ៣ តើដូចម្ដេច ។ អលោភៈ ១ អទោសៈ ១ អមោហៈ ១ ក្នុងវិបាកនៃកុសលធម៌ទាំងឡាយ ឬក្នុងកិរិយាព្យាកតធម៌ទាំងឡាយ នេះអព្យាកតហេតុ ៣ ។ នេះហៅថា ហេតុ

៩ ។

[ ៣១៥ ] បណ្ដាធម៌ទាំងនោះ អាហារ ៤ តើដូចម្ដេច ។ កពឡិង្ការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ នេះហៅថា អាហារ ៤ ។

[ ៣១៦ ] បណ្ដាធម៌ទាំងនោះ ផស្សៈ ៧ តើដូចម្ដេច ។ ចក្ខុសម្ផស្ស ១ សោតសម្ផស្ស ១ ឃានសម្ផស្ស ១ ជិវ្ហាសម្ផស្ស ១ កាយសម្ផស្ស ១ មនោធាតុសម្ផស្ស ១ មនោវិញ្ញាណធាតុសម្ផស្ស ១ នេះហៅថា ផស្សៈ ៧ ។

[ ៣១៧ ] បណ្ដាធម៌ទាំងនោះ វេទនា ៧ តើដូចម្ដេច ។ វេទនាកើតអំពីចក្ខុសម្ផស្ស ១ វេទនាកើតអំពីសោតសម្ផស្ស ១ វេទនាកើតអំពីឃានសម្ផស្ស ១ វេទនាកើតអំពីជិវ្ហាសម្ផ័ស្ស ១ វេទនាកើតអំពីកាយសម្ផស្ស ១ វេទនាកើតអំពីមនោធាតុសម្ផស្ស ១ វេទនាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស ១ នេះហៅថា វេទនា ៧ ។

[ ៣១៨ ] បណ្ដាធម៌ទាំងនោះ សញ្ញា ៧ តើដូចម្ដេច ។ សញ្ញាកើតអំពីចក្ខុសម្ផស្ស ១ សញ្ញាកើតអំពីសោតសម្ផស្ស ១ សញ្ញាកើតអំពីឃានសម្ផស្ស ១ សញ្ញាកើតអំពីជិវ្ហាសម្ផ័ស្ស ១ សញ្ញាកើតអំពីកាយសម្ផស្ស ១ សញ្ញាកើតអំពីមនោធាតុសម្ផស្ស ១ សញ្ញាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស ១ នេះហៅថា សញ្ញា ៧ ។

[ ៣១៩ ] បណ្ដាធម៌ទាំងនោះ ចេតនា ៧ តើដូចម្ដេច ។ ចេតនាកើតអំពីចក្ខុសម្ផស្ស ១ ចេតនាកើតអំពីសោតសម្ផស្ស ១ ចេតនាកើតអំពីឃាន-

សម្ផស្ស ១ ចេតនាកើតអំពីជិវ្ហាសម្ផស្ស ១ ចេតនាកើតអំពីកាយសម្ផស្ស ១ ចេតនាកើតអំពីមនោសម្ផស្ស ១ ចេតនា កើតអំពីមនោវិញ្ញាណធាតុ-សម្ផស្ស ១ នេះហៅថា ចេតនា ៧ ។

[ ៣២០ ] បណ្ដាធម៌ទាំងនោះ ចិត្ត ៧ តើដូចម្ដេច ។ ចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ នេះហៅថា ចិត្ត ៧ ។

[ ៣២១ ] ក្នុងកាមធាតុ មានខន្ធប៉ុន្មាន ។បេ។ មានចិត្តប៉ុន្មាន ។ ក្នុងកាមធាតុ មានខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ សច្ចៈ ៣ ឥន្ទ្រិយ ២២ ហេតុ ៩ អាហារ ៤ ផស្សៈ ៧ វេទនា ៧ សញ្ញា ៧ ចេតនា ៧ ចិត្ត ៧ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុមានខន្ធ ៥ តើដូចម្ដេច ។ រូបក្ខន្ធ ១ ។បេ។ វិញ្ញាណក្ខន្ធ ១ នេះហៅថា ក្នុងកាមធាតុ មានខន្ធ ៥ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុ មានអាយតនៈ ១២ តើដូចម្ដេច ។ ចក្ខាយតនៈ ១ រូបា-យតនៈ ១ ។បេ។ មនាយតនៈ ១ ធម្មាយតនៈ ១ នេះហៅថា ក្នុងកាម-ធាតុ មានអាយតនៈ ១២ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុ មានធាតុ ១៨ តើដូចម្ដេច ។ ចក្ខុធាតុ ១ រូបធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ ។បេ។ មនោធាតុ ១ ធម្មធាតុ ១ មនោវិញ្ញាណធាតុ ១ នេះហៅថា ក្នុងកាមធាតុ មានធាតុ ១៨ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុ មានសច្ចៈ ៣ តើដូចម្ដេច ។ ទុក្ខសច្ច ១ សមុទយសច្ច ១ មគ្គសច្ច ១ នេះហៅថា ក្នុង

កាមធាតុ មានសច្ចៈ ៣ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុ មានឥន្ទ្រិយ ២២ តើដូចម្ដេច ។ ចក្ខុន្ទ្រិយ ១ ។បេ។ អញ្ញាតាវិន្ទ្រិយ ១ នេះហៅថា ក្នុងកាមធាតុ មានឥន្ទ្រិយ ២២ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុ មានហេតុ ៩ តើដូចម្ដេច ។ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ នេះហៅថា ក្នុងកាមធាតុ មានហេតុ ៩ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុ មានអាហារ ៤ តើដូចម្ដេច ។ កពឡិង្ការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ នេះហៅថា ក្នុងកាមធាតុ មានអាហារ ៤ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុ មានផស្សៈ ៧ តើដូចម្ដេច ។ ចក្ខុសម្ផស្ស ១ ។បេ។ មនោវិញ្ញាណធាតុសម្ផស្ស ១ នេះហៅថា ក្នុងកាមធាតុ មានផស្សៈ ៧ ។ បណ្ដាធម៌ទាំងនោះ ក្នុងកាមធាតុ មានវេទនា ៧ សញ្ញា ៧ ចេតនា ៧ ចិត្ត ៧ តើដូចម្ដេច ។ ចក្ខុវិញ្ញាណ ១ ។បេ។ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ នេះហៅថា ក្នុងកាមធាតុ មានចិត្ត ៧ ។

[ ៣២២ ] ក្នុងរូបធាតុ មានខន្ធប៉ុន្មាន ។បេ។ មានចិត្តប៉ុន្មាន ។ ក្នុងរូបធាតុ មានខន្ធ ៥ អាយតនៈ ៦ ធាតុ ៩ សច្ចៈ ៣ ឥន្ទ្រិយ ១៤ ហេតុ ៨ អាហារ ៣ ផស្សៈ ៤ វេទនា ៤ សញ្ញា ៤ ចេតនា ៤ ចិត្ត ៤ ។ បណ្ដាធម៌ទាំងនោះ ក្នុងរូបធាតុ មានខន្ធ ៥ តើដូចម្ដេច ។ រូបក្ខន្ធ ១ ។បេ។ វិញ្ញាណក្ខន្ធ ១ នេះហៅថា ក្នុងរូបធាតុ មានខន្ធ ៥ ។ បណ្ដាធម៌ទាំងនោះ ក្នុងរូបធាតុ មានអាយតនៈ ៦ តើដូចម្ដេច ។ ចក្ខាយតនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ សទ្ទាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១

នេះហៅថា ក្នុងរូបធាតុ មានអាយតនៈ ៦ ។ បណ្តាធម៌ទាំងនោះ ក្នុងរូបធាតុ មានធាតុ ៩ តើដូចម្តេច ។ ចក្ខុធាតុ ១ រូបធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតធាតុ ១ សទ្ទធាតុ ១ សោតវិញ្ញាណធាតុ ១ មនោធាតុ ១ ធម្មធាតុ ១ មនោវិញ្ញាណធាតុ ១ នេះហៅថា ក្នុងរូបធាតុ មានធាតុ ៩ ។ បណ្តាធម៌ទាំងនោះ ក្នុងរូបធាតុ មានសច្ចៈ ៣ តើដូចម្តេច ។ ទុក្ខសច្ច ១ សមុទយសច្ច ១ មគ្គសច្ច ១ នេះហៅថា ក្នុងរូបធាតុ មានសច្ច ៣ ។ បណ្តាធម៌ទាំងនោះ ក្នុងរូបធាតុ មានឥន្ទ្រិយ ១៤ តើដូចម្តេច ។ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ មនិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ នេះហៅថា ក្នុងរូបធាតុ មានឥន្ទ្រិយ ១៤ ។ បណ្តាធម៌ទាំងនោះ ក្នុងរូបធាតុ មានហេតុ ៨ តើដូចម្តេច ។ កុសលហេតុ ៣ អកុសលហេតុ ២ អព្យាកតហេតុ ៣ ។ បណ្តាហេតុទាំងនោះ កុសលហេតុ ៣ តើដូចម្តេច ។ អលោភៈ ជាកុសលហេតុ ១ អទោសៈ ជាកុសសហេតុ ១ អមោហៈ ជាកុសលហេតុ ១ នេះហៅថា កុសលហេតុ ៣ ។ បណ្តាធម៌ទាំងនោះ អកុសលហេតុ ២ តើដូចម្តេច ។ លោភៈ ជាអកុសលហេតុ ១ មោហៈ ជាអកុសលហេតុ ១ នេះហៅថា អកុសលហេតុ ២ ។ បណ្តាហេតុទាំងនោះ អព្យាកតហេតុ ៣ តើដូចម្តេច ។ អលោភៈ ១ អទោសៈ ១ អមោហៈ ១ ។ ក្នុងវិបាកនៃកុសលធម៌ទាំងឡាយ ឬក្នុងកិរិយាព្យាកតធម៌ទាំងឡាយ នេះ

ហៅថា អព្យាកតហេតុ ៣ ។ នេះហៅថា ក្នុងរូបធាតុ មានហេតុ ៨ ។ បណ្ដាធម៌ទាំងនោះ ក្នុងរូបធាតុ មានអាហារ ៣ តើដូចម្ដេច ។ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ នេះហៅថា ក្នុងរូបធាតុ មានអាហារ ៣ ។ បណ្ដាធម៌ទាំងនោះ ក្នុងរូបធាតុ មានផស្សៈ ៤ តើដូចម្ដេច ។ ចក្ខុសម្ផស្ស ១ សោតសម្ផស្ស ១ មនោធាតុសម្ផស្ស ១ មនោ-វិញ្ញាណធាតុសម្ផស្ស ១ នេះហៅថា ក្នុងរូបធាតុ មានផស្សៈ ៤ ។ បណ្ដាធម៌ទាំងនោះ ក្នុងរូបធាតុ មានវេទនា ៤ តើដូចម្ដេច ។ សញ្ញាបួន ១ ចេតនាបួន ១ ចិត្តបួន ១ ចក្ខុវិញ្ញាណ សោតវិញ្ញាណ មនោធាតុ មនោ-វិញ្ញាណធាតុ ១ នេះហៅថា ក្នុងរូបធាតុ មានចិត្ត ៤ ។

[ ៣២៣ ] ក្នុងអរូបធាតុ មានខន្ធប៉ុន្មាន ។បេ។ មានចិត្តប៉ុន្មាន ។ ក្នុងអរូបធាតុ មានខន្ធ ៤ អាយតនៈ ២ ធាតុ ២ សច្ចៈ ៣ ឥន្ទ្រិយ ១១ ហេតុ ៨ អាហារ ៣ ផស្សៈ ១ វេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ ។ បណ្ដាធម៌ទាំងនោះ ក្នុងអរូបធាតុ មានខន្ធ ៤ តើដូចម្ដេច ។ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ នេះហៅថា ក្នុងអរូបធាតុ មានខន្ធ ៤ ។ បណ្ដាធម៌ទាំងនោះ ក្នុងអរូបធាតុ មានអាយតនៈ ២ តើដូចម្ដេច ។ មនាយតនៈ ១ ធម្មាយតនៈ ១ នេះហៅថា ក្នុងអរូបធាតុ មានអាយតនៈ ២ ។ បណ្ដាធម៌ទាំងនោះ ក្នុងអរូបធាតុ មានធាតុ ២ តើដូចម្ដេច ។ មនោ-វិញ្ញាណធាតុ ១ ធម្មធាតុ ១ នេះហៅថា ក្នុងអរូបធាតុ មានធាតុ ២ ។ បណ្ដាធម៌ទាំងនោះ ក្នុងអរូបធាតុ មានសច្ចៈ ៣ តើដូចម្ដេច ។ ទុក្ខសច្ច

១ សមុទយសច្ច ១ មគ្គសច្ច ១ នេះហៅថា ក្នុងអរូបធាតុ មានសច្ចៈ ៣ ។ បណ្តាធម៌ទាំងនោះ ក្នុងអរូបធាតុ មានឥន្ទ្រិយ ១១ តើដូចម្តេច ។ មនិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ នេះហៅថា ក្នុងអរូបធាតុ មានឥន្ទ្រិយ ១១ ។ បណ្តាធម៌ទាំងនោះ ក្នុងអរូបធាតុ មានហេតុ ៨ តើដូចម្តេច ។ កុសលហេតុ ៣ អកុសលហេតុ ២ អព្យាកតហេតុ ៣ នេះហៅថា ក្នុងអរូបធាតុ មានហេតុ ៨ ។ បណ្តាធម៌ទាំងនោះ ក្នុងអរូបធាតុ មានអាហារ ៣ តើដូចម្តេច ។ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ នេះហៅថា ក្នុងអរូបធាតុ មានអាហារ ៣ ។ បណ្តាធម៌ទាំងនោះ ក្នុងអរូបធាតុ មានផស្សៈ ១ តើដូចម្តេច ។ មនោវិញ្ញាណធាតុសម្ផស្ស នេះហៅថា ក្នុងអរូបធាតុ មានផស្សៈ ១ ។ បណ្តាធម៌ទាំងនោះ ក្នុងអរូបធាតុ មានវេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ តើដូចម្តេច ។ មនោវិញ្ញាណធាតុ នេះហៅថា ក្នុងអរូបធាតុ មានចិត្ត ១ ។

[ ៣២៤ ] ក្នុងអបរិយាបន្នធម៌ ( លោកុត្តរភូមិ ) មានខន្ធប៉ុន្មាន ។បេ។ មានចិត្តប៉ុន្មាន ។ ក្នុងអបរិយាបន្នធម៌ មានខន្ធ ៤ អាយតនៈ ២ ធាតុ ២ សច្ចៈ ២ ឥន្ទ្រិយ ១២ ហេតុ ៦ អាហារ ៣ ផស្សៈ ១ វេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ ។ បណ្តាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មានខន្ធ ៤ តើដូចម្តេច ។ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ

១ នេះហៅថា ក្នុងអបរិយាបន្នធម៌ មានខន្ធ ៤ ។ បណ្ដាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មានអាយតនៈ ២ តើដូចម្ដេច ។ មនាយតនៈ ១ ធម្មាយតនៈ ១ នេះហៅថា ក្នុងអបរិយាបន្នធម៌ មានអាយតនៈ ២ ។ បណ្ដាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មានធាតុ ២ តើដូចម្ដេច ។ មនោវិញ្ញាណធាតុ ១ ធម្មធាតុ ១ នេះហៅថា ក្នុងអបរិយាបន្នធម៌ មានធាតុ ២ ។ បណ្ដាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មានសច្ចៈ ២ តើដូចម្ដេច ។ មគ្គសច្ច ១ និរោធសច្ច ១ នេះហៅថា ក្នុងអបរិយាបន្នធម៌ មានសច្ចៈ ២ ។ បណ្ដាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មានឥន្ទ្រិយ ១២ តើដូចម្ដេច ។ មនិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ នេះហៅថា ក្នុងអបរិយាបន្នធម៌ មានឥន្ទ្រិយ ១២ ។ បណ្ដាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មានហេតុ ៦ តើដូចម្ដេច ។ កុសលហេតុ ៣ អព្យាកតហេតុ ៣ ។ បណ្ដាហេតុទាំងនោះ កុសលហេតុ ៣ តើដូចម្ដេច ។ អលោភៈ ជាកុសលហេតុ ១ អទោសៈ ជាកុសលហេតុ ១ អមោហៈ ជាកុសលហេតុ ១ នេះហៅថា កុសលហេតុ ៣ ។ បណ្ដាហេតុទាំងនោះ អព្យាកតហេតុ ៣ តើដូចម្ដេច ។ អលោភៈ ១ អទោសៈ ១ អមោហៈ ១ ក្នុងវិបាកនៃកុសលធម៌ទាំងឡាយ នេះហៅថា អព្យាតកហេតុ ៣ ។ នេះហៅថា ក្នុងអបរិយាបន្នធម៌ មានហេតុ ៦ ។ បណ្ដាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មាន

អាហារ ៣ តើដូចម្តេច ។ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញា-ណាហារ ១ នេះហៅថា ក្នុងអបរិយាបន្នធម៌ មានអាហារ ៣ ។ បណ្តាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មានផស្សៈ ១ តើដូចម្តេច ។ មនោ-វិញ្ញាណធាតុសម្ផស្ស ១ នេះហៅថា ក្នុងអបរិយាបន្នធម៌ មានផស្សៈ ១ ។ បណ្តាធម៌ទាំងនោះ ក្នុងអបរិយាបន្នធម៌ មានវេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ តើដូចម្តេច ។ មនោវិញ្ញាណធាតុ នេះហៅថា ក្នុងអបរិយាបន្ន-ធម៌ មានចិត្ត ១ ។

[ ៣២៥ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មានរាប់បញ្ចូលក្នុងកាមធាតុ ខន្ធប៉ុន្មាន មិនរាប់បញ្ចូលក្នុងកាមធាតុ ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មានរាប់បញ្ចូលក្នុងកាមធាតុ ចិត្តប៉ុន្មានមិនរាប់បញ្ចូល ក្នុងកាមធាតុ ។ រូបក្ខន្ធរាប់បញ្ចូលក្នុងកាមធាតុ ខន្ធ ៤ រាប់បញ្ចូលក្នុងកាមធាតុ ក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុ ក៏មាន ។ អាយតនៈ ១០ រាប់បញ្ចូលក្នុងកាមធាតុ អាយតនៈ ២ រាប់បញ្ចូលក្នុងកាមធាតុក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុក៏មាន ។ ធាតុ ១៦ រាប់បញ្ចូលក្នុងកាមធាតុ ធាតុ ២ រាប់បញ្ចូលក្នុងកាមធាតុក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុក៏មាន ។ សមុទយសច្ច រាប់បញ្ចូលក្នុងកាមធាតុ សច្ចៈ ២ មិនរាប់បញ្ចូលក្នុងកាមធាតុ ទុក្ខសច្ច រាប់បញ្ចូលក្នុងកាមធាតុក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុក៏មាន ។ ឥន្ទ្រិយ ១០ រាប់បញ្ចូលក្នុងកាមធាតុ ឥន្ទ្រិយ ៣ មិនរាប់បញ្ចូលក្នុងកាមធាតុ ឥន្ទ្រិយ ៩

រាប់បញ្ចូលក្នុងកាមធាតុក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុក៏មាន អកុសល-ហេតុ ៣ រាប់បញ្ចូលក្នុងកាមធាតុ ហេតុ ៦ រាប់បញ្ចូលក្នុងកាមធាតុក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុក៏មាន ។ កពឡិង្ការាហារ រាប់បញ្ចូលក្នុងកាមធាតុ អាហារ ៣ រាប់បញ្ចូលក្នុងកាមធាតុក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុក៏មាន ។ ផស្សៈ ៦ រាប់បញ្ចូលក្នុងកាមធាតុ មនោវិញ្ញាណធាតុសម្ផស្ស រាប់បញ្ចូលក្នុងកាមធាតុក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុក៏មាន ។ វេទនា ៦ សញ្ញា ៦ ចេតនា ៦ ចិត្ត ៦ រាប់បញ្ចូលក្នុងកាមធាតុ មនោវិញ្ញាណ-ធាតុ រាប់បញ្ចូលក្នុងកាមធាតុក៏មាន មិនរាប់បញ្ចូលក្នុងកាមធាតុក៏មាន ។

[ ៣២៦ ] បណ្ដាខន្ធទាំង ៥ ខន្ធប៉ុន្មានរាប់បញ្ចូលក្នុងរូបធាតុ ខន្ធប៉ុន្មាន មិនរាប់បញ្ចូលក្នុងរូបធាតុ ។បេ។ បណ្ដាចិត្តទាំង ៧ ចិត្តប៉ុន្មាន រាប់បញ្ចូលក្នុងរូបធាតុ ចិត្តប៉ុន្មានមិនរាប់បញ្ចូលក្នុងរូបធាតុ ។ រូបក្ខន្ធ មិនរាប់បញ្ចូលក្នុងរូបធាតុ ខន្ធ ៤ រាប់បញ្ចូលក្នុងរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុក៏មាន ។ អាយតនៈ ១០ មិនរាប់បញ្ចូលក្នុងរូបធាតុ អាយតនៈ ២ រាប់បញ្ចូលក្នុងរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុក៏មាន ។ ធាតុ ១៦ មិនរាប់បញ្ចូលក្នុងរូបធាតុ ធាតុ ២ រាប់បញ្ចូលក្នុងរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុក៏មាន ។ សច្ចៈ ៣ មិនរាប់បញ្ចូលក្នុងរូបធាតុ ទុក្ខសច្ច រាប់បញ្ចូលក្នុងរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុក៏មាន ឥន្ទ្រិយ ១៣ មិនរាប់បញ្ចូលក្នុងរូបធាតុ ឥន្ទ្រិយ ៩ រាប់បញ្ចូលក្នុងរូបធាតុ ក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុ ក៏មាន ។ អកុសលហេតុ ៣ មិនរាប់បញ្ចូលក្នុង

រូបធាតុ ហេតុ ៦ រាប់បញ្ចូលក្នុងរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុក៏មាន ។ កពឡិង្ការាហារ មិនរាប់បញ្ចូលក្នុងរូបធាតុ អាហារ ៣ រាប់បញ្ចូលក្នុងរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុក៏មាន ។ ផស្សៈ ៦ មិនរាប់បញ្ចូលក្នុងរូបធាតុ មនោវិញ្ញាណធាតុសម្ផស្ស រាប់បញ្ចូលក្នុងរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុក៏មាន ។ វេទនា ៦ សញ្ញា ៦ ចេតនា ៦ ចិត្ត ៦ មិនរាប់បញ្ចូលក្នុងរូបធាតុ មនោវិញ្ញាណធាតុ រាប់បញ្ចូលក្នុងរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងរូបធាតុក៏មាន ។

[ ៣២៧ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មាន រាប់បញ្ចូលក្នុងអរូបធាតុ ខន្ធប៉ុន្មាន មិនរាប់បញ្ចូលក្នុងអរូបធាតុ ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មាន រាប់បញ្ចូលក្នុងអរូបធាតុ ចិត្តប៉ុន្មាន មិនរាប់បញ្ចូលក្នុងអរូបធាតុ ។ រូបក្ខន្ធ មិនរាប់បញ្ចូលក្នុងអរូបធាតុ ខន្ធ ៤ រាប់បញ្ចូលក្នុងអរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុក៏មាន ។ អាយតនៈ ១០ មិនរាប់បញ្ចូលក្នុងអរូបធាតុ អាយតនៈ ២ រាប់បញ្ចូលក្នុងអរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុក៏មាន ។ ធាតុ ១៦ មិនរាប់បញ្ចូលក្នុងអរូបធាតុ ធាតុ ២ រាប់បញ្ចូលក្នុងអរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុក៏មាន ។ សច្ចៈ ៣ មិនរាប់បញ្ចូលក្នុងអរូបធាតុ ទុក្ខសច្ច រាប់បញ្ចូលក្នុងអរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុក៏មាន ។ ឥន្ទ្រិយ ១៤ មិនរាប់បញ្ចូលក្នុងអរូបធាតុ ឥន្ទ្រិយ ៨ រាប់បញ្ចូលក្នុងអរូបធាតុ ក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុ ក៏មាន ។ អកុសលហេតុ ៣ មិនរាប់បញ្ចូលក្នុងអរូបធាតុ ហេតុ ៦ រាប់បញ្ចូលក្នុង

អរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុក៏មាន ។ កពឡិង្ការាហារ មិនរាប់បញ្ចូលក្នុងអរូបធាតុ អាហារ ៣ រាប់បញ្ចូលក្នុងអរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុក៏មាន ។ ផស្សៈ ៦ មិនរាប់បញ្ចូលក្នុងអរូបធាតុ មនោវិញ្ញាណធាតុសម្ផស្ស រាប់បញ្ចូលក្នុងអរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុក៏មាន ។ វេទនា ៦ សញ្ញា ៦ ចេតនា ៦ ចិត្ត ៦ មិនរាប់បញ្ចូលក្នុងអរូបធាតុ មនោវិញ្ញាណធាតុ រាប់បញ្ចូលក្នុងអរូបធាតុក៏មាន មិនរាប់បញ្ចូលក្នុងអរូបធាតុក៏មាន ។

[ ៣២៨ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មានជាបរិយាបន្ន ខន្ធប៉ុន្មានជាអបរិយាបន្ន ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មាន ជាបរិយាបន្ន ចិត្តប៉ុន្មានជាអបរិយាបន្ន ។ រូបក្ខន្ធ ជាបរិយាបន្ន ខន្ធ ៤ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ អាយតនៈ ១០ ជាបរិយាបន្ន អាយតនៈ ២ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ ធាតុ ១៦ ជាបរិយាបន្ន ធាតុ ២ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ សច្ចៈ ២ ជាបរិយាបន្ន សច្ចៈ ២ ជាអបរិយាបន្ន ។ ឥន្ទ្រិយ ១០ ជាបរិយាបន្ន ឥន្ទ្រិយ ៣ ជាអបរិយាបន្ន ឥន្ទ្រិយ ៩ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ អកុសលហេតុ ៣ ជាបរិយាបន្ន ហេតុ ៦ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ កពឡិង្ការាហារ ជាបរិយាបន្ន អាហារ ៣ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ ផស្សៈ ៦ ជាបរិយាបន្ន មនោវិញ្ញាណធាតុសម្ផស្ស ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ វេទនា ៦

សញ្ញា ៦ ចេតនា ៦ ចិត្ត ៦ ជាបរិយាបន្ន មនោវិញ្ញាណធាតុ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។

[ ៣២៩ ] ក្នុងខណៈនៃបដិសន្ធិក្នុងកាមធាតុ ខន្ធប៉ុន្មានកើតប្រាកដ ។បេ។ ចិត្តប៉ុន្មានកើតប្រាកដ ។ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ខន្ធ ៥ នៃសត្វទាំងពួងកើតប្រាកដ ។ អាយតនៈ ១១ នៃសត្វពួកខ្លះកើតប្រាកដ អាយតនៈ ១០ នៃសត្វពួកខ្លះកើតប្រាកដ អាយតនៈ ១០ នៃសត្វពួកខ្លះ ដទៃទៀតកើតប្រាកដ អាយតនៈ ៩ នៃសត្វពួកខ្លះកើតប្រាកដ អាយតនៈ ៧ នៃសត្វពួកខ្លះកើតប្រាកដ ។ ធាតុ ១១ នៃសត្វពួកខ្លះកើតប្រាកដ ធាតុ ១០ នៃសត្វពួកខ្លះកើតប្រាកដ ធាតុ ១០ នៃសត្វពួកខ្លះដទៃទៀតកើតប្រាកដ ធាតុ ៩ នៃសត្វពួកខ្លះកើតប្រាកដ ធាតុ ៧ នៃសត្វពួកខ្លះកើតប្រាកដ ។ សច្ចៈ ១ នៃសត្វទាំងពួង កើតប្រាកដ ។ ឥន្ទ្រិយ ១៤ នៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ១៣ នៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ១៣ នៃសត្វពួកខ្លះដទៃទៀត កើតប្រាកដ ឥន្ទ្រិយ ១២ នៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ១០ នៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ៩ នៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ៩ ដទៃទៀតនៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ៨ នៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ៨ ដទៃទៀតនៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ៧ នៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ៥ នៃសត្វពួកខ្លះ កើតប្រាកដ ឥន្ទ្រិយ ៤ នៃសត្វពួកខ្លះ កើតប្រាកដ ។ ហេតុ ៣ នៃសត្វពួកខ្លះ កើតប្រាកដ

ហេតុ ២ នៃសត្វពួកខ្លះ កើតប្រាកដ សត្វពួកខ្លះជាអហេតុកៈ កើតប្រាកដ ។ អាហារ ៤ នៃសត្វទាំងពួង កើតប្រាកដ ។ ផស្សៈ ១ នៃសត្វទាំងពួង កើតប្រាកដ ។ វេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ នៃសត្វទាំងពួង កើតប្រាកដ ។

[ ៣៣០ ] ខន្ធ ៥ នៃសត្វទាំងពួង កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ តើដូចម្តេច ។ រូបក្ខន្ធ ១ ។បេ។ វិញ្ញាណក្ខន្ធ ១ ខន្ធទាំង ៥ នេះនៃសត្វទាំងពួង កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះអាយតនៈ ១១ នៃសត្វណា កើតប្រាកដក្នុងខណៈនៃបដិសន្ធិក្នុងកាមធាតុ ។ អាយតនៈ ១១ គឺចក្ខាយតនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ នៃពួកទេវតាជាកាមាវចរ នៃមនុស្សដែលកើតក្នុងបឋមកប្ប នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលមានអាយតនៈគ្រប់គ្រាន់ តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះអាយតនៈ ១១ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះអាយតនៈ ១០ នៃសត្វណា កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ អាយតនៈ ១០ គឺរូបាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ នៃប្រេតជាឱបបាតិកៈ នៃ

អសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរក ជាសត្វដែលខ្វាក់ អំពីកំណើត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះអាយតនៈ ១០ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះអាយតនៈ ១០ ដទៃទៀតនៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ អាយតនៈ ១០ គឺចក្ខាយតនៈ ១ រូបាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលថ្លង់អំពីកំណើត តែងកើតប្រាកដក្នុងខណៈនៃបដិសន្ធិ នេះអាយតនៈ ១០ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះអាយតនៈ ៩ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ អាយតនៈ ៩ គឺរូបាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរក ជាសត្វដែលខ្វាក់ និងថ្លង់អំពីកំណើត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះអាយតនៈ ៩ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិក្នុងកាមធាតុ ។ ចុះអាយតនៈ ៧ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ អាយតនៈ ៧ គឺរូបាយតនៈ ១ គន្ធាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនា-

យតនៈ ១ ធម្មាយតនៈ ១ នៃសត្វដេកក្នុងគភ៌ តែងកើតប្រាកដក្នុងខណៈនៃបដិសន្ធិ នេះអាយតនៈ ៧ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះធាតុ ១១ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ធាតុ ១១ គឺចក្ខុធាតុ ១ រូបធាតុ ១ សោតធាតុ ១ ឃានធាតុ ១ គន្ធធាតុ ១ ជិវ្ហាធាតុ ១ រសធាតុ ១ កាយធាតុ ១ ផោដ្ឋព្វធាតុ ១ មនោវិញ្ញាណធាតុ ១ ធម្មធាតុ ១ នៃទេវតាជាកាមាវចរ នៃមនុស្សដែលកើតក្នុងបឋមកប្ប នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលមានអាយតនៈគ្រប់គ្រាន់ តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះធាតុ ១១ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះធាតុ ១០ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ធាតុ ១០ គឺរូបធាតុ ១ សោតធាតុ ១ ឃានធាតុ ១ គន្ធធាតុ ១ ជិវ្ហាធាតុ ១ រសធាតុ ១ កាយធាតុ ១ ផោដ្ឋព្វធាតុ ១ មនោវិញ្ញាណធាតុ ១ ធម្មធាតុ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលខ្វាក់អំពីកំណើត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះធាតុ ១០ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាម-ធាតុ ។ ចុះធាតុ ១០ ដទៃទៀតនៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិក្នុងកាមធាតុ ។ ធាតុ ១០ គឺចក្ខុធាតុ ១ រូបធាតុ ១ ឃានធាតុ ១ គន្ធធាតុ ១ ជិវ្ហាធាតុ ១ រសធាតុ ១ កាយធាតុ ១ ផោដ្ឋព្វធាតុ ១ មនោ-

វិញ្ញាណធាតុ ១ ធម្មធាតុ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលថ្លង់អំពីកំណើត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះធាតុ ១០ នៃសត្វទាំងនុ៎ះ កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះធាតុ ៩ នៃសត្វណា កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ធាតុ ៩ គឺរូបធាតុ ១ ឃានធាតុ ១ គន្ធធាតុ ១ ជិវ្ហាធាតុ ១ រសធាតុ ១ កាយធាតុ ១ ផោដ្ឋព្វធាតុ ១ មនោ-វិញ្ញាណធាតុ ១ ធម្មធាតុ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលខ្វាក់ និងថ្លង់អំពីកំណើត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះធាតុ ៩ នៃសត្វទាំងនុ៎ះ កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះធាតុ ៧ នៃសត្វណា កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ធាតុ ៧ គឺរូបធាតុ ១ គន្ធធាតុ ១ រសធាតុ ១ កាយធាតុ ១ ផោដ្ឋព្វធាតុ ១ មនោវិញ្ញាណធាតុ ១ ធម្មធាតុ ១ នៃសត្វដេកក្នុងគភ៌ តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះធាតុ ៧ នៃសត្វទាំងនុ៎ះ កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះសច្ចៈ ១ នៃសត្វទាំងពួង កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ តើដូចម្តេច ។ ទុក្ខសច្ច នេះសច្ចៈ ១ នៃសត្វទាំងពួង កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ១៤ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ១៤ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬ

៥៥៥៥

បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ឬឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ នៃកាមាវចរទេវតាជាសហេតុកៈ ជាញាណសម្បយុត្ត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ១៤ នៃទេវតាទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ១៣ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ឥន្ទ្រិយ ១៣ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ឬឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ នៃកាមាវចរទេវតា ជាសហេតុកៈ ជាញាណវិប្បយុត្ត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ១៣ នៃទេវតាទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ១៣ ដទៃទៀតនៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ១៣ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ឬឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ នៃមនុស្សដែលកើតក្នុងបឋមកប្ប ជាសហេតុកៈ ជាញាណសម្បយុត្ត តែងកើតប្រាកដក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ១៣ នៃមនុស្សទាំងនុ៎ះ កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ១២ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ

ក្នុងកាមធាតុ ។ ឥន្ទ្រិយ ១២ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ឬឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ នៃមនុស្សដែលកើតក្នុងបឋមកប្បជាសហេតុកៈ ជាញាណវិប្បយុត្ត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ១២ នៃមនុស្សទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ១០ នៃសត្វណា កើតប្រាកដ ក្នុងខណៈបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ១០ គឺកាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ឬឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ នៃសត្វដែលដេកក្នុងគភ៌ជាសហេតុកៈ ជាញាណសម្បយុត្ត តែងកើតប្រាកដក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ១០ នៃសត្វទាំងនុ៎ះ កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ៩ នៃសត្វណា កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ៩ គឺកាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ឬឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ នៃសត្វដែលដេកក្នុងគភ៌ ជាសហេតុកៈ ជាញាណវិប្បយុត្ត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ៩ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ៩ ដទៃទៀតនៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ៩ គឺចក្ខុន្ទ្រិយ

១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលមានអាយតនៈគ្រប់គ្រាន់ តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ៩ នៃសត្វទាំងនុ៎ះ កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ៨ នៃសត្វណា កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ៨ គឺសោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលខ្វាក់អំពីកំណើត តែងកើតប្រាកដក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ៨ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ៨ ដទៃទៀតនៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិក្នុងកាមធាតុ ។ ឥន្ទ្រិយ ៨ គឺចក្ខុន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលថ្លង់អំពីកំណើត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ៨ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ៧ នៃសត្វណា កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ៧ គឺឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១

កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ នៃប្រេតជាឱបបាតិកៈ នៃអសុរជាឱបបាតិកៈ នៃតិរច្ឆានជាឱបបាតិកៈ នៃសត្វនរកជាសត្វដែលខ្វាក់ និងថ្លង់អំពីកំណើត តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ៧ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ៥ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ៥ គឺកាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ នៃសត្វដែលដេកក្នុងគភ៌ ជាអហេតុកៈ វៀរលែងតែពួកសត្វខ្ទើយចេញ តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ៥ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះឥន្ទ្រិយ ៤ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ឥន្ទ្រិយ ៤ គឺកាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ នៃពួកសត្វខ្ទើយ ដែលដេកក្នុងគភ៌ ជាអហេតុកៈ តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះឥន្ទ្រិយ ៤ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះហេតុ ៣ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ហេតុ ៣ គឺអលោភៈជាវិបាកហេតុ ១ អទោសៈជាវិបាកហេតុ ១ អមោហៈជាវិបាកហេតុ ១ នៃកាមាវចរទេវតា នៃមនុស្សដែលកើតក្នុងបឋមកប្ប នៃសត្វជាសហេតុកៈ ជាញាណសម្បយុត្តដែលដេកក្នុងគភ៌ តែងកើតប្រាកដក្នុងខណៈនៃបដិសន្ធិ នេះហេតុ ៣ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ

ក្នុងកាមធាតុ ។ ចុះហេតុ ២ នៃសត្វណា កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ហេតុ ២ គឺអលោភៈជាវិបាកហេតុ ១ អទោសៈជាវិបាកហេតុ ១ នៃកាមាវចរទេវតា នៃមនុស្សដែលកើតក្នុងបឋមកប្ប នៃសត្វជាសហេតុកៈជាញាណវិប្បយុត្ត ដែលដេកក្នុងគភ៌ តែងកើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ នេះហេតុ ២ នៃសត្វទាំងនុ៎ះ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ អហេតុកៈនៃពួកសត្វដ៏សេស កើតប្រាកដ ។ ចុះអាហារ ៤ នៃសត្វទាំងពួង កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ តើដូចម្ដេច ។ កពឡិង្ការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ នេះអាហារ ៤ នៃសត្វទាំងពួង កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ ចុះផស្សៈ ១ នៃសត្វទាំងពួង កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ តើដូចម្ដេច ។ មនោវិញ្ញាណធាតុសម្ផស្ស នេះផស្សៈ ១ នៃសត្វទាំងពួង កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ ។ វេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ នៃសត្វទាំងពួង កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងកាមធាតុ តើដូចម្ដេច ។ មនោវិញ្ញាណធាតុ នេះចិត្ត ១ នៃសត្វទាំងពួង កើតប្រាកដក្នុងខណៈនៃបដិសន្ធិក្នុងកាមធាតុ ។

[ ៣៣១ ] ខន្ធប៉ុន្មាន កើតប្រាកដ ។បេ។ ចិត្តប៉ុន្មាន កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ វៀរលែងតែពួកទេវតាជាអសញ្ញសត្វចេញ ខន្ធ ៥ កើតប្រាកដ អាយតនៈ ៥ កើតប្រាកដ ធាតុ ៥ កើតប្រាកដ សច្ចៈ ១ កើតប្រាកដ ឥន្ទ្រិយ ១០ កើតប្រាកដ ហេតុ ៣ កើតប្រាកដ អាហារ

៣ កើតប្រាកដ ផស្សៈ ១ កើតប្រាកដ វេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។

[ ៣៣២ ] ចុះខន្ធ ៥ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្តេច ។ រូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ នេះខន្ធ ៥ កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ ចុះអាយតនៈ ៥ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្តេច ។ ចក្ខាយតនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ នេះអាយតនៈ ៥ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ ចុះធាតុ ៥ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្តេច ។ ចក្ខុធាតុ ១ រូបធាតុ ១ សោតធាតុ ១ មនោវិញ្ញាណធាតុ ១ ធម្មធាតុ ១ នេះធាតុ ៥ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ ចុះសច្ចៈ ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្តេច ។ ទុក្ខសច្ច នេះសច្ចៈ ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ ចុះឥន្ទ្រិយ ១០ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្តេច ។ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ មនិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ឬឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ នេះឥន្ទ្រិយ ១០ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ ចុះហេតុ ៣ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្តេច ។ អលោភៈជាវិបាកហេតុ ១ អទោសៈជាវិបាកហេតុ ១

មោហៈជាវិបាកហេតុ ១ នេះហេតុ ៣ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ ចុះអាហារ ៣ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្ដេច ។ ផស្សអាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ នេះអាហារ ៣ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ ចុះផស្សៈ ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្ដេច ។ មនោ-វិញ្ញាណធាតុសម្ផស្ស នេះផស្សៈ ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ ។ ចុះវេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងរូបធាតុ តើដូចម្ដេច ។ មនោវិញ្ញាណធាតុ នេះចិត្ត ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិក្នុងរូបធាតុ ។

[ ៣៣៣ ] ចុះខន្ធប៉ុន្មាន ។បេ។ ចិត្តប៉ុន្មាននៃទេវតាជាអសញ្ញសត្វ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ។ ទេវតាជាអសញ្ញសត្វមានខន្ធ ១ គឺរូបក្ខន្ធ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ។ មានអាយតនៈ ២ គឺរូបាយតនៈ ១ ធម្មាយតនៈ ១ កើតប្រាកដ ។ មានធាតុ ២ គឺរូបធាតុ ១ ធម្មធាតុ ១ កើតប្រាកដ ។ មានសច្ចៈ ១ គឺទុក្ខសច្ច ១ កើតប្រាកដ ។ មានឥន្ទ្រិយ ១ គឺរូបជីវិតិន្ទ្រិយ កើតប្រាកដ ( ក្នុងខណៈនៃបដិសន្ធិ ) ។ ពួកទេវតាជាអសញ្ញសត្វ មិនមានហេតុ មិនមានអាហារ មិនមានផស្សៈ មិនមានវេទនា មិនមានសញ្ញា មិនមានចេតនា មិនមានចិត្ត កើតប្រាកដ ( ក្នុងខណៈនៃបដិសន្ធិ ) ។

[ ៣៣៤ ] ចុះខន្ធប៉ុន្មាន ។បេ។ ចិត្តប៉ុន្មាន កើតប្រាកដ ក្នុងខណៈនៃ

បដិសន្ធិ ក្នុងអរូបធាតុ ។ ខន្ធ ៤ កើតប្រាកដ អាយតនៈ ២ កើតប្រាកដ ធាតុ ២ កើតប្រាកដ សច្ចៈ ១ កើតប្រាកដ ឥន្ទ្រិយ ៨ កើតប្រាកដ ហេតុ ៣ កើតប្រាកដ អាហារ ៣ កើតប្រាកដ ផស្សៈ ១ កើតប្រាកដ វេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។

[ ៣៣៥ ] ចុះខន្ធ ៤ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ តើដូចម្ដេច ។ គឺវេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ នេះខន្ធ ៤ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។ ចុះអាយតនៈ ២ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ តើដូចម្ដេច ។ គឺមនាយតនៈ ១ ធម្មាយតនៈ ១ នេះអាយតនៈ ២ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។ ចុះធាតុ ២ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ តើដូចម្ដេច ។ គឺមនោវិញ្ញាណធាតុ ១ ធម្មធាតុ ១ នេះធាតុ ២ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។ ចុះសច្ចៈ ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ តើដូចម្ដេច ។ គឺទុក្ខសច្ច នេះសច្ចៈ ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។ ចុះឥន្ទ្រិយ ៨ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ តើដូចម្ដេច ។ គឺមនិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ នេះឥន្ទ្រិយ ៨ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។ ចុះហេតុ ៣ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ

ក្នុងអរូបធាតុ តើដូចម្តេច ។ គឺអលោភៈជាវិបាកហេតុ ១ អទោសៈជាវិបាកហេតុ ១ អមោហៈជាវិបាកហេតុ ១ នេះហេតុ ៣ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។ ចុះអាហារ ៣ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ តើដូចម្តេច ។ គឺផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ នេះអាហារ ៣ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។ ចុះផស្សៈ ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ តើដូចម្តេច ។ គឺមនោវិញ្ញាណធាតុសម្ផស្ស នេះផស្សៈ ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។ ចុះវេទនា ១ សញ្ញា ១ ចេតនា ១ ចិត្ត ១ កើតប្រាកដ ក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ តើដូចម្តេច ។ គឺមនោវិញ្ញាណធាតុ នេះចិត្ត ១ កើតប្រាកដក្នុងខណៈនៃបដិសន្ធិ ក្នុងអរូបធាតុ ។

[ ៣៣៦ ] ពួកធម៌ជាកាមាវចរ ពួកធម៌មិនមែនជាកាមាវចរ ពួកធម៌ជារូបាវចរ ពួកធម៌មិនមែនជារូបាវចរ ពួកធម៌ជាអរូបាវចរ ពួកធម៌មិនមែនជាអរូបាវចរ ពួកធម៌ជាបរិយាបន្ន ពួកធម៌ជាអបរិយាបន្ន ។

[ ៣៣៧ ] ពួកធម៌ជាកាមាវចរ តើដូចម្តេច ។ ខាងក្រោម រាប់តាំងអំពីអវីចិនរកជាទីបំផុត ខាងលើរាប់តាំងអំពីបរនិម្មិតវសវត្តីទេវតាជាទីបំផុត ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា ក្នុងចន្លោះនុ៎ះ ត្រាច់ចុះក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះពួកធម៌ជាកាមាវចរ ។

ពួកធម៌មិនមែនជាកាមាវចរ តើដូចម្តេច ។ ( ពួកធម៌ ) ជារូបាវចរ ជាអរូបាវចរ ជាអបរិយាបន្ន នេះពួកធម៌ មិនមែនជាកាមាវចរ ។ ពួកធម៌ជារូបាវចរ តើដូចម្តេច ។ ខាងក្រោម រាប់តាំងពីព្រហ្មលោកជាទីបំផុត ខាងលើរាប់តាំងពីអកនិដ្ឋទេវតាជាទីបំផុត ពួកធម៌ប្រព្រឹត្តទៅក្នុងចិត្ត និងចេតសិកណា របស់បុគ្គលដែលចូលឈានក្តី ដែលទៅកើតហើយក្តី ដែលនៅជាសុខ ក្នុងបច្ចុប្បន្នក្តី ក្នុងចន្លោះនុ៎ះ ត្រាច់ចុះក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះពួកធម៌ជារូបាវចរ ។ ចុះពួកធម៌ មិនមែនជារូបាវចរ តើដូចម្តេច ។ ( ពួកធម៌ ) ជាកាមាវចរ ជាអរូបាវចរ ជាអបរិយាបន្ន នេះពួកធម៌មិនមែនជារូបាវចរ ។ ចុះពួកធម៌ជាអរូបាវចរ តើដូចម្តេច ។ ខាងក្រោម រាប់តាំងអំពីអាកាសានញ្ចាយតនទេវតា ជាទីបំផុត ខាងលើ រាប់តាំងអំពីនេវសញ្ញានាសញ្ញាយតនទេវតា ជាទីបំផុត ពួកធម៌ប្រព្រឹត្តទៅក្នុងចិត្ត និងចេតសិកណា របស់បុគ្គលដែលចូលឈានក្តី ដែលទៅកើតហើយក្តី ដែលនៅជាសុខក្នុងបច្ចុប្បន្នក្តី ក្នុងចន្លោះនុ៎ះ ត្រាច់ចុះក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះពួកធម៌ជាអរូបាវចរ ។ ចុះពួកធម៌មិនមែនជាអរូបាវចរ តើដូចម្តេច ។ ( ពួកធម៌ ) ជាកាមាវចរ ជារូបាវចរ ជាអបរិយាបន្ន នេះពួកធម៌មិនមែនជាអរូបាវចរ ។ ចុះពួកធម៌ជាបរិយាបន្ន តើដូចម្តេច ។ ពួកធម៌ជាកុសល ជាអកុសល ជាអព្យាក្រឹត ប្រកបដោយអាសវៈ ជាកាមាវចរ ជារូបាវចរ ជាអរូបាវចរ និងរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាបរិយាបន្ន ។ ពួកធម៌ជាអបរិយាបន្ន តើដូច

ម្តេច ។ មគ្គផង ផលនៃមគ្គផង ជាតុមិនមានបច្ច័យតាក់តែងផង នេះពួក ធម៌ជាអបរិយាបន្ន ។

[ ៣៣៨ ] ទេវតា ៣ ពួក គឺសម្មតិទេវតា ១ ឧបបត្តិទេវតា ១ វិសុទ្ធិ-ទេវតា ១ ឈ្មោះថា ទេវតា ។ ពួកស្តេច ពួកព្រះរាជទេពី ពួករាជកុមារ ឈ្មោះថា សម្មតិទេវតា ។ ពួកទេវតារាប់តាំងអំពីទេវតាជាន់ចាតុម្មហារាជិកៈ ទៅទល់នឹងទេវតាជាន់លើនោះៗ ឈ្មោះថា ឧបបត្តិទេវតា ។ ពួកព្រះអរហន្ត ហៅថា វិសុទ្ធិទេវតា ។

[ ៣៣៩ ] ចុះបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម តើកើត ក្នុងទីណា ។ បុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ពួកខ្លះកើត ជាមួយនឹងខត្តិយមហាសាល ពួកខ្លះកើតជាមួយនឹងពួកព្រាហ្មណមហាសាល ពួកខ្លះកើតជាមួយនឹងពួកគហបតិមហាសាល ពួកខ្លះកើតជាមួយនឹងពួកទេវតា ជាន់ចាតុម្មហារាជិកៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ពួកខ្លះ កើតជាមួយនឹងពួកទេវតាជាន់យាមៈ ពួកខ្លះកើតជាមួយនឹងពួកទេវតា ជាន់ តុសិត ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់និម្មានរតី ពួកខ្លះកើតជាមួយនឹង ពួកទេវតាជាន់បរនិម្មិតវសវត្តី ។

[ ៣៤០ ] ចុះប្រមាណនៃអាយុរបស់មនុស្សតើប៉ុន្មាន ។ កំណត់ ១០០ ឆ្នាំ ឬតិចជាង ឬក៏ច្រើនជាង ១០០ ឆ្នាំ ។ ប្រមាណនៃអាយុរបស់ទេវតា ជាន់ចាតុម្មហារាជិកៈ តើប៉ុន្មាន ។ ៥០ ឆ្នាំណា ជារបស់នៃមនុស្ស ៥០

ឆ្នាំនុ៎ះ ជាមួយយប់ មួយថ្ងៃនៃទេវតាជាន់ចាតុម្មហារាជិកៈ ៣០ រាត្រីដោយរាត្រីនោះជា ១ ខែ ១២ ខែដោយខែនោះជា ១ ឆ្នាំ ៥០០ ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណនៃអាយុរបស់ទេវតាជាន់ចាតុម្មហារាជិកៈ ។ ( ចុះបើ ) រាប់ជាឆ្នាំរបស់មនុស្សវិញ តើត្រូវជាប៉ុន្មានឆ្នាំ ។ ត្រូវជា ៩ លានឆ្នាំ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់តាវត្តិង្ស តើប៉ុន្មាន ។ ១០០ ឆ្នាំណា ជារបស់នៃមនុស្ស ១០០ ឆ្នាំនុ៎ះ ជា ១ យប់ ១ ថ្ងៃ របស់ទេវតាជាន់តាវត្តិង្ស ៣០ រាត្រីដោយរាត្រីនោះជា ១ ខែ ១២ ខែដោយខែនោះជា ១ ឆ្នាំ ១ ពាន់ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណនៃអាយុ របស់ទេវតាជាន់តាវត្តិង្ស ។ ( ចុះបើ ) រាប់ជាឆ្នាំមនុស្ស តើត្រូវជាប៉ុន្មានឆ្នាំ ។ ត្រូវជា ៣ កោដិ ៦ លានឆ្នាំ ។ ចុះប្រមាណនៃអាយុរបស់ទេវតា ជាន់យាមៈ តើប៉ុន្មាន ។ ២០០ ឆ្នាំណា ជារបស់នៃមនុស្ស ២០០ ឆ្នាំនុ៎ះ ជា ១ យប់ ១ ថ្ងៃនៃទេវតាជាន់យាមៈ ៣០ រាត្រីដោយរាត្រីនោះ ជា ១ ខែ ១២ ខែដោយខែនោះជា ១ ឆ្នាំ ២ ពាន់ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណនៃអាយុរបស់ទេវតាជាន់យាមៈ ។ ( ចុះបើ ) រាប់ជាឆ្នាំមនុស្សវិញ តើត្រូវជាប៉ុន្មានឆ្នាំ ។ ត្រូវជា ១៤ កោដិ ៤ លានឆ្នាំ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់តុសិត តើប៉ុន្មាន ។ ៤០០ ឆ្នាំណា ជារបស់នៃមនុស្ស ៤០០ ឆ្នាំនុ៎ះជា ១ យប់ ១ ថ្ងៃ នៃទេវតាជាន់តុសិត ៣០ រាត្រីដោយរាត្រីនោះជា ១ ខែ ១២ ខែដោយខែនោះ ជាប្រមាណនៃអាយុ របស់ទេវតាជាន់តុសិត ។ ( ចុះបើ ) រាប់ជាឆ្នាំរបស់មនុស្សវិញ តើត្រូវជាប៉ុន្មានឆ្នាំ ។

ត្រូវជា ៥៧ កោដិ ៦ លានឆ្នាំ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់និម្មានរតី តើប៉ុន្មាន ។ ៨ រយឆ្នាំណា ជារបស់នៃមនុស្ស ៨ រយឆ្នាំនុ៎ះ ជាមួយយប់មួយថ្ងៃនៃទេវតាជាន់និម្មានរតី ៣០ រាត្រីដោយរាត្រីនោះជាមួយខែ ១២ ខែដោយខែនោះជាមួយឆ្នាំ ៨ ពាន់ឆ្នាំទិព្វដោយឆ្នាំនោះជាប្រមាណនៃអាយុរបស់ទេវតាជាន់និម្មានរតី ។ ( ចុះបើ ) រាប់ជាឆ្នាំមនុស្សវិញ តើត្រូវជាប៉ុន្មានឆ្នាំ ។ ត្រូវជា ២៣០ កោដិ ៤ លានឆ្នាំ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់បរនិម្មិតវសវត្តី តើប៉ុន្មាន ។ ១៦ រយឆ្នាំ ( ១៦០០ ) ណា ជារបស់នៃមនុស្ស ១៦ រយឆ្នាំនុ៎ះ ជា ១ យប់ ១ ថ្ងៃនៃទេវតាជាន់បរនិម្មិតវសវត្តី ៣០ រាត្រីដោយរាត្រីនោះ ជា ១ ខែ ១២ ខែដោយខែនោះ ជា ១ ឆ្នាំ ១៦ ពាន់ឆ្នាំទិព្វ ( ១៦០០០ ឆ្នាំ ) ដោយឆ្នាំនោះ ជាប្រមាណនៃអាយុរបស់ទេវតាជាន់បរនិម្មិតវសវត្តី ។ ( ចុះបើ ) រាប់ជាឆ្នាំមនុស្សវិញ តើត្រូវជាប៉ុន្មានឆ្នាំ ។ ត្រូវជា ៩ រយកោដិផង ២១ កោដិផង ៦ លានឆ្នាំផង ។

> ពួកទេវតា ដែលស្ថិតនៅក្នុងកាមាវចរសួគ៌ទាំង ៦ ជាន់នោះ
> ជាអ្នកសម្រេចនូវកាមទាំងពួង ។ អាយុរបស់ពួកទេវតាទាំង
> អស់ដែលបណ្ឌិតរាប់ដោយរួបរួម តើប៉ុន្មានឆ្នាំ ១២ រយកោដិ
> ផង ២៨ កោដិផង ៥ សែនឆ្នាំផង ជាអាយុរបស់ទេវតា
> ទាំងនោះ ដែលបណ្ឌិតប្រកាសហើយដោយទីបំផុតនៃឆ្នាំ ។

[ ៣៤១ ] ចុះបុគ្គលចម្រើនបឋមជ្ឈានយ៉ាងឱនថយ តើកើតក្នុងទីណា ។

បុគ្គលចម្រើនបឋមជ្ឈានយ៉ាងឱនថយ កើតជាមួយនឹងពួកទេវតាជាន់ព្រហ្ម-បារិសជ្ជៈ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នោះ តើប៉ុន្មាន ។ កប្ប ១ ចែកជា ៣ ភាគ ឬ ៤ ភាគ ( យក ១ ភាគជាអាយុរបស់ទេវតាជាន់នោះ ) ចុះបុគ្គលចម្រើនបឋមជ្ឈានយ៉ាងកណ្តាល តើកើតក្នុងទីណា ។ បុគ្គលចម្រើនបឋមជ្ឈានយ៉ាងកណ្តាល កើតជាមួយនឹងពួកទេវតាជាន់ព្រហ្ម-បុរោហិត ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នោះ តើប៉ុន្មាន ។ ពាក់កណ្តាលកប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះបុគ្គលចម្រើនបឋម-ជ្ឈាន ជាន់ខ្ពស់ តើកើតក្នុងទីណា ។ បុគ្គលចម្រើនបឋមជ្ឈានជាន់ខ្ពស់ កើតជាមួយនឹងពួកទេវតាជាន់មហាព្រហ្ម ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នោះ តើប៉ុន្មាន ។ ១ កប្ប ( ជាអាយុនៃទេវតាជាន់នោះ ) ។ ចុះបុគ្គលចម្រើនទុតិយជ្ឈានយ៉ាងឱនថយ តើកើតក្នុងទីណា ។ បុគ្គលចម្រើនទុតិយជ្ឈាន យ៉ាងឱនថយ កើតជាមួយនឹងពួកទេវតាជាន់បរិត្តាភៈ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នោះ តើប៉ុន្មាន ។ ពីរកប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះបុគ្គលចម្រើនទុតិយជ្ឈានយ៉ាងកណ្តាល តើកើតក្នុងទីណា ។ បុគ្គលចម្រើនទុតិយជ្ឈានយ៉ាងកណ្តាល កើតជាមួយនឹងពួកទេវតាជាន់អប្បមាណាភៈ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នោះ តើប៉ុន្មាន ។ ៤ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះបុគ្គលចម្រើនទុតិយជ្ឈានជាន់ខ្ពស់ តើកើតក្នុងទីណា ។ បុគ្គលចម្រើនទុតិយជ្ឈានជាន់ខ្ពស់ កើតជាមួយនឹងពួកទេវតាជាន់អាភស្សរៈ ។ ចុះប្រមាណនៃអាយុ

របស់ទេវតាជាន់នោះ តើប៉ុន្មាន ។ ៨ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះបុគ្គលចម្រើនតតិយជ្ឈានយ៉ាងឧនថយ តើកើតក្នុងទីណា ។ បុគ្គលចម្រើនតតិយជ្ឈានយ៉ាងឧនថយ កើតជាមួយនឹងពួកទេវតាជាន់បរិត្ត-សុភៈ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នោះ តើប៉ុន្មាន ។ ១៦ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះបុគ្គលចម្រើនតតិយជ្ឈាន យ៉ាងកណ្តាល តើកើតក្នុងទីណា ។ បុគ្គលចម្រើនតតិយជ្ឈាន យ៉ាងកណ្តាល កើតជាមួយនឹងពួកទេវតាជាន់អប្បមាណសុភៈ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នោះ តើប៉ុន្មាន ។ ៣២ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះបុគ្គលចម្រើនតតិយជ្ឈានជាន់ខ្ពស់ តើកើតក្នុងទីណា ។ បុគ្គលចម្រើនតតិយជ្ឈានជាន់ខ្ពស់ កើតជាមួយនឹងពួកទេវតាជាន់សុភកិណ្ហៈ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នោះ តើប៉ុន្មាន ។ ៦៤ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ បុគ្គលចម្រើនចតុត្ថជ្ឈាន ព្រោះមានអារម្មណ៍ផ្សេងគ្នា ព្រោះមានមនសិការផ្សេងគ្នា ព្រោះមានឆន្ទៈផ្សេងគ្នា ព្រោះមានបណិធិ ( ការតម្កល់ ) ផ្សេងគ្នា ព្រោះមានអធិមោក្ខ ( ការចុះចិត្ត ) ផ្សេងគ្នា ព្រោះមានអភិនីហារ ( ការកសាង ) ផ្សេងគ្នា ព្រោះមានបញ្ញាផ្សេងគ្នា ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់អសញ្ញសត្វ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់វេហប្ផលៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់អវិហៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់អតប្បៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់សុទស្សៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់សុទស្សី ពួកខ្លះ កើតជាមួយនឹងពួកទេវតា

ជាន់អកនិដ្ឋៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់អាកាសានញ្ចាយតនៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់វិញ្ញាណញ្ចាយតនៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់អាកិញ្ចញ្ញាយតនៈ ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់នេវ-សញ្ញានាសញ្ញាយតនៈ ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់អសញ្ញសត្តក្ដី ជាន់វេហប្ផលៈក្ដី តើប៉ុន្មាន ។ ៥០០ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់អវិហៈ តើប៉ុន្មាន ។ ១ ពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់អតប្បៈ តើប៉ុន្មាន ។ ២០០០ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ចុះប្រមាណនៃអាយុរបស់ទេវតាជាន់សុទស្សៈ តើប៉ុន្មាន ។ ៤០០០ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់សុទស្សីតើប៉ុន្មាន ។ ៨០០០ កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់អកនិដ្ឋៈ តើប៉ុន្មាន ។ ១៦ ពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់អាកាសានញ្ចាយតនៈ តើប៉ុន្មាន ។ ២០ ពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់វិញ្ញាណញ្ចាយតនៈ តើប៉ុន្មាន ។ ៤០ ពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់អាកិញ្ចញ្ញាយតនៈ តើប៉ុន្មាន ។ ៦០ ពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។ ចុះប្រមាណនៃអាយុរបស់ទេវតាជាន់នេវសញ្ញានាសញ្ញាយតនៈ តើប៉ុន្មាន ។ ៨៤ ពាន់កប្ប ( ជាអាយុរបស់

ទេវតាជាន់នោះ ) ។

ពួកសត្វដែលគេជះ គឺបុណ្យស្រួយហើយ រមែងទៅកាន់កាម-គតិ និងរូបគតិ ឬឲ្យដល់កវគ្គព្រហ្ម ក៏គង់ត្រឡប់មកកាន់ទុគ្គតិវិញ ពួកសត្វដែលមានអាយុវែងដល់ម៉្លោះ ក៏គង់ច្យុតដោយអស់អាយុ ព្រះមហេសីត្រាស់ថា គ្មានកពណានីមួយទៀងទេ ព្រោះហេតុនោះ អ្នកប្រាជ្ញ មានប្រាជ្ញារក្សាខ្លួន មានប្រាជ្ញាល្អិត អ្នកគិតនូវអត្ថ តែងចម្រើននូវមគ្គដ៏ប្រសើរ ដើម្បីដោះខ្លួនចាកជរា និងមរណៈ លុះចម្រើននូវមគ្គដ៏ស្អាត សម្រាប់ធ្វើដំណើរទៅកាន់អមតនិព្វានហើយ រមែងជាអ្នកមិនមានអាសវៈ កំណាត់នូវអាសវៈទាំងពួង ហើយបរិនិព្វាន ។

[ ៣៨២ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មានគួរគេដឹងច្បាស់ ខន្ធប៉ុន្មានគួរកំណត់ដឹង ខន្ធប៉ុន្មានគួរលះបង់ ខន្ធប៉ុន្មានគួរចម្រើន ខន្ធប៉ុន្មានគួរធ្វើឲ្យជាក់ច្បាស់ ខន្ធប៉ុន្មានមិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មានគួរដឹងច្បាស់ ចិត្តប៉ុន្មានគួរកំណត់ដឹង ចិត្តប៉ុន្មានគួរលះបង់ ចិត្តប៉ុន្មានគួរចម្រើន ចិត្តប៉ុន្មានគួរធ្វើឲ្យជាក់ច្បាស់ ចិត្តប៉ុន្មានមិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ ។ រូបក្ខន្ធគេគួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ ខន្ធ ៤ គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ក៏មាន គួរចម្រើន

ក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ។ អាយតនៈ ១០ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ អាយតនៈ ២ គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ក៏មាន គួរចម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ។ ធាតុ ១៦ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ ធាតុ ២ គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ក៏មាន គួរចម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ។ សមុទយសច្ច គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ តែមិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ មគ្គសច្ច គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ គួរចម្រើន តែមិនគួរធ្វើឲ្យជាក់ច្បាស់ទេ និរោធសច្ច គួរដឹងច្បាស់ គួរកំណត់ តែមិនគួរលះបង់ មិនគួរចម្រើន គួរធ្វើឲ្យជាក់ច្បាស់ ទុក្ខសច្ច គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរលះបង់ក៏មាន ។ ឥន្ទ្រិយ ៩ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ ទោមនស្សិន្ទ្រិយ គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ គួរចម្រើន តែមិនគួរធ្វើឲ្យជាក់ច្បាស់ទេ អញ្ញិន្ទ្រិយ គួរដឹងច្បាស់ គួរកំណត់ដឹង មិនគួរលះបង់ គួរ

បម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន អញ្ញាតាវិន្ទ្រិយ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរបម្រើន គួរធ្វើឲ្យជាក់ច្បាស់ ឥន្ទ្រិយ ៣ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ គួរបម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ឥន្ទ្រិយ ៦ គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ក៏មាន គួរបម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរលះបង់ មិនគួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ។ អកុសលហេតុ ៣ គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ តែមិនគួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ កុសលហេតុ ៣ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ គួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរបម្រើនក៏មាន អព្យាតកហេតុ ៣ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរបម្រើន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ។ កពឡិង្ការាហារ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ អាហារ ៣ គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ក៏មាន គួរបម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរលះបង់ មិនគួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ។ ផស្សៈ ៦ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ មនោវិញ្ញាណធាតុសម្ផស្ស គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ក៏មាន គួរបម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរលះបង់ មិនគួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ។ វេទនា ៦ សញ្ញា ៦ ចេតនា

៦ ចិត្ត ៦ គួរដឹងច្បាស់ គួរកំណត់ដឹង តែមិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ មនោវិញ្ញាណធាតុ គួរដឹងច្បាស់ គួរកំណត់ដឹង គួរលះបង់ក៏មាន គួរចម្រើនក៏មាន គួរធ្វើឲ្យជាក់ច្បាស់ក៏មាន មិនគួរលះបង់ មិនគួរចម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ក៏មាន ។

[ ៣៤៣ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មានមានអារម្មណ៍ ខន្ធប៉ុន្មានមិនមានអារម្មណ៍ ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មានមានអារម្មណ៍ ចិត្តប៉ុន្មានមិនមានអារម្មណ៍ ។ រូបក្ខន្ធ មិនមានអារម្មណ៍ ខន្ធ ៤ មានអារម្មណ៍ ។ អាយតនៈ ១០ មិនមានអារម្មណ៍ មនាយតនៈ មានអារម្មណ៍ ធម្មាយតនៈ មានអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ ធាតុ ១០ មិនមានអារម្មណ៍ ធាតុ ៧ មានអារម្មណ៍ ធម្មធាតុ មានអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ សច្ចៈ ២ មានអារម្មណ៍ និរោធសច្ច មិនមានអារម្មណ៍ ទុក្ខសច្ច មានអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ ឥន្ទ្រិយ ៧ មិនមានអារម្មណ៍ ឥន្ទ្រិយ ១៤ មានអារម្មណ៍ ជីវិតិន្ទ្រិយ មានអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ ហេតុ ៩ មានអារម្មណ៍ ។ កពឡិង្ការាហារ មិនមានអារម្មណ៍ អាហារ ៣ មានអារម្មណ៍ ។ ផស្សៈ ៧ វេទនា ៧ សញ្ញា ៧ ចេតនា ៧ ចិត្ត ៧ មានអារម្មណ៍ ។

[ ៣៤៤ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មានប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ទាំងជាអារម្មណ៍ ខន្ធប៉ុន្មានមិនមានអារម្មណ៍ តែជាអារម្មណ៍ ខន្ធប៉ុន្មានមិន

មានអារម្មណ៍ ។បេ។ បណ្ដាចិត្តទាំង ៧ ចិត្តប៉ុន្មាន ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ទាំងជាអារម្មណ៍ ចិត្តប៉ុន្មានមិនមានអារម្មណ៍ តែជាអារម្មណ៍ ចិត្តប៉ុន្មានមិនមានអារម្មណ៍ ។ រូបក្ខន្ធ មិនមានអារម្មណ៍ ខន្ធ ៤ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន ។ អាយតនៈ ១០ មិនមានអារម្មណ៍ មនាយតនៈប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន ធម្មាយតនៈ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ ធាតុ ១០ មិនមានអារម្មណ៍ ធាតុ ៦ មិនមានអារម្មណ៍ តែជាអារម្មណ៍ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន ធម្មធាតុ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ និរោធសច្ច មិនមានអារម្មណ៍ មគ្គសច្ច មិនមានអារម្មណ៍ តែជាអារម្មណ៍ សមុទយសច្ច ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន ទុក្ខសច្ច ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ ឥន្ទ្រិយ ៧ មិនមានអារម្មណ៍ ឥន្ទ្រិយ ៥ មិនមានអារម្មណ៍តែជាអារម្មណ៍ ឥន្ទ្រិយ ៩ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន

ជីវិតិន្ទ្រិយ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ ហេតុ ៩ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន ។ កពឡិង្ការាហារ មិនមានអារម្មណ៍ អាហារ ៣ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍តែជាអារម្មណ៍ក៏មាន ។ ផស្សៈ ៦ មិនមានអារម្មណ៍ តែជាអារម្មណ៍ មនោវិញ្ញាណធាតុសម្ផស្ស ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន វេទនា ៦ សញ្ញា ៦ ចេតនា ៦ ចិត្ត ៦ មិនមានអារម្មណ៍ តែជាអារម្មណ៍ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទាំងជាអារម្មណ៍ក៏មាន មិនមានអារម្មណ៍ តែជាអារម្មណ៍ក៏មាន ។

[ ៣៤៥ ] បណ្ដាខន្ធ ៥ ខន្ធប៉ុន្មានដែលបុគ្គលឃើញ ខន្ធប៉ុន្មានដែលបុគ្គលឮ ខន្ធប៉ុន្មានដែលបុគ្គលប៉ះពាល់ ខន្ធប៉ុន្មាន ដែលបុគ្គលដឹងច្បាស់ ខន្ធប៉ុន្មានដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ មិនដឹងច្បាស់ ។បេ។ បណ្ដាចិត្តទាំង ៧ ចិត្តប៉ុន្មានដែលបុគ្គលឃើញ ចិត្តប៉ុន្មានដែលបុគ្គលឮ ចិត្តប៉ុន្មានដែលបុគ្គលពាល់ត្រូវ ចិត្តប៉ុន្មាន ដែលបុគ្គលដឹងច្បាស់ ចិត្តប៉ុន្មានដែលបុគ្គលមិនឃើញ មិនពាល់ត្រូវ មិនដឹងច្បាស់ ។ រូបក្ខន្ធដែលបុគ្គលឃើញក៏មាន ឮក៏មាន ពាល់ត្រូវក៏មាន មិនឃើញ មិនឮ មិនពាល់ត្រូវ

តែដឹងច្បាស់ក៏មាន ខន្ធ ៤ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ។ រូបាយតនៈ ដែលបុគ្គលឃើញ តែមិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ សទ្ទាយតនៈ ដែលបុគ្គលមិនឃើញ តែឮ មិនពាល់ត្រូវ តែដឹងច្បាស់ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ដែលបុគ្គលមិនឃើញ មិនឮ តែពាល់ត្រូវ ដឹងច្បាស់ អាយតនៈ ៧ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ។ រូបធាតុ ដែលបុគ្គលឃើញ តែមិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ សទ្ទធាតុ ដែលបុគ្គលមិនឃើញ តែឮ មិនពាល់ត្រូវ តែដឹងច្បាស់ គន្ធធាតុ រសធាតុ ផោដ្ឋព្វធាតុ ដែលបុគ្គលមិនឃើញ មិនឮ តែពាល់ត្រូវ ដឹងច្បាស់ ធាតុ ១៣ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ។ សច្ចៈ ៣ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ទុក្ខសច្ច ដែលបុគ្គលឃើញក៏មាន ឮក៏មាន ពាល់ត្រូវក៏មាន មិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ក៏មាន ។ ឥន្ទ្រិយ ២២ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ។ ហេតុ ៩ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ។ អាហារ ៤ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ។ ផស្សៈ ៧ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ។ វេទនា ៧ សញ្ញា ៧ ចេតនា ៧ ចិត្ត ៧ ដែលបុគ្គលមិនឃើញ មិនឮ មិនពាល់ត្រូវ តែដឹងច្បាស់ ។

[ ៣៨៦ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មានជាកុសល ខន្ធប៉ុន្មានជាអកុសល ខន្ធប៉ុន្មានជាអព្យាក្រឹត ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មានជាកុសល ចិត្តប៉ុន្មានជាអកុសល ចិត្តប៉ុន្មានជាអព្យាក្រឹត ។ រូបក្ខន្ធ ជាអព្យាក្រឹត ខន្ធ ៤ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន អាយតនៈ ១០ ជាអព្យាក្រឹត អាយតនៈ ២ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ធាតុ ១៦ ជាអព្យាក្រឹត ធាតុ ២ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ សមុទយសច្ច ជាអកុសល មគ្គសច្ច ជាកុសល និរោធសច្ច ជាអព្យាក្រឹត ទុក្ខសច្ច ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ឥន្ទ្រិយ ១០ ជាអព្យាក្រឹត ទោមនស្សិន្ទ្រិយ ជាអកុសល អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ជាកុសល ឥន្ទ្រិយ ៤ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ឥន្ទ្រិយ ៦ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ អកុសលហេតុ ៣ ជាអកុសល កុសលហេតុ ៣ ជាកុសល អព្យាកតហេតុ ៣ ជាអព្យាក្រឹត ។ កពឡិង្ការាហារ ជាអព្យាក្រឹត អាហារ ៣ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ផស្សៈ ៦ ជាអព្យាក្រឹត មនោវិញ្ញាណធាតុសម្ផស្ស ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន វេទនា ៦ សញ្ញា ៦ ចេតនា ៦ ចិត្ត ៦ ជាអព្យាក្រឹត មនោវិញ្ញាណធាតុ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។

[ ៣៨៧ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មាន ប្រកបដោយសុខវេទនា ខន្ធ

ប៉ុន្មាន ប្រកបដោយទុក្ខវេទនា ខន្ធប៉ុន្មាន ប្រកបដោយអទុក្ខមសុខវេទនា ។បេ។ បណ្ដាចិត្តទាំង ៧ ចិត្តប៉ុន្មាន ប្រកបដោយសុខវេទនា ចិត្តប៉ុន្មាន ប្រកបដោយទុក្ខវេទនា ចិត្តប៉ុន្មាន ប្រកបដោយអទុក្ខមសុខវេទនា ។ ខន្ធ ២ មិនគួរពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងទេ ខន្ធ ៣ ប្រកបដោយសុខវេទនា ក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។ អាយតនៈ ១០ មិនគួរពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងឡើយ មនាយតនៈ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ធម្មាយតនៈ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មិនគួរពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងក៏មាន ។ ធាតុ ១០ មិនគួរពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងទេ ធាតុ ៥ ប្រកបដោយអទុក្ខមសុខវេទនា កាយវិញ្ញាណធាតុ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន មនោវិញ្ញាណធាតុ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ធម្មធាតុ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន

មិនគួរពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងក៏មាន ។ សច្ចៈ ២ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន និរោធសច្ច មិនគួរពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងទេ ទុក្ខសច្ច ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មិនគួរពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងក៏មាន ។ ឥន្ទ្រិយ ១២ មិនគួរពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងឡើយ ឥន្ទ្រិយ ៦ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ឥន្ទ្រិយ ៣ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ជីវិតិន្ទ្រិយ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មិនគួរពោលថា ប្រកបដោយសុខ-វេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយអទុក្ខមសុខវេទនាផងក៏មាន ។ ទោសៈ ជាអកុសលហេតុ ប្រកបដោយទុក្ខវេទនា ហេតុ ៧ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មោហៈ ជាអកុសលហេតុ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។ កពឡិង្ការាហារ មិនគួរពោល

ជាប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងទេ អាហារ ៣ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។ ផស្សៈ ៥ ប្រកបដោយអទុក្ខមសុខវេទនា កាយសម្ផស្ស ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន មនោវិញ្ញាណធាតុសម្ផស្ស ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខ-វេទនាក៏មាន ។ វេទនា ៧ មិនគួរពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងទេ ។ សញ្ញា ៥ ចេតនា ៥ ចិត្ត ៥ ប្រកបដោយអទុក្ខមសុខវេទនា កាយវិញ្ញាណ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន មនោវិញ្ញាណធាតុ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។

[ ៣៤៨ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មានជាវិបាក ខន្ធប៉ុន្មានមានវិបាកធម៌ជាប្រក្រតី ខន្ធប៉ុន្មានមិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មានជាវិបាក ចិត្តប៉ុន្មាន មានវិបាកធម៌ជាប្រក្រតី ចិត្តប៉ុន្មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ។ រូបក្ខន្ធ មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ខន្ធ ៤ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ អាយតនៈ ១០ មិនមែនជាវិបាក ទាំងមិនមែនមានវិបាក-

ធម៌ជាប្រក្រតី អាយតនៈ ២ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ ធាតុ ១០ មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ធាតុ ៥ ជាវិបាក មនោធាតុ ជាវិបាកក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ ជាប្រក្រតីក៏មាន ធាតុ ២ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ សច្ចៈ ២ មានវិបាកធម៌ជាប្រក្រតី និរោធសច្ច មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ទុក្ខសច្ច ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ ឥន្ទ្រិយ ៧ មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ឥន្ទ្រិយ ៣ ជាវិបាក ឥន្ទ្រិយ ២ មានវិបាកធម៌ជាប្រក្រតី អញ្ញិន្ទ្រិយ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន ឥន្ទ្រិយ ៩ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ ហេតុ ៦ មានវិបាកធម៌ជាប្រក្រតី អព្យាកតហេតុ ៣ ជាវិបាកក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ កពឡិង្ការាហារ មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី អាហារ ៣ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ ជាប្រក្រតីក៏មាន ។ ផស្សៈ ៥ ជាវិបាក មនោធាតុសម្ផស្ស ជាវិបាកក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន មនោវិញ្ញាណ-

ធាតុសម្ផស្ស ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ វេទនា ៥ សញ្ញា ៥ ចេតនា ៥ ចិត្ត ៥ ជាវិបាក មនោធាតុ ជាវិបាកក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន មនោវិញ្ញាណធាតុ ជាវិបាកក៏មាន មានវិបាក-ធម៌ជាប្រកតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។

[ ៣៤៩ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទាន ខន្ធប៉ុន្មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ខន្ធប៉ុន្មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទាន ចិត្តប៉ុន្មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ចិត្តប៉ុន្មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។ រូបក្ខន្ធ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន ខន្ធ ៤ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់

ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ អាយតនៈ ៥ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រ-យោជន៍ដល់ឧបាទាន សទ្ទាយតនៈ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន អាយតនៈ ៤ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន អាយតនៈ ២ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ ធាតុ ១០ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទាន សទ្ទធាតុ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ធាតុ ៥ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន ធាតុ ២ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក

ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ សមុទយសច្ច មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន សច្ចៈ ២ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ទុក្ខសច្ច មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន ។ ឥន្ទ្រិយ ៩ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទាន ទោមនស្សិន្ទ្រិយ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ឥន្ទ្រិយ ៣ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ ដល់ឧបាទាន ឥន្ទ្រិយ ៩ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ អកុសលហេតុ ៣ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន កុសលហេតុ

៣ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងជាប្រ-
យោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម
មិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន អព្យាកតហេតុ ៣
មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍
ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់
យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស
មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។
កពឡិង្ការាហារ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក
ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មាន
តណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន អាហារ ៣
មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍
ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់
យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស
មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។
ផស្សៈ ៥ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំង
ជាប្រយោជន៍ដល់ឧបាទាន មនោធាតុសម្ផស្ស មានកម្មប្រកបដោយកិលេស
មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្ម
ប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់
ឧបាទានក៏មាន មនោវិញ្ញាណធាតុសម្ផស្ស មានកម្មប្រកបដោយកិលេស

មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ វេទនា ៥ សញ្ញា ៥ ចេតនា ៥ ចិត្ត ៥ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទាន មនោធាតុ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មនោវិញ្ញាណធាតុ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។

[ ៣៥០ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មាន ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ខន្ធប៉ុន្មាន មិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធប៉ុន្មាន មិនមានវិតក្ក ទាំងមិនមានវិចារ ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មាន ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ចិត្តប៉ុន្មាន មិនមានវិតក្ក មានត្រឹមតែវិចារ ចិត្តប៉ុន្មាន មិនមានវិតក្ក ទាំងមិនមានវិចារ ។ រូបក្ខន្ធ មិនមានវិតក្ក ទាំងមិនមានវិចារ ខន្ធ ៣ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន

មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន សង្ខារក្ខន្ធ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន មិនគួរពោលថា ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារផង ថាមិនមានវិតក្ក មានត្រឹមតែវិចារផង ថាមិនមានវិតក្ក ទាំងមិនមានវិចារផងក៏មាន ។ អាយតនៈ ១០ មិនមានវិតក្ក ទាំងមិនមានវិចារ មនាយតនៈ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ធម្មាយតនៈ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន មិនគួរពោលថា ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារផង ថាមិនមានវិតក្ក មានត្រឹមតែវិចារៈផង ថាមិនមានវិតក្ក ទាំងមិនមានវិចារផងក៏មាន ។ ធាតុ ១៥ មិនមានវិតក្ក ទាំងមិនមានវិចារ មនោធាតុ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ មនោ-វិញ្ញាណធាតុ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ធម្មធាតុ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន មិនគួរពោលថា ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារផង ថាមិនមានវិតក្ក មានត្រឹមតែវិចារផង ថាមិនមានវិតក្ក ទាំងមិនមានវិចារផងក៏មាន ។ សមុទយសច្ច ប្រកប

ដោយវិតក្ក ទាំងប្រកបដោយវិចារ និរោធសច្ច មិនមានវិតក្ក ទាំងមិនមានវិចារ មគ្គសច្ច ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ទុក្ខសច្ច ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន មិនគួរពោលថា ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារផង ថាមិនមានវិតក្ក មានត្រឹមតែវិចារផង ថាមិនមានវិតក្ក ទាំងមិនមានវិចារផងក៏មាន ។ ឥន្ទ្រិយ ៩ មិនមានវិតក្ក ទាំងមិនមានវិចារ ទោមនស្សិន្ទ្រិយ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ឧបេក្ខិន្ទ្រិយ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ឥន្ទ្រិយ ១១ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។ អកុសលហេតុ ៣ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ហេតុ ៦ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។ កពឡិង្ការាហារ មិនមានវិតក្ក ទាំងមិនមានវិចារ អាហារ ៣ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។ ផស្សៈ ៥ មិនមានវិតក្ក ទាំងមិនមានវិចារ មនោធាតុសម្ផស្ស ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ មនោវិញ្ញាណធាតុ-

សម្ផស្ស ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។ វេទនា ៥ សញ្ញា ៥ ចេតនា ៥ ចិត្ត ៥ មិនមានវិតក្ក ទាំងមិនមានវិចារ មនោធាតុ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ មនោវិញ្ញាណធាតុ ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។

[ ៣៥១ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មាន មានរូប ខន្ធប៉ុន្មាន មិនមានរូប ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មាន មានរូប ចិត្តប៉ុន្មាន មិនមានរូប ។ រូបក្ខន្ធ មានរូប ខន្ធ ៤ មិនមានរូប ។ អាយតនៈ ១០ មានរូប មនាយតនៈ មិនមានរូប ធម្មាយតនៈ មានរូបក៏មាន មិនមានរូបក៏មាន ។ ធាតុ ១០ មានរូប ធាតុ ៧ មិនមានរូប ធម្មធាតុ មានរូបក៏មាន មិនមានរូបក៏មាន ។ សច្ចៈ ៣ មិនមានរូប ទុក្ខសច្ច មានរូបក៏មាន មិនមានរូបក៏មាន ។ ឥន្ទ្រិយ ៧ មានរូប ឥន្ទ្រិយ ១៤ មិនមានរូប ជីវិតិន្ទ្រិយ មានរូបក៏មាន មិនមានរូបក៏មាន ។ ហេតុ ៩ មិនមានរូប ។ កពឡិង្ការាហារ មានរូប អាហារ ៣ មិនមានរូប ។ ផស្សៈ ៧ មិនមានរូប ។ វេទនា ៧ សញ្ញា ៧ ចេតនា ៧ ចិត្ត ៧ មិនមានរូប ។

[ ៣៥២ ] បណ្តាខន្ធទាំង ៥ ខន្ធប៉ុន្មាន ជាលោកិយ ខន្ធប៉ុន្មាន ជាលោកុត្តរ ។បេ។ បណ្តាចិត្តទាំង ៧ ចិត្តប៉ុន្មាន ជាលោកិយ ចិត្តប៉ុន្មាន ជាលោកុត្តរ ។ រូបក្ខន្ធ ជាលោកិយ ខន្ធ ៤ ជាលោកិយក៏មាន ជាលោកុត្តរ

ក៏មាន ។ អាយតនៈ ១០ ជាលោកិយ អាយតនៈ ២ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ ធាតុ ១៦ ជាលោកិយ ធាតុ ២ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ សច្ចៈ ២ ជាលោកិយ សច្ចៈ ២ ជាលោកុត្តរ ។ ឥន្ទ្រិយ ១០ ជាលោកិយ ឥន្ទ្រិយ ៣ ជាលោកុត្តរ ឥន្ទ្រិយ ៩ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ អកុសលហេតុ ៣ ជាលោកិយ ហេតុ ៦ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ កពឡិង្ការាហារ ជាលោកិយ អាហារ ៣ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ ផស្សៈ ៦ ជាលោកិយ មនោវិញ្ញាណធាតុសម្ផស្ស ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ វេទនា ៦ សញ្ញា ៦ ចេតនា ៦ ចិត្ត ៦ ជាលោកិយ មនោវិញ្ញាណធាតុ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។

ខន្ធដែលបុគ្គលដឹងច្បាស់ ខន្ធដែលមានអារម្មណ៍ទាំង ២ ខន្ធ
ដែលបុគ្គលឃើញហើយ ខន្ធដែលជាកុសល ខន្ធដែលប្រកប
ដោយវេទនា ខន្ធដែលជាវិបាក ខន្ធដែលមានកម្មប្រកបដោយ
កិលេស មានតណ្ហាជាដើមកាន់យក ខន្ធដែលប្រកបដោយ
វិតក្ក ខន្ធដែលមានរូប ខន្ធដែលជាលោកិយ ។

**ធម្មហទយវិភង្គ ចប់**

**វិភង្គប្បករណៈ ចប់**

# អដ្ឋកថា

## ធម្មហទយវិភង្គ

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបការកំណត់ព្រះបាលី ក្នុងធម្មហទយវិភង្គជាលំដាប់បន្តអំពីខុទ្ទកវិភង្គដូចតទៅ

ក្នុងធម្មហទយវិភង្គនេះ ព្រះមានព្រះភាគត្រាស់ **សព្វសង្គាហិកវារ** គឺវារៈពោលដោយការរួបរួមធម៌ទាំងពួង ដោយអំណាចនៃពួកធម៌ទាំងឡាយ ១២ ពួក មានផ្តើមដោយពួកខន្ធជាដើម ។

វារៈទី ២ ទ្រង់ត្រាស់ **ឧប្បត្តានុប្បត្តិទស្សនវារ** គឺវារៈពោលដោយការសម្តែងការកើតឡើង និងការមិនកើតឡើង ក្នុងកាមធាតុជាដើមនៃធម៌ទាំងឡាយនោះៗឯង ។

វារៈទី ៣ ទ្រង់ត្រាស់ **បរិយាបន្នាបរិយាបន្នទស្សនវារ** គឺវារៈពោលដោយការសម្តែងធម៌ដែលទាក់ទងគ្នា និងមិនទាក់ទងគ្នា ក្នុងកាមធាតុទាំងនោះឯង ។

វារៈទី ៤ ទ្រង់ត្រាស់ **វិជ្ជមានាវិជ្ជមានធម្មទស្សនវារ** គឺវារៈពោលដោយការសម្តែងធម៌ដែលមាន និងមិនមាន ក្នុងខណៈនៃការកើតឡើង ក្នុងភូមិ ៣ ។

វារៈទី ៥ ទ្រង់ត្រាស់ **ទស្សនវារ** គឺវារៈពោលអំពីការសម្តែងធម៌ទាំងនោះ ដោយអំណាចនៃការប្រព្រឹត្តទៅក្នុងរវាងភូមិនៃធម៌ទាំងនោះ ។

វារៈទី ៦ ទ្រង់ត្រាស់ **ឧប្បាទកកម្មអាយុប្បមាណទស្សនវារ** គឺ

វារៈពោលអំពីការសម្ដែងកម្មជាហេតុកើតឡើង និងប្រមាណនៃអាយុក្នុងគតិទាំងឡាយ ។

វារៈទី ៧ ទ្រង់ត្រាស់ **អភិញ្ញេយ្យាទិវារ** គឺវារៈពោលដោយធម៌ដែលគប្បីដឹងក្រៃលែងជាដើម ។

វារៈទី ៨ ទ្រង់ត្រាស់ **សារម្មណានារម្មណវារ** គឺវារៈពោលដោយសារម្មណធម៌ និងអនារម្មណធម៌ជាដើម ។

វារៈទី ៩ ទ្រង់ត្រាស់ **ទស្សនវារ** ព្រោះសង្គ្រោះធម៌ មានខន្ធជាដើមនោះដោយអំណាចនៃទិដ្ឋៈ និងសុតៈជាដើម ។

វារៈទី ១០ ទ្រង់ត្រាស់ **ទស្សនវារ** ព្រោះសង្គ្រោះធម៌ទាំងនោះដោយអំណាចនៃមាតិកា មានកុសលត្តិកៈជាដើម ។

## អធិប្បាយ សព្វសង្គាហិកវារ

[ ៣០៧-៣២០ ] បណ្ឌិតគប្បីជ្រាបអត្ថក្នុងវារៈទី ១ ឈ្មោះថា **សព្វសង្គាហិកវារ** មុនដោយព្រះបាលី ដែលព្រះមានព្រះភាគទ្រង់បានកំណត់ដោយវារៈទាំង ១០ យ៉ាងនេះ គឺព្រះមានព្រះភាគ កាលទ្រង់សម្ដែងកម្លាំងនៃព្រះញាណរបស់ព្រះអង្គថា កាលត្រូវសួរថា តាំងអំពីអវីចីនរក រហូតដល់ភវគ្គព្រហ្ម ក្នុងរវាងនេះ ខន្ធមានប៉ុន្មាន អ្នកដទៃអាចមិនពោលថា ខន្ធមាន ១ ។បេ។ ឬថា ខន្ធមាន ៤ ឬថា ខន្ធមាន ៦ ហើយពោលថា ខន្ធមាន ៥ រមែងមិនមាន ទើបត្រាស់ពាក្យវិសជ្ជនាដែលសមគួរដល់សំណួរថា **បញ្ចក្ខន្ធា** ដូច្នេះ ។ បណ្ឌិតរមែងហៅពាក្យវិសជ្ជនា តាមពាក្យសួរថា

ឈ្មោះ **សព្ពញ្ញុតញ្ញាណ** ដូច្នេះ ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា **ទ្វាទសាយតនានិ** ជាដើម ក៏ន័យនេះឯង ។ បណ្ឌិតគប្បីជ្រាបប្រភេទនៃធម៌ទាំងឡាយ មានរូបក្ខន្ធជាដើម ដោយន័យដែលពោលហើយ ក្នុងខន្ធវិភង្គជាដើម ។

# អធិប្បាយ ឧប្បត្តានុប្បត្តិទស្សនវារ

[ ៣២១-៣២៤ ] ក្នុងវារៈទី ២ ធម៌ពួកណា រមែងកើតឡើងក្នុងកាមភព និងកើតឡើងដល់សត្វទាំងឡាយ ដែលកើតហើយក្នុងកាមធាតុ ជាធម៌ទាំងឡាយដែលទាក់ទងគ្នា ឬមិនទាក់ទងគ្នា ក្នុងកាមធាតុ ព្រះមានព្រះភាគទ្រង់សង្គ្រោះធម៌ទាំងអស់នោះ ហើយត្រាស់ពាក្យថា **កាមធាតុយា បញ្ចក្ខន្ធា** ក្នុងកាមធាតុមានខន្ធ ៥ ជាដើម ។ ក្នុងរូបធាតុជាដើម ក៏មានន័យនេះឯង ។ ព្រោះអាយតនៈទាំងឡាយ មានគន្ធាយតនៈជាដើម រមែងមិនធ្វើកិច្ចនៃអាយតនៈជាដើម ព្រោះការមិនមានឃានាយតនៈជាដើម នៃព្រហ្មទាំងឡាយដែលទាក់ទងក្នុងរូបធាតុ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **រូបធាតុយា ឆ អាយតនានិ នវ ធាតុយោ** ក្នុងរូបធាតុ មានអាយតនៈ ៦ មានធាតុ ៩ ដូច្នេះជាដើម ។ ម្យ៉ាងទៀត ព្រោះឈ្មោះថាធាតុ ដែលមិនទាក់ទងគ្នាដោយអំណាចនៃឱកាស ឬថា ដោយអំណាចនៃការកើតឡើងនៃសត្វ រមែងមិនមានហេតុណា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគមិនត្រាស់ពាក្យថា **អបរិយាបន្នធាតុយា** ធាតុដែលមិនទាក់ទងគ្នា ដូច្នេះ ធាតុណាមួយ ជា

លោកុត្តរ ដើម្បីសម្ដែងធាតុនោះៗ ឯង ទើបត្រាស់ថា **អបរិយាបន្នេ កតិ ខន្ធា** ក្នុងអបរិយាបន្នធម៌ ( លោកុត្តរភូមិ ) មានខន្ធប៉ុន្មានជាដើម ។

## អធិប្បាយ បរិយាបន្នាបរិយាបន្នទស្សនវារ

[ ៣២៥-៣២៨ ] ក្នុងវារៈទី ៣ បទថា **កាមធាតុបរិយាបន្នា** បានដល់ឈ្មោះថា បរិយាបន្ន ព្រោះអត្ថថា ការសេពនូវកាមធាតុ អធិប្បាយថា អាស្រ័យកាមធាតុ នៅខាងក្នុងកាមធាតុនោះ ដល់នូវការរាប់ថាជាកាមធាតុនោះឯង ។ ក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា **បរិយាបន្នា** បានដល់ ដែលកំណត់ដោយអំណាចនៃភព និងដោយអំណាចនៃឱកាស ឬដោយអំណាចនៃការកើតឡើងរបស់សត្វ ។ បទថា **អបរិយាបន្នា** បានដល់ដែលមិនកំណត់យ៉ាងនោះ ។

## អធិប្បាយ វិជ្ជមានាវិជ្ជមានធម្មទស្សនវារ

[ ៣២៩-៣៣០ ] ក្នុងវារៈទី ៤ បទថា **ឯកាទសាយតនានិ** បានដល់អាយតនៈ ១១ វៀរសទ្ទាយតនៈ ។ ពិតហើយ សទ្ទាយតនៈនោះ រមែងមិនកើតឡើង ក្នុងបដិសន្ធិក្ខណៈដោយពិត ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយន័យនេះ ។ ក្នុងពួកទាំង ៧ ព្រះមានព្រះភាគ មិនត្រាស់ដោយអំណាចនៃគតិថា ដល់ទេវតា និងអសុរ តែត្រាស់ថា នៃសត្វដែលដេកក្នុងគភ៌ ព្រោះមិនមានការផ្សេងគ្នា ។ ព្រោះហេតុនោះ គព្ភសេយ្យកសត្វទាំងឡាយរមែងកើតឡើងក្នុងទីណាមួយ អាយតនៈ ៧ របស់គព្ភសេយ្យ-

កសត្វទាំងនោះ គប្បីជ្រាបក្នុងទីនោះៗ ។ ធាតុទាំងឡាយក៏យ៉ាងនោះ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

## អធិប្បាយ ឆដ្ឋវារៈ

[ ៣៣៦-៣៣៧ ] ពាក្យណា ដែលគប្បីពោលក្នុងវារៈទី ៥ ពាក្យនោះ ខ្ញុំពោលហើយ ក្នុងអដ្ឋកថានៃធម្មសង្គហៈនោះឯង ។

## អធិប្បាយ ឧទានកកម្មអាយុប្បមាណាធិដ្ឋានវារៈ

[ ៣៣៨ ] ក្នុងវារៈទី ៦ មានវិគ្គហៈដូចតទៅនេះ ឈ្មោះថា ទេវៈ ព្រោះអត្ថថា ត្រេកអរដោយបញ្ចកាមគុណ ដោយភាពវិសេស ដោយឫទ្ធិ ដែលមានប្រការផ្សេងៗ ។ បទថា **សម្មតិទេវា** បានដល់ ទេវតាដោយសន្មតរបស់មនុស្សលោក យ៉ាងនេះ គឺព្រះរាជា ព្រះទេវី ។ បទថា **ឧបបត្តិទេវា** បានដល់ ជាទេវតាដោយឧបត្តិ ព្រោះកើតឡើងក្នុងទេវលោក ។ បទថា **វិសុទ្ធិទេវា** បានដល់ ជាទេវតាដោយភាពបរិសុទ្ធចាកកិលេសទាំងពួង គួរដល់ការបូជារបស់ទេវតាទាំងអស់ ។ បទថា **រាជានោ** បានដល់ ក្សត្រដែលមុទ្ធាភិសេកហើយ ។ បទថា **ទេវិយោ** បានដល់ ជាមហេសី របស់ព្រះរាជាទាំងនោះ ។ បទថា **កុមារា** បានដល់ ព្រះរាជកុមារដែលកើតឡើងក្នុងឧទររបស់ព្រះទេវីដែលបានអភិសេកហើយ ។

[ ៣៣៩ ] បទថា **ឧបោសថកម្មំ ករិត្វា** បានដល់ រក្សាឧបោសថដែលប្រកបដោយអង្គ ៨ ក្នុងថ្ងៃ ១៤ ជាដើម ឥឡូវនេះ ព្រោះបុញ្ញកម្ម មាន

ការឲ្យទានបន្តិចបន្តួចជាដើម រមែងជាបច្ច័យដល់ភាពជាមនុស្សមានរូបស្អាត គឺបុញ្ញកម្មដែលខ្លួនធ្វើហើយល្មមប្រមាណ រមែងជាបច្ច័យដល់ភាពជាមនុស្សមានរូបស្អាត បើបុញ្ញកម្មដែលខ្លួនធ្វើច្រើនក្រៃលែង ក៏រមែងជាបច្ច័យ ដល់ភាពជាខត្តិយមហាសាលជាដើម មានប្រការផ្សេងៗ ដោយមានប្រភេទច្រើនប្រការក្នុងភាពជាធំ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការផ្សេងគ្នានៃការកើតឡើងដោយអំណាចនៃបុញ្ញកម្មនោះ ទើបត្រាស់បទថា **អប្បេកច្ចេ គហបតិមហាសាលានំ** ជាដើម ។ ក្នុងបទថា **គហបតិ-មហាសាលានំ** នោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ សារៈរបស់គហបតីទាំងនោះ មានច្រើន ព្រោះហេតុនោះ ទើបឈ្មោះថា មហាសារៈ តែលោកពោលថា មហាសាលៈ ព្រោះធ្វើ **រ** អក្ខរៈ ជា **ល** អក្ខរៈ ។ ម្យ៉ាងទៀត គហបតីទាំងឡាយនោះឯងជាមហាសាល ឬថា ភាពមហាសាលទាំងឡាយ មានក្នុងគហបតីទាំងឡាយ ព្រោះហេតុនោះ ទើបគហបតីទាំងនោះឈ្មោះថា គហបតិមហាសាលៈ ។ ក្នុងពាក្យដ៏សេសទាំងឡាយ ក៏ន័យនេះឯង ។

ក្នុងបុគ្គលទាំងនោះ ក្នុងផ្ទះនៃបុគ្គលណា មានទ្រព្យរក្សាយ៉ាងតិច ៤០ កោដិ តែងប្រើប្រាស់កហាបណៈទាំងឡាយចម្អិនអាហារប្រចាំថ្ងៃ មួយថ្ងៃ ៥ អម្ពណៈ បុគ្គលនេះ ឈ្មោះថា គហបតីមហាសាល ។

ក្នុងផ្ទះនៃបុគ្គលណា មានទ្រព្យរក្សាយ៉ាងតិច ៨០ កោដិ ប្រើប្រាស់កហាបណៈទាំងឡាយប្រចាំថ្ងៃ មួយថ្ងៃ ១០ អម្ពណៈ បុគ្គលនេះឈ្មោះថា

ព្រាហ្មណមហាសាលៈ ។

ក្នុងព្រះរាជវាំងរបស់ព្រះរាជាអង្គណា មានទ្រព្យរក្សាក្នុងឃ្លាំង យ៉ាងតិច ១០០ កោដិ ប្រើកហាបណៈទាំងឡាយប្រចាំថ្ងៃ មួយថ្ងៃ ២០ អម្ពណៈ ( នាឡិ ) ព្រះរាជានេះ ឈ្មោះថា ខត្តិយមហាសាលៈ ។

បទថា **សហព្យតំ** បានដល់ ជាបុគ្គលរួមគ្នា គឺជាសម្លាញ់នឹងគ្នា អធិប្បាយថា កើតស្មើគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចាតុម្មហារាជិកានំ** ជាដើម ទេវតាទាំងឡាយ ឈ្មោះថា ចាតុម្មហារាជិកា រមែងមានត្រង់ពាក់កណ្តាលនៃភ្នំឈ្មោះ សិនេរុ ( លើភ្នំយុគន្ធរ ) ទេវតាទាំងនោះ ខ្លះរស់នៅត្រង់ភ្នំ ខ្លះរស់នៅត្រង់អាកាស ។ លំដាប់នៃទេវតាទាំងនោះ មានរហូតដល់ភ្នំកណ្តាប់ចក្កវាឡ ។ ទេវតាទាំងនោះ គឺទេវតាឈ្មោះ ខិឌ្ឌាបទោសិក ទេវតាឈ្មោះ មនោបទោសិក ទេវតាឈ្មោះ សីតវលាហក ( ទេវតាត្រជាក់ ) ទេវតាឈ្មោះឧណ្ហវលាហក ( ទេវតាក្តៅ ) ចន្ទិមទេវបុត្ត សុរិយទេវបុត្ត ទេវតាទាំងអស់នេះ សុទ្ធតែរស់នៅក្នុងជាន់ចាតុម្មហារាជិកានោះឯង ។

ជនទាំងឡាយ ៣៣ នាក់ កើតហើយក្នុងទេវលោកជាន់នោះ ព្រោះហេតុនោះ ទើបទេវលោកនោះ ឈ្មោះថា តាវត្តិង្ស ។ ម្យ៉ាងទៀត លោកពោលថា ពាក្យថា តាវត្តិង្ស ជាឈ្មោះរបស់ទេវតាទាំងនោះឯង ។ ទេវតាទាំងនោះតាំងនៅលើភ្នំ ( សិនេរុ ) ក៏មាន លើអាកាសក៏មាន ។ លំដាប់នៃទេវតាទាំងនោះ មានរហូតដល់ដល់ភ្នំកណ្តាប់ចក្កវាឡ ។ លំដាប់នៃទេវតា

*ជាយាមាជាដើមក៏ដូចគ្នា ។ ពិតហើយ ក្នុងទេវលោកមួយ លំដាប់ ( មួយជាន់ ) របស់ទេវតាទាំងឡាយដែលមិនដល់ភ្នំកណ្តាប់ចក្កវាឡមិនមាន ។*

*ក្នុងទេវតាទាំងនោះ ទេវតាពួកណាមានដំណើរទៅ ប្រព្រឹត្តទៅដល់ព្រមនូវសេចក្តីសុខដែលជាទិព្វ ព្រោះហេតុនោះ ទើបទេវតាទាំងនោះ ឈ្មោះថា* **យាមា** ។

*ទេវតាពួកណា ជាអ្នកត្រេកអរហើយ រីករាយហើយ ព្រោះហេតុនោះ ទើបទេវតាទាំងនោះ ឈ្មោះថា* **តុសិត** ។

*ទេវតាទាំងឡាយណានិម្មិតហើយនូវភោគៈ គឺកាមដែលខ្លួនគាប់ចិត្ត ក្នុងវេលាដែលប្រាថ្នា ដើម្បីត្រេកអរក្រៃលែងជាងអារម្មណ៍ ដែលតាក់តែងតាមប្រក្រតី ព្រោះហេតុនោះ ទើបទេវតាទាំងនោះ ឈ្មោះថា* **និម្មានរតី** ។

*ទេវតាពួកណា ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅក្នុងភោគៈទាំងឡាយ ដែលអ្នកដទៃដឹងវារៈនៃចិត្តហើយនិម្មិតឲ្យ ព្រោះហេតុនោះ ទើបទេវតាទាំងនោះ ឈ្មោះថា* **បរនិម្មិតវសវត្តី** ។

## អធិប្បាយ ប្រមាណនៃអាយុ

*[ ៣៤០ ] បទថា* **អប្បំ វា ភិយ្យោ** *អធិប្បាយថា មានប្រមាណ ១០០ ឆ្នាំ លើស ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ៦០ ឆ្នាំខ្លះ តែមិនដល់ ២០០ ឆ្នាំ ។ ពិតហើយ ពាក្យទាំងអស់នេះ ព្រះមានព្រះភាគត្រាស់ថា* **អប្បំ** *ដូច្នេះ ព្រោះមិនដល់ ២០០ ឆ្នាំ ។*

[ ៣៤១ ] គប្បីជ្រាបវិគ្គហៈ ក្នុងព្រហ្មបារិសជ្ជាជាដើមដូចតទៅនេះ ឈ្មោះថា ព្រហ្មបារិសជ្ជា ព្រោះជាអ្នកចោមរោម គឺជាបរិវារបម្រើមហាព្រហ្ម ។ ឈ្មោះថា ព្រហ្មបុរោហិតា ព្រោះតាំងនៅក្នុងភាពជាបុរោហិតរបស់ព្រហ្មទាំងនោះ ។ ឈ្មោះថា មហាព្រហ្ម ព្រោះជាព្រហ្មធំ ដោយភាពជាអ្នកមានពណ៌សម្បុរល្អ និងភាពជាអ្នកមានអាយុវែង ។ នៃមហាព្រហ្មទាំងនោះ ។ ជនទាំង ៣ នេះ រមែងនៅជាន់តែមួយ ក្នុងបឋមជ្ឈានភូមិ តែអាយុរបស់ព្រហ្មទាំងនោះផ្សេងគ្នា ។

ព្រហ្មឈ្មោះថា **បរិត្តាភា** ព្រោះមានរស្មីតិច ព្រហ្មឈ្មោះថា **អប្បមាណាភា** ព្រោះមានរស្មីប្រមាណមិនបាន ។ ដែលឈ្មោះថា **អាភស្សរា** ព្រោះរស្មីចេញអំពីសរីរៈនៃព្រហ្មទាំងនោះ ហាក់បីដូចអណ្តាតភ្លើងចេញអំពីប្រទីបដែលមានដងផ្សាយទៅ ផ្សាយចេញទៅកាន់ទីផ្សេងៗ ហាក់បីដូចជាដាច់ចេញអំពីខ្លួនទៅ ។ ជនទាំង ៣ នេះ រមែងនៅក្នុងជាន់តែមួយ ក្នុងទុតិយជ្ឈានភូមិ តែកំណត់អាយុនៃព្រហ្មទាំងនោះផ្សេងគ្នា ។

ព្រហ្ម ឈ្មោះថា **បរិត្តសុភា** ព្រោះការស្អាតនៃព្រហ្មទាំងនោះតិច ។ ឈ្មោះថា **អប្បមាណសុភា** ព្រោះការស្អាតនៃព្រហ្មទាំងនោះ មិនមានប្រមាណ ។ ឈ្មោះថា **សុភកិណ្ហា** ព្រោះព្រហ្មទាំងនោះ មានភាពស្អាតដេរដាសទូលំទូលាយ មានរស្មីនៃសរីរៈល្អ មានពណ៌សម្បុរកាយដូចគ្នា មានសិរីដូចដុំមាស រុងរឿងផូរផង់ តាំងនៅក្នុងហិបមាស ដូច្នោះ ។ ជនទាំង ៣ នេះ រមែងនៅក្នុងជាន់តែមួយក្នុងតតិយជ្ឈានភូមិ តែអាយុរបស់

ព្រហ្មទាំងនោះផ្សេងគ្នា ។

បទថា **អារម្មណានានត្តតា** បានដល់ ភាពជាអ្នកមានអារម្មណ៍ផ្សេងគ្នា ។ ក្នុងបទថា **មនសិការនានត្តតា** ជាដើម ក៏ន័យនេះ ។ ក្នុងការផ្សេងគ្នានេះ បុគ្គលម្នាក់មានបឋវីកសិណជាអារម្មណ៍ ។បេ។ បុគ្គលម្នាក់មានឱទាតកសិណជាអារម្មណ៍ នេះឈ្មោះថា មានអារម្មណ៍ផ្សេងគ្នា ។ បុគ្គលម្នាក់មនសិការបឋវីកសិណ ។បេ។ បុគ្គលម្នាក់មនសិការក្នុងឱទាតកសិណ នេះឈ្មោះថា មានមនសិការផ្សេងគ្នា ។ បុគ្គលម្នាក់មានឆន្ទៈក្នុងបឋវីកសិណ ។បេ។ បុគ្គលម្នាក់មានឆន្ទៈក្នុងឱទាតកសិណ នេះឈ្មោះថា មានឆន្ទៈផ្សេងគ្នា ។ បុគ្គលម្នាក់ធ្វើសេចក្តីប្រាថ្នា ក្នុងបឋវីកសិណ ។បេ។ បុគ្គលម្នាក់ធ្វើសេចក្តីប្រាថ្នា ក្នុងឱទាតកសិណ នេះឈ្មោះថា មានបណិធិ ( ការតម្កល់ ) ផ្សេងគ្នា ។ បុគ្គលម្នាក់រមែងបង្អោនចិត្តទៅដោយអំណាចបឋវីកសិណ ។បេ។ បុគ្គលម្នាក់រមែងបង្អោនចិត្តទៅដោយអំណាចឱទាតកសិណ នេះឈ្មោះថា មានអធិមោក្ខ ( ការចុះចិត្ត ) ផ្សេងគ្នា ។ បុគ្គលម្នាក់រមែងបង្អោនចិត្តឆ្ពោះទៅដោយអំណាចបឋវីកសិណ ។បេ។ បុគ្គលម្នាក់រមែងបង្អោនចិត្តឆ្ពោះទៅដោយអំណាចនៃឱទាតកសិណ នេះឈ្មោះថា មានអភិនីហារ ( ការកសាង ) ផ្សេងគ្នា ។ បុគ្គលម្នាក់មានបញ្ញា អាចកំណត់បឋវីកសិណ ។បេ។ បុគ្គលម្នាក់មានបញ្ញា អាចកំណត់ឱទាតកសិណ នេះឈ្មោះថា មានបញ្ញាផ្សេងគ្នា ។

ក្នុងការផ្សេងគ្នានោះ ព្រះមានព្រះភាគ ត្រាស់អារម្មណ៍ និងមនសិការ

ដោយចំណែកខាងដើម ។ ឆន្ទៈ បណិធិ អធិមោក្ខ និងអភិនីហារ រមែងប្រព្រឹត្តទៅក្នុងអប្បនាខ្លះ ក្នុងឧបចារៈខ្លះ ឯបញ្ញា ព្រះមានព្រះភាគត្រាស់ទាំងលោកិយ និងលោកុត្តរលាយឡំគ្នា ។

បទថា **អសញ្ញសត្តានំ** បានដល់ សត្វដែលវៀរចាកសញ្ញា ។ ពិតហើយ សមណព្រាហ្មណ៍ពួកខ្លះ បួសក្នុងលទ្ធិតិរ្ថិយ ឃើញទោសក្នុងចិត្តថា ព្រោះអាស្រ័យចិត្ត ឈ្មោះថា ការត្រេកអរ ការមិនត្រេកអរ និងការវង្វេងមាន ដូច្នេះ ទើបញុំាងសញ្ញាវិរាគៈឲ្យកើត ដោយមនសិការថា ឈ្មោះថាភាពជាបុគ្គលមិនមានចិត្ត ជារបស់ដែលគួរពេញចិត្តនោះ ជាទិដ្ឋធម្មនិព្វានហើយចម្រើនសមាបត្តិដែលចូលដល់សញ្ញាវិរាគៈនោះ ហើយក៏បដិសន្ធិក្នុងភព ដែលមិនមានសញ្ញានោះ ក្នុងខណៈនៃការកើតរបស់អសញ្ញសត្តព្រហ្មទាំងនោះ រូបក្ខន្ធតែម្យ៉ាងប៉ុណ្ណោះ រមែងកើតឡើង ។ ព្រហ្មទាំងនោះ កាលកើតឈរក៏ឈរនោះឯង កាលកើតអង្គុយក៏អង្គុយនោះឯង កាលកើតដេកក៏ដេកនោះឯងដូចគ្នានឹងរូបចម្លាក់ តាំងនៅក្នុងស្ថាននោះអស់ ៥០០ កប្ប ក្នុងទីបំផុតនៃព្រហ្មទាំងនោះ រូបកាយនោះ រមែងអន្តរធានទៅ កាមាវចរសញ្ញារមែងកើតឡើង ដោយហេតុនោះ ទើបទេវតាទាំងនោះប្រាកដថា ឃ្លាតហើយចាកកាយនោះ ព្រោះការកើតឡើងនៃសញ្ញាក្នុងកាមាវចរនេះ ។

ព្រហ្មដែលឈ្មោះថា **វេហប្ផលា** ព្រោះផលនៃជនទាំងនោះបរិបូណ៌ ។ ដែលឈ្មោះថា **អវិហា** ព្រោះមិនវិនាស មិនសូន្យចាកសម្បត្តិរបស់ខ្លួន ។ ដែលឈ្មោះថា **អតប្បា** ព្រោះមិនញុំាងសត្វណាមួយ ឲ្យក្តៅ ។ ដែល

ឈ្មោះថា **សុទស្សា** ព្រោះអត្ថថា មើលល្អ មានរូបស្អាត គួរជ្រះថ្លា ។ ដែលឈ្មោះថា **សុទស្សី** ព្រោះទេវតាទាំងនោះ រមែងឃើញដោយល្អ ឬការឃើញនៃទេវតាទាំងនោះល្អ ។ ដែលឈ្មោះថា **អកនិដ្ឋា** ព្រោះជាអ្នកចម្រើនបំផុត ដោយគុណទាំងអស់នោះឯង និងដោយភវសម្បត្តិ ទេវតាដែលមានគុណធម៌តិចតួច រមែងមិនមានក្នុងទីនេះ ។

បទថា **អាកាសានញ្ចាយតនូបគា** ព្រោះអត្ថថា ចូលដល់អាកាសា-នញ្ចាយតនៈ ។ ក្នុងបទក្រៅអំពីនេះ ក៏មានន័យនេះឯង ។

ភូមិ គឺកាមាវចរ ៦ ព្រហ្មលោក ៩ សុទ្ធាវាស ៥ អរូប ៤ អសញ្ញ-សត្វ ១ និងវេហប្ផលា ១ រួមជាទេវលោក ២៦ ភូមិ និងមនុស្សលោក ១ ទៀត ត្រូវជា ២៧ ភូមិ ដោយប្រការដូច្នេះ ។ បណ្ដាភូមិទាំងឡាយនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់កំណត់អាយុរបស់មនុស្ស និងទេវតា មិនបានកំណត់អាយុសត្វក្នុងអបាយភូមិ ៤ និងក្នុងភុម្មទេវតាទាំងឡាយ សួរថា នោះព្រោះហេតុអ្វី ឆ្លើយថា ក្នុងនរក កម្មប៉ុណ្ណោះជាប្រមាណ គឺកម្មមិនទាន់អស់ទៅដរាបណា ក៏រមែងឆេះក្នុងនរកដរាបនោះ ក្នុងអបាយដ៏សេស ក៏ដូចគ្នា ។ កម្មនោះឯងជាប្រមាណនៃភុម្មទេវតាទាំងឡាយ ។ ពិតហើយ ទេវតាពួកខ្លះកើតហើយក្នុងភូមិនោះ រមែងតាំងនៅត្រឹម ៧ ថ្ងៃ ពួកខ្លះតាំងនៅកន្លះខែក៏មាន ពួកខ្លះតាំងនៅមួយខែក៏មាន សូម្បីតាំងនៅមួយកប្បក៏មាន ។

ក្នុងទេវតា និងមនុស្សទាំងនោះ ក្នុងមនុស្សទាំងឡាយ ចំពោះពួកជនដែលតាំងនៅក្នុងភាពជាគ្រហស្ថ រមែងជាព្រះសោតាបន្នខ្លះ រមែងសម្រេច

ដល់សកទាគាមិផលខ្ខះ អនាគាមិផលខ្ខះ អរហត្តផលខ្ខះ ។ បណ្ដាព្រះអរិយៈទាំងនោះ ព្រះសោតាបន្នជាដើម រមែងតាំងនៅដរាបដល់អស់ជីវិត ចំណែកព្រះខីណាស្រពទាំងឡាយ រមែងបរិនិព្វាន ឬរមែងបួស ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា ធម្មតាអរហត្ត ជាគុណជាតប្រសើរបំផុត តែគ្រហស្ថជាភេទថោកទាប ។ ភេទនៃគ្រហស្ថ មិនអាចទ្រទ្រង់គុណដ៏ឧត្តមនោះបាន ព្រោះជាភេទថោកទាប ព្រោះហេតុនោះ ទើបព្រះខីណាស្រពទាំងនោះ ប្រាថ្នានឹងបរិនិព្វាន ឬដើម្បីនឹងបួស ។

ឯភុម្មទេវតា ទោះបីសម្រេចអរហត្តហើយ រមែងតាំងនៅដរាបដល់អស់ជីវិត ។ ក្នុងកាមាវចរទេវតា ៦ ជាន់ ព្រះសោតាបន្ន និងព្រះសកទាគាមីនោះឯង រមែងតាំងនៅដរាបដល់អស់ជីវិត ព្រះអនាគាមី គួរទៅកាន់រូបភព តែព្រះខីណាស្រពគួរបរិនិព្វាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានឱកាសដើម្បីពួនសម្ងំ ។ ក្នុងរូបាវចរ និងអរូបាវចរភូមិ ព្រះអរិយៈទាំងអស់ រមែងតាំងនៅដរាបដល់អស់ជីវិត ។ បណ្ដាព្រះអរិយបុគ្គលទាំងនោះ ព្រះសោតាបន្ន ព្រះសកទាគាមីដែលកើតក្នុងរូបាវចរនោះ រមែងមិនត្រឡប់មកក្នុងលោកនេះទៀតឡើយ រមែងបរិនិព្វានក្នុងភពនោះឯង ព្រោះថា ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ ឈ្មោះថា ជាអ្នកមិនត្រឡប់មក ព្រោះឈានលាភី ។ សួរថា ការកើតរបស់បុគ្គលដែលបានសមាបត្តិ ៨ អ្វីរមែងកំណត់ ឆ្លើយថា ឈានដែលស្ទាត់ជំនាញហើយ រមែងកំណត់ គឺឈានណានៃបុគ្គលនោះស្ទាត់ជំនាញហើយ បុគ្គលនោះ រមែងកើតឡើង

ដោយឈានដែលស្ទាត់ជំនាញនោះ ។

សួរថា ក្នុងឈានដែលស្ទាត់ជំនាញទាំងអស់ អ្វីរមែងកំណត់ ឆ្លើយថា សេចក្តីប្រាថ្នារមែងកំណត់ បុគ្គលប្រាថ្នាការកើតឡើងក្នុងទីណា រមែងកើតឡើងក្នុងទីនោះឯង ។

សួរថា កាលសេចក្តីប្រាថ្នាមិនមាន អ្វីរមែងកំណត់ ឆ្លើយថា សមាបត្តិដែលបុគ្គលនោះចូលដល់ហើយ ក្នុងសម័យជិតមរណៈ កំណត់ ។

សួរថា សមាបត្តិដែលដល់ព្រមហើយ ក្នុងសម័យជិតមរណៈមិនមាន អ្វីរមែងកំណត់ ឆ្លើយថា នេវសញ្ញានាសញ្ញាយតនសមាបត្តិរមែងកំណត់ ។ ពិតហើយ បុគ្គលនោះរមែងកើតឡើងក្នុងនេវសញ្ញានាសញ្ញាយតនភពដោយចំណែកមួយ ។ ព្រះអរិយសាវកដែលកើតក្នុងព្រហ្មលោក ៩ រមែងកើតឡើងក្នុងភពនោះៗ ឯង រមែងកើតឡើងក្នុងភពខាងលើខ្លះ មិនកើតឡើងក្នុងភពខាងក្រោមឡើយ ។ ចំណែកក្នុងបុថុជ្ជនទាំងឡាយ រមែងកើតក្នុងភពនោះខ្លះ កើតក្នុងភពដែលខ្ពស់ឡើងខ្លះ កើតក្នុងភពខាងក្រោមខ្លះ ។ ព្រះអរិយសាវកក្នុងសុទ្ធាវាស ៥ និងក្នុងអរូបភព ៤ រមែងកើតឡើង ក្នុងភពនោះខ្លះ កើតឡើងក្នុងភពដែលខ្ពស់ឡើងខ្លះ ។ ព្រះអនាគាមីដែលកើតក្នុងបឋមជ្ឈានភូមិ ជម្រះព្រហ្មលោក ៩ ឲ្យបរិសុទ្ធ តាំងនៅក្នុងព្រហ្មលោកខាងលើបំផុតហើយទើបបរិនិព្វាន ។ ទេវលោកទាំង ៣ នេះ គឺវេហប្ផលា ១ អកនិដ្ឋា ១ នេវសញ្ញានាសញ្ញាយតនៈ ១ ឈ្មោះថា ជាភពប្រសើរបំផុត ។ ព្រះអនាគាមីដែលកើតក្នុងភពទាំង ៣ នេះ រមែងមិនទៅកាន់ភពខាងលើ និង

មិនធ្លាក់ចុះមកកាន់ភពខាងក្រោម រមែងបរិនិព្វានក្នុងភពនោះៗ ឯងដូច្នេះ នេះជាបកិណ្ណកៈក្នុងវារៈទី ៦ ។

## អធិប្បាយ អភិញ្ញេយ្យាទិវារ

[ ៣៨២ ] ក្នុងវារៈទី ៧ បណ្ឌិតគប្បីជ្រាបភាពដែលខន្ធជាដើម ជាអភិញ្ញេយ្យធម៌ ដោយអំណាចការដឹងក្រៃលែងដែលកំណត់ខន្ធជាដើម ព្រមទាំងលក្ខណៈ ។ ភាពដែលខន្ធជាដើម ជាបរិញ្ញេយ្យធម៌ គឺធម៌ដែលគួរកំណត់ដឹង គប្បីជ្រាបដោយអំណាចនៃញាតបរិញ្ញា តីរណបរិញ្ញា បហានបរិញ្ញា ។ ភាពដែលខន្ធជាដើម ជាបរិញ្ញេយ្យធម៌នោះ ដោយអំណាចនៃញាតបរិញ្ញា និងតីរណបរិញ្ញាប៉ុណ្ណោះ ក្នុងបទថា **រូបក្ខន្ធោ អភិញ្ញេយ្យោ បរិញ្ញេយ្យោ ន បហាតព្វោ** ជាដើមនោះឯង គប្បីជ្រាបដោយអំណាចនៃបហានបរិញ្ញាក្នុងបទថា **សមុទយសច្ចំ អភិញ្ញេយ្យំ បរិញ្ញេយ្យំ បហាតព្វំ** ជាដើម ។

## អធិប្បាយ សារម្មណានារម្មណាទិវារ

[ ៣៨៣-៣៨៤ ] ក្នុងវារៈទី ៨ បណ្ឌិតគប្បីជ្រាបអនារម្មណៈ គឺការមិនមានអារម្មណ៍ និងអារម្មណៈ គឺការមានអារម្មណ៍ដោយអំណាចនៃចក្ខុវិញ្ញាណជាដើម ដែលមានរូបជាដើម ។

## អធិប្បាយ ទស្សនវារ

[ ៣៨៥ ] ក្នុងវារៈទី ៩ មានអត្ថងាយយល់ហើយ ។

# អធិប្បាយ ធម្មទានវារៈ

[ ៣៤៦-៣៥២ ] ក្នុងវារៈទី ១០ ពាក្យដែលខ្ញុំគប្បីពោល ពាក្យទាំងអស់នោះ ខ្ញុំបានពោលហើយ ក្នុងវារៈដែលពោលអំពីបញ្ហាបុច្ឆកៈ ក្នុងទីនោះៗ ឯង ។

## អដ្ឋកថា ធម្មហទយវិភង្គ
## ឈ្មោះសម្មោហវិនោទនី ចប់
## ដោយប្រការដូច្នេះ

# និគមគាថា

*ដោយពាក្យមានប្រមាណប៉ុណ្ណេះ*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ជាអ្នកគោរពនូវធម៌ ទ្រង់មានពួកទេវតារាប់ពាន់ចោមរោមហើយ ទ្រង់សម្តែងព្រះអភិធម្មដល់ទេវតាទាំងឡាយ ដែលគោរពធម៌ក្នុងទេវនគរ ។*

*ទ្រង់ជានាថមួយអង្គ មិនមានបុរសជាគម្រប់ពីរ ទ្រង់មានព្រះគុណបរិសុទ្ធត្រាស់វិភង្គប្បករណ៍ ដែលជាបករណ៍ទី ២ ដែលប្រដាប់ដោយវិភង្គ ១៨ ឯណា ដើម្បីប្រកាសអត្ថនៃបករណ៍នោះ ខ្ញុំ ដែលភិក្ខុឈ្មោះថា* **ពុទ្ធឃោស** *មានគុណតាំងមាំ មានគតិមិនយឺតយូរ មានការដឹងល្អ អារាធនាហើយ ទើបផ្តើមរចនាអដ្ឋកថា ក្នុងអត្ថដ៏ល្អិតល្អន់ដោយល្អ ឈ្មោះសម្មោហវិនោទនីព្រោះបន្ទោបង់នូវសេចក្តីវង្វេង សម្មោហវិនោទនីនេះ រួមយកសារៈនៃអដ្ឋកថារបស់អាចារ្យបុរាណ ឥឡូវនេះ បករណ៍នេះចប់ហើយ ដោយព្រះបាលី ៤១ ភាណវារ ដោយប្រាសចាកអន្តរាយហើយ យ៉ាងណា សូមមនោរថទាំងពួង របស់សព្វសត្វទាំងឡាយ ប្រាសចាកមន្ទិល ដល់នូវការសម្រេចយ៉ាងនោះចុះ ។ បុណ្យណា ដែលខ្ញុំរចនាបករណ៍វិសេសនេះ ដើម្បីការតាំងមាំនៃព្រះសទ្ធម្មឲ្យសម្រេចហើយ ដោយអានុភាពនៃបុណ្យនោះ សូមសត្វលោក ព្រមទាំងទេវលោក ដល់នូវសេចក្តីស្ងប់ ។ សូមព្រះសទ្ធម្មតាំងនៅអស់កាលយូរ សូមសត្វលោកត្រេកអរក្រៃលែង ក្នុងព្រះសទ្ធម្ម សូមចម្រើនសព្វកាល សូមជនបទទាំងឡាយ ដល់ព្រមដោយសេចក្តីសុខ មានសេចក្តីក្សេមសម្រាន្ត មានកិច្ចការកបានងាយជាដើម អស់កាលជានិច្ច ។*

អដ្ឋកថាវិភង្គប្បករណ៍ ឈ្មោះថា សម្មោហវិនោទនីនេះ ដែលព្រះថេរៈត្រូវបានគ្រូទាំងឡាយ ហៅថា **ពុទ្ធឃោស** ជាអ្នកប្រដាប់ដោយសទ្ធា ពុទ្ធិ វិរិយៈ បរិសុទ្ធក្រៃលែង ជាអ្នកញុំាងហេតុនៃគុណ មានសីល អាចារ អាជ្ជវៈ គឺភាពទៀងត្រង់ មទ្ទវៈ គឺការទន់ភ្លន់ជាដើមឲ្យតាំងឡើងហើយ ជាអ្នកអាចក្នុងការកាប់ឆ្ការព្រៃស្តុក គឺបទវិនិច្ឆ័យដែលលំបាក ក្នុងលទ្ធិរបស់ខ្លួន និងរបស់អ្នកដទៃ ដែលប្រកបដោយភាពមុតស្រួចនៃបញ្ញា ដែលមានកម្លាំងនៃញាណ ដែលមិនទើសទាក់ក្នុងសត្ថុសាសនៈ មានបរិយត្តិ គឺព្រះត្រៃបិដក មួយអន្លើដោយអដ្ឋកថា ដែលជាមហាវេយ្យាករណ៍ ជាអ្នកប្រកបដោយលម្អនៃពាក្យសម្តីដ៏វិចិត្រផង ជាអ្នកបន្លឺចេញបានស្ទាត់ជំនាញ ដែលកើតអំពីករណសម្បត្តិផង ជាអ្នកពោលដ៏កំពូល ដោយពោលបានទាំងការចង និងការស្រាយ ជាមហាកវី ជាអលង្ការនៃថេរវង្ស ក្នុងមហាវិហារ ជាប្រទីបនៃថេរវង្ស មានការតាំងមាំដោយល្អក្នុងឧត្តរិមនុស្សធម្ម ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ ជាដើម បែកធ្លាយក្នុងបដិសម្ភិទាជាបរិវារ ជាអ្នកមានសេចក្តីបរិសុទ្ធបរិបូណ៌ ជាអ្នករចនា ។

*សូមបករណ៍ឈ្មោះសម្មោហវិនោទនីនេះ ដែលសម្ដែងន័យ*

*ដើម្បីសម្ដែងសេចក្ដីបរិសុទ្ធនៃបញ្ញា ដល់កុលបុត្តទាំងឡាយ*

*ដែលស្វែងរកធម៌ជាគ្រឿងរលាស់ខ្លួនចេញចាកលោក រហូត*

*តាំងនៅក្នុងលោក ដរាបដែលនាមថា* **ពុទ្ធោ** *របស់អង្គព្រះ*

*លោកជេដ្ឋមហាឥសី ដែលទ្រង់មានព្រះហឫទ័យបរិសុទ្ធ ជា*

*តាទិបុគ្គល នៅប្រព្រឹត្តទៅក្នុងលោកហោង ។*

*ស្ដេចភ្នំតាំងនៅដរាបណា ព្រះចន្ទនៅភ្លឺដរាបណា សូមព្រះសទ្ធម្មរបស់*

*ព្រះគោតម ទ្រង់មានយសធំ តាំងនៅដរាបនោះហោង ។ល។*

**អដ្ឋកថាព្រះអភិធម្ម**

**ឈ្មោះសម្មោហវិនោទនី ចប់**

# ក្បាលទី ៦៩

# អភិធម្មបិដក បាលីប្រែ -៨២

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ

អភិធម្មបិដក សិក្ខាបទវិភង្គ ( អភិធម្មភាជនីយ ) .......... .......... ...... ២

អដ្ឋកថា អភិធម្មភាជនីយ .......... .......... .......... ១៥

អភិធម្មបិដក សិក្ខាបទវិភង្គ បញ្ហាបុច្ឆកៈ .......... .......... .......... ២៦

អដ្ឋកថា បញ្ហាបុច្ឆកៈ .......... .......... .......... ២៩

### បដិសម្ភិទាវិភង្គ

អភិធម្មបិដក ( សុត្តន្តភាជនីយ ) .......... .......... .......... ៣០

អដ្ឋកថា សុត្តន្តភាជនីយ .......... .......... .......... ៣៣

អធិប្បាយ សច្ចវារជាដើម .......... .......... .......... ៤២

អភិធម្មបិដក អភិធម្មភាជនីយ .......... .......... .......... ៤៤

អដ្ឋកថា អភិធម្មភាជនីយ .......... .......... ......... ៦១

អភិធម្មបិដក បញ្ហាបុច្ឆកៈ .......... .......... .......... ៦៧

អដ្ឋកថា បញ្ហាបុច្ឆកៈ .......... .......... .......... ៧៣

### ញាណវិភង្គ

អភិធម្មបិដក ញាណវិភង្គ .......... .......... ......... ៧៧

អដ្ឋកថា ញាណវិភង្គ ឯកកមាតិកាជាដើម .......... .......... .......... ៩៣

កម្លាំងកាយរបស់ព្រះតថាគត .......... .......... .......... ៩៦

អត្ថរបស់ ចក្ក សព្ទ .......... .......... ......... ១០០

អភិធម្មបិដក ឯកកនិទ្ទេស .......... .......... .......... ១០៩

អដ្ឋកថា ឯកកនិទ្ទេស .......... .......... .......... ១១៥

ហេតុនៃការយល់សប្តិ ៤ យ៉ាង .......... .......... .......... ១២៤

អភិធម្មបិដក ទុកនិទ្ទេស .......... .......... .......... ១៣០

អដ្ឋកថា ទុកនិទ្ទេស .......... .......... .......... ១៣៥

អភិធម្មបិដក តិកនិទ្ទេស .......... .......... .......... ១៣៨

អដ្ឋកថា តិកនិទ្ទេស .......... .......... .......... ១៤៦

អភិធម្មបិដក ចតុក្កនិទ្ទេស .......... .......... .......... ១៥៨

អដ្ឋកថា ចតុក្កនិទ្ទេស .......... .......... .......... ១៧០

អភិធម្មបិដក បញ្ចកនិទ្ទេស .......... .......... .......... ១៨២

អដ្ឋកថា បញ្ចកនិទ្ទេស .......... .......... .......... ១៨៣

អភិធម្មបិដក ឆក្កនិទ្ទេស .......... .......... .......... ១៨៧

អដ្ឋកថា ឆក្កនិទ្ទេស .......... .......... .......... ១៨៨

អភិធម្មបិដក សត្តកនិទ្ទេស .......... .......... .......... ១៩០

អដ្ឋកថា សត្តកនិទ្ទេស .......... .......... .......... ១៩២

អភិធម្មបិដក អដ្ឋកនិទ្ទេស .......... .......... .......... ១៩៤

អដ្ឋកថា អដ្ឋកនិទ្ទេស .......... .......... .......... ១៩៥

អភិធម្មបិដក នវកនិទ្ទេស .......... .......... .......... ១៩៦

អដ្ឋកថា នវកនិទ្ទេស .......... .......... .......... ១៩៧

អភិធម្មបិដក ទសកនិទ្ទេស .......... .......... .......... ១៩៨

អដ្ឋកថា ទសកនិទ្ទេស អធិប្បាយកម្លាំង ១០.......... .......... .......... ២១៦

រឿងព្រះបាទទីបរាជ .......... .......... .......... ២៥៨

រឿងព្រះមហាសោណត្ថេរ .......... .......... .......... ២៦២

រឿងវត្តពូកនិគ្រោធ .......... .......... ............ ២៧០

រឿងព្រះបាទកូដកណ្ណរាជ .......... .......... ............ ២៧៥

## ខុទ្ទកវត្ថុវិភង្គ

អភិធម្មបិដក ខុទ្ទកវត្ថុវិភង្គ .......... .......... ............ ៣០៥
អដ្ឋកថា ខុទ្ទកវត្ថុវិភង្គ ( ឯកកមាតិកាជាដើម ) .......... .......... ........... ៤១៥
អដ្ឋកថា ឯកកនិទ្ទេសជាដើម .......... .......... ............ ៤១៦
អដ្ឋកថា តណ្ហាវិចរិតនិទ្ទេស .......... .......... ............ ៥២៩
អដ្ឋកថា ទិដ្ឋិគតនិទ្ទេស .......... .......... .......... ៥៣៦

## ធម្មហទយវិភង្គ

អភិធម្មបិដក ធម្មហទយវិភង្គ .......... .......... ............ ៥៣៧
អដ្ឋកថា ធម្មហទយវិភង្គ .......... .......... ............ ៥៩២
អធិប្បាយ សព្វសង្គាហិកវារ .......... .......... ............ ៥៩៣
អធិប្បាយ ឧប្បត្តានុប្បត្តិទស្សនវារ .......... .......... ............ ៥៩៤
អធិប្បាយ បរិយាបន្នាបរិយាបន្នទស្សនវារ .......... .......... ............ ៥៩៥
អធិប្បាយ វិជ្ជមានាវិជ្ជមានធម្មទស្សនវារ .......... .......... ............ ៥៩៥
អធិប្បាយ ទស្សនវារ .......... .......... ............ ៥៩៦
អធិប្បាយ ឧបាទកកម្មអាយុប្បមាណទស្សនវារ .......... .......... .......... ៥៩៦
អធិប្បាយ ប្រមាណនៃអាយុ .......... .......... ............ ៥៩៩
អធិប្បាយ អភិញ្ញេយ្យាទិវារ .......... .......... ............ ៦០៦
អធិប្បាយ សារម្មណានារម្មណាទិវារ .......... .......... ............ ៦០៦
អធិប្បាយ ទស្សនវារ .......... .......... ............ ៦០៦
អធិប្បាយ ទស្សនវារ .......... .......... ............ ៦០៧